តើអ្នកណាជាអ្នកបង្កើតមនុស្សសត្វផ្សេងៗ?
តើអ្នកបង្កើតពិតជាព្រះអាទិទេព ជាព្រហ្ម ឬក៏ជាកម្ម?
តើយើងអាចកំណត់ផលកម្ម និងវាសនារបស់យើងបានឬទេ?

# កម្ម
# អ្នកសាងលោកពិត

**បណ្ឌិត ម៉ែម ទីន មន**
សាស្ត្រាចារ្យៈមហាសទ្ធម្មជោតិកធជ

សៀវភៅដ៏អស្ចារ្យនេះនឹងលាតត្រដាងនូវធម្មជាតិ
ពិតនៃជីវិតរបស់អ្នក និងហេតុផលនានាថា តើហេតុ
អ្វីបានជាអ្នកជាមនុស្សដូច្នេះ នៅពេលបច្ចុប្បន្ននេះ?

បណ្ឌិត ម៉ែម ទីន មន

កម្ម អ្នកសាងលោកពិត

សាស្ត្រាចារ្យៈមហាសទ្ធម្មជោតិកធជ

**បោះពុម្ពលើកទី ១**
ចំនួន ៦០០០ ក្បាល
ខ្នាត A 5
ខែ ឧសភា ឆ្នាំ ២០១៥
រោងពុម្ព ម៉េងហាវ ភ្នំពេញ
សម្រាប់ចែកជាធម្មទាន

ISBN-13: 978-99924-9018-0-8

តើអ្នកណាជាអ្នកបង្កើតមនុស្សសត្វផ្សេងៗ ?
តើអ្នកបង្កើតពិតជាព្រះអាទិទេព ជាព្រហ្ម ឬក៏ជាកម្ម ?
តើយើងអាចកំណត់ផលកម្ម និងវាសនារបស់យើងបានឬទេ ?

# កម្ម
# អ្នកសាងលោកពិត

**បណ្ឌិត ម៉ែម ទីន មន**
សាស្ត្រាចារ្យៈមហាសទ្ធម្មជោតិកធជ

សៀវភៅដ៏អស្ចារ្យនេះនឹងលាតត្រដាងនូវធម្មជាតិ
ពិតនៃជីវិតរបស់អ្នក និងហេតុផលនានាថា តើហេតុ
អ្វីបានជាអ្នកជាមនុស្សដូច្នេះ នៅពេលបច្ចុប្បន្ននេះ ?



- តើអ្នកណាជាអ្នកបង្កើតមនុស្ស និងសព្វសត្វ ?
- តើអ្នកណាជាអ្នកកំណត់ផលកម្ម និងវាសនារបស់សព្វសត្វ ?
- តើអ្នកបង្កើតពិតជាព្រះអាទិទេព ជាព្រហ្ម ឬក៏ជាកម្ម ?
- តើបាតុភូតអធិធម្មជាតិ អាចមានក្នុងធម្មជាតិដែរឬទេ ?
- តើយើងអាចកំណត់ផលកម្ម និងវាសនារបស់យើងបានឬទេ ?

## កម្ម
## អ្នកសាងលោកពិត

**បណ្ឌិត ម៉ែម ទីន មន**
សាស្ត្រាចារ្យៈមហាសទ្ធម្មជោតិកធជ

ចូរយកសម្មាទិដ្ឋិជាពន្លឺ ដើម្បីដឹកនាំអ្នក
ទៅរកសេចក្តីចម្រើន និងសុភមង្គល។

ឈ្មោះសៀវភៅ **កម្ម អ្នកសាងលោកពិត**
រៀបរៀងដោយ បណ្ឌិត ម៉ែម ទីន មន ជនជាតិភូមា
បកប្រែពីភាសាអង់គ្លេស
មកភាសាខ្មែរដោយ ភិក្ខុ សឿង វុទ្ធី ពីខាងដើមដល់ជំពូកទី៧
សាមណេរ សុខ ធារី ពីជំពូកទី៨រហូតដល់ចប់
សហការី ភិក្ខុ សង្ឃពោធី ពូ តុងហាវ
ភិក្ខុ នាគបណ្ឌិតោ សោម វិជ្ជា ហៅ រស្មី
ភិក្ខុ កោសល្យមុនី ហ៊ុន ចាន់ដែន
ពិនិត្យ និងកែសម្រួលដោយ ភិក្ខុ សង្ឃពោធី ពូ តុងហាវ
ភិក្ខុ នាគបណ្ឌិតោ សោម វិជ្ជា ហៅ រស្មី
ភិក្ខុ កោសល្យមុនី ហ៊ុន ចាន់ដែន
ឯកសារ សៀវភៅ Kamma, The Real Creator by
Dr. Mem Tin Mon
ការផ្សាយរបស់ ទីស្នាក់ការវិបស្សនាអន្តរជាតិកម្ពុជា កុដិលេខ១៣
វត្តឧណ្ណាលោម ក្រុងភ្នំពេញ
ចេញផ្សាយ ព.ស. ២៥៥៨
គ.ស. ២០១៤
បោះពុម្ពចំនួន ៦០០០ក្បាល

សម្រាប់ធម្មទាន



Buddha Sāsanaṁ ciraṁ tiṭṭhatu

Religious Publication Permission No. ( 3204260607 )
Cover Design Permission No. ( 3205 180807 )

**Publication** 2007, October
First Printing, 1000 Copies

**Publisher** Mehm Tay Zar Mon
Yadanar Min Literature ( 3455 )
15/19, U Wisara Housing Estate
Dagon Township, Yangon.

**Printer** U Tin Maung Win
( Cover+contents ) Thin Lai Win Press( 05946 )
No.1, Bo Yar Nyunt Street,
Yaw Min Gyi Quarter,
Dagon Township, Yangon.

**Distribution** Mya Mon Yadanar Literature
15/19, U Wisara Housing Estate
Dagon Township, Yangon.
Tel: 9-51-385261

# មាតិកា


❖ បុព្វបទ

១. តើអ្វីសំខាន់បំផុតនៅក្នុងជីវិត? ..... 1

២. បញ្ហាជីវិតសំខាន់ៗមួយចំនួន ..... 2

៣. តើនរណាអាចឆ្លើយបញ្ហាជីវិតទាំងនេះបាន? ..... 5

៤. ចិត្តវិភាគ ..... 7

៥. ចិត្ត និង កម្ម ..... 10

៦. ច្បាប់កម្មដែលមានអំណាចខ្លាំងអស្ចារ្យ ..... 14

៧. យើងអាចរៀបចំផលកម្ម
និងវាសនារបស់យើងដូចដែលយើងចូលចិត្ត ..... 17

**១ តើភពមានន័យដូចម្តេច?** ..... 22

១. តើភពជាអ្វី? ..... 22

២. ភពផ្សេងៗគ្នា ..... 26

៣. តើនរណាបង្កើតសព្វសត្វផ្សេងៗគ្នា ..... 29

៤. ការរកឃើញផ្នែកវិទ្យាសាស្ត្រ ..... 33

៥. ទារកក្នុងបំពង់សាក ..... 38

៦. ការបង្កាត់មនុស្ស ..... 41

**២ ល្បងប្រាជ្ញាជីវិត ដ៏ស៊ីជម្រៅ និងល្អិតសុខុម** ..... 48

១. តើជីវិតអាចកើតចេញពីរូបបានដែរឬទេ? ..... 48

២. ទ្រឹស្តីពន្ធុ ..... 49







៣.អតីតភព និង អនាគតភព ..... 52

**៣ ភស្តុតាងសម្រាប់អតីតជាតិ** ..... 55

១. បុគ្គលដែលចាំអតីតជាតិ ..... 56

២. ទេពកោសល្យផ្សេងៗរបស់ក្មេងមានពាសពេញសកលលោក ..... 62

៣.ការចាំអតីតជាតិ ដោយអេតឌីគ្រេហ្សឹន(អាយុក្ខ័យ)ការបង្វិល
ថយក្រោយទៅរកអតីតកាល តាមរយៈវិធីសណ្តំ ..... 64

អេដហ្គ័រ ខាយី មនុស្សមានអភិនីហារ ..... 67

បំណកស្រាយពីជីវិតដែលច្បាស់ជាងតារាងនៃតារាសាស្ត្រ ..... 71

ការនីទូរលេខម្នាក់ ..... 73

៤. ការដឹងអតីតជាតិតាមរយៈអភិញ្ញា ..... 74

ការសម្តែងបង្ហាញពីអតីតជាតិរបស់ព្រះសម្មាសម្ពុទ្ធ ..... 77

៥. ការដឹងអតីតជាតិ តាមវិបស្សនាកម្មដ្ឋាន ..... 82

**៤ ភ័ស្តុតាងសម្រាប់អនាគតភព** ..... **87**

១. ភ័ស្តុតាងតាមគម្ពីរពុទ្ធសាសនា ..... 88

២. ការពិនិត្យសង្កេតរបស់ព្រះមហាមោគ្គលាន ..... 97

៣.ការទំនាក់ទំនងជាមួយបុគ្គលស្លាប់
តាមរយៈការដឹងដោយឥទ្ធិវិធី ..... 100

អ្នកស្រី ឡេអូ នីវ៉ា ភីព័រ ក្អែកពណ៌ស និងឧបការី ..... 104

អ៊ីស្តែល រ៉ូប៊ឺត និងទេវតាពពកក្រហម ..... 107

សារសម្ងាត់រវាងគូស្នេហ៍មួយគូ ..... 113

នៅតែមានការចងចាំពីពិភពអមនុស្ស ..... 114

ការទំនាក់ទំនងរវាងសាធារណជន និង
ញាតិរបស់គេដែលស្លាប់ទៅ ..................................117
៤.ការទាក់ទងដោយផ្ទាល់ជាមួយបុគ្គលស្លាប់ទៅ....................121
គូស្នេហ៍មកពិភពផ្សេងគ្នាអាចនៅជាមួយគ្នាបាន................. 125
សារផ្ដាំផ្ញើពីពិភពអមនុស្ស ........................................ 130
៥. ការដឹងអនាគតភពដោយទិព្វចក្ខុនិងអភិញ្ញាផ្សេងៗ.............131
**៥ តើនរណាជាអ្នកសាងលោកពិត** ................................ 140
១. ភ្នាក់ងារដែលមានអំណាចបំផុត .................................. 140
២. ទស្សនៈរបស់ចិត្តវិទូ...................................................141
៣. តើចិត្តជាខួរក្បាលឬ?...................................................142
អភិធម្មពន្យល់ពីដំណើរប្រព្រឹត្តទៅរបស់នាម .........................148
៤. តើនរណាជាអ្នកង្កើតលោកពិត?........................................154
**៦ កម្មជាអ្វី**.............................................................**161**
១. តើអ្វីជាកម្ម? ...........................................................161
២. តើកម្មកើតឡើងដោយរបៀបណា?.....................................164
តើកម្មកើតចេញពីចិត្តដោយរបៀបណា? ..............................171
៣. ការប្រៀបធៀបរឿងស្ដេចដំរីឆទន្ត ..................................173
៤. កម្មពីរយ៉ាង សហជាតកម្ម និងនានក្ខណិកកម្ម.................181
៥. ទ្វារកម្ម៣យ៉ាង ........................................................184
៦. អកុសលកម្មបថ១០ ....................................................185
ល័ក្ខខ័ណ្ឌសម្រាប់បំពេញនូវកម្ម........................................187





៧. កុសលកម្មបថ១០........................................................ 192
៨. បុញ្ញកិរិយាវត្ថុ១០ ..................................................... 195
៩.តើកម្មស្ថិតនៅកន្លែងណា? ............................................ 197
១០.តើកម្មតាក់តែងភពថ្មីឱ្យកើតឡើងដោយរបៀបណា?.........200
**៧ តើកម្មឱ្យផលតាមរបៀបណា?**..................................**207**
១. ទម្លាប់នៃការសម្លឹងមើលកម្មដែលឱ្យផលភ្លាមៗ .................207
២. លទ្ធផល២យ៉ាងនៅក្នុងអំពើទាំងអស់..............................210
៣. របៀបនានក្ខណិកកម្មឱ្យផល...........................................215
របៀបកម្មឱ្យផលដូចនឹងទង្វើរបស់កម្មនោះ ....................... 216
៤. កម្មឱ្យផលរាប់ពាន់លានដង.......................................... 221
តើការសម្លាប់សត្វមានទោសដែរឬទេ?............................223
ស្រីមានរូបឆោមស្រស់ស្អាតនៅក្រុងវេសាលី .....................227
ដើម្បីរុងរឿងគ្រប់ៗជាតិបន្តបន្ទាប់..................................230
៥. ហេតុអ្វីបានជាមនុស្សខុសៗគ្នាពីម្នាក់ទៅម្នាក់ទៀត.............233
៦. នាម និងរូបកើតពីកម្ម...................................................240
**៨ ប្រភេទកម្មផ្សេងគ្នា**...............................................**244**
១. ថ្នាក់កម្ម៤យ៉ាងដែលកម្មនីមួយៗមាន៤ប្រភេទ.................244
២. កម្ម៤យ៉ាង ចែកតាមមុខងារ..........................................246
១)ជនកកម្ម - កម្មដែលបង្កើត .......................................246
២)ឧបត្ថម្ភកកម្ម - កម្មដែលឧបត្ថម្ភ...................................247
៣)ឧបបីលកកម្ម - កម្មដែលរារាំង ...................................248

៤)ឧបឃាតកកម្ម - កម្មបំផ្លិចបំផ្លាញ.............................. 251
ការប្រព្រឹត្តទៅនៃកម្មទាំង៤យ៉ាងចំពោះភិក្ខុទេវទត្ត ......... 253
៣. កម្ម៤ប្រភេទតាមលំដាប់នៃអាទិកម្ម................................ 254
១)គរុកកម្ម - កម្មដែលមានទម្ងន់ធ្ងន់.............................. 254
២)អាសន្នកម្ម - កម្មជិតពេលស្លាប់ ................................ 257
កម្មដ៏ចម្លែកនៃស្ត្រីឈរកាន់ក្អមទឹក............................ 259
តើកូនប្រុសអាចជួយឪពុកឱ្យទៅកើតសុគតិភព
ដោយរបៀបណា.................................................. 264
៣)អាចិណ្ណកម្ម - កម្មជាទម្លាប់..................................... 266
៤)កដត្តាកម្ម - កម្មមិនជាក់លាក់.................................. 269
សេចក្តីប្រៀបធៀបនៃហ្វូងគោ .................................. 270
កើតក្នុងអវិចីនរក ថ្វីត្បិតតែមានកម្មល្អច្រើន................. 273
៤. កម្ម៤ប្រភេទយោងតាមពេលវេលានៃការឱ្យផល ................ 275
១)ទិដ្ឋធម្មវេទនីយកម្ម - កម្មដែលឱ្យផលភ្លាមៗ ............... 276
ផលរបស់កម្ម មិនអាចចៀសវាងបានឡើយ ................ 279
អ្នកសប្បុរស ត្រូវបានរង្វាន់ក្នុងជាតិនេះឯង.....................281
២)ឧបបជ្ជវេទនីយកម្ម - កម្មដែលឱ្យផលបន្តបន្ទាប់ ........... 283
៣)អបរាបរិយវេទនីយកម្ម - កម្មដែលឱ្យផលមិនជាក់លាក់ .. 286
កម្មឱ្យផលជះត្រឡប់មកខ្លួនអ្នកធ្វើវិញ ........................291
កម្មឱ្យផលមិនកំណត់ ប្រៀបដូចស្រមោល
អន្ទោលតាមប្រាណ ............................................... 295







៤)អហោសិកម្ម - កម្មដែលតាមឱ្យផលមិនទាន់ ................. 296
៥. កម្ម៤យ៉ាងដែលទាក់ទងនឹងទីកន្លែងឱ្យផលកើតឡើង ......... 298
១)អកុសលកម្ម - កម្មអាក្រក់.......................................... 298
២)កាមាវចរកុសលកម្ម - កុសលកម្មជាកាមាវចរៈ .............. 298
៣)រូបាវចរកុសលកម្ម - កុសលកម្មជារូបាវចរៈ................. 299
៤)អរូបាវចរកុសលកម្ម - កុសលកម្មជាអរូបាវចរៈ............... 299
**៩ ចិត្ត ជាអ្នកសាងលោកពិត................................... 301**
១. ចិត្តជាអាទិទេពពិត ........................................................ 301
លោកិយអភិញ្ញាដ៏អស្ចារ្យ..............................................302
២. លក្ខណៈសម្បត្តិដែលគួរឱ្យភ្ញាក់ផ្អើលនៃឫទ្ធានុភាព .............303
ធ្វើរបស់នៅឆ្ងាយឱ្យមកជិត របស់ធំឱ្យក្លាយជាតូច .............306
ធ្វើរបស់ច្រើនឱ្យជាតិច របស់តិចឱ្យជាច្រើន .......................308
ធ្វើភាពងងឹតឱ្យភ្លឺ និងរបស់មើលមិនឃើញឱ្យឃើញបាន ......309
អំណាចកើតឡើងដោយចិត្តតាមរយៈកម្ម......................... 314
៣. របៀបដែលអកុសលកម្មឱ្យផល........................................ 315
៤. កុសលមូល២យ៉ាងនិងកុសលមូល៣យ៉ាង......................... 317
៥. ហីនកម្ម និងបណីតកម្ម ................................................ 318
មហាកុសលកម្មបានផលតិច..........................................320
៦. មនុស្ស៣ពួក ...............................................................322
៧. ភាពផ្សេងគ្នារបស់រូបព្រហ្ម...........................................325
៨. អរូបព្រហ្មដែលមានតែចិត្ត .......................................... 331

**១០ មរណៈ និង បដិសន្ធិ** ............ 336
១.តើអ្វីដែលទ្រទ្រង់ជីវិតឱ្យរស់នៅបាន? ............ 336
២. ហេតុអ្វីសត្វត្រូវស្លាប់? ............ 338
៣. តើមាននិមិត្តដូចម្តេចខ្លះមុនពេលស្លាប់? ............ 340
  និមិត្ត៣ប្រភេទពេលជិតស្លាប់ ............ 341
  និមិត្តនៅពេលជិតស្លាប់អាចផ្លាស់ប្តូរ ............ 343
  ទេវរថហោះមក មុនពេលស្លាប់ ............ 345
៤. តើភពថ្មីកើតឡើងបន្ទាប់ពីសេចក្តីស្លាប់ដូចម្តេច? ............ 348
៥.តើបុគ្គលក្នុងភពថ្មីដូចគ្នានឹងបុគ្គលក្នុងភពបច្ចុប្បន្នដែរឬទេ? ............ 353
៦. ភ័ស្តុតាងដែលអាចបញ្ជាក់ពីវិថីចិត្តតែមួយ ............ 355
  ការកើតឡើងនូវទិព្វចក្ខុ និងអភិញ្ញាដទៃទៀត ............ 359
  ការពិចារណាក្នុងបដិច្ចសមុប្បាទធម៌ ............ 360
  ភ័ស្តុតាងអំពីការចម្លងរបស់ចិត្ត និងចេតសិកនៅក្នុងវិថីចិត្ត ............ 364
**១១ សិទ្ធិ ដើម្បីបង្កើតផលកម្ម និងវាសនារបស់ខ្លួនឯងដោយសេរី** ............ 368
១. សេរីភាព និងច្បាប់កម្ម ............ 368
២. មិច្ឆាទិដ្ឋិ៣យ៉ាង ............ 371
៣. បុគ្គលគប្បីទីពឹងលើខ្លួនឯង ............ 373
៤. មាគ៌ាឆ្ពោះទៅរកជោគជ័យ និងរុងរឿង ............ 378
៥. គ្រួសារមួយជួបសេចក្តីវិនាសដោយសារខ្វះបញ្ញានិងវិរិយៈ ............ 384
៦. អ្នកមានដល់កំពូលដោយកម្មល្អបច្ចុប្បន្ន បញ្ញានិងវិរិយៈ ............ 388





៧. ឱកាសសម្រាប់កម្មល្អនិង កម្មអាក្រក់ឱ្យផល ............ 396
៨. អ្នកនឹងវេទនា ប្រសិនបើអ្នកសេពគប់នឹងមនុស្សពាល ............ 401
៩.បុគ្គលសេពគប់ជាមួយបុគ្គលមានកម្មល្អ រមែងបានចម្រើនរុងរឿង ............ 409
**១២ ច្បាប់កម្មដែលមានសភាពស៊ីជម្រៅនិងល្អិតសុខុម** ............ 411
១. លក្ខណៈរបស់នាមដែលមានសភាពស៊ីជម្រៅ និងល្អិតសុខុម ............ 411
២. នារទជាតក អធិប្បាយពីកម្មចម្លែកឱ្យផល ............ 415
  ការចាំជាតិខ្លួនឯងមួយជាតិ មិនអាចយល់ពីច្បាប់កម្មផលបានឡើយ ............ 421
  អំពើបាបកាន់តែរីកដុះដាលបើមានមិច្ឆាទិដ្ឋិ ............ 425
  ព្រះនាងរុស្សាទ្រទ្រង់ពន្យល់ធម៌ដល់ព្រះបិតា ............ 426
  នារទព្រហ្មសម្តែងធម្មទេសនា ............ 435
  ការបង្ហាញឋាននរក និងឋានសួគ៌ ............ 439
  សេចក្តីប្រៀបធៀបនូវយានដែលបំពេញនូវបំណងប្រាថ្នាគ្រប់យ៉ាង ............ 444
៣. ហេតុអ្វីអ្នកធ្វើបាបកាន់តែមាន ឯអ្នកធ្វើល្អបែរជាក្រីក្រទៅវិញ ............ 447
  អំពើអាក្រក់នឹងមិនឱ្យផលល្អ ............ 452
៤. ធ្វើជាអ្នកមាន និងរុងរឿងគ្រប់ៗជាតិ ............ 456
  កម្មល្អតែងតែមានអំណាចខ្លាំងជាងកម្មអាក្រក់ ............ 459
  ចូរញ៉ាំង កម្ម បញ្ញា និង វិរិយៈ ឱ្យមានតុល្យភាព ............ 461

៥. ចូរយើងនាំគ្នាហែលឆ្លងសង្សារវដ្តរួមគ្នា
រហូតដល់ត្រើយសុវត្ថិភាព ............................................ 466

# បុព្វបទ

## ១. តើអ្វីសំខាន់បំផុតនៅក្នុងជីវិត?

ព្រះពុទ្ធវចនៈគឺមានលក្ខណៈអស្ចារ្យណាស់។ យើងសូមសម្តែងនូវការដឹងគុណយ៉ាងស្មោះស្ម័គ្របំផុតចំពោះព្រះពុទ្ធ ដែលបានសម្តែងនូវសច្ចធម៌ក្នុងធម្មជាតិ ដែលពួកអ្នកទស្សនវិទូ ចិត្តវិទ្យា និង អ្នកវិទ្យាសាស្ត្រមិនបានដឹង។

ប្រការដែលសំខាន់បំផុតនៅក្នុងជីវិតគឺចិត្ត។ គឺចិត្តនេះឯង ដែលគ្រប់គ្រងនូវលោកទាំងមូល។ ចិត្តគ្រប់គ្រង គំនិត វាចា និងអំពើរបស់យើងទាំងអស់។ ដូចនេះហើយ ចិត្តជាអ្នកគ្រប់គ្រងលោកទាំងមូល។

*ប្រសិនបើយើងអាចគ្រប់គ្រងរបស់ម្យ៉ាងបាន នោះគឺចិត្តរបស់យើង, យើងនឹងបានរីករាយនូវសេចក្តីសុខរបស់មនុស្ស សេចក្តីសុខទិព្វ និងសេចក្តីសុខដ៏ឧត្តមនៃព្រះនិព្វាន។*

អ្នកចិត្តវិទ្យាទាំងឡាយ ក៏បានទទួលស្គាល់ថា ចិត្តមានឥទ្ធិពលមិនមានកំណត់ ហើយចិត្តនេះឯង អាចបំពេញអ្វីមួយក៏បាន។ យើងអាចមើលឃើញនូវភាពរីកចម្រើនយ៉ាងឆាប់រហ័សអស្ចារ្យក្នុងវិទ្យាសាស្ត្រ និង បច្ចេកវិទ្យាថា ឥទ្ធិពលរបស់ចិត្តបង្កើត





នូវវត្ថុដ៏អស្ចារ្យគ្មានដែនកំណត់។ តាមពិតអាកាសគឺមានដែនកំណត់! ប៉ុន្តែ អ្នកចិត្តវិទ្យាពុំបានយល់នូវអ្វីដែលហៅថាចិត្តពិតប្រាកដឡើយ។

ពួកអ្នកវិទ្យាសាស្ត្រ អាចពិនិត្យសង្កេតបានតែកាយធាតុភូត ដែលពាក់ព័ន្ធ រូប និងឋាមពល ហើយផ្អែកលើកាយសាស្ត្រ ពួកគេបានរកឃើញ, ពួកគេកំពុងបង្កើត និងផលិតនូវម៉ាស៊ីនអស្ចារ្យ និងរបស់របរប្រណីតៗជាច្រើន។ គេបានបញ្ជូនយានអាវកាសជាច្រើនទៅសិក្សាពីភពនានា ហើយបានបង្កើតស្ថានីយ៍យានអាវកាសសម្រាប់ធ្វើការស្រាវជ្រាវនៅទីនោះ។ ប៉ុន្តែ ពួកគេពុំទាន់បានសិក្សាពីចិត្តនៅឡើយ ហើយរហូតដល់បច្ចុប្បន្ននេះ ពួកគេមិនទាន់អាចបង្កើតឧបករណ៍ ដើម្បីសង្កេតមើលចិត្តបានទេ។ ដូច្នេះ ពួកអ្នកវិទ្យាសាស្ត្រអាចនាំមកបានភាពលូតលាស់ផ្នែកសម្ភារៈ ប៉ុន្តែមិនមែនភាពលូតលាស់ខាងផ្លូវចិត្តឡើយ។

មានតែព្រះសម្មាសម្ពុទ្ធទេ ទើបដឹងនូវចិត្តបានយ៉ាងច្បាស់គ្រប់ទិដ្ឋភាពទាំងអស់។

## ២. បញ្ហាជីវិតសំខាន់ៗមួយចំនួន

ហេតុអ្វីបានជាយើងរងទុក្ខតាមផ្លូវចិត្ត? ហេតុអ្វីបានជាគេ

កំពុងព្រួយបារម្ភអំពីរឿងរ៉ាវជាច្រើន? ហេតុអ្វីបានជាសោកសៅ និងទួញយំជារឿយៗ? ហេតុអ្វីបានជាគេខកចិត្ត និងបាក់ទឹកចិត្តជារឿយៗ? ហេតុអ្វីបានជាពួកគេខឹងត្រូវបានភ័ន្តច្រឡំ និងធ្វើអាក្រក់? ហេតុអ្វីបានគេទទួលរងភាពតានតឹងតាមផ្លូវចិត្ត ជម្ងឺផ្លូវចិត្ត និងជម្ងឺសួពូជ ពុទ្ធិវិបល្លាស និង ជម្ងឺរាងកាយ? ហេតុអ្វីបានជាមនុស្សព្យាយាមបោកប្រាស់ ធ្វើទារុណកម្ម និងសម្លាប់មនុស្សយ៉ាងនេះ? ហេតុអ្វីបានជាគេធ្វើសង្គ្រាមបណ្តាលឱ្យមានការស្លាប់យ៉ាងច្រើនដូច្នេះ ហេតុអ្វីបានជាពិភពលោកគ្មានសន្តិភាព? ហេតុអ្វីបានជាគេចូលចិត្តកាមគុណ និងប្រព្រឹត្តការសប្បាយខាងផ្លូវកាមច្រើនម្ល៉េះ? តើក្នុងកាមគុណមានខ្លឹមសារអ្វីឬទេ? តើយើងអាចដឹងថា មានសេចក្តីទុក្ខក្នុងឋានអបាយ នៅពីក្រោយកាមគុណដែរឬទេ?

តើយើងមានអតីតភព មុនបច្ចុប្បន្នភពនេះឬ? នៅពេលយើងស្លាប់ តើយើងនឹងកើតទៀតឬ? តើនរណាជាអ្នកបង្កើតភពផ្សេងៗគ្នា? ហេតុអ្វីបានជាមនុស្សខុសគ្នាក្នុងទ្រព្យ សុខភាព រូបរាង បញ្ញា សំណាង និងវាសនាដូច្នេះ? តើមានព្រះអាទិទេពដែលមានអំណាចគ្រប់គ្រងសំណាង និងវាសនារបស់មនុស្សមែនឬ? តើយើងមិនអាចមានសិទ្ធិសាងសំណាង និងវាសនា





របស់យើងតាមដែលយើងចូលចិត្តទេឬ? តើប្រការអ្វីសំខាន់បំផុតដែលត្រូវធ្វើក្នុងជីវិតពេលបច្ចុប្បន្ន? តើយើងគួរធ្វើអ្វីដើម្បីបានភាពរុងរឿង និងសេចក្តីសុខពីជីវិតមួយទៅជីវិតមួយទៀត? ទាំងនេះ គឺជាបញ្ហាសំខាន់មួយចំនួននៅក្នុងជីវិត។

ឡេអូ តូលស្តយ (Leo Tolstoy),១៨២៨-១៩១០, ជាអ្នកនិពន្ធ និងជាទស្សនវិទូខាងសាសនា សញ្ជាតិរុស្ស៊ី ដ៏ល្បីល្បាញ ដែលបានទទួលពានរង្វាន់ណូបែល ជាមួយរឿងប្រលោមលោក ដ៏អស្ចារ្យរបស់លោក មានចំណងជើងថា " សង្គ្រាម និង សន្តិភាព " ដែលត្រូវបានចាត់ទុកថាជារឿងប្រលោមលោកដ៏អស្ចារ្យ ដែលមិនធ្លាប់មានគេនិពន្ធ, លោកបានសញ្ជឹងគិតលើបញ្ហាមួយចំនួនដូចជា៖ " តើជីវិតបច្ចុប្បន្នរបស់អាត្មាអញកើតឡើងយ៉ាងដូចម្តេច? ហេតុអ្វីបានជាអាត្មាអញរស់នៅ? តើអាត្មាអញនឹងកើតឡើងម្តងទៀតបន្ទាប់ពីស្លាប់ឬ? តើអាត្មាអញនឹងកើតក្នុងភពដូចម្តេច? សំណួរទាំងនេះគឺពិតជាសំខាន់ណាស់។ នៅខណៈពេលដែលខ្ញុំមិនអាចឆ្លើយចំពោះសំណួរទាំងនេះបាន ខ្ញុំមានអារម្មណ៍ថា កន្លែងដែលខ្ញុំឈរនៅហាក់ដូចជាក្រឡាប់ចក្រ "។

ទស្សនវិទូកំពូលៗជាច្រើនបានពិចារណា អំពីបញ្ហាដ៏

ស៊ីជម្រៅ និង ល្អិតសុខុមទាំងនេះ។ ប៉ុន្តែពួកគេមិនអាចផ្តល់ចម្លើយសមហេតុផលបានឡើយ។

**៣. តើនរណាអាចឆ្លើយបញ្ហាជីវិតទាំងនេះបាន?**

ព្រះសម្មាសម្ពុទ្ធ ជាបុគ្គលត្រាស់ដឹងនូវអ្វីៗគ្រប់យ៉ាង។ ព្រះអង្គទ្រង់បានផ្តល់ចម្លើយមានហេតុផលគួរពេញចិត្ត ចំពោះបញ្ហាទាំងអស់នេះតាំងពីសម័យ តាឡេស (Thales), ៦២៤-៥៥០. មុនគ.ស ជាទស្សនវិទូក្រិចសម័យបុរាណ ដែលត្រូវបានចាត់ទុកថាជាបិតានៃទស្សនវិទូលោកខាងលិច។ តើព្រះអង្គបានផ្តល់ចម្លើយនៅកន្លែងណា?

ព្រះសម្មាសម្ពុទ្ធ ទ្រង់បានផ្តល់ចម្លើយពេញលេញ ចំពោះបញ្ហាពិភពលោកទាំងអស់ក្នុងឋានតាវតិង្ស។ ក្នុងមហាសករាជ ១១០(៥៧៨ ឆ្នាំមុនគ.ស) នៅពេលដែលព្រះអង្គទ្រង់បានសម្តែងនូវអភិធម្ម។ ព្រះអង្គទ្រង់បានប្រទានជំបូន្មានដល់ព្រះសារីបុត្រ អគ្គសាវ័កស្តាំរបស់ព្រះអង្គ ដែលជាអ្នកមានបញ្ញាឆ្នើមបំផុតស្តីអំពីព្រះអភិធម្ម ដើម្បីឱ្យអ្នកក្រោយអាចពន្យល់អភិធម្ម នៅក្នុងឋានមនុស្សលោកជំណាលគ្នាបាន។ អភិធម្មដែលបានសម្តែងក្នុងឋានមនុស្សលោកបានក្លាយទៅជា អភិធម្មបិដក។ ប្រសិនបើ បុគ្គលអាចសិក្សា និងយល់បានយ៉ាងហ្មត់ចត់





សូម្បីតែសេចក្តីសង្ខេបនៃព្រះអភិធម្មឈ្មោះថា " **អភិធម្មត្ថសង្គហៈ** " គឺថាជាខ្លឹមសារនៃអភិធម្មរបស់ព្រះសម្មាសម្ពុទ្ធ, បុគ្គលនោះឯងនឹងបានដឹងនូវចម្លើយពិតចំពោះបញ្ហាជីវិតទាំងអស់។

ហេតុអ្វីបានជាព្រះសម្មាសម្ពុទ្ធ អាចផ្តល់ចម្លើយសមហេតុផល?ហេតុផល គឺថា ព្រះអង្គអាចយល់យ៉ាងច្បាស់នូវគោលការណ៍ធម្មជាតិទាំងអស់ដែលគ្រប់គ្រងសកលលោក និងបរមត្ថធម៌គឺ ចិត្ត ចេតសិក និង រូប ដែលបង្កើតបានជា **នាម** និង **រូប ។** ព្រះអង្គអាចយល់បានយ៉ាងច្បាស់ជាក់ស្តែង និងច្បាស់លាស់នូវបាតុភូតផ្លូវចិត្តទាំងអស់ ដែលជាលទ្ធផលនៃអន្តរកម្មរវាង **នាមបរមត្ថ** និង **រូបបរមត្ថ** ក្នុងអតីត បច្ចុប្បន្ន និងអនាគត ។ លុះត្រាណាតែ បុគ្គលអាចយល់ចាក់ធ្លុះល្អិតល្អន់នូវវិស័យដ៏ទូលាយនៃចក្ខុវិស័យផ្នែកបាតុភូតផ្លូវចិត្ត ទាក់ទងនឹងអំឡុងពេលទាំង ៣ ទើបបុគ្គលអាចដោះស្រាយនូវបញ្ហាជីវិតដ៏ស៊ីជម្រៅ និងល្អិតសុខុមបាន។ ព្រះសម្មាសម្ពុទ្ធ មិនមែនត្រឹមតែផ្តល់គោលការណ៍ជាទ្រឹស្តីប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបង្ហាត់បង្រៀនឱ្យអនុវត្តអស់រយៈពេល៤៥ វស្សា ដែលនឹងនាំទៅរកការរំលត់ទុក្ខទាំងពួង និងការត្រាស់ដឹងក្នុងជីវិតនេះ នៅក្នុងឯកបរមសុខពោលគឺព្រះនិព្វាន ដែលជាសេចក្តីសុខស្ងប់ យ៉ាងក្រៃលែង។

*"មាគ៌ាតែមួយគត់ ដែលនាំទៅដល់ការសម្រេចនូវភាពបរិសុទ្ធ កំចាត់បង់នូវសេចក្ដីសោកសង្រេង បំបាត់នូវទុក្ខព្រួយ, ចូលទៅកាន់ផ្លូវត្រូវ និងការធ្វើឱ្យជាក់ច្បាស់នូវព្រះនិព្វានគឺអរិយមគ្គអង្គ៨ ឬត្រៃសិក្ខាទាំង៣ គឺ **សីល សមាធិ** និង**បញ្ញា**"។*

*(មហាសតិបដ្ឋានសូត្រ)*

### ៤. ចិត្តវិភាគ

ព្រះសម្មាសម្ពុទ្ធ ទ្រង់បានបង្រៀនពីរបៀបចម្រើនសមាធិចិត្ត និងពីរបៀបកំណត់ដឹងនូវចិត្ត ដែលជាសភាវមានឥទ្ធិពល និងពិបាកមើលឃើញបំផុត។ ព្រះអង្គក៏ទ្រង់បានផ្ដល់វិធីសាស្ត្រពីរបៀបវិភាគចិត្តទៅចេតសិករបស់វា។ ចិត្ត មិនមែនជាអង្គទោលឡើយ ប៉ុន្តែជាការផ្សំនៃចិត្តដែលជាអ្នកដឹងនូវអារម្មណ៍ និងចេតសិកជាច្រើនទៀត ដែលអាស្រ័យលើចិត្ត សម្រាប់ការកើតឡើង ហើយមានឥទ្ធិពលលើចិត្តតាមរបៀបជាច្រើន។

ក្នុងចំណោមចេតសិកទាំង៥២ដួង មានចេតសិកចំនួន ១៤ ឱ្យឈ្មោះថា អកុសលចេតសិក ។ ហើយក្នុងចំណោមអកុសលចេតសិកទាំងនេះទៀត មានកិលេស១០យ៉ាងដែលធ្វើ





ឱ្យសៅហ្មង ធ្វើឱ្យអាប់ឱន ញាំញី និងដុតនូវចិត្ត។ ពួកកិលេសទាំងនេះ រ៉ាប់រងចំពោះសេចក្ដីទុក្ខផ្លូវចិត្តទាំងអស់ និង អំពើអកុសលទាំងពួងនៅក្នុងលោក។ មេក្លោងទាំង៣នៃអកុសលចេតសិក គឺ លោភៈ ទោសៈ មោហៈ។

**លោភៈ** ចំណង់ សេចក្ដីប្រាថ្នា ឬ**ឧបាទាន**, វាក៏មានឈ្មោះថា **តណ្ហា** ក្នុងន័យនៃ " **ឧបាទាន** " និង " **រាគ** " ក្នុងន័យនៃពាក្យថា " **អាសវៈ** " និង " **កិលេស** "។

**ទោសៈ** ភាពគ្រោតគ្រាតនៃចិត្ត ឬភាពទ្រគោះបោះបោក សេចក្ដីក្រោធ ព្យាបាទ ការប្រទូស្តតប វាជាធាតុបំផ្លាញ ដ៏សាហាវបំផុត។

**មោហៈ** ការមិនដឹងនូវធម្មជាតិពិតនៃអារម្មណ៍ លក្ខណៈនៃសច្ចធម៌ និងលក្ខណៈរបស់កម្ម, វាក៏មានឈ្មោះថា "**អវិជ្ជា**" ក្នុងន័យនៃពាក្យថា "ងងឹត ឬអន្ធការ" ។

ចេតសិកទាំង៣នេះជាអកុសលមូល ឬសគល់នៃអំពើអកុសលទាំងពួង។ អកុសលកម្មមួយជាកម្មមានទោស ព្រោះវាបណ្ដាលឱ្យមានអន្តរាយដល់សត្វមានជីវិត និងនាំមកនូវផល

អាក្រក់។ ព្រោះអកុសលមូលទាំង៣នេះ មានឥទ្ធិពលលើចិត្ត មនុស្ស ពួកគេធ្វើអំពើមិនត្រឹមត្រូវ អំពើហិង្សា អំពើអាក្រក់ និង អំពើអកុសលផ្សេងៗ ដោយសារអកុសលមូលទាំង៣នេះឯង។ អកុសលមូលទាំងនេះ ធ្វើចិត្តឱ្យសៅហ្មង និងល្អក់កករ វាជាភ្លើង ក្តៅបំផុតក្នុងលោក។ ប្រសិនបើបុគ្គលណាមួយអាចគាស់រំលើង ឫសគល់ និងបំផ្លាញកិលេសទាំងអស់នេះបានហើយ បុគ្គលនោះ ឯងអាចពាល់ត្រូវឯកបរមសុខពោលគឺព្រះនិព្វានភ្លាម។

សោភណចេតសិក២៥ ដែលមានឥទ្ធិពលលើចិត្ត ហើយ ដឹកនាំចិត្តឱ្យធ្វើអំពើល្អ។ ពួកវាមានចំនួនច្រើន និងមានអំណាច ខ្លាំងជាងអកុសលចេតសិក។ បើគេចម្រើននូវសោភណចេតសិក ព្រមគ្នា ធ្វើឱ្យមានកម្លាំងខ្លាំង,វាអាចសង្កត់សង្កិន និងកំចាត់បង់ នូវអកុសលកិលេស បាន។

កុសលមូលទាំង៣ ដែលផ្ទុយនឹង អកុសលមូលទាំង ៣នោះគឺ អលោភៈ អទោសៈ និង អមោហៈ (បញ្ញា)។

**អលោភៈ:** មិនមានតណ្ហា មិនមាន ឧបាទាន ជា សប្បុរសធម៌

**អទោសៈ:** ភាពស្រទន់ ឬភាពទន់ភ្លន់ គ្មានសេចក្តី ក្រោធ បំណងល្អ ការសន្តោសប្រណី



កម្ម អ្នកសាងលោកពិត

ខន្តី និង មេត្តា។

**អមោហៈ:** បញ្ញា ចាក់ធ្លុះទៅក្នុងលក្ខណៈពិត នៃ អារម្មណ៍លក្ខណៈពិតនៃសច្ចធម៌ និង លក្ខណៈរបស់កម្ម, គេក៏ឱ្យឈ្មោះវាថា "**វិជ្ជា**"ក្នុងន័យនៃ "**បញ្ញា**" ។

ចេតសិក ទាំង៣យ៉ាងនេះ មានលក្ខណៈថ្លាស្អាត និង ប្រសើរណាស់។ វាតំណាងឱ្យគុណសម្បត្តិប្រសើរបំផុតរបស់ មនុស្ស។ យើងអាចចម្រើនវាបានដោយការឱ្យទាន រក្សាសីល និង ដោយការចម្រើនភាវនា។

**៥. ចិត្ត និង កម្ម**

ចិត្តដែលសម្បយុត្តជាមួយអកុសលមូលហៅថា " **អកុសលចិត្ត**"។ អកុសលចិត្តជាចិត្ត ដែលមានទោសហើយឱ្យផលអាក្រក់។

ចិត្តដែលសម្បយុត្តជាមួយកុសលមូលហៅថា " **កុសលចិត្ត**"។ កុសលចិត្តជាចិត្ត ដែលគ្មានទុក្ខទោស និងឱ្យផលល្អ ។

យោងទៅតាម **ចិត្តនិយាម** (ច្បាប់ចិត្ត) ចិត្តកើតឡើង បន្តបន្ទាប់គ្នាក្នុងល្បឿនយ៉ាងលឿនរាប់ពាន់លានដង ក្នុងមួយ ព្រិចភ្នែក ឬក្នុងមួយផ្ទាត់នៃម្រាមដៃដែលយើងធ្វើ។ ដូច្នេះ អំឡុងពេលដែលអកុសលកម្ម ដូចជាការសម្លាប់ត្រី ឬលួច

ទ្រព្យរបស់អ្នកដទៃ អកុសលចិត្តកើតឡើង និងរលត់ទៅវិញ រាប់ពាន់លានដង។

ដូចគ្នានេះដែរ ក្នុងអំឡុងពេល កុសលកម្មត្រូវបានធ្វើឡើង ដូចជាការថ្វាយបង្គំព្រះពុទ្ធរូប ឬប្រគេនចង្ហាន់ដល់ព្រះសង្ឃ កុសលចិត្តក៏កើតឡើង និងរលត់ទៅវិញរាប់ពាន់លានដងដែរ។

នៅពេល **ចិត្ត** និង**ចេតសិក**របស់វារលត់ វាបញ្ជូនថាមពលផ្ទាល់របស់វាទៅកាន់ចិត្តដែលកើតឡើងបន្ទាប់ទៀត មុនពេលវារលត់។ នៅខណៈពេលដែលថាមពលទាំងអស់ ដូចជាចំណេះដឹងដែលយើងបានរៀនសូត្រ និងបានកំណត់ចំណាំទុកមក អារម្មណ៍ដែលយើងបានសោយ។ល។ វាចេះតែប្រព្រឹត្តទៅពីចិត្តមួយទៅចិត្តមួយទៀតមិនចេះចប់ តាមពិតទៅវាស្ថិតនៅក្នុងក្រសែចិត្តនោះឯង។ ដូច្នេះ យើងអាចរំលឹកឃើញ ឬ នៅចងចាំអ្វីដែលយើងបានរៀន និងអ្វីដែលយើងបានទទួលបទពិសោធន៍តាំងពីវ័យកុមារ។ ព្រោះយើងអាចចងចាំនូវពាក្យដែលយើងរៀន យើងអាចនិយាយទៅកាន់គ្នាទៅវិញទៅមក។

ថាមពល ដែលសំខាន់ គឺជាថាមពលនៃចេតសិកឈ្មោះថា " **ចេតនា** " ឬ "បំណង"។ ចេតនា សម្បយុត្តជាមួយ





ចិត្តគ្រប់ប្រភេទ។ ចេតនា សម្បយុត្តជាមួយអកុសលមូលក្លាយជាអកុសលចេតនា។ ចេតនាដែលសម្បយុត្តជាមួយកុសលមូលទៅជាកុសលចេតនា។

នៅពេលដែលគេធ្វើអកុសលកម្ម ឬកុសលកម្ម ចេតនាធ្វើការប៉ុនប៉ងដើម្បីធ្វើកម្ម និងធ្វើកិច្ចការប្រកបដោយញាណសម្បយុត្តរបស់វា(ចិត្ត និងចេតសិក)សម្រាប់កិច្ចរៀងៗខ្លួនដើម្បីបំពេញនូវកម្មនោះ។ ឧទាហរណ៍ ក្នុងការសម្លាប់សត្វមូសមួយ ចេតនាជាអ្នកកំណត់នូវទង្វើដើម្បីសម្លាប់ នឹងបណ្តាលឡើងដោយ ចិត្ត និង ចេតសិក ដែលសម្បយុត្តជាមួយចេតនានោះ ដើម្បីធ្វើកិច្ចរៀងៗខ្លួនចំពោះការសម្លាប់សត្វមូសនោះ ដូច្នេះការបំពេញនូវកម្មនៃការសម្លាប់មូសនោះក៏បានសម្រេច។ ដោយសារតែ ចេតនា ជាអ្នកទទួលខុសត្រូវខាងការបំពេញនូវកម្ម ទើបព្រះសម្ពុទ្ធឱ្យឈ្មោះ ចេតនា ថាជា **កម្ម** ដូច្នេះ កម្មគឺជាអំពើប្រកបដោយ**ចេតនា**។

ឧទាហណ៍ក្នុងការសម្លាប់សត្វមាន់មួយ ចិត្តដែលមានឫសគល់ចេញពី**ទោសៈ** កើតឡើងរាប់ពាន់លានដង។ ចេតនាដែលសម្បយុត្តជាមួយ អកុសលចិត្តច្រើនរាប់ពាន់លានដងនោះឱ្យឈ្មោះថា សហជាតអកុសលកម្ម។ "**សហជាតកម្ម**" មាន

ន័យថា កម្ម ឬអំពើកើតព្រមគឺថា ចេតនាកើតឡើងព្រមជាមួយនឹងចិត្ត។ ចេតនាទាំងនោះឯងជាអ្នកធ្វើនូវ**កម្ម**។

នៅពេល អកុសលចិត្ត និងចេតនាច្រើនរាប់ពាន់លានដងរលត់ ចេតនានោះបានបន្សល់ទុកនូវថាមពល ឬទ្រព្យនៃកម្មរបស់វាក្នុងក្រសែចិត្ត។ ថាមពលនៃកម្មច្រើនរាប់ពាន់លានទាំងនេះស្តុកនៅក្នុងក្រសែចិត្តឱ្យឈ្មោះថា" **នានក្ខណិកអកុសលកម្ម**"។ នានក្ខណិកកម្ម មានន័យថា កម្មដែលកើតឡើងផ្សេងគ្នាគឺថាពេលដែលកម្មត្រូវបានគេធ្វើហើយ និងពេលវាឱ្យផលគឺវាផ្សេងគ្នា។ វាដូចជាពូជនៃរុក្ខជាតិមួយ។ វាអាចបង្កើតឡើងជាភពថ្មីមួយ។

ដូច្នេះ ក្នុងអំឡុងពេលដែលអកុសលកម្មមួយ ត្រូវបានធ្វើឡើង អកុសលកម្មរាប់ពាន់លានដង បានផ្ទុកនៅក្នុងក្រសែចិត្តនោះ ហើយនៅក្នុងអំឡុងពេលមួយ ដែលកុសលកម្មត្រូវបានគេធ្វើ អកុសលកម្ម ច្រើនរាប់លានដងត្រូវបានស្តុកនៅក្នុងក្រសែចិត្តនោះដែរ។

អកុសលកម្ម ផ្តល់នូវផលអាក្រក់ ចាប់ពីបច្ចុប្បន្នភពនេះទៅ និងក្នុងអនាគតភពនៅពេលដែលវាមានឱកាសឱ្យផល។ ដូច្នេះ ការសម្លាប់សត្វមាន់មួយ បុគ្គលអាចរងទុក្ខក្នុងនរកអស់





រយៈពេលយូរ ហើយបន្ទាប់មក បុគ្គលនោះអាចកើតជាសត្វតិរច្ឆាន ហើយត្រូវគេសម្លាប់ដូចគ្នាជាច្រើនដង ដូចដែលគាត់បានសម្លាប់សត្វមាន់ដូច្នោះដែរ។

កុសលកម្មឱ្យផលល្អចាប់ពីបច្ចុប្បន្នជាតិ និងគ្រប់ៗអនាគតជាតិ នៅពេលវាមានឱកាសឱ្យផល។ កុសលកម្ម ដ៏មានកម្លាំងមានសក្តានុពល បង្កើតបានជាភពមនុស្ស ឬភពទេវតា។ ដូច្នេះ កុសលកម្មច្រើនរាប់ពាន់លានដង ដែលផ្ទុកនៅក្នុងក្រសែចិត្ត ក្នុងខណៈពេលដែលស្ត្រីម្នាក់ថ្វាយបង្គំដោយគោរពចំពោះព្រះពុទ្ធ និងតាក់តែងឱ្យមានកំណើតសុខស្រួលកើតឡើងច្រើនដង ។

ដោយសារ អកុសលកម្ម ឬកុសលកម្ម ឱ្យផលអាក្រក់ ឬផលល្អរាប់ពាន់លានដង ដូច្នេះហើយ ទើប **អកុសលកម្ម ជាកម្មគួរឱ្យភ័យខ្លាច ចំណែកឯ កុសលកម្មជាកម្មគួរមានទំនុកចិត្ត ។**

### ៦. ច្បាប់កម្មដែលមានអំណាចខ្លាំងអស្ចារ្យ

**កម្ម**គឺជាកម្លាំងរបស់ចិត្ត ដែលមានថាមពលបំផុតនៅក្នុងលោក។កុសលចិត្ត កើតបានជាកុសលកម្ម, ចំណែកអកុសលចិត្ត បង្កើតបានជាអកុសលកម្ម។ កម្ម នេះ គឺជាកម្មដែលត្រូវបានបញ្ជូនពីចិត្តមួយទៅចិត្តមួយ ដូច្នេះហើយ ថាមពលនៃកម្មនេះឯង គឺស្ថិតនៅក្នុងក្រសែចិត្តនោះ។ ក្នុងពេលសេចក្តីស្លាប់ជិត

មកដល់ កម្មជាច្រើនលានដែលនៅក្នុងក្រសែចិត្តប្រកួតប្រជែងគ្នាដើម្បីមានឱកាសតាក់តែងនូវការកើតឡើងនៃភពថ្មី បន្ទាប់ទៀត។ ក្នុងពេលនៃសេចក្តីស្លាប់ កម្មដែលស្នងនោះនឹងចាប់ផ្តើមបង្កើតនូវវិបាកញាណរបស់វា ចេតសិកដែលសម្បយុត្ត និងកម្មជ្ជរូប ដែលបង្កើតនូវភពថ្មី ក្នុងឋានមួយដ៏សមរម្យ។

ក្នុងពេលនៃ **ចុតិ** និង **បដិសន្ធិ** បន្ទាប់ពីការបែកធ្លាយនៃចុតិចិត្ត នៅក្នុងភពចាស់ បដិសន្ធិចិត្តដែលកើតឡើងនៅក្នុងភពថ្មី ប្រព្រឹត្តទៅគ្មានដាច់នៅក្នុងក្រសែចិត្តនោះ។ ដូច្នេះកម្ម និងថាមពលដទៃទៀតទាំងអស់ដែលនៅក្នុងក្រសែចិត្តនៃភពចាស់នោះ នឹងត្រូវបានបញ្ជូនទៅកាន់ក្រសែចិត្តនៃភពថ្មី។ ប្រសិនបើ បុគ្គលនោះកើតជាមនុស្សទៀត សភាពនៃចិត្តចរិត ឥរិយាបថ របស់គាត់ ។ល។ នឹងមានលក្ខណៈដូចគ្នាច្រើន ឬតិចទៅនឹងបុគ្គលនោះពីមុន។ កម្មដែលត្រូវបញ្ជូនពីជីវិតមួយទៅកាន់ជីវិតមួយទៀត ក្នុងក្រសែចិត្ត គឺមានរបៀបដូចគ្នាដូច្នោះដែរ។ កម្មឱ្យផលនៅពេលណាដែលវាមានឱកាសឱ្យផល។ លក្ខណៈ ដែលវាឱ្យផលគឺដូចខាងក្រោម៖

“ **សទិសំ ផាកំ ជនេតិ** ” កម្ម នឹងបង្កើតបានផលដូចអំពើនៃកម្មនោះ។





“ **យាទិសំ វប្បតេ ពិជំ តាទិសំ ហរតេ ផលំ** ”

“បុគ្គលសាបព្រោះពូជដំណាំណា រមែងបានផលពីគ្រប់ពូជនោះវិញ”

“ **កល្យាណការី កល្យាណំ ផាបការី ច ផាបកំ** ”

អ្នកដែលធ្លាប់ធ្វើល្អ រមែងទទួលបានផលល្អ,

អ្នកដែលធ្លាប់ធ្វើអាក្រក់ រមែងទទួលបាន ផលអាក្រក់។

សព្វសត្វទាំងអស់ប្រព្រឹត្តទៅតាមកម្ម ដែលបានតាក់តែងពួកគេរៀងៗខ្លួន។ ផលកម្ម និងវាសនា របស់ពួកគេខុសគ្នា ព្រោះតែគេបានធ្វើកម្មផ្សេងៗគ្នា។

លក្ខណៈដែលកម្មកើតឡើងយ៉ាងដូចម្តេច និងលក្ខណៈនៃកម្មឱ្យផលយ៉ាងដូចម្តេចនោះត្រូវបានកំណត់ដោយ“ **ច្បាប់កម្ម** ”។ ដោយមានជំនួយពីច្បាប់កម្ម យើងអាចពន្យល់ហេតុផលខុសគ្នាតាមផលកម្ម និងវាសនារបស់មនុស្ស ព្រមទាំងបញ្ហាជីវិតជាច្រើនផងដែរ។

***ច្បាប់កម្ម*** *គឺមិនត្រូវបានត្រួតត្រាដោយអាទិទេព ដែលមានអំណាចណាមួយឡើយ។ វាជាច្បាប់ធម្មជាតិ ដែលដំណើរការទៅតាមចរន្តរបស់វាផ្ទាល់។វាមិនបានគាំទ្រដល់អ្នកមានឬអ្នក*

*ក្រទេ,វាតែងតែប្រព្រឹត្តទៅតាមប្រក្រតី។នៅពេល ដែលកម្មនោះចាស់ទុំ ហើយវាមានឱកាសហុច ផល, គ្មានបុគ្គលណាអាចបញ្ឈប់ វាបានឡើយ។*

ព្រះមហាមោគ្គលាន អគ្គសាវ័កឆ្វេងរបស់ព្រះសម្មាសម្ពុទ្ធ បានវាយសម្លាប់ឪពុកម្តាយពិការភ្នែករបស់លោក ដោយសារការចាក់រុកបញ្ចុះបញ្ចូលរបស់ប្រពន្ធក្នុងអតីតជាតិ។ ព្រះអង្គជាអគ្គ-សាវ័កឆ្វេមរបស់ព្រះពុទ្ធល្បីខាងឫទ្ធិអភិញ្ញា។ ប៉ុន្តែ លោកក៏មិនអាចឃាត់កម្មអាក្រក់របស់លោកមិនឱ្យផលបានដែរ ហើយលោកត្រូវបានវាយសម្លាប់ដោយពួកចោរ៥០០ នាក់វិញ។

## ៧.យើងអាចរៀបចំផលកម្ម និង វាសនារបស់យើងដូចដែលយើង ចូលចិត្ត

ថាមពល នុយក្លីអ៊ែរ ជាថាមពលសរីរាង្គដែលមានកម្លាំងបំផុតគេអាចបំលែងវាឱ្យទៅជាថាមពលអគ្គិសនី ដើម្បីប្រើប្រាស់ដោយជនភាគច្រើន សម្រាប់សុខុមាលភាពរបស់ពួកគេ។ ម្យ៉ាងវិញទៀត ថាមពលនុយក្លីអ៊ែរ គេអាចប្រើវា ដើម្បីបំផ្លាញទីក្រុង និងប្រទេស តាមរូបភាព គ្រាប់បែក អាតូមមិច និង គ្រាប់បែក អ៊ីដ្រូហ្សែន។ មនុស្សមានសិទ្ធិពេញលេញ





ដើម្បីជ្រើសរើសថា តើត្រូវប្រើថាមពល នុយក្លីអ៊ែរ សម្រាប់សុខុមាលភាពរបស់ប្រជាជន ឬក៏សម្រាប់ការបំផ្លាញពួកគេ។

ដូចគ្នានេះដែរ បុគ្គលគ្រប់រូបមានសិទ្ធិពេញលេញ ដើម្បីជ្រើសរើសថា តើគាត់នឹងប្រើប្រាស់ថាមពលផ្លូវចិត្តដ៏មានកម្លាំងសម្រាប់សុខុមាលភាពរបស់គាត់ ឬសម្រាប់សេចក្តីទុក្ខរបស់គាត់។ បុគ្គលគ្រប់រូបមានសេរីភាពពេញលេញ ដើម្បីរៀបចំផលកម្ម និងវាសនា របស់ខ្លួនដូចដែលខ្លួនចូលចិត្ត។ ច្បាប់កម្មនឹងដំណើរការដោយយុត្តិធម៌សម្រាប់គាត់ ដោយគ្មានការបំពេញចិត្តបុគ្គលណាមួយឡើយ។

ដូចស្ថានភាពបច្ចុប្បន្នរបស់បុគ្គលគ្រប់រូប ដែលបង្កើតឡើងដោយខ្លួនឯងទៅតាមឆន្ទានុសិទ្ធិ បុគ្គលនោះមិនគប្បីស្តីបន្ទោសអ្នកផ្សេងឡើយ។ គាត់គួរស្តីបន្ទោសខ្លួនឯង ប្រសិនបើគាត់ស្ថិតក្នុងស្ថានភាពអាក្រក់, ហើយគាត់គួរកោតសរសើរខ្លួនឯង ប្រសិនបើគាត់ស្ថិតនៅក្នុងស្ថានភាពល្អប្រសើរ។

លោក វិលលៀម ហ្សេកស្ពៀរ៍ (William Shakespeare) ១៥៦៤-១៦១៦ ជាកវីនិពន្ធជនជាតិអង់គ្លេស និងជាអ្នកនិពន្ធរឿងល្ខោនដ៏ល្បីល្បាញម្នាក់ បានសរសេរថា "ខ្ញុំជាប្រធាននៃដួងព្រលឹងរបស់ខ្ញុំ និងជាចៅហ្វាយ នៃវាសនារបស់ខ្ញុំ"។

ឥឡូវយើងអាចចាំទុកក្នុងចិត្តថា "ខ្ញុំជាប្រធាននៃចិត្តរបស់ខ្ញុំ និងជាអ្នកបង្កើតវាសនារបស់ខ្ញុំ"។

ការបង្កើតនូវផលកម្ម និងវាសនារបស់អ្នកផ្ទាល់ ដូចដែលអ្នកចូលចិត្ត។ ឧទាហរណ៍ និងវិធីជាច្រើននៃការបង្កើតសំណាង និង វាសនារបស់ខ្លួន ត្រូវបានពណ៌នាក្នុងសៀវភៅនេះ ។ ច្បាប់កម្ម ក៏ត្រូវបានពន្យល់យ៉ាងច្បាស់ និងពេញលេញនៅក្នុងសៀវភៅនេះផងដែរ។

ការយល់ឃើញត្រូវអំពីច្បាប់កម្ម កម្ម និងផលរបស់កម្ម នឹងធ្វើឱ្យបុគ្គលមានសម្មាទិដ្ឋិ ។ ប្រសិនបើអ្នកមិនយល់ច្បាប់កម្ម, កម្ម និងផលរបស់កម្ម មិនអើពើកម្ម ឬមិនជឿកម្ម អ្នកនឹងក្លាយជាបុគ្គលមានមិច្ឆាទិដ្ឋិ។

សម្មាទិដ្ឋិ បណ្ដាលកុសលកម្ម ដែលមិនទាន់កើតឡើងឱ្យកើតឡើង បង្កើនច្រើននូវកុសលកម្ម ដែលបានកើតឡើងហើយ នឹងតាក់តែងនូវភាពសុខស្រួលឱ្យកើតឡើងនៅពេលស្លាប់។ សម្មាទិដ្ឋិ មិនស្មើក្នុងការបណ្ដាលនូវកុសលកម្ម ឱ្យកើតឡើងក្នុងការបង្កើតច្រើនឡើងជាមួយកុសលកម្ម ដែលបានកើតឡើង និងការតាក់តែងនូវបដិសន្ធិក្នុងឋានសួគ៌។

មិច្ឆាទិដ្ឋិ បណ្ដាលឱ្យអកុសលកម្ម ដែលមិនទាន់កើត





ឡើងឱ្យកើតឡើងបាន បង្កើនច្រើននូវអកុសលកម្ម ដែលបានកើតឡើងរួចហើយ នឹងតាក់តែងនូវអបាយភូមិនៅពេលស្លាប់។ មិច្ឆាទិដ្ឋិ មិនស្មើគ្នាក្នុងការបណ្ដាលនូវអកុសលកម្មឱ្យកើតឡើងក្នុងការគុណទ្វេដងជាមួយអកុសលកម្មដែលបានកើតឡើង នឹងមានការតាក់តែងអបាយបដិសន្ធិ ក្នុងឋានអបាយ។ ដូច្នេះ មានសារៈសំខាន់ណាស់សម្រាប់គ្រប់ពុទ្ធសាសនិក ដើម្បីយល់ដឹងអំពីកម្ម និងផលនៃកម្មព្រមទាំងច្បាប់កម្ម។ ហេតុនេះហើយ ខ្ញុំបានផ្ដល់បាឋកថាជាច្រើនស្ដីពី " **កម្ម ដែលជាអ្នកកសាងលោកពិត** " ទាំងនៅក្នុងប្រទេស មីយ៉ាន់ម៉ា និងនៅបរទេស។

អ្នកស្ដាប់ទាំងឡាយ រីករាយយ៉ាងខ្លាំងដោយចង់ដឹងនូវថាមពលអាថ៌កំបាំងដ៏ខ្លាំងក្លានេះ ឱ្យឈ្មោះហៅថា កម្មធ្វើអំពើមកលើយើង និងរៀបចំនូវសំណាងវាសនារបស់យើង។ ដូច្នេះ គេបបួលខ្ញុំឱ្យសរសេរសៀវភៅស្ដីអំពីប្រធានបទនេះ។ ខ្ញុំបានចំណាយពេលយូរ ដើម្បីសរសេរសៀវភៅនេះទាំងភាសាអង់គ្លេស និងភាសាភូមា ដោយពណ៌នាគ្រប់លក្ខណៈទាំងអស់របស់កម្មតាមទស្សនៈផ្សេងៗ ដើម្បីជាប្រយោជន៍ដល់អ្នកអានទាំងអស់។

សូមឱ្យអ្នកយល់ដឹងនូវច្បាប់កម្ម ដើម្បីសម្រេចបាននូវសម្មាទិដ្ឋិ ហើយធ្វើការយល់ឃើញត្រូវនេះ ឱ្យទៅជាប្រទីបបំភ្លឺផ្លូវ

អ្នកឱ្យបានត្រឹមត្រូវ ដើម្បីជៀសវាងផ្លូវខុស ដែលដឹកនាំទៅរកឋាន អបាយ ហើយត្រូវដើរតាមផ្លូវត្រូវដែលឱ្យឈ្មោះថា **អរិយអដ្ឋង្គិក-មគ្គ** ដែលដឹកនាំអ្នកត្រង់ឆ្ពោះទៅកាន់សេចក្តីសុខស្ងប់ ជាអមតៈ ពោលគឺព្រះនិព្វាន។

សូមអ្នកទាំងឡាយបានរួចចាកទុក្ខទោសវិបត្តិ និងហានិ-ភ័យគ្រប់យ៉ាង និងសូមឱ្យបានសោយសុខក្នុងឋានមនុស្សលោក ឋានទេវលោក និងសុខក្នុងព្រះនិព្វានជារៀងរហូត។

*បណ្ឌិត ម៉ែម ទីន មន*



# ១

## តើភពមានន័យដូចម្តេច?

### ១.តើភពជាអ្វី?

ភពរបស់សត្វមានជីវិតរស់នៅអាចត្រូវបានចាត់ទុកថា ជាផលបូកនៃសកម្មភាព និងបទពិសោធន៍ របស់សត្វតាំងពីកើតរហូតដល់ស្លាប់។

អ្នកខ្លះបានផ្តល់ការកត់សម្គាល់ ដ៏ស្រស់ស្អាតមួយរួចជាស្រេចថា "ភពមួយ គឺជាសភាវរបស់សត្វដែល មានជីវិតរស់នៅពីកើតទៅស្លាប់"។

យោងតាមពុទ្ធអភិធម្មថា ភពមួយចាប់ផ្តើមពីការកើតឡើងនៃបដិសន្ធិចិត្ត ចេតសិករបស់វាដែលសម្បយុត្តជាមួយនឹងកម្មជរូប បង្កើតឡើងដោយកម្មណាមួយក្នុងអតីតរបស់សត្វនោះ ដែលឥឡូវកំពុងចាប់កំណើតក្នុងផ្ទៃនៃមាតា។

កម្មជរូប បង្កើតបានជាដំណក់វត្ថុរាវថ្លាតូចមួយដំណក់ហៅថា កលលៈ។ កលលៈ នេះត្រូវបានបង្កើតឡើងនៅក្នុងអូរុល

ឬកោសិកាភេទរបស់ម្តាយ ដែលបង្កឡើងដូចជាស៊ុត ដោយ ស្ពែរម៉ាតូសូអ៊ីត របស់ឪពុក អូវុល និង ស្ពែរម៉ាតូសូអ៊ីត របស់ឪពុកម្តាយ បានដើរតួជាឧបត្ថម្ភដ៏សំខាន់សម្រាប់ការកើតឡើងបានជាគ៌ភ។ កលលៈទុកដូចជាគ្រាប់ពូជ អូវុល និង ស្ពែរម៉ាតូសូអ៊ីត ប្រៀបបានដូចជាដីសើម កម្ម ដែលផលិត ប្រៀបបានដូចជាកសិករ [១]។

ដូច្នេះគ៌ភចាប់ផ្តើមពីខណៈពេលកំពុងកើតឡើងនៃបដិសន្ធិចិត្ត ចេតសិក និងកម្មជ្ជរូប។ កម្មអតីត ដែលតាក់តែងបដិសន្ធិនៃទារកឱ្យកើតឡើង ចេះតែបន្តបង្កើតនូវវិបាកវិញ្ញាណ និង ចេតសិករាល់ខណៈចិត្ត រហូតដល់កម្មនោះអស់ឥទ្ធិពលដល់ពេលស្លាប់។

មួយខណៈចិត្ត គឺមួយអាយុកាលរបស់ចិត្ត។ វាស្មើនឹង ៣ ខណៈខ្លីៗ ពោលគឺខណៈខ្លីនៃការកើតឡើងរបស់ចិត្តនោះ ខណៈខ្លីនៃការស្ថិតនៅរបស់ចិត្តនោះ និងខណៈខ្លីនៃការរលត់ទៅនៃចិត្តនោះ។ ចិត្តកើតឡើងបន្តបន្ទាប់គ្នាដោយគ្មានដាច់, ដូច្នេះ ក៏បង្កើតបានខ្សែច្រវាក់នៃក្រសែចិត្ត មួយ។

កម្មជាវិបាកចិត្តដំបូងឱ្យឈ្មោះថា " បដិសន្ធិចិត្ត "។ ការប្រព្រឹត្តទៅបន្តបន្ទាប់គ្នានៃវិបាកចិត្តហៅថា "ភវង្គ" ឬ "ខ្សែភវង្គ"។





វិបាកចិត្តចុងក្រោយនៅក្នុងភពមួយ ឱ្យឈ្មោះថា " ចុតិចិត្ត " ។ បន្ទាប់ពីចុតិចិត្តនោះទៅ សត្វក៏ស្លាប់ទៅ ដោយសារឧបត្ថម្ភកម្មអស់ថាមពល។ ប៉ុន្តែឧបត្ថម្ភកម្មដទៃទៀតនឹងមានឱកាស តាក់តែងនូវភពថ្មីមួយឱ្យកើតឡើងតាមរបៀបដូចគ្នា។

កម្មជ្ជរូប ត្រូវបានបង្កើតឡើងបន្តគ្នារាល់ខណៈខ្លីៗដោយចាប់ផ្តើមពីខណៈដែលកំពុងកើតឡើងនៃបដិសន្ធិចិត្ត។ ចិត្តជ្ជ-រូប បានកើតឡើងបន្តគ្នារាល់ខណៈ ដែលកំពុងកើតឡើងនៃភវង្គចិត្ត ដោយចាប់ផ្តើមពីខណៈដែលកំពុងកើតឡើងភវង្គចិត្តដំបូងរហូតដល់មរណៈ។ ដោយចាប់ផ្តើមពីពេលអាហារត្រូវបានបរិភោគដោយម្តាយ ហើយក៏ត្រូវទទួលបានដោយកូនក្នុងគ៌ភនោះ អាហារជ្ជរូបក៏កើតឡើងបន្តគ្នារាល់ខណៈរហូតដល់ស្លាប់។




ក្រសែចិត្តហូរទៅពីភពមួយទៅភពមួយទៀត

រូបទាំងអស់កើតឡើងជាទម្រង់រូបខន្ធ ដែលផ្ទុកដោយបរមត្ថរូប ៨. ៩. ១០ ប្រភេទ។ រូបខន្ធ នីមួយៗមានតេជោធាតុ។ តេជោធាតុនេះឈានដល់សភាពស្ថិតនៅមួយខណៈខ្លី ហើយបន្ទាប់មកទៀត វាបង្កើតជាតេជរូបបន្តគ្នារាល់ខណៈ។ រូបខន្ធនីមួយៗជាទូទៅមានអាយុ ១៧ ចិត្តខណៈ។

ដូច្នេះ ដោយសារការកើតឡើងនៃរូបជាច្រើនប្រភេទផ្សេងៗគ្នា គភ៌លូតលាស់ជាលំដាប់ ហើយទារកក៏ចាប់ផ្តើមកើតនៅថ្ងៃដ៏សមគួរដល់ពេលវេលា។ បន្ទាប់មកទារកនោះធំឡើងដោយសារការបង្កើតឡើង នូវរូបខន្ធបន្តបន្ទាប់រហូតដល់ពេញវ័យ។គ្រប់កម្មជរូបទាំងអស់រលត់ទៅនៅពេលស្លាប់។ គ្រប់ចិត្ត-ជរូប និងអាហារជរូបទាំងអស់ក៏រលត់ទៅវិញ បន្ទាប់ពីមរណៈដែរ។ មានតែតេជរូបទេ ដែលស្ថិតនៅជាសាកសព។

ដូច្នេះ ភពមួយត្រូវបានកំណត់ថា ជាការប្រព្រឹត្តទៅនៃការកើតឡើង និងការបែកធ្លាយទៅវិញនៃ នាម និង រូប ពីខណៈដែលកំពុងកើតឡើង បដិសន្ធិចិត្ត រហូតដល់ការរលត់ទៅវិញនៃចុតិចិត្ត។

នៅពេល អកុសលកម្ម មានឱកាសឱ្យផលជាឧបត្ថម្ភកកម្ម ភពថ្មីមួយទៀតត្រូវបានកើតឡើងក្នុងឋានអបាយមួយ។





នៅពេល កុសលកម្មជាកាមលោកមានឱកាសឱ្យផលជាឧបត្ថម្ភកកម្ម ភពថ្មីមួយត្រូវបានបង្កើតឡើង អាចនៅក្នុងឋានមនុស្ស ឬឋានទេវតា។ ឋានទាំងពីរប្រភេទនេះឱ្យឈ្មោះថាជាកាមាវចរសុគតិភព។

នៅពេលដែលកុសលកម្មជារូបភព ដែលជាកម្មកើតចេញពី រូបឈានចិត្ត មានឱកាសដើម្បីតាក់តែងនូវបដិសន្ធិថ្មីមួយ រូបព្រហ្មក៏ត្រូវបានបង្កើតឡើងដែរ។

នៅពេល កុសលកម្ម ជាអរូបភព ដែលជាកម្មកើតចេញពី អរូបឈានចិត្ត មានឱកាសដើម្បីតាក់តែងនូវបដិសន្ធិថ្មីអរូបព្រហ្ម គឺភពព្រហ្មគ្មានរូបក៏ត្រូវបានកើតឡើង។

**២. ភពផ្សេងៗគ្នា**

នៅក្នុងមូលបណ្ណាស មហាវេទល្លសូត្រ ព្រះមហាកោដ្ឋិកៈ បានសួរ ព្រះសារីបុត្រ អគ្គសាវ័កស្តាំរបស់ព្រះសម្មាសម្ពុទ្ធ ថា "បពិត្រលោកម្ចាស់ តើភពជាអ្វី ?"

ព្រះសារីបុត្រឆ្លើយតបថា"ម្នាលអាវុសោ ភពមាន ៣ គឺ កាមភព១ រូបភព១ និងអរូបភព១"។

"កាមភព" មានន័យថា ភពដែលអាស្រ័យកាម ដែលជាកន្លែងត្រូវសោយកាមគុណ។ កាមភពរួមមាន អបាយភូមិ

៤ ឋានមនុស្ស និងឋានទេវតាទាំង៦ជាន់។ ដូច្នេះ ភពតិរច្ឆាន ភពប្រេត ភពអសុរកាយ ភពនរក ភពមនុស្ស និងភពទេវតា ត្រូវរាប់បញ្ចូលក្នុងកាមភព។

"រូបភព" មានន័យថា អត្ថិភាពក្នុងភពដែលមានរូប។ រូបភពមានឋានមានរូប ១៦ ជាន់ មានឈ្មោះថា ព្រហ្មបរិសជ្ជា ព្រហ្មបុរោហិតា មហាព្រហ្មា ។ល។ ក្នុងចំណោមឋានទាំងនោះ ពួកព្រហ្ម ក្នុងឋាន អសញ្ញសត្ត មានតែរូប មិនមានចិត្តទេ ឯពួកព្រហ្ម ក្នុងឋាន១៥ ជាន់ទៀតមានទាំងកាយ និងចិត្ត។ ពួកព្រហ្ម មិនសោយនូវកាមគុណទេ ពួកគេរីករាយដោយសេចក្ដីសុខក្នុងឈាន។

"អរូបភព" មានន័យថា អត្ថិភាពក្នុងភពដែលគ្មានរូប។ អរូបភព មាន ឋាន៤ជាន់ ឱ្យឈ្មោះថា អាកាសានញ្ចាយតនៈ១ វិញ្ញាណញ្ចាយតនៈ១ អាកិញ្ចញ្ញាយតនៈ១ នេវសញ្ញា នាសញ្ញាយតនៈ១។ ពួកអរូបព្រហ្ម ដែលនៅក្នុងឋានទាំងនេះ មានតែចិត្ត មិនមានរូបកាយទេ។

ភាពខុសគ្នា មិនមែនត្រឹមតែដោយសារភាពខុសគ្នាក្នុងឋាន ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងខុសគ្នាក្នុងអាការៈ ទ្រព្យ សុខភាព ប្រាជ្ញា ឋានៈសង្គម អាយុកាល ។ល។ ទោះបីជាមាន





មនុស្សច្រើនជាង ៦៥០០ លាននាក់នៅក្នុងពិភពលោក ក៏ដោយក៏ពួកគេមិនដូចគ្នាដែរ។ ពួកគេទាំងអស់ខុសគ្នាពីមួយទៅមួយតាមទិដ្ឋភាពច្រើនយ៉ាង។

អ្នកខ្លះ ត្រូវបានចិញ្ចឹមបីបាច់ក្នុងវិមានស្កឹមស្កៃក្នុងគំនរវត្ថុប្រណីតៗ បរិបូណ៌ដោយបញ្ញាខ្ពស់ និងមានសុខភាពល្អ ខណៈពេលអ្នកខ្លះ ត្រូវបានចិញ្ចឹមបីបាច់ក្នុងខ្ទមតោកយ៉ាកក្រក្រៃលែង មានបញ្ញាអន់ថយ ចំណេះដឹងតិច និងសុខភាពខ្សោយ។

អ្នកខ្លះកើតមកបានជាសេដ្ឋីមានទ្រព្យរាប់លាន ចំណែកអ្នកខ្លះទៀតកើតមកជាអ្នកក្រ។ អ្នកខ្លះកើតមកមានរូបសម្បត្តិស្រស់ស្អាត អ្នកខ្លះកើតមកមានរូបរាងអាក្រក់យ៉ាងក្រៃលែង។ អ្នកមានទ្រង់ទ្រាយធម្មតា អ្នកខ្លះពិការ ងងឹតភ្នែក គ ថ្លង់។ល។ អ្នកខ្លះមានសុខភាពល្អណាស់ ឯអ្នកខ្លះទៀតដេកលើគ្រែមានជម្ងឺរ៉ាំរ៉ៃ។ អ្នកខ្លះពូកែខាងសិល្បៈតន្ត្រី ការច្រៀង ការរាំ កីឡា វិទ្យាសាស្ត្រ ឬបច្ចេកវិទ្យា ចំណែកអ្នកខ្លះទៀតមិនមានសមត្ថភាពខាងការងារណាមួយក្នុងជីវិតឡើយ។

នរណាជាអ្នកបង្កើតភពផ្សេងៗគ្នាដូច្នេះ? តើនរណារៀបចំជោគវាសនារបស់សត្វទាំងអស់ ធ្វើឱ្យពួកគេមិនដូចគ្នាក្នុងអាការៈ ប្រាជ្ញា អាកប្បកិរិយា ទ្រព្យ សុខភាព។ល។ តើ

ព្រះអាទិទេព បង្កើតនូវភាពខុសគ្នាទាំងអស់នេះឬ? តើមានហេតុផ្សេងទៀតដែលនាំឱ្យមានភាពផ្សេងគ្នាទាំងអស់នេះឬ?

### ៣. តើនរណាបង្កើតសព្វសត្វផ្សេងៗគ្នា?

ទាក់ទងទៅនឹងអត្ថិភាពរបស់សត្វផ្សេងៗគ្នា នៅក្នុងភព ជនខ្លះកាន់យកទិដ្ឋិថា សត្វទាំងនេះកើតឡើងដោយគ្មានហេតុ ហើយថា ពួកគេខុសគ្នាតាមលក្ខណៈជាច្រើន ដោយគ្មានហេតុផល។ ទិដ្ឋិនេះហៅថា " អហេតុកទិដ្ឋិ " គឺការយល់ថា អ្វីៗទាំងអស់គ្មានហេតុបច្ច័យតាក់តែង។

រាល់ព្រឹត្តការណ៍ និងអ្វីៗគ្រប់យ៉ាងដែលកើតឡើងសុទ្ធតែមានហេតុនៅពីក្រោយរឿងរ៉ាងទាំងនោះ។ ដោយសារបុគ្គលមានអវិជ្ជា មិនដឹងពីហេតុទាំងនេះ បុគ្គលនោះក៏កាន់យកទិដ្ឋិថា រឿងរ៉ាវទាំងអស់នោះកើតឡើងគ្មានហេតុ ពេលនោះបុគ្គលនោះនឹងខុស។ ប្រសិនបើបុគ្គលជឿថា ភ្លៀងធ្លាក់ដោយគ្មានហេតុផល ព្រោះតែបុគ្គលមិនដឹងនូវហេតុផលថា ហេតុអ្វីបានជាវាភ្លៀង ពេលនោះឯង បុគ្គលនោះនឹងខុស។

ជនជាច្រើនជឿថា ពិភពលោក និងសព្វសត្វទាំងអស់ត្រូវបានបង្កើតឡើងដោយ ព្រះអាទិទេព ។ ជំនឿនេះកើតឡើងមកពីពាក្យប្រៀនប្រដៅរបស់សាសនាមួយចំនួន។





ព្រះអាទិទេព មួយនោះមានឈ្មោះថា ឥស្សរៈ ជាភាសាបាលី និង ឥស្វារៈ ជាភាសាសំស្ក្រឹត។ ដូច្នេះ ទិដ្ឋិដែលជឿថា អាទិទេព មានអំណាចបង្កើតនូវសព្វសត្វទាំងអស់ ហើយកំណត់នូវជោគវាសនារបស់ពួកគេផងនោះឈ្មោះថា "ឥស្សរានិម្មានវាទ"។

ដោយមានសេរីភាពពេញលេញ ក្នុងការធ្វើការគោរពបូជា បុគ្គលអាចជឿលើសាសនាណាមួយក៏បាន ដែលខ្លួនឱ្យតម្លៃ។ ក៏ប៉ុន្តែបុគ្គលគួរសិក្សាដោយយកចិត្តទុកដាក់នូវជំនឿ ដែលបុគ្គលទទួលយកថា តើវាពិតជាត្រឹមត្រូវ មានហេតុផល មានប្រយោជន៍ ហើយវាអាចនាំទៅរកជីវិតប្រសើររីករាយ ឬអត់។ ចំណុចមួយចំនួនត្រូវបានលើកឡើងក្នុងទីនេះ សម្រាប់ធ្វើការពិចារណា។

មានសាសនាជាច្រើនដែលប្រៀនប្រដៅថា ព្រះអាទិទេព ជាអ្នកបង្កើតលោក និងសព្វសត្វទាំងអស់។ គេឱ្យឈ្មោះខុសៗគ្នាចំពោះអ្នកសាងលោកនេះ ហើយពួកគេមិនអាចព្រមព្រៀងគ្នាថា អ្នកសាងលោកទាំងឡាយនោះដូចគ្នាបានឡើយ។ ដូច្នេះ នរណាជាអ្នកបង្កើតលោកពិតប្រាកដ?គេនិយាយថា ប្រសិនបើ អាទិទេព សាងលោកនោះ មានសព្វានុភាព ហើយធ្វើអ្វីដែល

ខ្លួនចូលចិត្ត ហេតុអ្វីបានជាអ្នកនោះមិនបង្កើតមនុស្សត្រឹមត្រូវ យុត្តិធម៌ សត្វមានប្រយោជន៍ មិនបង្កឱ្យមានគ្រោះថ្នាក់ និងវត្ថុល្អៗ ដើម្បីបំពេញពិភពលោកទៅ? ហេតុអ្វីបានជាអាទិទេពបង្កើតមនុស្សអាក្រក់លូងខ្លៅ មានគ្រោះថ្នាក់ និងសត្វព្រៃ ពស់មានពិស ខ្យាដំរី មេរោគ និងបាក់តេរី ខ្យល់ព្យុះ និងរញ្ជួយផែនដីដ៏មានគ្រោះថ្នាក់បែបនេះ?

លោក អលប៊ឺត អាញស្តាញ (Albert Einstein) ជាអ្នកវិទ្យាសាស្ត្រដ៏ឆ្នើមបានធ្វើការកត់សម្គាល់ដូចខាងក្រោម៖

*"ប្រសិនបើព្រះអាទិទេព មានសព្វញ្ញុភាពអ៊ីចឹងរាល់ព្រឹត្តិការណ៍ដែលកើតឡើងរួមទាំងរាល់សកម្មភាពរបស់មនុស្ស រាល់គំនិតរបស់មនុស្ស និងរាល់អារម្មណ៍ និងសេចក្តីប្រាថ្នារបស់មនុស្ស ក៏ជាការងាររបស់ព្រះជាម្ចាស់ដូច្នោះមែន តើអាចគិតពីមនុស្ស ដែលមានទំនួលខុសត្រូវចំពោះការទទួលខុសត្រូវ និងគំនិតរបស់ពួកគេ នៅចំពោះមុខព្រះអាទិទេព បែបនេះដូចម្តេចកើត? ក្នុងការដាក់ទណ្ឌកម្ម និង ការឱ្យរង្វាន់ចំពោះទំហំដាក់លាក់ គប្បីឱ្យការវិនិច្ឆ័យលើព្រះអាទិទេពខ្លួនឯងផ្ទាល់។ តើករណីនេះអាចត្រូវបានផ្សំជាមួយភាពល្អ និងត្រឹមត្រូវផ្តល់ជូនចំពោះព្រះអាទិទេពបានដែរឬទេ?*





អ្នកធ្វើកំណែទម្រង់សង្គម សញ្ជាតិអង់គ្លេស និងជាជើងឯកខាងការទាមទារសិទ្ធិនារី ឈ្មោះ ឆាល ប្រេដឡាហ្វគ៍ (Charles Bradlaugh),១៨៣២-១៩៩១,បានធ្វើការកត់សម្គាល់ដូច្នេះគឺ៖

*"វត្តមាននៃសេចក្តីអាក្រក់គឺ ជាការជាន់ឈ្លីគួរឱ្យរន្ធត់រាំងស្ទះដល់អ្នកទេវនិយម។ ការឈឺចាប់ សេចក្តីទុក្ខ បទឧក្រិដ្ឋ ភាពក្រីក្រ ប្រឈមមុខនឹងការគាំទ្រនូវសេចក្តីល្អនិងការផ្លាស់ប្តូរគ្មានទីបំផុតជាមួយនឹងកម្លាំង ដែលមិនអាចឆ្លើយតបបាននូវសេចក្តីថ្លែងរបស់លោក អំពីទេវតាថា ល្អទាំងអស់ ឆ្លាតទាំងអស់ និងមានអំណាចទាំងអស់"(២)។*

ព្រះតេជគុណ នារទមហាថេរ បានសរសេរក្នុងសៀវភៅដ៏ល្បីល្បាញរបស់លោក ដែលមានចំណង ជើងថា "ព្រះពុទ្ធ និងការប្រៀនប្រដៅរបស់ព្រះអង្គ" ដូចខាងក្រោមថា៖

*"អ្នកនិពន្ធតាមគំនិតខ្លួនឯង បានប្រកាស ដោយប្តេជ្ញាថា ព្រះអាទិទេព បង្កើតមនុស្សបន្ទាប់ ពីរូបបដិមារបស់ព្រះទ្រង់។ ផ្ទុយទៅវិញ, អ្នកគិត សម័យទំនើបមួយចំនួនបានយល់ថា មនុស្សបាន បង្កើត ព្រះអាទិទេព បន្ទាប់ពីបដិមាផ្ទាល់ខ្លួន។ ដោយការរីកលូតលាស់ផ្នែកអារ្យធម៌ ទស្សនៈរបស់ មនុស្សស្តីពីព្រះអាទិទេព បានធ្វើឱ្យកាន់តែប្រសើរ ឡើង។ បច្ចុប្បន្ន មាននិន្នាការដើម្បីជំនួសព្រះ អាទិទេព ជាបុគ្គលឱ្យទៅជាព្រះអាទិទេពមិនមែន ជាបុគ្គល វិញ។ លោក វ៉ុលតែរ៍ (valtaire) បាន អះអាងថា" ព្រះអាទិទេព គឺជាការបង្កើតឡើងដ៏ ប្រសើរបំផុតរបស់មនុស្ស"(៣)។*

## ៤. ការរកឃើញផ្នែកវិទ្យាសាស្ត្រ

ក្នុងវិទ្យាសាស្ត្រធម្មជាតិ ដូចជា រូបវិទ្យា គីមីវិទ្យា ភូគព្ភសាស្ត្រ និងជីវសាស្ត្រ អ្នកវិទ្យាសាស្ត្រទាំងឡាយ រកឃើញថា រាល់ការកើតឡើងបាតុភូតធម្មជាតិទាំងអស់ សុទ្ធតែក្រោមកម្លាំងធម្មជាតិ និងហេតុនៃធម្មជាតិ។ ពួកគេមិនបានរកឃើញភស្តុតាងណាមួយបញ្ជាក់ថា បាតុភូតនោះបានបង្កើតឡើងដោយ ព្រះ





អាទិទេពនោះទេ។ ច្បាប់ជាមូលដ្ឋានមួយរបស់វិទ្យាសាស្ត្រដែលមានឈ្មោះថា "ច្បាប់ អភិរក្សរូបធាតុ និងថាមពល បញ្ជាក់ថា គេមិនអាចបង្កើត ឬបំផ្លាញនូវរូបធាតុ និងថាមពលបានឡើយ"។

លោក អលប៊ឺត អាញស្តាញ (Albert Einstein) ជាអ្នកវិទ្យាសាស្ត្រដ៏ឆ្នើមបានស្រាយបំភ្លឺនៅក្នុងឆ្នាំ ១៩០៥ ថា រូប និងថាមពល អាចត្រូវបានបំលែងពីមួយទៅមួយ ដោយសមីការ $E = mc^2$ ដែល " E " តំណាងឱ្យថាមពល "m" គឺទំហំ ឬម៉ាស់ ហើយ" c " គឺជាល្បឿននៃពន្លឺ។ ដូច្នេះ រូប និងថាមពលអាចចាត់ទុកបានថាដូចគ្នាតែមួយ។ រូបអាចចាត់ទុកថា ជាប្រភពនៃថាមពល ហើយថាមពលជាច្រើននឹងត្រូវបញ្ចេញនៅពេលដែលរូបនោះបែកធ្លាយ។ គោលការណ៍នេះត្រូវបានយកទៅប្រើប្រាស់ក្នុងគ្រាប់បែក អាតូមិក និងគ្រាប់បែក អ៊ីដ្រូសែន។

យោងទៅតាម ការសិក្សាសង្កេតរបស់អ្នកភូគព្ភសាស្ត្រ អាយុផែនដីរបស់យើង គឺ ៤៦០០ លាន ឆ្នាំ។ ៤៦០០ លាន ឆ្នាំកន្លងទៅនេះ ផែនដីបានកើតឡើងយ៉ាងពេញលេញ ប៉ុន្តែផ្នែកខ្លះនៃភពផែនដី នៅតែស្ថិតក្នុងដំណាក់កាលរលាយបន្តិចម្តងៗ។ ដោយសារផែនដីចុះថយកំដៅយឺតៗ ដូច្នេះ ដំបូងជីវិតជាទម្រង់បែបបាក់តេរី បានកើតមានឡើងនៅលើភពផែនដី

៤០០០ លានឆ្នាំកន្លងទៅនេះ។ ពពួកសត្វ ដែលមានកោសិកាតែមួយ និងសារជាតិផ្សិតជាច្រើនបានកើតឡើងដំបូង២១០០ លានឆ្នាំកន្លងទៅនេះ។

១៣០០លានឆ្នាំកន្លងទៅ សរីរៈដែលមានកោសិកាចម្រុះស្មុគស្មាញបានកើតឡើង ដំបូងជាទម្រង់បែបរុក្ខជាតិតូចៗនៅក្នុងសមុទ្រ។ ៣០០ លានឆ្នាំក្រោយមកទៀត ការបង្កើតតាមផ្លូវភេទបានកើតឡើង។ ៦២០លានឆ្នាំកន្លងទៅ ដង្កូវមានបំពង់ដូចរាងកាយ និងប្រព័ន្ធសរសៃប្រសាទជាដំបូងបានកើតឡើង។ ១១០លានឆ្នាំក្រោយមក សត្វមានឆ្អឹងខ្នងបានកើតឡើង។

ជីវិតនៅលើផែនដី ហើយនិងត្រីដែលមានថ្គាម បានកើតឡើង ៤២៥ លានឆ្នាំកន្លងទៅ។ ៣០លានឆ្នាំក្រោយមក ដំបូងសត្វល្អិតមានសរីរាង្គដូចសត្វពួកម្រើមព្រះ ឬក្អែប សត្វកណ្ដៀរ សត្វ ពីងពាង ខ្យាដំរី សត្វល្អូនដំបូងបានកើតឡើង។ សត្វល្អិតមានស្លាបបានកើតឡើងដំបូង ៣៣០ លានឆ្នាំកន្លងទៅ។ សត្វដាយណូស័រ សត្វនៅលើផែនដីជាច្រើនមានរាងធំៗបានធ្វើការរស់នៅតាមរបៀបធម្មជាតិរបស់វា ២៣៥ លានឆ្នាំកន្លងទៅ។ ពពួកសត្វមានសុក ក៏បានកើតមានឡើងដំបូង ក្នុងពេល ១១៤ លានឆ្នាំកន្លងទៅ។ហើយ៤០លានឆ្នាំកន្លងមកទៀត ថនិកសត្វ





យុគដំបូងក៏ស្លាប់ពាយអស់ទៅ។ ១៩ លានឆ្នាំក្រោយមកសត្វស្វាធំៗក៏បានបែកចេញពីពួកស្វាទាំងឡាយ។ ហូម៉ូអ៊ីរិកទូសមនុស្សដែលដើរមានជងខ្លួនត្រង់លេចមានឡើង ហើយការប្រមាញ់បានចាប់ផ្ដើម ១.៩ លានឆ្នាំកន្លងទៅ។ ការវិវឌ្ឍន៍បានប្រើពេលអស់ ៣០០,០០០ ឆ្នាំ សម្រាប់មនុស្ស ដើម្បីរៀនពីសិល្បៈនៃការបង្កើតភ្លើង។ មនុស្សសម័យទំនើបបច្ចុប្បន្ន គេឱ្យឈ្មោះថា ហូម៉ូសេភៀន(Homo Sapiens)ចាប់ផ្ដើមមានឡើង ៦០០,០០០ឆ្នាំកន្លងទៅនេះ។ មនុស្សសម័យទំនើបជាងនេះទៀត គេឱ្យឈ្មោះថា ហូម៉ូសេភៀន សេភៀន (Homo Sapiens Sapiens) កើតឡើង ៤០០,០០០ឆ្នាំកន្លងទៅនេះ(៤)។

របកគំហើញនានារបស់ភូគព្ភសាស្ត្រវិទូខុសគ្នាយ៉ាងជាក់ស្ដែងពីសេចក្ដីថ្លែងថា ព្រះអាទិទេព ដ៏មានអំណាច បង្កើតនូវភពផែនដី មនុស្ស និងសត្វគ្រប់ប្រភេទតែក្នុងរយៈពេល ៧ថ្ងៃកាលពី ៦០០០ឆ្នាំកន្លងទៅនេះ។ ហេតុនេះហើយ លោក អេច ជី វែល (H.G Wells, 1866-1446) ជាអ្នកប្រវត្តិសាស្ត្រពិភពលោក សញ្ជាតិអង់គ្លេសបានសរសេរថា:

" *នៅពេលយើងសិក្សាគម្ពីរសេក្ដិសិទ្ធិរបស់*
*យើង គេប្រាប់យើងថា ព្រះអាទិទេពបានបង្កើត*

*ពិភពលោកនេះ ៦០០០ ឆ្នាំកន្លងទៅនេះ។ នៅពេលយើងសិក្សា ភូគព្ភសាស្ត្រ យើងអាចយល់បានថាវាបានប្រើពេលរាប់ពាន់លានឆ្នាំសម្រាប់ភពផែនដីនេះ ដើម្បីធ្វើឱ្យ ត្រូចទៅៗ ហើយតាំងមានឡើង មុនពេលភាវៈមានជីវិតអាចកើតមានឡើង។ ម្ល៉ោះហើយ តើយើងអាចជឿនូវអ្វីដែលគេបានសរសេរនៅក្នុងគម្ពីរសេក្តិសិទ្ធិ របស់យើងដូចម្តេចកើត?"(៥)។*

" ទ្រឹស្តីនៃការវិវឌ្ឍន៍ " បង្កើតឡើងដោយ ឆាល ដារ៉ុន (Chales Darwin),១៨០៩-១៨៨២, ជាអ្នកធម្មជាតិ សញ្ជាតិអង់គ្លេស ក៏ប្រឆាំងទៅនឹង " ទ្រឹស្តីអ្នកសាងលោក" ដារ៉ុន បានកាត់បន្ថយឧបសគ្គ សម្រាប់ការរស់រានរបស់ជនទាំងឡាយផ្សេងគ្នាដែលមានការគាំទ្របំផុត អ្នកខ្លះត្រូវបានក្លាយទៅជាកូនជាចៅ។ ដោយមានការកែប្រែគោលការណ៍ នៃការសម្រិតសម្រាំងបែបធម្មជាតិនេះ ស្ទើរតែត្រូវបានទទួលយកជាសកល ដោយអ្នកវិទ្យាសាស្ត្រជាច្រើន(៦)។

ការស្រាវជ្រាវដឹកនាំដោយលោក ល្វីស បាស្ទ័រ(Louis Pasteur), ១៨២២-១៨៩៥, អ្នកវិទ្យាសាស្ត្របារាំងរូបនេះ





ហើយដែលបានស្ថាបនាឧបករណ៍កំដៅសម្លាប់មេរោគ ដែលបានលាតត្រដាងថា ភាវៈរស់ទាំងឡាយ អាចកើតចេញតែពីភាវៈមានជីវិតដូចគ្នា។ ដូច្នេះអ្នកវិទ្យាសាស្ត្ររូបនេះ បានទទួលយកគោលការណ៍នោះថា " ជីវិតទាំងអស់ កើតចេញមកពីជីវិត"(Omne Viuvum ex vivo)(៧)។ ដូច្នេះ គេជឿថា មនុស្សដំបូង បានបង្កើតឡើងលើភពផែនដី ដែលមានការរៀបចំចាត់ចែងគឺមានលក្ខណៈស៊ាំញ៉ាំណាស់។

## ៥.ទារកក្នុងបំពង់សាក

ក្នុងការពិនិត្យសង្កេតមើលអំពីគ៌ភ នៅក្នុងផ្ទៃរបស់ម្តាយ អ្នកវិទ្យាសាស្ត្រនានាបានយក អូវុល ពីស្បូនរបស់ប្រពន្ធនៃគូស្រករ ដែលគ្មានកូន ហើយដាក់វាទៅក្នុងបំពង់សាក។ គេដាក់បញ្ចូលទឹកកាមរបស់ប្តីទៅក្នុងបំពង់សាក ហើយមើលដោយម៉ៃក្រូស្កុប (កែវពង្រីក)។

ស្ពែរម៉ាតូសូអ៊ីតបានហែលជុំវិញ អូវុល ព្យាយាមចូលទៅក្នុងអូវុលនោះ ភ្នាស់របស់អូវុលបានរឹង ការពារមិនឱ្យស្ពែរម៉ាតូសូអ៊ីត(មេជីវិតទឹកកាមរបស់បុរស)ដទៃទៀត មិនឱ្យចូលទៅក្នុងអូវុល(ទឹកកាមឬមេជីវិតរបស់ស្ត្រី)នោះបានឡើយ(៨)។ សារធាតុ អូវុល ឈ្មោះថា ស៊ីកូត បានបង្កកំណើតនៅក្នុងផ្ទៃ

ស្បូននៃម្តាយ។ស៊ីកូតនោះបានភ្ជាប់ខ្លួនរបស់វាទៅនឹងជញ្ជាំងស្បូន នៅពេលដែលគ៌ភកើតឡើង។ ទារកបានកើតក្នុងពេលសមគួរ ដូចនៅក្នុងគភ៌ធម្មតា។ ទារកដែលកើតរបៀបនេះហៅថា"ទារកក្នុងបំពង់សាក"។

សព្វថ្ងៃនេះ អ្នកវិទ្យាសាស្ត្រជាច្រើនបានជួយគូស្វាមីភរិយាដែលគ្មានកូនពាសពេញពិភពលោក ដើម្បីទទួលបានកូនតាមរយៈបំពង់សាកនេះ។ គូស្វាមីភរិយាទាំងនោះមិនគួរយកកូនទៅតាមបំណងរបស់ព្រះអាទិទេពឡើយ ព្រោះអ្នកវិទ្យាសាស្ត្រអាចជួយពួកគេឱ្យមានកូនបាន។ ដូច្នេះ ប្រហែលគេចាត់ទុកថា អ្នកវិទ្យាសាស្ត្រ ទើបជាអ្នកបង្កើតលោកពិតប្រាកដមែន។

គេក៏អាចជួយឱ្យស្ត្រីអាចសម្រាលកូនបានច្រើនជាងមួយក្នុងពេលតែមួយបាន។ ប្រសិនបើម្តាយនៅពេលអនាគតមិនចង់សម្រាលកូន ដើម្បីចៀសវាងការឈឺចាប់ និង ដើម្បីថែរក្សាសម្ផស្សរបស់នាងៗអាចជួលស្ត្រីដទៃ ឱ្យសម្រាលកូនជំនួសនាងបាន។ អ្នកវិទ្យាសាស្ត្រគ្រាន់តែដាក់ទឹក អូវុល ជាមេជីវិតរបស់គូស្រករនោះ ក្នុងស្បូននៃស្ត្រីដែលគេជួលនោះ។ ទឹកអូវុល មានមេជីវិតនោះនឹងដាំភ្ជាប់ខ្លួនវាទៅនឹងជញ្ជាំងស្បូន ហើយស្ត្រី





ដែលគេជួលឱ្យពផ្ទៃនោះនឹងមានគ៌ភ។នាងនឹងសម្រាលកូនក្នុងពេលដ៏សមគួរមួយ។ ជួនកាលស្ត្រីដែលគេជួលនោះស្រលាញ់កូននោះដូចជាកូនរបស់ខ្លួនផ្ទាល់ ព្រោះនាងបានពផ្ទៃសម្រាប់កូននោះ ហើយបានចិញ្ចឹមដោយទឹកដោះរបស់នាងផ្ទាល់។ ដូច្នេះនាងបដិសេធមិនព្រមឱ្យកូននោះទៅគូស្វាមីភរិយា ដែលបានជួលនាងក៏មាន។ គូស្វាមីភរិយានោះត្រូវដាក់ពាក្យប្តឹងទៅតុលាការ។ ចៅក្រមបានឱ្យយកឈាមរបស់កូននោះ និងស្ត្រីដែលគេជួលនោះមកធ្វើតេស្ត ហើយឱ្យកូននោះទៅឪពុកម្តាយត្រឹមត្រូវវិញ។

ម្យ៉ាងវិញទៀត នៅពេលដែលស្ត្រីគេជួលនោះ បានទទួលប្រាក់ច្រើនសម្រាប់ការពផ្ទៃ និងសម្រាលកូនគេបែជាមានសេចក្តីលោភ ហើយសុខចិត្តពផ្ទៃកូនពីរ ឬបីនាក់របស់គូស្រករនោះៗក្នុងពេលតែមួយ។ ខ្ញុំបានអានកាសែតបានឃើញព័ត៌មានមួយគួរឱ្យភ្ញាក់ផ្អើលថា ស្ត្រីជនជាតិអ៊ីតាលីម្នាក់បានពផ្ទៃ កូនរបស់គូស្វាមីភរិយា៦នាក់ ក្នុងពេលដំណាលគ្នា។ ដោយសារស្បូនរបស់នាងមិនមានបន្ទប់គ្រប់គ្រាន់សម្រាប់ទារក៦នាក់ ទារកទាំងនោះត្រូវសម្រាលដោយការវះកាត់ ប្រហែលពីរខែមុនពេលត្រូវសម្រាល ហើយត្រូវបានចិញ្ចឹមដោយប្រដាប់ភ្ញាស់។ នៅពេល

ទារកនោះមានសុខភាពល្អស្រួលបួល គេឱ្យទារកទាំងនោះទៅឪពុកម្ដាយរបស់ពួកគេរៀងៗខ្លួន បន្ទាប់ពីបានធ្វើតេស្ដឈាមរួចហើយ។

**៦.ការបង្កាត់មនុស្ស**

ការស្រាវជ្រាវដ៏អស្ចារ្យ បានអនុវត្តដោយអ្នកវិទ្យាសាស្ត្រនៅពេលបច្ចុប្បន្នគឺការ "បង្កាត់" ដំណើរការថ្មីមួយនៃការផលិតកូន ដោយអលិង្គពីកោសិកាចេញពីរបស់ដើម។ ការបង្កាត់គឺជាដំណើរការមួយ ដើម្បីធ្វើការចម្លងជាក់ស្ដែងនៃរុក្ខជាតិ ឬក៏សត្វដោយការយកកោសិកាពីវា ហើយ អភិវឌ្ឍវាដោយសិប្បនិម្មិត។

នៅប្រទេសអង់គ្លេស អ្នកវិទ្យាសាស្ត្រទាំងឡាយបានបង្កាត់សត្វចៀមចំនួន ១៨ក្បាល ដោយជោគជ័យពីសត្វពពែឈ្មោះ ដូល្លី ។ សត្វចៀមទាំងអស់មានលក្ខណៈដូចមេរបស់ពួកវាបេះបិទ។

បន្ទាប់ពីបានទទួលជោគជ័យ ក្នុងការស្រាវជ្រាវទៅលើសត្វមក អ្នកវិទ្យាសាស្ត្រចង់បន្តធ្វើការស្រាវជ្រាវទៅលើមនុស្ស។ រដ្ឋាភិបាលជាច្រើន មិនលើកទឹកចិត្តឱ្យធ្វើការស្រាវជ្រាវនេះទេ ដោយខ្លាចក្រែងទទួលលទ្ធផលដែលមិនគួរឱ្យចង់បាន។ នៅក្នុងខែវិច្ឆិកា ឆ្នាំ២០០៤ ប្រធានសមាគមផ្សព្វផ្សាយពុទ្ធសាសនានៅ





ប្រទេសម៉ាឡេស៊ី បានស្នើខ្ញុំឱ្យធ្វើបាឋកថា "ស្ដីពីទស្សនៈព្រះអភិធម្ម លើការបង្កាត់មនុស្ស " នៅមហាវិហារពុទ្ធសាសនានៃទីក្រុងកូឡាឡាំពួរ ហើយខ្ញុំក៏បានយល់ព្រមជាមួយសេចក្ដីស្នើសុំនេះ។

យោងតាមទស្សនៈផ្នែកវិទ្យាសាស្ត្រ ការស្រាវជ្រាវលើសត្វ និងរុក្ខជាតិបានជោគជ័យ ក៏អាចធ្វើការស្រាវជ្រាវទៅលើមនុស្ស និងមនុស្សដែរ ហើយសត្វទាំងឡាយក៏មានប្រព័ន្ធសរីរៈដូចគ្នា។

យោងតាមទស្សនអភិធម្មវិញ ការបង្កាត់មនុស្សក៏នឹងអាចធ្វើបានជោគជ័យដូចជាការធ្វើទៅលើសត្វពពែឈ្មោះ ដូល្លី ដូច្នោះដែរ។ ហេតុផលគឺថា កម្មអាចបង្កើតបដិសន្ធិតាមរបៀប ៤ យ៉ាង ដូចខាង ក្រោម៖

**(១). ឧបបាតិក បដិសន្ធិ** កំណើតកើតឯង

កំណើតកើតឯងនេះ ប្រៀបបានដូចជាសត្វដែលគ្រប់អាយុត្រូវកើត។ ពួកព្រហ្ម ទេវតា សត្វនរក ប្រេត និងអសុរកាយ កើតឡើងមានវ័យលូតលាស់ធំតែម្ដងដោយពុំចាំបាច់ឆ្លងកាត់ការមានគ៌ភ ដូចដំណាក់កាលទារក ហើយពុំចាំបាច់មានឪពុកម្ដាយ ឬមេបាទេ។ នៅពេលដែលឧបត្ថម្ភកកម្មបង្កើតបាន

ជាវិបាកវិញ្ញាណរបស់ពួកសត្វទាំងនោះភ្លាម រួមជាមួយនឹងចេតសិក និងកម្មជរូប ពួកគេក៏កើតឡើងនៅកន្លែងលំនៅរបស់ពួកគេភ្លាមតែម្ដង ពោលគឺ ដូចជាវិមាន នៃទេវតា ព្រៃព្រឹក្សា ភ្នំ ឬក៏សមុទ្រជាដើម។ មនុស្សដំបូងបង្អស់នៅក្នុងលោក គឺកើតតាមរបៀបនេះឯង។ នាង **អម្ពបាលី** ស្រីពេស្យាដ៏ស្រស់ស្អាត នៅទីក្រុង វេសាលី ក៏បានកើតពីកំណើតដូច្នេះ ក្នុងសម័យពុទ្ធកាល។ សត្វត្រីក្នុងស្រះដែលមានស្តុកទឹកក្តៅនៅនិទាឃរដូវ ក៏ត្រូវកើតតាមរបៀបនេះដែរ។ ជនដែលបានទៅកើតជាទេវតា ឬប្រេតបន្ទាប់ពីស្លាប់ភ្លាម ក៏កើតដោយ ឧបបាតិកកំណើតដែរ។

រូបកាយរបស់ព្រហ្ម និងទេវតា ក៏មានផ្តុំឡើងដោយរូបជាតុ ដែលភាគច្រើនជាកម្មជរូប។ ដូច្នេះ គេមិនអាចមើលឃើញពួកព្រហ្ម និងទេវតានោះបានឡើយ ហើយនៅពេលពួកព្រហ្ម និងទេវតាស្លាប់ទៅ ក៏គ្មានសាកសពនៅដូចមនុស្សសត្វយើងធម្មតាទេ។ ពួកអ្នកវិទ្យាសាស្ត្រ ពុំទាន់បានដឹងកំណើតឧបបាតិកៈ នេះនៅឡើយ។

**(២)សំសេទជ បដិសន្ធិ** កំណើតចេញពីជាតុសើម

សត្វមូសពងដាក់ក្នុងថ្លុកដែលមានទឹកដក់ និងកន្លែង





សំណើម។ ពងនោះញាស់ទៅជាកូនដង្កូវ ដែលក្រោយមក ក៏ក្លាយទៅជាសត្វមូស។ សត្វកង្កែបក៏ពងនៅកន្លែងដែលមានទឹកដក់។ ពងនោះ ក៏ញាស់ទៅជាកូនក្អុក ដែលក្រោយមក ក៏ក្លាយទៅសត្វកង្កែប។ សត្វរុយពងដាក់លើម្ហូបដែលស្អុយផុយរលួយ និង សរីរាង្គពុកផុយ។ ពង ក៏ញាស់ទៅជាដង្កូវ បន្ទាប់មក ក៏ក្លាយទៅជាសត្វរុយ។ សត្វល្អិតភាគច្រើនបំផុត គឺកើតដោយកំណើតដូចនេះឯង។

ម្ចាស់ក្សត្រីយ៍ **បទុមវតី** កើតចេញពីក្នុងផ្កាឈូកដែលកំពុងរីក ចំណែកឯព្រះនាង **វេឡុវតី** កើតនៅក្នុងប្រហោងឫស្សី។ ការបង្កាត់ពូជសត្វ និងមនុស្សនឹងចាត់ចូលក្នុងប្រភេទសំសេទជៈ នេះឯង។

**(៣) អណ្ឌជ បដិសន្ធិ** កំណើតចេញពីស៊ុត

សត្វបក្សី និងមាន់កើតចេញពីស៊ុតក្នុងពោះមេរបស់វា។ ពួកវាជាសត្វដែលកើតចេញពីស៊ុតដែលមានសំបក។

**(៤). ជលាពុជ បដិសន្ធិ** កំណើតពីគ៌ភក្នុងផ្ទៃ

មនុស្ស និងសត្វតិរច្ឆានប្រភេទខ្លះកើតចេញពីផ្ទៃរបស់ម្តាយ។ ពួកគេកើតតាមសមគួរដល់ពេលវេលា ។ ភូមិទេវតា និងសត្វប្រេតខ្លះ ក៏កើតចេញពីផ្ទៃនៃមាតាដែរ។

ទាំង អណ្ឌជៈ និងជលាពុជកំណើតត្រូវបានចាត់ទុករួមគ្នាថាជា **គព្ភសេយ្យក** កំណើត [**គព្ភ** = ក្នុងផ្ទៃនៃមាតា+**សេយ្យក** = សត្វដែលដេក => **គព្ភសេយ្យក** សត្វដែលដេកក្នុងផ្ទៃនៃមាតា][៩]។

កម្ម គឺមានថាមពលខ្លាំងណាស់។ វាឱ្យផលរបស់វាជាវិបាកវិញ្ញាណចេតសិក សម្បយុត្តជាមួយនឹងកម្មជរូប ដែលអាចកើតជាសត្វដែលលូតលាស់ពេញលេញ ក្នុងឧបបាតិកកំណើត។ ឧបបាតិកកំណើត មិនចាំបាច់ត្រូវការសារធាតុផ្សំភ្ជាប់ជាមួយ ឬក៏កន្លែងសម្រាប់គ៌ភតោងយកឡើយ។

ដូច្នេះ ការបង្កាត់មនុស្សដែលនៅក្នុងនោះ កោសិការបស់ឪពុកម្ដាយមានមុខងារជាសារធាតុសំណុំ សម្រាប់ស្បូនឬគ៌ភតោងយក ក៏នឹងទទួលបានជោគជ័យ ដូចការបង្កាត់ទារកក្នុងបំពងសាក ដែលនៅក្នុងកោសិកាភេទរបស់ឪពុកម្ដាយ ដើរតួជាសារធាតុសំណុំភ្ជាប់គ្នាសម្រាប់ជាសមុដ្ឋាននៃការកើត។ ក៏ប៉ុន្តែ ការបង្កាត់មនុស្សគួរធ្វើដែរ ឬទេ?

ទេ!គេមិនគួរធ្វើវាទេ។ ជោគជ័យក្នុងការបង្កាត់មនុស្សនឹងត្រូវគេមើលឃើញថា ជាសមិទ្ធផលដ៏អស្ចារ្យ ផ្នែកវិទ្យាសាស្ត្រសម្រាប់រយៈពេលខ្លី។ បន្ទាប់មក វាត្រូវបានគេចាត់ទុកថា ជា





សមិទ្ធផលធម្មតា។ ប្រសិនបើ មនុស្សជាច្រើនត្រូវបានផលិតចេញតាមរោចក្របង្កាត់មនុស្សៗនឹងក្លាយទៅជាទំនិញ ឬរបស់របរថោក។ តម្លៃរបស់មនុស្ស សេចក្ដីថ្លៃថ្នូររបស់មនុស្ស និងការប្រៀនប្រដៅរបស់អ្នកអាទិទេពនិយម នឹងត្រូវធ្វើឱ្យវិនាសបាត់សូន្យឈឹង។

យើងមិនអាចរំពឹងចង់បានកូន ដែលផលិតដោយការបង្កាត់ឱ្យមាន បញ្ញា ដូចជាបញ្ញារបស់ម្ដាយ ឬឪពុករបស់ពួកគេបានទេ។ គេអាចដូចឪពុកម្ដាយរបស់គេដោយលក្ខណៈ និងអាការៈ ប៉ុន្តែមិនមែនប្រាជ្ញាទេ។ រាល់សត្វទាំងអស់ត្រូវបានតាក់តែងដោយកម្មរបស់ខ្លួនផ្ទាល់ វាមានកម្មរបស់វាជាហេតុ មេបា ឬឪពុកម្ដាយ និងពំនឹង។

កូនៗត្រូវការសេចក្ដីស្រលាញ់ថ្នាក់ថ្នម ពីឪពុកម្ដាយរបស់ពួកគេ។បើគ្មានសេចក្ដីស្រលាញ់ថ្នាក់ថ្នមពីសំណាក់ឪពុកម្ដាយរបស់គេទេ ពួកគេនឹងក្លាយទៅជាខុសប្រក្រតី។ ហើយពិភពលោកពោរពេញទៅដោយមនុស្សស្រាប់ ហើយប្រទេសមួយចំនួនត្រូវអនុវត្តការពន្យាកំណើត ។ ប្រសិនបើប្រទេសមួយនោះ ត្រូវការមនុស្សថែមទៀត សូមឱ្យរៀបការគូស្វាមីភរិយាបង្កើតនូវកូនជាទីស្រលាញ់របស់ខ្លួនដោយសេរី ហើយចិញ្ចឹម

បីបាច់ថែរក្សាកូននោះ ដោយសប្បាយរីករាយតាមធម្មតា។ សុភមង្គលរបស់មនុស្ស និងសុភមង្គលរបស់គ្រួសារភាគច្រើន ស្ថិតនៅលើការរួបរួមគ្រួសារ។

## ឯកសារយោង


1 Nãrada Mahã thera. the Buddha and His Teaching ; published by Singapore Buddhist Meditation Centre, p.224.
2 Ibid, p.224
3 Ibid, p.224
4 Larousse, Desk Reference Encyclopedia, Great Britain, pp. 58,60. 62.
5 Dr. K. Sri Dammananda , "Why we should practise Buddhism", Buddhist Missionary Society Malaysia. p. 15.
6 The Columbia Viking Desk Encyclopedia, New YorK p. 321.
7 Ibid, p. 957.
8 Dr. Mehm Tin Mon, " Scientific Evidence for Past Existence and Future Existences", p. 23
9 Ashin Janakãbhivamsa. "Abhidhamma in Daily life," SBVMS Publication, p. 243-245.




# ២

## ល្បងប្រាជ្ញាជីវិតដ៏ស៊ីជម្រៅ និងល្អិតសុខុម

### ១. តើជីវិតអាចកើតចេញពីរូប បានដែរឬទេ?

នៅពេលដែលការបង្កាត់សត្វធ្វើបានជោគជ័យ ការបង្កាត់មនុស្សក៏បានទទួលជោគជ័យដែរ ហើយត្រូវបានពិភាក្សាដោយហេតុផលតាមទស្សនៈព្រះអភិធម្ម នៅជំពូកចុងក្រោយ។ ប៉ុន្តែពួកអ្នកវិទ្យាសាស្ត្រ នឹងពិបាកស្វែងយល់ថា ហេតុអ្វីបានជាបានជោគជ័យ។ ដោយសារគេទទួលយកទ្រឹស្តីថា " ជីវិតទាំងអស់កើតចេញពីជីវិត " តើគេនឹងពន្យល់ថា សត្វមានជីវិតកើតចេញពីកោសិកា ដែលតាមពិតទៅជារូបធាតុឥតជីវិតដូចម្តេចកើត?

ការបង្កើតទារកក្នុងបំពង់សាកពី អូវុល របស់ម្តាយ ដែលបង្កកំណើតដោយ កោសិកាភេទ របស់ឪពុកហៅថា ស្ពឺម នោះកោសិកាទាំងពីរ ក៏ជារូបធាតុឥតជីវិតដែរ។ ម្យ៉ាងទៀត ពួកអ្នកវិទ្យាសាស្ត្រ ក៏នឹងឈ្ងេងយល់ថា វាពិបាកដើម្បីពន្យល់ពីរបៀប

ដែលទារកមានជីវិតកើតចេញពីកោសិកាពីរ ដែលជារូបធាតុនោះ ណាស់។

## ២. ទ្រឹស្តីពន្ធុ

នៅក្នុងរដូវលំអងផ្កាពោយ ពិភពរុក្ខជាតិឥតជីវិតរាង លំអងផ្កាឈើ និងស្លាកស្នាមបង្កើតបានជាពូជ ដែលបង្កើតបាន ជារុក្ខជាតិ ដូចគ្នាទៅនឹងរុក្ខជាតិមេ ក្នុងពេលវេលាសមរម្យ រុក្ខជាតិថ្មីនោះនឹងចេញផ្លែដូចគ្នានឹងរុក្ខជាតិមេដែរ។ ប៉ុន្តែនៅក្នុង ពិភពមនុស្ស កូនប្រុសស្រី ដូចឪពុកម្តាយរបស់គេតាមលក្ខណៈ អាការៈមួយចំនួនប៉ុណ្ណោះ ហើយកូនខ្លះខុសពីឪពុកម្តាយរបស់ ពួកគេទាំងស្រុង។ ឪពុកម្តាយមានពណ៌សម្បុរត្នោត សក់ពណ៌ ខ្មៅ ភ្នែកពណ៌ខ្មៅ ចំណែកកូនប្រុសស្រីមានសម្បុរស សក់ពណ៌ មាស និងភ្នែកពណ៌ខៀវ ដូចក្មេងជនជាតិអង់គ្លេស។ ពន្យល់ រឿងនេះ ជាមួយទ្រឹស្តីពន្ធុដូចម្តេច?

យោងទៅតាមទ្រឹស្តី **ពន្ធុ** កោសិកាអាចផលិតចេញពី ប្រភេទកោសិកាដូចគ្នា។ នៅក្នុងពេលពផ្ទៃ អាំប្រ៊ីយ៉ុង ចាប់ផ្តើម ជាមួយកោសិកាតែមួយពោលគឺអូវុល ដែលជាអ្នកបង្កកំណើត ។ នៅពេលដែលកោសិកាលូតលាស់ទៅជាទារក កោសិកា ថ្មីផ្សេងៗ





ជាច្រើនត្រូវបានបង្កើតឡើង។ តើគេអាចពន្យល់ករណីនេះដូច ម្តេច?

ដូចគ្នានេះដែរ ប្រសិនបើ " **អាដាម** " ជាមនុស្សដែលត្រូវ បង្កើតឡើងដំបូង មានពណ៌សម្បុរស សក់ពណ៌មាស នឹងភ្នែក ពណ៌ខៀវ, តើយើងអាចរៀបរាប់ពីការកើតឡើងនៃជនជាតិចិន និង ជនជាតិជប៉ុន ដែលមានសម្បុរលឿង សក់ និងភ្នែកពណ៌ ខ្មៅដូចម្តេច? ជនជាតិភូមា ថៃ ម៉ាឡេ និង ឥណ្ឌូនេស៊ី ដែល មានសម្បុរត្នោត សក់ និង ភ្នែក មានសម្បុរខ្មៅ សក់ខ្មៅរួញ និង ភ្នែកពណ៌ខ្មៅ ត្រូវពន្យល់ដូចម្តេច?

ក្នុងករណីដែលកូនភ្លោះមានរាងដូចគ្នាគេពន្យល់ថា អូវុល ឬស៊ីកូត ដែលបង្កកំណើតបំបែកទៅជាកោសិកាពីរ ហើយ កោសិកាពីរនោះ អភិវឌ្ឍដោយឡែកពីគ្នា ដើម្បីបង្កើតទារកពីរ ។ ប៉ុន្តែ ទារកដែលដូចគ្នានេះ ខុសគ្នាខាងលទ្ធភាពផ្លូវចិត្ត ដូចជា ចរិត ចំណាប់អារម្មណ៍ ប្រាជ្ញា ទេពកោសល្យ សំណាង និង វាសនា។ ពួកអ្នកវិទ្យាសាស្ត្រ មិនអាចផ្តល់ការពន្យល់ពេញចិត្ត សម្រាប់ភាពខុសគ្នានេះបានទេ។

*បញ្ហាដែលធ្ងន់ធ្ងរបំផុតនោះ គឺត្រូវផ្តល់ហេតុ*
*ផលឱ្យពេញចិត្តសម្រាប់ការកើតឡើងនៃ **ចិត្ត** និង*

***ជីវិត*** *ចេញពីរូបគឺថា កោសិការសេរីរាង្គទាំងពីរឱ្យឈ្មោះថាកោសិកា* ***អូវុល*** *និងកោសិកា* ***ស្ពែម៉ាតូសូអ៊ីត****។ពួកអ្នកវិទ្យាសាស្ត្រនៅស្ងៀមលើបញ្ហានេះ ។*

មិនបាច់និយាយថ្វីដល់ទៅការបង្កើតចិត្តចេញពីរូបទេ អ្នកវិទ្យាសាស្ត្រពិតជាមិនដឹងអ្វីទៅជា" **ចិត្ត** "។ ចិត្ត គឺជានាមធម៌ដែលមាន **ចិត្ត** និង **ចេតសិក**។ តាមពិតអ្នកវិទ្យាសាស្ត្រ មិនបានដឹងលក្ខណៈពិតរបស់ ចិត្ត និង ចេតសិក ហើយនិង របៀបដែលចេតសិក មានឥទ្ធិពលទៅលើចិត្ត ឱ្យទៅជាកុសល និង មានបញ្ញា ឬឱ្យទៅជាអាក្រក់ និងបំផ្លិចបំផ្លាញបំផុតនៅក្នុងលោក។

នៅពេលគេមិនបានដឹងពីលក្ខណៈ និងកិច្ចរបស់ **នាម** គេមានទំនោរទៅរកការស្មានថា ខួរក្បាលធ្វើតួនាទីជាចិត្ត។ នេះនឹងធ្វើឱ្យរឿងរ៉ាវកាន់តែអាក្រក់ឡើងៗសម្រាប់ខួរក្បាលនោះ គឺគ្រាន់តែជារូបធាតុ ហើយវាមិនដឹងថាអ្វីទៅល្អ អ្វីទៅអាក្រក់ទេ, អ្វីទៅត្រូវ អ្វីទៅខុសទេ និងអ្វីទៅជាគោលបំណង ដ៏ប្រសើរនៅក្នុងជីវិត។

ទ្រឹស្តីខួរក្បាល នឹងរាំងស្ទះដល់ការលូតលាស់របស់មនុស្ស និងការអភិឌ្ឍន៍ផ្លូវចិត្តឆ្ពោះទៅរកភាពប្រសើរបំផុត ដើម្បីសោយសេចក្តីសុខស្ងប់ជារៀងរហូត។ ដូច្នេះ ជារឿងសំខាន់ណាស់





ដើម្បីយល់ដឹងឱ្យបានច្បាស់ពីរបៀប ដែលចិត្តគ្រប់គ្រងជោគវាសនារបស់បុគ្គលម្នាក់ៗតាមរយៈកម្មជាមរតក។

### ៣. អតីតភព និង អនាគតភព

តាមពិតទៅ គឺអស្ចារ្យណាស់ ដែលអ្នកវិទ្យាសាស្ត្រអាចធ្វើការសិក្សាជាប្រព័ន្ធទៅលើមូលដ្ឋាននៃការបង្កើត ហ្វូស៊ីល វិទ្យុសកម្មកាបោន។ល។ និងផ្តល់នូវការទស្សទាយដ៏ល្អទៅលើអាយុផែនដីរបស់យើង និងការវិវត្តនៃជីវិតតាមដំណាក់ផ្សេងៗឆ្លងកាត់តាមប្រវត្តិសាស្ត្រ។ ក៏ប៉ុន្តែ ពួកគេមិនអាចសិក្សាអំពីអតីតជាតិរបស់សត្វមានជីវិតនីមួយៗបាន ហើយគេក៏មិនអាចមាន មធ្យោបាយ ដើម្បីសិក្សាពីអនាគតជាតិរបស់បុគ្គលបានដែរ។

ម្យ៉ាងវិញទៀត ពួកអ្នកវេទនិយម សម្តែងថា ព្រះអាទិទេពបង្កើតអ្វីៗគ្រប់យ៉ាង ដឹងអ្វីៗគ្រប់យ៉ាង និងគ្រប់គ្រងអ្វីៗគ្រប់យ៉ាង ក៏មិនបាននិយាយអ្វីសោះអំពីអតីតជាតិ ដែលតរាប់មិនបានរបស់បុគ្គល ព្រោះគេមិនអាចដឹងនូវជាតិដូច្នោះបានឡើយ។ នៅក្នុងលទ្ធិវេទនិយម មិនមានអនាគតជាតិជាក់ស្តែង បន្ទាប់ពីស្លាប់ឡើយ ព្រោះបុគ្គលនីមួយៗត្រូវរង់ចាំនៅផ្នូរសម្រាប់ថ្ងៃវិនិច្ឆ័យ។

ដោយសារអ្នកវិទ្យាសាស្ត្រជឿថា មនុស្សកើតឡើងពីការផ្សំនៃ ស្ពឹម និង អូវុល របស់ឪពុកម្តាយ នាំឱ្យមិនមានអតីតភព

ក្នុងជំនឿបែបនេះទេ។ ហើយក៏មិនមានអនាគតភពបន្ទាប់ពីសេចក្ដីស្លាប់ដែរ។ ដោយសារមនុស្សម្នាក់ៗ អាចរស់នៅសម្រាប់តែមួយជាតិ ហើយអំពើល្អ និង អាក្រក់នឹងមិនឱ្យផលណាមួយបន្ទាប់ពីបច្ចុប្បន្នជាតិ បុគ្គលនោះឯង នឹងមិនខ្វល់ធ្វើនូវអំពើជាកុសល ដូចជា ការឱ្យទាន រក្សាសីល និងការប្រតិបត្តិភាវនា ជាដើម។ បុគ្គលនោះព្យាយាមគ្រាន់តែដើម្បីសប្បាយជាមួយកាមគុណឱ្យបានច្រើនតាមតែអាចធ្វើទៅបាន។ ការរស់នៅប្រភេទនេះ នឹងមិននាំទៅរកសេចក្ដីសុខពិតប្រាកដក្នុងពេលបច្ចុប្បន្ន ហើយនឹងនាំទៅរកកំណើតក្នុងអបាយភូមិ បន្ទាប់ពីស្លាប់ទៅ។ ដូច្នោះ វានឹងក្លាយទៅជាការបាត់បង់ដ៏សម្បើមចំពោះគាត់។

នៅក្នុងពុទ្ធសាសនា និងសាសនាហិណ្ឌូ មាននិយាយពាក្យថា"សំសារៈ"(វិលកើតវិលស្លាប់)។ ចំនួននៃអតីតជាតិរបស់សត្វនីមួយៗមានច្រើនរាប់មិនអស់ ហើយសត្វទាំងនេះ នឹងរស់នៅពីជីវិតមួយទៅជីវិតមួយ ក្នុងអនាគត រហូតដល់ពេលបុគ្គលនោះត្រូវរួចរំដោះចេញពីសេចក្ដីទុក្ខក្នុង**សំសារៈ**។

មានភ័ស្តុតាងជាក់ច្បាស់ ដើម្បីបង្ហាញថា បុគ្គលនីមួយៗបានរស់នៅក្នុងអតីតកាលពីមុនរហូតដល់ជាតិនេះ ហើយបុគ្គលនោះឯងនឹងកើតក្នុងជាតិក្រោយទៀត បន្ទាប់ពីស្លាប់ទៅ។ ភ័ស្តុ-





តាងទាំងនេះ គេមិនអាចបដិសេធចោល ហើយគេមិនគួរមិនអើពើនោះឡើយ។ ការពន្យល់មានហេតុផលសម្រាប់ភពតទៅទៀតរបស់បុគ្គលនីមួយៗ គេគប្បីឈ្វេងយល់ ហើយការរៀបចំប្រសើរបំផុតគប្បីធ្វើឡើងដើម្បីយើងអាចរស់នៅដោយសុខសប្បាយ រុងរឿងគ្រប់អនាគតជាតិ តទៅមុខទៀត។

៣

# ភ័ស្តុតាងសម្រាប់អតីតជាតិ

ខ្ញុំបានប្រមូលភ័ស្តុតាងលក្ខណៈវិទ្យាសាស្ត្រច្បាស់លាស់ជាច្រើន ដើម្បីបង្ហាញថា ពិតជាមានអតីតជាតិ និងអនាគតជាតិរបស់បុគ្គលនីមួយៗ ក្នុងសៀវភៅរបស់ខ្ញុំដែលមានចំណងជើងថា "ភ័ស្តុតាងនៃវិទ្យាសាស្ត្រសម្រាប់អតីតជាតិ និង អនាគតជាតិ"។ ដោយសារមានអ្នកចាប់អារម្មណ៍សៀវភៅនេះជាច្រើន ទើបសៀវភៅនេះ ត្រូវបានបោះពុម្ពលើកជាភាសាភូមា។ អ្នកដែលចាប់អារម្មណ៍ អាចអានយ៉ាងពិស្តារអំពីអតីត និង អនាគតជាតិរបស់បុគ្គល ដែលគួរឱ្យកត់សម្គាល់មួយចំនួន នៅក្នុងសៀវភៅនោះ។ ក្នុងទីនេះ ខ្ញុំនឹងរៀបរាប់ភ័ស្តុតាងទាំងនោះដោយសង្ខេប ប៉ុន្តែចំសេចក្តី ដើម្បីធ្វើឱ្យរឿងរ៉ាវច្បាស់ឡើង។

ភ័ស្តុតាងខាងក្រោម គាំទ្រដល់អត្ថិភាពពិតនៃជីវិតទាំងឡាយក្នុងអតីតកាល។





១.មានបុគ្គលចាំជាតិរបស់ខ្លួននៅពាសពេញពិភពលោក។

២.ក្មេងមានទេពកោសល្យ មាននៅពេញពិភពលោក។

៣.គេអាចចាំអតីតជាតិបាន នៅពេលគេចាស់ទៅៗតាមរយៈវិធីសណ្តំ

៤.គេអាចដឹងអតីតជាតិ តាមរយៈអភិញ្ញា

៥.គេអាចដឹងអតីតជាតិ ដោយការប្រតិបត្តិវិបស្សនាកម្មដ្ឋាន

## ១.បុគ្គលដែលចាំអតីតជាតិ

មានបុគ្គលទូទាំងសកលលោក ដែលអាចចាំអតីតជាតិរបស់ខ្លួនយ៉ាងត្រឹមត្រូវ។ នៅក្នុងពុទ្ធសាសនានិយាយថា បុគ្គលទាំងនេះសម្រេចបាននូវបញ្ញាហៅថា"**ជាតិស្សរញាណ**"។ បុគ្គលទាំងឡាយ ដែលចង់បានបញ្ញាប្រភេទនេះ អាចធ្វើឱ្យសម្រេចសេចក្តីប្រាថ្នារបស់ខ្លួននៅពេលគេធ្វើកុសលកម្មនានា។ បុគ្គលល្បីល្បាញពីរនាក់ ដែលសម្រេចបានបញ្ញាបែបនេះ ដែលឥឡូវកំពុងរស់នៅទីក្រុងយ៉ាំងហ្គូន គឺលោកបណ្ឌិត **តា ហ្លាក់**( Dr.Tha Hla ) និង **អ៊ូ អេ ណៃង** ( Dr.U Aye Naing )។

( ១ ). លោកបណ្ឌិត **តា ហ្លាក់** ( Dr.Tha Hla ) គឺជាអ្នក

ឯកទេសខាងពាក់ស្បែក និងជាសាស្ត្រាចារ្យចូលនិវត្តន៍នៃវិទ្យាស្ថានវេជ្ជសាស្ត្រ។ ក្នុងអតីតជាតិ គាត់គឺជាក្រមុំសៅកែមានឈ្មោះថា **ឌ័រ ស្វេ ម៉ៃ** (Daw Shwe Mai )។ **ឌ័រ ស្វេ ម៉ៃ** បានបរិច្ចាគដីស្រែរបស់នាង ផ្ទះសម្បែង និងទ្រព្យសម្បត្តិរបស់នាង ប្រគេនដល់វត្តអារាម ហើយធ្វើសេចក្តីប្រាថ្នាឱ្យបានក្លាយទៅមនុស្សមានប្រាជ្ញាក្នុងជាតិក្រោយ។ បំណងប្រាថ្នារបស់នាងត្រូវបានសម្រេច ។ សូម្បីតែស្នាមស្លាកភ្លើងនៅលើទ្រូងរបស់ ឌ័រ ស្វេម៉ៃ ក៏ត្រូវបានផ្ទេរមកជិតជាប់លើទ្រូងរបស់បណ្ឌិត **តា ហ្លាក់**ដែរ(១)។

(២). **អ៊ូ អេ ណៃង**(Dr. U Aye Naing) ជាជំនួយការនាយកចូលនិវត្តន៍ និងជាទីប្រឹក្សាក្រសួងធម្មការ។ គាត់អាចចាំអតីតជាតិរបស់គាត់ថា ជាប្រធានជាតិការ៉ែន, **អ៊ូ នេ ជ័រ**(U Nay Gyaw) និង គ្រួសាររបស់គាត់យ៉ាងពិស្តារ។ គាត់ថែមទាំងចាំបាននូវផ្ទាំងដី ដែល **អ៊ូ នេ ជ័រ** ដាក់កាក់មាសប្រាក់កប់នៅក្នុងដីក្រោមដើមស្វាយ។ កាលមានអាយុ ៣ ឆ្នាំ **អ៊ូ អេ ណៃង** បានដើរទៅកាន់ផ្ទះចាស់ពីមុនរបស់គាត់ ហើយបានប្រាប់អតីតកូនប្រុសស្រីរបស់គាត់ឱ្យជីកយកផ្ទាំងនោះ។ ពួកគេជីកយកបានវា ហើយជឿថា កូនប្រុសនោះពិតជាឪពុករបស់ខ្លួនមែន។ គាត់បានទៅលេងអតីតគ្រួសាររបស់គាត់ជារៀងរាល់ឆ្នាំ(២)។





(៣). បណ្ឌិត **អៀន ស្ទើវិនសិន** (Dr.Ian Stevenson) សាស្ត្រាចារ្យ មកពីសាកលវិទ្យាល័យ វឺជីនីញ៉ា សហរដ្ឋអាមេរិក បានធ្វើការស្រាវជ្រាវទូទាំងពិភពលោក ទៅលើមនុស្សដែលអាចប្រាប់ពីអតីតជាតិរបស់ពួកគេ។ បន្ទាប់ពីបានធ្វើការសិក្សាប្រហែលមួយពាន់ករណី, ហើយបានធ្វើការបោះពុម្ពសៀវភៅជាច្រើន តាមការស្រាវជ្រាវរបស់គាត់មក គាត់បានសន្និដ្ឋានថា ក្មេងៗដែលគាត់បានពិនិត្យសង្កេតទាំងនោះ អាចប្រាប់យ៉ាងត្រឹមត្រូវអំពីអតីតជាតិរបស់ខ្លួន(៣)។

(៤). នៅមីយ៉ាន់ម៉ា (ភូមា) ភាគកណ្តាលក្នុងភូមិមួយឈ្មោះ **អ៊ិន ពីន ហ្លាក់** នៅសង្កាត់ **តាហ្គូន** មានកូនក្មេងស្រីម្នាក់កើតមកមានដុំសាច់ពកពីរនៅលើក្បាលរបស់ខ្លួនដូចជាស្នែងក្របី។ នាងឈ្មោះ **ម៉ា ហ្តេ** (Ma Htay) នៅពេលនាងអាចនិយាយបានច្បាស់ នាងបាននិយាយ អំពីអតីតជាតិ ២ដងរបស់នាង។

ក្នុងអតីតជាតិទី១របស់នាងៗឈ្មោះ **ឌ័រ ម៉្វាក់** នៅភូមិ **ញ៉េងប៊ីន ជី**។ **ឌ័រ ម៉្វាក់** បានជួល **ម៉ា តេងទីន** និងម្តាយរបស់នាងឱ្យធ្វើការនៅក្នុងស្រែរបស់នាង។ **ម៉ា តេងទីន** ទើបតែមានអាយុ១៣ឆ្នាំ ប៉ុន្តែនាងមានរាងខ្ពស់មាំ។ ដូច្នេះ ម្តាយរបស់នាងបណ្តោយឱ្យនាងធ្វើការដូចមនុស្សពេញវ័យដែរ។ ប៉ុន្តែនៅពេល

**ឌរ ម៉្វាក់** ឱ្យប្រាក់ថ្លៃឈ្នួលដល់ពួកគេ នាងឱ្យ **ម៉ា តេងទីន** តែថ្លៃពាក់កណ្ដាលនៃតម្លៃមនុស្សពេញវ័យ ដោយនិយាយថា **ម៉ា តេង ទីន** ជាកូនក្មេង។ ម្ដាយរបស់ **ម៉ា តេង ទីន** បាននិយាយអង្វរថា "យើងជាអ្នកក្រីក្រ ដូច្នេះហើយ ទើបខ្ញុំបណ្ដោយឱ្យកូនខ្ញុំធ្វើការដូចមនុស្សពេញវ័យ ដើម្បីទទួលបានប្រាក់ឈ្នួលរបស់មនុស្សពេញវ័យ ដូច្នេះ សូមមេត្តាផ្ដល់ឱ្យនាងនូវប្រាក់ឈ្នួលដូចមនុស្សពេញវ័យ។ **ឌរ ម៉្វាក់** បដិសេធមិនព្រមឱ្យថ្លៃឈ្នួលនោះទេ។ នោះជាការបោកប្រាស់ថ្លៃឈ្នួលពាក់កណ្ដាលរបស់ **ម៉ា តេង ទីន**។ ដូច្នេះ នៅពេល**ឌរ ម៉្វាក់** បានស្លាប់ទៅ នាងបានទៅចាប់កំណើតនៅក្នុងផ្ទៃនៃក្របីរបស់ **ម៉ា តេងទីន**។ នាងកើតជាក្របីញី កើតកូនបាន៣ក៏ស្លាប់ទៅ។ នៅពេលយប់មុនពេលស្លាប់ **ម៉ា តេនទីន** សុបិនថា ក្របីញីនោះមករកនាងហើយឱ្យសាច់ដល់នាង។ **ម៉ា តេងទីន** មានគភ៌ ហើយសម្រាលកូនបាន ***ម៉ា ហ្វៃ*** ដែលមានសាច់ពកដុះឡើងពីរដូចស្នែងនៅលើក្បាល ដើម្បីចង្អុលបង្ហាញថាអតីតជាតិរបស់នាងគឺជាក្របី។ **ម៉ា ហ្វៃ** បានចាំកូនក្របីឈ្មោលទាំង៣របស់នាងក្នុងអតីតជាតិ ហើយទួញសោកស្រក់ទឹកភ្នែកចំពោះកូនទាំង៣នោះ។ បណ្ឌិត **អៀន ស្ដេវិនសិន** បានមកប្រទេសមីយ៉ាន់ម៉ា ដើម្បីពិនិត្យសង្កេតលើករណីនេះ(៤)។





(៥). **សានទី ទេវី** (Shanti Devi) កើតនៅក្នុងក្រុង ញូវ-ដេលី ប្រទេសឥណ្ឌាឆ្នាំ១៩២៦។ កាលនាងមានអាយុ ៣ ឆ្នាំ នាងបានប្រាប់ ឪពុកម្ដាយរបស់នាងថា នាងមានប្ដីឈ្មោះ **កទនាថ ចៅប៊ី** (Kandanath Chaubi) ជាឈ្មួញក្រណាត់ នៅ**មុទ្រៈ**។ នាងនិយាយថា នាងជាប្រពន្ធរបស់គាត់ឈ្មោះ **លុតឌី** ក្នុងអតីតជាតិ ហើយថា **លុតឌី** បានស្លាប់១០ថ្ងៃ បន្ទាប់ពីសម្រាលបានកូនប្រុសមួយ។

ដោយសារនាងបាននិយាយរឿយៗ អំពីអតីតជាតិរបស់នាង ឪពុករបស់នាងបានសរសេរសំបុត្រមួយថ្លែងទៅកាន់ " **កទ-នាថ ចៅប៊ី** " (Kandanath Chaubi)។ ប្រហែល១សប្ដាហ៍ក្រោយមក មានសំបុត្រមួយឆ្លើយតបមកពី កទនាថ ចៅប៊ីថា តាមពិតទៅ **លុតឌី** គឺជាប្រពន្ធរបស់គាត់មែន ហើយនាងស្លាប់១០ថ្ងៃបន្ទាប់ពីសម្រាលកូនប្រុសមួយ។ គាត់ក៏សុំការអនុញ្ញាតឱ្យគាត់បានឃើញ **សានទី ទេវី** ។ ពីរបីថ្ងៃក្រោយមក ខណៈពេលដែល **សានទី** កំពុងលេងនៅខាងមុខផ្ទះ នាងបានរត់ចូលទៅក្នុងបន្ទប់គេងភ្លាម។ នៅពេលម្ដាយនាងសួរ នាងឆ្លើយថា ប្ដីមុនរបស់នាង គឺឈរនៅច្រកទ្វារ។ គឺ **កទនាថ ចៅប៊ី** ហ្នឹងឯង នៅពេលអ្វីទាំងអស់ដែល **សានទី** បាននិយាយគឺជាការពិត ឪពុករបស់នាង

បានផ្តល់ពត៌មានដល់ផ្នែកស្រាវជ្រាវថា កូនស្រីរបស់គាត់អាចចាំអតីតជាតិរបស់នាងបានយ៉ាងច្បាស់។ គេបានរៀបចំដំណើរមួយទៅយក **សានទី ទេវី** ទៅមុទ្រ:។

នៅកន្លែងស្ថានីយ៍មុទ្រ: **សានទី** បានធ្វើបដិសណ្ឋារកិច្ចពួកញាតិពីមុនរបស់នាង តាមឈ្មោះ។ គេដាក់នាងក្នុងរទេះ..... ហើយសុំឱ្យប្រាប់ទិសដៅទៅកាន់ផ្ទះពីមុនរបស់នាង។ **សានទី** បានផ្តល់ប្រាប់ទិសដៅត្រឹមត្រូវ។ នាងនៅតែអាចចាំផ្ទះនោះបាន ទោះបីគេគូពណ៌ខុសពីមុនក៏ដោយ។

មុនពេលដើរចូលទៅក្នុងផ្ទះ អ្នកស្រាវជ្រាវបានសួរ **សានទី** អំពីបន្ទប់ និងគ្រឿងសង្ហារឹមនានានៅក្នុងបន្ទប់នីមួយៗ។ គេរកឃើញថា ពិតនូវអ្វីដែលនាងបាននិយាយ។ នៅពេលកំពុងអង្គុយ **សានទី** បាននិយាយថានាង(លុតឌី) បានកប់កាក់ប្រាក់ចំនួន ១០០ នៅជ្រុងមួយនៃបន្ទប់នោះ។ អ្នកស្រាវជ្រាវបានជីកយកដោយរីករាយ ប៉ុន្តែរកលុយនោះមិនឃើញទេ។ ពេលនោះ **កទនាថ ចៅប៊ី** បានសុំទោសពួកគេថា គាត់បានជីកយកលុយនោះពីមុនរួចហើយ[៥]។

អ្នកអានអាចធ្វើការស្រាវជ្រាវផ្ទាល់ខ្លួន ព្រោះក្មេងៗដែលចាំជាតិអាចមាននៅគ្រប់ក្រុង គ្រប់ភូមិ។





## ២.ទេពកោសល្យផ្សេងៗរបស់ក្មេង មានពាសពេញសកលលោក

(១).ក្មេងអច្ឆរិយនៅប្រទេសអង់គ្លេសឈ្មោះ **គ្រីស្ទៀន ហេនីកែន**(Christian Heineken) អាចនិយាយក្នុងពេល២ឬ៣ម៉ោងបន្ទាប់ពីកើត។ គាត់អាចនិយាយតាមអត្ថបទគម្ពីរបាយបល (Bible)នៅអាយុ១ឆ្នាំ។ គាត់អាចឆ្លើយសំណួរណាមួយក៏បានអំពីភូគព្ភសាស្ត្រនៅអាយុ២ ឆ្នាំ។ គាត់អាចនិយាយភាសាបារាំង និង ភាសាឡាតាំងនៅអាយុ៣ឆ្នាំ។ គាត់ក្លាយជានិស្សិតផ្នែកទស្សនវិជ្ជា នៅអាយុ ៤ ឆ្នាំ។ គាត់អាចចាំនូវចំណេះដឹង ដែលគាត់បានរៀនក្នុងអតីតជាតិរបស់គាត់បានយ៉ាងច្បាស់[៦]។

(២). **វិលលៀម ជេម ស៊ីដីស**(William JamesSidis) ជាក្មេងអច្ឆរិយរបស់សហរដ្ឋអាមេរិក អាចអាន និងសរសេរនៅអាយុ២ឆ្នាំ ។ គាត់អាចនិយាយភាសា បារាំង រុស្សី អង់គ្លេស អាល្លឺម៉ង់ ព្រមទាំងភាសាឡាតាំង និងភាសាក្រិចខ្លះៗនៅអាយុ ៨ឆ្នាំ។

(៣). **ម៉ាកូឡេ** (Macaulay) នៅប្រទេសអង់គ្លេស អាចសរសេរប្រវត្តិសាស្ត្រពិភពលោកនៅអាយុ៦ឆ្នាំ។ គាត់ពិតជាបានសិក្សាប្រវត្តិសាស្ត្រពិភពលោក ក្នុងអតីតជាតិរបស់គាត់[៦]។

(៤). **ជិន ជិន** (Jen Jen) នៅសាធារណរដ្ឋប្រជានិត

ចិន យល់ភាសាចិន និងភាសាអង់គ្លេស នៅពេលគាត់មានអាយុ ១៨ខែ,គាត់អាចនិយាយភាសាទាំងពីរនេះនៅអាយុ២ឆ្នាំ។ គាត់អាចអានភាសាអង់គ្លេស និងភាសាចិននៅអាយុ៣ឆ្នាំ។ គាត់រៀនគណិតវិទ្យានៅវិទ្យាល័យ វូហាន នៅអាយុ៤ឆ្នាំ ជានិស្សិតដែលនៅក្មេងបំផុត ក្នុងឆ្នាំ១៩៨៥(៧)។

(៥). **ម៉ា ហ្លាក់ជី** (Ma Hla Gyi) នៅប្រទេសមីយ៉ាន់ម៉ា ក្នុងឆ្នាំ ១៩៥៤ អាចអានភាសាបាលី និងយល់អត្ថន័យបាននៅអាយុ៦ឆ្នាំ ។ នាងចាំអតីតជាតិរបស់នាងថា កាលពីមុននាងជាព្រះថេរពហុសូត្រ មួយអង្គ។

(៦).មានក្មេងប្រុសម្នាក់ទៀត នៅប្រទេស មីយ៉ាន់ម៉ា ឈ្មោះ **បិដក ម៉ោង ទុន ចែង** (Pitaka Maung Tun Kyaing) ព្រោះគាត់អាចសូត្របិដកបាលីបានយ៉ាងច្រើន នៅអាយុ៦ឆ្នាំ។ គេបានអញ្ជើញគាត់ទៅស្រុកភូមិជាច្រើនដើម្បីឱ្យសូត្របិដកបាលីនៅក្នុងពិធីសូត្រធម៌។ គាត់ជាភិក្ខុពហុសូត្រមួយអង្គកាលពីអតីតជាតិ។ ដោយសារគាត់ចាំបិដកបាលី ក្នុងបច្ចុប្បន្នជាតិនេះ គាត់អាចសូត្របាលីបានដោយពុំចាំបាច់រៀន។

ដូច្នេះ នៅក្នុងលោកមានបុគ្គលចម្រើន ដោយបុគ្គលិកលក្ខណៈខ្ពស់ជាច្រើន ដូចជា អង្គព្រះសម្មាសម្ពុទ្ធជាដើម។ តើ





ទាំងនេះ ជាផលិតផលមួយជាតិឬ? តើវាអាចមកពីខួរក្បាលដែលមានលក្ខណៈពិសេសឬ?ពួកអ្នកវិទ្យាសាស្ត្របានសិក្សាទៅលើខួរក្បាលរបស់ **អលប៊ឺត អាញស្តាញ** (Albert Einstein) បន្ទាប់ពីគាត់ស្លាប់ ។ ពួកគេមិនបានរកឃើញលក្ខណៈពិសេសអ្វីទេ។ ទេពកោសល្យនានាអាចបង្ហាញជាភស្តុតាងដោយលទ្ធភាពឯកទេស តាមរយៈការរៀនសូត្រពីអតីតរបស់គាត់ ក្នុងជាតិមុន។

### ៣.ការចាំអតីតជាតដោយអេតឌីគ្រេហ្សិន (អាយុក្ខ័យ) ការបង្វិលថយក្រោយ ទៅរកអតីតកាល តាមរយៈវិធីសណ្តំ

អ្នកដែលមិនអាចចាំអតីតជាតិរបស់ខ្លួនបាន គេអាចឱ្យធ្វើការសណ្តំ ហើយស្នើសុំឱ្យប្រាប់អំពីអតីតជាតិរបស់ពួកគេ។ គេអាចសួរអ្នកដែលត្រូវបានគេសណ្តំនោះ អំពីអតីតជាតិរបស់គាត់ អំពីព្រឹត្តិការណ៍ក្នុងវ័យកុមាររបស់គាត់ និងអំពីអតីតជាតិរបស់គាត់ផងដែរ។ គេបានសិក្សា និងអនុវត្តបច្ចេកទេសនេះជាច្រើននៅ អឺរ៉ុប និង សហរដ្ឋអាមេរិក។

(១). អ្នកស្រី **ន. បេកឺ** (Mrs. N.Paker) មេផ្ទះ នៅប្រទេសអង់គ្លេស មិនចេះនិយាយភាសាបារាំងទេ។ គាត់មិនដែលរៀនភាសាបារាំងឡើយ ហើយគាត់ក៏មិនដែលទៅប្រទេសបារាំងដែរ។ ប៉ុន្តែនៅពេលគេសណ្តំគាត់ៗអាចនិយាយអំពីព្រឹត្តិ-

ការណ៍ជាច្រើន ដែលបានកើតឡើងក្នុងទីក្រុងប៉ារីស ជាភាសាបារាំងយ៉ាងស្ទាត់[៨] ។

(២). ព្រះតេជគុណ **ម៉ាទីន** (Martin) បព្វជិតសាសនាគ្រិស្ត នៅទីក្រុង **ផិនស៊ីលវិននៀ** (pensylvania) ហើយនិងសមាជិកវិហារគ្រិស្តចំនួន២២រូប ចង់ធ្វើការសិក្សាស្រាវជ្រាវរបស់ពួកគេផ្ទាល់ទាក់ទងទៅនឹងអតីតជាតិ។ពួកគេបានរៀនពីសិល្បៈនៃការសណ្តំ ហើយគេបានឱ្យបរិស័ទនៅវិហាររបស់គេ ដែលមិនជឿអតីតជាតិឱ្យធ្វើវិធីសណ្តំដែរ។ ប៉ុន្តែនៅពេលដែលគេស្នើសុំឱ្យប្រាប់អំពីអតីតជាតិរបស់ផងគេ ពួកគេបានប្រាប់ថា ពួកគេជាអ្វីក្នុងអតីត ហើយរស់នៅកន្លែងណា ធ្វើការនៅកន្លែងណា និងមានអ្វីកើតឡើងក្នុងអតីតជាតិរបស់ពួកគេ។ រាល់ការនិយាយនោះត្រូវថតទុក ហើយចាក់ឱ្យពួកគេមើលវិញ។ " តើខ្ញុំកំពុងនិយាយពីអតីតជាតិរបស់ខ្ញុំឬ?" " ខ្ញុំមិនអាចជឿបានទេ " ពួកគេបានកត់សម្គាល់យ៉ាងដូច្នេះ ក្នុងការភ្ញាក់ផ្អើលដ៏អស្ចារ្យ។ នៅពេលដែលសេចក្តីប្រកាសរបស់ពួកគេក្រោមការធ្វើសណ្តំ អំពីអតីតជាតិនោះ ត្រូវបានគេពិនិត្យសង្កេត គេបានរកឃើញថា វាជារឿងពិត។ ការស្រាវជ្រាវរបស់ពួកគេបានបោះពុម្ពចេញជាសៀវភៅមួយក្បាលមានចំណងជើងថា **ការស្រាវជ្រាវពីការចាប់ជាតិ និង**





**ហួសពីនេះ**[៩]។

(៣)គណៈកម្មការស្រាវជ្រាវមួយក្រុម នៅសហរដ្ឋអាមេរិកបានសណ្តំឱ្យអ្នកស្រី **វើចជិននៀ ទិគហេ**(Mrs.Virginia Tighe) ៦ដងក្នុងឆ្នាំ១៩៥២-១៩៥៣ ។ ក្នុងពេលទាំង៦ដង គាត់បាននិយាយអំពីអតីតជាតិរបស់គាត់ថា ជា **ប្រ៊ៃ ឌី មឺហ្វី** (**Bridy Murphy**) នៅទីក្រុង **បែលហ្វាស** ប្រទេស **អៀកឡង់** ប្រហែល ១៥០ឆ្នាំកន្លងទៅ។ គាត់បានប្រាប់កន្លែងដែលនាងរស់នៅឈ្មោះផ្លូវ ឈ្មោះកន្លែងហាងធំ ដែលគាត់ធ្លាប់ទៅទិញឥវ៉ាន់ និងឈ្មោះរបស់ប្តីគាត់ ដែលធ្លាប់ធ្វើសាស្ត្រាចារ្យច្បាប់ នៅមហាវិទ្យាល័យម្ចាស់ក្សត្រីយ៍កំឡុងឆ្នាំ១៨៤៧។ ក្រុមគណៈកម្មការស្រាវជ្រាវបានធ្វើដំណើរទៅកាន់ទីក្រុង **បែលហ្វាស** ដើម្បីធ្វើការពិនិត្យសង្កេត។ ពួកគេមិនអាចរកឃើញឈ្មោះផ្លូវ អាសយដ្ឋានដែល **ប្រ៊ៃ ឌី មឺហ្វី** បានរស់នៅ និងហាងធំ ដែលគាត់ធ្លាប់ទៅទិញឥវ៉ាន់នោះឡើយ។ អ្វីៗបានផ្លាស់ប្តូរក្នុងអំឡុងពេល១៥០ឆ្នាំ។ ប៉ុន្តែនៅពេលដែល គេធ្វើការសិក្សាសៀវភៅកំណត់ហេតុទីក្រុងចាស់ និងរបាយការណ៍នោះ គេបានរកឃើញឈ្មោះហាងធំដែលបានរៀបរាប់ប្រាប់ដោយអ្នកស្រី ***វើជិននៀ ទិគហេ*** ។ គេក៏បានឃើញរបាយការណ៍ ដែលម្ចាស់ក្សត្រីយ៍ប្រទេសអង់គ្លេស

មកកាន់ប្រទេស **អៀកឡង់** ក្នុងឆ្នាំ១៨៤៧ ហើយសម្ពោធមហាវិទ្យាល័យរបស់ម្ចាស់ក្សត្រីយ៍ ដែលជាកន្លែងប្ដីរបស់ **ប្រ៉ែឌីមីហ្វី** ធ្វើការជាសាស្ត្រាចារ្យច្បាប់នៅទីនោះ។ រឿងរបស់ **ប្រ៉ែឌីមីហ្វី** ត្រូវបានបោះពុម្ពតាមកាសែត និងទស្សនាវដ្ដីនានាយ៉ាងល្បីល្បាញនៅសហរដ្ឋអាមេរិក។

## អេដហ្គ័រ ខាយី មនុស្សមានអភិនីហារ

សមត្ថភាព និងសមិទ្ធិផលរបស់ **អេដហ្គ័រ ខាយី** នៅសហ - រដ្ឋអាមេរិក គឺមានអាថ៌កំបាំង និង អស្ចារ្យណាស់។ គាត់កើតនៅ **កេនទុកគី**ឆ្នាំ១៨៧៧។ ឪពុកម្ដាយរបស់គាត់ជាកសិករ មិនមានការអប់រំខ្ពស់ទេ។ គាត់បានទៅសិក្សាសាលានៅជនបទ ដល់ថ្នាក់ទី៩។ ពេលនោះគាត់ធ្វើការជាស្មៀននៅបណ្ណាគារមួយ។ ក្រោយមក គាត់បានក្លាយជាអ្នកលក់ធានារ៉ាប់រងម្នាក់។ នៅអាយុ២១ឆ្នាំ គាត់មានជម្ងឺលោកបំពង់ក ហើយបាត់បង់សំឡេង។ គាត់បានព្យាបាលរយៈពេល១ឆ្នាំ ប៉ុន្តែគ្មានប្រសិទ្ធភាពអ្វីទេ។

បន្ទាប់មក ខណៈពេលដែលគាត់បានកំពុងធ្វើជាអ្នកស៊ីឈ្នួលថតរូបអ្នកធ្វើដំណើរកំសាន្ត និងជាអ្នកចេះវិធីសណ្ដំម្នាក់។ ឈ្មោះ **លោក ហាត** (Hart)បានមកកាន់ទីក្រុង។ គាត់បានយល់ព្រមធ្វើសណ្ដំដល់ **អេដហ្គ័រ ខាយី**។ ដោយអភិនីហារអាចនិយាយ





ក្នុងសំឡេងធម្មតា ក្រោមវិធីសំណ្ដំនោះ។ ក្រោយមកអ្នកនៅក្នុងស្រុកម្នាក់ឈ្មោះលោក **ឡេនី** (Layne) ដែលមានទេពកោសល្យជាអ្នកសណ្ដំ បានធ្វើសណ្ដំដល់លោកខាយី ហើយបានស្នើឱ្យគាត់រៀបរាប់លក្ខខណៈជម្ងឺរបស់គាត់។

**អេដហ្គ័រ ខាយី** បានឆ្លើយតបក្នុងសំឡេងធម្មតា "តាមសភាពធម្មតារាងកាយមិនអាចនិយាយបានទេ ដោយសាររោគខ្វិនមួយផ្នែកនៃសាច់ដុំខាងក្រោមខ្សែសំឡេង ដោយបង្កើតឡើងដោយសរសៃប្រសាទ។ នេះជាល័ក្ខខ័ណ្ឌចិត្តវិទ្យា បង្កើតឡើងដោយផលប៉ះពាល់ផ្នែករាងកាយ។ វាអាចបំបាត់ដោយការបង្កើតនូវការធ្វើចលនាចំពោះផ្នែកដែលប៉ះពាល់ ដោយការផ្ដល់យោបល់នៅខណៈពេលក្នុងល័ក្ខខ័ណ្ឌដែលមិនដឹងខ្លួន"។

លោក **ឡេនី** បានស្នើលោក **ខាយី** យ៉ាងរហ័សថា ការធ្វើចលនារបស់គាត់នឹងបានកើនឡើង ចំពោះផ្នែកដែលមានផលប៉ះពាល់ល័ក្ខខ័ណ្ឌនោះនឹងត្រូវបំបាត់បាន។ ជាបណ្ដើរៗ ទ្រូងខាងលើរបស់ខាយី បន្ទាប់មកករបស់គាត់បានប្រែទៅជាពណ៌ស៊ីជំពូ បន្ទាប់មកប្រែទៅជាពណ៌ផ្កាកូលាប បន្ទាប់មកទៀតទៅជាពណ៌ក្រហមដាំ។ បន្ទាប់ពី២០នាទីក្រោយមក បុរសដែលកំពុងដេកនោះ គ្រហែមហើយនិយាយថា" ឥឡូវនេះអស់អ្វីហើយ ។

ល័ក្ខខ័ណ្ឌនៃជម្ងឺ គឺអាចបំបាត់បានហើយ។ ហើយធ្វើការស្នើយោបល់ថា ចលនាបានត្រឡប់ទៅរកសភាពធម្មតា ហើយទុកឱ្យរាងកាយដឹងខ្លួនឡើង"។

លោក **ឡេនី** បានស្នើឱ្យ **អេដហ្គ័រ ខាយី** ភ្ញាក់ឡើងតាមបញ្ជាហើយនិយាយតាមធម្មតា។ ក្នុងសភាពសណ្តំ រឿងរ៉ាវហោក់ដូចកើតឡើងដល់ ឡេនី ថាបើ ខាយី អាចមើលឃើញ ហើយវិនិច្ឆ័យល័ក្ខខ័ណ្ឌជម្ងឺរបស់គាត់ផ្ទាល់បាន គាត់ក៏ប្រហែលជាអាចមើលឃើញ និងវិនិច្ឆ័យជម្ងឺ របស់អ្នកដទៃបានដែរ។ គេបានព្យាយាមធ្វើពិសោធន៍លើ ឡេនី ផ្ទាល់ ដែលកំពុងរងការឈឺចាប់ដោយជម្ងឺក្រពះ។ ក្រោមការធ្វើសណ្តំ ខាយី បានពណ៌នានូវល័ក្ខខ័ណ្ឌជម្ងឺក្នុងរាងកាយរបស់ ឡេនី ហើយបានស្នើឱ្យមានការព្យាបាលតាមវិធីជាក់លាក់មួយ។ ការព្យាបាលនោះដំណើរការទៅបាន។ បន្ទាប់មក ខាយី បានធ្វើរោគវិនិច្ឆ័យលើអ្នកជម្ងឺជាច្រើន និងផ្តល់នូវការអានយ៉ាងត្រឹមត្រូវ។

ការអានអាចធ្វើឡើងនៅពេលយប់ ឬនៅកណ្តាលថ្ងៃ។ ២ឬ៣នាទីបន្ទាប់ពីដេកទម្រេតខ្លួន គាត់នឹងបានលង់លក់។ ពេលនោះ **ឡេនី** ឬប្រព័ន្ធរបស់ **ខាយី** ឬបុគ្គលទទួលបន្ទុកដទៃទៀត នឹងផ្តល់ឱ្យគាត់នូវយោបល់សមរម្យ។





រូបមន្តធម្មតា ដូច្នេះ គឺ "ឥឡូវអ្នកនឹងមាននៅចំពោះមុខអ្នក( ឈ្មោះរបស់បុគ្គល ) ដែលមានទីតាំងនៅ( ផ្លូវ អាស័យដ្ឋាន ទីក្រុង រដ្ឋ )។ អ្នកនឹងត្រួតពិនិត្យរូបកាយរបស់គាត់ ដោយប្រុង-ប្រយ័ត្ន ពិនិត្យវាឱ្យបានហ្មត់ចត់, ហើយប្រាប់ខ្ញុំនូវល័ក្ខខ័ណ្ឌជម្ងឺដែលអ្នករកឃើញនៅពេលបច្ចុប្បន្ន ដោយប្រាប់នូវហេតុនៃស្ថាន-ភាពជម្ងឺកំពុងមាន ព្រមទាំងយោបល់សម្រាប់ជួយសង្គ្រោះរូបកាយនោះ។ អ្នកនឹងឆ្លើយនូវសំណួរ ដូចដែលខ្ញុំសួរពួកគេ"។

ក្រោមវិធីសណ្តំ **អេដហ្គ័រ ខាយី** មានសមត្ថភាពដឹងផ្លូវចិត្ត។ គាត់អាចពិនិត្យអ្នកជម្ងឺដែលនៅឆ្ងាយ ហើយមើលធ្លុះទៅក្នុងរូបកាយរបស់អ្នកដទៃ ដើម្បីវិនិច្ឆ័យនូវលក្ខណៈជម្ងឺ និងការព្យាបាលយ៉ាងត្រឹមត្រូវ។ ដូច្នេះ អ្នកជម្ងឺទុព្វលភាពមិនចាំបាច់នាំទៅជួបគាត់ទេ។ គាត់អាចធ្វើការវិនិច្ឆ័យរោគ និងព្យាបាលជម្ងឺបានយ៉ាងត្រឹមត្រូវ មិនមែននៅតែសហរដ្ឋអាមេរិកទេ ប៉ុន្តែថែមទាំងមកពីប្រទេសដទៃផងដែរ។ **អេដហ្គ័រ ខាយី** បានផ្តល់ការវិនិច្ឆ័យ និង ព្យាបាលដោយញាណតាំងពីឆ្នាំ១៩០១ម្ល៉េះ ហើយអ្នកជម្ងឺប្រហែល ៣០.០០០នាក់ បានជាសះស្បើយពីជម្ងឺរ៉ាំរ៉ៃរបស់ពួកគេ។ គាត់ ក៏អាចមើលឃើញនូវកម្មអតីតរបស់ពួកគេ ហើយគាត់និយាយថា *ជម្ងឺខ្លះជាប់ទាក់ទងនឹងកម្ម*

*អាក្រក់ របស់ពួកគេកាលពីអតីត*។ ដើម្បីព្យាបាលជម្ងឺទាក់ទងនឹងកម្មក្នុងអតីត ផលអាក្រក់នៃអកុសលកម្មនោះ គេគប្បីត្រូវបញ្ឈប់អកុសលកម្មដោយការធ្វើនូវកុសលកម្មជំនួស ហើយជម្ងឺបច្ចុប្បន្ននេះគប្បីត្រូវព្យាបាលដោយឱសថសមរម្យ។ ថ្នាំដែល **ខាយី** ចេញវេជ្ជបញ្ជាព្យាបាលនោះភាគច្រើនជាថ្នាំឫសឈើ ។ គ្រឹះស្ថានព្យាបាលរបស់ **អេដហ្គ័រ ខាយី** មួយបានបង្កើតឡើងនៅ វឺជីននីញ៉ាប៊ីច។ របាយការណ៍អ្នកជម្ងឺទាំងឡាយត្រូវបានរក្សាទុកនៅក្នុងគ្រឹះស្ថាននោះឯង។

## បំណកស្រាយពីជីវិតដែលច្បាស់ជាងតារាងនៃតារាសាស្ត្រ

នៅ**ដេតុន អូហៃយ៉ូ**( Dayton Ohio )មិនមែនរហូតដល់ឆ្នាំ ១៩២៣ ទេ ដែលសំអាងជាលើកដំបូងចំពោះការចាប់ភពកំណើត ដែលកើតមានឡើងក្នុងអំឡុងការដឹងមួយរបស់ **អេដហ្គ័រ ខាយី** ។ ក្រោយពីបុរសម្នាក់បានស្នើសុំនូវតារាងហោរាសាស្ត្រដល់គាត់មក ខាយី បានរៀបរាប់ដោយហេតុផលពីសភាពបាត់ស្មារតីរបស់គាត់ថា *ការសំខាន់ជាងការជម្រុញពីឥទ្ធិពលភពគឺភាពអង់អាច ទេពកោសល្យ និង សមត្ថភាព នានា ដែលកើតមានចំពោះមនុស្សកាលពីជាតិមុន នៅលើពិភពផែនដីនេះ។*

បន្ទាប់មកបានប្រតិបត្តិតាម " ការដឹងជាតិ " ដែលនៅក្នុង





នោះ **ខាយី** បានរៀបរាប់ចំណុចពិស្តារមួយចំនួន ពីការចាប់ភពមុននៅលើផែនដី ដោយសម្រាំងចំណុចទាំងឡាយច្បាស់លាស់ដែលមានឥទ្ធិពលបំផុតក្នុងពេលបច្ចុប្បន្ន។ ពេលនោះជារឿយៗគាត់បានដាក់ឈ្មោះ ថ្ងៃ ខែ និងទីកន្លែង ព្រមទាំងកត្តាជំរុញលក្ខណៈឱ្យមានផ្នែក ទេពកោសល្យ ភាពទន់ខ្សោយ និងសមត្ថភាព ហើយពេលខ្លះ បញ្ហាផ្លូវកាយ និងចិត្ត ដែលកើតឡើងជាលទ្ធផល គាត់បានពន្យល់ថា ការចងចាំបាននាំយកកម្រិតភវង្គៈដ៏ស៊ីជម្រៅមួយពីជាតិមុននោះឯង[២]។

ការដឹងជាតិស្តីអំពី **អេហ្គ័រ ខាយី** ខ្លួនឯងផ្ទាល់បានលាតត្រដាងថា គាត់បានបួសជាបព្វជិតគ្រិស្តម្នាក់នៅប្រទេស អេហ្សីបកាលពីច្រើនសតវត្សកន្លងទៅនេះ ដែលបានអំណាចនៃ រហស្ស-វិទ្យាដ៏អស្ចារ្យ ។ ប៉ុន្តែ ឆន្ទៈខ្លួនឯង និងការត្រេកត្រអាលនឹងកាមគុណ បានសឱ្យឃើញនូវសេចក្តីវិនាសអន្តរាយរបស់គាត់។ ក្នុងការចាប់ជាតិក្រោយមកទៀត នៅប្រទេស **ពែក** គាត់បានធ្វើជាគ្រូពេទ្យ។ នៅពេលគាត់មានរបួសក្នុងដំណើរផ្លូវឆ្ងាយ តាមវាលខ្សាច់ ស្ទើរតែនឹងត្រូវស្លាប់នៅលើវាលខ្សាច់នោះ។ គាត់នៅទីនោះម្នាក់ឯង ដោយគ្មានអាហារ ទឹកសម្រាប់ផឹក និងជម្រកស្នាក់នៅស្រួលបួលឡើយ គាត់បានចំណាយពេល៣ថ្ងៃ៣យប់ ក្នុងការ

ឈើចាប់រាងកាយបែបនេះ រហូតដល់គាត់បានប្រឹងប្រែងព្យាយាម ដ៏ខ្ពង់ខ្ពស់ ដើម្បីឱ្យវិញ្ញាណរបស់គាត់រួចផុតពីរូបកាយរបស់គាត់។

គាត់បានជោគជ័យក្នុងការព្យាយាមនេះ។ នេះ គឺស្ថិតក្នុងផ្នែកជាមូលដ្ឋាន សម្រាប់ឥន្ទ្រីយ៍របស់គាត់ក្នុងពេលបច្ចុប្បន្ន សម្រាប់ការរំដោះចិត្ត របស់គាត់ចេញពីការកំណត់នៃរាងកាយរបស់គាត់ [២]។

*ប្រសិនបើបុគ្គលបានដាំពូជនៃវិជ្ជានិងពូជ*
*នៃចរណៈគឺការប្រព្រឹត្តល្អផ្នែកសីលធម៌,ពូជនោះ*
*នឹងក្លាយជារុក្ខជាតិដ៏ធំនៅជាតិក្រោយ។*

## ការនិទូរលេខម្នាក់

ការនីទូរលេខក្មេងម្នាក់ នៅទីក្រុង ញូយ៉ក ចង់ដឹងអំពីទូរលេខចំឡែក ដែលគេបានសួរនាងនៅឱកាសជាច្រើន ដើម្បីឱ្យផ្ញើទៅកាន់ វីជីនីញ៉ាប៊ីច។ នាងបានធ្វើការស៊ើបសួរអំពីអត្តសញ្ញាណរបស់ **អេហ្គ័រ ខាយី** ។ ការចង់ដឹងរបស់នាងបានកើតមានរឹតតែខ្លាំងឡើង, ហើយបានសម្រេចចិត្តឱ្យ មានការដឹងជាតិ។

គេបានប្រាប់នាងក្នុងការមើលនោះថា នាងកំពុងបានធ្វើឱ្យខ្ជះខ្ជាយពេលវេលាធ្វើជា អូបេរ៉ាទ័រតេឡេក្រាម (Telegraph Operator)ហើយថា នាងគួរតែសិក្សាសិល្បៈផ្នែកជំនួញវិញ ព្រោះ





នាងធ្លាប់ជាអ្នកមានភាពប៉ិនប្រសប់ ដ៏មានសមត្ថភាពក្នុងអតីតជាតិជាច្រើនដង ហើយអាចធ្វើមនុស្ស ដូចនេះម្តងទៀត។

គំនិតចូលជាសិល្បៈជំនួញ ឬប្រភេទនៃជំនួញដទៃទៀត មិនដែលធ្លាប់កើតមានដល់ខួរក្បាលរបស់នាងឡើយ ប៉ុន្តែ ស្ថិតនៅលើកម្លាំងនៃញាណដ៏ក្លាហានមួយថា នាងក៏អាចធ្វើអ្វីមួយផ្សេងបានដែរ នាងបានដាក់ចិត្តរៀននៅសាលាសិល្បៈ ចំពោះការភ្ញាក់ផ្អើលរបស់នាងបានយល់ឃើញថា នាងមានទេពកោសល្យច្បាស់លាស់ នាងក៏បានក្លាយជាអ្នកសិល្បៈជំនួញ ដែលបានទទួលជោគជ័យយ៉ាងខ្ពង់ខ្ពស់ យ៉ាងឆាប់រហ័ស ហើយដោយចៃដន្យបានផ្ទេរបុគ្គលិកលក្ខណៈរបស់នាង ទៅក្នុងដំណើរការនោះ [១០]។

## ៤. ការដឹងអតីតជាតតាមរយៈអភិញ្ញា

វិជ្ជាពិសេស ដែលបុគ្គលអាចដឹងអតីតជាតិរបស់ខ្លួនបានដោយត្រឡប់ទៅមើលប្រឡាយនៃការកើតឡើង និងការរលត់ទៅវិញនៃខន្ធ៥ក្នុងអតីតជាតិផ្សេងៗឱ្យឈ្មោះថា បុព្វេនិវាសានុសតិ អភិញ្ញា។

មានបុគ្គល ៦ យ៉ាង ដែលអាចសម្រេចនូវវិជ្ជានេះបាន។

បុគ្គលទាំងនោះគឺ ១. ពួកឥសី ២. សាវ័កធម្មតា ៣. មហាសាវ័ក ៤. អគ្គសាវ័ក ៥. ព្រះបច្ចេកពុទ្ធ និងទី៦.ព្រះសម្មាសម្ពុទ្ធ។

(១).តាបស ឬឥសីក្រៅពុទ្ធសាសនា អាចរឭកឃើញអតីតជាតិរបស់ពួកគេបានចំនួន៤០ កប្បថយក្រោយព្រោះបញ្ញារបស់ពួកគេនៅខ្សោយ ដោយសារពួកឥសីទាំងនោះ មិនអាចកំណត់ដឹងនូវនាមនិងរូបបាន។

(២).សាវ័កធម្មតារបស់ព្រះសម្មាសម្ពុទ្ធ អាចរឭកដឹងអតីតជាតិនីមួយៗ របស់ខ្លួនបាន១០០០កប្បរាប់ត្រឡប់ថយក្រោយ ព្រោះបញ្ញារបស់លោកអស្ចារ្យ។

(៣).មហាសាវ័ករបស់ព្រះសម្មាសម្ពុទ្ធ អាចរឭកអតីតជាតិនីមួយៗរបស់ពួកលោកបាន ១០០.០០០ កប្ប។

(៤).អគ្គសាវ័ករបស់ព្រះសម្មាសម្ពុទ្ធ អាចរឭកអតីតជាតិនីមួយៗរបស់ខ្លួន បាន ១អសង្ខេយ្យ និង១០០.០០០កប្ប។

(៥).ព្រះបច្ចេកពុទ្ធ អាចរឭកអតីតជាតិនីមួយៗរបស់ព្រះអង្គបាន២ អសង្ខេយ្យ និង១០០.០០០ កប្ប។

(៦).ព្រះសព្វញ្ញុពុទ្ធ អាចរឭកដឹងជាតិរបស់ព្រះអង្គផ្ទាល់ និងពពួកសត្វដទៃមិនមានចំនួនកំណត់។

នាពេលបច្ចុប្បន្ន ជនទាំងឡាយណាដែលចង់ចម្រើន





នូវអភិញ្ញា ដើម្បីរឭកដឹងនូវឈានសមាបត្តិទាំង៨ ក្នុងកសិណ ១០ ហើយបន្ទាប់មកប្រតិបត្តិតាមរបៀប១៤យ៉ាង ដូចដែលបង្រៀនដោយព្រះសម្មាសម្ពុទ្ធ។

ការរៀបរាប់អំពីអភិញ្ញានៃការដឹងអតីតជាតិ តាមគម្ពីរពុទ្ធសាសនា មានដូចតទៅ " លោកដាក់ចុះនូវចិត្តរបស់លោកចំពោះវិជ្ជានៃការរឭកអតីតជាតិ។ លោករឭកអតីតជាតិ ច្រើនដងគឺថា ១ជាតិ ២ជាតិ ៣ជាតិ ១០ជាតិ ២០ជាតិ ៣០ជាតិ ១០០ជាតិ ១០០០ជាតិ ១០០.០០០ជាតិ កាលនោះខ្ញុំមានឈ្មោះដូចនេះមួយ មានពូជដូចនេះមួយ មានអាការៈបែបនេះមួយ មានអាហារបែបនេះមួយ មានសុខទុក្ខជារបស់ខ្លួនបែបនោះមួយ អស់អាយុទៅបែបនេះមួយ, ហើយស្លាប់ពីទីនោះទៅខ្ញុំបានមកកើតក្នុងទីនេះ, ខ្ញុំបានកើតកន្លែងផ្សេងទៀត កាលនោះខ្ញុំមានឈ្មោះដូចនេះមួយ មានពូជដូចនេះមួយ មានអាការៈបែបនេះមួយ មានអាហារបែបនេះមួយ មានសុខទុក្ខជារបស់ខ្លួនបែបនោះមួយ អស់អាយុទៅបែបនេះមួយ, ហើយស្លាប់ពីទីនោះទៅខ្ញុំបានមកកើតក្នុងទីនេះ ដូច្នេះ លោករឭកឃើញអតីតជាតិជាច្រើនថា មានលក្ខណៈ និងភិនភាគដូច្នេះ ឬ ដូច្នោះមួយ" (D.i,81)។

## ការសម្តែងបច្ឆាញពីអតីតជាតិរបស់ព្រះសម្មាសម្ពុទ្ធ

បន្ទាប់ពីសម្រេចការត្រាស់ដឹងភ្លាម ព្រះសម្មាសម្ពុទ្ធទ្រង់បានបន្លឺវាចាប្រកបដោយបីតិថាៈ

*តថាគតបានអន្ទោលទៅមកក្នុងវដ្តសង្សារ ស្វែងរកនូវជាងផ្ទះ ប៉ុន្តែរកមិនឃើញ។ ការកើតនាំមកនូវសេចក្តីទុក្ខម្តងហើយម្តងទៀត។*

*"ម្នាលជាងផ្ទះ! ឥឡូវតថាគត បានរកឃើញអ្នកហើយ។ អ្នកលែងអាចកសាងផ្ទះតថាគតបានទៀតហើយ។ បង្កង់ផ្ទះរបស់អ្នក ត្រូវបានបែកបាក់អស់ហើយ ។ ដំបូលផ្ទះរបស់អ្នក ត្រូវបានបែកបាក់រាយប៉ាយអស់ហើយ។ ចិត្ត របស់តថាគតលែងមានអ្វីតាក់តែងបានទៀតហើយ ។ តណ្ហារបស់តថាគតបានរីងស្ងួតអស់ហើយ"។*

*( ធម្មបទលេខ១៥៣-១៥៤ )*

ក្នុងសេចក្តីប្រៀបធៀបនេះ "ផ្ទះ" សំដៅយក "កាយ" និង "ចិត្ត" ជាងផ្ទះគឺ"តណ្ហា" បង្កង់ ឬផ្ទោងផ្ទះ បានដល់ "កិលេស" និង ដំបូលផ្ទះសំដៅយក"អវិជ្ជា"។

ព្រះសម្មាសម្ពុទ្ធ ទ្រង់សម្តែងគូសបញ្ជាក់ថា តណ្ហានេះ





ហើយ ដែលបណ្តាលឱ្យមានភពថ្មីកើតឡើងពីជាតិមួយទៅជាតិមួយ ហើយនៅពេលតណ្ហាត្រូវបានកំចាត់បង់ទាំងស្រុងដោយមគ្គញាណទាំង៤ ភពថ្មីនឹងលែងមានហើយ ដោយហេតុនេះហើយ សេចក្តីទុក្ខថ្មី ក៏លែងមានដែរ។

ដោយសារសត្វខ្លះបានធ្វើអំពើ អកុសលកម្ម គេបានកើតក្នុងអបាយភូមិ៤ បន្ទាប់ពីស្លាប់ទៅ។ សត្វខ្លះទៀតបានធ្វើកុសលកម្មផ្សេងៗ បានទៅកើតក្នុងសុគតិភព ក្នុងភពថ្មីបន្ទាប់ពីស្លាប់ទៅ។ ព្រះសម្មាសម្ពុទ្ធ ទ្រង់សម្តែងរឿងនេះយ៉ាងច្បាស់លាស់ នៅក្នុងព្រះសូត្រជាច្រើន។

ក្នុងគ្រាមួយនោះ ព្រះសម្មាសម្ពុទ្ធព្រមទាំងព្រះសង្ឃជាច្រើន បានធ្វើដំណើរពីទីក្រុង សាវត្ថី ទៅកាន់ទីក្រុងសាកេត ហើយបានសឹង១យប់ ក្នុងព្រៃមួយឈ្មោះ **អញ្ជនៈ** ។ នៅថ្ងៃបន្ទាប់ទៀត ព្រះពុទ្ធ និងភិក្ខុសង្ឃទាំងឡាយ បាននិមន្តចូលទៅកាន់ទីក្រុង **សាកេត** ដើម្បីបិណ្ឌបាត។

នៅត្រង់ទ្វារនៃទីក្រុងនោះ ព្រះសម្មាសម្ពុទ្ធ ទ្រង់បានជួបព្រាហ្មណ៍អ្នកមានទ្រព្យធនម្នាក់នៃទីក្រុង សាកេត ។ នៅពេលឃើញព្រះសម្មាសម្ពុទ្ធ ព្រាហ្មណ៍នោះបានចូលទៅជិតព្រះអង្គដោយរីករាយ ហាក់ដូចជាបានជួបកូនប្រុសរបស់ខ្លួន ដែល

បាត់មុខយូរហើយ ដោយនិយាយថា"ឱកូនប្រុស ឪពុកខានបាន ឃើញអ្នកជាយូរណាស់មកហើយ"។ ព្រះសម្មាសម្ពុទ្ធ ទ្រង់បាន ប្រាប់ព្រះភិក្ខុសង្ឃទាំងឡាយថា ទុកឱ្យព្រាហ្មណ៍នេះធ្វើតាម ចិត្តរបស់គាត់ចុះ។

ព្រាហ្មណ៍នោះឱបព្រះសម្មាសម្ពុទ្ធនិយាយថា "កូនប្រុស ឪពុកខានជួបអ្នកយូរហើយ។ យើងបានបែកគ្នាជាយូរមកហើយ"។ គាត់បានអារាធនាព្រះពុទ្ធ ដើម្បីឱ្យគាត់ប្រគេនចង្ហាន់ដល់ព្រះអង្គ និងព្រះភិក្ខុសង្ឃ។ ព្រះសម្មាសម្ពុទ្ធទ្រង់បានទទួលនិមន្តដោយ នៅស្ងៀម។ ព្រាហ្មណ៍នោះបានយកបាត្រព្រះសម្មាសម្ពុទ្ធ ហើយ នាំផ្លូវទៅ។ គាត់ក៏បានប្រាប់ដំណឹងប្រពន្ធគាត់ថា "កូនរបស់ខ្ញុំ កំពុងមក ចូររៀបចំអាសនៈ ដើម្បីព្រះពុទ្ធ និង ភិក្ខុសង្ឃផង!"។

ប្រពន្ធបានរៀបចំអាសនៈរង់ចាំព្រះពុទ្ធ។ នៅពេលឃើញ ព្រះពុទ្ធទ្រង់យាងមកពីចម្ងាយ សេចក្តីស្រឡាញ់របស់ម្តាយ ចំពោះកូនរបស់គាត់ ក៏កើតឡើងក្នុងចិត្តគាត់។ គាត់ក៏ឱបជើង របស់ព្រះសម្មាសម្ពុទ្ធ ហើយទួញសោករៀបរាប់ថា "កូនប្រុស ម្តាយៗ មិនបានឃើញកូនជាយូរយារណាស់មកហើយ"។

ព្រះសម្មាសម្ពុទ្ធ ទ្រង់បានសម្តែងនូវព្រះសូត្រដ៏សមរម្យ





មួយចំពោះព្រាហ្មណ៍ប្តីប្រពន្ធនោះ។ ពួកគាត់ទាំងពីរបានសម្រេច នូវសោតាបន្ន។ ពួកគាត់បានសុំឱ្យព្រះពុទ្ធអនុញ្ញាតឱ្យពួកគាត់ ប្រគេនចង្ហាន់ដល់ព្រះអង្គ និងភិក្ខុសង្ឃទាំងឡាយ ដរាបណា ព្រះពុទ្ធគង់នៅទីក្រុងសាកេត។ ព្រះសម្មាសម្ពុទ្ធ ទ្រង់បានបដិ-សេធសេចក្តីស្នើសុំនោះ ព្រោះព្រះអង្គចង់ឱ្យប្រជាជនទាំងឡាយ មានឱកាសប្រគេនចង្ហាន់ដល់ព្រះអង្គផងដែរ។ ប៉ុន្តែ ព្រះអង្គ ទ្រង់បានទទួលយកសេចក្តីស្នើសុំរបស់ព្រាហ្មណ៍នោះបន្ទាប់ទៀត ដើម្បីឆាន់ចង្ហាន់នៅផ្ទះរបស់គាត់បន្ទាប់ពីបិណ្ឌបាត ហើយដើម្បី សម្តែងនូវព្រះសូត្រជារៀងរាល់ថ្ងៃ។

តាំងពីថ្ងៃនោះមក អ្នកនៅទីក្រុង សាកេត ហៅព្រាហ្មណ៍ នោះថាជាពុទ្ធបិតា ហើយភរិយារបស់គាត់ថាជាពុទ្ធមាតា។

ព្រះអានន្ទត្ថេរ ដ៏មានអាយុបានសួរព្រះសម្មាសម្ពុទ្ធថា ហេតុអ្វីបានជាអ្នកក្រុង សាកេត ហៅព្រាហ្មណ៍ជាស្វាមីភរិយា នោះថាដូច្នេះ ហើយហេតុអ្វីបានជាព្រាហ្មណ៍ជាប្តីប្រពន្ធនោះ និយាយថា ពួកគាត់ជាពុទ្ធបិតានិងពុទ្ធមាតាដូច្នេះ។

"ម្នាលអានន្ទ ព្រាហ្មណ៍នេះ និងភរិយារបស់គាត់ជា មាតាបិតារបស់តថាគតអស់រយៈកាល ៥០០ជាតិជាប់តៗគ្នា ធ្លាប់ជា មាតាបិតា បងប្រុសស្រី របស់តថាគតចំនួន ៥០០ជាតិ

និងជា មាតាបិតា ប្អូនប្រុសស្រី របស់តថាគតចំនួន៥០០ជាតិ។ ដូច្នេះ ព្រះសម្មាសម្ពុទ្ធទ្រង់បានមានពុទ្ធដីកាថា ព្រាហ្មណ៍ និងភរិយារបស់គាត់និយាយថា ពួកគេជាមាតាបិតារបស់តថាគត ដោយក្ដីស្រឡាញ់ដ៏ពិសេស ដែលពួកគាត់បានធ្វើចំពោះតថាគត ក្នុងអតីតជាតិនោះឯង”។

នៅពេលដែលព្រាហ្មណ៍ និងភរិយារបស់គាត់មានឱកាស គោរពបូជាចំពោះព្រះពុទ្ធ និងភិក្ខុសង្ឃទាំងឡាយយ៉ាងជិតស្និទ្ធ ហើយស្ដាប់នូវធម៌តាមសមគួរប្រចាំថ្ងៃ ពួកគាត់បានសម្រេចផលញាណកំរិតខ្ពស់ទាំង៣ ក៏បានក្លាយជាព្រះអរហន្ត។ នៅពេលដែលពួកគាត់ស្លាប់ ព្រះសម្មាសម្ពុទ្ធ ទ្រង់បានយាងមកកាន់ពិធីបុណ្យសពរបស់គាត់ ហើយសម្ដែងធម្មទេសនាស្ដីពីជរាសូត្រ។ នៅចុងបញ្ចប់នៃព្រះសូត្រនោះ ជនទាំងឡាយចំនួន ៨៤,០០០ នាក់បានសម្រេចជាអរិយបុគ្គល។

ព្រោះតែសព្វសត្វទាំងឡាយ អន្ទោលទៅមកក្នុងភពរាប់មិនអស់ក្នុងវដ្ដសង្សារគឺថា គ្មានបុគ្គលណាមួយ ដែលថាមិនមែនជាឪពុកម្ដាយ ជាកូនប្រុស កូនស្រី របស់យើងជាដើមឡើយ។ ព្រះសម្មាសម្ពុទ្ធ ទ្រង់បានសម្ដែងដូច្នេះ នៅក្នុង *អនមតគ្គសូត្រ* ។





## ៥. ការដឹងអតីតជាតតាមវបស្សនាកម្មដ្ឋាន

ដោយការសមាទានសមថភាវនា ដំបូងបុគ្គលត្រូវចម្រើនសម្មាសមាធិចិត្ត ដែលរារាំងកិលេសចិត្តជាដើមហេតុនៃសេចក្ដីទុក្ខទាំងពួង ដែលកើតឡើងក្នុងចិត្ត។ នៅពេលចិត្តបរិសុទ្ធ វាផ្សាយនូវពន្លឺភ្លឺ និងជ្រួតជ្រាប ដែលបង្កលក្ខណៈងាយស្រួលដល់យោគីដើម្បីចាក់ធ្លុះទៅក្នុង កាយ និងចិត្ត ដើម្បីកំណត់ដឹងនូវ **នាម** និង **រូប** ដែលបង្កើតបានជាកាយ និង ចិត្តនោះ។

វិជ្ជាអាចកំណត់ដឹងនូវ រូបធាតុ ដូចជា បឋវីធាតុ អាបោធាតុ តេជោធាតុ វាយោធាតុ និង នាម ដូចជា ចិត្ត ចេតសិក ឱ្យឈ្មោះថា ***នាមរូបបរិច្ឆេទញាណ។***

នៅពេលបានសម្រេចញាណនេះ យោគីដឹងនូវអ្វីដែលមានពិតក្នុងបុគ្គលថាគ្រាន់តែជាខន្ធ ៥ បង្កើតឡើងដោយ **នាម** និង **រូប** ដែលកើតឡើងហើយរលត់ទៅវិញយ៉ាងរហ័សជាបន្តបន្ទាប់ ហើយមិនមានភាពទៀតទាត់ ដែលអាចហៅបានថា “ ខ្លួន បុគ្គល អញ ជីវៈ អត្តៈ ឬ អាត្ម័ន”។ ដូច្នេះ លោកអាចកំចាត់បង់នូវសកាយទិដ្ឋិបាន(ការយល់ឃើញខុសថា កាយជារបស់ខ្លួន)។

បន្ទាប់មកទៀត លោកកំណត់ដឹងនូវហេតុដែលកើតឡើងនូវ នាម និង រូប ។ លោកកំណត់ដឹងដោយញាណផ្ទាល់ នូវ

ហេតុទាំង៤គឺ កម្ម ចិត្ត ឧតុ និង អាហារ ដែលជាហេតុនាំឱ្យកើតនូវរូប។ លោកក៏កំណត់ដឹងនូវ ផោដ្ឋព្វ រវាង សឡាយតនៈ ទាក់ទងនឹង អាយតនៈ ៦ ខាងក្រៅ ដែលនាំឱ្យកើតឡើងនូវវិថីរបស់ ចិត្ត និង ចេតសិក។

បន្ទាប់មកទៀត ហេតុ និង ផល នៃបដិច្ចសមុប្បាទ ត្រូវបានកំណត់ដឹង និង ផ្ទៀងផ្ទាត់ដើម្បីជម្រះនូវវិចិកិច្ឆា ទាក់ទងនឹងអតីត បច្ចុប្បន្ន និងអនាគត ដូចជាថា " តើអាត្មាអញនៅក្នុងអតីតឬ? អាត្មាអញនៅក្នុងអតីតជាអ្វី? បានកើតជាអ្វី តើអាត្មាអញជាអ្វីក្នុងអតីត។ តើអាត្មាអញនឹងបានកើតជាអ្វីទៀតក្នុងពេលអនាគត។ មកពីភពអ្វីមកកាន់ភពនេះ? តើភពអ្វីនឹងកើតមានបន្ទាប់ពីបច្ចុប្បន្នភពនេះទៀត?

ញាណកំណត់ដឹងនូវបច្ច័យនៃ **នាម** និង ***រូប***( *បច្ចយបរិគ្គហញាណ*)នៅពេលយោគីបានកំណត់ដឹងនូវបច្ច័យនៃ នាម និង រូបដោយមធ្យោបាយ ដែលជាប់ទាក់ទងដោយហេតុបច្ចុប្បន្ននៃបដិច្ចសមុប្បាទ ហើយបានកំចាត់បង់នូវភាពស្រពិចស្រពិល អំឡុងកាលទាំង៣ទាំង អតីត អនាគត និងបច្ចុប្បន្ន ត្រូវបានយល់ដឹងដោយលោក ស្របពេលនៃ មរណៈ និង បដិសន្ធិ។ លក្ខណៈ





នេះជាសភាពបរិសុទ្ធនៃចិត្ត ដោយកំចាត់បង់នូវសេចក្តីសង្ស័យ *(កង្ខាវិតរណវិសុទ្ធិ)*។

ដូច្នេះ ដោយការកំណត់ដឹងនូវសមថភាវនា ដើម្បីចម្រើននូវសមាធិ និង ចិត្តវិសុទ្ធិ ហើយបន្ទាប់មកចម្រើននូវវិបស្សនាភាវនា ដើម្បីកំណត់ដឹងនូវទំនាក់ទំនងហេតុបច្ច័យនៃ បដិច្ចសមុប្បាទ, បុគ្គលអាចសង្កេតមើលយ៉ាងច្បាស់នូវអតីតជាតិ និង អនាគតជាតិ របស់ខ្លួនដោយញាណផ្ទាល់។

អ្នកខ្លះអាចជជែកដេញដោលថា តើយើងអាចសង្កេតមើលអនាគតជាតិ ដែលមិនទាន់មកដល់ដូចម្តេច? មែនហើយ អ្នកវិទ្យាសាស្ត្រទាំងឡាយ បានសិក្សាការវិវត្តនៃភពផែនដី និង ឋានព្រះច័ន្ទ អាចទស្សន៍ទាយយ៉ាងច្បាស់នូវថ្ងៃខែ និង ពេលវេលានៃចន្ទគ្រាស និងការធ្វើឱ្យងងឹតផែនដី។ ដូចគ្នានេះដែរ ដោយការក្រឡេកមើលទំនាក់ទំនងហេតុបច្ច័យនៃ នាម និង រូប សាចុះសាឡើង បុគ្គលអាចសង្កេតឃើញនូវអតីតជាតិ ព្រមទាំងអនាគតជាតិផងដែរ។ ចិត្តបរិសុទ្ធ ដែលមានសមាធិ ដែលបានអប់រំដោយប្រពៃ អាចមើលឃើញនូវ អតីត និង អនាគត។

មានមជ្ឈមណ្ឌលសមាធិឈ្មោះ " **មជ្ឈមណ្ឌលពុទ្ធសាសនាអន្តរជាតិព្រៃ ផាអោក** " នៅ មីយ៉ានម៉ា ដែលជាកន្លែង

យោគីទាំងឡាយមកពីប្រទេសជាច្រើន កំពុងចម្រើនសមថភាវនា និង វិបស្សនាភាវនា អនុលោមទៅតាមព្រះពុទ្ធដីកា។ យោគីជាច្រើនអាចសង្កេតឃើញ អតីតជាតិ និង អនាគតជាតិរបស់ខ្លួនដោយពេញចិត្តក្នុងការធ្វើឱ្យជាក់ច្បាស់ នូវទំនាក់ទំនងហេតុបច្ច័យនៃ បដិច្ចសមុប្បាទ ដែលជាសូត្រដ៏សំខាន់ពន្យល់ពីវដ្តសង្សារ របស់សព្វសត្វទាំងអស់ប្រកបដោយហេតុផល(១១)។

## *ឯកសារយោង*


1 Dr.Mehm Tim Mom, "Scientific Evidences for Past Existences and Futuer Existences,"published in Myanmar Language.Seventh Printing , P. 196-200.
2 Ibid....P.200-205.
3 Ibid....p.195
4 Dr.Mehm Tim Mom, "Two Paths for Future Existence",published in Myanmar Language. Third Printing, p.195
5 Dr.Mehm Tim Mom, "Scientific Evidences for Past Existences and Futuer Existences," Seventh Printing, p.212-213
6 Narada Maha Thera " The Buddha and His Teaching".published by Singapor Buddhist Meditation Centre, pp 233-249.
7 Dr.Mehm Tim Mom, "Scientific Evidences for Past Existences and Futuer Existences," published in Myanmar Language.Seventh Printing , P. 117 .
8 Ibid . 170-171.
9 Ibid. 165-168
10 Gina Cerminara, " Many Mansion: The Edgar Cayce Story of Reincarnation".a Signet Book.







11 Pa-auk Tawya sayadaw and Dr.Mehm Tim Mon, "Breakthrough in Samatha Meditation and Vipassanã Meditation" Yangon, pp. 51-75.

៤

## ភ័ស្តុតាងសម្រាប់អនាគតភព

ប្រសិនបើ បុគ្គលជឿអតីតភព, បុគ្គលក៏អាចជឿអនាគតភព, សម្រាប់បច្ចុប្បន្ន គឺជាអនាគតជាតិនៃជីវិតអតីត។

មានភ័ស្តុតាងច្បាស់លាស់ជាច្រើន ដើម្បីបញ្ជាក់បដិសន្ធិនាពេលអនាគត បន្ទាប់ពីសេចក្តីស្លាប់ក្នុងបច្ចុប្បន្នភព។ ភ័ស្តុតាងខាងក្រោមនឹងពណ៌នាដោយសង្ខេប ប៉ុន្តែច្បាស់លាស់។

(១) ភ័ស្តុតាងពីគម្ពីរពុទ្ធសាសនា

(២) ការពិនិត្យសង្កេត របស់ព្រះមហាមោគ្គលាន

(៣)ការទាក់ទងជាមួយបុគ្គលស្លាប់ដោយអំណាចចិត្ត

(៤) ការទាក់ទងដោយផ្ទាល់ ជាមួយបុគ្គលស្លាប់

(៥)ការដឹងអនាគតជាតិដោយទិព្វចក្ខុ អភិញ្ញាក្នុងការដឹងនូវបដិសន្ធិ យោងទៅតាម កម្ម និង អភិញ្ញា ក្នុងការដឹងនូវអនាគតជាតិ ។





### ១. ភ័ស្តុតាងតាមគម្ពីរពុទ្ធសាសនា

(១).សេដ្ឋីឈ្មោះអនាថបណ្ឌិក ដែលបានសាងវត្តជេតពនថ្វាយព្រះសម្មាសម្ពុទ្ធ បានទៅកើតនៅក្នុងឋានតុសិត បន្ទាប់ពីស្លាប់។ ទេវតាមកកាន់វត្ត ជេតពន កណ្តាលអធ្រាតផ្សាយពន្លឺពេញវត្ត បានថ្វាយបង្គំចំពោះព្រះសម្មាសម្ពុទ្ធដោយគោរព ហើយបាននិយាយថា " ជេតពន " ជាលំនៅស្ថានអចិន្ត្រៃយ៍សម្រាប់ព្រះពុទ្ធ និងព្រះភិក្ខុសង្ឃ។ ដូច្នេះ ទូលបង្គំរីករាយខ្លាំងណាស់ព្រះអង្គ"។ ព្រះសម្មាសម្ពុទ្ធ ទ្រង់បានត្រាស់ចំពោះព្រះសង្ឃអំពីហេតុនេះ [១]។

(២). ខណៈពេលដែលព្រះសម្មាសម្ពុទ្ធ បានកំពុងគង់នៅក្នុងវត្ត ជេតពន មានព្រាហ្មណ៍កំណាញ់ទ្រព្យម្នាក់មានទ្រព្យឈ្មោះ អទិន្នបុព្វក មិនបានហៅពេទ្យមកព្យាបាលកូនប្រុសរបស់គាត់ឈ្មោះ មដ្ឋកុណ្ឌលី ដែលកើតរោគលឿង និងរោគទល់លាមកទេ។ គាត់បានស៊ើបសួរថ្នាំដ៏សមរម្យមួយ ក្នុងចំណោមអ្នកធ្វើថ្នាំបុរាណក្នុងស្រុក ហើយរៀបចំផ្សំថ្នាំដោយខ្លួនឯង។ ថ្នាំនោះមិនអាចព្យាបាលជម្ងឺកូនប្រុសរបស់គាត់ទេ ហើយល័ក្ខខ័ណ្ឌជម្ងឺរបស់កូនគាត់កាន់តែធ្ងន់ធ្ងរឡើង។ ទីបំផុត គាត់បានអញ្ជើញគ្រូផ្សំថ្នាំមកកាន់ផ្ទះរបស់គាត់។ អ្នកផ្សំថ្នាំដឹងថា គាត់មិនអាចព្យាបាល

កូនប្រុសរបស់ព្រាហ្មណ៍នោះបានទេ។ ដូច្នេះ គាត់បានចាកចេញដោយឥតធ្វើការព្យាបាល ដោយនិយាយថា " ខ្ញុំក៏មានកិច្ចការសំខាន់ត្រូវធ្វើដែរ "។

ព្រាហ្មណ៍នោះបានយកកូនឈឺរបស់គាត់ ទៅទុកនៅច្រកទ្វារផ្ទះរបស់គាត់ ព្រោះគាត់មិនចង់ឱ្យមិត្ត ដែលចូលមកមើលកូនគាត់ចូលក្នុងផ្ទះរបស់គាត់ ខ្លាចក្រែងគេឃើញទ្រព្យដ៏ច្រើនរបស់គាត់។ នៅពេលដែលព្រះសម្មាសម្ពុទ្ធប្រមើលមើលលោកនៅព្រឹកព្រលឹម ព្រះអង្គបានទតឃើញមដ្ឋកុណ្ឌលី។ ទោះបីក្មេងនោះអាយុ១៦ឆ្នាំហើយក៏ដោយ ក៏គាត់នៅមិនទាន់បានធ្វើនូវអំពើជាកុសលណាមួយនៅឡើយ ដោយសារតែមិច្ឆាទិដ្ឋិរបស់គាត់។ ព្រះសម្មាសម្ពុទ្ធ ក៏ទ្រង់បានដឹងថា ក្មេងប្រុសនោះនឹងស្លាប់ក្នុងពេលឆាប់ៗ ហើយនឹងកើតក្នុងឋានអបាយ។ ដូច្នេះ នៅពេលទ្រង់បិណ្ឌ-បាត ព្រះពុទ្ធទ្រង់បានឈរត្រង់ទ្វារផ្ទះព្រាហ្មណ៍ ហើយបញ្ចេញរស្មី ដើម្បីឱ្យក្មេងនោះកត់សម្គាល់ដឹងថាព្រះអង្គទ្រង់យាងមក។

នៅពេលឃើញព្រះពុទ្ធដ៏រុងរឿង ដូច្នេះ មដ្ឋកុណ្ឌលី បានសម្តែងការគោរពយ៉ាងជ្រាលជ្រៅចំពោះព្រះពុទ្ធ។ កុសលចិត្តរាប់ពាន់លានដងបានកើតឡើង និង រលត់ទៅវិញក្នុងខ្សែចិត្តរបស់មដ្ឋកុណ្ឌលី ខណៈពេលដែលគាត់បានសម្តែងការគោរពចំពោះ



កម្ម អ្នកសាងលោកពិត

ព្រះពុទ្ធដោយមនោវិការ។ ព្រះសម្មាសម្ពុទ្ធ ទ្រង់បានជ្រាបកុសលកម្ម មួយក្នុងចំណោមកុសលកម្មទាំងនេះ នឹងតាក់តែងបដិសន្ធិរបស់ក្មេងប្រុសនោះ ក្នុងឋានទេវលោកបន្ទាប់ពីស្លាប់ទៅ។ ដូច្នេះ ព្រះសម្មាសម្ពុទ្ធបានបន្តការបិណ្ឌបាត។ មដ្ឋកុណ្ឌលី បានមើលព្រះសម្មាសម្ពុទ្ធ ដោយសេចក្តីគោរព រហូតដល់ព្រះអង្គទ្រង់បានយាងទៅឆ្ងាយ។ ពេលភ្លាមនោះ គាត់បានស្លាប់ ហើយទៅកើតជាទេវតាក្នុងវិមានមាស ពន្ធព័ទ្ធដោយទេពអប្សរ១០០០នាក់ នៅក្នុងឋានតាវតិង្ស។

***មដ្ឋកុណ្ឌលី*** *អាចសោយសុខដ៏អស្ចារ្យនៅ ឋានទេវលោក ដោយគ្រាន់តែចម្រើននូវការគោរពចំពោះព្រះសម្មាសម្ពុទ្ធ តែបន្តិចមុនពេលគាត់ស្លាប់។ ប្រសិនបើ យើងអាចចម្រើននូវការគោរពដ៏ជ្រាលជ្រៅអស់ពីចិត្ត ចំពោះព្រះសម្មាសម្ពុទ្ធ អស់មួយជីវិតរបស់យើងៗពិតជានឹងបានទទួលនូវអានិសង្សច្រើនឥតគណនា។*

និយាយពីព្រាហ្មណ៍កំណាញ់នោះ បានទៅកាន់ទីស្មសានរាល់ថ្ងៃ ហើយទួញសោកនៅក្បែរផ្នូរកូនប្រុសគាត់។ ទេវបុត្រមដ្ឋកុណ្ឌលី អាចមើលឃើញឪពុករបស់ខ្លួនពីឋានសួគ៌។ ដូច្នេះ

ក៏ចុះមកកាន់ឋានមនុស្សលោក ក្លែងខ្លួនដូច មដ្ឋកុណ្ឌលី បេះបិត ហើយទួញយំខ្លាំងៗ។

ព្រាហ្មណ៍នោះ បានកត់សម្គាល់នូវការយំ ហើយសួរថា

"ហេតុអ្វីបានជាអ្នកឯងដូចកូនខ្ញុំម្ល៉េះ? ហេតុអ្វីបានជាអ្នកយំ?"

"ខ្ញុំមានរទេះមួយ ប៉ុន្តែ ខ្ញុំអត់មានកង់សម្រាប់រទេះនោះទេ។ ដូច្នេះហើយទើបខ្ញុំយំ"។

"ខ្ញុំនឹងធ្វើកង់រទេះនោះឱ្យអ្នក។ តើអ្នកចង់បានកង់មាស ឬកង់ប្រាក់?"

"ខ្ញុំអត់ចង់បានកង់មាស ឬកង់ប្រាក់ទេ។ ខ្ញុំចង់បានព្រះអាទិត្យ និងព្រះច័ន្ទធ្វើជាកង់រទេះរបស់ខ្ញុំ"។

"អ្នកឯងឆ្កួតណាស់។ អ្នកណាអាចយកព្រះអាទិត្យ និងព្រះច័ន្ទឱ្យអ្នកឯងបាន?

តើយំចង់បានរបស់ដែលមិនអាចទទួលបានធ្វើអ្វី?"

"ខ្ញុំយំចង់បានព្រះអាទិត្យ និងព្រះច័ន្ទ ដែលខ្ញុំអាចមើលឃើញ។ អ្នកឯងយំចង់បានកូនដែលស្លាប់ទៅហើយ ដែលអ្នកមិនអាចឃើញ។ តើរវាងយើងទាំងពីរមួយណាឆ្កួតជាងមួយណា?។

"ល្អៗខ្ញុំឆ្កួតជាង។ និយាយអ៊ីចឹង តើអ្នកជានរណា ?"

"ខ្ញុំជាកូនប្រុសរបស់អ្នក ដែលបានស្លាប់ទៅហើយនោះ





ឈ្មោះ មដ្ឋកុណ្ឌលី "។

" តើអ្នកនៅឯណា ឥឡូវ?"

" ខ្ញុំជាទេវបុត្រនៅឋានតាវតិង្ស "។

" តើអ្នកបានធ្វើអំពើល្អអ្វីខ្លះទើបបានទៅកើតជាទេវបុត្រ? "

"ខ្ញុំបានសម្តែងនូវការគោរពដ៏ជ្រាលជ្រៅ ចំពោះព្រះសម្មាសម្ពុទ្ធ មុនពេលដែលខ្ញុំបានស្លាប់។ ចូរកុំធ្វើជាអ្នកកំណាញ់ ហើយកុំមានចិត្តជាប់ជំពាក់ចំពោះទ្រព្យរបស់អ្នកខ្លាំងពេក។ ចូរប្រើទ្រព្យរបស់អ្នកធ្វើជាចង្ហាន់ប្រគេនព្រះពុទ្ធ និងភិក្ខុសង្ឃទាំងឡាយ " ។

ព្រាហ្មណ៍អ្នកមាន បាននិមន្តព្រះពុទ្ធ និងព្រះភិក្ខុសង្ឃមកទទួលភត្តាហារនៅផ្ទះរបស់ខ្លួននៅថ្ងៃបន្ទាប់។ ជនទាំងឡាយអ្នកនៅក្នុងក្រុងសាវត្ថី បានភ្ញាក់ផ្អើលដោយបានឮដំណឹងថាព្រាហ្មណ៍កំណាញ់នោះនឹងធ្វើទានដល់ព្រះពុទ្ធ និងព្រះភិក្ខុសង្ឃ។ ដូច្នេះ ពួកគេមកមើលគាត់ធ្វើទានចំពោះព្រះពុទ្ធ និងព្រះភិក្ខុសង្ឃ។ ព្រះសម្មាសម្ពុទ្ធ ទ្រង់សម្តែងធម្មទេសនាថា " មនោបុព្វង្គមាធម្មា " មានន័យថា " ចិត្តជាប្រធានលើអ្វីទាំងអស់"។ គ្រានោះព្រាហ្មណ៍កំណាញ់ និងមដ្ឋកុណ្ឌលី បានសម្រេចជាសោតាបន្ន។ ជនទាំងឡាយចំនួន ៨៤០០០នាក់ក៏បានសម្រេចជាសោតាបន្នបុគ្គលដែរ[២]។

(៣)គ្រាមួយនោះ ព្រះសម្មាសម្ពុទ្ធទ្រង់បានសម្ដែង ធម្មទេសនា នៅក្នុងវេលាល្ងាចជិត ស្រះ**គគ្គរា** ក្នុងដែន **ចម្បា** ។ មានសត្វកង្កែបមួយ បានចេញពីក្នុងស្រះនោះមកស្ដាប់សំឡេងព្រះធម៌ ដោយបីតិសោមនស្ស និងដោយក្ដីគោរព។ ខណៈពេលនោះ ក្មេងគង្វាលគោម្នាក់ បានមកកន្លែងដែលសត្វកង្កែបតូចនោះអង្គុយនៅស្ងៀមខាងក្រោយអ្នកស្ដាប់ ហើយចៃដន្យគាត់ដាក់ជញ្ជញ្រសង្កត់ចំកង្កែបនោះ។ កង្កែបនោះស្លាប់ទៅបានទៅកើតទេវបុត្រក្នុងវិមានមាសដ៏អស្ចារ្យមួយ មានបរិវារជាច្រើននៅក្នុងឋានតាវតិង្ស។

ដោយការពិចារណា ទេវបុត្រនោះបានដឹងថា កុសលកម្មរបស់ខ្លួនបានកើតចេញពីការស្ដាប់ធម៌ដោយគោរព កាលនៅជាកង្កែប នាំឱ្យខ្លួនបានមកកើតក្នុងឋានទេវតានេះ។ ដូច្នេះទេវបុត្រនោះច្យុតចាកវិមានរបស់ខ្លួនភ្លាម មកកាន់ឋានមនុស្សលោក ហើយថ្វាយបង្គំព្រះសម្មាសម្ពុទ្ធ។ ព្រះពុទ្ធទ្រង់បានជ្រាបអំពីទេវបុត្រនោះ។ ទោះជាយ៉ាងណាក្ដី ដើម្បីឱ្យអ្នកស្ដាប់ដឹងព្រះអង្គទ្រង់បានសួរទេវបុត្រនោះថា "តើអ្នកជានរណា?"

"ទូលបង្គំជាកូនបង្កែបតូច មកពីស្រះនេះ។ ខណៈដែលទូលបង្គំកំពុងស្ដាប់សំឡេងរបស់ព្រះអង្គដោយគោរព ទូលបង្គំត្រូវបានគេធ្វើឱ្យស្លាប់ ហើយបានមកកើតជាទេវបុត្រមួយអង្គ"។





ព្រះសម្មាសម្ពុទ្ធ ទ្រង់បានសួរ៣ដង ហើយទេវបុត្រនោះបានផ្ដល់ចម្លើយដូចគ្នា៣ដង។ បរិស័ទទាំងឡាយរីករាយចង់ដឹងយ៉ាងខ្លាំង អំពីអានិសង្សនៃការស្ដាប់ធម៌របស់ព្រះសម្មាសម្ពុទ្ធ។ ព្រះសម្មាសម្ពុទ្ធ បានបន្តការសម្ដែងធម៌ទេសនាដោយពិស្ដារ។ ជនទាំងឡាយ ៨៤០០០ នាក់ បានសម្រេចធម៌ និងរួចចាកសេចក្ដីទុក្ខ។ ទេវបុត្រនោះបានជាសោតបន្នបុគ្គល [៣]។

(៤) មានព្រាហ្មណ៍ម្នាក់នៅជិតវត្ត ជេតពន ឈ្មោះ " តោទេយ្យ " ។ ទោះបីគាត់ជាសេដ្ឋីមានប្រាក់រាប់កោដិ ក៏ដោយ ក៏គាត់មិនដែលឱ្យទានសូម្បីតែមួយសេន ព្រោះគាត់មានទិដ្ឋិយល់ឃើញខុស។ នៅពេលដែលគាត់ស្លាប់ទៅ គាត់កើតជាឆ្កែនៅផ្ទះរបស់គាត់ ដែលគាត់មានចិត្តជាប់ជំពាក់នោះ។ ដោយសារឆ្កែនោះ អាចចាំអតីតជាតិរបស់ខ្លួនបាន វាក៏ដើរតាមកូនប្រុសរបស់វាឈ្មោះ សុភៈ នៅទីណាដែលសុភៈដើរទៅ ឆ្កែនោះដើរតាមគាត់រហូត។ សុភៈ ចូលចិត្តឆ្កែនោះ ក៏ដាក់ឱ្យវាដេកលើគ្រែ ហើយចិញ្ចឹមបីបាច់យ៉ាងល្អ។

ព្រះពុទ្ធទ្រង់បានដឹងអំពីឆ្កែនោះ ដូច្នេះ ព្រះអង្គទ្រង់យាងកាត់មុខផ្ទះរបស់សុភៈនៅពេលបិណ្ឌបាត។ ឆ្កែនោះព្រុះព្រះអង្គ ហើយព្រះអង្គទ្រង់ឈប់ រួចមានពុទ្ធដីកាថា " **អូ!**

**តោទេយ្យ** អ្នកមិនបានគោរពចំពោះតថាគតទេ កាលនៅជាមនុស្ស ហើយឥឡូវព្រុះតថាគត ពេលកើតជាសត្វឆ្កែ"។

ឆ្កែនោះមានទឹកមុខក្រៀមក្រំ នៅពេលបានឮពាក្យក្រើនរំលឹករបស់ព្រះពុទ្ធ។ វាជារឿងមួយគួរឱ្យខ្មាសអៀនណាស់ ដែលព្រះសម្មាសម្ពុទ្ធបានដឹងពីជីវិតរបស់ខ្លួន។ ដូច្នេះ ដោយមានការរកាំចិត្តយ៉ាងខ្លាំង វាក៏ដេកនៅលើគំនរផេះចង្ក្រាន។ នៅពេលឃើញឆ្កែនោះដេកនៅលើផេះ សុភៈ ក៏បានសួរមនុស្សរបស់គាត់ថា ឆ្កែនេះមានរឿងអ្វីបានជាដូច្នេះ។

អ្នកបម្រើឆ្លើយថា "បាទលោកម្ចាស់ ព្រះសមណគោតម ហៅឆ្កែនេះថា " **តោទេយ្យ** "។

" ព្រះសមណគោតម ចោទថា បានកើតជាឆ្កែបន្ទាប់ពីស្លាប់ទៅ។ អាត្មាអញមិនអាចទ្រាំនឹងការប្រមាថនេះបានទេ។ ដូច្នេះ អញនឹងទៅជម្រះរឿងនេះជាមួយព្រះអង្គសិន " ។ សុភៈ បានទៅកាន់វត្ត ជេតពន ទាំងកំហឹង។ ព្រះសម្មាសម្ពុទ្ធទ្រង់បានជ្រាបអំពីការមករបស់គាត់ ហើយរង់ចាំមើលគាត់។ នៅពេលដែលគាត់បានចូលទៅជិតព្រះសម្មាសម្ពុទ្ធ ព្រះអង្គទ្រង់បានសួរគាត់ដោយស្រគត់ស្រគំថា " សុភៈ តើអ្នកទទួលបានកំណប់ពាងមាសទាំង៤ ដែលបន្សល់ទុកដោយឪពុករបស់អ្នកហើយឬនៅ?"





ទោះបីជា សុភៈ ទទួលបានប្រាក់កាសទាំងអស់ ដោយបន្សល់ទុកដោយឪពុករបស់គាត់ក៏ដោយ ក៏គាត់នៅមិនទាន់បានទទួលកំណប់ពាងមាសទាំង ៤ នោះនៅឡើយ។ គាត់បានកំពុងរកពាងមាសនោះ ហើយព្រះសម្មាសម្ពុទ្ធដឹងអំពីរឿងនេះ។ នៅពេល ព្រះពុទ្ធ ទ្រង់បានសួរនូវអ្វីដែលគាត់ចាប់អារម្មណ៍បំផុតនោះ កំហឹងរបស់គាត់ក៏បានរសាយមួយរំពេច ហើយបានឆ្លើយ " អត់ទេ ទូលបង្គំមិនបានទទួលពាងមាសនោះនៅឡើយទេ " ។

"ប្រសិនបើអ្នកចង់បានមាសនោះ ចូរទៅផ្ទះ ហើយចិញ្ចឹមវាដោយអាហារឆ្ងាញ់ៗឱ្យបានឆ្អែត។ នៅពេលដែលវាងងុយដេក អ្នកទះខ្នងវាតិចៗដោយដៃ ហើយសួរថា " ពុកៗ តើពុកកប់ពាងមាសនោះនៅឯណា? អ្នកនឹងទទួលបានចម្លើយ " ។

សុភៈ បានដើរទៅផ្ទះដោយរីករាយ។ គាត់ឱ្យចំណីឆ្កែរបស់គាត់ស៊ីឆ្អែត។ នៅពេលដែលវាងងុយដេក គាត់ទះខ្នងវាតិចៗ ហើយសួរថា " ពុក តើពុកកប់ពាងមាសនៅកន្លែងណា? "

ដូច្នេះ មនុស្សមិនស្ទាក់ស្ទើរក្នុងការហៅឆ្កែរបស់គេថា "ឪពុក" ទេ ដើម្បីទទួលបានពាងមាសនោះ។ ឆ្កែរបស់ សុភៈ រីករាយខ្លាំងណាស់ ដោយកូនប្រុសដើមរបស់ខ្លួនបានហៅវាថា " ឪពុក "។ វាបានលោតហើយរត់ទៅកន្លែងកប់មាសនោះភ្លាម។

នៅពេលជីកត្រង់កន្លែងនោះ សុភៈ បានមាសមែន គាត់បាន អរគុណចំពោះព្រះពុទ្ធ ហើយក៏បានក្លាយទៅជាឧបដ្ឋាករបស់ ព្រះសម្មាសម្ពុទ្ធ [៤]។

(៥)ភិក្ខុឈ្មោះ តិស្សៈ បានសុគតនៅក្នុងវត្ត ជេតពន ដោយមានចិត្តជាប់ជំពាក់ សោកស្តាយចំពោះចីវរថ្មីមួយ ដែល ប្រគេនដោយបងស្រីរបស់លោក។ លោកបានកើតជាចៃនៅក្នុង ចីពរនោះ។ នៅពេលដែលសទ្ធិវិហារិក បានកំពុងចែកចាយចីពរ របស់លោក និងរបស់ផ្សេងៗទៀត ចៃនោះស្រែកថា " ខ្ញុំមិនឱ្យ ចីពររបស់ខ្ញុំទេ " ព្រះពុទ្ធ បានឮចៃនោះស្រែកពីគន្ធកុដិរបស់ព្រះ អង្គ។ ព្រះអង្គបានប្រាប់ភិក្ខុទាំងឡាយរង់ចាំដល់រយៈពេល ៧ ថ្ងៃ មុនពេលធ្វើការចែកចាយរបស់របររបស់ភិក្ខុ តិស្សៈ។ បន្ទាប់ពី បាន៧ថ្ងៃ ចៃនោះ ក៏បានស្លាប់ ហើយទៅកើតក្នុងភពថ្មីទៀត។

## ២. ការពិនិត្យសង្កេត របស់ព្រះមហាមោគ្គលាន

ព្រះមហាមោគ្គលាន អគ្គសាវ័កឆ្វេងរបស់ព្រះសម្មាសម្ពុទ្ធ ល្បីល្បាញខាងអភិញ្ញា ក្នុងចំណោមសាវ័កទាំងឡាយរបស់ព្រះ ពុទ្ធ។ ជារឿយៗលោកបាននិមន្តទៅមើលឋានទេវតា និងឋាន អបាយ សម្ភាសន៍ទេវតា និងសត្វនរកទាំងឡាយ។

(១) លោកនឹងបានសួរពួកទេវតា អំពីហេតុដែលពួក





គេមានភាពប្រណីតដ៏អស្ចារ្យ។

បន្ទាប់ពីបានដឹងអំពើបុណ្យដែលពួកគេបានធ្វើ ហើយ និងភាពប្រណីតដែលពួកទេវតានោះបានសោយ លោកបាន ត្រឡប់មកឋានមនុស្សលោកវិញ ហើយប្រាប់ជនទាំងឡាយ អំពីរឿងទាំងនេះ។

គ្រាមួយនោះលោកបានឃើញវិមានដ៏ធំ ថ្មីស្រឡាងមួយ នៅក្នុងឋានតាវតិង្ស ហើយបានសួរម្ចាស់វិមាននោះ ពីរឿងដែល នាងបានវិមាន។ ម្ចាស់វិមានបាននិយាយថា "នៅពេលនាង វិសាខា អ្នកមានទ្រព្យបានកសាងវត្ត បុព្វារាម ថ្វាយព្រះសម្មា-សម្ពុទ្ធ ហើយចែកនូវបុណ្យនាង ខ្ញុំបានពោលសរសើរអំពើ បុណ្យរបស់នាង ហើយបានអនុមោទនាថា សាធុ! សាធុ! ដោយសារអំពើបុណ្យហ្នឹង ធ្វើឱ្យខ្ញុំបានវិមាននេះឯង"។

(២)ព្រះមហាមោគ្គលាន ក៏បានទៅមើលឋានអបាយ។ លោកបានសួរពួកសត្វនរក នូវអ្វីដែលជាហេតុនៃសេចក្តីទុក្ខ របស់ពួកសត្វនរកទាំងនោះ។ ពួកនរក ឬសត្វនៅឋានអបាយ នោះ បានប្រាប់លោកអំពីអកុសលកម្ម ដែលពួកគេបានធ្វើ។ លោកបាននិមន្តត្រឡប់មកឋានមនុស្សលោកវិញ ហើយប្រាប់ រឿងរ៉ាវទាំងនេះ ដល់មនុស្សទាំងឡាយ។

នៅក្នុងរឿងមួយ បុរសម្នាក់មានប្រពន្ធពីរ។ គាត់យកចិត្ត

ទុកដាក់ចំពោះប្រពន្ធដែលមានវ័យក្មេង ហើយស្អាតជាង។ ប្រពន្ធចាស់មានចិត្តច្រណែននាង ហើយលួចសំលៀកបំពាក់ស្អាតៗ និងគ្រឿងសំអាងរបស់នាង ដើម្បីកុំឱ្យធ្វើខ្លួនបាន។ ក៏ប៉ុន្តែ បុរសនោះនៅតែចាប់អារម្មណ៍ប្រពន្ធក្មេងជាង។ យប់មួយ ប្រពន្ធចាស់បានចាក់ម្សៅរមស់លើគ្រែរបស់ប្រពន្ធក្មេង ។ នៅពេលប្រពន្ធក្មេងនោះចូលគេងលើគ្រែ នាងរមាស់ពេញខ្លួន ហើយមានស្នាមកន្ទួលលើស្បែក។ នាងទួញយំយ៉ាងវេទនា។

ស្រីចាស់ជាភរិយារបស់គាត់នោះ បានស្លាប់ទៅមិនយូរប៉ុន្មាន ក៏បានកើតជាប្រេត ដោយឧបបាតិកកំណើត។ នាងបានបង្ហាញខ្លួននៅចំពោះមុខស្រីក្មេងនោះ នៅវេលាល្ងាចមួយ ពេលនាងកំពុងងូតទឹក។ នាងមានរូបកាយអាក្រក់ គួរឱ្យភ័យខ្លាចបំផុត ធ្វើឱ្យភរិយាជាស្ត្រីក្មេងនោះ ភ្ញាក់ផ្អើលស្ទើរខ្យល់ចាប់ស្លាប់បាត់ស្មារតី។

“ប្អូនស្រីកុំខ្លាច។ខ្ញុំជាបងស្រីរបស់អ្នក។ បន្ទាប់ពីស្លាប់ទៅខ្ញុំបានកើតជាប្រេត។ ខ្ញុំគ្មានអ្វីសម្រាប់បរិភោគទេ។ ខ្ញុំឥតមានសំលៀកបំពាក់ ព្រោះខ្ញុំបានលួចសំលៀកបំពាក់ស្រស់ស្អាតរបស់អ្នក។ ខ្ញុំមានស្នាមកន្ទួលនៅលើស្បែក ហើយរមាស់ពេញខ្លួន ដូចដែលខ្ញុំបានធ្វើចំពោះអ្នក។ សូមអភ័យទោសចំពោះខ្ញុំ





និងជួយខ្ញុំផង។ ប្រេតនោះបាននិយាយថា “សូមប្រគេនចង្ហាន់និងចីវរ ចំពោះព្រះសង្ឃ ហើយឧទ្ទិសបុណ្យកុសលឱ្យខ្ញុំផង”។

ព្រោះតែកម្មអាក្រក់ពីអតីតជាតិ បុគ្គលត្រូវកើតជាប្រេត។ ប្រសិនបើញាតិគេធ្វើបុណ្យ ហើយឧទ្ទិសឱ្យ បើប្រេតនោះអាចរីករាយលើអំពើកុសល ហើយនិយាយក្នុងចិត្តតិចៗថា“សាធុ! សាធុ!” កុសលកម្ម ដែលនាងទទួលបានអាចរំដោះនាងចេញពីអបាយភូមិ ហើយផ្តល់ឱ្យនាងនូវអាហារ ភេសជ្ជៈ និងគ្រឿងស្លៀកពាក់ផ្សេងៗ។ ឱហ្ន៎ ! កុសលកម្ម និងអកុសលកម្ម មានអំណាចដល់ម្លឹង!

### ៣.ការទំនាក់ទំនងជាមួយបុគ្គលស្លាប់ តាមរយៈការដឹងដោយឥទ្ធិវិធី

នៅពេលមនុស្សខ្លះស្លាប់ទៅ គេអាចកើតជាទេវតា ឬប្រេត។ ទេវតាមានដូចជា ភូមិទេវតា នៅឋានចាតុមហារាជិកា។ ក្នុងចំណោមទេវតា ទាំងភូមិទេវតា និងរុក្ខទេវតាមានលំនៅដ្ឋានរបស់ពួកគេផ្ទាល់។ អាស្រ័យនៅទីកន្លែង និងការរស់នៅប្រកបដោយការលំបាក ដូចជារស់នៅលើដើមឈើ នៅគុម្ពោតឈើ ជ្រលងភ្នំ ជ្រោះជ្រលងដងអូរ ឧម្មង្គ លំនៅខ្មោច សំណង់ចាស់ដែលគេបោះបង់ចោល និងទីប៉ាឆា ទេវតាទាំងនេះហៅថា ភុម្មសិត

ទេវតា។ ពួកប្រេតទាំងឡាយមិនមានលំនៅដ្ឋានផ្ទាល់ខ្លួន។ គេហៅជាទូទៅថា ខ្មោចបិសាច យក្ស ម្រេញគង្វាល ជាដើម។

ពួកខ្មោចព្រាយបិសាចទាំងនេះ គ្មានលំនៅដ្ឋាន ជាពួកសត្វក្នុងអបាយភូមិ។ ដោយសារពួកសត្វទាំងនេះប្រាសចាកសេចក្តីសុខ គេអាចហៅថា "វិនិបាតិក អសុរៈ" ដូច្នេះក៏បាន។

ពួកប្រេតជាវិនិបាតិកតូចតាចនៅតាមដងផ្លូវ តាមចន្លោះផ្ទះ និងនៅគ្រប់ក្រហែងកៀនកោះ។ ពួកសត្វទាំងនោះធ្វើដំណើរទៅមកតាមផ្លូវ ពីកន្លែងមួយទៅកន្លែងមួយ ដើម្បីស្វែងរកអាហារសំណល់ សំបោរ ស្លេស្ម ជាដើម។ ពួកគេមានសភាពឱនថយ ទាបអន់ជាងមនុស្ស។ ពួកសត្វទាំងនោះ មិនអាចចូលក្នុងបរិវេណ ឬផ្ទះដោយគ្មានការអនុញ្ញាតពីម្ចាស់ឡើយ។ គេមានសភាពខ្ពស់ជាងមនុស្ស ដោយលក្ខណៈមួយ គឺថាគេអាចធ្វើខ្លួនគេមិនឱ្យមើលឃើញដោយអំណាចកម្មរបស់ខ្លួន។ ពួកសត្វទាំងនោះអាចការពារខ្លួនផ្ទាល់ ដោយអំណាចនេះពីការបៀតបៀនរបស់មនុស្ស។

ដូចមនុស្សទាំងឡាយខុសគ្នាក្នុង ឋានៈ ស្ថានភាព និងឥរិយាបថ ពួកអមនុស្សទាំងឡាយក៏ខុសគ្នា ក្នុងលទ្ធភាព ស្ថានភាព និងឥរិយាបថ ដូច្នោះដែរ ។ ប្រសិនបើបុគ្គលស្លាប់ទៅកើតជា អមនុស្ស ទេវតា ឬប្រេត ឥរិយាបថ និងចរិតលក្ខណៈរបស់





សត្វទាំងពីរពួកនេះមានច្រើន ឬ តិចជាងគ្នាដូចគ្នា។ មានពួកអមនុស្សចិត្តល្អ ដែលចូលចិត្តជួយមនុស្សលោក ហើយក៏មានពួកអមនុស្សអាក្រក់ ដែលចូលចិត្តយាយីមនុស្សដែរ។

បន្ទាប់ពីស្លាប់ទៅ ប្រសិនបើបុគ្គលនោះកើតជាឧបបាតិកជាទេវតា ឬប្រេត ពួកអមនុស្សទាំងនេះ អាចទាក់ទងជាមួយញាតិរបស់ខ្លួនបាន។ ពួកទេវតា និងប្រេត ដែលអាចធ្វើការទាក់ទងជាមួយមនុស្សគឺពួករុក្ខទេវតា ភុម្មសិតទេវតា និងពួកបរទត្តូជីវិតប្រេត ដែលនៅជិតមនុស្ស។ ព្រោះសត្វទាំងឡាយក្នុងអបាយភូមិ ជាសត្វសោយទុក្ខក្នុងកាមភព ពួកគេមានសភាពនៃសេចក្តីទុក្ខច្រើនជាងភុម្មសិតទេវតា។ មានពួកប្រេតប្រភេទផ្សេងៗគ្នាជាច្រើន ហើយក្នុងចំណោមពួកប្រេតទាំងនោះ មានតែបរត្តូជីវិតប្រេតទេ ដែលអាចមានទំនាក់ទំនងជាមួយមនុស្ស ហើយអាចទទួលការឧទ្ទិសបុណ្យ នៅពេលដែលពពួកញាតិរបស់ខ្លួនធ្វើហើយឧទ្ទិសឱ្យ។

ពួកភុម្មសិតទេវតា និងប្រេតពួកខ្លះអាចកើតជាឧបបាតិកកំណើត ឬពួកសត្វទាំងនោះអាចចាប់កំណើតក្នុងផ្ទៃម្តាយរបស់ខ្លួន ហើយសម្រាលចេញពីផ្ទៃដូចមនុស្សយើងដែរ បដិសន្ធិបន្ទាប់ពីបានចាប់កំណើតក្នុងផ្ទៃ។

នៅពេលដែលពួកសត្វអមនុស្សទាំងនោះ កើតជាឧបបាតិក

បដិសន្ធិ រូបកាយរបស់សត្វអមនុស្សនោះមានកម្មជរូបភាគច្រើន។ ដូច្នេះ គេមិនអាចមើលឃើញ ក៏មិនអាចប៉ះដោយមនុស្សបានដែរ។ ពួកអមនុស្សដែលមានលទ្ធភាព ឬ ឫទ្ធិទាប មិនអាចធ្វើខ្លួនឱ្យមើលឃើញបានទេ ប៉ុន្តែពួកមនុស្សដែលមានឫទ្ធិខ្ពស់ អាចធ្វើខ្លួនឱ្យមើលឃើញបាន។

ទោះបី ពួកគេកំពុងធ្វើដំណើរទៅមកតាមផ្លូវគ្រប់ច្រកល្ហកក៏ដោយ ក៏យើងមិនអាចមើលឃើញដោយមំសចក្ខុ គឺភ្នែកធម្មតាបានដែរ។ ទោះជាយ៉ាងនេះក្តី ប្រសិនបើយើងប្រតិបត្តិគឺចម្រើននូវសម្មាសមាធិ ឬ ញាណពិសេសយើងអាចមើលពួកគេឃើញ។

ក្រៅពីនេះ ក៏មានមនុស្សខ្លះ នៅក្នុងពិភពលោកបរិបូណ៌ដោយឥទ្ធិបាទតាំងពីកំណើត អាចមើលឃើញទេវតា និងប្រេតហើយទាក់ទងជាមួយពួកអមនុស្សទាំងនេះបាន។ បុគ្គលល្បីៗមួយចំនួនដែលមានឥទ្ធិបាទគឺអ្នកស្រី **ឡេអូនីរ៉ា ភីព័រ**( Mrs. Leonora Piper ) និង បណ្ឌិត **អេលីហ្សាប៊ែត គូប្លឺ-រូស្ស** ( Dr.Elizabeth Kubler-Ross )នៅសហរដ្ឋអាមេរិក និងអ្នកស្រី **អ៊ីស្តែល រ៉ូប៊ឺត**( Mrs.Estelle Roberts )ប្រទេសនៅអង់គ្លេស។





## អ្នកស្រី ឡេអូនីរ៉ា ភីព័រ ភ្នែកពណ៌ស និង ឧបការី

អ្នកស្រី **ឡេអូនីរ៉ា ភីព័រ**( Mrs.Leonora Piper ) រៀបការជាមួយលោក **វីលលៀម ភីព័រ**( William Piper )នៅអាយុ ២២ឆ្នាំ។ បីឆ្នាំក្រោយមក នាងមានកូនស្រីម្នាក់។ ពេលនោះរបួសចាស់បានចាប់ផ្តើមធ្វើឱ្យនាងមានបញ្ហា។ នាងបានពិគ្រោះជាមួយបុគ្គលខ្វាក់ម្នាក់ ដែលមានញាណពិសេស។ នាងបានសន្លប់បាត់ស្មារតី នៅពេលត្រូវបានពិនិត្យដោយបុគ្គលនោះ។

សប្តាហ៍បន្ទាប់ អ្នកស្រី **ភីព័រ** បានទៅជួបបុគ្គលនោះជាទៀងទាត់ ក្នុងនោះ បុគ្គលនោះបានធ្វើការទាក់ទងជាមួយមនុស្សស្លាប់។ អ្នកស្រី **ភីព័រ** មានអារម្មណ៍ថានាងត្រូវសណ្តំ។ នាងក្រោកឡើងរើសក្រដាសមកសរសេរនៅលើតុជាមួយខ្មៅដៃ ដោយបានកត់ត្រាយ៉ាងរហ័ស ហើយបានឱ្យក្រដាសនោះទៅមនុស្សម្នាក់ក្នុងរង្វង់នោះ។

នៅពេលនាងដឹងខ្លួនឡើងវិញ បុរសនោះបានអរគុណនាង ដែលបានឱ្យគាត់នូវសារមួយពីរកូនប្រុសរបស់គាត់ដែលស្លាប់។ ចាប់ពីពេលនោះមក នាងបានក្លាយជាមនុស្សមានញាណពិសេស ដែលបានធ្វើការទាក់ទងរវាងអមនុស្ស និងញាតិពីមុនរបស់អមនុស្ស។

ក្នុងការទាក់ទងជាមួយពិភពអមនុស្សនោះ មគ្គុទ្ទេសក៍អមនុស្សម្នាក់ អាចត្រូវគ្រប់គ្រងអណ្តាតរបស់អ្នកស្រី **ភីព័រ** ឱ្យនិយាយពាក្យ ដែលអមនុស្សនោះចង់ឱ្យនាងនិយាយ ឬក៏អមនុស្សជាអ្នកណែនាំនោះ គ្រប់គ្រងដៃរបស់អ្នកស្រី **ភីព័រ** ឱ្យសរសេរដោយស្វ័យប្រវត្តិ នូវអ្វីដែលពិភពអមនុស្សនោះចូលចិត្តទាក់ទង។

ដូច្នេះ បុគ្គលបីនាក់មកពីឋានអមនុស្ស អាចផ្ញើសារតាមរយៈអ្នកស្រី **ភីព័រ** ក្នុងពេលដំណាលគ្នាគឺម្នាក់កាន់ដៃស្តាំរបស់នាងឱ្យសរសេរដោយស្វ័យប្រវត្តិ ម្នាក់ទៀតកាន់ដៃឆ្វេងរបស់នាងឱ្យសរសេរនូវសារ បុគ្គលទីបីគ្រប់គ្រងអណ្តាតរបស់នាងឱ្យនិយាយនូវសារនោះចេញមក។ ក្នុងអំឡុងពេលនោះ អ្នកស្រី **ភីព័រ** នឹងបានស្ថិតនៅក្រោមការសណ្តំដោយគ្មានដឹងខ្លួន។

ទស្សនវិទូ សញ្ជាតិអាមេរិក ដែលល្បីឈ្មោះលើពិភពលោកគឺលោក **វីលលៀម ជេម** (William James) សាស្ត្រាចារ្យចិត្តវិទ្យានៅសាកលវិទ្យាល័យ **ហារ៉ឺដ** (Harvard University) បានត្រួតពិនិត្យវង្វង់ទាក់ទងរបស់អ្នកស្រី **ភីព័រ** អស់រយៈពេលមួយឆ្នាំកន្លះ ហើយបានសិក្សាពីញាណពិសេសរបស់នាង។ គាត់បានធ្វើការកត់សម្គាល់ដូចខាងក្រោម៖

*"ប្រសិនបើ អ្នកចង់បដិសេធសេចក្តីថ្លែងការណ៍ថា សត្វក្អែកទាំងអស់គឺ មានពណ៌ខ្មៅ អ្នក*





*មិនចាំបាច់ព្យាយាមបង្ហាញថា សត្វក្អែកទាំងអស់មិនមែនខ្មៅនោះទេ។ អ្នកគ្រាន់តែស្វែងរកក្អែកពណ៌សមួយ។ ប្រសិនបើ អ្នកអាចបង្ហាញក្អែកពណ៌សមួយ ពេលនោះសេចក្តីថ្លែងការណ៍ ដែលថា សត្វក្អែកទាំងអស់គឺពណ៌ខ្មៅ គឺត្រូវបានចាត់ទុកជាមោឃៈ។ ក្អែកពណ៌ស ដែលខ្ញុំបានរកឃើញគឺអ្នកស្រី **ភីព័រ** ។ ពេលនាងស្ថិតក្រោមការសណ្តំនាងអាចមើលឃើញ ស្តាប់ឮ និងដឹងនូវអ្វីដែលគេមិនអាចមើលឃើញ ស្តាប់ឮ និងដឹងដោយលក្ខណៈធម្មតាបាន"។*

អ្នកស្រី **ភីព័រ** ត្រូវបានគេអញ្ជើញទៅប្រទេសអង់គ្លេសជាច្រើនដង។ រូបវិទ្យាវិទូ សញ្ជាតិ អង់គ្លេស ដ៏ល្បីឈ្មោះម្នាក់គឺលោក **អូលីវើ ឡុច** (Sir Oliver Lodge) បានរៀបចំវង្វង់ទាក់ទងរបស់អ្នកស្រី **ភីព័រ** នៅផ្ទះរបស់គាត់។ ជារឿយៗគាត់សរសើរ អ្នកស្រី **ភីព័រ** ថា ដោយសារតែនាង គាត់បានជឿថា មានអនាគតជាតិ។ អ្នកស្រី **ភីព័រ** បានទស្សន៍ទាយថា កូនប្រុសរបស់គាត់ឈ្មោះ **រ៉េម៉ុនដ៏** (Raymond) បានស្លាប់ក្នុងសង្គ្រាមលោកលើកទី១។ ការទស្សន៍ទាយនោះគឺពិត។

អ្នកស្រី **ភីព័រ** បានស្លាប់នៅឆ្នាំ១៩៥០។ នៅពេលកូន

ស្រីរបស់នាង បានសរសេរសៀវភៅមួយក្បាលអំពីនាង **លោក អូលីវ ឡូច** បានសរសេរក្នុងសេចក្ដីផ្ដើមដូចខាងក្រោមៈ

*"អ្នកស្រី **ភីព័រ** គឺជាឧបការីជនដ៏អស្ចារ្យម្នាក់របស់មនុស្សជាតិ។ នាងបានធ្វើអំពើល្អជាច្រើនដល់ប្រជាជន ដោយអំណាចនៃវិញ្ញាណដឹងក្រៅខ្លួនរបស់នាង។ នាងបានធ្វើឱ្យស្ងប់នូវសេចក្ដីទុក្ខ និង សេចក្ដីព្រួយបារម្ភរបស់គ្រួសារដែលបាក់បែកជាច្រើន ដោយការជួយពួកគេដើម្បីទាក់ទងជាមួយបុគ្គលជាទីស្រលាញ់របស់គេដែលស្លាប់ទៅ។ នាងបានធ្វើយ៉ាងច្បាស់ ក្នុងការអនុវត្តភាគច្រើនបំផុត និងអការៈច្បាស់ថាមានអនាគតជាតិ បន្ទាប់ពីសេចក្ដីស្លាប់។ នាងបានបង្កើតឱកាសសម្រាប់អ្នកវិទ្យាសាស្ត្រដើម្បីពិនិត្យសង្កេតលក្ខណៈ និងគុណសម្បត្តិរបស់វិញ្ញាណ ដែលដឹងនៅខាងក្រៅរូបកាយរបស់ខ្លួននោះ"។*

## អ៊ីស្តែល រ៉ូប៊ឺត និងទេវតាពពកក្រហម

**អ៊ីស្តែល រ៉ូប៊ឺត** នៅប្រទេសអង់គ្លេស អាចមើលឃើញពួកអមនុស្ស ហើយធ្វើការទាក់ទងជាមួយអមនុស្សនោះអស់មួយជីវិត





រស់នាងតាំងពីនៅក្មេង។ នាងបានជួយមនុស្ស ដើម្បីទំនាក់ទំនងជាមួយញាតិរបស់គេ ដែលស្លាប់ទៅជាច្រើនលើក តាំងពីឆ្នាំ ១៩២៥-១៩៧០។

នៅពេល **អ៊ីស្តែល រ៉ូប៊ឺត** ធ្វើដំណើរចេញទៅក្រៅ នាងអាចមើលឃើញពួកអមនុស្ស ត្រេចចរតាមដងផ្លូវ។ វាហាក់ដូចជាការជួបមនុស្សជាច្រើនតាមផ្លូវអ៊ូអរ ដ៏មមាញឹកនៅតាមកន្លែងប្រកបរបបចិញ្ចឹមជីវិតគឺថា ម្នាក់ៗធ្វើដំណើរប្រកបកិច្ចការរៀងៗខ្លួនដូច្នោះដែរ។ បន្ទាប់ពីបានឃើញពួកអមនុស្សជាច្រើនដងរឿងរ៉ាវនោះ បានក្លាយទៅជាថ្មីកធម្មតា ។

**អ៊ីស្តែល រ៉ូប៊ឺត** បានរៀបការនៅអាយុ១៨ឆ្នាំ។ នាងមានកូន៣នាក់ ហើយបន្ទាប់មក ប្ដីរបស់នាងមានជម្ងឺរុំារ៉ៃ ដេកនៅនឹងគ្រែ។ ដូច្នេះ នាងត្រូវថែរក្សាប្ដីឈឺរបស់នាង ព្រមទាំងកូនៗនិងធ្វើការដើម្បីទំនុកបម្រុងគ្រួសារ។ ដូច្នេះ នាងត្រូវរ៉ាប់រងកិច្ចការលំបាក និងមានសេចក្ដីទុក្ខជាច្រើន។

នៅពេលប្ដីរបស់នាងស្លាប់ទៅ ប្ដីនាងបានមករកនាងទាំងនៅខ្លួនជាទេវតា ៣ដង ៣យប់ផ្ទួនៗ។ ដោយបានឃើញនាងមានទឹកមុខក្រៀមក្រំ ទេវតានោះបានបបួលនាងទៅជាមួយខ្លួន។

នាងសួរថា " តើខ្ញុំអាចទៅជាមួយអ្នកដូចម្ដេចកើត ? "

ទេវតានោះថា "អ្នកស្លាប់ ហើយមកជាមួយគ្នា" ។ នាង ក៏ឆ្លើយថា "ខ្ញុំមិនអាចស្លាប់បានទេ ខ្ញុំត្រូវចិញ្ចឹមបីបាច់ថែរក្សាកូនៗ" ។ ទេវតានោះក៏លែងនិយាយអ្វីទៀត ហើយក៏បានចាកចេញទៅដោយក្រៀមក្រំ។

នៅថ្ងៃមុនពេលថ្ងៃបញ្ចុះសព ទេវតានោះបានមកម្តងទៀត ហើយសុំអភ័យទោសនាងថា " ខ្ញុំមិនយល់ទេ។ ខ្ញុំមិនត្រូវការអ្នកទៀតទេ។ អ្នកមិនចាំបាច់បំរើខ្ញុំទៀតឡើយ។ ខ្ញុំអាចរស់នៅដោយខ្លួនឯងបាន។ អ្វីដែលអ្នកនិយាយគឺពិត។ បុគ្គលគ្រប់រូបគឺអាចរស់បាននៅភពអមនុស្ស បន្ទាប់ពីសេចក្តីស្លាប់ពីឋានមនុស្សលោក ។ វាជារឿងមួយគួរឱ្យភ្ញាក់ផ្អើលណាស់"។

**អ៊ីស្តែល រ៉ូប៊ឺត** បាននិយាយថា " នៅពេលអ្នកបានរស់ឡើងវិញ បន្ទាប់ពីស្លាប់ បុគ្គលដទៃទៀតទាំងអស់ដែលស្លាប់ទៅ ក៏រស់រានឡើងមានជីវិតឡើងវិញ បន្ទាប់ពីការស្លាប់របស់ពួកគេក្នុងជាតិជាមនុស្សដែរ។ ខ្ញុំត្រូវប្រាប់មនុស្សផងគ្នាអំពីរឿងនេះ ដើម្បីឱ្យពិភពលោកទាំងមូលដឹងអំពីវា"។

នៅពេលនោះ **អ៊ីស្តែល រ៉ូប៊ឺត** មានអាយុ៣០ឆ្នាំ។ នាងបានរៀបការជាមួយលោក **អាសឺរ៍ រ៉ូប៊ឺត** នៅឆ្នាំក្រោយ។ ដោយសារនាងមិនបានធ្វើការទៀត នាងមានពេលជាច្រើនដើម្បីគិតអំពីទេវតាទាំងឡាយដែលមករកនាង។ នាងក៏បានចូលរួម





កិច្ចប្រជុំខាងសាសនា ដែលនៅក្នុងនោះពួកញាតិដែលមានជីវិតរស់នៅ បានទាក់ទងជាមួយពួកអមនុស្សនៃបុគ្គលជាទីស្រលាញ់របស់គេដែលស្លាប់ទៅ តាមរយៈការបញ្ចូលរូបដែលដឹងដោយវិញ្ញាណក្រៅខ្លួន។

ពេលនោះរូបបញ្ចូលនោះប្រាប់ **អ៊ីស្តែល រ៉ូប៊ឺត**ថា " អ្នកក៏ជារូបអារក្សដែរ។ អ្នកឯងមានកិច្ចការជាច្រើនត្រូវធ្វើ។ នៅពេលដែលពិភពអមនុស្សជ្រើសរើសអ្នក ហើយផ្តល់ទំនួលខុសត្រូវដល់អ្នក ចូរកុំបដិសេធ "។

**អ៊ីស្តែល រ៉ូប៊ឺត** ចង់ប្រើឫទ្ធិនៃការដឹងដោយវិញ្ញាណក្រៅខ្លួនរបស់នាង ដើម្បីជាប្រយោជន៍ដល់ជនជាច្រើន។ យប់មួយនាងបានអង្គុយម្នាក់ឯងក្នុងទីងងឹត ដើម្បីទាក់ទងជាមួយនឹងពិភពអមនុស្ស។ ពេលនោះនាងឮសំឡេងកំពុងនិយាយជាភាសាអង់គ្លេសយ៉ាងច្បាស់ថាៈ

"ខ្ញុំមកដើម្បីបំរើពិភពលោក។ ខ្ញុំនឹងធ្វើការជាមួយអ្នក"។

**អ៊ីស្តែល រ៉ូប៊ឺត** បានសួរថា "តើអ្នកជានរណា ?"

សំឡេងនោះបានឆ្លើយថា "នាងស្គាល់ថា ពពកក្រហម ខ្ញុំនឹងធ្វើជាអ្នកនាំផ្លូវអ្នក"។

នៅខណៈពេលនោះ ក្បាលមនុស្សមួយបានលេចហ៊ុម

ព័ទ្ធដោយពន្លឺដែលមានពណ៌ **អូលីវ** មានភ្នែកពណ៌ខ្មៅ រាងស្គម ហើយមានពុកមាត់ពណ៌ខ្មៅ។

ពពកក្រហមជាបណ្ឌិតមានអំណាច។ គាត់បានធ្វើជាទេវតានាំផ្លូវ និងជាអ្នកថែរក្សាដល់ **អ៊ីស្តែល** ជាងហាសិបឆ្នាំ។ ក្នុងការទំនាក់ទំនងជាមួយ **អ៊ីស្តែល រ៉ូប៊ឺត** គាត់បានពន្យល់បំភ្លឺពីអត្ថិភាពរបស់ពិភពអមនុស្ស ចំពោះមនុស្សម្នាក់តាមលក្ខណៈនៃការអនុវត្ត និងភាពអស្ចារ្យ ។ គាត់ ក៏បានព្យាបាលអ្នកជម្ងឺជាច្រើនពីរោគរ៉ាំរ៉ៃរបស់ពួកគេ។

គាត់ក៏បានស្រាយបំភ្លឺភាពខុសគ្នារវាង ពិភពអមនុស្ស និងពិភពសរីរាង្គឱ្យអ្នកវិទ្យាសាស្ត្របានដឹង។

ឧទាហរណ៍ មួយសប្តាហ៍បន្ទាប់បានជួបជាមួយ **រិត ខ្លោដ** (Red cloud) **អ៊ីស្តែល** បានអញ្ជើញ **អាស័រ** ប្តីរបស់នាងឱ្យអង្គុយនៅខាងមុខនាង នៅបន្ទប់ទទួលភ្ញៀវក្នុងទីងងឹត។ គេអង្គុយទល់មុខគ្នាលើកៅអីនីមួយៗ។ រំពេចនោះមានភ្លើងស្វែងរកភ្លឺដូចពណ៌មាស កើតមានលើ **អ៊ីស្តែល រ៉ូប៊ឺត** ត្រង់ពីខាងលើ ដូចជាពន្លឺព្រាលនៃភ្លើងស្វែងរកមានចំពោះអ្នករបាំនៅលើឆាក។ **អាស័រ** បានឆ្លើយតបយ៉ាងលឿន។

គាត់បានកត់សម្គាល់ថា **អ៊ីស្តែល,** អ្នកនៅឯណា? តើអ្នកនៅកន្លែងណា?





"ខ្ញុំកំពុងអង្គុយនៅខាងមុខអ្នក។ ខ្ញុំឥតទៅណាទេ"។

"វាមិនអាចទេ។ ឥតមាននរណាម្នាក់ នៅលើកៅអីរបស់អ្នកទេ។ ខ្ញុំអាចមើលឃើញកម្រាល និងខ្នងកៅអីរបស់អ្នក"។

"ក្នុងករណីហ្នឹង ចូរអ្នករាប់ប្រហោងកៅអីផ្តៅរបស់អ្នកមើល"។

"**អាស័រ** ឈ្ងោកទៅមុខ ហើយទើសកៅអីផ្តៅនោះ ដោយចង្អុលដៃរបស់គាត់ ដើម្បីរាប់ប្រហោង។ គាត់ឥតបានប៉ះត្រូវ **អ៊ីស្តែល រ៉ូប៊ឺត** ទេ"។

**អាស័រ** ឆ្លើយថា "មាន២៨ប្រហោងក្នុងមួយជួរ"។ ពេលនោះភ្លើងដែលរកមើលនោះ ក៏បាត់ទៅភ្លាម។ **អ៊ីស្តែល** និង **អាស័រ** បានកំពុងអង្គុយដូចពីមុនក្នុងទីងងឹត។ **អាស័រ** បានបើកភ្លើងនៅក្នុងបន្ទប់ភ្លាម ហើយរាប់ប្រហោងជួរនៃប្រហោងកៅអីផ្តៅនោះ។ តាមពិតទៅ គឺមានប្រហោងចំនួន ២៨ ក្នុងមួយជួរមែន។

ពីរបីឆ្នាំក្រោយមក **អ៊ីស្តែល រ៉ូប៊ឺត** ក្លាយជាអ្នកល្បី។អ្នកថតរូបម្នាក់ បានថតរូបឥតព្រៀងទុកមួយរបស់ **អ៊ីស្តែល រ៉ូប៊ឺត** ដែលកំពុងអង្គុយនៅលើកៅអីមួយ។ នៅពេលដែលគេផ្តិតហ្វីលរូបថត គឺមានតែកៅអីទទេគឺ **អ៊ីស្តែល រ៉ូប៊ឺត** មិនឃើញ **អ៊ីស្តែល រ៉ូប៊ឺត** អង្គុយលើកៅអីនោះទេ។

## សារសម្ងាត់ រវាងគូស្នេហ៍មួយគូ

ថ្ងៃមួយ ស្រីក្រមុំម្នាក់បានចូលរួមការប្រជុំស្ដីពីចិត្តរបស់ **អ៊ីស្ដែល រ៉ូប៊ឺត**។ នាងចង់ទាក់ទងជាមួយគូស្នេហ៍របស់នាង ដែលបានស្លាប់ទៅថ្មីៗ ក្នុងគ្រោះថ្នាក់មួយ។ ព្រលឹងគូស្នេហ៍ របស់នាងមកដល់ភ្លាម ហើយផ្ដាំផ្ញើដល់ **អ៊ីស្ដែល** ម្ដងហើយ ម្ដងទៀត។

**អ៊ីស្ដែល** ស្ទាក់ស្ទើរមិនហ៊ាននិយាយចេញមកនូវសារនោះ ដូច្នេះនាងបានសួរស្រីក្រមុំនោះថា "តើគូស្នេហ៍របស់អ្នកធ្លាប់ និយាយពាក្យទ្រគោះបោកឬទេ?"

"ទេ, តើគាត់បាននិយាយអ្វីទេ?"

"គាត់បានកំពុងនិយាយសាចុះសាឡើងមិនអ៊ីចឹងទេឬ?"

"តើអ៊ីចឹងមែនឬ? ហា! ហា! ហ្នឹងគឺជាសារល្បីល្បាញ មួយពីការសម្ដែងល្ខោនរបស់ **ប៊ឺន ណាជហ្សរ៍** ។ នៅពេលគូ ស្នេហ៍របស់ខ្ញុំ និងខ្ញុំនៅជាមួយគ្នា ហើយបានព្រមព្រៀងគ្នា ប្រើសារផ្ដាំផ្ញើនោះដើម្បីប្រាប់អ្នកនៅរស់ ប្រសិនបើយើងទាំង ពីរ,នរណាម្នាក់បានស្លាប់ទៅ"។

ពួកអមនុស្សដែលកើតដោយ ឧបបាតិកបដិសន្ធិ ចងចាំ នូវអតីតជាតិ និងសង្សាររបស់ពួកគេបាន។ គេនៅតែស្រលាញ់





សង្សាររបស់គេ ទោះបីជាពួកគេទៅទីណាក៏ដោយ។ **អ៊ីស្ដែល រ៉ូប៊ឺត** បានកត់សម្គាល់ថា ចរិតលក្ខណៈ អាកប្បកិរិយា និង របៀបដែលពួកគេបាននិយាយ មិនបានផ្លាស់ប្ដូរទេ។

## នៅតែមានការចងចាំពីពិភពអមនុស្ស

**ធីរិន រ៉ូប៊ឺត**(Terrence Roberts) កូនប្រុសពៅរបស់ **អ៊ីស្ដែល** មិនជឿទៅលើការដឹងដោយវិញ្ញាណក្រៅខ្លួនទេ ហើយ គាត់មិនចង់ដឹងឮពីពិភពអមនុស្សឡើយ។ **អ៊ីស្ដែល** ចង់ឱ្យកូន ប្រុសរបស់នាងដឹងអំពីអនាគតភពរបស់មនុស្ស នៅពេលដែល ពួកគេបានស្លាប់ទៅ។ ប៉ុន្តែនាងមិនចង់និយាយដោយការបង្ខំ ឡើយ។

នៅពេល **ធីរិន** អាយុម្ភៃឆ្នាំ គាត់បានក្លាយជានាយ ទាហានវ័យក្មេងខាងទ័ពអាកាស។ នៅថ្ងៃចុងសប្ដាហ៍មួយ គាត់បានមកផ្ទះជាមួយមិត្តស្រីម្នាក់ ដើម្បីមកមើលម្ដាយរបស់ គាត់។ នៅខណៈពេលពួកគេកំពុងជជែកគ្នាក្នុងបន្ទប់ទទួល ភ្ញៀវ **អ៊ីស្ដែល រ៉ូប៊ឺត** បាននិយាយទៅកាន់កូនប្រុសរបស់នាង ហៅគាត់ថា "**ថេរី** មិត្តរបស់អ្នកម្នាក់ កំពុងឈរនៅក្បែរអ្នក"។

"ពិតឬ ? តើគាត់ឈ្មោះអ្វី?"

**ធីរិន** បានទុកវាថាជារឿងកំប្លែង ហើយក៏ឆ្លើយលេងៗ។

“ឈ្មោះរបស់គាត់គឺ **ជីមី មាកហ្វាឡែន** ។ តើអ្នកមានមិត្តឈ្មោះដូច្នេះទេ?”

“អូមែនហើយ! តើគាត់ស្លាប់ហើយឬ?”

“គាត់បានស្លាប់ប្រហែលមួយឆ្នាំហើយ។ ហេតុអ្វីបានជាគាត់ចេះតែហៅអ្នកថា “**ថូឌី** ?”

“ពិតឬ? ឱព្រះអើយ! គេមិនបានហៅឈ្មោះខ្ញុំថា “**ថូឌី**” អស់ជាច្រើនឆ្នាំហើយ។ មានតែជីមីទេ ហៅខ្ញុំដូច្នេះ។ នៅពេលយើងនៅជាសិស្សសាលា ខ្ញុំចិញ្ចឹមគីង្គក់បី ឬបួនក្បាល ព្រោះខ្ញុំស្រឡាញ់វា។ ដូច្នេះ គាត់ហៅខ្ញុំថា “**ថូឌី**”។ ម៉ែ តើម៉ែឮគាត់ហៅខ្ញុំថា “**ថូឌី**” ទេ?

“តើឱ្យម៉ាក់អាចដឹងយ៉ាងមេចទៅ ប្រសិនបើគាត់មិនបានហៅកូនដូច្នេះនោះ?”

“តើគាត់ស្លាប់ដូចម្តេចម៉ាក់?”

“គាត់បានបម្រើការងារជាទាហានជើងទឹក។ ក្នុងអំឡុងសង្គ្រាមលោកលើកទី២ នៅខណៈពេលនាវារបស់ពួកគេបានបោះយុថ្កា នៅប្រទេស **ស្កុតឡែន** យន្តហោះសត្រូវបានទម្លាក់គ្រាប់បែកលើនាវារបស់ពួកគេ ហើយគាត់ក៏ត្រូវបានហក់ទៅក្នុងសមុទ្រ។ គាត់ក៏លង់ទឹកសមុទ្រទៅ។ គាត់បាននិយាយថា





ម្តាយរបស់គាត់នៅតែមានជីវិតរស់នៅ ក្នុងផ្ទះចាស់របស់ពួកគេ”។

“**ជីរិន** ក្រោកឡើងមួយរំពេច ហើយកាន់ដៃមិត្តស្រីរបស់គាត់”។

“មក, តោះទៅផ្ទះរបស់ម្តាយ **ជីមី** ។ ខ្ញុំស្គាល់កន្លែង”។ ពួកគេបានត្រឡប់មកប្រហែលពីម៉ោងក្រោយមក ។ ពួកគេបាននិយាយទៅកាន់ម្តាយរបស់ ជីមី ហើយគេបានរកឃើញថា អ្វីដែល **អ៊ីស្តែល រ៉ូប៊ីត** បាននិយាយគឺពិត។

**អ៊ីស្តែល រ៉ូប៊ីត** បាននិយាយថា **ជីរិន** “ជីមី មិត្តរបស់អ្នកបានផ្ញើសារមួយឱ្យអ្នក ចូរអ្នកមើលនៅម៉ោង៩ព្រឹក ថ្ងៃច័ន្ទ។ គាត់នឹងបង្ហាញនូវសញ្ញាណខ្លះៗ ដែលអ្នកអាចចងចាំ”។

នៅព្រឹកថ្ងៃច័ន្ទ **ជីរិន** ត្រូវរាយការណ៍ចំពោះកាតព្វកិច្ច នៅការិយាល័យរបស់គាត់។ ក៏ប៉ុន្តែ គាត់បានដេកជ្រុល។ ដូច្នេះគាត់កំពុងបានម៉ឺម្នាស្ទុះទៅកាន់ទីធ្លាព្រះវិហារគ្រិស្ត ដើម្បីរាយការណ៍ចំពោះកាតព្វកិច្ចឱ្យទាន់ពេលវេលា។ ពេលនោះឯង នាឡិកាប៉ោល នៅលើជញ្ជាំងរោទិ៍៩ដង។ **ជីរិន** បានឱនបន្តិច ដើម្បីដើរកាត់ក្រោមមែកស្រល់។ ក៏ប៉ុន្តែមួករបស់គាត់កោះជាប់មែកស្រល់នោះ ហើយក៏បានក្រវាត់ធ្លាក់មកលើដី។

នៅខណៈពេលដែល **ជីរិន** បានរើសមួករបស់គាត់ៗ

បាននឹកឃើញការផ្ដាំផ្ញើរបស់ **ជីមី** ។ នៅពេលជាមួយគ្នានោះដែរ គាត់ក៏បាននឹកឃើញថា **ជីមី** ធ្លាប់ប្រាប់សញ្ញាមួករបស់គាត់នៅសាលាម្ដង ហើយម្ដងទៀតកាលនៅជាសិស្សសាលា។

"អូ! **ជីមី** មិត្តរបស់ខ្ញុំអ្នកនៅតែចាំខ្ញុំបានពីពិភពអមនុស្ស!"

## ការទំនាក់ទំនងរវាងសាធារណជន និងញាតិរបស់គេដែលស្លាប់ទៅ

ជាង៥០ឆ្នាំ **អ៊ីស្ដែល រ៉ូប៊ីត** បានផ្ដល់សេវាកម្មរបស់នាងចំពោះសាធារណជន ដើម្បីជួយពួកគេ ដើម្បីទំនាក់ទំនងជាមួយញាតិរបស់គេដែលស្លាប់ទៅពីភពអមនុស្ស។ ការទាក់ទងជាសាធារណៈជាមួយអ្នកស្លាប់ទៅ ត្រូវបានប្រារព្ធធ្វើនៅសាលសាធារណៈដ៏ល្បីល្បាញនៅពាសពេញប្រទេស អង់គ្លេស ព្រមទាំងនៅ អឺរុប និង អៀកឡង់។ មនុស្សរាប់ពាន់នាក់បានចូលរួមពេញសាល ដើម្បីមានឱកាសទំនាក់ទំនងជាមួយញាតិរបស់ខ្លួនដែលស្លាប់ទៅ។





## ការទំនាក់ទំនងរវាងសាធារណជន និង ពិភពអមនុស្ស នៅសាលារ៉ូយ៉ាល់ អលប៊ឺត ទីក្រុងឡុងដ៍

ព័ត៌មានអំពីការប្រារព្ធធ្វើការទំនាក់ទំនងជាសាធារណៈ ជាមួយបុគ្គលដែលស្លាប់ទៅ ធម្មតាត្រូវបានប្រកាសជាមុន នៅក្នុងទស្សនាវដ្ដីនិងតាមកាសែតនានា។ ដូច្នេះ ប្រជាជនបានប្រជុំគ្នានៅសាលសាធារណៈ នៅថ្ងៃដែលបានណាត់ជួប។ ញាតិដែលស្លាប់ទៅជាច្រើន ពិភពអមនុស្សក៏បានមកកាន់កន្លែងដែលបានធ្វើការទំនាក់ទំនងនោះដែរ។

**អ៊ីស្ដែល រ៉ូប៊ីត** ក៏បានទៅកាន់សាលនោះមួយម៉ោងមុន ហើយបានធ្វើការទាក់ទងជាមួយពិភពអមនុស្ស។

"ខ្ញុំមកទីនេះ ដើម្បីសាងមិត្តភាពរវាងអ្នក និងញាតិ ដែលកំពុងរស់នៅរបស់អ្នក។ ខ្ញុំ នឹងជួយអ្នក ដើម្បីធ្វើការទំនាក់ទំនងជាមួយពួកគេ។ សូមអ្នកទាំងអស់គ្នាជួយខ្ញុំផង"។

*បុគ្គលទាំងឡាយមកពីពិភពអមនុស្ស ក៏ចង់ទំនាក់ទំនងជាមួយញាតិរបស់ពួកគេដែរ។ ពួកគេចង់ប្រាប់ញាតិរបស់ពួកគេថា ពួកគេមិនបានស្លាប់ទេ ហើយពួកគេនៅមានជីវិតរស់នៅឡើយ។ពួកគេចង់បញ្ចប់នូវសេចក្ដីទុក្ខសោក និងសេចក្ដីព្រួយបារម្ភរបស់ឪពុកម្ដាយ និង*

*ញាតិរបស់ពួកគេ។ ពួកគេបានព្យាយាមទាក់ទងជាមួយ ញាតិរបស់ពួកគេ ប៉ុន្តែពួកគេមិនអាចធ្វើបាន។ ដូច្នេះ ពួកគេបានកំពុងរង់ចាំឱកាសមាសនេះ ដើម្បីធ្វើការទំនាក់ទំនងជាមួយញាតិរបស់ពួកគេតាមរយៈការបញ្ចូលរូប។*

ពេលវេលាសំរាប់ធ្វើការទំនាក់ទំនងបានមកដល់។ សមាជិកនៃក្រុមប្រឹក្សា និង **អ៊ីស្តែល រ៉ូប៊ឺត** បានចាប់ផ្តើមកម្មវិធី។ ការប្រជុំខាងសាសនាបានចាប់ផ្តើមឡើង ដោយការសូត្រធម៌បួងសួង។ បន្ទាប់មក សមាជិកល្បីនៃប្រធានក្រុមប្រឹក្សាបានចាប់ធ្វើសុន្ទរកថាផ្តើម។

បន្ទាប់មក **អ៊ីស្តែល រ៉ូប៊ឺត** បានដើរទៅខាងមុខឆាក កាន់ក្បាលមីក្រូនៅក្នុងដៃរបស់នាង។ បុគ្គលទាំងឡាយ ដែលមិនអាចមើលឃើញមកពីពិភពអមនុស្ស បានមកឈរជុំវិញនាង សូមអង្វរឱ្យនាងអនុញ្ញាតឱ្យគាត់ ឬនាងទាក់ទងឪពុកម្តាយរបស់គាត់ ឬរបស់នាង។ **អ៊ីស្តែល**បានស្នើសុំឱ្យពួកគេនិយាយម្តងម្នាក់។ អ្នកស្តាប់បានកំពុងរង់ចាំការរំពឹងគិតយ៉ាងខ្លាំង។ **អ៊ីស្តែល រ៉ូប៊ឺត** បានចង្អុលដៃស្តាំរបស់នាងទៅកាន់អ្នកស្តាប់និយាយដោយមីក្រូហ្វូនថា "**មូលីចនសិន លីសស្លេ** កូនស្រីរបស់អ្នកបានផ្តាំអ្នកថា "ម៉ាក់ៗ បានមើលរូបថតរបស់ខ្ញុំ ហើយបានយំនៅព្រឹកនេះ។ ខ្ញុំក្រៀមក្រំណាស់ ដែលបានឃើញម៉ាក់ទួញយំ។ ខ្ញុំនៅជាមួយម៉ាក់។ ខ្ញុំមិនស្លាប់ទេ។ ខ្ញុំនៅរស់។ ខ្ញុំបាននិយាយទៅរកម៉ាក់ ប៉ុន្តែ ម៉ាក់មិនអាចឮខ្ញុំទេ។ ម៉ាក់ សូមម៉ាក់កុំយំទៀតអី"។





អ្នកស្រី **ម៉ូលី ចន សិន** រីករាយណាស់ដែលបានឮការផ្តាំផ្ញើនោះ។

**អ៊ីស្តែល រ៉ូប៊ឺត** បានប្រកាសម្តងទៀតថា" លោក **ហារិចសិន** ខ្ញុំមានការផ្តាំផ្ញើមួយសំរាប់អ្នកពី **ចននី** កូនប្រុសរបស់អ្នក។ គាត់និយាយថា គាត់បានស្លាប់ទៅដោយគ្រោះថ្នាក់ចរាចរណ៍ម៉ូតូ។ នេះគឺជាការផ្តាំផ្ញើរបស់គាត់ "ពុក និងម៉ែ ខ្ញុំសោកស្តាយខ្លាំងណាស់ ដែលធ្វើឱ្យអ្នកមិនសប្បាយជាមួយនឹងគ្រោះថ្នាក់ចរាចរណ៍របស់ខ្ញុំ។ វាបានកើតឡើងយ៉ាងឆាប់រហ័ស ដែលខ្ញុំមិនអាចចៀសវាងបាន។ ប៉ុន្តែ ខ្ញុំមិនស្លាប់ទេ ខ្ញុំនៅតែមានជីវិតរស់នៅ។ កុំព្រួយបារម្ភអំពីខ្ញុំអី។ អ្វីៗគ្រប់យ៉ាងដែលខ្ញុំត្រូវការ។ កុំទុកម៉ូតូនោះអី ខ្ញុំអាចធ្វើដំណើរបានលឿនជាងម៉ូតូនោះ"។

ការផ្តាំផ្ញើខ្លះខ្លី ខ្លះវែង ខ្លះទៀតមិនច្បាស់លាស់។ មានតែបុគ្គលទាំងឡាយ ដែលមានការពាក់ព័ន្ធទើបនឹងអាចយល់បាន។ អ្នកទាំងឡាយណាដែលទទួលបានការផ្តាំផ្ញើ គឺមានសេចក្តីរីករាយយ៉ាងខ្លាំង ហើយស្រែកពាក្យអរគុណចំពោះ **អ៊ីស្តែល រ៉ូប៊ឺត**។ កិច្ចប្រជុំខាងសាសនាបានប្រព្រឹត្តទៅអស់

រយៈពេលប្រហែលមួយម៉ោង។ ពេលនោះឯង **ពពកក្រហម** ជាទេវតាអ្នកណែនាំ បានក្រើនរំលឹក **អ៊ីស្ដែល រ៉ូប៊ឺត** ឱ្យបញ្ឈប់កិច្ចប្រជុំនោះ។ គាត់តែងតែឃ្លាំមើលស្ថានភាពនោះ ដោយយកចិត្តទុកដាក់ ហើយគាត់មិនចង់ឱ្យ **អ៊ីស្ដែល** មានបន្ទុកធ្ងន់ និងគ្រោះថ្នាក់ឡើយ។

នៅពេលដែល **អ៊ីស្ដែល រ៉ូប៊ឺត** បានប្រកាសថា វាដល់ពេលបញ្ចប់កិច្ចប្រជុំនោះ អ្នកស្ដាប់ជាច្រើន និងជនទាំងឡាយមកពីពិភពអមនុស្ស មានអារម្មណ៍មិនទាន់អស់ចិត្ត ពីព្រោះពួកគេមិនមានឱកាស ដើម្បីទំនាក់ទំនងនៅថ្ងៃនោះ។

វាជាដំណឹងមួយល្អដែលបានដឹងថា នៅពេលដែលបុគ្គលស្លាប់ ហើយបានកើតក្នុងភពអមនុស្ស ហើយពួកគេនៅតែចាំ និងស្រឡាញ់ឪពុកម្ដាយ និងញាតិរបស់ពួកគេនៅក្នុងភពមនុស្ស[៦]។

### ៤. ការទាក់ទងដោយផ្ទាល់ជាមួយបុគ្គលស្លាប់ទៅ

(១).កូនកង្កែបតូចមកពីស្រះ **គគ្គរា** ក្នុងដែន**ចម្បា**បានស្ដាប់សំឡេងព្រះធម៌របស់ព្រះសម្មាសម្ពុទ្ធប្រកបដោយបីតិ និងសេចក្ដីគោរព។ នៅពេលវាត្រូវបានធ្វើឱ្យស្លាប់ដោយអ្នកគង្វាលគោ ក៏បានកើតក្នុងឋានតាវតិង្ស។ ទេវបុត្រនោះ បានចុះចាកវិមានរបស់ខ្លួនមកកាន់ឋានមនុស្ស ហើយបានថ្វាយបង្គំចំពោះ





ព្រះសម្មាសម្ពុទ្ធ។ នៅពេលដែល ព្រះសម្មាសម្ពុទ្ធ ទ្រង់បានសួរទេវបុត្រនោះបានប្រាប់រឿងរ៉ាវរបស់ខ្លួន ដើម្បីឱ្យអ្នកស្ដាប់បានដឹងថា គាត់បានស្លាប់កាលពីនៅជាសត្វកង្កែប ហើយបានមកកើតជាទេវបុត្រមួយអង្គ។ នេះគឺជាឧទាហរណ៍មួយនៃការធ្វើការទាក់ទងផ្ទាល់ជាមួយអ្នកស្លាប់។

(២).**មដ្ឋកុណ្ឌលី** ជាកូនប្រុសរបស់ព្រាហ្មណ៍ជាអ្នកមានកំណាញ់ម្នាក់បានស្លាប់ទៅ ហើយបានទៅកើតជាទេវបុត្រមួយអង្គ នៅក្នុងឋានតាវតិង្ស ដោយសារកុសលកម្មរបស់គាត់បានចំរើននូវការគោរពចំពោះព្រះសម្មាសម្ពុទ្ធ។ គាត់បានចុះមកជួបជាមួយឪពុករបស់គាត់ ហើយបានបញ្ចុះបញ្ចូលឪពុករបស់ខ្លួន ឱ្យធ្វើទានចំពោះព្រះពុទ្ធ និងព្រះសង្ឃ នេះក៏ជាព្រឹត្តិការណ៍មួយ នៃការទំនាក់ទំនងផ្ទាល់រវាងអ្នកស្លាប់ និងអ្នកនៅរស់។

(៣).ក្នុងរឿងនៃប្រេតជាប្រពន្ធដើមរបស់បុរសម្នាក់ ដែលបានស្លាប់ទៅហើយ បានកើតជាប្រេតដោយឧបបាតិកបដិសន្ធិ ហើយពេលនោះប្រេតនោះ ក៏បានបង្ហាញខ្លួនចំពោះមុខភរិយាជាស្រីក្មេង ហើយសុំឱ្យជួយ។ រឿងនេះបានពណ៌នាជាឧទាហរណ៍មួយទៀត នៃការទាក់ទង ផ្ទាល់រវាងអ្នកស្លាប់ និងអ្នកនៅរស់។

(៤).ព្រះមហា មោគ្គលាន បានទៅកាន់ឋានទេវតា ព្រមទាំងឋាននរក ដើម្បីធ្វើសម្ភាសន៍ជាមួយទេវតា និងពួកសត្វនរក

អំពីអតីតកម្មរបស់ពួកគេ។ ដូច្នេះ ប្រសិនបើយើងមានអភិញ្ញា យើងក៏អាចធ្វើការទាក់ទងដោយផ្ទាល់ ជាមួយបុគ្គលដែលស្លាប់បានដែរ។

(៥).ប្រសិនបើអ្នកអានទាំងឡាយ មិនពេញចិត្តជាមួយនឹងភ័ស្តុតាងតាមគម្ពីរពុទ្ធសាសនានានាទេ ហើយពួកគេចង់ដឹងនូវភ័ស្តុតាងទំនើប ពួកគេអាចសិក្សានូវកិច្ចប្រជុំខាងសាសនារបស់ **អ៊ីស្តែល រ៉ូប៊ឹត** ដែលបានធ្វើឡើងក្រោមការណែនាំរបស់ **វិត ខ្លោជ** ដែលជាពុទ្ធិទេវតាចាប់ពីឆ្នាំ១៩២៥-១៩៧០ ដែលនៅក្នុងនោះ ពួកគេបានជួយញាតិ ដែលកំពុងរស់នៅដើម្បីឱ្យនិយាយទៅកាន់មនុស្សស្លាប់ ដោយការទាក់ទងតាមសំឡេងផ្ទាល់។

**អ៊ីស្តែល រ៉ូប៊ឹត** និង **វិត ខ្លោជ** បានប្រើត្រែតូចៗជាឧបករណ៍ដើម្បីបង្កើតសំឡេងបញ្ចូលអារ័ក្ស។ **វិត ខ្លោជ** បានបង្រៀនអារ័ក្សពីរបៀបប្រើប្រាស់ត្រែ។

កិច្ចប្រជុំខាងសាសនា ដោយការទាក់ទងតាមសំឡេងផ្ទាល់ ត្រូវបានធ្វើឡើង នៅពេលយប់ស្ថិតក្នុងបរិយាកាសស្ងៀមស្ងាត់។ បុគ្គលទាំងឡាយ ដែលចង់ធ្វើការទាក់ទងដោយផ្ទាល់ ជាមួយអ្នកស្លាប់អង្គុយជុំវិញ **អ៊ីស្តែល** កាន់ដៃគ្នាជារង្វង់មូលនៅក្នុងបន្ទប់ទទួលភ្ញៀវរបស់ **អ៊ីស្តែល** ។ ត្រែតូចមួយដែលមានការលាបថ្នាំមាននពន្លឺចែងចាំង អាចមើលឃើញក្នុងទីងងឹត បានដាក់នៅចំ





កណ្ដាលរង្វង់។ បង្អួចទាំងឡាយត្រូវបានបិទ វាំងននទាំងឡាយក្រាស់ៗ បានដាក់ចុះដើម្បីការពារពន្លឺមិនឱ្យចូលបន្ទប់។

តន្ត្រីដ៏ស្រទន់មួយត្រូវបានប្រគុំឡើង ជាតន្ត្រីបូរាណមួយ។ បុគ្គលទាំងអស់នៅក្នុងរង្វង់នោះ បានត្រូវស្នើសុំឱ្យសម្រួលចិត្តរបស់ពួកគេ។ ប្រសិនបើបុគ្គលណាមួយកំពុងគិតយ៉ាងខ្លាំង ឬកំពុងឆ្ងល់អំពីការទាក់ទងតាមសំឡេងផ្ទាល់ ការទាក់ទងជាមួយពិភពអមនុស្សនោះ នឹងត្រូវបានរំខាន។ ពួកអមនុស្សដែលបានធ្វើការទាក់ទងក៏ត្រូវបន្ធូរ ឬសម្រួលចិត្តរបស់ពួកគេដែរ ហើយត្រូវតែធ្វើឱ្យរួចចាកផុតពីការព្រួយបារម្ភ ឬភាពអន្ទះសា។ **អ៊ីស្តែល** ត្រូវបានដាក់ក្រោមការសណ្ដំដោយ **វិត ខ្លោជ។** នៅពេលដែលល័ក្ខខ័ណ្ឌទាំងអស់ ត្រូវបានធ្វើត្រឹមត្រូវការធ្វើទំនាក់ទំនង តាមសំឡេងផ្ទាល់ពីភពអមនុស្សបានធ្វើឡើងជាប់តៗគ្នា។

កិច្ចប្រជុំខាងសាសនានោះ បានចាប់ផ្ដើមជាមួយការធ្វើបដិសណ្ឋារៈពី **វិត ខ្លោជ** ថា "*អស់លោក លោកស្រី អ្នកនាងកញ្ញាជាទីមេត្រី, សូមទាំងអស់គ្នាមានសុខភាព និងប្រកបដោយសុក-មង្គល*" ។ បន្ទាប់មក ត្រែបានធ្វើចលនាជុំវិញបន្ទប់ យ៉ាងរហ័សដោយគ្មានការប៉ះពាល់ដល់ពិដាន ឬគ្រឿងសង្ហារឹមទេ។

នៅពេលដែលអារ័ក្សបញ្ជាន់ ចង់និយាយទៅកាន់មនុស្សនៅក្នុងរង្វង់នោះ,អ្នកផ្លុំត្រែបានឈប់ជិតត្រចៀករបស់បុគ្គលនោះ

ហើយសំឡេងរបស់រូបអារ័ក្សនោះ ក៏បានមានឡើង។ ទោះបីជាសំឡេងនៃពួកអមនុស្សទាំងឡាយចេញមកតាមត្រៃតែមួយ ដូចគ្នាក៏ដោយ ប្រហែលមិនអាចខុសគ្នាតាមសំឡេង អាការៈនៃការនិយាយរបស់ពួកគេ ការជ្រើសរើសពាក្យរបស់ពួកគេ ការនិយាយលើកដាក់សំឡេងរបស់ពួកគេគឺខុសគ្នា។ ដូច្នេះអ្នកស្តាប់ទាំងឡាយ អាចដឹងថា អ្នកណាកំពុងនិយាយបាន។

ឧទាហរណ៍ៈ អ្នកស្រី **អ៊ីឡែន ហាដហ្វីល** (Ellan Hadfied) គឺមានវត្តមានក្នុងការជួបជុំខាងសាសនាមួយ។ កូនស្រីរបស់នាងដែលស្លាប់ទៅ បានកើតជាអមនុស្ស បាននិយាយទៅកាន់នាងតាមរយៈសំឡេងត្រៃ។ នាងមានការប្រាកដថា ហ្នឹងហើយជាកូនស្រីរបស់នាងដែលស្លាប់ទៅ ពីព្រោះរបៀបនៃការនិយាយ និងការលើកដាក់សំឡេង គឺដូចគ្នានឹងកូនស្រីរបស់នាងធ្លាប់និយាយ។ អ្នកស្រី **ហាដហ្វីល** បានពន្យល់រឿងនេះ ទៅដល់អ្នកសារពត៌មានទាំងឡាយ។

### គូស្នេហ៍មកពីភពផ្សេងគ្នាអាចនៅជាមួយគ្នាបាន

បុគ្គលដែលមានកិត្តិយសម្នាក់ ដែលបានធ្វើការទាក់ទងផ្ទាល់ជាមួយប្រពន្ធរបស់គាត់ ក្នុងការជួបជុំកិច្ចប្រជុំសាសនារបស់អ៊ីស្តែល ដោយការទាក់ទងសំឡេងផ្ទាល់គឺលោក **ហិនរី សិហ្រ្គេរ**។





លោក **ហិនរី សិហ្រ្គេរ** បានមានមហិច្ឆតាដ៏ខ្លាំងក្លា ដើម្បីបំបែកឯតទគ្គកម្មក្នុងការប្រណាំងឡានពិភពលោក។ នៅពេលដែលគាត់កំពុងអនុវត្តជាមួយការប្រណាំងឡាន ក្នុងទីក្រុង ដេតូណាប៊ីច រដ្ឋ ហ្វ័ររីដា បុគ្គលម្នាក់មកពីប្រទេសអង់គ្លេស បានសរសេរលិខិតទៅកាន់គាត់ ដើម្បីប្រាប់គាត់នូវបណ្តាំ ដោយព្រលឹងរបស់អតីតជើងឯក អ្នកប្រណាំងឡានពិភពលោក ក្នុងកិច្ចប្រជុំសាសនាមួយ។ ការផ្តាំផ្ញើជាការព្រមានដល់លោក **ហិនរី សិហ្រ្គេរ** ឱ្យប្រុងប្រយ័ត្នក្នុងការប្រណាំង។

នៅពេលលោក **ហិនរី សិហ្រ្គេរ** បានត្រឡប់មកប្រទេសអង់គ្លេសវិញ គាត់បានសិក្សាពីកិច្ចប្រជុំសាសនាមួយចំនួន។ មិនយូរប៉ុន្មានបន្ទាប់ពីនោះមក គាត់បានចូលរួមក្នុងការប្រណាំងកាណូតនៅទន្លេ **វិនឌ័រ មៀរ** ជាទន្លេដែលធំបំផុតក្នុងប្រទេសអង់គ្លេស គាត់កំពុងបំបែកឯតទគ្គកម្ម កាណូត របស់គាត់បានលិចហើយគាត់ក៏បានស្លាប់ទៅ។

**ហិនរី សិហ្រ្គេរ** បានក្លាយទៅជាអមនុស្សបន្ទាប់ពីស្លាប់ទៅ ហើយគាត់បានព្យាយាមធ្វើការទាក់ទងជាមួយប្រពន្ធរបស់គាត់ នៅក្នុងកិច្ចប្រជុំសាសនារបស់ **អ៊ីស្តែល រ៉ូប៊ីត** តាមសំឡេងផ្ទាល់។ នៅពេលបានឮដំណឹងនេះ អ្នកស្រី **សិហ្រ្គេរ** បានមកកាន់កិច្ចប្រជុំសាសនារបស់**អ៊ីស្តែល រ៉ូប៊ីត**។

បន្ទាប់ពីកិច្ចប្រជុំបានចាប់ផ្ដើមភ្លាម ត្រែក៏បានឈប់នៅក្បែរ អ្នកស្រី **សិហ្វ្រេរ** ។ ពាក្យថា ឪ ចេញមកពីត្រែមក ពោលគឺមានតែពាក្យ **ហិនរី សិហ្វ្រេរ** ទេដែលធ្លាប់ហៅប្រពន្ធជាទីស្រឡាញ់របស់គាត់ដូច្នេះ។ អ្នកស្រី **សិហ្វ្រេរ** បានរីករាយយ៉ាងខ្លាំង ដោយដឹងថា វាពិតជាប្ដីរបស់នាងនិយាយមកកាន់នាងពីភពអមនុស្ស។ ពេលនោះឯង អារក្សអមនុស្សមិនអាចគ្រប់គ្រងនូវត្រែក៏ធ្លាក់មកលើឥដ្ឋ។

សំឡេងរបស់ **រិត ខ្លោដ** បានលេចឡើងយ៉ាងច្បាស់ថា "កុំរកាំចិត្តអី។ ត្រែនោះបានធ្លាក់មកលើឥដ្ឋព្រោះអ្នកស្រី **សិហ្វ្រេរ** រំភើបចិត្តខ្លាំងពេក ហើយ **ហិនរី សិហ្វ្រេរ** មិនសូវមានជំនាញក្នុងការប្រើត្រែផង។ ខ្ញុំនឹងជួយគាត់ឱ្យបានជោគជ័យនៅពេលក្រោយ" ។

ក្នុងពេលក្រោយៗទៀត អ្នកស្រី **សិហ្វ្រេរ** នៅស្ងប់ស្ងៀម ហើយនាងអាចបន្ទូរអារម្មណ៍របស់នាងបានយ៉ាងល្អ។ លោក **ហិនរី សិហ្វ្រេរ** ក៏មានជំនាញក្នុងការប្រើត្រែដែរ ហើយគាត់និយាយដោយសំឡេងតិចៗ ឬសំឡេងខ្ពស់ តាមដែលគាត់ចូលចិត្តចំពោះប្រពន្ធរបស់គាត់។

"ឪ ខ្ញុំបាននៅជាមួយអ្នកកាលពីថ្ងៃទី១៤"។

"តើអ្នកនៅចាំថ្ងៃនោះទេ?"





"អូ! មែនហើយវាថ្ងៃខួបកំណើតរបស់អ្នក"។

"តើអ្នកបានជិះឡានជាមួយខ្ញុំឬ?"

"ពិតមែនហើយ! សូមប្រុងប្រយ័ត្នជាមួយការបើកបររបស់អ្នក។ អ្នកឯងបើកលឿនណាស់"។

"កុំព្រួយបារម្ភអី ខ្ញុំជាអ្នកបើកបរមានជំនាញម្នាក់"។

"មែនហើយ! តើខ្ញុំមិនមែនជាអ្នកបើកបរមានជំនាញទេឬ?"

ពួកគេនិយាយទៅកាន់គ្នាទៅវិញទៅមកដោយរីករាយ ជាច្រើននាទីពីមួយថ្ងៃទៅមួយថ្ងៃអស់រយៈពេលជាច្រើនខែ។ ពួកគេបាននិយាយយ៉ាងស្និទ្ធស្នាល អំពីគ្រាដើមរបស់ពួកគេអំពីរឿងកិច្ចការផ្ទះ អំពីមិត្តភក្តិ អំពីឪពុករបស់ **ហិនរី** និងរឿងរ៉ាវតូចតាចដែលអាចយល់បានតែពួកគេប៉ុណ្ណោះ។ គូស្នេហ៍ទាំងពីរនាក់អាចរស់នៅជាមួយគ្នាបានជាមួយគ្នាម្ដងទៀត ទោះបីជាពួកគេនៅភពផ្សេងគ្នាក៏ដោយ។

*គូស្នេហ៍ទាំងឡាយអាចជួបជុំ និងរីករាយតាមពេលវេលាដែលនៅជាមួយគ្នា ខាងក្រោយរាំងននៃសេចក្ដីស្លាប់។*

បន្ទាប់ពីធ្វើការទំនាក់ទំនងជាមួយប្ដីរបស់នាង ដែលស្លាប់ទៅអស់រយៈពេលមួយឆ្នាំ តាមការទាក់ទងដោយសំឡេងផ្ទាល់ អ្នកស្រី **សិហ្វ្រេរ** បានប្រកាសទៅកាន់ពិភពលោកតាមរយៈកាសែត

ដោយកស្តុតាងច្បាស់លាស់ថា ប្តីរបស់នាងកំពុងមានជីវិតរស់នៅក្នុងភពអមនុស្ស។

*"វាជារឿងធម្មតាដែលឪពុកម្តាយ និងកូន ប្តី និងប្រពន្ធ ញាតិ បងប្រុស បងស្រី ត្រូវបែកគ្នាដោយសេចក្តីស្លាប់, បុគ្គលគ្រប់រូបត្រូវទទួលរងដោយសេចក្តីទុក្ខ និងសេចក្តីសោកសង្រេងចិត្ត។ វាជាកាតព្វកិច្ចរបស់ខ្ញុំ ដើម្បីជួយជនទាំងឡាយដែលញាំញីដោយសេចក្តីទុក្ខ ដុតកំឡោចដោយសេចក្តីសោក ដោយសារការឃ្លាតចាកបុគ្គលជាទីស្រឡាញ់របស់ពួកគេ។*

*ខ្ញុំរីករាយ និងមានសេចក្តីសុខណាស់ ព្រោះខ្ញុំអាចរស់នៅជាមួយប្តីខ្ញុំបានក្នុងកិច្ចប្រជុំសាសនាដោយការទាក់ទងតាមសំឡេងផ្ទាល់ ទោះបីជាគាត់បានស្លាប់ជាងមួយឆ្នាំទៅហើយក្តី ខ្ញុំប្រាថ្នាឱ្យមនុស្សទាំងអស់បានសេចក្តីសុខសប្បាយរីករាយដូចខ្ញុំ"* ។

សំរាប់ការអនុវត្តដោយអ្នកស្រី **សិហ្រ្គេរ** ដ៏ក្លាហានមោះមុតនេះទាំង **វិតខ្លោដ** ជាទេវតាណែនាំ និង **ហិនរី សិហ្រ្គេរ** បានកោតសសើរទះដៃអបអរសាទនាង។

អ្នកស្រី **សិហ្រ្គេរ** បានស្លាប់នៅក្នុងឆ្នាំ១៩៦៨ នាង ក៏បានកើតជាទេវតាអាចរស់នៅជាមួយប្តីរបស់នាង ក្នុងឋានទេវលោក





នោះ។ ពួកគេបានមករក **អ៊ីស្តែល រ៉ូប៊ីត** ហើយថ្លែងអំណរគុណចំពោះនាង ដោយស្មោះអស់ពីចិត្ត ចំពោះវិភាគទានរបស់នាងដើម្បីជាសេចក្តីសុខដល់ជនច្រើនគ្នាជាច្រើនឆ្នាំ[៦]។

## សារផ្តាំផ្ញើពីភពអមនុស្ស

មានពត៌មានពិសេសមួយនៅក្នុងទស្សនាវដ្តី News Week បោះពុម្ពនៅថ្ងៃទី ១ ខែឧសភា ឆ្នាំ ១៩៧៨ ចុះផ្សាយថា ស្ត្រីជនជាតិអាមេរិកកាំងមានវ័យចំណាស់ម្នាក់ឈ្មោះ **ម៉ារី ស្វ៊ត** (Mary Swart) បានស្លាប់ទៅហើយ បានមកថ្លែងអំណរគុណលោកបណ្ឌិត **អេលីហ្សាប៉ែត គូប្លឺ-រ៉ូស** (Dr.Elizabeth Kubler-Ross) ក្នុងរូបភាពជាអមនុស្ស។ តាមសេចក្តីស្នើសុំរបស់បណ្ឌិត ***គូប្លឺ-រ៉ូស*** អមនុស្សនោះបានសរសេរសោរថ្លែងអំណាគុណ។ នៅសហរដ្ឋអាមេរិក មានគណៈកម្មការសុខុមាលភាពដើម្បីថែរក្សាមនុស្សចាស់ជរាឯកោដែលនៅឆ្ងាយពីកូនប្រុសស្រីពួកគេ។ លោកបណ្ឌិត **គូប្លឺ-រ៉ូស** បានធ្វើការនៅកន្លែងមួយនៃគណៈកម្មការនេះ។ លោកបណ្ឌិត **គូប្លឺ-រ៉ូស** បរិបូរណ៍ដោយញាណ ដែលអាចដឹងបាន នៅខាងក្រៅខ្លួនតាំងពីកំណើត។ អ្នកខ្លះបានក្លាយទៅជាអមនុស្សពេលស្លាប់ទៅ ហើយពួកគេបានមករកបណ្ឌិត ***គូប្លឺ-រ៉ូស*** ដើម្បីថ្លែងអំណរគុណ ។ **ម៉ារី ស្វ៊ត** ក៏បានក្លាយទៅជាអមនុស្សនៅ

ពេលស្លាប់ទៅដែរ។ អមនុស្សនោះ បានបង្ហាញខ្លួននៅចំពោះមុខលោកបណ្ឌិត **គូប្លឺ-រ៉ូស** ហើយថ្លែងអំណរគុណ រាល់ជំនួយចំពោះនាងទាំងអស់។

លោកបណ្ឌិត **គូប្លឺ-រ៉ូស** បានស្នើសុំឱ្យអមនុស្សទាំងអស់ប្រើប្រាស់នូវពាក្យផ្តាំផ្ញើ ហើយនិងការសរសេរនៅលើក្រដាសលើតុរបស់នាង ហើយសរសេរលិខិតបដិសណ្ឋារៈចំពោះមិត្តធម្មតាដែលស្គាល់ពួកគេទាំងពីរ។ អមនុស្ស បានយល់ព្រមជាមួយនឹងសេចក្តីស្នើសុំនោះ ដោយបានសរសេរលិខិត ហើយនិងបានចុះហត្ថលេខា នាងក៏បានចុះថ្ងៃខែផងដែរ។ លិខិតនេះត្រូវបានបោះពុម្ពនៅក្នុងទស្សនាវដ្តីសារពត៌មាន News Week ដែរ។

លោកបណ្ឌិត **គូប្លឺ-រ៉ូស** ក៏បានជួបអមនុស្ស ជាអ្នកណែនាំ ហើយពួកគេបានប្រាប់នាងអំពីពិភពរបស់អមនុស្សដែរ។ ជនជាតិអាមេរិកកាំងទូទៅ ក៏បានចាប់អារម្មណ៍យ៉ាងខ្លាំងក្នុងការស្រាវជ្រាវរបស់បណ្ឌិត **គូប្លឺ-រ៉ូស** និងអ្នកប្រាជ្ញអំពីពិភពអមនុស្ស។ នៅពេលការស្ទាបស្ទង់ ត្រូវបានធ្វើឡើងនៅក្នុងឆ្នាំ១៩៧៨ ជនជាតិអាមេរិកកាំង ៧% បានជឿថាមានជាតិក្រោយ បន្ទាប់ពីស្លាប់ទៅ។

### ៥. ការដឹងអនាគតភពដោយទិព្វចក្ខុ និងអភិញ្ញាផ្សេងៗ

នៅក្នុងពុទ្ធសាសនា ព្រះពុទ្ធបានត្រាស់សម្តែងពីលោកិយ





អភិញ្ញា៧ យ៉ាង ដែលស្រាយបំភ្លឺអំពីអំណាចចិត្តដ៏អស្ចារ្យ។ ព្រះសម្មាសម្ពុទ្ធ ក៏ទ្រង់បានបង្ហាញពីរបៀបចម្រើននូវអភិញ្ញាទាំងនេះដែរ។ ដូច្នេះ បុគ្គលទាំងឡាយ ដែលមានបំណងចង់មានអភិញ្ញានេះ សព្វថ្ងៃអាចធ្វើវាទៅដោយការប្រតិបត្តិក្រោមសំណាក់គ្រូដ៏ល្អ និងមានសមត្ថភាព។

ក្នុងចំណោមអភិញ្ញាទាំង៧ **ទិព្វចក្ខុ** ឬ **ចុតូបបាតញាណ** អាចមើលឃើញសត្វទាំងឡាយដែលច្យុតចាកពីលោកនេះ និងពួកសត្វទាំងឡាយដែលបានកើតនៅភព៣១ជាន់។ ការសង្កេតនេះបានបង្ហាញយ៉ាងជាក់ច្បាស់ថា សត្វទាំងឡាយត្រូវបានកើតឡើងវិញក្នុងភពថ្មី បន្ទាប់ពីស្លាប់ទៅ។

ទិព្វចក្ខុលើសអស់ភ្នែកមនុស្សធម្មតាក្នុងឫទ្ធិរបស់វា ដើម្បីមើលឃើញនូវវត្ថុទាំងឡាយ ដែលអាចមើលបាន។ វាអាចមើលឃើញមិនត្រឹមតែវត្ថុរឹង ឬទន់ដែលប្រាកដចំពោះភ្នែកមនុស្សធម្មតាប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងវត្ថុទាំងឡាយល្អិតសុខុម និងវត្ថុទិព្វទាំងឡាយដែលនៅឆ្ងាយ និងកំបាំងផងដែរ។ តាមពិតទៅវាអាចមើលឃើញនូវសត្វមានជីវិតទាំងអស់ និងវត្ថុទាំងឡាយគ្មានជីវិត នៅក្នុងលោកទាំងមូល ព្រមទាំងក្នុងភព៣១ ជាន់ផងដែរ។ ទិព្វចក្ខុរបស់ព្រះសម្មាសម្ពុទ្ធ អាចមើលឃើញនូវសត្វមានជីវិតទាំងអស់ ក្នុងមួយសែនចក្រវាឡ។

តាមរយៈអភិញ្ញានោះ បុគ្គលអាចមើលឃើញសត្វទៀប នឹងស្លាប់ ឬក៏កំពុងចាប់កំណើត និងសត្វដែលមានកំណើតទាប ឬខ្ពស់ សត្វដែលមានរាងកាយស្អាត និងមិនស្អាត ហើយនិង សត្វទាំងឡាយ ដែលបានទៅកាន់សុគតិភព ឬ ទុគតិភព។

បន្ទាប់ពីមើលឃើញនូវសត្វក្នុងឋានអបាយវេទុក្ខ តាមរយៈទិព្វចក្ខុរបស់ព្រះអង្គៗបានប្រមើលឃើញថា " អំពើអ្វីដែលសត្វទាំងនេះបានធ្វើ ហើយត្រូវទៅសោយទុក្ខដ៏អាក្រក់ក្រៃលែងយ៉ាងដូច្នេះ?"។ នៅពេលនោះ **យថាកម្មូបគ្គញ្ញាណ** ជាញាណដែលអាចបង្កឱ្យព្រះអង្គមើលឃើញនូវអកុសលកម្ម ដែលធ្វើដោយសត្វទាំងនេះ នៅក្នុងព្រះកាយព្រះអង្គ។

ដូចគ្នានេះដែរ បន្ទាប់ពីមើលឃើញដោយទិព្វចក្ខុរបស់ព្រះអង្គ នូវសេចក្តីសុខដ៏ក្រៃលែង ដែលសត្វទាំងនេះសោយនៅឋានមនុស្សលោក ទេវលោក និងព្រហ្មលោក ព្រះអង្គទ្រង់បានពិចារណាថា "ប្រភេទនៃអំពើអ្វីទៅហ្ន៎! ដែលមនុស្ស ទេវតា ព្រហ្មទាំងនេះ បានធ្វើ ហើយសោយនូវសេចក្តីសុខដ៏ក្រៃលែងយ៉ាងនេះនៅក្នុងឋានរបស់ខ្លួនរៀងៗខ្លួនដូច្នេះ?"។

គ្រានោះឯង **យថាកម្មូបគ្គញ្ញាណ** ជាញាណដែលអាចឱ្យ





ព្រះអង្គ មើលឃើញនូវកុសលាកុសលកម្ម ដែលសត្វទាំងនេះបានធ្វើ កើតឡើងនៅក្នុងព្រះកាយព្រះអង្គ។

*យថាកម្មូបគ្គញ្ញាណ ញាណអាចមើលឃើញពីចម្ងាយយោងទៅតាមកម្មដែលដឹងថា សត្វនេះកើតយោងទៅតាមកម្មរបស់ខ្លួន ដឹងមិនមែនត្រឹមតែអនាគតភពរបស់សត្វនោះទេ ប៉ុន្តែថែមទាំងហេតុនៃកម្មទាំងឡាយ សំរាប់ការកើតឡើងនៃភពទាំងឡាយថ្មីទៀតផង*(៧)។

ផ្អែកលើទិព្វចក្ខុ បុគ្គលអាចចម្រើន មិនត្រឹមតែញាណមើលឃើញពីទីឆ្ងាយតាមកម្មរបស់សត្វប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងញាណមើលឃើញព្រឹត្តិការណ៍នាពេលអនាគត ព្រមទាំងអនាគតភពឈ្មោះថា ***អនាគតំ សញ្ញាណ*** *(ញាណដឹង អំពើអនាគត)*។

បួនអសង្ខេយ្យ និងកម្រៃមួយសែនកប្បកន្លងទៅនេះ ព្រះពុទ្ធទ្រង់ ព្រះនាម **ទីបង្ករ** អមដោយព្រះអរហន្តចំនួន៤សែនអង្គ ទ្រង់យាងចូលទៅក្នុងទីក្រុង **រម្មាវតី** តាមផ្លូវធំ។ ប្រជាជន និងទេវតាជាច្រើនបានស្វាគមន៍ព្រះអង្គ និងព្រះអរហន្ត ដោយការទូងស្គរបន្លឺសំឡេងឡើង។

ក្នុងកាលនោះ ដោយអំណាចនៃព្រះសម្មាសម្ពុទ្ធ មនុស្សទាំងឡាយអាចមើលឃើញទេវតា ហើយទេវតាក៏អាចមើលឃើញមនុស្សវិញដែរ។ ទាំងមនុស្ស និងទេវតា បានលើកដៃប្រណម្យ

គោរពចំពោះព្រះសម្មាសម្ពុទ្ធ និងភិក្ខុសង្ឃទាំងឡាយ ដែលធ្វើដំណើរតាម ។

**សុមេធ** តាបសវ័យក្មេង ទោះបីជាលោកបានសម្រេចនូវអភិញ្ញាក៏ដោយ ក៏ទ្រង់បានព្យាយាមជួសជុលចំណែកនៃផ្លូវជាច្រើនថ្វាយព្រះអង្គ ដោយព្រះកាយខ្លួនឯងផ្ទាល់។ មុនពេលការជួសជុលបានចប់សព្វគ្រប់ គាត់បានឃើញព្រះសម្មាសម្ពុទ្ធដ៏រុងរឿង ទ្រង់យាងមកដល់។ លោកទ្រង់បានពិចារណាថាៈ

"ថ្ងៃនេះ អាត្មាអញគួរតែបូជាជីវិតរបស់អញចំពោះមុខព្រះសម្មាសម្ពុទ្ធ ដើម្បីកុំឱ្យព្រះអង្គទ្រង់យាងកាត់ផ្លូវភក់ល្បប់ ដោយលំបាក។ សូមឱ្យព្រះសម្មាសម្ពុទ្ធ និងភិក្ខុសង្ឃទាំងអស់ ទ្រង់យាងជាន់លើខ្នងរបស់អាត្មាអញ ដូចជាស្ពាន។ ការប្រើប្រាស់រាងកាយជាផ្លូវចំពោះព្រះសម្មាសម្ពុទ្ធ និងភិក្ខុសង្ឃទាំងឡាយនោះនឹងនាំមកនូវសេចក្តីសុខ និងសុខុមាលភាពជាយូរអង្វែង"។

ដោយបានប្តេជ្ញាដូច្នេះ លោក ក៏ក្រាលស្បែកខ្លានៅលើផ្លូវភក់ល្បប់នោះ ហើយទ្រាលពីលើ។ ពេលនោះ សេចក្តីប្រាថ្នាចង់ក្លាយជាព្រះពុទ្ធក៏កើតឡើងក្នុងខ្លួនតាបសនោះថាៈ "ប្រសិនបើអាត្មាអញប្រាថ្នាដូច្នេះ ថ្ងៃនេះឯងអាត្មាអញអាចក្លាយជាព្រះអរហន្តមួយអង្គ។ ប៉ុន្តែ តើមានប្រយោជន៍អ្វីចំពោះអាត្មាអញ ដើម្បីធ្វើឱ្យជាក់ច្បាស់នូវព្រះនិព្វានតែម្នាក់ ដូចជាភិក្ខុធម្មតា? អាត្មា





អញនឹងព្យាយាមអស់ពីសមត្ថភាព ដើម្បីសម្រេចបាននូវភាពជាព្រះសម្មាសម្ពុទ្ធ"។

ក្នុងគ្រានោះឯង ព្រហ្មណ៍ជាស្រីក្រមុំឈ្មោះ នាង **សុមិត្តា** បានមកចូលរួមជាមួយប្រជាជន។ នាងបានកាន់យកនូវផ្កាឈូករីកស្គុះស្គាយ ចំនួនប្រាំបីទង មកថ្វាយចំពោះព្រះសម្មាសម្ពុទ្ធ។ នៅពេលភ្នែករបស់នាងបានក្រឡេកឃើញ **សុមេធ** តាបស ភ្លាមនាងក៏បានចាប់ចិត្តស្រឡាញ់ចំពោះតាបសនោះមួយរំពេច។ នាងបានឱ្យលោកនូវផ្កាឈូកប្រាំ ដោយនិយាយថាៈ " តាបសជាទីគោរព សូមអ្នកថ្វាយផ្កាឈូកទាំងនេះ ចំពោះព្រះសម្មាសម្ពុទ្ធចុះ។ ផ្កាឈូកបីសល់ពីនេះ ខ្ញុំក៏សម្រាប់ថ្វាយព្រះសម្មាសម្ពុទ្ធដែរ។ បពិត្រតាបសជាទីស្រឡាញ់ ក្នុងអំឡុងពេលអ្នកកំពុងបំពេញបារមី ដើម្បីបានត្រាស់ជាព្រះពុទ្ធ សូមឱ្យខ្ញុំបានជាដៃគូរួមចំណែកជីវិតរបស់អ្នកផង"។

**សុមេធ** តាបស បានទទួលយកនូវផ្កាទាំងនោះ ហើយក៏ថ្វាយចំពោះព្រះសម្មាសម្ពុទ្ធ ហើយធ្វើការបួងសួង ដើម្បីសម្រេចជាព្រះពុទ្ធ។ នាង **សុមិត្តា** ក៏បានថ្វាយផ្កាឈូករីកក្រពុំទាំងបីនោះចំពោះព្រះសម្មាសម្ពុទ្ធ ហើយក៏បានបួងសួងសូមឱ្យសេចក្តីប្រាថ្នារបស់នាងបានជាដៃគូរួមចំណែកជីវិតជាមួយ **សុមេធ** តាបស

អំឡុងពេលលោកកំពុងបានបំពេញបារមី ដើម្បីបានត្រាស់ដឹងជាព្រះពុទ្ធឱ្យបានសម្រេច។

ដោយសង្កេតឃើញហេតុការណ៍នោះព្រះពុទ្ធ **ទីបង្ករ** បានឈប់ ហើយប្រើអភិញ្ញារបស់ព្រះអង្គដើម្បីមើលឃើញទៅក្នុងអនាគត ដើម្បីធ្វើឱ្យជាក់ច្បាស់ថា តើការបួងសួងរបស់ **សុមេធ** និង **សុមិត្តា** បានសម្រេចឬអត់។ ***អនាគតំសញាណំ*** របស់ព្រះសម្មាសម្ពុទ្ធអាចមើលឃើញទៅក្នុងអនាគតគ្មានដែនកំណត់ និងគ្មានអ្វីរារាំង។ គ្រានោះឯងព្រះអង្គទ្រង់បានបន្លឺវាចា និងបានព្យាករណ៍ថាៈ

*"ម្នាលភិក្ខុទាំងឡាយ* ***សុមេធ*** *តាបសនេះ នឹងបានក្លាយជាអ្នកត្រាស់ដឹងមួយរូប បន្ទាប់ពីអស់កប្បជាច្រើនទៅនេះ ដោយប្រាកដប្រមាណបួនអសង្ខេយ្យ និងកម្រៃមួយសែនកប្ប ចាប់ពីពេលឥឡូវនេះទៅ។ តាបសនេះនឹងបានជាព្រះពុទ្ធទ្រង់ព្រះនាមគោតម។*

*"មាតា និង បិតា របស់ព្រះពុទ្ធគោតម គឺព្រះនាម* ***មាយាទេវី*** *និង ស្តេច* ***សុទ្ធោទនៈ*** *។ អគ្គសាវ័កទាំងពីររបស់ព្រះអង្គគឺ* ***ឧបតិស្សៈ*** *និង* ***កោលិតៈ*** *(ព្រះសារីបុត្រ និងព្រះមហាមោគ្គលាន)។*





*ភិក្ខុឈ្មោះ អានន្ទ នឹងបានជាឧបដ្ឋាករបស់ព្រះអង្គ។* ***ខេមា*** *និង* ***ឧបលវណ្ណាថេរី*** *នឹងបានជាអគ្គសាវ័កស្ត្រី"។*

*ព្រះពុទ្ធ* ***ទីបង្ករ*** *ទ្រង់មានព្រះបន្ទូលទៅកាន់* ***សុមេធ*** *ថាៈ*

*"ម្នាល* ***សុមេធ! សុមិត្តា*** *ក្មេងស្រីនេះនឹងបានជាដៃគួរមចំណែកជាមួយជីវិតរបស់អ្នក ជួយអ្នកដោយស្មោះស្មើក្នុងការគាំទ្រ និងការធ្វើដើម្បីសម្រេចនូវភាពជាព្រះពុទ្ធ។ នាងនឹងបំពេញចិត្តអ្នករាល់គំនិត ពាក្យសំដី និងទង្វើរបស់នាង។ នាងមានលក្ខណៈគួរជាទីស្រឡាញ់ សំដីផ្អែមល្ហែម និងរីករាយគួរជាទីពេញចិត្ត។ ក្នុងជាតិចុងក្រោយរបស់នាង ក្នុងសាសនារបស់អ្នកជាព្រះពុទ្ធនាងនឹងក្លាយជាអគ្គសាវ័កស្រីដែលនឹងទទួលមរតកសាសនារបស់អ្នកនូវភាពជាព្រះអរហត្តបរិបូណ៌ដោយអភិញ្ញា"*[៨]។

ចិត្ត សម្បយុត្តជាមួយអភិញ្ញាគឺ មានអំណាចអស្ចារ្យ។ ការព្យាករណ៍របស់ព្រះសម្មាសម្ពុទ្ធនឹងមិនដែលខុសឡើយ។ វាតែងតែត្រឹមត្រូវជានិច្ច។

ម្ល៉ោះហើយមិនគប្បីមានសេចក្តីសង្ស័យ ចំពោះភពជាក់ស្តែងនៃអតីតជាតិ និងអនាគតជាតិរបស់យើងឡើយ។ ភ័ស្តុតាងយ៉ាងច្បាស់នៃវិទ្យាសាស្ត្រជាច្រើន ផ្តល់នូវសាក្សីចំពោះការអះអាងនេះ ។

*ប្រសិនបើ យើងរកឃើញក្អែកពណ៌សមួយ ការអះអាងថា "**ក្អែកទាំងអស់ គឺពណ៌ខ្មៅ**" គឺគ្មានសុពលភាពនិងត្រូវចាត់ទុកជាមោឃៈ។ ដូចគ្នានេះដែរ នៅពេលយើងបានរកឃើញនូវភស្តុតាងច្បាស់លាស់ជាច្រើន អំពីអតីតជាតិ និងអនាគតជាតិ ជំនឿដែលថាៈ "**អតីតជាតិ និង អនាគតជាតិ មិនមាន**" នឹងត្រូវគ្មានសុពលភាព និងចាត់ទុកជាមោឃៈទាំងស្រុង។*

## ឯកសារយោង


1. Uparipannasa Pali, Anathapindikovada sutta.
2. Dhammapada Commentary.
3. Vimana Story, 201.
4. Dighanikaya Commentary, 1,317.
5. Dr. Mehm Tin Mon, "Scientific Evidences of Past Existences and Future Existence", Seventh Printing pp.75-86.
6. Ibid., pp. 86-98.
7. Dr. Mehm Tim Mon, "Samatha", Advanced Level, vol.11,pp.151-158.

8,Bhaddanta Vicittasarabhivasa, "The Great Chronicle of Buddhas", Vol. I. Part I. Pp48-58 ។




# ៥

# តើនរណាជាអ្នកសាងលោកពិត

## ១. ភ្នាក់ងារដែលមានអំណាចបំផុត

**ចិត្តេន នីយតិ លោកោ**

ចិត្តដឹកនាំនូវពិភពលោក។

**ចិត្តេន បរិកស្សិតិ**

ចិត្តទាក់ទាញអ្វីៗគ្រប់យ៉ាងឱ្យដើរតាមវា។

**ចិត្តស្ស ឯកធម្មស្ស សព្វេវវសមនវ គូតតិ**

អ្វីៗគ្រប់យ៉ាង តែងតែប្រព្រឹត្តតាមបំណងរបស់វត្ថុម្យ៉ាងនោះគឺបានដល់ចិត្ត។ (សំយុត្តនិកាយ, ចិត្តសូត្រ)។

ចិត្តរបស់បុគ្គលគ្រប់រូប រមែងដឹកនាំជីវិតរបស់បុគ្គលនោះ។ ហើយបុគ្គលនោះឯង កំពុងដឹកនាំលោកនេះ។ ដូច្នេះ វាគឺចិត្តទេដែលដឹកនាំលោកទាំងមូល។ លោកទាំងអស់តោងប្រព្រឹត្តទៅតាមបំណងរបស់ចិត្ត។

រាល់ខេត្តក្រុងទាំងអស់ អគារ រថភ្លើង អាកាសរថយន្ត រថភ្លើង យន្តហោះ និងយានអវកាស វិទ្យាសាស្ត្រទំនើបៗ និង បច្ចេកវិទ្យាជឿនលឿន វប្បធម៌ អក្សរសាស្ត្រ និង សិល្បៈ។ល។ ត្រូវបានបង្កើតឡើង និងគ្រប់គ្រងដោយចិត្ត។ ដូច្នេះ មិនគប្បី សង្ស័យអំពីអំណាចគ្មានកំណត់របស់ចិត្តឡើយ។

## ២. ទស្សនៈរបស់ចិត្តវិទូ

ចិត្តវិទូនានាក៏គាំទ្រការអះអាងថា ចិត្តមានអំណាចគ្មានដែនកំណត់ដែរ។ ដោយដឹងលទ្ធភាពរបស់ចិត្តពួកគេថាៈ "ចិត្តមានថាមពលគ្មានកំណត់។ វាអាចធ្វើអ្វីៗគ្រប់យ៉ាង។ វាថែមទាំងអាចរំកិលភ្នំបាន ប្រសិនបើបុគ្គលពិតជាមានជំនឿចិត្តអាចធ្វើដូច្នេះបាន។ ភាពមានបាន ឬភាពក្រីក្រ ជោគជ័យ ឬបរាជ័យ អាស្រ័យលើចិត្ត"។ ដូច្នេះ បើយើងតាំងចិត្តថាៈ

"ខ្ញុំត្រូវតែជោគជ័យ ខ្ញុំត្រូវតែមាន។ ចិត្តរបស់ខ្ញុំនឹងពិតជានាំមកនូវជោគជ័យ និងភាពមានបាន"។ ប្រសិនបើបុគ្គលពិតជាមានជំនឿ និងការកសាងទំនុកចិត្តបែបនេះ ក្នុងសមត្ថភាពរបស់ខ្លួន ឆន្ទៈដ៏ខ្លាំងក្លានឹងនាំឱ្យបានសម្រេចជោគជ័យ និងមានបានការព្យាយាមជាប់មិនដាច់ ដើម្បីបំពេញនូវជោគជ័យ និងស្គាល់ច្បាស់លាស់អំពីមធ្យោបាយដ៏ត្រឹមត្រូវដើម្បីប្រព្រឹត្ត បន្ទាប់មក





បុគ្គលនោះឯង ពិតជានឹងបានសម្រេចជោគជ័យ និងក្លាយជាអ្នកមានជាពុំខាន។

"ប្រសិនបើ បុគ្គលមិនជឿនូវសមត្ថភាពរបស់ចិត្តថា វាអាចបំពេញអ្វីៗគ្រប់យ៉ាងបាន ហើយប្រកាន់ខ្ជាប់នូវគំនិតថា ខ្លួននឹងត្រូវរស់នៅជាអ្នកក្រ បុគ្គលនោះនឹងពិតជានៅក្រអស់មួយជីវិត"។

ប្រសិនបើ យើងក្រឡេកមើលពិភពលោកបច្ចុប្បន្ន អ្នកដែលមានចំណេះដឹង និងចិត្តវិស័យត្រឹមត្រូវ ធ្វើកិច្ចការត្រឹមត្រូវដោយសេចក្តីព្យាយាម ពួកគេនឹងទទួលបានជោគជ័យ និងរុងរឿង។ ជនទាំងឡាយណា ដែលមិនចង់ធ្វើការងារណាមួយដោយសេចក្តីព្យាយាមដ៏ខ្លាំងក្លាទេ នឹងនៅតែក្រអស់មួយជីវិត សូម្បីតែពួកគេខំបន់ស្រន់ឱ្យព្រះអាទិទេពជួយរាល់ថ្ងៃយ៉ាងណាក្តី។

ម្ល៉ោះហើយ វាប្រាកដណាស់ថា ខ្លួនយើងហ្នឹងឯងជាអ្នកសាងនូវជោគវាសនារបស់ខ្លួនយើង មិនមែនដោយសារព្រះអាទិទេព ដ៏មានអំណាច ដែលយើងមិនដែលឃើញ មិនដែលដឹង មកសាងឬផ្តល់ជោគវាសនាឱ្យយើងនោះឡើយ។

## ៣. តើចិត្តជាខួរក្បាលឬ?

ដោយសារចិត្តគ្រប់គ្រងអំពើ អាកប្បកិរិយា គំនិត អារម្មណ៍

ការត្រិះរិះពិចារណារបស់យើង ដូច្នេះ វាជាថាមពលសំខាន់ចាំបាច់បំផុត ដែលយើងមាន។

ទោះជាយ៉ាងណាក្តី នៅពេលគេមិនអាចមើលឃើញចិត្ត ហើយមិនអាចពិនិត្យសង្កេតដោយឧបករណ៍វិទ្យាសាស្ត្រ អ្នកវិទ្យាសាស្ត្រមួយចំនួនសន្មតថា ចិត្តមិនមានទេ ហើយតួនាទីរបស់ចិត្តត្រូវបានដំណើរការដោយខួរក្បាល។ នោះមានន័យថា គេយល់ថាចិត្ត ជាខួរក្បាល។

ពួកគេដឹងថា សរសៃប្រសាទទាំងអស់នៅក្នុងសរីរាង្គកាយត្រូវបានគ្រប់គ្រងដោយខួរក្បាល ហើយគេប៉ាន់ស្មានថា ខួរក្បាលផ្ទុកនូវណឺរ៉ូន(កោសិកាកាយប្បសាទ) ជាងបីកោដិជាឧបករណ៍ទំនាក់ទំនង ដើម្បីទទួលដំណឹងតាមទម្រង់នៃការជម្រុញ ដោយថាមពលអគ្គិសនីពីប្រព័ន្ធសរសៃប្រសាទផ្សេងៗ ហើយបញ្ជូនដំណឹងតាមប្រព័ន្ធទាំងនេះ។

ដូច្នេះ ប្រព័ន្ធទំនាក់ទំនងខួរក្បាល មានលក្ខណៈស្មុគស្មាញ និងស្អាតជាងប្រព័ន្ធទំនាក់ទំនងនៅក្នុងទីក្រុងធំៗ នៅក្នុងពិភពលោក ដូចជាទីក្រុងញូយ៉ក ទីក្រុងឡុងដ៍ និងទីក្រុងតូក្យូ។ ដោយសារប្រព័ន្ធទំនាក់ទំនងខួរក្បាល មានលំដាប់លំដោយល្អ ដូច្នេះហើយ ទើបអ្នកប្រាជ្ញមួយចំនួនថែមទាំងគិតថា វាពិតជាបង្កើត





ឡើងដោយព្រះអាទិទេពដ៏មានអំណាច។ តាមជាតុពិតចំនួននៃសត្វទាំងឡាយក្នុងចក្រវាឡមានរាប់មិនអស់។

សត្វតូចធំទាំងអស់សុទ្ធតែមាន ចិត្ត និង ខួរក្បាល។ ឥរិយាបថ ផ្លូវចិត្ត និង អំណាចនៃការគិតរបស់សត្វទាំងឡាយខុសគ្នាពីមួយទៅមួយ។ សូម្បីក្នុងបុគ្គលម្នាក់ ឥរិយាបថ និងការគិតរបស់គាត់ប្រែប្រួលគ្រប់វេលាទាំងអស់។ ដូច្នេះ ប្រសិនបើ ព្រះអាទិទេព មានអំណាចគ្រប់គ្រងគំនិតទាំងអស់របស់សត្វទាំងឡាយ ព្រះអាទិទេពនោះ នឹងក្លាយជាបុគ្គលដែលរវល់បំផុត និងមានការព្រួយបារម្ភយ៉ាងច្រើននៅក្នុងលោក។ ព្រះអាទិទេព នោះនឹងស្ថិតក្នុងល័ក្ខខ័ណ្ឌមួយគួរឱ្យអាណិតអាសូរ។ ហេតុអ្វីបានជាព្រះអាទិទេពនោះ មិនអាចរស់នៅដោយរីករាយ និងសុខស្ងប់ដោយខ្លួនឯង?

នៅពេលមនុស្សទាំងឡាយ មិនបានដឹងហេតុពិតប្រាកដនៃភ្លៀងរដូវប្រាំង ទឹកជំនាន់ ព្យុះកំណាច រញ្ជួយផែនដី បន្ទុះភ្នំភ្លើងផ្លេកបន្ទោរ អំឡុងពេលគ្រោះទុរ្ភិក្ស និងចម្បាំងរាំងជល់ គេគិតថាព្រះអាទិទេពខឹង ហើយបង្កើតបាតុភូតទាំងនេះ ឬព្រះអាទិទេពបង្កើតហេតុទាំងនេះឡើង។ គំនិត និងជំនឿបែបនេះ ជាប៉ែកខាងទស្សនៈខុសហេតុផល។ នៅពេលចំណេះដឹងរបស់មនុស្សកាន់

តែអភិវឌ្ឍន៍ ហើយមនុស្សកាន់តែយល់ដឹងហេតុបានត្រឹមត្រូវ គេក៏ដឹងច្បាស់ថា រាល់បាតុភូតធម្មជាតិទាំងអស់ កើតឡើងដោយសារហេតុរបស់ធម្មជាតិ ហើយថា ហេតុនោះមិនមែនបង្កើតឡើងដោយព្រះអាទិទេពណាមួយឡើយ។

ត្រង់ចំណុចនេះ ដូចជាករណីរបស់ចិត្តដែរ ដោយសារអ្នកប្រាជ្ញជាច្រើនមិនដឹងថាអ្វីទៅជាចិត្តពិតប្រាកដ ហើយថែមទាំងមិនដឹងពីធម្មជាតិពិត និងតួនាទីរបស់ចិត្ត គេក៏ជឿថាខួរក្បាលដើរតួនាទីជាចិត្ត ហើយវាកំពុងត្រូវបានគ្រប់គ្រងដោយព្រះអាទិទេព។ តាមពិតទៅ ខួរក្បាលគឺគ្រាន់តែជារូបធាតុប៉ុណ្ណោះ ហើយរូបធាតុនេះទៀតសោត មិនអាចគិត ឬមានអារម្មណ៍ វាមិនចេះសប្បាយ ឬខឹងក្រោធឡើយ។ ហើយថែមទាំងមិនមានព្រះអាទិទេពមានអំណាចណាមួយ នៅក្នុងភពទាំង ៣១ ជាន់នេះ ទៀតផង។

ចិត្តមនុស្សដឹងនូវលក្ខណៈ និងសារៈនៃរូបធាតុ។ ម្ល៉ោះហើយ វាអាចបង្កើតវត្ថុអស្ចារ្យជាច្រើន ដូចជាយន្តហោះប្រតិកម្ម យានអវកាស ស្ថានីយ៍យានអវកាស ផ្កាយរណប ប្រព័ន្ធទំនាក់ទំនងតាមផ្កាយរណប កុំព្យូទ័រ ទូរស័ព្ទឥតខ្សែ និងទូរទស្សន៍។ អ្នកមិនមានចំណេះដឹងផ្នែកវិទ្យាសាស្ត្រ ប្រហែលជាគិតថា វត្ថុដ៏





អស្ចារ្យទាំងអស់នេះ បង្កើតឡើងដោយបុគ្គលដែលមានសព្វានុភាព។ តាមធាតុពិត គឺចិត្តទេដែលនាំឱ្យបង្កើតវត្ថុទាំងនេះឡើង។

សព្វថ្ងៃកុំព្យូទ័រដ៏ទំនើបអស្ចារ្យ អាចដោះស្រាយចំណោទតែក្នុងវិនាទីប៉ុណ្ណោះ ដែលប្រហែលប្រើអ្នកគណិតវិទ្យាចំនួន១០០នាក់ក្នុង១ខែ ទើបអាចដោះស្រាយវិធីសន្មតិនានានោះបាន។ កុំព្យូទ័រមួយ អាចផ្ទុកទិន្នន័យបានរាប់លាន នៅក្នុង មិម៉ូរី របស់វា ហើយអាចបង្កើតឡើងវិញ នូវការពិតដែលយើងចង់បានភ្លាមៗ។ កុំព្យូទ័រនានាបានត្រូវរចនា ឬ ឱសាញ ដើម្បីលេងអុក ឬកីឡាបាល់ទាត់។ ប៉ុន្តែប្រសិនបើយើងសួរថា " តើកុំព្យូទ័រ មានប្រាជ្ញាមានវិញ្ញាណ និងថាមពលនៃការគិតដោយខ្លួនវាបានឬទេ? ចម្លើយថា "ទេ" ព្រោះហេតុអ្វី?

កុំព្យូទ័រមួយគ្រឿង មិនអាចចេះគិតដោយខ្លួនវាបានទេ។ វាឥតមានបញ្ញា មានវិញ្ញាណ ហើយគ្មានចំណង់ចង់ទៅទីនេះ ឬទីនោះឡើយ។ ប្រសិនបើយើងនិយាយរឿងរ៉ាវខូចចិត្ត ឬបេះដូងប្រាប់វា កុំព្យូទ័រនឹងមិនមានអារម្មណ៍ឈឺចុកចាប់ក្នុងដើមទ្រូង ហើយវាក៏មិនចេះស្រក់ទឹកភ្នែកដែរ។ ប្រសិនបើយើងនិយាយរឿងកំប្លែង ឬរឿងប្រគុំដន្ត្រីឱ្យកុំព្យូទ័រស្តាប់វានឹងមិនសើច ហើយមិនរីករាយ

ជាមួយយើងដែរ ព្រោះវាឥតមានអារម្មណ៍។ វាអាចធ្វើតែអ្វីដែលគេបានរៀបចំកម្មវិធី ឬកម្មវិធីទុកឱ្យជាមុនប៉ុណ្ណោះ។

ខួរក្បាលដូចកុំព្យូទ័រមួយគ្រឿង។ ដោយសារសរសៃប្រសាទទាំងអស់ នៅក្នុងរាងកាយជួបប្រជុំគ្នានៅក្នុងខួរក្បាល ហើយខួរក្បាល ជាអវៈយវៈគ្រប់គ្រងផ្នែកកណ្ដាល ទើបវាសំខាន់ណាស់។ ប៉ុន្តែ ខួរក្បាលមិនអាចដឹងអារម្មណ៍ ឬចេះគិតដោយខ្លួនវាបានឡើយ។ ប្រៀបដូចកុំព្យូទ័រត្រូវបានគ្រប់គ្រងដោយមនុស្សយ៉ាងណា ខួរក្បាលក៏ត្រូវបានចិត្តជាអ្នកគ្រប់គ្រងយ៉ាងដូច្នោះដែរ។

លោកសាស្ត្រាចារ្យ **ចន អ៊ីឃ្លីស** (John Eccles) ជាកោសិកាកាយប្បសាទវិទូដ៏ល្បីល្បាញបំផុត បានធ្វើការស្រាវជ្រាវយ៉ាងពិសេសមួយទៅលើខួរក្បាល ដែលបានធ្វើការកត់សម្គាល់ដូចខាងក្រោមៈ

"ការសិក្សាលើរចនាសម្ពន្ធ័របស់ខួរក្បាល បង្ហាញថា ខួរក្បាល គឺជាប្រភេទនៃកុំព្យូទ័រមួយគ្រឿង ដែលដំណើរការដោយខ្មោចមួយ។ ខ្មោចនៅត្រង់នេះ មានន័យថា អ្វីមួយដែលមិនអាចរកឃើញដោយឧបករណ៍ទាំងឡាយ ដែលគេប្រើដើម្បីរកនូវវត្ថុសម្ភារៈនានា"។ ខ្មោចហ្នឹង គប្បី ចាត់ទុកថាជាចិត្តហ្នឹងឯង។

រាល់ទិន្នន័យនៃវិញ្ញាណទាំងអស់ ដែលមកពី ភ្នែក ត្រចៀក





ច្រមុះ អណ្ដាត និង កាយ ត្រូវគេទុកក្នុង មិម៉ូរី របស់ខួរក្បាល។ ទិន្នន័យនៃវិញ្ញាណថ្មីមួយ ដែលមកពីទ្វារនៃវិញ្ញាណមួយនោះត្រូវបានភ្ជាប់ជាមួយទិន្នន័យ ដែលស្តុកទុកនៅក្នុងខួរក្បាលនោះ ហើយខួរក្បាលក៏សម្រេចថា វាជាអារម្មណ៍អ្វី ។ អនុមានទាំងនេះមិនត្រឹមត្រូវតាមព្រះអភិធម្មទេ។

## អភិធម្ម ពន្យល់ពីដំណើរប្រព្រឹត្តទៅរបស់នាម

យោងតាមព្រះអភិធម្ម "**នាម**" គឺជាការផ្សំឡើងដោយ"**ចិត្ត**" និង "**ចេតសិក**" ។ ចិត្ត និងចេតសិក កើតឡើង និងរលត់ទៅព្រមជាមួយគ្នា។ ចិត្ត កើតឡើងនឹងរលត់ទៅវិញជាង១កោដិដងបន្តបន្ទាប់គ្នារាល់វិនាទី។

ចិត្ត គឺជាអ្នកដឹងនូវវិញ្ញាណ។ វាមានឥទ្ធិពលច្រើនយ៉ាងដោយសារចេតសិក។ ចេតសិក ទាំងអស់មាន៥២ដួងគឺ ឧបេក្ខា ១៣ អកុសល១៤ និងសោភណកុសលចេតសិក២៥។

ឧបេក្ខាចេតសិក ផ្ទុកនូវ " **ផស្សៈ** " រវាងចិត្តនិងអារម្មណ៍ " **វេទនា** "ជាអ្នកសោយនូវអារម្មណ៍ "**សញ្ញា**" ជាអ្នកកត់សម្គាល់នូវភាពជាក់លាក់នៃអារម្មណ៍ " **ចេតនា** " ជាអ្នកធ្វើអំពើ និងជាអ្នកបណ្ដាលនូវចេតសិករបស់វាឱ្យធ្វើនូវអំពើ "**ឯកគ្គតា**" ជាអ្នកបង្រួមនូវចេតសិករបស់វា ហើយឱ្យផ្ចង់ចិត្តទៅលើអារម្មណ៍តែ

មួយ “**ឆន្ទៈ**” សេចក្តីប្រាថ្នាឬចំណង់ចង់ធ្វើអ្វីមួយ “**វិរិយៈ**” គឺសេចក្តីព្យាយាម។ល។ ចេតសិកទាំងនេះ សម្បយុត្តជាមួយទាំងកុសលចិត្ត និងអកុសលចិត្ត។

អកុសលចេតសិក រាប់ទាំង **មោហៈ** គឺការមិនដឹងនូវលក្ខណៈពិតរបស់អារម្មណ៍ **លោភៈ** ដែលប្រាថ្នាចង់បានលុយទ្រព្យសម្បត្តិ កាមគុណ ។ល។ **ទោសៈ** ដែលបង្កើតបានជា **បដិឃៈ** និង**ព្យាបាទ**។ អកុសលចេតសិក ទាំង៣នេះឈ្មោះថា អកុសលមូល ដែលធ្វើឱ្យចិត្តទៅជា អកុសល ដែលជាឫសគល់នៃអំពើអាក្រក់គ្រប់យ៉ាងនៅក្នុងពិភពលោក។ អកុសលមូលទាំង៣នេះនាំឱ្យកើត **ទិដ្ឋិខុស** ឬ **មានៈ អហិរិកៈ អនោត្តប្បៈ** ជាដើម។

សោភណចេតសិក មាន **បញ្ញា** ឬ **អមោហៈ អលោភៈ អទោសៈ ហិរិ ឱត្តប្ប ករុណា មុទិតា**។ ៣ខាងដើមគឺ **អមោហៈ អទោសៈ អលោភៈ** ឈ្មោះថាកុសលមូល ដែលធ្វើឱ្យចិត្តទៅជាកុសល ដែលជាឫសគល់នៃអំពើល្អគ្រប់យ៉ាងនៅក្នុងលោក។

នៅពេលរូបាម្មណ៍ ប៉ះផ្ទប់ជាមួយចក្ខុ រូបរបស់វាកើតឡើងច្បាស់ នៅក្នុងចក្ខុបសាទ។ អាវជ្ជនៈចិត្ត តម្រង់ខ្សែចិត្តនោះ ទៅកាន់រូបនេះ ហើយចក្ខុវិញ្ញាណមើលឃើញនូវរូបនោះ ឯ **សម្បដិ-ច្ឆនចិត្ត** ទទួលបាននូវរូបនោះ ហើយ **សន្តីរណចិត្ត** សង្កេតមើលវា





ហើយចិត្តនេះឯងជាអ្នកសម្រេចថា តើរូបារម្មណ៍នោះល្អ ឬអាក្រក់នៅពេលដែលកើតឡើង។ អាស្រ័យលើការសម្រេចចិត្តនោះ កុសល ឬអកុសលចិត្តកើតឡើង៧ដង ជាជវនចិត្តសោយនូវអារម្មណ៍នោះ។ តទាលម្ពនចិត្ត ២ កើតឡើងតទៀត ដើម្បីបន្តសោយនូវអារម្មណ៍នោះ។ ពេលនោះអារម្មណ៍រលត់ ហើយភវង្គប្រព្រឹត្តតាមធម្មតា។

អារម្មណ៍ដែលរលត់ទៅនោះ កើតឡើងវិញនៅក្នុងភវង្គដែលដើរតួជាមនោទ្វារ អាចចាប់យកនូវអតីតារម្មណ៍។ ខណៈនោះ វិថីចិត្តជាច្រើន កើតឡើងយ៉ាងឆាប់រហ័ស បន្តបន្ទាប់គ្នាកំណត់ដឹងនូវរូប ទ្រង់ទ្រាយ ទំហំ លក្ខណៈពិស្តារ និងឈ្មោះនៃអារម្មណ៍នោះ។ ចិត្តធ្វើការលឿនជាងកុំព្យូទ័រ។

អ៊ីចឹង រាល់ចិត្តទាំងអស់សុទ្ធតែត្រូវប្រព្រឹត្តទៅព្រមជាមួយចេតសិកសំខាន់ទាំង៧គឺ ផស្សៈ វេទនា សញ្ញា ចេតនា សមាធិ ជីវិតិន្ទ្រិយ និងមនសិការៈ។ ចេតសិកទាំងនេះ ដើរតួជាជំនួយដល់ចិត្ត ដើម្បីដឹងនូវអារម្មណ៍។

**នាម** ពោលគឺជាការផ្សំឡើងដោយ **ចិត្ត** និង **ចេតសិក** ដែលរលត់ទៅភ្លាមបន្ទាប់ពីវាបានកើតឡើង។ ក៏ប៉ុន្តែ មុនពេលវារលត់ **ចិត្ត** និង**ចេតសិក** ផ្ទេរនូវថាមពលរបស់វា ទៅកាន់ចិត្តដែល

កើតឡើងបន្ទាប់ទៀត។ **សញ្ញា** ផ្ទេរនូវលក្ខណៈពិស្តាររបស់អារម្មណ៍ដែលវាបានដឹង **វេទនា** ផ្ទេរនូវសញ្ញាដែលវាបានសោយ **ចិត្ត** ផ្ទេរនូវអ្វីដែលវាបានដឹងជាដើម។ ទិន្នន័យទាំងនេះត្រូវបានពាំនាំពីចិត្តមួយទៅកាន់ចិត្តមួយ។ ដូច្នេះ វាស្ថិតនៅក្នុងខ្សែចិត្ត ឬវិថីចិត្តដដែល។ វាស្រដៀងគ្នាទៅនឹងទិន្នន័យ ដែលត្រូវស្តុកទុកក្នុង មិម៉ូរី នៃកុំព្យូទ័រមួយដូច្នោះដែរ។

ប្រៀបដូចកុំព្យូទ័រអាចផលិតនូវទិន្នន័យ ដែលវាស្តុកទុកបានភ្លាមយ៉ាងណា ចិត្ត ក៏អាចរលឹកឃើញនូវទិន្នន័យដែលវាបានស្តុកទុកភ្លាមយ៉ាងដូច្នោះដែរ។ ដោយហេតុនេះហើយ ទើបយើងអាចចាំបាននូវអ្វីដែលយើងបានរៀន និងបានពិសោធតាំងពីកុមារភាពមកម្ល៉េះ។ យើងអាចភ្លេចនូវទិន្នន័យជាច្រើន ប៉ុន្តែយើងអាចរលឹកឃើញនូវទិន្នន័យនោះឡើងវិញ ក្រោមការស្មឹងស្មាធិ៍។

ត្រង់ចំណុចនេះ សូមបញ្ជាក់ថា នៅពេលស្លាប់ បន្ទាប់ពីចុតិចិត្តរលត់ទៅភ្លាមនៅក្នុងបច្ចុប្បន្នភព បដិសន្ធិចិត្ត ក៏កើតឡើងភ្លាមនៅក្នុងភពបន្ទាប់ (អនាគតភព) ដោយគ្មានចន្លោះពេលក្នុងវិថីចិត្តនោះឡើយ។ ដូច្នេះ ទិន្នន័យ ដែលយើងបានរៀនសូត្រ និងបានឆ្លងកាត់បទពិសោធន៍ទាំងប៉ុន្មាននៅក្នុងជីវិតនេះ ត្រូវបានផ្ទេរទៅកាន់វិថីចិត្ត នៃជីវិតបន្ទាប់ទៀត។





ហេតុដូច្នេះហើយ ទើបមានក្មេងជាច្រើននៅលើសកលលោក អាចចាំនូវអតីតជាតិរបស់ពួកគេបានយ៉ាងត្រឹមត្រូវ ហើយបានជាមានក្មេងមានទេពកោសល្យអាចចាំ និងសូត្រនូវអ្វីដែលពួកគេបានរៀនសូត្រក្នុងអតីតជាតិយ៉ាងអស្ចារ្យ។ ម្យ៉ាងវិញទៀត ឥរិយាបថផ្លូវចិត្ត ចរិតលក្ខណៈប្រាជ្ញា និងចំណាប់អារម្មណ៍នៅក្នុង អនាគតភព តំណាងឱ្យអ្វីៗទាំងអស់ដែលមាននៅក្នុងបច្ចុប្បន្នភពនេះឯង។

ប្រសិនបើខួរក្បាល គឺជាចិត្តនៅពេលដែលខួរក្បាលថ្មីបង្កើតឡើងនៅក្នុងភពថ្មី ហើយវាទទេឥតមានទិន្នន័យអ្វីសោះ ក្នុងពេលកើតដូចដែលបានគូសបញ្ជាក់ដោយ **ដេកាតស៍** ជាទស្សនវិទូឆ្នើមដែរនោះ ខួរក្បាលពិតជាមិនអាចចាំបាននូវអតីតជាតិ និងអ្វីៗដែលបានសូត្ររៀនក្នុងអតីតឡើយ។ អ្នកមានទេពកោសល្យជាច្រើនអាចអាន និងសរសេរដោយគ្មានបានរៀន ហើយអ្នកខ្លះទៀតដូចជា **គ្រីស្មៀន ហេនីកេន** និងបិដក **ម៉ោង ទុន ចែង** អាចសូត្រអត្ថបទគម្ពីរ **ប៊ីប** ឬអត្ថបទគម្ពីរព្រះត្រៃបិដកបាន។ ក្មេងស្រីឈ្មោះ **ម៉ា ហ្លាក់ ជី** របស់ប្រទេស **មីយ៉ាន់ម៉ា** អាចអានភាសាបាលី ហើយយល់សេចក្តីបានក្នុងអាយុ៦ឆ្នាំដោយមិនទាន់បានរៀនភាសាបាលី ក្នុងបច្ចុប្បន្នជាតិនៅឡើយ។ **គ្រីស្មៀន ហេនីកេន**

អាចសូត្រអត្ថបទពី គម្ពីរប៊ីប ក្នុងអាយុ១ឆ្នាំ ហើយឆ្លើយសំណួរខ្លះៗ អំពីភូមិវិទ្យាក្នុងអាយុ២ឆ្នាំ។ ចំណុចទាំងអម្បាលនេះ ពុំអាចពន្យល់បានតាមទ្រឹស្តីខួរក្បាលទេ ប៉ុន្តែអាចពន្យល់បានតាមព្រះអភិធម្មបានយ៉ាងល្អ។

លើសពីនេះទៅទៀត លទ្ធភាពនៃការមើលឃើញពួកអមនុស្ស និងធ្វើការទំនាក់ទំនងជាមួយពួកអមនុស្សនោះ ដោយការប្រើវិញ្ញាណក្រៅខ្លួន(*អ្នកស្រីកីព័រ* និង *អ៊ីស្តែល រ៉ូប៊ឺត*)សមត្ថភាពនៃការធ្វើរោគវិនិច្ឆ័យ និងការព្យាបាលអ្នកជម្ងឺ ពីចម្ងាយរាប់រយម៉ាយ (*អេដហ្គ័រ ខាយី*) លទ្ធភាពនៃការធ្វើឱ្យដឹងជាតិ ដែលពន្យល់ពីល័ក្ខខ័ណ្ឌនៃអតីតជាតិក៏ដូចជាបច្ចុប្បន្នជាតិ (*អេដហ្គ័រ ខាយី*) ទិព្វចក្ខុដែលអាចមើលឃើញសព្វសត្វទាំង៣១ ជាន់ ញាណនៃការមើលឃើញសត្វទាំងឡាយ ដែលកំពុងចុតិ ព្រមទាំងសត្វទាំងឡាយដែលកំពុងបដិសន្ធិក្នុងភព ទាំង៣១ ជាន់ ហៅថា **ចុតូប្បាតញ្ញាណ** ញាណដែលអាចដឹងថា សត្វទាំងឡាយដែលកំពុងកើតក្នុងភពផ្សេងៗ។ យោងទៅតាមកម្មរបស់ខ្លួន ហៅថា **កម្មូបគញាណ** ញាណដែលអាចដឹងនូវ អនាគតជាតិ និងព្រឹត្តិការណ៍ក្នុងពេលអនាគត ហៅថា **អនាគតំសញាណ** សមត្ថភាពដែលអាចបង្កើតជារូបផ្សេងៗ និងសំដែងនូវអំណាចផ្សេងៗ





ហៅថា **ឥទ្ធិវិធ អភិញ្ញា** ជាដើម ទាំងអស់នេះគេមិនអាចចម្រើន ឬអប់រំដោយខួរក្បាលបានឡើយ។

ម្ល៉ោះហើយចិត្តពុំមែនជាខួរក្បាលទេ។ ចិត្ត គឺជានាមធម៌ដែលមានលក្ខណៈឧត្តមប្រសើរជាងខួរក្បាល ដែលជាអង្គរូបធាតុរាប់ពាន់លានដង។ ចិត្ត បង្កើត មនុស្ស សត្វ ជាតិសាសន៍ អរិយធម៌ វប្បធម៌ អក្សរសាស្ត្រ គ្រប់ប្រភេទទាំងអស់ ព្រមទាំងជោគវាសនារបស់សព្វសត្វទាំងអស់ផងដែរ។ ពិតមែនហើយ ចិត្តគឺជានាមធម៌ដែលមានថាមពលបំផុត ដែលអាចលើកកម្ពស់មនុស្ស ឱ្យឈានដល់ថ្នាក់ខ្ពស់បាន។ ជនទាំងឡាយណា ដែលមិនទាន់យល់អ្វីទៅជាចិត្តពិតប្រាកដ គួរសិក្សាអភិធម្ម និងប្រតិបត្តិភាវនា។

## ៤. តើនរណាជាអ្នកបង្កើតលោកពិត?

ចូរកុំនាំឱ្យមានបញ្ហា ដើម្បីស្វែងរកអ្នកបង្កើតលោកពិតប្រាកដនៅក្នុងពិភពលោកទាំងមូល ឬនៅក្នុងភពទេវតាទាំងអស់។ ព្រះសម្មាសម្ពុទ្ធ អាចមើលឃើញសព្វសត្វទាំងអស់យ៉ាងទូលំទូលាយ ក្នុងចម្ងាយមួយសែនចក្រវាឡ ព្រមទាំងក្នុងភពទាំង៣១ ជាន់ ដោយទិព្វចក្ខុរបស់ព្រះអង្គផ្ទាល់។ ព្រះអង្គអាចចាក់ធ្លុះ

ទៅដល់បរមត្ថសច្ចៈ ដែលបង្កើតបានជាសមាសធាតុនៃ **នាម** និង**រូប**។

ទោះបីជាព្រះអង្គអាចមើលឃើញ ដោយទិព្វចក្ខុ ទូលំទូលាយ គ្មានដែនកំណត់ក្តី ព្រះអង្គឥតបានឃើញព្រះអាទិទេព ឬសត្វប្រកបដោយសព្វានុភាពណាមួយ ដែលអាចបង្កើតលោកជាមួយសព្វសត្វទាំងអស់របស់ខ្លួនឡើយ ព្រះអង្គក៏មិនដែលឃើញថាមាន**ព្រលឹង** ឬ **ជីវៈ** ឬ **អត្ត** ឬ **ជីវិតិន្ទ្រិយ**ណាមួយ ដែលទៀងនៅអមតៈហើយអាចរក្សារូបកាយឱ្យរស់នៅសកម្មរហូតបានឡើយ។

ម្ល៉ោះហើយ អាទិទេព ដែលអាចបង្កើតលោក និងសព្វសត្វទាំងអស់មិនមានទេ **ព្រលឹង** ឬ **ជីវៈ** ឬ **អត្ត** ឬ **ជីវិតិន្ទ្រិយ** ដែលនឹកស្មានថា ត្រូវបង្កើតឡើងដោយព្រះអាទិទេពនោះ ក៏ពិតជាមិនមានដែរ។ ធាតុពិតដែលមាននៅក្នុងលោកនេះ មានតែ៣យ៉ាងប៉ុណ្ណោះគឺៈ **ចិត្ត** **ចេតសិក** និង **រូប** រួមទាំង**ថាមពល**។

ចិត្ត និង ចេតសិក ហៅរួមជាមួយគ្នាថា "**នាម**" ពោលគឺអ្វីៗដែលជានាមធម៌នេះឯង។ ឯ រូប និងថាមពល ហៅរួមគ្នាថា " **រូប** " ពោលគឺសំដៅយកអ្វីៗដែលជារូបធម៌។ ដូច្នេះ មានតែ "**នាម**" និង "**រូប**" ប៉ុណ្ណោះ ដែលស្ថិតនៅក្នុងលោកទាំងមូល។

នាមធម៌ និង រូបធម៌ ទាំងឡាយគឺមិនទៀងទេ តែងកើត





ឡើងហើយរលត់ទៅវិញយ៉ាងឆាប់រហ័សគ្មានឈប់។ ហេតុនេះហើយ សព្វសត្វមានជីវិត និងវត្ថុឥតជីវិតទាំងអស់គឺមិនទៀងនៅរហូតទេ សភាវទាំងនេះឯងកំពុងកើត និងរលត់ទៅភ្លាមយ៉ាងឆាប់រហ័សឥតឈប់ឈរ។ ដូច្នេះ" **អនិច្ចៈ**" គឺជាសាមញ្ញលក្ខណៈរបស់សព្វសត្វមានជីវិត និងវត្ថុគ្មានជីវិតទាំងអស់។ វិទ្យាសាស្ត្របកស្រាយការពិតនេះ ដោយការអះអាងថាៈ

*"អេឡិចត្រុង វិលជុំវិញ នុយក្លីអ៊ែរ របស់អាតូមនីមួយៗ យ៉ាងឆាប់រហ័ស ហើយរ៉ាឡង់ស៍ អេឡិចត្រុង ដែលមានគ្រាប់ច្រើនបំផុតនៅផ្នែកខាងក្រៅ ធ្វើចលនាពីអាតូមមួយទៅអាតូមមួយ"* ។

អ្វីដែលមិនទៀងជាទុក្ខ និងសភាពនៃការឈឺចាប់ញាំញីជាប្រចាំដោយការបែកធ្លាយ ឬការរលត់ទៅនៃ នាម និងរូប ដែលយើងស្រឡាញ់រាប់ថាជារូបកាយ និងចិត្តរបស់យើងនោះ ពិតជានាំមកនូវសេចក្តីទុក្ខ។ ដូច្នេះ "**ទុក្ខៈ**" សេចក្តីទុក្ខគឺពិតជាសាមញ្ញ-លក្ខណៈ របស់សព្វសត្វមានជីវិត ទាំងអស់។

លើសពីនោះទៅទៀត ប្រសិនបើយើងអាចចម្រើននូវសមាធិចិត្ត ពោលគឺការស្រូបយកនូវសភាពនៃចិត្ត ហៅថា ឈាន ដោយការប្រតិបត្តិសមថភាវនា ចិត្តនឹងទៅជាបរិសុទ្ធមានថាមពលផ្សាយ

ចេញនូវពន្លឺយ៉ាងភ្លឺ និងចាក់ធ្លុះទៅក្នុងអ្វីៗទាំងអស់។ ដោយមានជំនួយពីពន្លឺនេះ បុគ្គលអាចមើលឃើញធ្លុះទៅក្នុងរូបកាយរបស់ខ្លួន ក៏ដូចជារូបកាយរបស់អ្នកដទៃ ដើម្បីសង្កេតមើលឃើញនូវនាម និងរូបនោះ ដែលកំពុងកើតឡើង និងរលត់ទៅវិញយ៉ាងឆាប់រហ័សឥតឈប់ឈរ។

ដោយសារបរមត្ថធម៌គឺ **ចិត្ត ចេតសិក រូប** និង **ថាមពល** ជាធម៌មានតែឈ្មោះតែគ្មានរូប គ្មានទ្រង់ទ្រាយដូច្នេះហើយ ទើបបុគ្គលមិនអាចសង្កេតមើលឃើញ កាយ បុគ្គល ឬ សត្វមានជីវិត ដោយ មនោចក្ខុន្ទ្រីយ៍ ដែលមានជំនួយពីពន្លឺភ្លឺចាក់ធ្លុះនោះបានទេ។ ដូច្នេះ តាមធាតុពិត គឺពុំមានបុគ្គល ឬតួខ្លួន ឬព្រលឹង ឬអាត្មន់ឡើយ។ លក្ខណៈដែលមិនមែនខ្លួន មិនមែនព្រលឹង របស់សព្វសត្វទាំងអស់នេះហើយ ឱ្យឈ្មោះថា "**អនត្តា**"។

សាមញ្ញលក្ខណៈទាំង៣នេះ ពោលគឺភាពមិនទៀង ភាពជាទុក្ខ និងភាពមិនមែនជារបស់ខ្លួនតែងកើតមានដល់សព្វសត្វមានជីវិតនិងវត្ថុគ្មានជីវិតទាំងអស់។ លក្ខណៈទាំង៣គឺ **អនិច្ចៈ ទុក្ខៈ** និង **អនត្តា** នេះមានសារសំខាន់ណាស់ ព្រោះវាពណ៌នានូវលក្ខណៈពិតរបស់អារម្មណ៍ វត្ថុរួមទាំងសត្វមានជីវិតទាំងអស់ និងសកលលោកផងដែរ។ ដោយសារចិត្តត្រូវបិទបាំងដោយមោហៈ





យើងមិនអាចមើលឃើញនូវលោកតាមសភាវពិតទេ ដែលនៅក្នុងនោះមានតែ បរមត្ថធម៌ ដែលគ្មានរូប គ្មានទ្រង់ទ្រាយស្ថិតនៅ កើតរលត់ និង ធ្វើអន្តរកម្ម តាមរបៀបផ្សេងៗ ដើម្បីបង្កើតនូវបាតុភូត នាម និងរូប ដ៏ស្មុគស្មាញនេះឡើង។

នៅក្នុងលោកនេះ មិនមានសត្វមានជីវិត មិនមានវត្ថុឥតជីវិត មិនមានបុគ្គល និង តួខ្លួនស្ថិតនៅទេ គឺមានតែ ចិត្ត ចេតសិក និង រូបធម៌ ប៉ុណ្ណោះ ដែលស្ថិតនៅ។ ដោយសារមិនមានបុគ្គល មិនមានតួខ្លួនតាំងនៅ ដូច្នេះយើងមិនចាំបាច់ត្រូវការអ្នកបង្កើតលោកណាមួយ មកបង្កើតវត្ថុទាំងនេះឡើយ។ ព្រោះតែមនុស្សយើងបិតបាំងដោយ មោហៈ គេមិនអាចមើលឃើញនូវបរមត្ថធម៌នេះបានទេ។ គេមើលឃើញ ដឹងបាន ត្រឹមតែបញ្ញាត្តិប៉ុណ្ណោះ ដែលបង្ហាញថា សត្វមានជីវិត និងវត្ថុឥតជីវិតទាំងអស់ពិតជាមាន។ ដូច្នេះ គេសន្មតថា អ្នកសាងលោក ដែលមានសព្វានុភាពនោះ បង្កើតនូវវត្ថុទាំងអស់នោះឡើង។

ការប្រមើលឃើញខុសនៃភពអន្ធការនេះ ជាហេតុនាំឱ្យមានទិដ្ឋិយល់ឃើញខុសដោយគិតថា ពិតជាមានសត្វមានជីវិត និងតួខ្លួន។ មិច្ឆាទិដ្ឋិជាមូលដ្ឋានមួយ ដែលបានញាំញីយើងអស់ជាច្រើនកប្បហើយនោះ គឺសកាយទិដ្ឋិ ដោយប្រកាន់ថា ពិតជា

មាន "អញ" ឬ "ខ្លួន" ។ មិច្ឆាទិដ្ឋិ គឺការយល់ឃើញខុសនេះ ធ្វើឱ្យបុគ្គលមានសេចក្តីកំណាញ់ ផ្តោតយកខ្លួនជាធំ ឬជាសំខាន់ និងមានសេចក្តីលោភ ព្យាយាមដើម្បីប្រយោជន៍ផ្ទាល់ខ្លួន ក្នុងការចំណាយរបស់អ្នកដទៃ។ ផ្អែកលើការយល់ឃើញខុសជាមូលដ្ឋាននេះ នាំឱ្យមានមិច្ឆាទិដ្ឋិដទៃជាច្រើនទៀត កើតឡើងក្នុងលោក ហើយបង្កើតឱ្យមានបញ្ហាជាច្រើនរាប់មិនអស់។

ប្រការដែលគួរឱ្យខ្លាចបំផុត អំពីសកាយទិដ្ឋិនោះគឺថា វាអាចនាំឱ្យបុគ្គលធ្វើនូវអំពើអាក្រក់ ហើយទាញទម្លាក់បុគ្គលនោះទៅក្នុងឋានអបាយបន្ទាប់ពីស្លាប់ទៅ។ យោងតាមពុទ្ធដីកាថា ការកំចាត់បង់នូវសកាយទិដ្ឋិជារឿងសំខាន់បំផុត និងត្រូវធ្វើជាបន្ទាន់បំផុតផងដែរ។ ដូច្នេះ ដើម្បីយល់បាននូវលក្ខណៈពិតរបស់អារម្មណ៍ និងសាមញ្ញលក្ខណៈ៣ នៃបរមត្ថធម៌ ដែលជាចង្កោមមូលដ្ឋានគ្រឹះនៃសត្វមានជីវិតទាំងអស់នោះ គឺសំខាន់ណាស់។

តាមពិតទៅ វាជារឿងសំខាន់បំផុត ដើម្បីដឹងឱ្យច្បាស់នូវលក្ខណៈ និងឥទ្ធិពលនានារបស់ចិត្ត ដែលជាថាមពលអស្ចារ្យបំផុត ដែលមនុស្សបានដឹង។ យើងអាចមើលឃើញចិត្តរៀបចំនូវជោគវាសនារបស់បុគ្គលម្នាក់ៗ ហើយយើងអាចសិក្សាតាមហេតុផលនៃធម៌របស់ព្រះសម្មាសម្ពុទ្ធថា ចិត្តហ្នឹងឯង ជាអ្នកតាក់





តែងអនាគតភពរបស់បុគ្គលម្នាក់ៗ បន្ទាប់ពីស្លាប់ទៅ តាមរយៈថាមពលរបស់ចិត្ត ដែលមានអំណាចហៅថា "**កម្ម**" ដែលនឹងត្រូវពន្យល់នៅក្នុងជំពូកបន្ទាប់ពីនេះ។

តាមពិតទៅ ចិត្ត គឺជាអ្នកបង្កើតលោកពិត។ វាជាប្រការមួយសំខាន់ណាស់ ដើម្បីសិក្សាពីរបៀប ដែលចិត្តបង្កើតសព្វសត្វទាំងអស់នៅក្នុងលោក និងក្នុងភពទាំង៣១ជាន់ តាមរយៈ "**កម្ម**" ។ វាសំខាន់ស្មើគ្នានឹងការដឹងថា រាល់ព្រះធម៌របស់ព្រះសម្មាសម្ពុទ្ធទាំងអស់ អាចត្រូវបានគេធ្វើឱ្យជាក់ច្បាស់ដោយចំណេះដឹង ឬបញ្ញារបស់ខ្លួនផ្ទាល់ ដែលមានលក្ខណៈច្បាស់ជាងឧបករណ៍វិទ្យាសាស្ត្រទៅទៀត។

*ប្រសិនបើបុគ្គលអាចគ្រប់គ្រងនូវរបស់ម្យ៉ាងបាន នោះបានដល់ចិត្ត មិនឱ្យធ្វើនូវអំពើអាក្រក់គ្រប់យ៉ាង ហើយឱ្យធ្វើនូវអំពើល្អ ពេលនោះបុគ្គលអាចសម្រេចបាននូវសេចក្តីសុខរបស់មនុស្ស សេចក្តីសុខនៃទេវតា និងសុខក្នុងព្រះនិព្វានផងដែរ។*

៦

# កម្មជាអ្វី

## ១. តើអ្វីជាកម្ម?

**កម្ម** ជាពាក្យបាលី មានន័យថា "**អំពើ**" ឬ "**ការធ្វើ**"។ កម្ម ជាពាក្យសំស្ក្រឹតសរសេរថា "**កម៌**"។

មានតែអំពើប្រកបដោយចេតនាមួយប៉ុណ្ណោះ ដែលយើងហៅថា "កម្ម"។ អំពើមិនប្រកបដោយចេតនា ឬបំណង មិនហៅថាកម្មទេ។ ហេតុផលគឺថា ចេតនាជាអ្នកបំពេញសកម្មភាព ឬ អំពើណាមួយ។

ជាតួយ៉ាង ប្រសិនបើយើងមិនមានបំណងជាន់លើស្រមោចទេ ហើយពួកវាងាប់ ប្រការនេះមិនបណ្តាលឱ្យកម្មកើតឡើងទេ។ ប្រសិនបើ យើងមានបំណងជាន់លើស្រមោច ដើម្បីសម្លាប់ពួកវា ហើយពួកវាងាប់ អកុសលកម្មកើតឡើង។

ដូច្នេះ យើងគប្បីចាត់ទុក កម្ម ថាជាអំពើ ឬការធ្វើប្រកប





ដោយចេតនា។

កម្មមិនមែនជា "វាសនា" ដែលថ្លែងបញ្ញិតបញ្ចៀងថា អ្វីមួយ កើតឡើងដោយមិនមានហេតុទេ។ កម្មហ្នឹងឯងជាហេតុ ហើយវានឹងបង្កើតឱ្យមានផលសមស្របរបស់វា។

គ្មានអ្វីមួយកើតឡើងដោយគ្មានហេតុនោះទេ ពោលគឺ មនុស្សមានសំណាង ឬមិនបានអាស្រ័យផលនៃកម្ម(អំពើប្រកបដោយចេតនា) ដែលគេបានធ្វើពីមុន នៅក្នុងបច្ចុប្បន្នជាតិ ឬ អតីតជាតិនោះទេ។

មានតែនៅពេលដែលគេយល់ទ្រឹស្តី "កម្ម" និងផលរបស់កម្មត្រឹមត្រូវ ទើបគេមានការយល់ត្រូវ និងការត្រិះរិះត្រូវ(សម្មាទិដ្ឋិ និង សម្មាសង្កប្បៈ)។ ការយល់ត្រូវ គឺ "**សម្មាទិដ្ឋិ**"។ ការយល់ត្រូវនាំឱ្យមានការត្រិះរិះត្រូវ ការនិយាយត្រូវ ការងារត្រូវ ការចិញ្ចឹមជីវិតត្រូវ និងសីលធម៌ល្អ។

ការមិនផ្តោតអារម្មណ៍ទៅលើ " កម្ម " និងផលរបស់កម្ម ការមិនយល់ និងការមិនអើពើ នឹងនាំទៅរកការយល់ខុស(មិច្ឆាទិដ្ឋិ )។ ការយល់ខុស ហៅថា "**មិច្ឆាទិដ្ឋិ**"។ ការយល់ខុស នាំឱ្យមានការត្រិះរិះខុស ការនិយាយខុស ការងារខុស ការចិញ្ចឹមជីវិតខុស និង អត្តចរិតមិនល្អ។

ហេតុដូច្នេះ បុគ្គលអ្នកយល់ពី 'កម្ម និង ផលរបស់កម្ម' និងអ្នកមិនយល់ គឺខុសគ្នាទាំងស្រុង ដូចមេឃ និងដី។

ការយល់ត្រូវ (សម្មាទិដ្ឋិ) ញ៉ាំងកុសលកម្ម ដែលមិនទាន់កើតឡើងឱ្យកើតឡើងបាន កុសលកម្ម ដែលកើតឡើងហើយ ឱ្យចម្រើនឡើងជាភិយ្យោភាព និងជាបច្ច័យនាំឱ្យមានបដិសន្ធិ នៅក្នុងសុគតិភពបន្ទាប់ពីស្លាប់។ សម្មាទិដ្ឋិ មិនមានអ្វីស្មើ ក្នុងការតាក់តែងបដិសន្ធិ នៅក្នុងសុគតិភព (ឋានសួគ៌)។

ការយល់ខុស (មិច្ឆាទិដ្ឋិ)ញ៉ាំងអកុសលកម្ម ដែលមិនទាន់កើតឡើងឱ្យកើតឡើង អកុសលកម្មដែលកើតឡើងហើយ ឱ្យរឹងរឹតតែចម្រើនឡើង និងជាបច្ច័យនាំឱ្យមានបដិសន្ធិនៅក្នុង ទុគ្គតិភពបន្ទាប់ពីស្លាប់។ មិច្ឆាទិដ្ឋិ មិនមានអ្វីស្មើក្នុងការតាក់តែងបដិសន្ធិ នៅក្នុងទុគ្គតិភព (នរក ប្រេត និងតិរច្ឆាន)។

*ទ្រឹស្តីកម្ម និងផលរបស់កម្ម គឺជាទ្រឹស្តីសំខាន់មួយ នៅក្នុងព្រះពុទ្ធសាសនា។ បុគ្គលនឹងក្លាយជាពុទ្ធសាសនិកពិតប្រាកដ គឺនៅពេលដែលបុគ្គលនោះយល់ពី កម្ម និងផលរបស់កម្ម ជឿទៅលើកម្ម និងផលរបស់វា និងមាន សម្មាទិដ្ឋិ (ការយល់ត្រូវ)។*





*បុគ្គលគប្បីយល់ពីកម្មកើតឡើងរបៀបណា ហើយវាប្រព្រឹត្តទៅបែបណា ធ្វើបែបនេះ បុគ្គលនឹងមានសេចក្តីខ្មាសបាប និងសេចក្តីខ្លាចបាប មិនប្រព្រឹត្តអំពើអកុសល និង មានឆន្ទៈ និងសេចក្តីរីករាយពេញចិត្តធ្វើអំពើជា កុសលទាំងឡាយ។ពេលនោះបុគ្គលនឹងក្លាយជាបុគ្គលត្រង់ (ត្រង់កាយ ត្រង់ចិត្ត)មានអត្តចរិតល្អ និងអាចបង្កើតជោគវាសនាល្អ និង គតិល្អ (ទីដែលត្រូវបដិសន្ធិ) សម្រាប់ខ្លួនឯង។*

## ២. តើកម្មកើតឡើងដោយរបៀបណា?

**កម្មដែលត្រូវធ្វើឡើង មាន ៣ យ៉ាង៖**

(១) កម្មដែលធ្វើឡើង ដោយកាយ ហៅថា កាយកម្ម

(២) កម្មដែលធ្វើឡើង ដោយវាចា ហៅថា វចីកម្ម

(៣) កម្មដែលធ្វើឡើង ដោយចិត្ត ហៅថា មនោកម្ម

កាយ ក្បាល ដៃ ជើង និងបបូរមាត់ មិនអាចកម្រើកឡើងបានដោយខ្លួនឯងផ្ទាល់ទេ ពួកវាកម្រើកបានដោយសារចិត្ត តាមរយៈចិត្តជរូប រូបបង្កើតឡើងដោយចិត្ត។ ដូច្នេះ ចិត្តទេដែលជាអ្នកធ្វើនូវកម្មទាំងបីពិតប្រាកដពោលគឺ ធ្វើនូវកាយកម្ម វចីកម្ម និងមនោកម្ម។

តើកម្មកើតចេញពីចិត្ត ដោយរបៀបណា?

ចិត្ត គឺជាការរួមបញ្ចូលគ្នានៃ ចិត្ត និងចេតសិក។ ទោះបី ចិត្តជាប្រធានក្រុមក៏ដោយ ក៏វាត្រឹមតែការដឹងនូវរូបារម្មណ៍។ វាគឺ ចេតសិក ទេ ដែលមានឥទ្ធិពលធ្វើឱ្យចិត្តប្រព្រឹត្តនូវកម្មជា កុសល និងកម្មជា អកុសល។

ចេតសិក ធំៗបី ដែលមានឥទ្ធិពលធ្វើឱ្យចិត្តប្រព្រឹត្តនូវ អកុសល គឺ លោភៈ ទោសៈ និង មោហៈ។ ពួកវាជាអកុសលមូល ពោលគឺ ពួកវា ជាហេតុបច្ច័យនៃអកុសលកម្ម។

លោភៈ មានតណ្ហា ឬឧបាទានជាលក្ខណៈ។ វានឹងមិន បោះបង់ចោលលក្ខណៈនេះទេ។ បន្ទាប់ពីទទួលបានអ្វីមួយ ដែល វាកាន់យកហើយ វានឹងកាន់យករបស់មួយផ្សេងទៀត។ បុគ្គល ទទួលបានរបស់កាន់តែច្រើន វានឹងកាន់យករបស់ផ្សេងទៀតកាន់ តែច្រើន។ ទ្រព្យទាំងអស់នៅលើផែនដីមិនអាចបំពេញសេចក្ដីចង់ បានរបស់លោភៈបានទេ។ ដោយសារតែបុគ្គលចង់បានទ្រព្យអ្នក ដទៃ បុគ្គលអាចប្រព្រឹត្តការនិយាយកុហក លួចទ្រព្យគេ បោក ប្រាស ប្លន់ទ្រព្យសម្បត្តិ និងថែមទាំងសម្លាប់ជីវិតអ្នកដទៃ ទៀត ផង។ ចំពោះធម្មជាតិនៃការកាន់យកកាមគុណរបស់លោភៈ មិន ចេះចប់មិនចេះហើយ គ្មានដែនកំណត់គេហៅថា **តណ្ហា**។ ហើយ ដោយសារវាធ្វើចិត្តមិនបរិសុទ្ធ និងដុតបំផ្លាញចិត្ត ដោយការប្រាថ្នា





ចង់បានអារម្មណ៍ និងការជាប់ចិត្តចំពោះអារម្មណ៍ទាំងនោះ គេ ហៅវាថា **រាគៈ**។ នៅពេលដែល **រាគៈ** គ្របដណ្ដប់ចិត្តដូចបិសាច វាជំរុញឱ្យចិត្តហ៊ានប្រព្រឹត្តការចាប់រំលោភ ការផិតក្បត់ និងឃាត កម្ម។

វាជាប្រការគួរឱ្យភ្ញាក់ផ្អើល ដែលថាលោភៈអាចមាន ឥទ្ធិពលទៅលើចិត្តយ៉ាងល្អិតបំផុត ញ៉ាំងចិត្តឱ្យប្រព្រឹត្តអំពើ ទាំងឡាយ ដើម្បីបំពេញបំណងសេចក្ដីប្រាថ្នារបស់វា។ ព្រះគុណ ម្ចាស់ តោង ម្យ សយាដ័រ(Taung Myo Sayaday) ដ៏ល្បី ឈ្មោះ សរសេរថា " *ពិភពលោក ដែលជាឋានរបស់មនុស្សលោក គឺត្រូវ គ្រប់គ្រងដោយលោភៈ* "។

ទោសៈ មានការស្អប់ កាច គំនុំគុំកួន ឬកំហឹងជាលក្ខណៈ។ បើតាមពាក្យប្រៀនប្រដៅរបស់ព្រះសម្មាសម្ពុទ្ធ **លោភៈ** អាចបំផ្លិច បំផ្លាញពិភពលោកឱ្យអន្តរាយខ្លាំងបំផុត។ **ទោសៈ** ដែលប៉ោង ឡើងខ្លាំងធ្វើឱ្យមនុស្សខឹង ខឹងខ្លាំង កាច និង ឃោរឃៅ។ វាមាន ឥទ្ធិពលធ្វើឱ្យចិត្តស្អប់ ធ្វើឱ្យគ្រោះថ្នាក់ ធ្វើទារុណកម្ម ឬសម្លាប់អ្នក ដទៃ។ មនុស្សអាចសម្លាប់សូម្បីតែចៅហ្វាយ ឬអ្នកមានគុណយ៉ាង សាហាវឃោរឃៅ ដោយសារគេខឹងជាមួយចៅហ្វាយ ឬដោយសារ គេចង់បានលុយរបស់ចៅហ្វាយ។

**ទោសៈ** ដែលសៅហ្មងក្នុងចិត្តបណ្ដាលឱ្យមានការក្រៀមក្រំចិត្ត ទុក្ខព្រួយ តូចចិត្ត ចង្អៀតចង្អល់ចិត្ត ខកចិត្ត ព្រួយចិត្ត អស់សង្ឃឹម ។ល។ ឱ្យកើតឡើង។ ភាពតានតឹងផ្លូវចិត្ត ដែលបណ្ដាលមកពីភាពតានតឹង និងតឹងតែង (ខំប្រឹងហួសពីសមត្ថភាព)ក៏ជាលទ្ធផលនៃទោសៈដែរ ហើយវាអាចបណ្ដាលឱ្យមានជម្ងឺផ្សេងៗ។ ពេលណាក៏ដោយ ទោសៈដែលកើតឡើងក្នុងចិត្ត វាកើតរួមជាមួយសេចក្ដីទុក្ខផ្លូវចិត្ត។

**មោហៈ** បញ្ឆោត និងធ្វើឱ្យចិត្តងងឹត ដូច្នេះ វាមិនអាចធ្វើឱ្យខុសគ្នា រវាងត្រូវ និងខុស ល្អ និងអាក្រក់បានទេ។ វាធ្វើឱ្យសត្វលោកមិនដឹងពីធម្មជាតិពិតនៃអារម្មណ៍។ យើងមិនដឹងថា សត្វលោក និង វត្ថុ គ្មានជីវិតទាំងអស់មាន នាម និងរូប ដែលកើតនិងរលត់យ៉ាងលឿន និង យ៉ាងសកម្មបំផុត។ ដូច្នេះ វាមានសាមញ្ញលក្ខណៈ ៣ គឺមិនទៀង(អនិច្ចៈ) ជាទុក្ខ(ទុក្ខៈ)និងមិនមែនជារបស់ខ្លួន (អនត្តា)។

**នាម** និង**រូប** ក៏មានលក្ខណៈជាអសុភផងដែរ។ ដោយសារយើងមានអវិជ្ជាបិទបាំង យើងអាចគិតថា អ្នកនេះស្រស់ស្អាតសង្ហារ និងគួរឱ្យទាក់ទាញ។ ព្រះពុទ្ធទ្រង់ទូន្មានឱ្យមើលបុគ្គលប្រកបដោយការវិភាគពេលគឺត្រូវបែងចែកបុគ្គលនោះទៅជាសក់





រោម ក្រចក ធ្មេញ ស្បែក សាច់ សរសៃ ឈាម ឆ្អឹង ពោះវៀនតូច ពោះវៀនធំ អាហារចាស់ អាហារថ្មីជាដើម និងពិនិត្យពិចារណាផ្នែកនីមួយៗយ៉ាងល្អិតសុខុម។ គ្រប់ផ្នែកនៃកាយគឺមិនស្អាត និងគួរឱ្យខ្ពើម។

នៅពេលអវិជ្ជាបិទបាំង យើងមិនដឹងពីធម្មជាតិពិតនៃអារម្មណ៍ យើងគិតថាអារម្មណ៍ គឺទៀង(និច្ចៈ) ជាសុខ(សុខៈ) ជារបស់ខ្លួន(អត្តា) និងស្រស់ស្អាត(សុភៈ)។ ហេតុដូច្នេះ យើងប្រាថ្នាចង់បានកាមគុណទាំងនេះដោយលោភៈ។ យើងក៏ចម្រើនការយល់ខុស ដោយគិតថា "អាត្មាអញ" ពិតជាមាន។ ជាវិបាកយើងក្លាយជាមនុស្សអាត្មានិយម គិតតែពីខ្លួនឯង មានការគិតនិងអាណិតអាសូរអ្នកដទៃតិចតួច។

**លោភៈ ទោសៈ** និង **មោហៈ** គឺជាកិលេសគួរឱ្យខ្លាចបំផុតដែលធ្វើឱ្យចិត្តមិនបរិសុទ្ធ បន្ទាប់នឹងដុតបំផ្លាញចិត្ត។ វាជាហេតុបច្ច័យនៃអំពើអាក្រក់ មិនយុត្តិធម៌ និងឃោរឃៅ នៅលើពិភពលោក។ វាក៏ជាហេតុសំខាន់នៃសេចក្ដីទុក្ខផងដែរ។ យើងគួររីករាយបំផុត បើយើងអាចកម្ចាត់វាចេញពីក្នុងចិត្តបាន។

វិធីបដិបត្តិ ដើម្បីលុបបំបាត់ចោលអកុសលមូលមិនឱ្យកើត

ឡើងគឺត្រូវចម្រើនអង្គបដិបក្ខគឺ កុសលមូល។ កុសលមូល មាន **អលោភៈ អទោសៈ** និង **អមោហៈ** (បញ្ញា)។

**អលោភៈ** គឺជាគូបដិបក្ខនឹងលោភៈ។ វាមានការមិនជាប់នៅក្នុង តណ្ហា ឬ ឧបាទានជាលក្ខណៈ។ វាមិនប្រាថ្នាចង់បានទ្រព្យសម្បត្តិអ្នកដទៃ ហើយវាក៏មិនស្អិតជាប់នៅក្នុងទ្រព្យសម្បត្តិនោះដែរ។ បុគ្គលអាចលះបង់លុយកាក់ ឬទ្រព្យសម្បត្តិរបស់ខ្លួនក្នុងការបរិច្ចាគទាន។ បុគ្គលអាចលះបង់ប្រយោជន៍ផ្ទាល់ខ្លួន និងជួយអ្នកដទៃ។ បុគ្គលអាចលះបង់ដោយសប្បុរស នូវពេលវេលា និងប្រាក់កាស ដើម្បីជាសុខុមាលភាពដល់អ្នកដទៃ។ ការដាក់ទាន មានន័យថា លុបបំបាត់ចោល **លោភៈ** និងចម្រើន **អលោភៈ** ដែលជាគុណភាពដ៏ល្អ និងវិជ្ជមានរបស់មនុស្សលោក។

**អទោសៈ** គឺជាគូបដិបក្ខនឹងទោសៈ។ លក្ខណៈរបស់វាគឺមិនកាច ឱនលំទោន មិនស្អប់ ស្រឡាញ់ មិនឃោរឃៅ អត់ឱនទោស និង មេត្តា។ វាធ្វើឱ្យបុគ្គលមិនខឹងក្រេវក្រោធ សូម្បីនៅពេលដែលអ្នកដទៃស្តីបន្ទោស ឬធ្វើឱ្យរងរបួស និងត្រៀមខ្លួនអត់ឱនទោសដល់អ្នកដទៃ ដែលបានធ្វើខុស។ ការអត់ឱនទោសគឺជាលក្ខណៈដ៏ល្អ និងវិជ្ជមាន ដូចសុភាសិតមួយចែងថា "ការអត់ឱនទោសគឺជាព្រះ"។ មេត្តា ក៏ជាគុណធម៌ដ៏ល្អ និងវិជ្ជមាន ដោយ





ប្រាថ្នាឱ្យសព្វសត្វទាំងអស់មានសេចក្តីសុខ និង រួចផុតពីភ័យ។ វាពិតជាធ្វើឱ្យបុគ្គលស្អាត។ ដើម្បីចម្រើន អទោសៈ ឬ មេត្តា យើងត្រូវសមាទានសីល និងចម្រើនផ្សព្វផ្សាយមេត្តាធម៌។

**ប្រាជ្ញាញាណ(** អមោហៈ ឬបញ្ញា) គឺជាគូបដិបក្ខផ្ទាល់នឹងអវិជ្ជា (**មោហៈ**)។ វាអាចចែកដាច់រវាងត្រូវ និងខុស ល្អនិងអាក្រក់។ វាយល់យ៉ាងច្បាស់ពីធម្មជាតិពិតនៃអារម្មណ៍ ពោលគឺមិនទៀងជាទុក្ខ មិនមែនជារបស់ខ្លួន និងមិនស្អាត។ វាអាចកម្ចាត់ភាពងងឹត ឬការបិទបាំង ដែលបង្កដោយអវិជ្ជា។ ដូច្នេះលោកហៅវាថា **វិជ្ជា** (បញ្ញា) រីឯ មោហៈ ថា **អវិជ្ជា**។

បញ្ញាគឺជាថាមពលផ្លូវចិត្តដ៏មានឥទ្ធិពលបំផុត។ ដើម្បីចម្រើនបញ្ញា យើងត្រូវទទួលបានចំណេះដឹងផ្លូវលោក ក៏ដូចជាចំណេះដឹងលោកុត្តរ ដោយការស្តាប់ព្រះធម៌ សិក្សាព្រះធម៌ ធម្មសាកច្ឆាជាមួយពហូសូត្រ និងបដិបត្តិសមាធិ។ នៅពេលយើងអាចចម្រើនបញ្ញាថ្នាក់ខ្ពស់បំផុត ហៅថា មគ្គបញ្ញា៤ ដោយវិបស្សនាកម្មដ្ឋាន យើងអាចកម្ចាត់បង់កិលេសទាំងអស់ចេញពីចិត្តរបស់យើង និងអាចរីករាយនឹងបរមសុខនៅក្នុងព្រះនិព្វានយ៉ាងពិតប្រាកដ។

ដូច្នេះ ចេតសិកទាំងឡាយមានឥទ្ធិពលខ្លាំងណាស់។ វា

អាចគ្របដណ្ដប់ចិត្តយ៉ាងល្អិត ឱ្យប្រព្រឹត្តនូវអំពើផ្សេងៗ។ អកុសល និងអកុសលចេតសិក បន្ទាបចិត្ត និងគ្រប់គ្រងចិត្តឱ្យកំណាច និងហ៊ានប្រព្រឹត្តអំពើអាក្រក់គ្រប់បែបយ៉ាង។ រីឯកុសល និងសោភណចេតសិក ផ្ដល់ឱ្យចិត្តនូវសេចក្ដីថ្លៃថ្នូរ និងគ្របដណ្ដប់ចិត្ត ឱ្យប្រព្រឹត្តនូវអំពើល្អផ្សេងៗ។

## តើកម្មកើតចេញពីចិត្តដោយរបៀបណា?

ឧបមាថា មូសខាំថ្ពាសរបស់អ្នក។ ចិត្តដឹងថាវាឈឺ ដូច្នេះ ទោសៈ កើតឡើង។ ពេលណាក៏ដោយ **ទោសៈ** និង**លោភៈ** កើតឡើង **មោហៈ**ក៏កើតឡើងដែរ។ **មោហៈ** ប្រកាន់ថា អាត្មាអញ និងមូស ពិតជាមាន និងថា មូសខាំអាត្មាអញឱ្យឈឺចាប់។ ដូច្នេះ ទោសមូលចិត្ត ឬអកុលសចិត្តក៏កើតឡើង។ អ្នកទៅជាខឹង ហើយ **ទោសៈ** គ្របដណ្ដប់ចិត្តឱ្យសម្លាប់មូស។ ទោសៈធ្វើ សហជាតិធម៌ទាំងឡាយ(ចិត្ត និង ចេតសិក)ទៅជាកាច និងឃោរឃៅ ប៉ុន្តែវាមិនអាចប្រព្រឹត្តការសម្លាប់បានទេ។ វាគឺចេតនាឯណោះទេ ដែលប្រព្រឹត្តការសម្លាប់។

ចេតនាជា **អញ្ញសមានាចេតសិក** ដែលកើតរួមជាមួយចិត្តទាំងអស់។ វាក្លាយជាអកុសល ដោយសារឥទ្ធិពលនៃទោសៈ។ ដើម្បីបំពេញសេចក្ដីត្រូវការរបស់ទោសៈ ចេតនាបានកំណត់បំណង





ដើម្បីសម្លាប់មូស។ វាដើរតួ និងនាំឱ្យសហជាតិធម៌ទាំងឡាយបំពេញនូវកិច្ចរៀងៗខ្លួន ដើម្បីប្រព្រឹត្តការសម្លាប់។ ជាវិបាកចិត្តបង្កើតរូបក្ខន្ធ ដែលធ្វើឱ្យដៃកម្រើក ទៅវាយមូស។ មូសក៏ងាប់។

## នរណាជាអ្នកសម្លាប់មូស?

ដោយសារដៃវាយមូស តើដៃជាអ្នកសម្លាប់មូសឬ? ដៃនិយាយថា "ខ្ញុំគ្រាន់តែជារូប។ ខ្ញុំមិនអាចកម្រើកដោយខ្លួនឯងទេ។ ចិត្តបានធ្វើឱ្យខ្ញុំកម្រើកទៅវាយមូស។ ខ្ញុំមិនដឹងនូវអ្វីដែលបាននឹងកំពុងធ្វើនោះទេ"។ ដូច្នេះ ដៃមិនមែនជាពិរុទ្ធជនពិតប្រាកដទេ។

អ៊ីចឹង តើចិត្តដែលបានធ្វើឱ្យដៃកម្រើកជាឃាតកឬ? ចិត្តក៏នឹងធ្វើសេចក្ដីជំទាស់ផងដែរ "ខ្ញុំគ្រាន់តែដឹងនូវអារម្មណ៍។ ខ្ញុំដឹងថា មូសខាំថ្ពាស ហើយវាឈឺ។ ខ្ញុំគ្មានបំណងសម្លាប់មូសទេ ។ ដោយសារចេតនានាំខ្ញុំឱ្យកម្រើកដៃ ខ្ញុំគ្រាន់តែបានកម្រើកដៃ"។ ដូច្នេះ យើងអាចឃើញថា ចិត្តគ្រាន់តែអ្នករួមដៃប៉ុណ្ណោះ មិនមែនជាឃាតកពិតប្រាកដទេ។

អ៊ីចឹង តើនរណាជាឃាតកពិតប្រាកដ? វាគឺចេតនាដោយសារវាកំណត់បំណងដើម្បីសម្លាប់មូស និងដើរតួ និងជាអ្នកនាំ

ចិត្ត និងចេតសិកផ្សេងទៀតឱ្យបំពេញកិច្ចរៀងៗខ្លួនដើម្បីប្រព្រឹត្តការសម្លាប់។

ដោយសារចេតនាមានទំនួលខុសត្រូវលើការរៀបចំសកម្មភាព និងបំពេញសកម្មភាព វាត្រូវបានបញ្ជាក់ភិនភាគ ជាមួយសកម្មភាព ហើយ ព្រះពុទ្ធទ្រង់ហៅថា កម្ម។

“ **ចេតនាហំ ភិក្ខវេ កម្មំ វទាមិ** ”

ម្នាលភិក្ខុទាំងឡាយ តថាគតហៅចេតនាថាជា កម្ម។

“**ចេតយិត្វា កម្មំ ករោតិ កាយេន វាចាយ មនសា**”

មានចេតនាជាអ្នកនាំបុគ្គលធ្វើកម្មតាមរយៈ កាយ វាចា ឬ ចិត្ត។

**៣.ការប្រៀបធៀបរឿងស្តេចដំរីឆទ្ទន្ត**

ពេលណាក៏ដោយ ខ្ញុំផ្តល់បាឋកថា ស្តីពីកម្មដែលជាអ្នកបង្កើតលោកពិត ខ្ញុំធ្លាប់បានលើករឿងស្តេចដំរី ឆទ្ទន្ត មកបញ្ជាក់ជាឧទាហរណ៍។

ស្តេចដំរី ឆទ្ទន្ត ជាព្រះបរមពោធិសត្វនៃព្រះពុទ្ធគោតម។ ព្រះអង្គគង់នៅវាលទំនាបធំទូលាយព័ទ្ធជុំវិញដោយជួរភ្នំហិមពាន្ត។ ដំរីឆទ្ទន្ត មានមហេសីពីរអង្គឈ្មោះមហាសុភទ្ទា និងចូឡសុភទ្ទា ព្រមទាំងបរិវារប្រាំពីរពាន់សុទ្ធតែជាដំរីស។ នៅរដូវដើមសាលព្រឹក្ស





(sal trees) មានផ្ការីកស្គុះស្គាយ ដំរី ឆទ្ទន្ត បាននាំមហេសីទាំងពីរនៅក្រោមដើមសាលព្រឹក្ស ហើយបានយកប្រមោយ ចាប់កាន់មែកឈើ ដើម្បីអង្រួនឱ្យផ្កាឈើធ្លាក់មកលើខ្នង។

ផ្កាឈើបានធ្លាក់មកលើខ្នងរបស់ មហាសុភទ្ទា ប៉ុន្តែ ស្រមោចមួយជុំបានធ្លាក់មកលើខ្នងរបស់ចូឡសុភទ្ទា។ ចូឡសុភទ្ទា ធ្វើទុកក្នុងចិត្តជាឧបាយថា " ស្តេចដំរីស្រឡាញ់អគ្គមហេសីច្រើនជាងខ្លួន។ ព្រះអង្គបានអង្រួនផ្កាឈើដាក់លើខ្នងអគ្គមហេសី ប៉ុន្តែ ព្រះអង្គបានអង្រួនស្រមោចភ្លើងដាក់លើខ្នងរបស់ខ្លួន។ ព្រះអង្គមិនស្រឡាញ់ខ្ញុំ យ៉ាងពិតប្រាកដទេ។ ព្រះអង្គស្អប់ និងធ្វើឱ្យខ្លួនមានសេចក្តីអាម៉ាស់។ ហេតុអ្វីអាត្មាអញត្រូវស្រឡាញ់ព្រះអង្គ? អាត្មាអញស្អប់ព្រះអង្គ ហើយនឹងធ្វើឱ្យព្រះអង្គខូចចិត្ត។"

ការធ្វើទុកក្នុងចិត្តខុសអាចមានគ្រោះថ្នាក់ខ្លាំងក្លាណាស់។ វាអាចធ្វើឱ្យអ្នកដែលខ្លួនស្រឡាញ់ក្លាយទៅជាសត្រូវមួយរំពេច។ សេចក្តីស្រឡាញ់ ដែលកើតចេញពីការប្រកាន់មាំ ដោយ លោភៈ អាចប្រែក្លាយទៅជាសេចក្តីស្អប់យ៉ាងងាយស្រួល ដោយគ្រាន់តែមានព្រឹត្តិការណ៍មិនពេញចិត្តបន្តិចបន្តួច។ មានសុភាសិតជាភាសាភូមាថា "សេចក្តីស្រឡាញ់ធំធេងអាចផ្ទុះទៅជាសេចក្តីស្អប់ក៏ធំដែរ។"

នៅពេលសេចក្ដីស្អប់កើតឡើង ទោសមូលចិត្ត ក៏កើតឡើងព្រមដោយអវិជ្ជា (មោហៈ)។ អវិជ្ជាធ្វើឱ្យចិត្តងងឹត ដូច្នេះបុគ្គលមិនអាចធ្វើទុកក្នុងចិត្តដោយប្រាជ្ញាបានទេ។ ដោយមានបំណងសម្លាប់ស្ដេចដំរី ចូឡសុភទ្ទា បានបេះផ្កាឈើសាលព្រឹក្សប្រគេនព្រះបច្ចេកពុទ្ធ បានប្រាថ្នាថា "ដោយបុណ្យដែលបានធ្វើសូមឱ្យខ្ញុំកើតជាស្ត្រីមានសម្រស់ស្រស់ស្អាត នៅជាតិក្រោយ។ សូមឱ្យខ្ញុំក្លាយជាអគ្គមហេសីនៃព្រះរាជា និងសូមឱ្យខ្ញុំមានទំហូរពាក់ដែលធ្វើពីភ្លុកនៃស្ដេចដំរី ឆទ្ទន្ត។"

ដោយសារសេចក្ដីស្អប់ចំពោះស្វាមីរបស់នាង ចូឡសុភទ្ទាលែងរីករាយតទៅទៀត។ នាងចង់ស្លាប់ឆាប់ៗ ដើម្បីបានកើតជាមហេសី ព្រះរាជា និងដើម្បីសម្លាប់ស្ដេចដំរី។ នាងមិនអាចដេកលក់ និងមិនអាចបរិភោគអាហារ។ មិនយូរប៉ុន្មាននាងក៏ស្លាប់។ នាងបានកើតជាស្ត្រីស្រស់ស្អាត។ នៅពេលពេញវ័យព្រះរាជាក្រុងពារាណសីបានឃើញនាង ហើយបានរៀបអភិសេកនាងជា អគ្គ-មហេសី។

ព្រះនាងអាចចាំជាតិ ហើយភ្លើងកំហឹង ដែលចង់សម្លាប់





ស្ដេចដំរី ឆទ្ទន្ត កំពុងដុតកម្ដៅព្រះនាង។ ដូច្នេះ មានគម្រោងសម្លាប់ស្ដេចដំរី ឆទ្ទន្ត ព្រះនាងបានផ្ទុំនៅលើក្រឡាព្រះបន្ទំមិនសោយព្រះក្រយា។

ដោយសារ ព្រះរាជាក្រុងពារាណសី មានសេចក្ដីស្នេហាចំពោះព្រះអគ្គមហេសីថ្មីវ័យក្មេង និង មានរូបឆោមស្រស់ស្អាតអស់ពីព្រះរាជហឫទ័យ ព្រះអង្គបារម្ភពីស្ថានភាពរបស់ព្រះនាងខ្លាំងណាស់។ ដូច្នេះ ព្រះអង្គបានសួរព្រះនាងថា "មហេសីជាទីស្រឡាញ់ តើអូនចង់បានអ្វីប្រាប់បងមក ទោះអ្វីក៏ដោយ នៅក្រោមព្រះអាទិត្យ ដែលអូនចង់បាន បងនឹងយកមកឱ្យអូន។"

ដោយបានទទួលពាក្យសន្យាពីព្រះរាជា មហេសីនិយាយថា "ទូលបង្គំចង់ពាក់ទំហូរធ្វើពីភ្លុកស្ដេចដំរីស ឆទ្ទន្ត ដែលមានលំនៅនៅព្រៃហេមពាន្ត។ បើទូលបង្គំមិនអាចពាក់ទំហូរនោះទេទូលបង្គំពិតជាក្ស័យព្រះជន្ម"។

ព្រះរាជាបានកោះហៅព្រានល្បីៗទាំងអស់ នៅក្នុងនគរព្រះអង្គ ហើយទ្រង់បានប្រគល់កាតព្វកិច្ចក្នុងការសម្លាប់ស្ដេចដំរី និង យកភ្លុកទៅឱ្យព្រានស្ទាត់ជំនាញ និង មានកម្លាំងខ្លាំងក្លាឈ្មោះ សោនុត្តរៈ។ ព្រះរាជអគ្គមហេសី បានប្រាប់ផ្លូវទៅកាន់ព្រៃជាទីអាស្រ័យនៅរបស់ស្ដេចដំរី ឆទ្ទន្ត។ ព្រះនាងក៏បានប្រទាន

ដល់ព្រាននូវចីវរមួយលៀង និងបានឱ្យដំបូន្មានព្រានពាក់ចីវរនៅពេលមានគ្រោះថ្នាក់ ព្រោះស្តេចដំរី ឆទ្ទន្ត គោរពអ្នកបួសខ្លាំងណាស់។

សោនុត្តរៈ ក៏បានធ្វើដំណើរទៅកាន់ព្រៃហេមពាន្ត ដូចដែលព្រះនាងបានប្រាប់។ នៅពេលព្រានបានទៅដល់ទីលំនៅរបស់ស្តេចដំរី ឆទ្ទន្ត ព្រានក៏បានសិក្សាពីចលនារបស់ស្តេចដំរី។ ស្តេចដំរីចុះមុជទឹកក្នុងស្រះជារៀងរាល់ថ្ងៃ និងឈរនៅក្រោមដើមពោធិ៍មួយ។ ព្រានបានជីករូងក្នុងដី និងធ្វើរន្ធមួយនៅកន្លែងដែលស្តេចដំរីតែងឈរ។ ដំណក់ទឹកបានស្រក់ពីខ្លួន ហើយផ្ចិតរបស់ស្តេចដំរីនៅចំពីលើរន្ធដែលព្រានបានធ្វើ។

ដោយមិនបង្អង់យូរ ព្រាន ក៏បានបាញ់ស្តេចដំរី ដោយសរមានពិស។ សរត្រូវចំផ្ចិតចូលទៅក្នុងខ្លួនស្តេចដំរី ដោយកម្លាំងយ៉ាងខ្លាំង។ ដោយសារមានការឈឺចុកចាប់យ៉ាងខ្លាំង ឆទ្ទន្ត បានស្រែកយ៉ាងខ្លាំង។ ព្រះរាជអគ្គមហេសី និងបរិវាររបស់ព្រះអង្គបានហោះមកតាមអាកាស ។

"សត្រូវបានបាញ់អាត្មាអញ។ ចូរទៅរកសត្រូវនោះ" ស្តេចដំរីបានមានព្រះរាជឱង្ការ។ ដំរីទាំងអស់បានហោះទៅរកសត្រូវនោះ។

នៅពេលនៅតែមួយអង្គឯង ឆទ្ទន្ត បានសញ្ជឹងគិតថា "សរ





ចូលតាមផ្ចិតរបស់អាត្មាអញ។ សត្រូវត្រូវតែនៅក្រោមអាត្មាអញ"។ ដូច្នេះ ព្រះអង្គបានកាយដីនៅក្រោមព្រះអង្គ។ នៅពេលឃើញព្រាន ស្តេចដំរីបានព្យាយាមទាញព្រានឡើងដោយប្រមោយ។

ព្រានបានគេច ហើយបានពាក់ចីវរនៅលើប្រមោយយ៉ាងរហ័ស ដោយបានឃើញចីវរ កំហឹងរបស់ ឆទ្ទន្ត បានរលាយបាត់អស់។ ព្រះអង្គបានលើកព្រានឡើងថ្នមៗ ហើយមានបន្ទូលថា "ម្នាលសម្លាញ់ ដ៏មានអាយុ យើងមិនមែនជាសត្រូវរបស់អ្នកទេ។ ហេតុអ្វីបានជាអ្នកបាញ់យើងយ៉ាងឃោរឃៅយ៉ាងនេះ?"

ព្រានបានឆ្លើយថា " បពិត្រព្រះអង្គ ព្រះរាជអគ្គមហេសីរបស់ព្រះរាជាក្រុងពារាណសី ចូឡសុភទ្ទា ព្រះនាងចង់បានភ្លុករបស់ព្រះអង្គយកទៅធ្វើជាព្រះទំហូរ។ ព្រះរាជាទ្រង់បង្គាប់ទូលបង្គំឱ្យសម្លាប់ព្រះអង្គ និងយកភ្លុករបស់ព្រះអង្គ។ ដើម្បីធ្វើតាមព្រះរាជបង្គាប់របស់ព្រះរាជា ទូលបង្គំត្រូវតែបាញ់ព្រះអង្គ ជាមួយសរមានពិស។ ដូច្នេះ បុគ្គលបីនាក់ចូលពាក់ព័ន្ធនៅក្នុងការបាញ់សម្លាប់នេះ។ ប្រសិនបើ ព្រះអង្គសម្លាប់ទូលបង្គំៗតែម្នាក់ឯងទេដែលត្រូវស្លាប់។ ប្រសិនបើព្រះអង្គទ្រង់អាណិតទូលបង្គំៗនឹងមានជីវិត"។

ឆទ្ទន្ត បានគិតឃើញពេលដែលព្រះអង្គបានគង់នៅរួមគ្នា

ជាមួយមហេសីទាំងពីរអង្គ។ ព្រះអង្គបានដឹងថា ចូឡសុភទ្ទា បានយល់ច្រឡំចំពោះសេចក្តីស្នេហារបស់ព្រះអង្គ ចំពោះព្រះនាង ហើយព្រះនាងបានចង់កំហឹងចំពោះព្រះអង្គ។ ព្រះនាងចង់សម្លាប់ ព្រះអង្គ និងយកភ្លុករបស់ព្រះអង្គធ្វើជាព្រះទំហូរ។

ឆទ្ទន្ត បានអនុញ្ញាតឱ្យព្រានកាត់យកភ្លុករបស់ព្រះអង្គ។ ព្រានបានប្រើកម្លាំងយ៉ាងខ្លាំង ដើម្បីកាត់ភ្លុកជាមួយរណារ។ ប៉ុន្តែភ្លុករឹងខ្លាំង ដែលព្រានមិនអាចធ្វើស្នាមពៀច(ស្នាមខូង)លើ ភ្លុកបាន។ ដូច្នេះ ឆទ្ទន្ត បានយករណារដោយប្រមោយរបស់ព្រះ អង្គ ហើយបានកាត់ភ្លុករបស់ព្រះអង្គ ដោយផ្ទាល់ព្រះអង្គឯង។ ព្រះអង្គបានឱ្យភ្លុកទៅព្រាន ហើយអនុញ្ញាតឱ្យព្រានចេញទៅ។

នៅពេលព្រាន បានថ្វាយភ្លុកចំពោះព្រះរាជាៗបានហុច ថ្វាយដល់ព្រះអគ្គមហេសីយ៉ាងរីករាយ។ ព្រះនាងបានដាក់ភ្លុក សរលោងលើព្រះឱរាព្រះនាង ហើយបានឱបរឹតដោយហត្ថាទាំង ទ្វេរបស់ព្រះនាង។ នៅពេលព្រះនាងបានឮរឿងរ៉ាវទាំងមូលពីព្រាន រ៉ាយរ៉ាប់ទូលថា ស្តេចដំរី ឆទ្ទន្ត ជាអ្នកកាត់ភ្លុកដោយព្រះអង្គផ្ទាល់ និងបានថ្វាយព្រះនាងដោយសុខចិត្ត ព្រះនាងបាននឹកឃើញកំហុស របស់ព្រះនាង។ ព្រះនាងបាននឹកឃើញកាលដែលព្រះនាងកំពុង សប្បាយរីករាយព្រះទ័យរួមជាមួយស្តេចដំរីឆទ្ទន្ត។





"អាត្មាអញខុស។ ស្តេចដំរី ឆទ្ទន្ត មិនបានស្អប់អាត្មាអញ ទេ។ ព្រះអង្គពិតជាស្រឡាញ់ខ្លួនខ្លាំងណាស់។ ព្រះអង្គថែមទាំង បានកាត់ភ្លុករបស់ព្រះអង្គ និងថ្វាយឱ្យខ្លួន។"

ដោយបានគិតហើយគិតទៀតថាស្តេចដំរី ឆទ្ទន្ត បានយក ព្រះទ័យ និងមានសេចក្តីស្នេហាចំពោះព្រះនាង ហើយព្រះនាង បានសម្លាប់ព្រះអង្គយ៉ាងឃោរឃៅ វិប្បដិសារីដ៏ធំធេងបានកើត មានចំពោះព្រះនាង ហើយភ្លើងនៃទោសៈ (កំហឹង) ដ៏ក្តៅបាន ឆេះរោលក្នុងកាយព្រះនាង រហូតដល់សោយទីវង្គត។

នៅក្នុងរឿងនេះ បុគ្គលបីនាក់បានជាប់ពាក់ព័ន្ធ នៅក្នុង ការសម្លាប់ស្តេចដំរីឆទ្ទន្ត។ តើនរណាជាឃាតក?

ព្រានបានបាញ់ដំរី ពីព្រោះព្រះរាជាទ្រង់បានបង្គាប់ឱ្យគាត់ ធ្វើដូច្នេះ។ ចំណែកឯព្រះរាជា ដែលត្រូវបង្គាប់ឱ្យព្រានធ្វើ ពីព្រោះ អគ្គមហេសីជាទីស្រឡាញ់របស់ព្រះអង្គ ជាអ្នកនាំព្រះអង្គឱ្យធ្វើ ដូច្នេះ។ ព្រានតំណាងដៃ ដែលបានសម្លាប់មូស ព្រះរាជាតំណាង ចិត្ត ដែលបានកម្រើកដៃឱ្យទៅសម្លាប់មូស រីឯអគ្គមហេសី តំណាងចេតនា ដែលបានកំណត់បំណងដើម្បីសម្លាប់មូស និង ជាអ្នកនាំចេតសិកដទៃទៀតឱ្យចូលរួមក្នុងការសម្លាប់។

ដោយសារព្រះរាជអគ្គមហេសីមានហេតុ ដែលនាំឱ្យមាន

ការសម្លាប់ស្តេចដំរី ឆទ្ទន្ត និងជាអ្នកនាំព្រះរាជា និងព្រានឱ្យសម្លាប់ ឆទ្ទន្ត ព្រះនាងគឺជាឃាតកដំបូង និងពិតប្រាកដជាពិរុទ្ធជនសំខាន់មួយ។ ដូចគ្នាដែរ នៅក្នុងការសម្លាប់មូស ចេតនាគឺជាឃាតកពិតប្រាកដ និងជាពិរុទ្ធជនចម្បងគេ។

## ៤. កម្មពីរយ៉ាង សហជាតកម្ម និងនានក្ខណិកកម្ម

សហជាតកម្ម ជាអ្នកធ្វើកម្ម ហើយកម្មនេះ នឹងនាំឱ្យមានផល ដែលសមនឹងឱ្យផលរបស់វា។

ក្នុងព្រះអដ្ឋកថាគម្ពីរអភិធម្មថា ចិត្តទាំងឡាយអាចកើត និង រលត់មួយហើយមួយទៀត ជាងមួយរយកោដិ ក្នុងមួយផ្ទាត់ម្រាមដៃ ឬមួយពព្រិចភ្នែក។ ដូច្នេះ ចិត្តច្រើនកោដិកើតរលត់ក្នុងពេលសម្លាប់មូស។ ចិត្តប្រហែលពាក់កណ្តាលគឺជាទោសមូលចិត្ត ឬអកុសលចិត្ត។

ចេតនា ដែលសម្បយុត្តជាមួយអកុសលចិត្តទាំងនេះ ជាអ្នកប្រព្រឹត្តការសម្លាប់។ ចេតនាទាំងនេះហៅថា **សហជាតកម្ម** **សហជាត** មានន័យថា "ដែលកើតឡើងជាមួយគ្នា" ពោលគឺចេតនា និងចិត្តកើតឡើងជាមួយគ្នា។

នាមធម៌ (ចិត្ត និងចេតសិក) រលត់ភ្លាមៗ បន្ទាប់ពីបានកើតឡើង។ ប៉ុន្តែ ចិត្ត និងចេតសិក ដែលបានកើតរលត់បាន





បន្សល់ទុកនូវសំណល់របស់វានៅក្នុងក្រសែចិត្ត (ភវង្គចិត្ត) មុននឹងវារលត់ទៅ។ សំណល់ទាំងនេះត្រូវបានបញ្ជូនពីចិត្តមួយទៅចិត្តមួយទៀត។ ដូច្នេះ សំណល់ទាំងនេះគឺនៅក្នុងក្រសែចិត្ត។

ថាមពលចិត្ត ឬថាមពលរបស់កម្ម ដែលនៅក្នុងក្រសែចិត្ត លោកឱ្យឈ្មោះថា **នានក្ខណិកកម្ម** មានន័យថា ពេលវាត្រូវបានបង្កើតឡើង និងពេលវាឱ្យផល គឺខុសគ្នា។

ដូច្នេះ កម្មពីរយ៉ាងនេះត្រូវបានបង្កើតឡើងនៅក្នុងគ្រប់អំពើប្រកបដោយចេតនាទាំងអស់។ កម្មទាំងពីរប្រភេទនេះ នឹងឱ្យផលសមស្របរបស់វា។ នានក្ខណិកកម្ម ប្រៀបដូចជាគ្រាប់ពូជ ដែលបានបន្សល់ទុកបន្ទាប់ពីផ្លែឈើទុំបានបែកជាដុំតូចៗ។ គ្រាប់ពូជអាចបង្កើតរុក្ខជាតិថ្មីបានយ៉ាងណា រីឯនានក្ខណិកកម្មក៏អាចឱ្យផលទៅភពថ្មីយ៉ាងដូច្នោះដែរ។

នៅក្នុងការសម្លាប់ត្រី មាន់ ឬមនុស្សម្នាក់ ទោសមូលចិត្តរាប់កោដិបានកើត និងរលត់ទៅវិញ។ ចេតនាសម្បយុត្តជាមួយចិត្តទាំងនេះហៅថា **សហជាតកម្ម** ។ នៅពេលចេតនាទាំងឡាយនេះបានរលត់ វាបានបន្សល់ទុកនូវថាមពលរបស់កម្មនៅក្នុងក្រសែចិត្ត។ ថាមពលកម្មរាប់កោដិ ទាំងនេះហៅថា **នានក្ខណិកកម្ម**។

ដូចគ្នានេះដែរ នៅក្នុងការលួច ឬការបោកប្រាស់ ឬការ

ប្លន់ទ្រព្យសម្បត្តិអ្នកដទៃ លោភមូលចិត្ត រាប់កោដិបានកើត និងរលត់ទៅវិញ។ ដូច្នេះ សហជាតកម្ម និងនានក្ខណិកកម្ម រាប់កោដិនឹងត្រូវបានបង្កើតឡើង។

ម្យ៉ាងទៀត នៅពេលបុគ្គលធ្វើកម្មជាកុសល ដូចជាការឱ្យទាន ឬការថ្វាយបង្គំព្រះពុទ្ធ ឬការធ្វើសមាធិភាវនា កុសលចិត្តរាប់កោដិកើតនិងរលត់ទៅវិញ។ ដូច្នេះ សហជាតកម្ម និងនានក្ខណិកកម្ម រាប់កោដិ ក៏នឹងត្រូវបានបង្កើតឡើងផងដែរ។

ចេតនា ដែលសម្បយុត្តជាមួយអកុសលចិត្ត (ចិត្ត និងចេតសិក) ដូចជា ទោសមូលចិត្ត ឬលោភមូលចិត្ត ហៅថា អកុសលសហជាតកម្ម ឬអកុសលកម្ម។ ថាមពលរបស់កម្ម ដែលបានបន្សល់ទុកនៅក្នុងក្រសែចិត្ត នៅពេលចេតនាទាំងនេះរលត់ហៅថា អកុសលនានក្ខណិកកម្ម ឬអកុសលកម្ម។

ដូចគ្នាដែរ ចេតនាដែលសម្បយុត្តជាមួយកាមាវចរកុសលចិត្ត(ចិត្ត និងចេតសិក)ហៅថា កាមាវចរកុសលសហជាតកម្ម ឬកាមាវចរកុសលកម្ម។ ថាមពលកម្មដែលបានបន្សល់ទុកនៅក្នុងក្រសែចិត្ត នៅពេលចេតនាទាំងនេះរលត់ហៅថា កាមាវចរកុសលនានក្ខណិកកម្ម ឬកាមាវចរកុសលកម្ម។

នៅក្នុង សមថភាវនា នៅពេលយោគីអាចចម្រើន ឈាន





រូបាវចរកុសលចិត្ត កើតឡើងរាប់កោដិ។ ចេតនា ដែលសម្បយុត្ត ជាមួយ រូបាវចរកុសលចិត្តទាំងនេះ ហៅថា រូបាវចរកុសលសហជាតកម្ម។ ថាមពលកម្ម ដែលបានបន្សល់ទុកនៅក្នុងក្រសែចិត្ត នៅពេលចេតនាទាំងនេះរលត់ហៅថា កាមាវចរកុសលនានក្ខណិកកម្ម។

ដូចគ្នាដែរ នៅពេលយោគីអាចចម្រើនអរូបាវចរកុសលឈាន អរូបាវចរកុសលសហជាតកម្ម និងអរូបាវចរកុសលនានក្ខណិកកម្ម រាប់កោដិ នឹងត្រូវបានបង្កើតឡើង។

**៥. ទ្វារកម្ម៣យ៉ាង**

ទីកន្លែងដែលកម្មកើតឡើង ឬមធ្យោបាយដែលកម្មកើតឡើង ហៅថាទ្វារកម្ម។

**១. កាយទ្វារ** - ទ្វារកាយ

ចលនារាងកាយពិសេសហៅថាកាយវិញ្ញត្តិ ជាទីដែលកាយកម្មកើតឡើង ឬមធ្យោបាយ ដែលកាយកម្មទាំងឡាយកើតឡើង។

**២. វចីទ្វារ** - ទ្វារវាចា

ចលនាបង្កើតពាក្យសំដីរបស់មាត់ហៅថា វចីវិញ្ញត្តិមធ្យោបាយ ដែលវចីកម្មទាំងឡាយ កើតឡើង។

**៣. មនោទ្វារ** - ទ្វារចិត្ត

វាសំដៅទៅលើចិត្តទាំងអស់ជាទីដែលមនោកម្មកើតឡើង

ឬមធ្យោបាយដែលមនោកម្មទាំងឡាយកើតឡើង។

**កម្មបីយ៉ាង ចែកទៅតាមទ្វារកម្ម**

**១. កាយកម្ម** - អំពើដោយកាយ

វាជាទូទៅត្រូវបានធ្វើឡើងដោយចលនារាងកាយពិសេស ឬ កាយវិញ្ញត្តិ។

**២. វចីកម្ម** - អំពើដោយវាចា

វាជាទូទៅត្រូវបានធ្វើឡើងដោយវចីវិញ្ញត្តិ។

**៣. មនោកម្ម** - អំពើដោយចិត្ត

វាត្រូវបានធ្វើឡើងនៅក្នុងចិត្ត ឬដោយចិត្ត ហៅថា មនោទ្វារ តាមរយៈការគិត ការលបធ្វើអំពើអាក្រក់ទៅលើនរណាម្នាក់ ការធ្វើ សមាធិភាវនា ។ល។

**៦. អកុសលកម្មបថ ១០**

អកុសលកម្មបថ មានន័យថា ផ្លូវ ឬ គន្លង នៃអំពើជាអកុសល។ អកុសលកម្មបថមាន ១០ គឺកាយកម្ម ៣ វចីកម្ម ៤ និងមនោកម្ម ៣ ។ គេស្គាល់កម្មបថនីមួយៗ ដោយចេតនាដែលផ្តើមការព្យាយាមធ្វើអំពើណាមួយ។

ចេតនាបែបហ្នឹងគឺជាអកុសលកម្ម ដោយមិនគិតថា វាធ្វើ





អំពើចប់ ឬមិនចប់នោះទេ។ ប្រសិនបើ វាឈានដល់ការបញ្ចប់នៃការប្រព្រឹត្តអំពើ និងសម្រេចគោលបំណងរបស់វា អ៊ីចឹងវាក្លាយជាកម្មបថពេញលេញ។ កិច្ចនៃកម្មបថពេញលេញគឺថាកម្មដែលបានបង្កើតមានអំណាចឧបត្ថម្ភបដិសន្ធិឱ្យបំពេញកិច្ច ពោលគឺកិច្ចនៃជនកកម្ម។

**ក. អកុសលកាយកម្ម ៣**

១)បាណាតិបាត -ការសម្លាប់សត្វមានជីវិត,

២)អទិន្នាទាន -ការលួច ឬ យកទ្រព្យសម្បត្តិអ្នកដទៃ មិនស្របច្បាប់,

៣)កាមេសុមិច្ឆាចារ -ការប្រព្រឹត្តខុសក្នុងកាម។

**ខ. អកុសលវចីកម្ម ៤**

៤) មុសាវាទ -ការនិយាយកុហក ឬពាក្យមិនពិត,

៥) បិសុណាវាចា -ការនិយាយបង្ខូចបង្កាច់,

៦) ផរុសវាចា -ការនិយាយពាក្យអាក្រក់,

៧) សម្ផប្បលាប -ការនិយាយពាក្យរោយរាយ ឥតប្រយោជន៍

**គ. អកុសលមនោកម្ម ៣**

៨) អភិជ្ឈា -ការប្រាថ្នា និងការគួចចិត្តចង់បានទ្រព្យអ្នក

ដទៃ មកធ្វើជាទ្រព្យរបស់ខ្លួន,

៩) ព្យាបាទ -បំណងអាក្រក់ និងការចង់ឱ្យអ្នកដទៃដល់នូវសេចក្តីវិនាស

១០) មិច្ឆាទិដ្ឋិ -គំនិតយល់ខុស ហើយប្រកាន់ថាត្រូវយល់ថា កម្ម និងផល របស់កម្មមិនមាន។

## លក្ខខណ្ឌសម្រាប់បំពេញនូវកម្ម

១.ការសម្លាប់សម្រេចទៅបានចាំបាច់ត្រូវមានអង្គ (លក្ខ-ខណ្ឌ) ៥ ខាងក្រោម៖

(ក) សត្វមានជីវិត

(ខ) សេចក្តីដឹងថាសត្វមានជីវិត

(គ) គិតនឹងសម្លាប់

(ឃ) ព្យាយាមនឹងសម្លាប់ និង

(ង) សត្វស្លាប់ដោយព្យាយាមនោះ។

ទម្ងន់នៃអំពើអាក្រក់អាស្រ័យលើគុណធម៌ និងទំហំនៃសត្វដែលត្រូវសម្លាប់។ ការសម្លាប់បុគ្គលមានគុណធម៌(មានសីល)និងសត្វធំត្រូវបានចាត់ទុកថា អាក្រក់ជាងការសម្លាប់មនុស្សអាក្រក់ ឬសត្វតូច។

ទោសនៃការសម្លាប់មាន អាយុខ្លី មានជម្ងឺច្រើន មានទុក្ខ





ព្រួយ ដោយសារការព្រាត់ប្រាស់ពីមនុស្សជាទីស្រឡាញ់ មានសេចក្តីភ័យខ្លាចជារឿយៗ និងកើតក្នុងអបាយភូមិ។

២. ការលួចសម្រេចទៅបានចាំបាច់ត្រូវមានអង្គ ៥៖

(ក) ទ្រព្យដែលមានម្ចាស់គេហួងហែងរក្សា

(ខ)សេចក្តីដឹងថា ទ្រព្យមានម្ចាស់គេហួងហែងរក្សា

(គ) គិតនឹងលួច

(ឃ) ព្យាយាម នឹងលួច និង

(ង) លួចបានដោយព្យាយាមនោះ។

ទោសនៃការលួច ឬយកទ្រព្យសម្បត្តិអ្នកដទៃ មានភាពក្រីក្រ សេចក្តីទុក្ខលំបាក ការខកចិត្ត ការរស់នៅពឹងអាស្រ័យលើអ្នកដទៃ និងកើតក្នុងអបាយភូមិ។

ទម្ងន់នៃអំពើអាក្រក់អាស្រ័យលើទ្រព្យសម្បត្តិ ដែលបានលួច និង គុណធម៌នៃម្ចាស់ទ្រព្យ។ ប្រសិនបើបុគ្គលលួច ឬយកបច្ច័យដែលទាយកបូជាចំពោះព្រះពុទ្ធ ឬចំពោះព្រះពុទ្ធសាសនា អំពើអាក្រក់នេះគឺធ្ងន់ធ្ងរណាស់។

៣. ការប្រព្រឹត្តខុសក្នុងកាមសម្រេចទៅបានត្រូវមានអង្គ៤ ៖

(ក)ស្ត្រី ឬបុរសដែលមិនគួរនឹងគប់រកគឺស្ត្រី ឬបុរសដែលយើងមិនបានរៀបការជាមួយ

(ខ) គិតនឹងសេពមេថុនធម្ម

(គ) ព្យាយាម នឹងសេពមេថុនធម្ម និង

(ឃ) ញ៉ាំងមគ្គនិងមគ្គឱ្យដល់គ្នា។

ទោសនៃការប្រព្រឹត្តខុសក្នុងកាមគឺ មានសត្រូវច្រើន គ្មានសេចក្តីចម្រើន គ្មានសេចក្តីសុខ រស់នៅជាមួយប្តី ឬប្រពន្ធដែលខ្លួនមិនពេញចិត្ត កើតជាមនុស្សខ្ទើយ ឬកើតជាស្ត្រី និង កើតក្នុងអបាយភូមិ។

៤. ការនិយាយកុហកសម្រេចទៅបានត្រូវមានអង្គ ៤ ៖

(ក) រឿងមិនពិត

(ខ) គិតនឹងពោលឱ្យខុស

(គ) ព្យាយាមនឹងពោលឱ្យខុស និង

(ឃ) ញ៉ាំងអ្នកដទៃឱ្យដឹងច្បាស់នូវសេចក្តីខុសនោះ។

ទោសនៃការនិយាយកុហកមាន សម្តីមិនច្បាស់ ធ្មេញមិនស្មើល្អ មាត់មានក្លិន ស្បែកស្ងួត គ្មានភាពសមរម្យនៃកាយវិការរាងកាយ មានទ្រង់ទ្រាយមិនធម្មតា គ្មានការជឿទុកចិត្តលើ និងកើតក្នុងអបាយភូមិ។

៥.ការនិយាយបង្ខូចបង្កាច់សម្រេចទៅបានចាំបាច់ ត្រូវមានអង្គ ៤ ៖





(ក) អ្នកដទៃដែលមានរូប គឺខ្លួនគប្បីញុះញង់បំបែក

(ខ) គិត នឹងញុះញង់បំបែក

(គ) ព្យាយាមនឹងញុះញង់បំបែកអ្នកដទៃនោះ និង

(ឃ)ញ៉ាំងអ្នកនោះឱ្យដឹងច្បាស់ នូវដំណើរដែលខ្លួនញុះ-ញង់ បំបែកនោះ។

ទោសនៃការនិយាយបង្ខូចបង្កាច់គឺការបែកមិត្ត ដោយគ្មានមូល ហេតុគ្រប់គ្រាន់ និងកើតក្នុងអបាយភូមិ។

៦. ការនិយាយពាក្យអាក្រក់សម្រេចទៅបានត្រូវមានអង្គ ៣៖

(ក) អ្នកដទៃដែលមានរូប គឺខ្លួនគប្បីជេរប្រទេច

(ខ) ចិត្តខឹងរន្ធត់ និង

(គ)បានជេរប្រទេចគេ។

ទោសនៃការនិយាយពាក្យអាក្រក់គឺរូបរាងអាក្រក់ សំឡេងមិនជាទីគាប់ចិត្ត មានសត្រូវច្រើន អ្នកដទៃស្អប់ ទោះស្លូតត្រង់ក៏ដោយ និងកើតក្នុងអបាយភូមិ។

៧. ការនិយាយពាក្យរោយរាយឥតប្រយោជន៍សម្រេចទៅបាន ចាំបាច់ត្រូវមានអង្គ ២៖

(ក) ពាក្យឥតប្រយោជន៍ និង

(ខ) បានពោលពាក្យឥតប្រយោជន៍នោះ។

ទោសនៃការនិយាយពាក្យរោយរាយ មានអវយវៈរាងកាយមានខ្វោះ មានពាក្យសម្ដីមិនគួរកាន់យក និងកើតក្នុងអបាយភូមិ។

៨. ការប្រាថ្នាចង់បានទ្រព្យអ្នកដទៃមកធ្វើជាទ្រព្យរបស់ខ្លួន សម្រេចទៅបានចាំបាច់ត្រូវមានអង្គ ៣ ៖

(ក) ទ្រព្យរបស់អ្នកដទៃ

(ខ)គិតចង់បង្អោនទ្រព្យឱ្យបានមកជាទ្រព្យរបស់ខ្លួន និង

(គ) គ្រោងនឹងយកទ្រព្យនោះមកជាទ្រព្យរបស់ខ្លួន។

ទោសនៃការប្រាថ្នាចង់បានទ្រព្យអ្នកដទៃ គឺការមិនសម្រេចបំណងរបស់ខ្លួន និងកើតក្នុងអបាយភូមិ។

៩.បំណងអាក្រក់ចង់ឱ្យអ្នកដទៃវិនាស សម្រេចទៅបានត្រូវមានអង្គ ៣ ៖

(ក) អ្នកដទៃក្រៅពីខ្លួន

(ខ)គិតគុំកួនប្រុងនឹងឱ្យអ្នកនោះដល់នូវសេចក្ដីវិនាស និង

(គ) គ្រោងនឹងធ្វើឱ្យអ្នកនោះ ដល់នូវសេចក្ដីវិនាស។

ទោសនៃបំណងអាក្រក់ចង់ឱ្យអ្នកដទៃវិនាស គឺ រូបរាងអាក្រក់ មានជម្ងឺច្រើនមុខ មានធម្មជាតិមិនឱ្យគេស្រឡាញ់រាប់អាន និងកើតក្នុងអបាយភូមិ។





១០. គំនិតយល់ខុសសម្រេចទៅបានចាំបាច់ត្រូវមានអង្គ ៣ ៖

(ក) អវិជ្ជាមិនស្គាល់កម្ម និងផលរបស់កម្ម

(ខ)ចិត្តប្រែប្រួលដោយអាការៈខុសពីអ្វីដែលគេយល់ និង

(គ)ឃើញខុសយ៉ាងណា ក៏ប្រកាន់សេចក្ដីខុសនោះថាជាត្រូវវិញ។

ទោសនៃការយល់ខុសមានដូចជា ការប្រាថ្នាលាមក ខ្វះបញ្ញា សេចក្ដីវៃឆ្លាតមិនមុត មានជម្ងឺរ៉ាំរ៉ៃ មានគំនិតដែលគេ តិះដៀលការធ្វើអំពើអាក្រក់កាន់តែច្រើន និងកើតក្នុងអបាយភូមិ។

**៧. កុសលកម្មបថ ១០**

កុសលកម្មបថមាន ១០ គឺកាយកម្ម ៣ វចីកម្ម ៤ និងមនោកម្ម ៣។ គេស្គាល់កម្មបថនីមួយៗ ដោយចេតនាដែលផ្ដើមការព្យាយាមធ្វើអំពើណាមួយ។ ចេតនាបែបហ្នឹងគឺជា កុសលកម្មដោយមិនគិតថាវាធ្វើអំពើចប់ ឬមិនចប់នោះទេ។ ប្រសិនបើវាឈានដល់ការបញ្ចប់នៃការប្រព្រឹត្តអំពើ និងសម្រេចគោលបំណងនៃការចៀសវាងមិនធ្វើអំពើអាក្រក់របស់វា អ៊ីចឹងវាក្លាយជាកម្មបថពេញលេញ ពោលគឺជនកកម្ម ដែលមានអំណាចឱ្យមានបដិសន្ធិថ្មី។

**ក. កុសលកាយកម្ម ៣**

(១) បាណាតិបាត វិរតិ -ការវៀរចាកការសម្លាប់សត្វមានជីវិត,

(២) អទិន្នាទាន វិរតិ -ការវៀរចាកការលួច ឬយកទ្រព្យសម្បត្តិអ្នកដទៃ

(៣) កាមេសុមិច្ឆាចារវិរតិ -ការវៀរចាកការប្រព្រឹត្តខុសក្នុងកាម ។

**ខ. កុសលវចីកម្ម ៤**

(៤) មុសាវាទ វិរតិ -ការវៀរចាក ការនិយាយកុហក,

(៥) បិសុណាវាចា វិរតិ -ការវៀរចាក ការនិយាយបង្ខូចបង្កាច់,

(៦) ផរុសវាចា វិរតិ -ការវៀរចាក ការនិយាយពាក្យអាក្រក់,

(៧) សម្ផប្បលាប វិរតិ -ការវៀរចាក ការនិយាយពាក្យរោយរាយ ឥតប្រយោជន៍។

**គ. កុសលមនោកម្ម ៣**

(៨) អនភិជ្ឈា -ការមិនប្រាថ្នាចង់បានទ្រព្យអ្នកដទៃ





(៩) អព្យាបាទ -បំណងល្អនិងការមិនចង់ឱ្យអ្នកដទៃដល់នូវសេចក្តីវិនាស,

(១០) សម្មាទិដ្ឋិ -គំនិតយល់ត្រូវ ជឿកម្ម និងផលរបស់កម្ម។

គួរកត់ចំណាំថា អកុសលកម្មបថ ១០ ក៏ហៅថា "**ទុច្ចរិត ១០**" មានន័យថា "ដំណើរប្រព្រឹត្តអាក្រក់ ១០ យ៉ាង" រីឯកុសលកម្មបថ ១០ ក៏ហៅថា "**សុចរិត ១០**" មានន័យថា "ការប្រព្រឹត្តល្អ ១០ យ៉ាង"។

វាសំខាន់ណាស់ក្នុងការដឹងអ្វីមួយអាក្រក់ ឬអកុសល និងអ្វីមួយល្អ ឬកុសល តាមទស្សនៈកម្ម និងផលរបស់កម្ម។ អកុសលកម្ម ត្រូវធ្វើឡើងដោយអកុសលចិត្ត ដែលបង្កើតឱ្យមាន អកុសលកម្ម រាប់កោដិកើតឡើង និងឱ្យផលជាអកុសលរាប់កោដិផងដែរ។ ម្យ៉ាងទៀត កុសលកម្មត្រូវធ្វើឡើងដោយកុសលចិត្ត ដែលបង្កើតឱ្យមានកុសលកម្មរាប់កោដិ និងឱ្យផលជា កុសល រាប់កោដិផងដែរ។

ហេតុដូច្នេះ បុគ្គលគប្បីមានឆន្ទៈ និងឧស្សាហ៍ចៀសវាងអកុសលកម្ម ១០ និងដោយហេតុនោះ គប្បីបំពេញកុសលកម្មក្នុងពេលជាមួយគ្នាដែរ។ ក្រៅពីធ្វើដូច្នេះ បុគ្គលគប្បីធ្វើចិត្តឱ្យបរិសុទ្ធ

ផងដែរ ដោយការសង្កត់អកុសលមូលមិនឱ្យកើតឡើង។ ធ្វើដូច្នេះ គេអាចរស់នៅស្រប ទៅតាមការប្រៀនប្រដៅរបស់ព្រះសម្មាសម្ពុទ្ធ គ្រប់ព្រះអង្គ ពោលគឺ "វៀរចាកអំពើអាក្រក់ទាំងពួង ធ្វើតែអំពើល្អគ្រប់យ៉ាង និងជម្រះចិត្តឱ្យបរិសុទ្ធ"។

បុគ្គលអាចសម្រេចគោលដៅនេះបាន ដោយគ្រាន់តែកាន់សីលប្រាំ (បញ្ចសីល) ដោយសេចក្តីមិនប្រមាទ។ ហេតុដូច្នេះ បញ្ចសីលសំខាន់ណាស់ ហើយនៅក្នុងការកាន់សីលប្រាំយើងគប្បីប្រុងប្រយ័ត្នចៀសវាងអកុសលកម្មបថទាំង ១០។

## ៨. បុញ្ញកិរិយាវត្ថុ ១០

"បុញ្ញកិរិយាវត្ថុ" មានន័យថា ទីតាំងដែលនាំឱ្យកើតបានជាបុណ្យជាកុសល ដែលគួរធ្វើ ពីព្រោះវាបង្កើតផលច្រើន។

| | |
|---|---|
| ១. ទាន | -ការឱ្យទាន ឬសប្បុរសធម៌, |
| ២. សីល | -ការរក្សាសីល ៥, ៨, ១០ ជាដើម, |
| ៣. ភាវនា | -ការចម្រើនសមថកម្មដ្ឋាន ឬ វិបស្សនាកម្មដ្ឋាន, |
| ៤. អបចាយន | -ការគោរពកោតក្រែង ឱនលំទោន ជឿស្តាប់ចាស់ទុំព្រះសង្ឃ |
| ៥. វេយ្យាវច្ច | -ខ្នះខ្នែងខ្វល់ខ្វាយក្នុងអំពើបុណ្យ |





| | |
|---|---|
| ៦. បត្តិទាន | -ការឱ្យចំណែកបុណ្យ |
| ៧.បត្តានុមោទនា | -ការត្រេកអរទទួលយកចំណែកបុណ្យ ដែលគេឱ្យ |
| ៨. ធម្មស្សវន | -ការស្តាប់ធម៌ដោយគោរព |
| ៩. ធម្មទេសនា | -ការបង្រៀន ឬសម្តែងធម៌ឱ្យគេស្តាប់ |
| ១០. ទិដ្ឋុជុកម្ម | -ការធ្វើសេចក្តីយល់ឃើញរបស់ខ្លួនឱ្យត្រូវត្រង់តាមផ្លូវពិត។ |

បុញ្ញកិរិយាវត្ថុ ១០ ខាងលើអាចសង្ខេបជា ៣ ក្រុម

១. ក្រុមទាន - ទាន, បត្តិទាន, បត្តានុមោទនា,

២. ក្រុមសីល - សីល, អបចាយន, វេយ្យាវច្ច,

៣. ក្រុមភាវនា - ភាវនា,ធម្មស្សវន, ធម្មទេសនា, ទិដ្ឋុជុកម្ម។

ជាទូទៅ បុញ្ញកិរិយាវត្ថុខាងលើត្រូវបានធ្វើជាមួយកាមាវចរកុសលចិត្ត លើកលែងតែបុគ្គលបានសម្រេចឈាន និងមគ្គក្នុងសមាធិ។ ដូច្នេះ ជាទូទៅ បុញ្ញកិរិយាវត្ថុឱ្យផលជាកាមាវចរកុសលកម្ម។

បុគ្គលគប្បីបំពេញបុញ្ញកិរិយាវត្ថុទាំងអស់នេះ ឱ្យបានច្រើនតាមដែលអាចធ្វើបាន ដើម្បីប្រមូលកុសលកម្មឱ្យច្រើនឡើង និងជម្រះចិត្តឱ្យបរិសុទ្ធ។

## ៩. តើកម្មស្ថិតនៅកន្លែងណា?

នៅក្នុងគម្ពីរមិលិន្ទបញ្ហា ស្តេចមិលិន្ទ បានទូលសួរព្រះអរហន្តនាគសេនថា "បពិត្រព្រះគុណម្ចាស់ដ៏ចម្រើន លោកមានថេរដីកាអំពីកុសលកម្ម និងអកុសលកម្ម។ តើកម្មទាំងនេះតាំងនៅទីណា?"

"បពិត្រមហារាជ កុសលកម្មក្តី អកុសលកម្មក្តីតាំងនៅក្នុងក្រសែចិត្ត និងកាយ។ គេមិនអាចបង្ហាញថា កម្មទាំងនេះតាំងនៅត្រង់នេះ ឬតាំងនៅត្រង់នោះបានទេ។ ប៉ុន្តែ គេអាចឧបមាបាន។"

"សូមព្រះគុណម្ចាស់ ឧបមាមកមើល។"

"សូមថ្វាយព្រះពរ នៅពេលដើមស្វាយកើតចេញពីគ្រាប់ស្វាយ ពន្លកផ្តល់ផ្កាផ្លែត្រូវបានបញ្ជូនពីគ្រាប់ទៅដើមស្វាយតូច។ ពន្លកនៅក្នុងដើមស្វាយរហូតដល់ដើមស្វាយធំ។ ប៉ុន្តែពន្លកនោះមើលមិនឃើញ បង្ហាញមិនបានទេ។ ប៉ុន្តែ នៅពេលដើមស្វាយចេញផ្លែ យើងអាចនិយាយបានថា ពន្លកផ្តល់ផ្កាផ្លែមាននៅក្នុងដើមស្វាយ។ ដូចគ្នានេះដែរ កម្មក៏មើលមិនឃើញ និងមិនអាចបង្ហាញផងដែរ យើងអាចមើលឃើញភពផ្សេងៗដែលកើតពីកម្ម។ ដូច្នេះ យើងអាចនិយាយថាកម្មតាំងនៅក្នុងក្រសែចិត្ត និងកាយ។"

"បពិត្រព្រះគុណម្ចាស់ លោកម្ចាស់ឆ្លើយសមគួរហើយ។"





សំណួរដែលស្តេចមិលិន្ទបានសួរ ក៏បានកើតឡើងម្តងទៀតនៅក្នុងសតវត្សទី ២០។ បណ្ឌិត **ប. រ. អ៊ែមបេដការ៍** (Dr.B.R. Ambedkar)ជារដ្ឋមន្ត្រីតុលាការនៃប្រទេសឥណ្ឌា នៅពេលនោះបានសួរសំណួរដូចគ្នាទៅព្រះថេរៈ **អរិយធម្ម** (បរិញ្ញាបត្រ) គង់នៅពុទ្ធវិហារ ទីក្រុងប៉មប៉ៃ។ ព្រះថេរៈ **អរិយធម្ម** ជាព្រះសង្ឃមានប្រាជ្ញាឈ្លាសវៃ ជាសិស្សគណរបស់ព្រះមហាថេរៈ **ឧក្កឋៈ** នៃតំបន់តោងវិនជី ប្រទេសភូមា។

បណ្ឌិត **អ៊ែមបេដការ៍** ជាមេដឹកនាំប្រជាជនឥណ្ឌាវណ្ណៈទាប (ចណ្ឌាល)។ ប្រជាជនប្រហែល ២០ លាននាក់ នៃក្រុមប្រជាជនវណ្ណៈទាបបានក្លាយជាពុទ្ធសាសនិកជន ពីព្រោះនៅក្នុងព្រះពុទ្ធសាសនា គ្មានការប្រកាន់វណ្ណៈ រួមទាំងកម្ម និងផលរបស់កម្ម។ ដូច្នេះ បណ្ឌិត **អ៊ែមបេដការ៍** បានសួរសំណួរខាងក្រោមទៅព្រះថេរៈ អរិយធម្ម។

"ព្រះគុណម្ចាស់ មានទ្រឹស្តីកម្ម និងផលរបស់កម្ម នៅក្នុងព្រះពុទ្ធសាសនា។ តើកម្មនេះតាំងនៅទីណា?"

"អាត្មាភាពសូមឆ្លើយសំណួររបស់លោក ដោយសួរលោកនូវសំណួរខ្លះៗ។ តើលោក បានទទួលសញ្ញាបត្រប៉ុន្មាន?"

"បរិញ្ញាបត្រ អនុបណ្ឌិត បណ្ឌិតទស្សនវិជ្ជា បណ្ឌិតវិទ្យា-

សាស្ត្រ និងបណ្ឌិតច្បាប់ រួមគ្នាមានប្រាំសញ្ញាបត្រ ព្រះគុណម្ចាស់។"

"តើលោករៀនរយៈពេលប៉ុន្មាន ដើម្បីបានសញ្ញាបត្រទាំងនេះ?"

"សាមសិបឆ្នាំ ព្រះគុណម្ចាស់។"

"តើចំណេះដឹងនៃសញ្ញាបត្រទាំងនេះមាននៅក្នុងខ្លួនលោកទេ?"

"ព្រះករុណា មាន។"

" ដូច្នេះ សូមបង្ហាញចំណេះវិជ្ជាផ្នែកបណ្ឌិតវិទ្យាសាស្ត្រដល់អាត្មាភាព មកមើល។"

" ខ្ញុំព្រះករុណាមិនអាចបង្ហាញចំណេះដឹង នៅក្នុងខ្លួនខ្ញុំព្រះករុណាដល់ព្រះគុណម្ចាស់បានទេ។ ប៉ុន្តែ ខ្ញុំព្រះករុណាអាចបង្ហាញព្រះគុណម្ចាស់ នូវសញ្ញាបត្របណ្ឌិតវិទ្យាសាស្ត្រ ដែលខ្ញុំព្រះករុណាបានទទួល "។ "ពិតមែនហើយ សញ្ញាបត្រគឺគ្រាន់តែជាតួអក្សរ ដែលគេបោះពុម្ពនៅលើក្រដាស ប៉ុណ្ណោះ។ តើចំណេះវិជ្ជារបស់លោកមាននៅក្នុងខ្លួនលោក ឬនៅលើក្រដាស?"

"វាមាននៅក្នុងខ្លួនខ្ញុំព្រះករុណា ព្រះគុណម្ចាស់ "។

"តើវាតាំងនៅទីណា នៅក្នុងមាត់របស់លោក ឬនៅក្នុងទ្រូង





ឬនៅក្នុងបេះដូងរបស់លោក?"

"ខ្ញុំព្រះករុណាមិនអាចនិយាយថា វាតាំងនៅទីណាមួយបានទេ។ ប្រសិនបើ ព្រះគុណម្ចាស់សួរសំណួរអំពីមុខវិជ្ជានេះ ខ្ញុំព្រះករុណាអាចឆ្លើយសំណួរបាន។ ហើយខ្ញុំព្រះករុណាក៏អាចប្រើប្រាស់ចំណេះដឹងនេះ នៅក្នុងការងារប្រចាំថ្ងៃរបស់ខ្ញុំព្រះករុណាផងដែរ។"

"លោកនិយាយត្រូវហើយ។ អាត្មាភាពជឿថា ចំណេះដឹងទាំងឡាយនៃសញ្ញាបត្រ ដែលលោកទទួលបាន ពិតជានៅក្នុងខ្លួនលោក។ តែលោកមិនអាចបង្ហាញអាត្មាភាពបាន។ ដូចគ្នាដែរ កម្ម តាំងនៅក្នុងក្រសែចិត្តរបស់យើង ប៉ុន្តែយើងមិនអាចបង្ហាញដល់មនុស្សបាន។ ដោយការពិចារណាទៅលើផលផ្សេងៗ ដែលកើតពីកម្ម យើងត្រូវជឿថា កម្មមាននៅក្នុងខ្លួនយើង។

"ព្រះគុណម្ចាស់បានឆ្លើយសមគួរហើយ ខ្ញុំព្រះករុណាសូមសួរសំណួរមួយផ្សេងទៀត។"

## ១០.តើកម្មតាក់តែងភពថ្មី ឱ្យកើតឡើងដោយរបៀបណា?

"នៅពេលមនុស្សស្លាប់ តើកម្មបង្កើតភពថ្មីតាមរបៀបណា? សាសនាហិណ្ឌូពន្យល់ពីការចាប់ជាតិថ្មីសាមញ្ញបំផុត។ ព្រលឹងធំដែល គេហៅថា ជីវអត្តៈ មានចេញពីរាងកាយនេះ នៅពេលរាង

កាយនេះស្លាប់ ហើយចូលទៅក្នុងរាងកាយថ្មីមួយ ដោយបង្កើតភពថ្មី។ ឧបមាដូច បក្សីនៅលើដើមឈើមួយ នឹងហើរទៅកាន់ដើមឈើមួយផ្សេងទៀត នៅពេលដើមឈើទីមួយត្រូវគេកាប់ ហើយតាំងនៅលើដើមឈើទីពីរ ”។

“ចម្រើនពរលោករដ្ឋមន្ត្រី ព្រះសម្មាសម្ពុទ្ធទ្រង់បានឈ្វេងយល់យ៉ាងច្បាស់ ដោយទិព្វចក្ខុ និងញាណរបស់ព្រះអង្គថា គ្មានព្រលឹង ឬ អត្ត ឬជីវអត្ត អមតៈអចិន្ត្រៃយ៍ កើតមានពិតនោះទេ។ ទ្រឹស្តីស្តីពីកម្ម ដែលមើលមិនឃើញតាក់តែងភពថ្មី ឱ្យកើតឡើងមានសភាពជ្រៅ និងល្អិតសុខុមខ្លាំងណាស់។ គេមិនអាចពន្យល់សាមញ្ញ ដូចបក្សីហើរពីដើមឈើមួយទៅដើមឈើមួយទៀតបានទេ។ ប្រសិនបើ លោកចង់ដឹងសូមលោកឱ្យកម្មកររបស់លោកយកកញ្ចក់មួយផ្ទាំងមក។”

“ឥឡូវនេះ កញ្ចក់មួយផ្ទាំងនៅទីនេះហើយ ព្រះគុណម្ចាស់។”

“សូមលោកឈរនៅពីមុខកញ្ចក់។ ឥឡូវនេះ នៅពេលលោកឈរនៅពីមុខកញ្ចក់ភ្លាម បុរសម្នាក់ក៏បានលេចមុខនៅក្នុងកញ្ចក់ផងដែរ។ តើបុរសនៅក្នុងកញ្ចក់ជាលោក ឬមនុស្សម្នាក់ផ្សេងទៀត?”

“វាមិនអាចជាមនុស្សម្នាក់ផ្សេងទៀតទេ។ គឺត្រូវតែជាខ្ញុំ





ព្រះករុណា ”។

“ប៉ុន្តែលោក និងបុរសនៅក្នុងកញ្ចក់កំពុងបែរមុខដាក់គ្នា។ ប្រសិនបើ លោកជាមនុស្សតែមួយ ហេតុអ្វីបានជាលោកបែរមុខបញ្ច្រាសគ្នា?”

“ខ្ញុំព្រះករុណា សូមកែខៃចម្លើយរបស់ខ្ញុំព្រះករុណាឱ្យល្អឡើង។ បុរសនៅក្នុងកញ្ចក់មិនមែនជាខ្ញុំព្រះករុណាទេ តែជារូបភាពរបស់ខ្ញុំព្រះករុណា ”។

“ពិតមែនហើយ តើលោកមានរូបថតទេ? តើរូបថតគឺជារូបភាពរបស់លោកផងដែរឬ?”

“ករុណា ព្រះគុណម្ចាស់។”

“ដាក់រូបថតនៅពីមុខកញ្ចក់។ ឥឡូវសូមលើកដៃរបស់លោកឡើង។ សូមដាក់ដៃរបស់លោកចុះ។ សូមអង្គុយចុះ។ សូមក្រោកឡើង។ ឥឡូវបុរសនៅក្នុងកញ្ចក់បានធ្វើសកម្មភាព ដូចបេះបិទដូចលោកបានធ្វើ ប៉ុន្តែ រូបភាពរបស់លោក រូបថត មិនបានធ្វើអ្វីសោះ។ តើលោកនៅតែចង់ឆ្លើយបដិសេធថា បុរសនៅក្នុងកញ្ចក់មិនមែនជាលោកទៀតឬ? តើអាត្មាភាពគួរសួរអ្នកដទៃឬទេ?”

“ព្រះគុណម្ចាស់មិនចាំបាច់សួរអ្នកដទៃទេ។ បុរសនៅក្នុងកញ្ចក់គឺជាខ្ញុំព្រះករុណា។”

"បើអ៊ីចឹង បំបែកកញ្ចក់ដោយញញួរ។"

កម្មកររបស់បណ្ឌិត អ៊ែមបេដការ៍ បានបំបែកកញ្ចក់។

"ឥឡូវនៅពេល កញ្ចក់បានបែកភ្លាម បុរសនៅក្នុងកញ្ចក់ក៏បានបាត់ដែរ។ ប្រសិនបើ លោក និងបុរសនៅក្នុងកញ្ចក់ជាមនុស្សតែមួយ ហេតុអ្វីបានជាលោកមិនបាត់ទៅដែរ? តើលោកចង់និយាយថា បុរសនៅក្នុងកញ្ចក់មិនមែនជាលោកទេ?"

"ខ្ញុំព្រះករុណាមិនដឹងជាឆ្លើយយ៉ាងម៉េចទេ។ សូមព្រះគុណម្ចាស់ ឆ្លើយនឹងសំណួរនេះចុះ។"

"អ៊ីចឹង យើងគប្បីនិយាយថា បុរសនៅក្នុងកញ្ចក់ជាលោកក៏មិនមែន មិនមែនលោកក៏មិនមែន។ គ្មានអ្វីត្រូវបានបញ្ជូនពីលោកទៅបុរសនៅក្នុងកញ្ចក់។ ដូច្នេះ យើងមិនអាចនិយាយថាបុរសនៅក្នុងកញ្ចក់ជាលោកបានទេ។ ប៉ុន្តែ បើគ្មានលោកទេ បុរសក៏មិនអាចមាននៅក្នុងកញ្ចក់បានដែរ។ ដោយសារលោក បុរសដូចគ្នាបេះបិទនឹងលោក មាននៅក្នុងកញ្ចក់។ ដោយសារបុរសទាក់ទងនឹងលោកដោយហេតុ និង ផល យើងក៏មិនអាចនិយាយថា បុរសមិនមែនជាលោកបានផងដែរ។"

"ដូចគ្នាដែរ នៅពេលមនុស្សម្នាក់ស្លាប់ កម្មមួយក្នុងចំណោមកម្មទាំងឡាយរបស់គាត់ តាក់តែងភពថ្មី គ្មាននាម និងរូបណា





មួយត្រូវបានបញ្ជូនទៅភពថ្មី។ នាម និង រូប ទាំងអស់នៅក្នុងភពមុនរលត់ និង រលាយអស់នៅក្នុងភពមុននោះ។ ប៉ុន្តែ កម្មនៅក្នុងភពមុនជាបច្ច័យតាក់តែងភពថ្មី ឱ្យកើតឡើង ដោយទំនាក់ទំនងហេតុ និងផល ដែលព្រះពុទ្ធ ទ្រង់បានសម្តែងនៅក្នុង **បដិច្ចសមុប្បាទ** "។

"ដើម្បីពន្យល់ឱ្យងាយយល់ អាត្មាភាពសូមលើកយកអកុសលកម្ម មានឱកាសបង្កើតភពថ្មី។ ដូច្នេះ កម្មនោះបង្កើតវិបាកចិត្តរបស់វា សម្បយុត្តជាមួយ ចេតសិក និងកម្មជរូបនៅក្នុងភពថ្មី។ កម្មនោះក៏បន្តបង្កើតវិបាកទាំងនេះ ដរាបវាមានកម្លាំងកម្ម រក្សាភពថ្មីឱ្យតាំងនៅ។ វិបាកចិត្តទីមួយនៅក្នុងភពថ្មីហៅថា "បដិសន្ធិចិត្ត"។ វិបាកចិត្ត ដែលកើតបន្តបន្ទាប់ហៅថា *ភវង្គចិត្ត* ដែលរក្សាភពថ្មីឱ្យតាំងនៅ។ វិបាកចិត្ត ចុងក្រោយហៅថា *ចុតិចិត្ត* ពីព្រោះភពថ្មីបញ្ចប់នៅពេលចិត្តនេះបានរលត់។"

"អកុសលកម្មបង្កើតអកុសលវិបាកចិត្ត សម្បយុត្តចេតសិក និងកម្មជរូប ដែលបង្កបង្កើតភពថ្មីនៅក្នុងអបាយភូមិ។ បើ កាមាវចរកុសលកម្ម មានឱកាសឱ្យផលនៅពេលស្លាប់ វានឹងបង្កើតកុសលវិបាកចិត្តសម្បយុត្តចេតសិក និងកម្មជរូប ដែលបង្កបង្កើត

ភពថ្មីនៅក្នុងឋានមនុស្ស ឬទេវតា។ បើ រូបាវចរកុសលចិត្តមាន ឱកាសឱ្យផល នឹងទៅកើតក្នុងរូបព្រហ្ម។"

"ដូច្នេះ ព្រះពុទ្ធសាសនាបានពណ៌នាលម្អិត ស្តីអំពីបដិសន្ធិផ្សេងៗ ដែលបង្កើតឡើងដោយកម្មផ្សេងៗ។ ព្រលឹងអមតៈ អចិន្រ្តៃយ៍ មិនមានតួនាទីក្នុងការចាប់បដិសន្ធិពីភពមួយទៅភពមួយទៀតទេ។"

"ហេតុដូច្នេះ ដោយសារគ្មាន នាម និង រូប ត្រូវបានបញ្ជូនពីភពចាស់ទៅភពថ្មី យើងមិនអាចនិយាយថា មនុស្សកើតថ្មីគឺជាមនុស្សចាស់នោះទេ។ ទោះបីយ៉ាងណាក៏ដោយ ដោយសារការប្រព្រឹត្តទៅនៃ នាម និង រូប ក្នុងភពចាស់ហូរបន្តទៅភពថ្មី យើងក៏មិនអាចនិយាយថា មនុស្សថ្មីមិនមែនជាមនុស្សចាស់បានដែរ។"

"សូម្បីនៅក្នុងភពបច្ចុប្បន្ន កម្ម ដែលបានឱ្យបដិសន្ធិទៅភពនេះ បន្តបង្កើតវិបាកចិត្តរបស់វា សម្បយុត្តចេតសិក និង កម្មជរូប មួយហើយមួយទៀត។ ដូច្នេះ នាម និងរូបចាស់ កំពុងរលាយបាត់ ហើយ នាម និង រូបថ្មីកំពុងបង្កើតឡើង។ តាមរយៈ នាម និងរូប កំពុងផ្លាស់ប្តូរ គ្រប់ពេល យើងចាត់ទុកភពទាំងមូលថាជាបុគ្គលតែមួយពីព្រោះ នាម និង រូប ត្រូវបានភ្ជាប់គ្នានៅក្នុងច្រវ៉ាក់បន្តគ្នា។"





"ដោយសារក្រសែនាម និងក្រសែរូប ហូរបន្តពីភពចាស់ទៅភពថ្មី យើងគប្បីចាត់ទុកបុគ្គលថ្មីថា ជាបុគ្គលចាស់ ដោយសម្មតិសច្ចៈ។ តើវាច្បាស់ហើយឬនៅលោក?"

"វាច្បាស់ណាស់ និងមានហេតុផលណាស់។ សូមអរព្រះគុណ ព្រះគុណម្ចាស់ច្រើនណាស់។"

ប្រជាជនឥណ្ឌាវណ្ណៈទាបជាង ២០ លាននាក់ ដែលដឹកនាំដោយបណ្ឌិត **ប. រ. អ៊ែមបេដការ៍** (Dr.B.R. Ambedkar) បានក្លាយជាពុទ្ធសាសនិកជន។ វាជាប្រការគួរឱ្យរីករាយណាស់ ដែលបានឮព័ត៌មានល្អនេះ។

# ៧

## តើកម្មឱ្យផលតាមរបៀបណា?

### ១. ទម្លាប់នៃការសម្លឹងមើលកម្មដែលឱ្យផលភ្លាមៗ

ជាធម្មតា មនុស្សយើងច្រើនមានទម្លាប់សម្លឹងមើលកម្ម ដែលឱ្យផលភ្លាមៗ។ ប្រសិនបើ ឱ្យផលភ្លាមៗពួកគេចូលចិត្តធ្វើ វា ទោះបីវាជាអំពើអកុសលក៏ដោយ។ ប្រសិនបើ គ្មានផលភ្លាម ទេ ពួកគេមិនចូលចិត្តធ្វើទេ ទោះបីវាជាអំពើកុសលក៏ដោយ។

ការពិតជាក់ស្តែង នេះគ្រាន់តែជាការប្រមើលតាមបែប គិតខ្លី និងអាត្មានិយមតែប៉ុណ្ណោះ ។ តាមការប្រមើលបែបនេះ ប្រសិនបើមនុស្សធ្វើតែអំពើអកុសល មិនធ្វើអំពើកុសលទេ គេនឹង គ្មានអ្វីសោះ រួមចំណែកសម្រាប់សុខុមាលភាពមនុស្សជាតិ ក៏ ដូចជាសុខុមាលភាពខ្លួនឯង ក្នុងរយៈពេលយូរអង្វែង។ គេថែម ទាំងអាចធ្វើឱ្យរកាំចិត្តដល់សហគមន៍ ដែលមានសេចក្តីសុខ និង សន្តិភាព ព្រមទាំងសន្តិភាពពិភពលោក។





ដូចព្រះពុទ្ធទ្រង់បានប្រទានឱវាទដល់ព្រះរាហុល ជាឱរស របស់ព្រះអង្គ នៅក្នុង **អម្ពលដ្ឋិករាហុ លោវាទសូត្រ** លុះត្រាណា យើងមានសេចក្តីប្រុងប្រយ័ត្នធ្វើអំពើមិនមានទោស មិនមានផល ជាទុក្ខ គឺយើងអាចរួមចំណែកអ្វីមួយដើម្បីសុខុមាលភាពរបស់ សហគមន៍ ក៏ដូចជាសុខុមាលភាពរបស់យើងផងដែរ។ ដោយ ការធ្វើរបៀបនេះ យើងក៏អាចផ្តល់ការគាំទ្រដល់ការខំប្រឹងខ្នះ ខ្នែងដ៏ប្រសើរ ដើម្បីស្ថាបនាពិភពលោកប្រកបដោយសេចក្តីសុខ និងសន្តិភាព។

"ម្នាលរាហុល កញ្ចក់មានប្រយោជន៍ដូចម្តេច។"

"បពិត្រព្រះអង្គដ៏ចម្រើន កញ្ចក់មានប្រយោជន៍ខាងការឆ្លុះ មើលមុខ។"

"យ៉ាងនោះមែនហើយ ដោយការឆ្លុះមើលកញ្ចក់ បុគ្គលអាច មើលឃើញថា តើមានគុណវិបត្តិអ្វី ឬអត់នៅលើមុខរបស់ខ្លួន។ ដូច គ្នានេះដែរ ម្នាលរាហុល បើអ្នកចង់ធ្វើអំពើណាមួយ ដោយកាយ ដោយវាចា ឬ ដោយចិត្ត អ្នកត្រូវពិចារណា កាយកម្ម វចីកម្ម ឬ មនោកម្ម នោះសិនថា "តើកាយកម្ម វចីកម្ម ឬមនោកម្ម របស់អាត្មា អញនេះឯង ប្រព្រឹត្តទៅដើម្បីបៀតបៀនខ្លួនផង ប្រព្រឹត្តទៅដើម្បី បៀតបៀនអ្នកដទៃផងឬហ្ន៎។ បើវាប្រព្រឹត្តទៅដើម្បីបៀតបៀន

ដល់បុគ្គលទាំងពីរចំណែក គឺខ្លួនឯង និងអ្នកដទៃផង កាយកម្ម វចីកម្ម ឬមនោកម្ម នេះជាអកុសល ចម្រើនតែខាងសេចក្តីទុក្ខ មានផលជាទុក្ខ អ្នកមិនត្រូវធ្វើអំពើ ដោយកាយ ដោយវាចា ឬ ដោយចិត្ត ដែលមានទំនងយ៉ាងនេះដោយដាច់ខាត។"

"ប្រសិនបើ កាយកម្ម វចីកម្ម ឬ មនោកម្ម នោះ មិន ប្រព្រឹត្តទៅដើម្បីបៀតបៀនបុគ្គលទាំងពីរចំណែក គឺខ្លួនឯង និង អ្នកដទៃផង កាយកម្ម វចីកម្ម ឬមនោកម្មនេះជាកុសល ចម្រើន តែខាងសេចក្តីសុខ មានផលជាសុខ។ ម្នាលរាហុល អ្នកត្រូវ ធ្វើអំពើ ដោយកាយ ដោយវាចា ឬដោយចិត្ត ដែលមានទំនង យ៉ាងនេះចុះ។ ម្នាលរាហុល ប្រសិនបើអ្នកកំពុងធ្វើ ឬបានធ្វើ អំពើ ដោយកាយ ដោយវាចា ឬដោយចិត្ត អ្នកត្រូវពិចារណា កាយកម្ម វចីកម្ម ឬមនោកម្មនោះ ដោយទំនងដូចគ្នា។ ប្រសិន បើវាប្រព្រឹត្តទៅដើម្បីបៀតបៀននឹងធ្វើឱ្យបុគ្គលណាមួយមានទុក្ខ វាជាអំពើមានទោស និងជាអកុសល ចម្រើនតែខាងសេចក្តីទុក្ខ មានផលជាទុក្ខ។ អ្នកត្រូវឈប់ធ្វើវា និងមិនធ្វើវាម្តងទៀតទេ។ ប្រសិនបើ វាមិនប្រព្រឹត្តទៅដើម្បីបៀតបៀតណាមួយទេ វាជា អំពើកុសល ចម្រើនតែខាងសេចក្តីសុខ មានផលជាសុខ ម្នាល រាហុល អ្នកត្រូវធ្វើអំពើមានទំនងយ៉ាងនេះឱ្យរឿយៗទៅចុះ"។





នេះគឺជាឱវាទត្រឹមត្រូវ និងល្អប្រសើរណាស់។ បើមនុស្ស គ្រប់រូបគោរពធ្វើតាមឱវាទនេះ មនុស្សលោកទាំងអស់អាចរស់ នៅយ៉ាងរីករាយជាមួយគ្នា ហើយសន្តិភាពពិតពលោកនឹងត្រូវ បង្កើតឡើងភ្លាមៗ។

**២. លទ្ធផល ២ យ៉ាង នៅក្នុងអំពើទាំងអស់**

អំពើជាអកុសល ចម្រើនតែសេចក្តីទុក្ខ មានផលជាទុក្ខ គឺ **ទុច្ចរិត១០** មាន អកុសលកាយកម្ម ៣ គឺការសម្លាប់សត្វ១ លួច ទ្រព្យគេ១ ការប្រព្រឹត្តខុសក្នុងកាម១។ អកុសលវចីកម្ម ៤ គឺការ និយាយកុហក១ ការនិយាយបង្ខូចបង្កាច់១ ការនិយាយ ពាក្យអាក្រក់១ ការនិយាយពាក្យរោយរាយឥតប្រយោជន៍១ ។ អកុសលមនោកម្ម ៣ គឺគម្រោងការចង់បានទ្រព្យអ្នកដទៃ១ គម្រោងការចង់ឱ្យអ្នកដទៃដល់នូវសេចក្តីវិនាសអាយុជីវិត និង ទ្រព្យសម្បត្តិ១ គំនិតយល់ខុស ហើយប្រកាន់ថាត្រូវ បដិសេធ កម្ម និងផលរបស់កម្ម ១ ។

អំពើជាអកុសលទាំងនេះ ប្រព្រឹត្តធ្វើឡើងដោយអកុសល ចិត្ត ហើយ អកុសលចិត្ត ច្រើនកោដិកើតរលត់ក្នុងពេលធ្វើ អកុសលកម្ម។ ចេតនាដែលសម្បយុត្តជាមួយអកុសលចិត្តទាំង

នេះ ហៅថា **អកុសលសហជាតកម្ម**។ ដោយសារកម្មទាំងឡាយនេះអកុសលកម្មត្រូវបានធ្វើហើយ អកុសលកម្មនេះឱ្យផលអាក្រក់។

ម្យ៉ាងទៀត នៅពេលអកុសលចិត្តខាងលើ និងសម្បយុត្តចេតនារលត់។ ចេតនាបានបន្សល់ទុកនូវថាមពលកម្មរបស់វានៅក្នុងក្រសែចិត្ត។ ថាមពលកម្មទាំងនេះឈ្មោះថា **អកុសល-នានក្ខណិកកម្ម**។ ថាមពលកម្មទាំងនេះត្រូវបានបញ្ជូនពីចិត្តមួយទៅចិត្តមួយទៀត ហើយថាមពលកម្មទាំងនេះនឹងនៅក្នុងភវង្គចិត្តអស់មួយជីវិត។ ជាងនេះទៅទៀត នៅពេលស្លាប់ ថាមពលកម្មទាំងនេះត្រូវបានបញ្ជូនទៅក្នុងក្រសែចិត្តនៃភពថ្មីនោះ។ ដូច្នេះថាមពលទាំងនេះ នឹងត្រូវបញ្ជូននៅក្នុងភវង្គចិត្ត ពីជាតិមួយទៅជាតិមួយទៀត ដោយឱ្យផលរបស់វានៅពេលណាដែលវាមានឱកាស។

ហេតុដូច្នេះ នៅពេលបុគ្គលធ្វើនូវអំពើជា អកុសល ណាមួយ បុគ្គលនឹងទទួលបាននូវផល ២ យ៉ាង គឺផលជាអកុសលនៃអកុសលសហជាតកម្ម និងផលធ្ងន់ធ្ងរនៃ អកុសលនានក្ខណិកកម្ម ។

អំពើជាកុសល ចម្រើនតែខាងសេចក្តីសុខ មានផលជា





សុខគឺ**សុចរិត១០**។ យើងអាចធ្វើអំពើជាកុសលទាំងនេះ ដោយចៀសវាងអំពើជាអកុសល ឬទុច្ចរិត ១០។

ជាតួយ៉ាង ប្រសិនបើ ចៀសវាងការសម្លាប់មូស ដែលខាំយើង ហើយទុកវាទៅដោយបំណងល្អ ទុកវាឱ្យរស់យ៉ាងសប្បាយរីករាយ សោភណកុសលចិត្ត រាប់កោដិកើតឡើង កំឡុងពេលនេះ។ ចេតនា សម្បយុត្តជាមួយកុសលចិត្តទាំងនេះ ឈ្មោះថា **កុសលសហជាតកម្ម** ។ ដោយសារកម្មទាំងនេះ អំពើជាកុសលដែលបានទុកឱ្យមូសទៅកាន់ទីសុវត្ថិភាព ត្រូវបានបំពេញ ហើយអំពើជាកុសលនេះនឹងឱ្យផលជាកុសល ដូចជាការទុកឱ្យមូសរស់នៅយ៉ាងរីករាយជាមួយអ្នកជាទីស្រឡាញ់របស់វា។

ម្យ៉ាងទៀត នៅពេល កុសលចិត្តខាងលើ និងសម្បយុត្តចេតនា រលត់ ចេតនាបានបន្សល់ទុកនូវថាមពលកម្មរបស់វានៅក្នុងក្រសែចិត្ត។ ថាមពលកម្មទាំងនេះឈ្មោះថា **កុសលនានក្ខ-ណិកកម្ម** ។ ថាមពលកម្មទាំងនេះ ត្រូវបានបញ្ជូននៅក្នុងក្រសែចិត្តនៃជាតិនេះ ក៏ដូចជានៅក្នុងក្រសែចិត្តនៃជាតិបន្តបន្ទាប់ទៀតដែរ ដោយឱ្យផលជាកុសលនៅពេលណាដែលវាមានឱកាស។

ផលនៃសហជាតកម្មភ្លាមៗ គឺឃើញជាក់ស្តែងនៅក្នុងបច្ចុប្បន្នជាតិ។ ជាឧទាហរណ៍ ប្រសិនបើ បុរសម្នាក់បានសម្លាប់

មនុស្សម្នាក់ មនុស្សនោះត្រូវស្លាប់យ៉ាងលំបាកវេទនា រួមជាមួយសេចក្តីភ័យខ្លាច ហើយប្រពន្ធ និងគ្រួសារនឹងភិតភ័យស្រឡាំងកាំង ដោយសេចក្តីទុក្ខ និងសេចក្តីសោកដ៏ធំធេង។ ពួកគេនឹងត្រូវរស់នៅក្នុងភាពក្រីក្រអស់មួយជីវិត។ ឃាតកអាចរត់គេចខ្លួន និងត្រូវរស់នៅក្នុងភាពភ័យខ្លាចគេចាប់ខ្លួន។ គាត់នឹងត្រូវគេចាប់ខ្លួនបាន កាត់ទោសនៅក្នុងតុលាការ នឹងត្រូវកាត់ទោសប្រហារជីវិត ឬត្រូវកាត់ទោសឱ្យជាប់ពន្ធនាគារអស់មួយជីវិត។

អំពើបុណ្យ អំពើជាកុសល រួមមាន ការធ្វើទាន ការរក្សាសីល និងការចម្រើនសមាធិភាវនា បន្ថែមលើកុសលកម្មបថ១០។ ប្រសិនបើ បុគ្គលបានដាក់បាត្រព្រះសង្ឃមួយស្លាបព្រា កុសលចិត្ត រាប់កោដិកើតឡើងក្នុងពេលកំពុងដាក់បាត្រ ហើយកុសលសហជាតកម្ម និងកុសលនានក្ខណិកកម្ម ក៏កើតឡើងក្នុងពេលដំណាលគ្នាដែរ។

ជាផលនៃ សហជាតកម្ម នៃការដាក់បាត្រចំពោះព្រះសង្ឃៗអាចឆាន់ចង្ហាន់បិណ្ឌបាតនោះយ៉ាងមនោរម្យ។ ជាផលនៃការប្រើប្រាស់ចង្ហាន់បិណ្ឌបាត ព្រះអង្គអាចមាន សុខភាពល្អ និងប្រកបដោយអាយុ (អាយុវែង) វណ្ណៈ (ពណ៌សម្បុរល្អ) សុខៈ(ការគង់នៅជាសុខ)ពលៈ(កម្លាំងមាំមួន) និងបដិភាណៈ





(បញ្ញាច្រើន) ដោយសារ ព្រះអង្គបានសិក្សារៀនសូត្រដោយល្អ។ នៅពេលព្រះសង្ឃរីករាយនឹងអានិសង្សទាំងប្រាំនេះ ទាយកអ្នកឱ្យនូវចង្ហាន់បិណ្ឌបាត ក៏នឹងទទួលបានអានិសង្ស ដូចគ្នាដែរនៅក្នុងជាតិជាច្រើន។ នៅពេល ព្រះសង្ឃក្លាយជាអ្នកចេះដឹងច្រើន (ពហុស្សូត) និងអាចសម្តែងព្រះធម៌ទេសនា អ្នកស្តាប់ជាច្រើននឹងទទួលបានអានិសង្សច្រើនអនេក ពីការយល់ដឹងព្រះធម៌នោះដែរ។

និន្នាការនៃផលរបស់កម្មប្រព្រឹត្តទៅដូចជារលកអង្កាញ់ៗនៅលើផ្ទៃទឹកបឹង ដែលកើតពីការធ្លាក់នៃដុំថ្ម ឬដូចសូរខ្ទរនៃសំឡេងរបស់យើងនៅឯតំបន់ភ្នំ ឬដូច **ច្បាប់ចលនា** របស់លោកញូវតុន នៅក្នុងរូបវិទ្យា "គ្រប់ចលនាទាំងអស់ មានប្រតិកម្មតបស្មើនឹងផ្ទុយគ្នា។"

ប្រសិនបើ យើងញញឹមដាក់អ្នកដទៃ គេនឹងញញឹមដាក់យើងវិញ។

ប្រសិនបើ យើងចងចញ្ចើមដាក់គេៗនឹងចងចញ្ចើមដាក់យើងវិញផងដែរ។

*អំពើអាក្រក់នឹងឱ្យផលអាក្រក់។*

*អំពើល្អនឹងឱ្យផលល្អ។*

*បុគ្គលអ្នកសាបព្រោះពូជណា តែងបានផលពីពូជនោះ។*

*(ព្រះពុទ្ធវចនៈ)*

បើបុគ្គលមានចិត្តត្រូវទោសប្រទូស្ត ហើយ ពោលក្តី ធ្វើក្តី នូវទុច្ចរិត ព្រោះទុច្ចរិតទាំងនោះ ទុក្ខរមែងជាប់តាមបុគ្គលនោះទៅ ដូចកង់រទេះវិលតាមដានជើងគោដែលកំពុងអូសទៅ។

*(គាថាធម្មបទ ១)*

បើបុគ្គលមានចិត្តជ្រះថ្លាហើយ ពោលក្តី ធ្វើក្តី នូវសុចរិត ព្រោះសុចរិតទាំងនោះ សុខរមែងជាប់តាមបុគ្គលនោះទៅ ដូចស្រមោលអន្ទោលតាមប្រាណ។

*(គាថាធម្មបទ២)*

## ៣. របៀបនានក្ខណិកកម្មឱ្យផល

នានក្ខណិកកម្ម ប្រៀបដូចគ្រាប់ពូជរុក្ខជាតិ ហើយរបៀបកម្មនេះ ឱ្យផលប្រៀបដូចរបៀបគ្រាប់ពូជរុក្ខជាតិ បង្កើតកូនរុក្ខជាតិថ្មី។

***សទិសំ បាកំ ជនេតិ។***

*កម្មនឹងឱ្យផលដូចនឹងទង្វើរបស់កម្មនោះ។*





***យាទិសំ វបតេ ពីជំ, តាទិសំ ហរតេ ផលំ។***

*អ្នកសាបព្រោះនូវពូជណា អ្នកនឹងបានផ្លែផ្កានៃពូជនោះ។*

***កល្យាណការី កល្យាណំ បាបការី ច បាបកំ។***

*អ្នកធ្វើកម្មល្អ រមែងបានផលល្អ។*

*អ្នកធ្វើកម្មអាក្រក់ រមែងបានផលអាក្រក់។*

### របៀបកម្មឱ្យផលដូចនឹងទង្វើរបស់កម្មនោះ

កម្មឱ្យផលដូចគ្នានឹងរបៀប ដែលកម្មនេះបានត្រូវធ្វើ។ របៀបឱ្យផលដោយកម្មបែបនេះហៅថា **ច្បាប់កម្ម** (កម្មនិយាម)។ និទានខាងក្រោមនឹងបង្ហាញឱ្យឃើញច្បាប់នេះ។

សម័យមួយ ព្រះមានព្រះភាគគង់នៅវត្តជេតពន មានបុរស ៣ នាក់បានចូលទៅរកព្រះអង្គ ស្ទើរតែដំណាលគ្នា។

បុរសទី១បានក្រាបទូលថា "បពិត្រព្រះអង្គដ៏ចម្រើន ពេលខ្ញុំព្រះអង្គ បានឆ្លងកាត់ភូមិមួយ នៅជិតក្លោងទ្វារចូលរាជធានីតាមផ្លូវចូលទៅកាន់វត្តជេតពន ផ្ទះមួយនៅក្នុងភូមិត្រូវភ្លើងឆេះ។ ស្មៅចិញ្ចៀនសម្រាប់ដាក់នៅក្នុងផើងនៅលើផ្ទះ ត្រូវភ្លើងឆេះ។ វាបានហោះឡើងដោយកម្លាំងភ្លើងទៅលើអាកាស ហើយបាន

ពាក់កសត្វក្អែកមួយ កំពុងហើរខ្ពស់នៅលើអាកាស។ សត្វក្អែកបានត្រូវភ្លើងឆេះស្លាប់ទៅ។"

បុរសទី២ បានក្រាបទូលថា "បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានទើបត្រឡប់មកពីស្រុកនាយតាមសំពៅ។ អ្នកដំណើរនៅលើសំពៅមានប្រមាណ ៧០០ នាក់បានធ្វើដំណើរចេញពីកំពង់ ហើយបានជាប់គាំងនៅកណ្ដាលមហាសមុទ្រ។ សំពៅមិនអាចទៅមុខបានទេ ទោះបីធ្វើតាមមធ្យោបាយយ៉ាងណាក៏ដោយ។ បន្ទាប់មក នាយសំពៅបានប្រាប់អ្នកនៅលើសំពៅថា នៅលើសំពៅមានអ្នកបានប្រព្រឹត្តបាបកម្មធ្ងន់ធ្ងរ។ អ្នកនោះនឹងត្រូវរកឃើញដោយការផ្សងសំណាងចាប់ស្លាក និងត្រូវទម្លាក់ទៅក្នុងសមុទ្រ ដើម្បីសង្គ្រោះជីវិតអ្នកដទៃទៀត។

"ដូច្នេះ ពួកគេបានយល់ព្រមចាប់ស្លាក។ គឺប្រពន្ធរបស់នាយសំពៅ ជាអ្នកចាប់ត្រូវស្លាកសំណាងអាក្រក់។ ដោយសារនាងមើលទៅស្ងប់ស្ងៀម សាមញ្ញ ស្លូតបូត និងស្រស់ស្អាត អ្នកនៅលើសំពៅមានសេចក្ដីអាណិតអាសូរនាង ហើយបានស្នើឱ្យចាប់ស្លាកម្ដងទៀត។ នាងក៏បានចាប់ត្រូវស្លាកសំណាងអាក្រក់ជាលើកទី២ និងទី៣ទៀត។ ដូច្នេះ នាងត្រូវចងនៅកដោយឆ្នាំងដាក់ដីខ្សាច់ ហើយត្រូវទម្លាក់ទៅក្នុងមហាសមុទ្រ។ សំពៅក៏បាន





ទៅមុខភ្លាមៗ។ អ្នកនៅលើសំពៅក៏បានទៅដល់គោលដៅប្រកបរបរជួញដូរ និងបានត្រឡប់មកវិញ។"

បុរសទី៣ ក៏បានក្រាបទូលរឿងរបស់ខ្លួនថា "បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានឆ្លងកាត់ភ្នំតាមផ្លូវកាត់ព្រៃ។ ភិក្ខុ ៧ អង្គបាននិមន្តចូលទៅក្នុងរូងភ្នំ ដើម្បីសម្រាកព្រះកាយ។ ប៉ុន្តែដុំថ្មធំមួយស្រាប់តែរមៀលចុះពីលើកំពូលភ្នំ ហើយបានមកបិទមាត់រូងភ្នំ។ ភិក្ខុទាំង៧ អង្គ មិនអាចរុញថ្មចេញ ហើយក៏មិនអាចសុំឱ្យគេជួយបានដែរ។ ដូច្នេះ ភិក្ខុទាំង ៧ អង្គត្រូវគង់នៅក្នុងរូងភ្នំអស់ ៧ ថ្ងៃ ដោយមិនមានចង្ហាន់ និងទឹកសម្រាប់ឆាន់។ នៅថ្ងៃទី ៨ ដុំថ្ម ក៏បានរមៀលចេញដោយខ្លួនឯង ហើយភិក្ខុទាំងអស់ ក៏បាននិមន្តចេញមកក្រៅ"។

បុរសទាំង ៣ ក៏បានទូលសួរព្រះពុទ្ធពីបុព្វកម្ម នៃអ្នកទាំងនោះ នៅក្នុងហេតុការណ៍ ដ៏ចម្លែកនោះ។

**"សព្វេ សត្តា កម្មស្សកា កម្មំ សត្តេ វិភជតិ"**

"សត្វទាំងឡាយមានកម្មជារបស់ខ្លួន។ ម្នាលឧបាសកទាំងឡាយ កុសលកម្ម និង អកុសលកម្មនេះ ជាមេចំណែកចែកសត្វឱ្យអាក្រក់ឱ្យល្អផ្សេងគ្នា។"

ដោយបុរសទាំង ៣ មិនយល់នូវពុទ្ធភាសិតនេះ ពួកគេក៏បានអារាធនាព្រះអង្គឱ្យសម្តែងជាសេចក្តីពិស្តារ។

“ ម្នាលឧបាសកទាំងឡាយ សត្វក្អែកកាលពីជាតិមុនជាអ្នកធ្វើស្រែចំការម្នាក់។ អ្នកចំការនោះបានខឹងនឹងគោរបស់គាត់ដែលគាត់មិនអាចបង្គាប់វាឱ្យធ្វើការបាន។ អ្នកចំការ ក៏បានចងចំបើងនៅករបស់គោ ហើយបានដុតភ្លើង និងបានដោះលែងគោនោះទៅ។ គោត្រូវភ្លើងឆេះយ៉ាងខ្លាំង វាក៏បានរត់ហើយរត់ទៀត។ គោក៏បានស្លាប់ទៅ។ ដោយសារអកុសលកម្មនេះ ស្មៅចិញ្ចៀនដែលភ្លើងកំពុងឆេះបានហោះឡើងទៅលើអាកាស ហើយបានពាក់កសត្វក្អែក ហើយបានដុតសត្វក្អែករហូតដល់ស្លាប់។”

“ប្រពន្ធរបស់នាយសំពៅ កាលពីជាតិមុនជាស្រីក្រមុំម្នាក់មានរូបស្រស់ស្អាត នៅក្នុងភូមិ។ ប្តីរបស់នាងបានស្លាប់ ហើយបានកើតជាឆ្កែ។ ឆ្កែនោះក៏បានដើរតាមនាង ទោះនាងបានទៅទីណាក៏ដោយ។ កម្លោះៗនៅក្នុងភូមិបាននិយាយលេងសើចជាមួយនាងថា នាងកំពុងទៅប្រមាញ់សត្វជាមួយឆ្កែរបស់នាង និងបានសាច់ជាច្រើនឱ្យពួកគេ។ នាងខ្មាស់គេជាខ្លាំង។ ក្រោយមកពេលនាងចេញទៅក្រៅ នាងបានព្យាយាមបណ្តេញឆ្កែចេញកុំឱ្យតាមនាង ប៉ុន្តែ ឆ្កែមិនចេញ។ នាងបានខឹងយ៉ាងខ្លាំង។ នាងបាន





ចងកឆ្កែនឹងផ្ទាំងដាក់ដីខ្សាច់ ហើយបានបោះទម្លាក់ទៅក្នុងប្រឡាយ។ នាងបានជួបវាសនាដូចគ្នា នៅពេលនាងជាប្រពន្ធរបស់នាយសំពៅ នៅជាតិបន្ទាប់របស់នាង។”

“បពិត្រព្រះអង្គដ៏ចម្រើន ហេតុអ្វីបានជាភិក្ខុជាប់នៅក្នុងរូងភ្នំ ?”

“ភិក្ខុទាំងនោះកាលពីជាតិមុនជាអ្នកគង្វាលគោ។ ល្ងាចមួយ នៅពេលពួកគេដេញគោមកផ្ទះវិញ ពួកគេបានឃើញសត្វត្រកួតមួយ បានចូលទៅក្នុងដំបូក។ ដោយសារពួកគេមិនមានពេលចាប់សត្វត្រកួតនោះ ជាបណ្តោះអាសន្ន ពួកគេបានបិទមាត់ដំបូកដោយមែកឈើ ដោយមានបំណងចាប់សត្វត្រកួតនោះនៅថ្ងៃក្រោយ។”

“នៅថ្ងៃបន្ទាប់ ពួកគេបានដេញគោទៅកន្លែងមានស្មៅថ្មីអស់មួយសប្តាហ៍។ ពួកគេបានត្រឡប់មកកន្លែងមានស្មៅចាស់នៅថ្ងៃទី៨ ។ នៅពេលពួកគេឃើញដំបូក ពួកគេនឹកឃើញសត្វត្រកួត។ ពួកគេបានយកមែកឈើចេញពីមាត់រូងដំបូក ហើយរង់ចាំវាយសត្វត្រកួតនឹងដំបង។ ប៉ុន្តែដោយសារ សត្វត្រកួតអត់ចំណីមួយសប្តាហ៍មក វាស្គមកំព្រឹង និងឥតកម្លាំង ហើយពួកគេ

មានសេចក្ដីអាណិតអាសូរ ក៏បានដោះលែងទៅ។ ដូច្នេះ ភិក្ខុ ក៏ត្រូវអត់អាហារអស់រយៈពេល ៧ ថ្ងៃផងដែរ នៅក្នុងរូងភ្នំ។

*(និទានធម្មបទ ភាគ ២ រឿងតយោជន)*

### គ្មានកន្លែងលាក់ពួនទេ

*"បុគ្គលអ្នកធ្វើបាបកម្ម ទោះបីចូលទៅពួដ៏អាកាស ក្នុងកណ្ដាលសមុទ្រ កាន់ចន្លោះភ្នំទាំងឡាយ ក៏មិនគប្បីរួចចាកបាបកម្ម ព្រោះទីកន្លែងលើផែនដី ដែលបុគ្គលឋិតនៅហើយ គប្បីរួចចាកបាបកម្មបាននោះមិនដែលមានឡើយ។"*

*(គាថាធម្មបទ ១២៧)*

### ៤. កម្មឱ្យផលរាប់ពាន់លានដង

មនុស្សភាគច្រើនកត់សម្គាល់ទៅលើផលភ្លាមរបស់កម្ម។ ពួកគេមិនដឹងថា នានក្ខណិកកម្ម អាចឱ្យផលរាប់កោដិដង នៅជាតិបន្ទាប់ៗនោះទេ។ ដោយចិត្តកើត និង រលត់ជាង មួយរយកោដិ ក្នុងមួយផ្ទាត់ម្រាមដៃ ឬមួយពព្រិចភ្នែក កុសលកម្មរាប់កោដិ ត្រូវទុកនៅក្នុងក្រសែចិត្ត នៅពេលកុសលកម្មត្រូវបានធ្វើ។ កម្មទាំងនេះអាចឱ្យផលជាកុសលច្រើនជាងកោដិដង។





*ដូចសុភាសិតថា "បើយើងធ្វើទានច្រើន ដូចគ្រាប់ពោធិ៍នៅលើដើម យើងនឹងទទួលបានផលច្រើន ជាងគ្រាប់ពោធិ៍ដែលនៅលើដើមទៅទៀត។"*

ដូចគ្នាដែរ ការធ្វើអំពើជាអកុសល អកុសលកម្មរាប់កោដិត្រូវបានផ្ទុកនៅក្នុងក្រសែចិត្ត។ អកុសលកម្មមានកម្លាំងនីមួយៗអាចតាក់តែង អបាយភូមិ ឱ្យកើតឡើងបាន។ ដូច្នេះ បុគ្គលអាចបដិសន្ធិនៅក្នុងអបាយភូមិរាប់លានដង ដោយបានធ្វើអំពើអកុសលណាមួយ។ ដោយសារផលនៃអំពើអកុសលធ្ងន់ធ្ងរ និងគួរឱ្យរន្ធត់តក់ស្លុត យើងគប្បីប្រុងប្រយ័ត្នជៀសវាងអំពើអាក្រក់ និងធ្វើអំពើល្អ អំពើជាកុសល។

ក៏ព្រោះអំពើកុសលឱ្យផលជាកុសល ច្រើនជាងកោដិដង កុសលកម្មជាទីពឹងអាស្រ័យបាន។ ដោយកម្មឱ្យផលដូចនឹងទង្វើរបស់កម្មនោះ ប្រសិនបើបុគ្គលមានប្រាថ្នាចង់ក្លាយជាអ្នកមានទ្រព្យគ្រប់ៗជាតិបន្តបន្ទាប់ បុគ្គលគប្បីឱ្យទាន(ធ្វើបុណ្យ) ឱ្យបានច្រើនតាមដែលអាចផ្ដត់ផ្គង់ និង ឱ្យបានរឿយៗតាមលទ្ធភាព។ ប្រសិនបើ បុគ្គលមានប្រាថ្នាចង់រស់នៅមាន សុភមង្គល នៅក្នុងជាតិជាច្រើនបន្តបន្ទាប់ បុគ្គលគប្បីរក្សាសីលឱ្យបានខ្ជាប់ខ្ជួន។ បុគ្គលព្រមឱ្យសព្វសត្វទាំងអស់រស់នៅប្រកប

ដោយសុភមង្គល ដោយមិនមានភាពអមិត្ត និងកំហឹង ដោយរក្សាសីលឱ្យបរិសុទ្ធ។ ដូច្នេះបុគ្គលនឹងទទួលបានអានិសង្សដូចគ្នាច្រើនជាតិ។

ប្រសិនបើ បុគ្គលមានប្រាថ្នាចង់មានចំណេះដឹងជ្រៅជ្រះ និងមានបញ្ញាច្រើន នៅក្នុងជាតិជាច្រើនបន្តបន្ទាប់ បុគ្គលគប្បីសិក្សាព្រះត្រៃបិដក និងអក្សរសាស្ត្រផ្នែកពុទ្ធនិយម ហើយនឹងចម្រើនសមាធិភាវនា។ ម្យ៉ាងទៀតនៅពេលណាក៏ដោយ បុគ្គលធ្វើបុណ្យ បុគ្គលគប្បីធ្វើសេចក្តីប្រាថ្នាថា "សូមឱ្យអាត្មាអញក្លាយជាបុគ្គលអ្នកមានបញ្ញាច្រើន។" ដើម្បីសម្រេចការរួចស្រឡះចាកវដ្តទុក្ខ បុគ្គលគប្បីមានប្រាថ្នាថា "សូមឱ្យអានិសង្សនៃបុណ្យនេះជាបច្ច័យជួយឧបត្ថម្ភអាត្មាអញ ឱ្យបានសម្រេចព្រះនិព្វាន ក្នុងអនាគតដ៏ឆាប់។"

ប្រសិនបើ មនុស្សជាទីស្រឡាញ់ មិត្តភ័ក្តិ និងសាច់ញាតិធ្វើបុណ្យដូចគ្នារួមគ្នា ដោយមានប្រាថ្នាចង់ជួបគ្នាទៀត ក្នុងអនាគតច្រើនជាតិ ការប្រាថ្នារបស់ពួកគេនឹងបានសម្រេច។

**តើការសម្លាប់សត្វមានទោសដែរឬទេ?**

បើតាមទ្រឹស្តី ការបង្កើតសត្វទាំងឡាយ ត្រូវបានបង្កើតសម្រាប់ការប្រើប្រាស់របស់មនុស្ស ហើយមនុស្សអាចសម្លាប់សត្វ





និងប្រើប្រាស់សាច់ជាអាហារ។ មិនមានបាបទេ ក្នុងការសម្លាប់សត្វ។

អ្នកខ្លះនិយាយថា សត្វមិនមានបញ្ញា ដូច្នេះ មិនមានបាបទេ ក្នុងការសម្លាប់សត្វ។ ប្រការនេះមិនពិតទេ សូម្បីតែសត្វតូចៗដូចជាស្រមោច ក៏មានបញ្ញាដែរ។ ពួកគេដឹងពីរបៀបរកអាហាររបៀបផ្តល់ព័ត៌មានដល់គូកនរបស់ពួកគេ ឱ្យមកកន្លែងដែលមានអាហារ និងរបៀបរក្សាទុកអាហារនៅក្រោមដី។

ពីព្រោះសព្វសត្វទាំងអស់មានបញ្ញា សព្វសត្វទាំងអស់មានខ្លួនជាទីស្រឡាញ់ជាងគេបំផុត ហើយសព្វសត្វទាំងអស់ភ័យខ្លាចសេចក្តីទុក្ខ និងសេចក្តីស្លាប់។ ដោយសារម្នាក់ៗភ័យខ្លាចសេចក្តីស្លាប់ បើម្នាក់សម្លាប់ ម្នាក់ទៀតយ៉ាងឃោរឃៅ មិនមានមេត្តាចិត្ត តើវាយុត្តិធម៌ និងត្រឹមត្រូវទេ ?

*សត្វទាំងឡាយគ្រប់ប្រាណ តែងតក់ស្លុតនឹងអាជ្ញា ព្រោះថាជីវិតជាទីស្រឡាញ់របស់សត្វទាំងពួង បុគ្គលគួរធ្វើខ្លួនឱ្យជាឧបមា ហើយមិនគួរប្រហារដោយខ្លួនឯង មិនគួរប្រើគេឱ្យប្រហារឡើយ។*

*(គាថាធម្មបទ ១៣០)*

ដោយសារមនុស្សគ្រប់រូបសុទ្ធតែបានឆ្លងកាត់ជាតិរាប់មិនអស់នៅក្នុងសង្សារវដ្តដ៏វែងឆ្ងាយ យើងខ្លួនឯងក៏បានកើតជាសត្វច្រើនជាតិផងដែរ។ ចូរគ្រាន់តែនឹកស្រមៃថា តើយើងមានអារម្មណ៍គួរឱ្យខ្លាចប៉ុណ្ណា ដែលគេធ្វើទារុណកម្ម និងសម្លាប់យើង។ ក្រៅពីនេះ សត្វជាច្រើននៅជុំវិញយើងអាចជា ឪពុកម្តាយ កូនប្រុស កូនស្រី ឬសាច់ញាតិរបស់យើង នៅក្នុងអតីតជាតិផងដែរ។

យើងបានអានរឿងស្រីក្រមុំនៅក្នុងភូមិ ដែលប្តីរបស់នាងបានស្លាប់ ហើយបានកើតជា សត្វសុនខ តាមនាងគ្រប់ទីកន្លែងដែលនាងបានទៅ។ ដោយសារនាងមិនបានដឹងរឿងនេះ នាងបានសម្លាប់សត្វសុនខតូចយ៉ាងឃោរឃៅ ដោយត្រូវបានចងកនឹងផ្ទាំងដាក់ដីខ្សាច់ រួចទម្លាក់ទៅក្នុងទឹក។

ព្រាហ្មណ៍ តោទេយ្យ ជាអ្នកមានទ្រព្យច្រើន ប៉ុន្តែ មិនដែលលះបង់ទ្រព្យធ្វើជាទានណាមួយទេ ក្រោយពេលស្លាប់ បានកើតជាសត្វសុនខ នៅក្នុងផ្ទះរបស់គាត់។ សុនខបានចាំជាតិ និងស្រឡាញ់ជាប់ចិត្តនឹងកូនប្រុសរបស់ខ្លួនកាលពីជាតិមុន ឈ្មោះ សុភៈ ខ្លាំងណាស់។

ច្បាប់ធម្មជាតិរបស់កម្ម (កម្មនិយាម) បានបង្ហាញយ៉ាងច្បាស់ថា ការសម្លាប់សត្វតិរច្ឆាន គឺជាអំពើបាបគួរឱ្យខ្លាច។





នៅក្នុងការសម្លាប់សត្វតិរច្ឆាន ឬសត្វមានជីវិតណាមួយ អកុសលទោសមូលចិត្តរាប់កោដិកើត និងរលត់។ ដូច្នេះ អកុសល-សហជាតកម្ម រាប់កោដិ និងអកុសលនានក្ខណិកកម្ម រាប់កោដិត្រូវបានបង្កើតឡើង។ កម្មទាំងនេះនឹងឱ្យផលដូចគ្នា នឹងទង្វើសមស្របរបស់វា។ នៅក្នុងសាសនាព្រះពុទ្ធសមណគោតម **ធម្ម-ទិន្នាថេរី** ជាឯតទគ្គៈផ្នែកខាងសម្តែងធម៌ ប៉ែកខាងភិក្ខុនី។ ភិក្ខុនីធម្មទិន្នា ជាព្រះអរហន្តី និងមានអភិញ្ញាអាចចាំជាតិបាន។

ធម្មទិន្នាថេរី បានសម្តែងប្រាប់សព្រហ្មចារិនីថា ព្រះនាងធ្លាប់ជាភរិយារបស់ព្រាហ្មណ៍ ក្នុងជាតិមួយក្នុងអតីតជាតិ។ ថ្ងៃមួយមិត្តជិតស្និទ្ធ របស់ព្រាហ្មណ៍ជាស្វាមីបានមកលេងផ្ទះ ហើយស្វាមីរបស់នាង បានប្រាប់ឱ្យនាងចំអិនអាហារភោជនល្អៗ។ ថ្ងៃនោះនាងមិនអាចរកទិញសាច់មកពីផ្សារបានទេ។ នាងបានសម្លាប់សត្វចៀមតូចមួយក្បាលនៅផ្ទះរបស់នាង ដោយកាត់ករបស់វា។

ស្វាមីរបស់នាង និងមិត្តរបស់គាត់បានសរសើរនាង ដែលបានចំអិនអាហារមានរសជាតិឆ្ងាញ់។ ប៉ុន្តែ នៅពេលនាងស្លាប់ទៅ អកុសលកម្ម នៃការសម្លាប់កូនចៀមបានបញ្ជូននាង ឱ្យទៅកើតក្នុងនរក ដែលនាងត្រូវភ្លើងឆេះ និងទទួលទារុណកម្ម អស់រាប់ពាន់ឆ្នាំ។

នៅពេលនាងរួចចាកពីនរក នាងបានកើតជាសត្វតិរច្ឆានច្រើនជាតិ ស្មើនឹងរោមចៀម ដែលនាងបានសម្លាប់ ហើយនៅក្នុងជាតិនីមួយៗ នាងបានត្រូវគេសម្លាប់ដោយកាត់ក។

នាងបានសម្លាប់តែកូនចៀមមួយក្បាលទេ។ នាងបានត្រូវគេសម្លាប់ច្រើនដងរាប់មិនអស់ ដូចគ្នានឹងនាងបានសម្លាប់កូនចៀមអ៊ីចឹងដែរ។ នាង ក៏ត្រូវទទួលរងទុក្ខយ៉ាងសម្បើមនៅក្នុងនរកអស់រាប់ពាន់ឆ្នាំផងដែរ។ ឱ ! ផលនៃអកុសលកម្មអីក៏គួរឱ្យខ្លាចម្ល៉េះទេ!

## ស្ត្រីមានរូបឆោមស្រស់ស្អាតនៅក្រុងវេសាលី

ក្នុងសាសនាព្រះពុទ្ធសមណគោតម ស្រីក្រមុំ មានសម្រស់ស្រស់ស្អាតម្នាក់បានកើតក្នុងឧបបាតិកកំណើត នៅចន្លោះមែកស្វាយមួយ ក្នុងអម្ពឧទ្យានរបស់ពួកស្ដេចលិច្ឆវី។ នាងមានឈ្មោះថា **អម្ពបាលី** ដោយសារនាងបានកើតនៅចន្លោះមែកស្វាយ។

អ្នកថែឧទ្យានបានស្លៀកសំលៀកបំពាក់ឱ្យនាង ហើយនាំនាងទៅថ្វាយពួកស្ដេចលិច្ឆវី។ ពួកស្ដេចលិច្ឆវីចូលចិត្តនាង និងចង់បាននាងគ្រប់ៗគ្នា។ ប៉ុន្តែ ដោយសារនាងមិនអាចចែកឱ្យទៅរាជបុត្រណាមួយបាន នាងបានត្រូវតែងតាំងជាស្រីផ្កាមាស។ នាងបានទទួលតម្លៃខ្លួនខ្ពស់។ ដូច្នេះ នាងបានក្លាយជាអ្នកមាន





ទ្រព្យសម្បត្តិ។ សម្រស់ស្រស់ស្អាតខុសពីធម្មតា និងភាពស្ដុកស្ដម្ភរបស់នាង គឺជាផលបុណ្យក្នុងអតីតជាតិដែលនាងបានធ្វើ។ ជាស្រីផ្កាមាសគឺជាផលនៃបាបកម្មរបស់នាង។ យើងនឹងសិក្សាពីកម្មទាំងនេះបន្តិចទៀតនេះ។

កាលព្រះបាទ ពិម្ពិសារ នៅក្មេង ព្រះអង្គបានទៅរកនាងអម្ពបាលី ជាអ្នកដែលព្រះអង្គមិនធ្លាប់ស្គាល់ ហើយបាននៅជាមួយនាងបីបួនថ្ងៃ។ នាងមានផ្ទៃពោះ ហើយបានប្រសូត្រកូនប្រុសមួយ។ នៅពេលកូនប្រុសនេះធំឡើងបានបួសជាភិក្ខុ។

អម្ពបាលី បានថ្វាយអម្ពឧទ្យានរបស់នាងចំពោះព្រះពុទ្ធនិងព្រះភិក្ខុសង្ឃ។ នៅពេលនាងចាស់ នាងបានស្ដាប់ព្រះធម៌ដែលភិក្ខុជាកូនប្រុសរបស់នាងបានសម្ដែង ហើយនាងបានបួសជាភិក្ខុនី។ នាងបានចម្រើនសមាធិ ប្រៀបធៀបរាងកាយចាស់ជរារបស់ព្រះនាងជាមួយរាងកាយស្រស់ស្អាតរបស់ព្រះនាង កាលវ័យនៅក្មេង។ ព្រះនាងបានសម្រេចការត្រាស់ដឹងជាព្រះអរហន្តីព្រមទាំងអភិញ្ញា។

ព្រះនាង បានសម្ដែងប្រាប់សព្រហ្មចារិនីទាំងឡាយរបស់ព្រះនាងថា ព្រះនាងបានជួបព្រះពុទ្ធ ៤ ព្រះអង្គ។ ក្នុងសាសនាព្រះពុទ្ធ ផុស្សៈ ព្រះនាងជាប្អូនស្រីរបស់ព្រះមហាមុនី។ ព្រះនាង

បានថ្វាយមហាទានចំពោះព្រះពុទ្ធ និងសាវ័ក ហើយបានប្រាថ្នារូបសម្បត្តិ។ នោះគឺជាកម្មដែលបានធ្វើឱ្យ អម្ពបាលី មានរូបសម្បត្តិស្រស់ស្អាតខុសពីធម្មតា។

ក្នុងសាសនាព្រះពុទ្ធ សិខី នាងបានបួសជាភិក្ខុនី មានវ័យនៅក្មេង។ ល្ងាចមួយ ព្រះនាងបានតាមភិក្ខុនីដទៃទៀតទៅថ្វាយបង្គំព្រះចេតីយ៍ ហើយបានដើរប្រទក្សិណព្រះចេតីយ៍។ ព្រះនាងបានជាន់លើទឹកមាត់មានស្លេស្ម។ ភ្លាមៗ ព្រះនាងបានខឹងជេរផ្ដាសាថា "តើស្រីផ្កាមាសណាបានស្ដោះទឹកមាត់នេះ?"

គ្មាននរណាម្នាក់បានកត់សម្គាល់ការជេរផ្ដាសារបស់ព្រះនាងទេ។ ដូច្នេះ វាហាក់ដូចជា ព្រះនាងមិនបានជេរផ្ដាសានរណាម្នាក់ទេ។ ប៉ុន្តែ គឺព្រះអរហន្តីមានវ័យចាស់មួយអង្គ ជាអ្នកបានស្ដោះទឹកមាត់មានស្លេស្ម។ ដោយសារព្រះអរហន្តីមានវ័យចាស់ ព្រះនាងមិនបានដឹងថា ព្រះនាងបានស្ដោះទឹកមាត់ នៅពេលព្រះនាងបានកណ្ដាស់នោះទេ។

ដូច្នេះ អម្ពបាលី បានប្រព្រឹត្តទោសធ្ងន់ធ្ងរប្រឆាំងព្រះអរហន្តី ដោយបានហៅព្រះនាងថា ស្រីផ្កាមាស។ ចំពោះបាបកម្មដ៏ឃោរឃៅនេះ នាងបានកើតនៅក្នុងនរក នៅពេលនាងស្លាប់ជំនួសដោយកុសលកម្មជាច្រើន ដែលនាងបានធ្វើនៅក្នុងជាតិនោះ។





បន្ទាប់ពីត្រូវបានទទួលរងទារុណកម្មរាប់ពាន់ឆ្នាំនៅក្នុងនរក បានមកកើតជាមនុស្សជាស្រីផ្កាមាសអស់ ១០ ពាន់ជាតិ។

ក្នុងសាសនាព្រះពុទ្ធ កស្សបៈ នាងបានបួសជាភិក្ខុនី ម្ដងទៀត។ ព្រះនាងបានបដិបត្តិត្រៃសិក្ខា ហើយបានប្រាថ្នាក្នុងឧបបាតិកកំណើត។ ដូច្នេះ នាងបានកើតក្នុងឧបបាតិកកំណើត ក្នុងបច្ឆិមភពជា អម្ពបាលី។ ដោយព្រះនាងបានសម្រេចការរួចចាកសង្សារវដ្តក្នុងសាសនាព្រះពុទ្ធសមណគោតម សេចក្ដីទុក្ខទាំងអស់របស់ព្រះនាងអស់ហើយ។

*(ថេរីអបទាន,២. ២៩៥-២៩៦)*

ផលមិនជាទីពេញចិត្តនៃអកុសលកម្ម ដែលកើតឡើងពីសម្ដីអាក្រក់គឺធ្ងន់ធ្ងរ និងគួរឱ្យតក់ស្លុត។ បុគ្គលគប្បីប្រុងប្រយ័ត្នជានិច្ច កុំប្រព្រឹត្តអកុសលវចីកម្ម។

## ដើម្បីរុងរឿងគ្រប់ៗជាតិបន្តបន្ទាប់

ដោយសារអ្នកវិទ្យាសាស្ត្រប្រើច្បាប់រូបធាតុធម្មជាតិ ដើម្បីបង្កើតអព្ភូតហេតុ ដូចជា អវកាសយានលឿនជាងសំឡេង និងប្រព័ន្ធគមនាគមន៍ ផ្កាយរណបយ៉ាងណា បុគ្គលទៀងត្រង់ ក៏អាចប្រើ ច្បាប់កម្មធម្មជាតិ ដើម្បីរុងរឿងគ្រប់ៗជាតិបន្តបន្ទាប់ដែរ។

នៅក្នុងបច្ចុប្បន្នជាតិ អ្នកទាំងឡាយណាបានសន្សំប្រាក់

ច្រើន អាចដាក់នៅក្នុងធនាគារ ហើយរស់នៅបន្តយ៉ាងសប្បាយរីករាយជាមួយការប្រាក់បានមកពីធនាគារ។ ប៉ុន្តែ ពួកគេមិនអាចយកលុយរបស់ពួកគេទៅជាមួយពួកគេ ទៅជាតិក្រោយបានទេ។

អានិសង្សទទួលបានពីកុសលកម្មនៃការធ្វើទាន គឺមួយកោដិដង ច្រើនជាងការប្រាក់ ដែលផ្តល់ឱ្យដោយធនាគារ។ កុសលកម្មនៃការរក្សាសីលគឺខ្លាំងជាងកុសលកម្មនៃការធ្វើទាន។ បុគ្គលអ្នកមានសីល ដែលបានរក្សាសីលបរិសុទ្ធអស់មួយជីវិត ដោយមិនបានធ្វើទុក្ខទោសដល់សត្វមានជីវិត នឹងរស់នៅយ៉ាងសប្បាយរីករាយអស់អសង្ខេយ្យជាតិ ក្នុងអនាគត។

កុសលកម្ម នៃការរក្សាសីល នឹងជាបច្ច័យញ៉ាំងសុគតិបដិសន្ធិ នៅក្នុងឋាន មនុស្ស ឬទេវតា ម្តងហើយម្តងទៀត រីឯកុសលកម្ម នៃការធ្វើទាន នឹងផ្តល់ឱ្យគ្រប់ជាតិបន្តបន្ទាប់ នូវទ្រព្យសម្បត្តិ និងភាពថ្កុំថ្កើន។

បុគ្គលអ្នកបានយកត្រៃសរណគមន៍ជាទីពឹងទីរលឹក និងគោរពបូជាចំពោះព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃ ពេញមួយជីវិត នឹងរីករាយជាមួយបដិសន្ធិក្នុងសុគតិភពរាប់មិនអស់ ដោយមិនបានបដិសន្ធិនៅក្នុងអបាយភូមិសូម្បីតែមួយជាតិ និងទីបំផុតរួចចាកសេចក្តីទុក្ខទាំងពួង ដោយគ្រាន់តែយកត្រៃសរណគមន៍ ជា





ទីពឹងទីរលឹក។ បុគ្គលបែបហ្នឹងគឺ **ព្រះសរណគមនត្ថេរ** ជាសាវ័ករបស់ព្រះពុទ្ធសមណគោតម។

នៅក្នុងអតីតជាតិ ក្នុងសាសនាព្រះពុទ្ធ **អនោមទស្សី** ព្រះសរណគមនត្ថេរ បានកើតក្នុងត្រកូលអ្នកក្រីក្រ ជាអ្នកបម្រើមាតាបិតាដែលមាតាបិតាលោកខ្វាក់ មួយអសង្ខេយ្យ មួយសែនកប្បកន្លងទៅហើយ។ លោកមិនអាចទទួលត្រៃសរណគមន៍ពីព្រះពុទ្ធបាន។ ប៉ុន្តែលោកបានទទួលត្រៃសរណគមន៍ ពីសំណាក់អគ្គសាវ័ករបស់ព្រះអង្គឈ្មោះ **និសភៈ** ហើយបានរក្សាសរណគមន៍ឱ្យពេញលេញអស់មួយជីវិត។ ដូច្នេះ លោកបានចម្រើនកុសលកម្មច្រើនកោដិ។

ដោយសារកុសលកម្មនេះ នៅក្នុងជាតិមួយចាប់ពីជាតិបន្ទាប់មក រហូតដល់បច្ឆិមភព អស់អសង្ខេយ្យប្រមាណមិនបាន និងមួយសែនកប្ប លោកបានកើតម្តងហើយម្តងទៀត នៅក្នុងឋានទេវតា និងមនុស្ស និងមិនដែលធ្លាក់ទៅក្នុងអបាយភូមិឡើយ។ លោកថែមទាំងបានជា **សក្កទេវរាជ** ធំជាងទេវតា សោយសេចក្តីសុខដ៏ជាទិព្វ អស់៨០ដង និងបានជាស្តេចចក្រពត្តិសោយរាជ្យក្នុងប្រទេសធំទូលាយ អស់ ៧៥ ដង។

លុះដល់បច្ឆិមភព លោកបានកើតក្នុងត្រកូលមហាសាល

ដ៏ស្អុកស្កម្ភ ក្នុងក្រុងសាវត្ថី។ កាលមានអាយុ៧ឆ្នាំ លោកបរិបូ-ណ៌ដោយល្បែង ពេលកំពុងលេងជាមួយក្មេងៗដទៃទៀត បានចាកចេញពីទីក្រុងចូលទៅកាន់អារាមមួយនៅវេលាល្ងាច ហើយភិក្ខុមួយអង្គ លោករួចចាកផុតកិលេស មិនមានឧបធិ បានសម្ដែងធម៌ដល់ក្មេងៗទាំងបានឱ្យសរណគមន៍។ បន្ទាប់ពីថាតាមភិក្ខុ "**ពុទ្ធំ សរណំ គច្ឆាមិ, ធម្មំ សរណំ គច្ឆាមិ, សង្ឃំ សរណំ គច្ឆាមិ**" មក លោករលឹកឃើញសរណគមន៍របស់លោក ហើយបានដល់អរហត្ត។ ក្រោយមកលោកក៏បានឧបសម្បទាជាភិក្ខុ និងមាននាមថា **សរណគមនត្ថេរ។**

*(អបទាន ១,៨២)*

## ៥. ហេតុអ្វីបានជាមនុស្សខុសៗគ្នា ពីម្នាក់ទៅម្នាក់ទៀត

នៅលើពិភពលោកសព្វថ្ងៃ មានប្រជាជន៦៥០០លាននាក់ ប៉ុន្តែ មិនមានមនុស្សពីរនាក់មានរូបរាង ក៏ដូចជាអាកប្បកិរិយាដូចគ្នាបេះបិទនោះទេ។ សូម្បីតែកូនភ្លោះជនជាតិសៀម ដែលមានរូបរាងស្រដៀងគ្នា ក៏ខុសគ្នាខាង អាកប្បកិរិយា ផ្លូវចិត្ត សតិប្រាជ្ញា សុខភាព អាយុ (ពីកើតដល់ស្លាប់) ទ្រព្យសម្បត្តិជាដើម។ តើអ្នកណាជាអ្នកធ្វើឱ្យមនុស្សខុសគ្នា?

កាលព្រះមានព្រះភាគគង់នៅក្នុងវត្តជេតពន **សុភមាណព**





ជាបុត្ររបស់ តោទេយ្យព្រាហ្មណ៍ បានក្រាបទូលសួរព្រះមាន-ព្រះភាគ នូវ១៤សំណួរ ដែលទាក់ទងនឹងកិច្ចការសង្គម។

"បពិត្រព្រះគោតមដ៏ចម្រើន ទោះបីមានពួកមនុស្សច្រើនក្នុងលោកនេះក្តីក៏ពួកមនុស្សទាំងអស់ខុសគ្នាពីម្នាក់ទៅម្នាក់ទៀត។ តើអ្វីជាហេតុ អ្វីជាបច្ច័យ ដែលនាំឱ្យពួកមនុស្សកើតមកជាមនុស្សខ្លះមានអាយុខ្លី ខ្លះមានអាយុវែង ខ្លះមានអាពាធច្រើន ខ្លះមានអាពាធតិច ខ្លះមានសម្បុរល្អ ខ្លះមានសម្បុរអាក្រក់ ខ្លះមានសក្តិតូច ខ្លះមានសក្តិធំ ខ្លះមានភោគសម្បត្តិតិច ខ្លះមានភោគសម្បត្តិច្រើន ខ្លះមានត្រកូលទាប ខ្លះមានត្រកូលខ្ពស់ ខ្លះមានប្រាជ្ញាតិច ខ្លះមានប្រាជ្ញាច្រើន?"

ដំបូងព្រះពុទ្ធទ្រង់បានវិសជ្ជនាភាសិតសង្ខេបថា៖

"**សព្វេ សត្តា កម្មស្សកា មាណវ សត្តា កម្មទាយាទា កម្មយោនី កម្មពន្ធូ កម្មប្បដិសរណា កម្មំ សត្តេ វិភជតិ យទិទំ ហីនប្បណីតតាយាតិ**"

"ម្នាលមាណព សត្វទាំងឡាយមានកម្មជារបស់ខ្លួន មានកម្មជាទាយាទ មានកម្មជាកំណើត មានកម្មជាផៅពង្ស មានកម្មជា

គ្រឿងរលឹក កម្មតែងចែកសត្វទាំងឡាយ ដើម្បីឱ្យថោកទាប និងខ្ពង់ខ្ពស់។″

ដោយសារកម្មទាំងឡាយ មនុស្សធ្វើនៅក្នុងអតីតជាតិ ក៏ដូចជាបច្ចុប្បន្នជាតិរបស់ពួកគេខុសគ្នា។ វាសនា និងជោគវាសនារបស់គេក៏មិនដូចគ្នា។ **សុភមាណព** បានទូលសូមឱ្យព្រះពុទ្ធទ្រង់សម្តែងសេចក្តីពិស្តារ។ ដូច្នេះ ព្រះអង្គបានសម្តែងសេចក្តីពិស្តារដូចតទៅ។

### (១) អាយុខ្លី និងអាយុវែង

ស្ត្រី ឬបុរសពួកខ្លះក្នុងលោកនេះ ជាអ្នកសម្លាប់សត្វ តាំងនៅក្នុងការបៀតបៀន និងការសម្លាប់។ បន្ទាប់អំពីសេចក្តីស្លាប់ទៅ រមែងទៅកើតក្នុងអបាយភូមិ៤ មាន តិរច្ឆាន ប្រេត អសុរកាយ នរក។ ប៉ុន្តែ បើកើតជាមនុស្សវិញ ដោយការឧបត្ថម្ភនៃកុសលកម្ម ដែលខ្លួនបានធ្វើហើយ រមែងជាអ្នកមានអាយុខ្លី។

អ្នកទាំងឡាយណាមានសេចក្តីអាណិតអាសូរ លះបង់ការសម្លាប់សត្វ រមែងទៅកើតក្នុងសុគតិសួគ៌ទេវលោក។ ប៉ុន្តែបើកើតជាមនុស្សវិញរមែងជាអ្នកមានអាយុវែង។

### (២)សុខភាពមិនល្អ និង សុខភាពល្អ

មនុស្សពួកខ្លះក្នុងលោកនេះ ជាអ្នកបៀតបៀនសត្វទាំង





ឡាយ និងបង្កគ្រោះថ្នាក់ដល់សត្វទាំងឡាយ។ ព្រោះអំពើនោះដែលខ្លួនបានធ្វើយ៉ាងនេះ បានកាន់ខ្ជាប់ខ្ជួនយ៉ាងនេះ បុគ្គលនោះ លុះទម្លាយរាងកាយ បន្ទាប់អំពីសេចក្តីស្លាប់ទៅ រមែងទៅកើតក្នុងកំណើតអបាយភូមិ៤។ ប៉ុន្តែបើកើតជាមនុស្សវិញដោយការឧបត្ថម្ភនៃកុសលកម្ម ដែលខ្លួនបានធ្វើហើយ រមែងជាអ្នកមានអាពាធច្រើន ងាយមានជម្ងឺ។

អ្នកទាំងឡាយណាមានសេចក្តីអាណិតអាសូរ មិនបង្កគ្រោះថ្នាក់ដល់អ្នកដទៃ លុះទម្លាយរាងកាយ បន្ទាប់អំពីសេចក្តីស្លាប់ទៅ រមែងទៅកើតក្នុងសុគតិសួគ៌ទេវលោក។ ប៉ុន្តែបើកើតជាមនុស្សវិញ រមែងជាអ្នកមានសុខភាពល្អ ។

### (៣) ការមានរូបអាក្រក់ ឬ រូបល្អ

មនុស្សពួកខ្លះក្នុងលោកនេះ ជាអ្នកមានសេចក្តីក្រោធ ឆាប់ថ្នាំងថ្នាក់ ឆាប់ខឹង។ ដោយសារសេចក្តីក្រោធនេះ និយាយទ្រគោះបោះបោក ជេរប្រទេចផ្តាសាអ្នកដទៃ។ នៅពេលស្លាប់ទៅ បុគ្គលនោះ រមែងទៅកើតក្នុងអបាយភូមិ៤ ។ ប៉ុន្តែ បើកើតជាមនុស្សវិញ ដោយការឧបត្ថម្ភនៃកុសលកម្មដែលខ្លួនបានធ្វើហើយ រមែងជាអ្នកមានរូបអាក្រក់។

មួយទៀត មនុស្សពួកខ្លះ ជាអ្នកចេះអត់ឱន ត្រាប្រណី

មានសេចក្តីមេត្តា និងមិនធាប់ខឹង។ ទុកជាគេស្តីថាច្រើន ក៏មិនថ្នាំងថ្នាក់ មិនជេរប្រទេចផ្តាសាអ្នកដទៃ ដោយសម្តីអាក្រក់។ នៅពេលស្លាប់ទៅ រមែងទៅកើតក្នុងសុគតិសួគ៌ទេវលោក ឬបើកើតជាមនុស្សវិញជាអ្នកមានរូបស្អាត ដូច្នេះបើអ្នកចង់មានរូបសម្រស់ស្អាត ចូរគ្រប់គ្រងសេចក្តីក្រោធរបស់អ្នក និងចម្រើនសេចក្តីអត់ឱនទោស និងសេចក្តីមេត្តា។

### (៤) ការមានមិត្តតិច ឬ មិត្តច្រើន

មនុស្សពួកខ្លះជាអ្នកច្រណែន និង មិនពេញចិត្តចំពោះជោគជ័យរបស់អ្នកដទៃ។ ព្រោះការច្រណែននោះ បុគ្គលនោះរមែងកើតក្នុងអបាយភូមិ ៤ បន្ទាប់ពីសេចក្តីស្លាប់។ ប៉ុន្តែ បើកើតជាមនុស្សវិញ រមែងមានមិត្តតិច ឬគ្មានសោះ។

មួយទៀត មនុស្សពួកខ្លះជាអ្នកមិនច្រណែន ពេញចិត្តចំពោះជោគជ័យរបស់អ្នកដទៃ។ នៅពេលស្លាប់ទៅ រមែងទៅកើតក្នុងសុគតិសួគ៌ទេវលោក ឬបើកើតជាមនុស្សវិញ រមែងមានមិត្តច្រើន។

### (៥)ការមានភោគសម្បត្តិតិច ឬភោគសម្បត្តិច្រើន

មនុស្សពួកខ្លះជាអ្នកកំណាញ់ និងជាប់ជំពាក់នឹងទ្រព្យសម្បត្តិរបស់ខ្លួន។ពួកគេមិនបានឱ្យអ្វីមួយក្នុងការបរិច្ចាគ។ ព្រោះ





សេចក្តីកំណាញ់នោះរមែងកើតក្នុងអបាយភូមិ បន្ទាប់ពីស្លាប់ទៅ។ ប៉ុន្តែ បើកើតជាមនុស្សវិញ រមែងជាអ្នកមានភោគសម្បត្តិតិច។

មួយទៀត អ្នកទាំងឡាយណា ជាអ្នកមានចិត្តសប្បុរសបរិច្ចាគទាន រមែងកើតក្នុងសុគតិសួគ៌ទេវលោក បន្ទាប់ពីសេចក្តីស្លាប់ ឬបើកើតជាមនុស្សវិញ រមែងជាអ្នកមានភោគសម្បត្តិ។

### (៦) ត្រកូលទាប ឬ ត្រកូលខ្ពង់ខ្ពស់

មនុស្សពួកខ្លះជាអ្នករឹងត្អឹង មើលងាយ មានអំនួត។ ពួកគេមើលងាយអ្នកដទៃ និងមានសេចក្តីគោរពតិចចំពោះអ្នកដទៃ។ ព្រោះមោទនភាពមិនពិតនេះ រមែងកើតក្នុងអបាយភូមិ បន្ទាប់ពីសេចក្តីស្លាប់។ ប៉ុន្តែបើកើតជាមនុស្សវិញ រមែងមានត្រកូលថោកទាប។

មួយទៀត មនុស្សពួកខ្លះមិនមានមោទនភាពក្លែងក្លាយ ប៉ុន្តែមានការបន្ទាបខ្លួន។ ពួកគេគោរពអ្នកដែលគួរគោរព។ នៅពេលស្លាប់ទៅ រមែងទៅកើតក្នុងសុគតិសួគ៌ទេវលោក ឬបើកើតជាមនុស្សវិញ រមែងជាអ្នកមានត្រកូលខ្ពង់ខ្ពស់។

### (៧) ការមានប្រាជ្ញាតិច ឬប្រាជ្ញាច្រើន

មនុស្សពួកខ្លះមិនចង់ចេះដឹង និងមិនមានចំណង់ចង់សិក្សារៀនសូត្រ។ ពួកគេមិនសួរ សមណៈ ឬព្រាហ្មណ៍ថា អ្វីជាកុសល អ្វីជាអកុសល អ្វីមានទោស អ្វីមិនមានទោស អ្វីគួរសេព

អ្វីមិនគួរសេព អ្វីមានប្រយោជន៍ក្នុងបច្ចុប្បន្ន ក៏ដូចជាបរលោក។ ដោយមិនមានប្រាជ្ញាដឹងការងារត្រូវ ពួកគេប្រព្រឹត្តអំពើអកុសល ដូច្នេះហើយ នៅពេលស្លាប់ទៅ រមែងទៅកើតក្នុងអបាយភូមិ៤។ ប៉ុន្តែបើកើតជាមនុស្សវិញ ដោយការឧបត្ថម្ភនៃកុសលកម្មខ្លះដែលបានធ្វើហើយ រមែងជាអ្នកមានប្រាជ្ញាតិច។

មួយទៀត មនុស្សពួកខ្លះចង់ចេះចង់ដឹង មានចំណង់ចង់សិក្សា និងសួរ សមណៈ ឬ ព្រាហ្មណ៍។ ពួកគេដឹងអ្វីត្រូវ អ្វីខុស និងរស់នៅប្រកបដោយធម៌។ នៅពេលស្លាប់ទៅរមែងកើតក្នុងសុគតិសួគ៌ទេវលោក ឬបើកើតជាមនុស្សវិញរមែងជាអ្នកមានប្រាជ្ញាច្រើន។

(*ឧបរិបណ្ណាស បាលីចូឡកម្មវិភង្គសូត្រ*)

ការឆ្លើយវិសជ្ជនារបស់ព្រះសម្មាសម្ពុទ្ធ ចំពោះបញ្ហាកម្មរបស់**សុភមាណព** មានលក្ខណៈសមហេតុសមផល និងប្រកបដោយវិចារណញ្ញាណ។ ការឆ្លើយវិសជ្ជនាទាំងអស់ អាចបញ្ជាក់ឱ្យឃើញយ៉ាងច្បាស់បាននៅក្នុង វិបស្សនាកម្មដ្ឋាន ។ វិសជ្ជនាទាំងនេះ ផ្តល់គោលការណ៍ណែនាំពីរបៀបដឹកនាំជីវិត ប្រកបដោយធម៌ ក៏ដូចជាដើម្បីកើតជាមនុស្សមានសម្បុរល្អ មានប្រាជ្ញា





ច្រើន នៅក្នុងគ្រួសារមានទ្រព្យសម្បត្តិ ក្នុងត្រកូលខ្ពង់ខ្ពស់ និងមានសក្តិធំ មានមិត្តច្រើន។

ព្រះពុទ្ធទ្រង់បង្ហាញយ៉ាងត្រឹមត្រូវថា សព្វសត្វទាំងអស់គឺជាម្ចាស់លើអំពើរបស់ខ្លួន ជាម្ចាស់លើកម្មរបស់ខ្លួន។ កម្មតែមួយគត់គឺជាសម្បត្តិរបស់ខ្លួន មិនមានអ្វីក្រៅពីនេះទេ។ ដូច្នេះ កម្មសំខាន់ណាស់ចំពោះមនុស្សគ្រប់រូប។

### ៦.នាម និង រូបកើតពីកម្ម

កុសលកម្ម និងអកុសលកម្ម បង្កើតទាំងនាមធម៌ ទាំងរូបធម៌ ជាវិបាករបស់កម្ម។

### នាមធម៌ជាវិបាករបស់កម្ម

អកុសលកម្ម បង្កើត អកុសលវិបាកចិត្ត និង សម្បយុត្តចេតសិកទាំងឡាយ។

កាមាវចរកុសលកម្ម បង្កើត កាមាវចរកុសលវិបាកចិត្តទាំងឡាយ និងសម្បយុត្តចេតសិក ទាំងឡាយ។

រូបាវចរកុសលកម្ម បង្កើត រូបាវចរកុសលវិបាកចិត្ត ទាំងឡាយ និងសម្បយុត្តចេតសិកទាំងឡាយ។

អរូបាវចរកុសលកម្ម បង្កើត អរូបាវចរកុសលវិបាកចិត្តទាំងឡាយ និងសម្បយុត្តចេតសិកទាំងឡាយ។

វិបាកចិត្តមានកិច្ចជាបដិសន្ធិចិត្ត ភវង្គចិត្ត និងចុតិចិត្ត។

វិបាកចិត្ត និងសម្បយុត្តចេតសិកទាំងឡាយមានខន្ធ ៤។

រូបធម៌ដែលបង្កើតដោយកម្មមានរូបកើតពីកម្ម(កម្មជរូប) និង រូប កើតពី ឧតុ មានកម្មជា បច្ច័យ (កម្មបច្ចយឧតុជរូប)។

**កម្មជរូប** (រូបកើតពីកម្ម)

(១) ចក្ខុបសាទ - ទ្វារភ្នែក

(២) សោតបសាទ - ទ្វារត្រចៀក

(៣) ឃានបសាទ - ទ្វារច្រមុះ

(៤) ជិវ្ហាបសាទ - ទ្វារអណ្តាត

(៥) កាយបសាទ - ទ្វារកាយ

(៦) ជីវិតរូប - រូបមានជីវិត

(៧) ឥត្ថីភាវរូប - រូបសភាវៈជាស្ត្រី

(៨)បុរិសភាវរូប - រូបសភាវៈជាបុរស

(៩) ហទយវត្ថុ - បេះដូង

រូបមិនកើតតែឯងទេ។ រូបតែងកើតជាកងនៃរូប(រូបកលាប)។ កម្មជរូបខាងលើកើតឡើង ដោយការផ្សំនៃអនិទស្សនរូប ៨ ដែលកើតពីកម្ម មានដូចជា បឋវី (ដី), អាបោ (ទឹក), តេជោ (ភ្លើង),





វាយោ (ខ្យល់), វណ្ណៈ (ពណ៌), គន្ធៈ (ក្លិន), រសៈ (រសជាតិ), និងឱជា (ឱជារស)។

អាស្រ័យលើកម្លាំងថាមពលនៃជនកកម្ម ការមើលរបស់ភ្នែក ការឮរបស់ត្រចៀក ការហិតក្លិនរបស់ច្រមុះ ការភ្លក់រសជាតិរបស់អណ្តាត ជាដើម អាចខុសៗគ្នា ចំពោះបុគ្គលខុសគ្នា។

## កម្មបច្ចយឧតុជរូប

កម្មបច្ចយឧតុជរូប ជារូបកើតពីឧតុមានកម្មជាហេតុបច្ច័យ។

អាស្រ័យលើកុសលកម្ម និងអកុសលកម្មរបស់សត្វ អាកាសធាតុអាចនៅទៀងទាត់ ដែលមានខ្យល់ និងភ្លៀងទៀងទាត់ ឬវាអាចផ្លាស់ប្តូរយ៉ាងកំហ៊ុក បណ្តាលឱ្យមានការរាំងស្ងួតធ្ងន់ធ្ងរ និងទឹកជំនន់ធំសម្បើមដោយសារភ្លៀងធ្លាក់ខ្លាំងឥតឈប់។ មួយទៀត អាស្រ័យលើល័ក្ខខ័ណ្ឌអាកាសធាតុទាំងនេះ ផលិតផលកសិកម្ម ដូចជាអង្ករ ស្រូវសាលី ពោត សណ្តែក ជាដើម អាចមានការចិញ្ចឹមពេញលេញ ឬអាចមិនមានការចិញ្ចឹមសោះ។ មួយទៀត អាស្រ័យលើការចិញ្ចឹមពេញលេញ ឬការទទួលការចិញ្ចឹមមិនគ្រប់គ្រាន់ សត្វលោកអាចក្លាយជាមានសុខភាពល្អ ឬមិនមានសុខភាពល្អ និងអាចមានអាយុវែង ឬអាយុខ្លី។

ក្រៅពីនេះ នៅពេលសត្វនៅក្នុងឋានទេវលោក ទាំងឋានទេវតា ទាំងឋានព្រហ្ម វិមានទិព្វ វិមានប្រកបដោយសីហវិលាស អាហារទិព្វ ឧទ្យាន ផ្កា រុក្ខជាតិ ជាដើម ដែលកើតពីឧតុជរូប ក៏កើតឡើង សម្រាប់ទេវតាប្រើប្រាស់ ជាផលបុណ្យនៃកុសលកម្មរបស់ទេវតាដែលបានសាង។ នៅក្នុងនរកផងដែរ ភ្លើងនរក ខ្ទះភ្លើង ខ្ទះទឹកក្រុត កង់ភ្លើង ជាដើម ត្រូវបង្កើតឡើងដោយឧតុជរូប ដើម្បីធ្វើទារុណកម្មសត្វនរក អាស្រ័យតាមអកុសលកម្មរបស់សត្វនរកនោះ។

ហេតុដូចនេះ មនុស្សលោកមានបុណ្យ (កុសលកម្ម) កើតនៅលើដីមានជីជាតិ ជាមួយអាកាសធាតុល្អ រុក្ខជាតិខៀវស្រងាត់ សួនច្បារស្រស់បំព្រង ផលិតផលកសិកម្មមានសារជាតុចិញ្ចឹម និងបរិបូរណ៌ដោយទឹក។ ទោះបីយ៉ាងណា អ្នកមានបាប (អកុសលកម្ម)កើតនៅលើដីសោះកក្រោះ គ្មានទឹក គ្មានដីមានជីជាតិ គ្មានផលិតផលកសិកម្ម និងអាកាសធាតុហួសហេតុ។

(មន្ទីរកិច្ចការសាសនា "គម្ពីរពុទ្ធសាសនា" ភាគ ១, ទំ. ៦៦១-៦៦២)



# ៨

## ប្រភេទកម្មផ្សេងគ្នា

### ១. ថ្នាក់កម្ម៤យ៉ាង ដែលកម្មនីមួយៗមាន៤ប្រភេទ

តើមានកម្មច្រើនប៉ុណ្ណាទៅ ដែលកើតរលត់ៗ នៅក្នុងសន្តានរបស់មនុស្សគ្រប់រូបនោះ? ចូរពិចារណាឱ្យបានម៉ត់ចត់។ ចិត្តជាមួយនឹងចេតសិក ដែលសម្បយុត្តកើត និងរលត់ច្រើនជាងមួយសែនកោដិដង ក្នុងមួយផ្ទាត់ម្រាមដៃ ។ ដូច្នេះ កុសលកម្មជាងរយកោដិកើតមានគ្រប់វិនាទី នៅពេលដែលយើងកំពុងធ្វើអំពើល្អ។ ដូចគ្នានេះដែរ អកុសលកម្មជាងរយកោដិកើតមានគ្រប់វិនាទី នៅពេលដែលយើងកំពុងធ្វើអំពើអាក្រក់ ។

ហេតុដូច្នេះហើយ នៅក្នុងជីវិតបច្ចុប្បន្ននេះ កុសលកម្ម និងអកុសលកម្មរាប់រយកោដិ អាចកើតមានទៅតាមទង្វើរបស់យើង។ ដូចគ្នានេះដែរ កុសលកម្ម និង អកុសលកម្ម រាប់រយ

កោដិបានកើតមានតាំងពីជាតិមុនៗមករាប់មិនអស់។ កម្មទាំងអស់នេះ បានបដិសន្ធិនៅក្នុងវិថីចិត្តរបស់យើងពីមួយជាតិទៅមួយជាតិ រហូតមកដល់បច្ចុប្បន្នជាតិនេះ។ ដូច្នេះ ទាំងកុសលកម្ម និងអកុសលកម្ម នៅក្នុងសន្តានរបស់យើង គឺច្រើនជាអនេកសូម្បីតែកុំព្យូទ័រក្នុងសម័យដ៏ទំនើបនេះ ក៏ពុំអាចគណនាបានឡើយ ។

កម្មទាំងអស់នេះ កំពុងតែរង់ចាំពេលវេលាសមស្របនឹងឱ្យផល។ ដោយសារ កម្ម មានច្រើនជាអនេក ដែលមានតែព្រះពុទ្ធជាបរមគ្រូនៃយើងប៉ុណ្ណោះ ទើបព្រះអង្គទ្រង់ជ្រាបច្បាស់ថាកម្មណាខ្លះនឹងឱ្យផលបែបណា ឬនៅពេលណានោះ ។

*កម្មវិបាកោ អចិន្តេយ្យោ* កម្មទាំងឡាយគឺ មិនអាចគិតបានប្រមាណត្រូវ។ ដើម្បីឱ្យយល់កាន់តែច្បាស់អំពីវិបាកនៃកម្មទាំងឡាយនោះ ព្រះសម្មាសម្ពុទ្ធបានសម្តែងកម្ម៤ពួក ហើយដែលក្នុងពួកនីមួយៗមាន៤យ៉ាងដូចខាងក្រោមនេះ ៖

(១) កម្ម៤យ៉ាងចែកតាមមុខងារ
(២) កម្ម៤យ៉ាងចែកតាមការដែលឱ្យផល
(៣) កម្ម៤យ៉ាងចែកតាមពេលវេលាដែលត្រូវឱ្យផល
(៤) កម្ម៤យ៉ាងចែកតាមទីកន្លែងដែលត្រូវឱ្យផល





## ២. កម្ម៤យ៉ាងចែកតាមមុខងារ

| | |
|---|---|
| (១) ជនកកម្ម | ផលិតកម្ម (កម្មឱ្យផលហើយតាក់តែងជាតិកំណើតថ្មី) |
| (២) ឧបត្ថម្ភកកម្ម | កម្មដែលជួយទំនុកបំរុង |
| (៣) ឧបបីលកកម្ម | កម្មដែលជាឧបសគ្គរាំង |
| (៤) ឧបឃាតកកម្ម | កម្មដែលកាត់ផ្តាច់ និងឱ្យផលដោយខ្លួនឯង។ |

### ១) ជនកកម្ម - *កម្មដែលបង្កើត*

ជនកកម្ម ឬផលិតកម្ម គឺជាកម្មដែលមានអំណាចខ្លាំងអាចផលិតកំណើតថ្មីបាន។ ហើយកម្មនេះ មានអានុភាពពេញលេញ ព្រោះថាទាំងកុសលកម្ម និងអកុសលកម្មតាមបំពេញមុខងាររបស់ខ្លួន គឺផលិតនូវវិបាកចិត្តជាមួយនឹងចេតសិកដែលសម្បយុត្ត និងកម្មជរូប ពេញមួយជីវិតរបស់យើង។ ការកើតឡើងនៃវិបាកចិត្ត ដែលសម្បយុត្តជាមួយនឹងចេតសិក ហើយនិង កម្មជរូប មានន័យថា ការកើតឡើងនៃបញ្ចក្ខន្ធ ឬកំណើតថ្មីមួយ ។

ចិត្ត កើតបន្តបន្ទាប់គ្នាតាមទំនងរបស់វា ដោយមិនឈប់

ឈរ ។ វិបាកចិត្តទីមួយដើរតួជា"បដិសន្ធិចិត្ត"វិបាកចិត្តបន្ទាប់ដើរតួជា"ភវង្គចិត្ត"និងវិបាកចិត្តចុងក្រោយដើរតួជា "ចុតិចិត្ត" ។

ប្រសិនបើ កម្ម ដែលតាក់តែងនោះ ជាកុសលកាមាវចរ កំណើតថ្មីអាចបដិសន្ធិក្នុងមនុស្សលោក ឬក៏អាចក្នុងឋានណាមួយនៃទេវលោក។ ប្រសិនបើ កម្ម ដែលតាក់តែងនោះ គឺជាអកុសលកម្ម កំណើតថ្មីនឹងបដិសន្ធិក្នុងកំណើតណាមួយនៃអបាយភូមិ។ ហើយប្រសិនបើ កម្ម ដែលតាក់តែងនោះមានកម្លាំងខ្លាំង កំណើតថ្មីនោះមានអាយុវែង បើទុព្វលភាពនឹងមានអាយុខ្លី។

**២) ឧបត្ថម្ភកកម្ម** - *កម្មដែលឧបត្ថម្ភ*

ឧបត្ថម្ភកកម្មនេះ មិនមានកម្លាំងគ្រប់គ្រាន់ដើម្បីតាក់តែងជាតិកំណើតបានទេ ប៉ុន្តែអាចជួយទំនុកបំរុងដល់ជនកកម្មឱ្យផលជាសុខ ឬទុក្ខតាមពេលវេលារបស់វា ឬក៏ជួយពង្រឹងនូវដំណើរដែលប្រព្រឹត្តទៅនៃបញ្ចក្ខន្ធដែលតាក់តែងដោយជនកកម្ម ។

បុគ្គលកើតក្នុងឋានសួគ៌បាន ដោយអាស្រ័យកុសលកម្មជាអ្នកទំនុកបំរុង ហើយកុសលកម្មទាំងឡាយ ដែលតាមទំនុកបំរុងនោះ ដើរតួជាឧបត្ថម្ភកកម្ម ចំណែកឯ អកុសលកម្មទាំងឡាយ ដែលជាប់តាមសន្តាននៃបុគ្គលនោះដើរតួជា ឧបបីលក





កម្ម(កម្មរារាំង)។ កុសលកម្មដែលបុគ្គលបានប្រព្រឹត្តក្នុងកំណើតថ្មីនេះ នឹងដើរតួជាឧបត្ថម្ភកកម្ម ចំណែកឯ អកុសលកម្ម នឹងដើរតួជា ឧបបីលកកម្ម ។ ឧទាហរណ៍ថា ប្រសិនបើ បុគ្គលម្នាក់ធ្វើអំពើល្អ មានដូចជា៖ ការបរិច្ចាគទាន រក្សាសីល ធ្វើសមាធិជាដើម ដូច្នេះ កុសលកម្មថ្មី ដែលបុគ្គលបានធ្វើនេះនឹងដើរតួជាឧបត្ថម្ភកកម្ម តាមទំនុកបំរុងបុគ្គលនោះឱ្យបានសុខចម្រើន ឬក៏ទំនុកបំរុងនូវបុគ្គលនោះ ដោយបច្ច័យផ្សេងៗ រហូតពេញមួយជីវិតរបស់គេ ។ កម្ម ដែលបានបំពេញក្នុងបច្ចុប្បន្ននេះ នឹងជួយឧបត្ថម្ភដល់កម្មដែលបុគ្គលបានធ្វើពីមុនមក។ នៅពេលដែលកុសលកម្មទាំងឡាយឱ្យផលស្របពេលគ្នា បុគ្គលនោះ នឹងបានទទួលនូវជោគជ័យ រាល់គ្រប់ការងារសព្វសារពើ ដែលខ្លួនកំពុងធ្វើក្នុងជីវិតប្រចាំថ្ងៃ ។

**៣) ឧបបីលកកម្ម** - កម្មដែលរារាំង

ឧបបីលកកម្មនេះ មានអំណាចធ្វើឱ្យតួនាទីនៃជនកកម្មមានកម្លាំងអន់ថយ រំខាន ឬក៏ពន្យា ។ នៅពេលដែលកុសលកម្មតាក់តែងកំណើតថ្មីនៅក្នុងទេវលោក កុសលកម្ម និង អកុសលកម្ម រាប់រយកោដិ ក៏នឹងជាប់តាមទៅដែរ។ កុសលកម្មទាំងនោះ

ណាមួយនឹងឱ្យផលល្អប្រសើរ ដើរតួជា ឧបត្ថម្ភកកម្ម ហើយ អកុសលកម្មនឹងឱ្យផលជាទុក្ខ ដើរតួជា ឧបបីលកកម្ម ។

ដូចគ្នានេះដែរ នៅពេលដែលអកុសលកម្មឱ្យផលវានឹង តាក់តែងទៅក្នុងកំណើតណាមួយនៃអបាយភូមិ មានទំនងដូច គ្នានឹងកុសលកម្មដែរ ។ ប៉ុន្តែក្នុងទីនេះ កុសលកម្មនឹងដើរតួជា ឧបបីលកកម្ម ដើម្បីការពាររារាំង និងពន្យារនូវផលជាអកុសល ចំណែកឯ អកុសលកម្ម នឹងដើរតួជាឧបត្ថម្ភកកម្មដោយការឱ្យ ផលជាទុក្ខ ។

ដូច្នេះហើយ ក្នុងជីវិតរបស់យើងតែងតែមានការឡើង ចុះៗជានិច្ច ព្រោះថា កុសលកម្ម ដែលតែងតែជួយទំនុកបំរុង និងអកុសលកម្ម ដែលតែងតែរារាំងនោះ រមែងផ្លាស់វេនគ្នាឱ្យ ផលជាដរាប។ ជាពិសេសជាងនេះទៅទៀតនោះ នៅពេលដែល បុគ្គលធ្វើកុសលកម្មជារឿយៗតៗមក កុសលកម្មទាំងនោះនឹង មានកម្លាំងខ្លាំងឡើងៗ ហើយកុសលកម្មទាំងនោះ អាចនឹងរារាំង សង្កត់សង្កិននូវអកុសលកម្មមិនឱ្យមានឱកាសឱ្យផលបាន។ នៅ ពេលដែលកុសលកម្ម ឱ្យផលផ្ទួនៗមក បុគ្គលនោះនឹងសោយនូវ សេចក្តីសុខ សេចក្តីចម្រើន នៅក្នុងជីវិតរបស់ខ្លួន។ ទោះបីយ៉ាង ណាក៏ដោយ បើសិនជាបុគ្គលនោះសប្បាយនឹងសេចក្តីសុខ





របស់ខ្លួនពេក ដល់ថ្នាក់ភ្លេចភ្លាំងស្មារតីមិនបានបន្តធ្វើអំពើល្អ នោះ អកុសលកម្ម ដែលធ្លាប់បានសាងពីមុនមកនឹងមានឱកាស ពង្រីកខ្លួនកើនឡើងៗ មានកម្លាំងខ្លាំងក្លា អាចរារាំងនូវកុសល កម្មមិនឱ្យផលបាន។ អកុសលកម្មដែលកើនឡើងហើយនោះនឹង ឱ្យផលជាទុក្ខ តៗគ្នារហូតតាមទំនងនៃការឱ្យផល របស់កុសល កម្មដែរ ។

បន្ទាប់មក មុខរបរការងារផ្សេងៗនៃបុគ្គលនោះនឹងធ្លាក់ ចុះ វាសនារបស់គាត់នឹងអន់ថយ ហើយអាចជួបប្រទះនូវការ ខាតបង់ទ្រព្យសម្បត្តិ បញ្ហាសុខភាព កេរ្តិ៍ឈ្មោះ ឬក៏បញ្ហាផ្សេងៗ នៅក្នុងសង្គម ។ សមាជិកណាមួយនៃក្រុមគ្រួសារអាចមានជំងឺ គ្រោះថ្នាក់ ឬក៏អាចស្លាប់បាត់បង់ជីវិត។ ដូចមានពំនោលមួយ តែងលើកឡើងថា៖ *"សំណាងពុំដែលកើតមានដល់មនុស្សដែល មិនធ្វើអ្វីសោះនោះទេ" "លំពែងតែងធ្លាក់ចុះក្នុងទីទាប " "ភ្លៀង រមែងហូរតាមបង្ហូចដែលមានភ្លៀងតក់"*

នៅពេលសំណាងអន់ថយទៅៗ បុគ្គលនោះប្រហែលជា នឹងស្វះស្វែងរកគ្រូទាយ ឬហោរា ដើម្បីជួយបញ្ចៀសនូវគ្រោះ នោះ ហើយសូមឱ្យបាននូវសំណាងល្អវិញ។ តែបើតាមសភាព ពិត ទីតាំងនៃតារា និង ភពទាំងឡាយអាចមានឥទ្ធិពលតិចតួច

ឬក៏គ្មានសោះ ចំពោះភ័ព្វសំណាងរបស់បុគ្គលម្នាក់ៗ ។ គឺអកុសលកម្មដែលបុគ្គលបានសាងពីមុនមកឯណោះទេ ដែលនាំឱ្យមានគ្រោះអាក្រក់នោះ។ មាគ៌ាដែលអាចបញ្ចៀសនូវគ្រោះអាក្រក់ផ្សេងៗនោះគឺមានតែការខិតខំធ្វើអំពើល្អប៉ុណ្ណោះ ព្រោះថា អំពើល្អដែលបុគ្គលបានធ្វើហើយ អាចនឹងសង្កត់នូវគ្រោះអាក្រក់ផ្សេងៗមិនឱ្យផលបាន ហើយអំពើល្អនោះនឹងបន្តឱ្យផល។

ដូច្នេះហើយ ក្នុងជីវិតរបស់មនុស្សយើងតែងតែមានការឡើង និងធ្លាក់ចុះជាធម្មតាទៅតាមកុសលកម្ម និងអកុសលកម្មដែលវាតែងតែប្រជែងគ្នាឱ្យផល។ ហេតុនេះហើយ អ្នកនិពន្ធរឿងជនជាតិអង់គ្លេសដ៏ល្បីល្បាញគឺលោក វិល្លាម ហ្សេក្សៀរ៍ ( *William Shakespeare* ) បានសរសេរទុកថា៖

*ជីវិតពោរពេញទៅដោយការឡើង និងធ្លាក់ចុះ*
*ជីវិតមិនមែនជាដំណេកផ្កាកុលាបនោះទេ។*

**៤) ឧបឃាតកកម្ម** - កម្មដែលបំផ្លិចបំផ្លាញ

ឧបឃាតកកម្ម មិនត្រឹមតែកាត់ផ្ដាច់នូវផលរបស់ជនកកម្ម ប៉ុណ្ណោះទេ ថែមទាំងបំផ្លិចបំផ្លាញ ហើយឱ្យផលរបស់វា។ ឬអាចនិយាយបានថា នៅពេលបុគ្គលស្លាប់ភ្លាមៗ គេនឹងទៅ





ចាប់កំណើតតាមកម្ម ដែលកាត់ផ្ដាច់នោះ។ ឧបឃាតកកម្មអាចជាកុសល ឬអកុសល ខាងណាខ្លាំងជាង ខាងនោះឱ្យផលមុន។ ឧទាហរណ៍ថា បុរសម្នាក់ បើតាមកម្ម ដែលតាក់តែងមកតម្រូវឱ្យគាត់មានអាយុវែង ប៉ុន្តែឧបឃាតកកម្ម អាចកើតមានដែលនាំឱ្យបុរសនោះស្លាប់មុនអាយុ ដោយអាការៈផ្សេងៗ ដូចជា គាំងបេះដូង ឬគ្រោះថ្នាក់ចរាចរណ៍ជាដើម។ម្យ៉ាងវិញទៀត ប្រេតដែលបានទៅកើតក្នុងឋាននរកនោះ ក៏ដោយសារតែអកុសលកម្មដែលតាក់តែងមក។ សាច់ញាតិសន្ដានប្រគេនចង្ហាន់ និងសំពត់ចីវរដល់ភិក្ខុសង្ឃ ហើយឧទ្ទិសផ្សាយទៅឱ្យ។ បើសិនជាប្រេតនោះត្រេកអរអនុមោទនាចំពោះផលនៃទាននោះថា សាធុ សាធុ ឬល្អហើយ ល្អហើយ កុសលកម្មដែលប្រេតនោះ ទទួលបាននឹងដើរតួជា ឧបឃាតកកម្ម កាត់ផ្ដាច់នូវអកុសលកម្មក្នុងនរកនោះ ហើយប្រេតនោះ ស្លាប់ពីបេតវិស័យនោះភ្លាមៗហើយនឹងទៅកើតក្នុងឋានសួគ៌ដោយអំណាចនៃឧបឃាតកកម្មនេះឯង។

វាគួរឱ្យជ្រះថ្លាណាស់ នៅពេលដែលយើងបានជ្រួតជ្រាបច្បាស់នូវច្បាប់កម្មផល ដែលពន្យល់តាមព្រឹត្តិការណ៍ជាក់ស្ដែងក្នុងជីវិតរស់នៅ។

## ការប្រព្រឹត្តទៅនៃកម្មទាំង៤យ៉ាងចំពោះ ភិក្ខុទេវទត្ត

ដើម្បីឱ្យកាន់តែជាក់ច្បាស់ អំពីការប្រព្រឹត្តទៅនៃកម្មទាំង ៤យ៉ាងខាងលើសូមលើកយករឿងភិក្ខុទេវទត្ត មកបង្ហាញក្នុងទី នេះដោយសង្ខេប។ កុសលកម្មដែលលោកបានសាងមក បាន តាក់តែងឱ្យប្រសូត្រក្នុងត្រកូលរាជវង្ស។ សេចក្ដីសុខសម្បូរ សប្បាយគ្រប់បែបយ៉ាងរបស់លោក គឺកើតចេញអំពីជនកកម្ម និងឧបត្ថម្ភកកម្មជាកុសល ដែលលោកបានសាងពីមុនមក។ ការ សាងផ្នួស ជាភិក្ខុភាវៈជាមួយនឹងក្សត្រនៃសក្យត្រកូលទាំងឡាយ ដូចជា ព្រះអានន្ទ ព្រះអនុរុទ្ធ និងការបានសម្រេចលោកិយ ឈាន ដោយការធ្វើសមាធិជាដើម ទាំងនេះគឺជាកុសលវិបាកនៃ ឧបត្ថម្ភកកម្ម។

បន្ទាប់មក លោកបានសាងបាបកម្មមួយយ៉ាងធ្ងន់ធ្ងរ ដោយព្យាយាមធ្វើឃាតព្រះសម្មាសម្ពុទ្ធ តែបានត្រឹមធ្វើឱ្យមាន របួសម្រាមព្រះបាទ ហើយនឹងបានបំបែកបំបាក់សង្ឃ។ នៅពេល ដែលអកុសលកម្មទាំងនេះ ឱ្យផលដើរតួជាឧបបីលកកម្ម(កម្ម រារាំង)លោកត្រូវបានបណ្ដេញចេញពីសហគមន៍សង្ឃ។ មិនយូរ ប៉ុន្មាន បន្ទាប់ពីបានសាងបាបកម្មដ៏ធ្ងន់ធ្ងរ ដោយការបំបែក





សង្ឃ ហើយ ឧបឃាតកកម្ម ក៏ចាប់ផ្ដើមឱ្យផល។ ភិក្ខុទេវទត្ត ក៏ត្រូវបានធរណីស្រូបធ្លាក់ទៅសោយទុក្ខក្នុង អវចីនរក។

**៣. កម្ម៤ប្រភេទតាមលំដាប់នៃអាទិកម្ម**

១) **គរុកកម្ម** កម្មធ្ងន់

២) **អាសន្នកម្ម** កម្មជិតស្លាប់

៣) **អាចិណ្ណកម្ម** កម្មអចិន្ត្រៃយ៍ (ទម្លាប់)

៤) **កដត្តាកម្ម** កម្មមិនជាក់លាក់

កម្មទាំងអស់ដែលប្រព្រឹត្តទៅក្នុងវិថីចិត្តចែកជា៤ប្រភេទ ទៅតាមលំដាប់នៃអាទិភាព ដែលអាចឱ្យផលជាបដិសន្ធិក្នុង កំណើតថ្មីនៅពេលជិតស្លាប់។

១)**គរុកកម្ម** - *កម្មដែលមានទម្ងន់ធ្ងន់*

គរុកកម្ម ខាងកុសល គឺមានទម្ងន់ខ្លាំងក្លាដែលមិនមាន កម្មឯណានីមួយអាចមកកាត់ផ្ដាច់ ឬជំនួសក្នុងការសម្រេចនៃ ជាតិបន្ទាប់។ ម្យ៉ាងវិញទៀត គរុកកម្មនេះ ច្បាស់ណាស់ថានឹង ឱ្យផលតាក់តែងកំណើតថ្មីនៅជាតិខាងមុខ។

ចំណែកឯ គរុកកម្មខាងអកុសល គឺបាបកម្មដ៏ធ្ងន់៥យ៉ាង (បញ្ចានន្តរិយកម្ម) ហើយនិងការយល់ខុសជាប្រចាំ (និយត- មិច្ឆាទិដ្ឋិ)។

## បញ្ចានន្តរិយកម្ម៥

១) បិតុឃាតកកម្ម សម្លាប់បិតា

២) មាតុឃាតកកម្ម សម្លាប់មាតា

៣) អរហន្តឃាតកកម្ម សម្លាប់ព្រះអរហន្ត

៤) លោហិតុប្បាទកកម្ម បង្ករបួសចំពោះព្រះពុទ្ធ

៥) សង្ឃភេទកកម្ម ញុះញង់បំបែកបំបាក់សង្ឃ

ទោសនៃកម្មទាំងឡាយ មានទម្ងន់តាមលំដាប់ដូចបានរៀបរាប់ពីលើចុះមកក្រោម។ បុគ្គលណា ប្រព្រឹត្តធ្វើទោសណាមួយក្នុងចំណោមទោសទាំង៥នៃអនន្តរិយកម្មនេះ ពេលស្លាប់ទៅនឹងទៅកាន់ទុគតិភព។ បុគ្គលដែលជានិយតមិច្ឆាទិដ្ឋិ គឺបុគ្គលដែលបដិសេធនូវ កម្ម និង ផលនៃកម្ម នោះក៏រាប់បញ្ចូលក្នុងអកុសលគរុកកម្មដែរ (បាបកម្មធ្ងន់)។ នៅពេលដែលបុគ្គលនេះស្លាប់ទៅ នឹងទៅចាប់កំណើតក្នុងលោកន្តរិកនរកដែលងងឹតសូន្យជានិច្ច។

ចំណែកខាង កុសលកម្ម វិញ មានអំពើជាកុសលដែលប្រព្រឹត្តទៅក្នុងរូបភព៥(រូបាវចរកុសលកម្ម) និងអំពើជាកុសលដែលប្រព្រឹត្តទៅក្នុងអរូបភព៤(អរូបាវចរកុសល)ដែលជាកុសលគរុកកម្ម(អំពើល្អដ៏មានទម្ងន់)។ បុគ្គលដែលបានសម្រេចឈាន





រហូតដល់ថ្ងៃស្លាប់ នឹងបានទៅកើតក្នុងព្រហ្មលោក។ បុគ្គលដែលបានចាក់ធ្លុះក្នុងមគ្គ និងផលដោយការចម្រើននូវ វិបស្សនាកម្មដ្ឋាន ហើយញ៉ាំងកុសលកម្មក្នុងលោកុត្តរ(លោកុត្តរកុសលកម្ម) ឱ្យកើតឡើងជាគរុកកម្ម នឹងបិទនូវទ្វារនៃអបាយទាំង៤ជារៀងរហូត។ ដូច្នេះបុគ្គលនេះ ក្រោយពេលស្លាប់ពីលោកនេះទៅ នឹងទៅកើតក្នុងសុគតិភពតែម្យ៉ាង។

ប្រសិនបើ បុគ្គលម្នាក់បានចម្រើននូវឈានឱ្យកើតឡើងហើយ ប៉ុន្តែក្រោយមកបានប្រព្រឹត្តនូវ អានន្តរិយកម្ម ណាមួយក្នុងចំណោម ៥ នោះ អកុសកលកម្មនឹងបិទបាំងនូវកុសលកម្មហើយក្រោយមកញ៉ាំងកំណើត ក្នុងអបាយឱ្យកើតឡើងបាន។ ឧទាហរណ៍ជាក់ស្តែងគឺ ភិក្ខុទេវទត្ត ដែលត្រូវជាសាច់ញាតិជីដូនមួយ នៃព្រះសម្មាសម្ពុទ្ធ បានបាត់បង់នូវឫទ្ធានុភាព ហើយទៅកើតក្នុងអវិចីនរក ដោយសារតែការដែលខ្លួនបានធ្វើឱ្យមានរបួសដល់ម្រាមព្រះបាទនៃព្រះសម្ពុទ្ធ និងការដែលខ្លួនបានញ៉ាំងគណៈសង្ឃឱ្យបែកបាក់។

ជាងនេះទៅទៀត ប្រសិនបើ បុគ្គលម្នាក់បានប្រព្រឹត្តនូវកម្មណាមួយក្នុងចំណោម អនន្តរិយកម្មទាំង ៥ បុគ្គលនោះនឹងមិនអាចបានចាក់ធ្លុះក្នុងលោកុត្តរធម៌ឡើយ ពីព្រោះថា អកុសល

កម្មនោះមានទម្ងន់ធ្ងន់ពេកមិនអាចជំនះបាន។ ហេតុដូច្នេះហើយ ព្រះបាទ អជាតសត្តុ ខណៈពេលកំពុងតែស្តាប់នូវសាមញ្ញផលសូត្រ ដែលទ្រង់ប្រទានដោយព្រះសម្មាសម្ពុទ្ធ មានល័ក្ខខ័ណ្ឌគ្រប់គ្រាន់ ដើម្បីសម្រេចសោតាបត្តិមគ្គ ប៉ុន្តែព្រះអង្គមិនបានចាក់ធ្លុះក្នុងមគ្គ និងផលឡើយ នេះក៏ដោយសារតែទ្រង់បានធ្វើឃាតព្រះបិតារបស់ខ្លួនគឺព្រះបាទពិម្ពិសារ ដែលព្រះអង្គជាសោតាបន្នបុគ្គល។

ក្រោយមក បើទោះជា ព្រះបាទអជាតសត្តុ បានបំពេញកុសលកម្មយ៉ាងច្រើន ដូចជាទ្រង់បានរាជូបត្ថម្ភ ក្នុងការប្រារព្ធធ្វើសង្គាយនាលើកទីមួយ និង ទ្រង់បានសាងព្រះចេតិយដ៏ធំអស្ចារ្យដើម្បីតម្កល់ព្រះសារីរិកធាតុព្រះសាស្តាយ៉ាងណាក៏ដោយ ក៏ទ្រង់នៅតែមិនអាចគេចផុតពីកំណើតក្នុងនរកឡើយ នេះគឺដោយសារតែទ្រង់បានប្រព្រឹត្តអនន្តរិយកម្ម គឺបិតុឃាតនឹងឯង។

**២) អាសន្នកម្ម** - *កម្មជិតពេលស្លាប់*

កម្មនៅពេលជិតស្លាប់ គឺជាកម្លាំងនៃកម្មទាំងជាកុសល និងអកុសលដែលបុគ្គលបានធ្វើទុកមក ឬក៏ចងចាំក្នុងរយៈពេលដ៏ខ្លីមុនពេលស្លាប់។ ប្រសិនបើពុំមានគរុកកម្មទេ អាសន្នកម្ម





នេះនឹងដើរតួនាទីរបស់ខ្លួនតាក់តែងកំណើត ដោយហេតុថាកម្មនេះមានកម្លាំងខ្លាំងក្លា ព្រោះកើតនៅពេលរៀបនឹងស្លាប់។

ប្រសិនបើ បុគ្គលម្នាក់ដែលធ្លាប់បានសាងបាបកម្មច្រើនធ្វើអំពើល្អមុនពេលខ្លួនស្លាប់ ឬក៏ចងចាំនូវអំពើល្អដែលខ្លួនបានធ្វើមុនពេលស្លាប់នោះ បុគ្គលនោះនឹងបានទៅកើតក្នុងសុគតិភព។ ម្យ៉ាងវិញទៀត ប្រសិនបើ បុគ្គលដែលធ្លាប់បានសាងកុសលកម្មច្រើនចងចាំនូវអំពើអាក្រក់ណាមួយ ដែលខ្លួនធ្លាប់សាងក្នុងពេលមុន ឬក៏បានធ្វើអំពើអាក្រក់មុនពេលស្លាប់ បុគ្គលនោះនឹងទៅកើតក្នុងទុគតិភព។

ព្រោះហេតុនេះហើយ វាជាការចាំបាច់ណាស់ដែលយើងត្រូវរៀបចំចំពោះមាតាបិតា ឬក៏មនុស្សជាទីគោរពស្រឡាញ់របស់យើងឱ្យធ្វើអំពើល្អមុនពេលហៀបនឹងស្លាប់ ឬក៏ជួយក្រើនរំលឹកពួកគាត់ក្នុងជង្ហើមចុងក្រោយ ឱ្យនឹករលឹកឃើញអំពើល្អគ្រប់យ៉ាងដែលពួកគាត់បានសាង។

ទោះបីជាបុគ្គលដែលបានសាងបាបច្រើន បានទៅកើតក្នុងសុគតិភពដោយអំណាចនៃអំពើល្អដែលខ្លួនបានធ្វើមុនពេលស្លាប់ក៏ដោយ មិនមែនមានន័យថាបុគ្គលនោះ អាចគេចផុតពីអកុសលកម្ម ដែលខ្លួនបានសាងកាលនៅរស់នោះឡើយ។ នៅ

ពេលដែលបុគ្គលនោះបានសុខបានចម្រើន បាបកម្មទាំងនោះក៏នឹងអាចឱ្យផលទៅតាមកាលសមស្របរបស់វាដែរ។ វៀរលែងតែបុគ្គលនោះ រក្សានូវត្រៃសិក្ខា (សីល សមាធិ បញ្ញា) ឱ្យបានខ្ជាប់ខ្ជួន ហើយបានចាក់ធ្លុះក្នុងមគ្គ និងផល ដូចនេះ អកុសលកម្មទាំងឡាយនឹងមានកម្លាំងខ្សោយ ហើយមិនអាចអូសទាញបុគ្គលនោះទៅកាន់អបាយបានឡើយ។

## កម្មដ៏ចម្លែកនៃស្ត្រីឈរកាន់ក្អមទឹក

ព្រះគ្រូចៅអធិការវត្ត តោងម្យ៉ូ( *Taungmyo Sayadaw)* ដ៏ល្បីល្បាញមានព្រះនាម ជនកភិវង្ស( *Venerable Janakabhi vamsa)* បាននិទានរឿងមួយនៅក្នុងគម្ពីរ មហាបដ្ឋាន របស់លោក ស្តីអំពីស្ត្រីម្នាក់ដែលឈរកាន់ក្អមទឹក។ ស្ត្រីរូបនេះ រស់នៅក្នុងទីក្រុង អនុរាធបុរៈ ហើយនាងមានជីវភាពធូរធា និងជាអ្នកមានជំនឿយ៉ាងមាំនៅក្នុងព្រះរតនត្រ័យ។

នាងបានកសាងវត្ត ហើយឧទ្ទិសថ្វាយចំពោះភិក្ខុសង្ឃមានព្រះគ្រូចៅអធិការ តោង តាម៉ាន (*Taung Taman Sayadaw)* ជាប្រមុខ។ នៅក្នុងទីក្រុង អនុរាធបុរៈ នោះ នារដូវប្រាំងមានការខ្វះទឹកសម្រាប់ប្រើប្រាស់ជាខ្លាំង។ ដូចនេះហើយ នាងបានបញ្ឈរក្អមទឹកយ៉ាងច្រើន នៅតាមផ្លូវបំបែកនៃទីក្រុង។





ហេតុនេះហើយ នាងត្រូវបានគេហៅថា ស្ត្រីកាន់ក្អមទឹកបញ្ឈរ។

នាងបានស្លាប់ដោយជរាពាធ។ នៅឯពិធីបុណ្យសពរបស់នាង ព្រះគ្រូចៅអធិការ តោង តាម៉ាន បានដឹកនាំក្បួនដង្ហែរទៅកាន់ឈាបនដ្ឋាន ហើយប្រទានសីល និងឧទ្ទិសផ្សាយកុសលជូនចំពោះរូបគាត់។ ព្រះគ្រូក៏បានប្រទានធម្មទេសនាតាមកាលគួរដល់ប្រជាពុទ្ធបរិស័ទ ដែលបានចូលរួម។

នៅបុណ្យ៧ថ្ងៃ សាច់ញាតិរបស់គាត់បាននិមន្តភិក្ខុសង្ឃដើម្បីទទួលភត្ត ហើយព្រះគ្រូ តោង តាម៉ាន ក៏បានប្រទានធម្មទេសនាដែរ។ នៅតាមផ្លូវត្រឡប់មកវត្តវិញ លោកបានឮសំឡេងស្រែកហៅនៅលើដងផ្លូវ "ព្រះតេជគុណ ព្រះតេជគុណ"។

ពេលបានឮសំឡេងហើយ ព្រះគ្រូចៅអធិការនៅចំណាំបានថាជាសំឡេងនៃស្ត្រីកាន់ក្អមទឹកបញ្ឈរ។ រួចហើយលោកក៏បានសួរទៅកាន់គាត់ថា "តើអ្នកគឺជាញោមស្ត្រីកាន់ក្អមទឹកបញ្ឈរឬ?"។

គាត់ក៏បានឆ្លើយតប "ព្រះករុណា ព្រះតេជគុណ"។ ព្រះគ្រូចៅអធិការក៏សួរបន្ត " តើឥឡូវនេះញោមនៅឯណា? "

ប៉ុន្តែ ពុំមានការឆ្លើយតបឡើយ។ រហូតលោកសួរលើកទី

៣ ទើបគាត់ឆ្លើយប្រាប់ដោយសំឡេងខ្សាវៗថា៖ "ខ្ញុំព្រះករុណាឥឡូវនេះ គឺជាប្រេត"។

"ញោមស្រីបានធ្វើបុណ្យច្រើនណាស់។ ហេតុអ្វីបានទៅកើតជាប្រេតអ៊ីចឹង?"

ព្រោះខ្ញុំព្រះករុណាខ្វាយខ្វល់ពីកូនស្រី និងចៅៗរបស់ខ្ញុំព្រះករុណា ព្រោះមុនពេលស្លាប់ ពួកគេនាំគ្នាទ្រហោរយំនៅចំពោះមុខខ្ញុំព្រះករុណា"។

នៅពេលជិតស្លាប់ វាជាការចាំបាច់ណាស់ដែលត្រូវតែភាវនាធម៌ យកព្រះរតនត្រ័យ ជាទីពឹងទីរលឹក ឬរឭកនឹកដល់អំពើល្អដែលខ្លួនបានសាងសន្សំនៅក្នុងចិត្តឱ្យបានរឿយៗ។ កូនប្រុសស្រីគ្រប់រូប គួរតែជួយរំលឹកមាតាបិតាដែលហៀបនឹងស្លាប់ ដើម្បីឱ្យគាត់បានចងចាំអំពើល្អទាំងឡាយ ដែលពួកគាត់ធ្លាប់បានសាងសន្សំទុកមក ឬក៏ឱ្យពួកគាត់តាំងអារម្មណ៍ឱ្យស្ងប់ ហើយភាវនាគុណព្រះពុទ្ធថា "**អរហំ អរហំ**"។ បងប្អូនកូនចៅមិនគួរយំសោកបោកខ្លួន នៅក្បែរមនុស្សដែលរៀបនឹងស្លាប់ឡើយ បើពុំនោះទេ នឹងនាំឱ្យមានការខ្វាយខ្វល់ដល់បុគ្គលនោះ ដូចយ៉ាងដូច រឿងស្ត្រីកាន់ក្អមទឹកបញ្ឈរដែលបានបង្ហាញខាងលើ។

សេចក្តីខ្វល់ខ្វាយ ឬព្រួយបារម្ភបង្កើតបានជាទោសមូល





ចិត្ត។ ការជាប់ជំពាក់ចំពោះបុត្រធីតា បង្កើតបានជាលោភមូលចិត្ត។ អកុសលចិត្តទាំងនេះ បើកទ្វារឱ្យអកុសលកម្មតាក់តែងរៀបចំកំណើតថ្មី។ ហេតុដូច្នេះហើយ បានជាស្ត្រីកាន់ក្អមទឹកបញ្ឈរនោះទៅកើតជាប្រេត។

ខ្មោចស្ត្រីកាន់ក្អមទឹកបញ្ឈរនោះ បាននិយាយថា "ខ្ញុំករុណា អត់មានឱកាសបានស្តាប់ធម្មទេសនារបស់ព្រះតេជគុណទេ នៅឯឈាបនដ្ឋាននាថ្ងៃបូជានោះ"។ "ហេតុអ្វីបានជាញោមស្រីមិនបានស្តាប់?" "មិត្តស្រីខ្ញុំករុណាដែលជាខ្មោចដែរនោះ បាននាំខ្ញុំករុណាទៅភ្នំមួយដែលមានទឹកធ្លាក់"។

នៅឋានមនុស្សលោកយើងនេះ អ្នកមានទ្រព្យសម្បត្តិច្រើន ហើយជាអ្នកមានការបរិច្ចាគទាននោះ រមែងមានប្រជាប្រិយភាពក្នុងចំណោមជន។ មនុស្សគ្រប់រូបតែងជួយជ្រោមជ្រែង និងគោរពស្រឡាញ់ចំពោះមនុស្សបែបនេះណាស់។ នៅពេលដែលគេស្លាប់ទៅជាខ្មោចហើយក៏ដោយ ក៏ខ្មោចទាំងឡាយនោះនៅតែជ្រោមជ្រែង និងគោរពស្រឡាញ់ដែរ។ ហេតុដូច្នេះហើយ ខ្មោចស្រីជាមិត្តនោះ បានរាក់ទាក់ចំពោះខ្មោចស្ត្រីកាន់ក្អមទឹកបញ្ឈរនោះ ហើយនាំគាត់ទៅកាន់កន្លែងកំសាន្តនាឋានខ្មោចនោះ។ គោលបំណងដែលគាត់ត្រូវបាននាំទៅកំសាន្តនៅទឹកធ្លាក់

នោះ គឺដើម្បីកុំឱ្យស្ត្រីកាន់ក្អមទឹកបញ្ឈរ មានឱកាសស្តាប់ធម្មទេសនា។ ប្រសិនបើគាត់បានស្តាប់ធម្មទេសនា កុសលកម្ម ដែលគាត់បានសាងទាំងប៉ុន្មាននឹងដើរតួជាឧបឃាតកកម្ម កាត់ផ្តាច់នូវកំណើតក្នុងអបាយ ហើយផ្តល់កំណើតថ្មីក្នុងសុគតិភព។

ពួកប្រេតទាំងនោះចង់ឱ្យគាត់នៅទីនោះដែរ ព្រោះថានៅពេលដែលកូនចៅសាច់ញាតិដឹងថា ម្តាយគេទៅកើតជាប្រេតហើយ ប្រាកដជានឹងធ្វើទានថ្វាយភិក្ខុសង្ឃជារឿយៗ ហើយនឹងផ្សាយផលដល់គាត់មិនខាន។ នៅពេលដែលអាហារសេសសល់គាត់នឹងបោះចាល ដូច្នេះ ប្រេតទាំងឡាយនោះនឹងទៅរើសយកមកបរិភោគឱ្យស្កប់ស្កល់ដែរ។

"ប៉ុន្តែថ្ងៃនេះ ខ្ញុំករុណាបានស្តាប់ធម្មទេសនា ដែលព្រះតេជគុណបានសម្តែង ហើយខ្ញុំករុណាក៏បានទទួលនូវចំណែកនៃបុណ្យដែល កូនប្រុស កូនស្រីបានថ្វាយទានចំពោះភិក្ខុសង្ឃហើយដែរ។ ដូច្នេះ ខ្ញុំករុណា បានឱកាសទៅចាប់កំណើតថ្មីក្នុងសុគតិភពហើយ ។ ខ្ញុំករុណាថ្វាយបង្គំលាសិនហើយព្រះតេជគុណ" ។ សំឡេងនៃស្ត្រីកាន់ក្អមទឹកបញ្ឈរដែលជាប្រេតនោះក៏រសាត់ស្ងាត់បាត់ទៅ។

ព្រះធម៌របស់ព្រះសាស្តាចារ្យអាចជួយស្រោចស្រង់មនុស្ស





ដែលស្លាប់ទៅឱ្យរួចចាកទុក្ខទោសពីអបាយភូមិ។ ការជួយស្រោចស្រង់នេះ គឺសមហេតុសមផលណាស់ ព្រោះជំរុញឱ្យមនុស្សបំពេញនូវបុណ្យកុសល ធ្វើអំពើល្អផ្សេងៗ។ ប្រសិនបើ យើងចេះសាងសន្សំ និង បំពេញអំពើល្អឱ្យបានជាប់រឿយៗ ដោយឧបាយនៃប្រាជ្ញា នោះយើងនឹងទទួលបាននូវផលប្រយោជន៍យ៉ាងល្អប្រសើរ។

## តើកូនប្រុសជួយឪពុកឱ្យទៅកើតក្នុងសុគតិភព ដោយរបៀបណា

ព្រះថេរៈព្រះនាម សោណៈ គង់នៅលើភ្នំឈ្មោះ សោណគិរី ក្នុងប្រទេសស្រីលង្កា លោកបានត្រាស់ជាព្រះអរហន្ត ដោយសារវីរិយភាព ដ៏មុតមាំរបស់លោក។ ប៉ុន្តែ ញោមប្រុសរបស់លោក នៅតែរកស៊ីដើរបរបាញ់ បើទោះជាខ្លួនចាស់ជរាហើយក៏ដោយ។ ក្រោយមកនៅពេលដែលគាត់ទុព្វលភាពពេក ពុំអាចទៅបរបាញ់ទៀតបាន ទើបគាត់សម្រេចចិត្តសាងផ្នួសបួសជាភិក្ខុក្នុងអារាមនៃព្រះថេរៈជាកូននោះទៅ។

មិនយូរប៉ុន្មានផង ភិក្ខុថ្មីដែលមានវ័យជរានេះ ក៏ធ្លាក់ខ្លួនមានអាពាធជាទម្ងន់។ លោកបានឃើញឆ្កែជាច្រើនក្បាលមានមាឌធំ មានភ្នែកក្រហមឆ្អៅ មានចង្កូមស្រួចដូចរណារ កំពុងតែ

រត់ទៅលើភ្នំសំដៅមករកខាំលោក។ លោកមានការភិតភ័យយ៉ាងខ្លាំង ហើយក៏បានប្រាប់ទៅព្រះថេរៈ សោណៈជាបុត្រថា " កូនប្រុស ឆ្កែធំៗណាស់ កំពុងតែរត់ឡើងភ្នំ សំដៅមកខាំឪហើយ ចូរកូនដេញពួកវាចេញទៅ " ។

ព្រះសោណត្ថេរ ដែលជាព្រះអរហន្ត ភ្លាមៗនោះទ្រង់ពិចារណា ហើយជ្រួតជ្រាបថា ភិក្ខុជាបិតាកំពុងតែឃើញនូវនិមិត្តនៃសេចក្ដីស្លាប់ ដែលហៀបនឹងមកដល់(អាសន្ននិមិត្ត) និមិត្តនៃអបាយ កំពុងតែប្រាកដដល់លោកហើយ លោកប្រាកដជានឹងទៅកើតក្នុងអបាយភូមិ នៅពេលដែលផុតដង្ហើមដោយសារបាបកម្មនៃការបរបាញ់សត្វ។

ព្រះសោណត្ថេរ ក៏បានប្រើសាមណេរទាំងឡាយ ឱ្យទៅស្វែងរកផ្កា ហើយដាក់តម្កល់ជុំវិញចេតិយនៅលើភ្នំនោះ។ បន្ទាប់មក ក៏ឱ្យគេសែងភិក្ខុជាបិតាដែលចាស់ជរានោះទៅកាន់ចេតិយ។ "បពិត្រព្រះបិតា ដ៏ចម្រើន សូមទ្រង់នមស្សការថ្វាយបង្គំចំពោះព្រះបរមចេតិយ ពួកខ្ញុំព្រះករុណាទាំងឡាយសូមបូជាផ្កាចំពោះព្រះបរមចេតិយជំនួស សូមព្រះបិតាត្រេកអរ ជ្រះថ្លាចំពោះការថ្វាយនូវផ្កាទាំងនេះ ចំពោះព្រះសម្មាសម្ពុទ្ធ "។

ភិក្ខុជាបិតាក៏បានថ្វាយបង្គំព្រះបរមចេតិយ ហើយត្រេកអរ





ចំពោះការថ្វាយផ្កាដល់ព្រះសម្មាសម្ពុទ្ធ។

នៅពេលនោះ អាសន្ននិមិត្ត និមិត្ត ដែលកើតឡើងពេលជិតស្លាប់នោះ ក៏បានផ្លាស់ប្ដូរ។

"កូនប្រុស ញោមស្រីចុងទាំងឡាយ ដ៏ស្រស់ស្អាតរបស់កូន កំពុងតែបក់ដៃហៅឪឱ្យទៅជាមួយ តើឪគួរទៅជាមួយពួកគេទេ ? "។

"សូមបិតាអញ្ជើញទៅជាមួយពួកគេចុះ "។

ព្រះថេរៈ ជាកូនដឹងថា ម្ដាយចុងដែលញោមប្រុស បានប្រាប់នោះថា ជាស្រីទេពអប្សរឋានទេវលោកចុះមកទទួលរូបគាត់ទៅឋានសួគ៌ហើយ។ ព្រះសោណត្ថេរ មានសេចក្ដីសោមនស្សណាស់ ដែលបានជួយញោមប្រុសរបស់ខ្លួនមិនឱ្យទៅកើតក្នុងអបាយ។

(ក្រសួងកិច្ចការសាសនា ហត្ថកម្មពុទ្ធសាសនា ភាគ១ ទំព័រ៦៧៧)

## ៣) អាចិណ្ណកម្ម - *កម្មជាទម្លាប់*

អាចិណ្ណកម្ម គឺជាអំពើល្អ ឬអាក្រក់ដែលបុគ្គលទម្លាប់ធ្វើជាប្រចាំ ឬក៏អ្វីមួយដែលបុគ្គលបានធ្វើតែម្ដងហើយចងចាំនឹករលឹករឿយៗ។ ប្រសិនបើគ្រូបង្រៀនតែងតែពន្យល់ណែនាំសិស្សរបស់ខ្លួនដោយបំណងល្អ ដើម្បីឱ្យពួកគេមានចំណេះដឹង ការ

បង្រៀនជាប្រចាំនេះគឺជាកុសលអាចិណ្ណកម្ម គឺអំពើល្អជាប្រចាំ ឬទម្លាប់។ ប្រសិនបើស្ត្រីម្នាក់តែងចំអិនអាហារ ហើយដាក់បាត្រភិក្ខុសង្ឃអង្គសាមណេរជារៀងរាល់ថ្ងៃ ដូច្នេះទង្វើនេះក្លាយជាកុសលកម្មអចិន្ត្រៃយ៍។

ប្រសិនបើ បុគ្គលម្នាក់មានប្រក្រតីរក្សានូវសីល ហើយតែងតែពិចារណាត្រេកអរ ចំពោះសេចក្តីបរិសុទ្ធ ក្នុងសីលនោះជាប្រចាំ ការរក្សានូវសីលនេះហៅថា កុសលអាចិណ្ណកម្ម ។ សម្រាប់បុគ្គលអ្នកមានប្រក្រតីចម្រើននូវកម្មដ្ឋាន ការចម្រើននូវកម្មដ្ឋាននេះហៅថាអាចិណ្ណកម្ម។ សម្រាប់បុគ្គលអ្នកនេសាទត្រីបរបាញ់សត្វ លួចឆក់ប្លន់ ។ល។ ដើម្បីការចិញ្ចឹមជីវិតជាប្រចាំ ទង្វើបាបទាំងនេះក្លាយជាអកុសលអាចិណ្ណកម្ម គឺអំពើអាក្រក់ជាប្រចាំ ឬទម្លាប់។ ចាប់តាំងពីញោមប្រុសរបស់ព្រះសោណត្ថេរ រកស៊ីបរបាញ់ចិញ្ចឹមជីវិតមក ការបរបាញ់នេះឯងគឺជាអកុសលអាចិណ្ណកម្ម។ ហេតុនេះហើយ បានជាគាត់មាននិមិត្តឃើញឆ្កែនរកមាឌធំ មករកខាំគាត់ នៅពេលគាត់ជិតស្លាប់។

ប្រសិនបើ មិនមានវត្តមានគរុកកម្ម និងអាសន្នកម្មទេ អាចិណ្ណកម្ម នឹងដើរតួនាទីរបស់វាជាអ្នកសម្រេចតាក់តែងជាតិកំណើតថ្មី។





## ទម្លាប់គឺជាធម្មជាតិទីពីរ

អំពើល្អ ឬអំពើអាក្រក់ ដែលបុគ្គលបានធ្វើជាប្រចាំក្លាយទៅជាធម្មជាតិទីពីរ ឬក៏ជាទម្លាប់ធម្មជាតិនៃបុគ្គលនោះ។ ដូចនេះបុគ្គលនោះនឹងយកចិត្តទុកដាក់តែពីរឿងនោះ ហើយបន្តធ្វើវាជាប្រចាំដោយមិនបានបង្គាប់បញ្ជាខ្លួនឯងឡើយ។ គ្រូបង្រៀនដែលបង្ហាត់សិស្សរបស់គាត់ជាប្រចាំ នឹងរលឹកនឹកឃើញអាកប្ប-កិរិយាការបង្ហាត់បង្រៀនរបស់ខ្លួននៅពេលជិតស្លាប់។ បុគ្គលដែលបរបាញ់សត្វ នឹងឃើញឈុតឆាកការបរបាញ់របស់ខ្លួននៅពេលជិតស្លាប់ដែរ។ បុគ្គលអ្នកមានប្រក្រតីរលឹកនឹកដល់គុណព្រះសម្មាសម្ពុទ្ធ នឹងចងចាំនូវទង្វើនោះនៅពេលខ្លួនជិតស្លាប់ដែរ។ ដូច្នេះហើយ អំពើដែលយើងតែងធ្វើជាប្រចាំរៀងរាល់ថ្ងៃនឹងក្លាយជាអាសន្នកម្ម ដែលធ្វើឱ្យយើងនឹករលឹកឃើញនៅពេលជិតស្លាប់ ហើយវានឹងធ្វើតួនាទីរបស់ខ្លួនតាក់តែងកំណើតថ្មីឱ្យយើងតាមយថាកម្ម។

*វាជារឿងសំខាន់ណាស់ ដែលមនុស្សយើងត្រូវ*
*តែរស់នៅឱ្យបានល្អ ហើយអ្វីដែលចាំបាច់ជាង*
*នេះទៀតនោះ គឺយើងត្រូវស្លាប់ឱ្យបានល្អដែរ។*
*បច្ចុប្បន្នកាល គឺជាពេលវេលា ដ៏ប្រសើរបំផុត*

*សម្រាប់រៀបចំដំណើរបរលោក។ វិធីសាស្ត្រដ៏ល្អបំផុត ដើម្បីរៀបចំដំណើរនេះ គឺការទម្លាប់ធ្វើសេចក្តីល្អ ក្នុងពេលដែលយើងកំពុងរស់នៅ។ មានសេចក្តីល្អច្រើនយ៉ាងណាស់ សម្រាប់ឱ្យយើងជ្រើសរើសមានជាអាទិ៍ ការឱ្យទាន ការរក្សាសីល ឬ ភាវនា។ ប្រសិនបើយើងធ្វើសេចក្តីល្អជាប្រចាំ សេចក្តីល្អនេះ នឹងក្លាយជា កុសលអាចិណ្ណកម្ម គឺអំពើល្អជាប្រចាំ ឬ ជាទម្លាប់ ហើយអំពើល្អនេះ វានឹងតាក់តែងកំណើតក្នុងសុគតិភព។*

**៤) កដត្តាកម្ម** - *កម្មមិនជាក់លាក់*

កដត្តាកម្មនេះ គឺជាកម្មទីទៃអំពីកម្មទាំងឡាយដែលបានរៀបរាប់មកខាងលើ កម្មនេះគឺ ជាកម្មដែលបុគ្គលបានសាងពីមុនមក ហើយមិនបានចងចាំទេ ប៉ុន្តែវាអាចមានកម្លាំងគ្រប់គ្រាន់ដើម្បីតាក់តែងជាកំណើតថ្មីបានដែរ។ កម្មមិនជាក់លាក់នេះវានឹងមានឱកាសតាក់តែងកំណើតថ្មីបាន ប្រសិនបើមិនមានវត្តមាននៃកម្មទាំងបីខាងលើនោះមកបំពេញតួនាទីទេ។





## សេចក្តីប្រៀបធៀបនៃហ្វូងគោ

ដោយសារតែ កុសលកម្ម និង អកុសលកម្ម ដែលយើងបានសន្សំទុកក្នុងសន្តានច្រើនជាអនេក ធ្វើឱ្យយើងពិបាកនឹងបែកចែកថា កម្មណាមួយនឹងមានឱកាសឱ្យផលមុនក្នុងការតាក់តែងកំណើតថ្មី។ កម្មទាំងឡាយនឹងប្រកួតប្រជែងគ្នា ដណ្តើមយកឱកាសឱ្យផល។ ប្រសិនបើ មានវត្តមានគរុកកម្ម ដូច្នេះ គរុកកម្មនឹងឈ្នះដោយមិនបាច់ប្រជែង ហើយវានឹងជាអ្នកតាក់តែងកំណើតថ្មី។

ប្រសិនបើ មិនមានវត្តមានគរុកកម្មទេ អាសន្នកម្មនឹងឆក់ឱកាសតាក់តែងកំណើតថ្មី។ ប្រសិនបើ គរុកកម្ម និងអាសន្នកម្ម អវត្តមាន អាចិណ្ណកម្មនឹងឆក់ឱកាសតាក់តែងកំណើតថ្មី។ ប្រសិនបើ អាចិណ្ណកម្មអវត្តមានទៀត កដត្តាកម្មនឹងឆក់ឱកាសតាក់តែងកំណើតថ្មី។

ការឱ្យផលនៃកម្មទាំងបួនប្រភេទខាងលើនេះ អាចប្រៀបធៀបទៅនឹងហ្វូងគោ។ ឧទាហរណ៍ថា មានគោជាច្រើនក្បាលដែលគេរក្សាទុកក្នុងក្រោលយ៉ាងធំមួយនៅពេលរាត្រី។ លុះពេលព្រឹកឡើង ទ្វារនៃក្រោលនោះ ត្រូវបានគេបើកដើម្បីឱ្យគោទាំង

នោះបានចេញទៅវាលស្មៅ។ ឥឡូវនេះ សូមពិចារណាទាំងអស់គ្នាមើលថា តើគោមួយណាចេញមកមុនគេ?

គោទាំងអស់សុទ្ធតែចង់ចេញមកមុនរៀងៗខ្លួន ដូច្នេះប្រាកដជាមានការច្របូកច្របល់ និងប្រញាយគ្នាដើម្បីបានចេញមុន។ ប៉ុន្តែប្រសិនបើ មានគោមួយក្បាលដែលចំណានជាងគេដែលត្រូវបានគោទាំងឡាយគោរពទុកដូចជាមេ អ៊ីចឹង គោមួយក្បាលនេះប្រាកដបានចេញមុនគេមិនខាន។ នេះប្រៀបបានទៅនឹងគរុកកម្ម ដែលពុំមានកម្មណាមួយហ៊ានប្រឡងប្រជែងជាមួយឡើយ ហើយវានឹងឱ្យផលតាក់តែងកំណើតថ្មី។

ម្យ៉ាងវិញទៀត ប្រសិនបើ ពុំមានគោណាមួយ ដែលត្រូវបានគេចាត់ទុកជាមេនោះទេ គោដែលនៅជិតមាត់ទ្វារជាងគេនឹងបានចេញមកមុន។ នេះប្រៀបបានទៅនឹងអាសន្នកម្ម ដែលឱ្យផល ហើយតាក់តែងកំណើតថ្មី។

ប្រសិនបើ ពុំមានគោទាំងពីរប្រភេទខាងលើទេ គោដែលមានការប្រុងស្មារតីជាងគេ ដែលតែងតែចងចាំពេលវេលាដែលគេត្រូវបើកទ្វារជាប្រចាំនោះ នឹងដើរទៅរង់ចាំមាត់ទ្វារមុនគេ មុនពេលទ្វារបើក ដល់ពេលគេបើកទ្វារ គោមួយក្បាលនេះនឹងបាន





ចេញមុនគេ។ នេះប្រៀបបានទៅនឹងអាចិណ្ណកម្ម ដែលវាដើរតួនាទីក្នុងការតាក់តែងកំណើតថ្មី។

នៅពេលខ្លះ ពេលដែលគ្មានគោទាំងបីប្រភេទខាងលើទេ នឹងមានការប្រញាយគ្នារវាងគោដែលមានកម្លាំងខ្លាំងៗ ដើម្បីបានចេញមុន។ ដូច្នេះដោយសារតែការបុករុញច្រានគ្នានៃគោដែលមានកម្លាំងខ្លាំងៗ គោដែលចាស់ៗ មានកម្លាំងខ្សោយអាចចេញមកមុន ព្រោះត្រូវបានគេរុញដោយកម្លាំង ខ្លួនប្រាកដជាខ្ទាតចេញមុនមិនខាន។ នេះមិនខុសអីនឹងករណីដែល កដត្តាកម្ម(កម្មមិនជាក់លាក់) មានឱកាសក្នុងការតាក់តែងកំណើតថ្មីឡើយ។

មាន កុសលកម្ម និង អកុសលកម្ម រាប់មិនអស់នៅក្នុងសន្តានដែលបានសន្សំទុកមក ហើយទាំងអស់នេះសុទ្ធតែអាចដើរតួជា កដត្តាកម្មបានទាំងអស់។ ប្រសិនបើ កុសលកដត្តាកម្ម(អំពើល្អមិនច្បាស់លាស់)មានឱកាសឱ្យផល បុគ្គលនោះនឹងមានសំណាងល្អ។ តែបើ អកុសលកដត្តាកម្ម ឱ្យផលមុននោះនឹងមានដំណើរឆ្ពោះទៅកាន់ទុគតិភព ហើយបើទៅកើតក្នុងទីនោះហើយ ពិបាកនឹងចេញមកវិញណាស់ព្រោះទីនោះជាកន្លែងកើតស្លាប់ៗ ។ យើងមិនគួរអនុញ្ញាតឱ្យ អកុសលកដត្តាកម្ម

សម្រេចជោគវាសនាឱ្យយើងនោះទេ ព្រោះថា យើងគឺជាម្ចាស់ជោគវាសនារបស់ខ្លួនយើង។ ដូច្នេះ យើងគួរណាស់តែព្យាយាមទម្លាប់ធ្វើអំពើល្អឱ្យបានច្រើន ដើម្បីឱ្យអំពើល្អនេះតាក់តែងកំណើតថ្មីក្នុងសុគតិភពឱ្យយើង។

## កើតក្នុងអវិចីនរកថ្វីត្បិតតែមានកម្មល្អច្រើន

ព្រះនាង មល្លិកាទេវី ជាព្រះអគ្គមហេសីនៃព្រះបាទបសេនទិកោសល នៅក្នុងក្រុងសាវត្ថី បានបំពេញបុណ្យកុសលយ៉ាងច្រើនជាមួយនឹងព្រះរាជា។ ជាងនេះទៅទៀត ព្រះនាង ក៏ធ្លាប់បានប្រគេនចង្ហាន់បិណ្ឌបាតដ៏ល្អប្រណីត ជាមួយព្រះរាជាថ្វាយភិក្ខុសង្ឃ មានព្រះសម្មាសម្ពុទ្ធជាប្រធាន។ ប៉ុន្តែ អកុសលពេលមួយ ព្រះនាងបានប្រព្រឹត្តអកុសលកម្មមួយ ដ៏គួរឱ្យកត់សម្គាល់។ ថ្ងៃមួយខណៈពេល ព្រះនាងកំពុងតែស្រង់ទឹក ស្រាប់តែមានឆ្កែមួយក្បាលចូលទៅក្នុងបន្ទប់ទឹកនោះដែរ ពេលនោះព្រះនាងក៏បានសេពកាមជាមួយនឹងឆ្កែនោះ។ នៅពេលព្រះនាងចេញពីបន្ទប់ទឹក ឆ្កែនោះចេះតែដើរតាមជាហេតុធ្វើឱ្យព្រះរាជាកត់សម្គាល់ ហើយក៏បានសួរទៅព្រះនាងភ្លាម។ តែព្រះនាងមល្លិកា បានឆ្លើយយ៉ាងភ្លៀវភ្លាថា នាងចេញមកតែម្នាក់ឯងទេ ព្រះអង្គប្រហែលជាយល់ច្រឡំហើយ។ ព្រះរាជាក៏ជឿតាមបន្ទូល





អគ្គមហេសី ហើយទ្រង់មិនដេញដោលទៀតឡើយ។ ប៉ុន្តែ អកុសលកម្មនេះ ធ្វើឱ្យព្រះនាងចងចាំនៅពេលដែលព្រះនាងជិតសោយព្រះវិលាល័យ។ ដោយសារតែ អកុសលកដត្តាកម្ម នេះឱ្យផលនឹងហើយ ទើបបានជាព្រះនាងត្រូវទៅរងទុក្ខ ក្នុងអវិចីនរកអស់ប្រាំពីរថ្ងៃ។

ព្រះបាទបសេនទិកោសល ជឿជាក់ថា ព្រះអគ្គមហេសីដ៏វៃឆ្លាតរបស់ព្រះអង្គ ប្រាកដជាបានទៅកើតក្នុងទេវលោកមិនខាន។ ប៉ុន្តែដើម្បីបញ្ជាក់ឱ្យកាន់តែច្បាស់ ព្រះអង្គក៏យាងទៅកាន់វត្តជេតពន ដើម្បីទូលសួរព្រះសាស្តា។ ព្រះសាស្តា ដោយព្រះបញ្ញាញាណរបស់ព្រះអង្គ បណ្តាលឱ្យព្រះរាជាភ្លេចសួរសំណួរ ព្រះរាជាបែរជាទ្រង់សួររឿងផ្សេងៗទៅវិញ ហើយក៏យាងត្រឡប់ទៅរាជវាំងវិញ។ នៅថ្ងៃបន្ទាប់ទៀត ព្រះរាជា ក៏យាងទៅកាន់វត្តជេតពនម្តងទៀត ដើម្បីទូលសួរព្រះសាស្តាអំពីព្រះអគ្គមហេសីដែលសោយព្រះវិលាល័យហើយនោះ ទៅកើតក្នុងទីណា ប៉ុន្តែក៏ដូចថ្ងៃមុនដែរ ដោយអំណាចពុទ្ធានុភាព ព្រះរាជាចេះតែភ្លេច។ រហូតដល់ថ្ងៃទីប្រាំបី ទើបព្រះសាស្តាទ្រង់បណ្តាលឱ្យព្រះរាជានឹកឃើញ ទើបក្នុងថ្ងៃនោះ ព្រះបាទ បសេនទិកោសល ក៏ទ្រង់

សួរនូវរឿងនេះចំពោះព្រះសាស្តា។ ព្រះបរមសាស្តាទ្រង់ត្រាស់ថា ឥឡូវនេះព្រះនាង មល្លិកា ទ្រង់នៅឋានតុសិតឯណោះ។

ព្រះនាង មល្លិកាទេវី ពិតជាមានសំណាងណាស់ ទ្រង់សោយទុក្ខក្នុងអវិចីនរក ត្រឹមតែប្រាំពីរថ្ងៃមនុស្សប៉ុណ្ណោះ។ កុសលកម្មទាំងឡាយដ៏ច្រើន ដែលព្រះនាងទ្រង់បានបំពេញមក កុសលកម្មទាំងនោះណាមួយបានដើរតួជា ឧបឃាតកកម្ម កាត់ផ្តាច់នូវអកុសលកម្ម ដែលនាំឱ្យព្រះនាងទៅកើតក្នុងអវិចីនរក ហើយឱ្យផលជាសុខនាំព្រះនាងទៅកាន់សុគតិភពវិញ។ ដូច្នេះ យើងឃើញថា មានតែកុសលកម្មទេដែលយើងអាចពឹងពាក់ពំនាក់អាស្រ័យបាន។

## ៤.កម្ម៤ប្រភេទយោងតាមពេលវេលានៃការឱ្យផល

| | |
|---|---|
| **(១)ទិដ្ឋធម្មវេទនីយកម្ម** | កម្មដែលឱ្យផលភ្លាមៗ ឬក្នុងបច្ចុប្បន្ន |
| **(២)ឧបបជ្ជវេទនីយកម្ម** | កម្មដែលឱ្យផលបន្តបន្ទាប់ |
| **(៣)អបរាបរិយវេទនីយកម្ម** | កម្មដែលឱ្យផលមិនកំណត់ ឬមិនដាក់លាក់ |
| **(៤)អហោសិកម្ម** | កម្មដែលមិនឱ្យផល |





នៅពេលបុគ្គលម្នាក់ធ្វើអំពើល្អ ឬអំពើអាក្រក់ កុសលចិត្ត ឬអកុសលចិត្ត កើតឡើងប្រាំពីរដង ដើរតួជាជវនចិត្តនៅក្នុងវិថីចិត្ត។ ជវនចិត្ត កើតជាមួយមហន្តារម្មណ៍ ហើយដឹងនូវអារម្មណ៍ទាំងឡាយ ដែលចេញចូល ហេតុដូចនេះហើយ ទើបហៅថា ជវនចិត្ត។

ចេតនាដែលសម្បយុត្ត(ប្រកបព្រម)ជាមួយនឹង ជវនចិត្តទីមួយ ដែលជាជវនចិត្ត មានកម្លាំងខ្សោយជាងគេ ក្នុងចំណោមជវនចិត្ត ទាំងប្រាំពីរហៅថា ទិដ្ឋធម្មវេទនីយកម្ម កម្មដែលឱ្យផលក្នុងជាតិនេះ។ ចេតនាដែលសម្បយុត្តជាមួយនឹងជវនចិត្តទីប្រាំពីរដែលជា ជវនចិត្ត មានកម្លាំងខ្លាំងជាងគេក្នុងចំណោមជវនចិត្តទាំងប្រាំពីរហៅថា ឧបបជ្ជវេទនីយកម្ម។ កម្មនេះឱ្យផលចាប់ពីជាតិទីពីរហូតដល់ជាតិចុងក្រោយ ដែលបុគ្គលបានសម្រេចអរហត្តផល ហើយកម្មនឹងឱ្យផលនៅពេលដែលវាមានឱកាស។ កម្មទាំងពីរប្រភេទខាងលើនេះនឹងក្លាយជា អហោសិកម្ម(មិនឱ្យផល)ប្រសិនបើ វាគ្មានឱកាស ក្នុងកំឡុងពេលដែលវាត្រូវឱ្យផល។

**(១) ទិដ្ឋធម្មវេទនីយកម្ម** -កម្មដែលឱ្យផលភ្លាមៗ

ក្នុងមួយផ្ទាត់ម្រាមដៃ ចិត្តកើតរលត់ៗច្រើនជាងមួយ

សែនកោដិដង (មាន២៨សូន្យ) ហើយក្នុងវិថីចិត្តមួយមានចិត្តប្រហែលដប់ប្រាំពីរ។ ដូច្នេះ ក្នុងមួយសែនកោដិចិត្តអាចមានវិថីចិត្តប្រហែលជាង ៥០,០០០លាន។ នៅក្នុងវិថីចិត្តទាំងនេះ ជវនចិត្តទីមួយ មានចិត្តប្រហែល ជាង៥០,០០០លាន ជវនចិត្តទីប្រាំពីរជាង ៥០,០០០លាន និងជវនចិត្តនៅកណ្តាល ជាង ២៥០,០០០លាន។

ដូច្នេះ ក្នុងការធ្វើអភិវាទចំពោះព្រះសាស្តាក្នុងពេលតែមួយខណៈ ឬក៏ក្នុងពេលតែមួយញ៉ិចមូសឱ្យស្លាប់ យ៉ាងហោចណាស់ ៥០,០០០លាន ទិដ្ឋធម្មវេទនីយកម្ម ៥០,០០០លាន ឧបបជ្ជវេទនីយកម្ម និង ២៥០,០០០ លាន អបរាបរិយវេទនីយកម្មអាចកើតមាន។ ទិដ្ឋធម្មវេទនីយកម្មទាំងនេះ ប្រសិនបើគ្មានឱកាសឱ្យផលក្នុងជាតិនេះទេ នឹងក្លាយជា អហោសិកម្ម គឺលែងឱ្យផលហើយ។ មានឧទាហរណ៍ច្រើនណាស់ ដែលអាចបញ្ជាក់អំពីការឱ្យផលនៃទិដ្ឋធម្មវេទនីយកម្មនេះ។ ដូចជារឿងបុរសកំសត់ម្នាក់ ឈ្មោះ **មហាទុគ្គត** ដែលមានឱកាសបានប្រគេនចង្ហាន់បិណ្ឌបាតចំពោះព្រះពុទ្ធទ្រង់ព្រះនាម កស្សបៈ ហើយបុរសនោះក៏ក្លាយទៅជាអ្នកមានទ្រព្យសម្បត្តិច្រើនមួយរំពេចនោះ។

កាលព្រះសម្ពុទ្ធសមណគោតម ទ្រង់គង់ធរមាននៅ មាន





គ្រួសារទុគ៌តមួយ បុរសឈ្មោះ **បុណ្ណៈ**ជាប្តី និងភរិយាបានប្រគេនចង្ហាន់បិណ្ឌបាតដល់ព្រះសារីបុត្ត ដែលទើបតែយាងចេញពីនិរោធសមាបត្តិ។ ក្រោយមកមិនយូរប៉ុន្មានប្តីប្រពន្ធទាំងពីរនាក់កំពុងតែភ្ជួរស្រែ ក៏ស្រាប់តែឃើញដីដែលខ្លួនភ្ជួរនោះក្លាយទៅជាដុំមាស ទាំងពីរនាក់ប្តីប្រពន្ធក៏ក្លាយទៅជាអ្នកមានស្តុកស្តម្ភ។

នៅនគរ សាវត្ថី មានគ្រួសារដ៏ក្រខ្សត់មួយឈ្មោះ **កាកវាលិយ** ពួកគេក្រខ្លាំងណាស់រកតែផ្ទះនៅមិនចង់បាន សូម្បីតែកន្ទេល គ្រែ ក៏គ្មានដែរ រាល់ថ្ងៃពួកគេដេកផ្ទាល់នឹងដី។ រាល់ថ្ងៃ ពួកគេរស់ដោយសារតែការចែករំលែកអាហារបន្តិចបន្តួច ពីសំណាក់អ្នកភូមិ ហើយបានត្រឹមតែម្នាក់មួយចំអែតប៉ុណ្ណោះ។ ព្រឹកមួយនៅពេលដែលពួកគេរៀបនឹងបរិភោគបបរ ស្រាប់តែព្រះមហាកស្សបៈ ដែលទើបតែចេញពីនិរោធសមាបត្តិ យាងមកបិណ្ឌបាតដល់មុខផ្ទះ។ ពួកគេជ្រះថ្លាណាស់ ក៏យកបបររបស់ខ្លួនទៅប្រគេនចំពោះព្រះមហាកស្សបៈ។ ប្រាំពីរថ្ងៃក្រោយមកពួកគេបានទទួលភាជន៍មាសមួយដ៏ល្អប្រណីត ហើយក៏ក្លាយជាអ្នកមាន ទ្រព្យសម្បត្តិស្តុកស្តម្ភ។

កម្លោះម្នាក់ឈ្មោះ នន្ទ បានប្រព្រឹត្តមេថុនធម្មទៅលើ

ឧប្បលវណ្ណាថេរី ដែលជាសាវ័កែឆ្វេងខាងភិក្ខុនីនៃព្រះសមណគោតម ភ្លាមៗនោះដែរ ក៏ត្រូវបានធរណីស្រូបទៅបាត់។

អ្នកកាប់ជ្រូកឈ្មោះ ចុន្ទ រាល់ថ្ងៃហូបតែសាច់ជ្រូក បើគ្មានសាច់ជ្រូកទេ គាត់មិនចេះបរិភោគទេ។ ថ្ងៃមួយពេលអត់មានសាច់ជ្រូកធ្វើម្ហូប គាត់ក៏ទៅកាត់អណ្ដាតគោយកមកចៀនហូប។ នៅពេលដែលគាត់កំពុងតែបរិភោគ អណ្ដាតរបស់គាត់ស្រាប់តែដាច់ដោយឯងៗ ហើយធ្លាក់ចូលក្នុងចានរបស់គាត់។

យ៉ាងណាមិញ នៅក្នុងបច្ចុប្បន្ននេះ បើសិនជាយើងយកចិត្តទុកដាក់ពិនិត្យអង្កេតមើល យើងនឹងឃើញឧទាហរណ៍ជាក់ស្តែងយ៉ាងច្រើន ដែលឱ្យផលក្នុងបច្ចុប្បន្ននេះ។ បុគ្គលអ្នកប្រព្រឹត្តបទឧក្រិដ្ឋផ្សេងៗដូចជា ចោរកម្ម ប្លន់ សម្លាប់ ចាប់រំលោភ ។ល។ នឹងត្រូវផ្តន្ទាទោសតាមច្បាប់ មានការដាក់ខ្នោះច្រវ៉ាក់ ដាក់គុកជាដើម។ ពួកគេត្រូវតែទទួលនូវផលនៃបាបកម្មដែលពួកគេបានសាងក្នុងជាតិនេះភ្លាមៗ ដោយមិនរង់ចាំជាតិក្រោយឡើយ។

## ផលរបស់កម្មមិនអាចជៀសវាងបានឡើយ

មានអត្ថបទមួយគួរឱ្យចាប់អារម្មណ៍ដែលបោះពុម្ពផ្សាយក្នុងទស្សនាវដ្តី ម្យ៉ាត់ មង្គលៈ (*Myat Mangala,Vol.5, No.8*)។





មានស្ត្រីម្នាក់ឈ្មោះ ដាវ ម៉ាពូ (*Daw Mar Pu*) រស់នៅក្នុងភូមិទូយិនសេក(*Du Yin Seik*) ស្រុក តាថុន (*Thaton Township*) ប្រទេសភូមា និយាយមិនច្បាស់ដោយសារតែបបូរមាត់ខាងលើរបស់នាងឆែប។ នាងចិញ្ចឹមជីវិតដោយការដើរលក់ត្រី នាងទូលកញ្ជើដើរលក់ត្រីជុំវិញភូមិ ហើយស្រែកថា៖

"ត្រូវការយិញយាយទេ?" (*Would you like to yuy yish?*) អ្នកភូមិដឹងយ៉ាងច្បាស់ថា នាងស្រែកថា "ត្រូវការទិញត្រីទេ?" ប៉ុន្តែមានបុរសម្នាក់នោះឈ្មោះថា កូ តាន ធុន (*Ko Than Tun*) តែងតែលេងសើចធ្វើតម្រាប់តាមនាង។ នាងអន់ចិត្តណាស់ ប៉ុន្តែចេះតែខំអត់ធ្មត់ទៅ ដោយសារនាងជាអ្នកក្រ។ មិនយូប៉ុន្មាន ប្រពន្ធបុរស កូ តានធុន កើតបានកូនប្រុសម្នាក់ដែលមានបបូរមាត់ខាងលើឆែបដូចនាង ម៉ាពូ ដែរ។ ក្រោយមកទៀត កូតានធុន កើតបានកូនប្រុសម្នាក់ទៀតមានសភាពប្រក្រតី ប៉ុន្តែនៅពេលកូននោះធំឡើងចូលចិត្តលេងជាមួយនឹងកូនប្រុសច្បងយូរៗទៅ កូនប្អូននោះស្រាប់តែនិយាយមិនច្បាស់ ដូចបងរបស់ខ្លួនដែរ។ កូតានធុន ដោយសារភាពក្រីក្រ ដូចនេះប្រពន្ធរបស់គាត់ត្រូវទិញម្សៅធ្វើនំលក់។ ដោយលក់នៅផ្ទះមិនសូវដាច់នោះ ទើបឱ្យកូនបង ដែលមានអាយុ៦ឆ្នាំហើយនោះ ដើរ

លក់តាមភូមិ នៅពេលដើរលក់តាមផ្លូវ កុមារនោះតែងតែស្រែកឱ្យគេមកទិញនំ៖

"ត្រូវការយិញយំទេ?"

ម្តងនេះ មានបុរសម្នាក់ឈ្មោះ កូ ម្យិន ថេ (*Ko Myint Htay*)លេងសើចហើយធ្វើតម្រាប់តាម។ កុមារនោះអន់ចិត្តយ៉ាងខ្លាំងរហូតដល់យំ។ ក្រោយមកមិនយូរប៉ុន្មានប្រពន្ធ កូ ម្យិន ថេ កើតបានកូនស្រីម្នាក់ ដែលមានបបូរមាត់ឆែបដែរ។ ពេលធំឡើងនាងក៏និយាយមិនច្បាស់ដែរ។

នេះសបញ្ជាក់ឱ្យឃើញថា កម្មដែលបុគ្គលបានសាងហើយមិនអាចគេចផុតបានទេ។ ផលនៃបាបកម្មនោះនឹងឱ្យផលក្នុងបច្ចុប្បន្នជាតិនេះឯង។

## អ្នកសប្បុរសត្រូវបានរង្វាន់ក្នុងជាតិនេះឯង

អ្នកដែលធ្វើអំពើល្អរមែងទទួលផលក្នុងបច្ចុប្បន្ននេះដែរ។ នៅពេលខ្ញុំទៅរដ្ឋ កឈិន (*Kachin State*) ដែលនៅប៉ែកខាងជើងនៃប្រទេសភូមា ដើម្បីបង្រៀនព្រះអភិធម្ម ខ្ញុំបានជួបលោក កូ ធុន ធុន(*Ko Tun Tun*)និងនាង មា វ៉េ វ៉េ(*Ma Way Way*)។ លោក ធុនធុន គឺជាពុទ្ធសាសនិក មកពីភូមិភាគកណ្តាលនៃប្រទេសភូមា ហើយនាង មា វ៉េ វ៉េ គឺជាគ្រីស្តសាសនិកមកពី





ម្យិតជិណា(*Myit-kyina*)។ ប្តីប្រពន្ធដ៏ក្មេងនេះបានទៅ ផាកាន (*Hpar Kant*) ដូចគេស្គាល់ថាជាទឹកដីរតនវត្ថុ(សំបូរត្បូង មាស ពេជ្រ) ដែលមានចំងាយត្រឹមតែ១៥ម៉ាយពី ម្យិតជិណា។ ពួកគេមានក្បាលដីមួយកន្លែងនៅទីនោះ ហើយក៏នាំគ្នាជីករុករកក្រែងមានរតនវត្ថុ ប៉ុន្តែពីរបីថ្ងៃកន្លងផុតទៅគ្មានឃើញអ្វីសោះ។

ថ្ងៃមួយមានព្រះសង្ឃមួយអង្គនិមន្តទៅកាន់ ផាកាន ដែរ មនុស្សម្នានៅទីនោះនាំគ្នាយកចង្ហាន់ទៅប្រគេនលោក។ ធុនធុន ក្រោយពីបានត្រូវឆ្នោតហើយ ក៏នាំភរិយារបស់ខ្លួនយកចង្ហាន់ទៅប្រគេនព្រះសង្ឃ ដែរ។

មួយអាទិត្យក្រោយមក នាង មា វ៉េ វ៉េ ក៏បានជួបព្រះសង្ឃមួយអង្គនៅតាមផ្លូវ នាងក៏បានទូលសួរលោកថា "តើព្រះតេជគុណមានចង្ហាន់ឆាន់គ្រប់គ្រាន់ទេ?" "អាត្មាភាពជាអាគន្តុកៈពិបាកនឹងបិណ្ឌបាតណាស់" "បើដូចនេះ សូមព្រះតេជគុណនិមន្តទទួលភត្តនៅផ្ទះខ្ញុំព្រះកុណានៅថ្ងៃស្អែក"។

ពេលទៅដល់ផ្ទះបានប្រាប់ប្តីរបស់នាង បុរសជាប្តីមានសទ្ធាជ្រះថ្លាណាស់ ហើយក៏បានរៀបចំចង្ហាន់ប្រគេនលោកនៅថ្ងៃបន្ទាប់នោះទៅ។ បន្ទាប់ពីប្រគេនចង្ហាន់លោកបានតែពីរថ្ងៃគត់ ប្តីប្រពន្ធទាំងពីរបានជីកប្រទះឃើញត្បូងទទឹម(*Rubies*)

យ៉ាងច្រើននៅក្នុងដីរបស់ពួកគេ។ នៅពេលដែលពួកគេត្រឡប់ទៅ ម្យិតជិណា វិញ ក៏បានជួបជាមួយព្រះគ្រូមេគណនៃវត្តនោះ ដែលមានព្រះនាម វុន ថូ (*Wun Tho Sayadaw*) ដែលលោកកំពុងតែកសាងវត្ត។ ធុនធុន ក៏បានអរាធនាសូមព្រះគ្រូកសាងវត្តទាំងមូល។ ពេលក្រោយមកទៀតពួកគេបានប្រទះឃើញត្បូងមួយចំនួនទៀតពីដីឡូរបស់ពួកគេ។ វត្តដែលពួកគេបានកសាងប្រគេនព្រះសង្ឃនោះធំណាស់ មានអាគារកំពស់ពីរជាន់។ ជាងនេះទៅទៀតពួកគេក៏បានប្រគេនឡាន ប៉ាហ្សេរ៉ូមួយ ដល់លោកគ្រូចៅអធិការផងដែរ។

ធ្វើទានកាន់តែច្រើន ពួកគេកាន់តែមាន។ ផលនៃអំពើល្អដោយការប្រគេនចង្ហាន់ដល់ភិក្ខុសង្ឃ មានអានិសង្សច្រើនគួរជាទីគាប់ចិត្ត។

**(២) ឧបបជ្ជវេទនីយកម្ម** - កម្មដែលឱ្យផលបន្តបន្ទាប់

ចេតនាសម្បយុត្តជាមួយនឹង ជវនចិត្ត ទីប្រាំពីរ ដែលជាជវនចិត្តមានកម្លាំងខ្លាំងជាងគេក្នុងចំណោមជវនចិត្តទាំងប្រាំពីរ ហៅថា ឧបបជ្ជវេទនីយកម្ម។ កម្មនេះឱ្យផលទៅជាតិខាងមុខ បើពុំនោះទេនឹងក្លាយជាអហោសិកម្ម។

ស្ត្រីវ័យចំណាស់ម្នាក់ឈ្មោះ ចណ្ឌាលី ដែលរស់នៅ





ដោយការសុំទាន កំពុងតែដើរនៅលើដងវិថីនៃក្រុងរាជគ្រឹះ។ នាងបានប្រាកដក្នុងសំណាញ់ញាណនៃព្រះសាស្តា ដោយសារតែនាងមិនបានធ្វើបុណ្យនឹងគេ នាងប្រាកដជាទៅកាន់អបាយនៅពេលស្លាប់ទៅ។

ព្រះសាស្តាចារ្យនៃយើងប្រកបដោយមហាករុណាទិគុណចំពោះស្ត្រីចំណាស់នេះ ដូចនេះ ព្រះអង្គ ក៏ទ្រង់យាងទៅបិណ្ឌបាត ហើយបានជួបនាងនៅឯជាយក្រុងរាជគ្រឹះ។ នៅពេលដែលព្រះសាស្តាទ្រង់ឈប់ពីមុខនាងៗក៏ឈប់ង៉ក់ដែរ ហើយក្រឡេកមើលព្រះសាស្តា ប៉ុន្តែ នាងមិនបានធ្វើគារវកិច្ចឡើយ ព្រោះមិនបានដឹងថា ជាព្រះសាស្តា។ ដូច្នេះ នាងពុំទាន់ទទួលបានបុណ្យកុសលអ្វីនៅឡើយ ដោយសារតែពុំបានធ្វើគារវកិច្ចចំពោះព្រះសាស្តា។

ព្រះមហាមោគ្គល្លាន ដែលនិមន្តទៅជាមួយព្រះពុទ្ធ ទ្រង់យល់ច្បាស់អំពីព្រះទ័យព្រះពុទ្ធ ដែលទ្រង់ចង់ប្រទានពរជ័យឱ្យស្ត្រីនេះ ដូចនេះ លោកក៏លួងលោមស្ត្រីនោះថា "ម្នាលញោមស្រី ព្រះសាស្តាចារ្យកំពុងតែគង់នៅទីចំពោះមុខនៃញោមហើយ ព្រះអង្គនឹងប្រទានពរជ័យដល់ញោមៗស្រីជិតស្លាប់ទៅហើយ បើស្លាប់ទៅប្រាកដជានឹងទៅកាន់អបាយពុំខាន ហេតុនេះសូម

ញោមស្រីធ្វើការវកិច្ចចំពោះព្រះសាស្តាចុះ"។

នៅពេលនោះ នាងក៏ចាប់ផ្តើមសម្លឹងមើលទៅព្រះសាស្តាម្តងទៀត ដោយយកចិត្តទុកដាក់ ហើយទើបថ្វាយបង្គំព្រះអង្គ។ ការថ្វាយបង្គំចំពោះព្រះសម្មាសម្ពុទ្ធ សូម្បីត្រឹមតែមួយនាទីប៉ុណ្ណោះ ក៏កុសលកម្មរាប់រយកោដិអាចកើតមានបាន។ បណ្តាកម្មទាំងនេះ កម្មដែលមានកម្លាំងជាងគេ គឺ**ឧបបជ្ជវេទនីយកម្ម** នឹងឯងដែលដើរតួនាទីតាក់តែងកំណើតឱ្យស្ត្រីនេះ បានទៅកាន់សុគតិភព។ ព្រះសម្មាសម្ពុទ្ធ ទ្រង់ជ្រាបក្នុងរឿងនេះយ៉ាងច្បាស់ ទើបទ្រង់និមន្តទៅទីនោះ។

បន្ទាប់មក ចណ្ឌាលី ស្ត្រីចំណាស់ ក៏បានបន្តដំណើររបស់នាងទៅមុខទៀត ដោយដំណើរទាំងរញ៉ីរញ៉ៃស្រាប់តែមានគោមេមួយក្បាល និងកូនរបស់វាបានបុកនាងដួលស្លាប់បាត់ទៅ។ កុសលកម្មដែលកើតពីការថ្វាយបង្គំចំពោះព្រះសាស្តានោះ បានឧបត្ថម្ភឱ្យនាងបានទៅកើតជា ទេពធីតា ក្នុងវិមានទិព្វនៃឋានតាវតិង្ស។ ភ្លាមៗនោះ នាងក៏បានចុះមកឋានមនុស្ស ហើយទៅធ្វើគារវកិច្ច និងថ្លែងអំណរគុណចំពោះព្រះមោគ្គល្លាន ដែលបានណែនាំនាងឱ្យថ្វាយបង្គំព្រះសាស្តា។

ព្រះបាទ អជាតសត្តុ ឡើងសោយរាជ្យដោយការធ្វើឃាត





ព្រះបិតារបស់ខ្លួន គឺព្រះបាទពិម្ពិសារ ដែលទ្រង់ជាសោតាបន្នបុគ្គល។ ក្រោយមកបុត្ររបស់អជាតសត្តុ ក៏ធ្វើឃាតអជាតសត្តុ ដែលជាបិតារបស់ខ្លួនដែរ។ បាបកម្ម ដ៏ធ្ងន់របស់ព្រះបាទអជាតសត្តុ ឱ្យផលក្នុងបច្ចុប្បន្ននេះដែរ ហើយបន្តឱ្យផលទៀត គឺនៅពេលសោយទីវង្គតទៅ ក៏ទៅរងទុក្ខក្នុងមហានរក។

គ្រូរបស់អជាតសត្តុ គឺភិក្ខុទេវទត្ត ដែលបានញ៉ាំងលោហិតប្បាទនៃព្រះសាស្តាឱ្យធ្លាក់ចុះ ហើយនិងបំបែកបំបាក់សង្ឃ បាបកម្មទាំងឡាយដ៏ធ្ងន់នេះដើរតួជា ឧបបជ្ជវេទនីយកម្ម បន្តឱ្យផលរហូត ទីបំផុតភិក្ខុទេវទត្ត ត្រូវនៅរងទុក្ខក្នុងអវិចីនរកមកទល់សព្វថ្ងៃ។

**(៣) អបរាបរិយវេទនីយកម្ម**- កម្មឱ្យផលមិនដាក់លាក់

ចេតនាសម្បយុត្តជាមួយ ជវនចិត្ត ទាំងប្រាំកណ្តាលដែលធំជាងកម្មទាំងពីរប្រភេទខាងលើប្រាំដងនោះ ហៅថា អបរាបរិយវេទនីយកម្ម។ កម្មនេះឱ្យផលក្នុងពេលណាមួយនៃជាតិទីពីរខាងមុខ រហូតដល់ជាតិចុងក្រោយ ដែលបុគ្គលសម្រេចអរហត្តផល ក៏នៅតែឱ្យផល ឱ្យតែមានឱកាស។ ឱ្យតែនៅមានកំណើតបន្តបន្ទាប់ កម្មនេះនឹងមិនក្លាយទៅជាអហោសិកម្ម ឡើយ។

ព្រះសម្មាសម្ពុទ្ធ ទ្រង់បានបំពេញបារមីអស់រយៈកាល

បួនអសង្ខេយ្យកម្រៃមួយសែនកប្ប។ ដោយសារតែមហាកុសលកម្មនេះ ព្រះអង្គទ្រង់បានសេចក្តីសុខចម្រើនរៀងរហូត នៅក្នុងដំណើរឆ្ពោះទៅរក សម្មាសម្ពោធិញាណ រហូតដល់ព្រះអង្គទ្រង់បានត្រាស់ដឹងជាព្រះសម្មាសម្ពុទ្ធ។ កាលនៅជា ពោធិសត្វ ទ្រង់ក៏ធ្លាប់បានសាង អកុសលកម្ម ខ្លះដែរ ហេតុនេះហើយបានជាព្រះអង្គទ្រង់មានព្រះរោគាពាធផ្សេងៗដូចជា ឈឺព្រះកេស ចុកព្រះបិដ្ឋ រាករុះ ជាដើម សូម្បីតែក្នុងជាតិចុងក្រោយបានត្រាស់ជាព្រះសម្មាសម្ពុទ្ធហើយក៏ដោយ។

ព្រះមហាមោគ្គល្លាន សាវ័កឆ្វេងនៃព្រះសាស្តាគឺជាឯតទគ្គៈខាងឫទ្ធានុភាព ក្នុងចំណោមសាវ័កទាំងឡាយនៃព្រះសាស្តា។ លោកអាចធ្វើឱ្យវិមានទិព្វ វេជយន្តា របស់សក្កទេវរាជ ជាស្តេចនៃទេវតាញាប់ញ័របាន ដោយប្រើតែម្រាមជើងរបស់លោកប៉ុណ្ណោះ។ លោកអាចទូន្មានស្តេចនាគរាជដ៏កំណាចឈ្មោះនន្ទោបនន្ទបាន។ ប៉ុន្តែបើទោះជាយ៉ាងនេះក្តី ក៏លោកនៅតែមិនអាចគេចផុតអំពីកម្មបានឡើយ គឺនៅទីបំផុតលោកត្រូវបានចោរទាំងប្រាំរយនាក់សម្លាប់ទាល់តែបាន។ តើហេតុអ្វី?

នៅក្នុងក្រុងរាជគ្រឹះ ចោរប្រាំរយនាក់បានធ្វើកិច្ចប្រជុំមួយ៖ ចោរម្នាក់បានសួរទៅកាន់គ្នីគ្នាថា " តើអ្នកទាំងអស់គ្នា





ដឹងទេ តើហេតុអ្វីបានជា សមណគោតម ទទួលបានការបូជាច្រើនយ៉ាងនេះ។ ដោយគ្មាននរណាមួយឆ្លើយ ចោរម្នាក់នោះក៏បាននិយាយតទៀតថា "ហេតុដែល សមណគោតម ទទួលបានការបូជាច្រើននោះ គឺដោយសារតែមហាមោគ្គល្លាន។ លោកបានទៅកាន់ទេវលោក ហើយបានសួរទេវតាទាំងឡាយអំពីមូលហេតុអ្វីខ្លះ ដែលនាំឱ្យពួកគេបានមកកើតក្នុងឋានសួគ៌នេះ។ ពេលត្រឡប់មកឋានមនុស្សវិញ មហាមោគ្គល្លាន បានយកដំណឹងនេះទៅផ្សព្វផ្សាយដល់មនុស្សគ្រប់គ្នា។ ម្យ៉ាងវិញទៀត នៅពេលដែលលោកទៅទស្សនាឋាននរក លោកក៏បានសាកសួរពួកប្រេតទាំងឡាយនោះ អំពីមូលហេតុដែលនាំឱ្យពួកគេមកកើតក្នុងឋាននោះ។ ហើយពេលត្រឡប់មកវិញ ក៏យកដំណឹងនេះទៅផ្សព្វផ្សាយដល់មនុស្សទាំងឡាយ។ ហេតុដូច្នេះហើយមនុស្សទាំងឡាយជឿជាក់លើកម្ម និងផលរបស់កម្ម ហើយក៏នាំគ្នារឹតតែជ្រះថ្លាចំពោះព្រះសមណគោតមថែមទៀត។ ហើយក៏នាំគ្នាគោរព និង បូជាចំពោះ ព្រះសមណគោតម នោះកាន់តែច្រើនឡើង។ ដូចនេះ បើសិនជាពួកយើងអាចសម្លាប់ ព្រះមហាមោគ្គល្លានបាន ការបូជាទាំងឡាយនឹងត្រឡប់មកយើងជាពុំខាន។ តើអ្នកទាំងអស់គ្នាយល់ព្រមជាមួយនឹងខ្ញុំទេ"។

ចោរទាំងឡាយ ក៏យល់ស្របនឹងមតិនេះ ព្រោះចង់បានលាភ។ ពួកគេក៏ទទួលបានប្រាក់ចំនួន១០០០កហាបណៈពីមេចោររបស់ពួកគេ។ ពួកគេក៏បានទៅកាន់ភ្នំ ឥសិគិលិ ហើយឡោមព័ទ្ធវត្តដែលព្រះមហាមោគ្គល្លាន គង់នៅលើផ្ទាំងថ្ម កាឡសីលា។ ព្រះមហាមោគ្គល្លាន ទ្រង់ជ្រាបរឿងនេះដោយឫទ្ធិរបស់លោក ហើយក៏ហោះចេញទៅ។ ប៉ុន្តែពួកចោរទាំងប្រាំរយនៅតែនាំគ្នាឡោមព័ទ្ធវត្តរបស់លោកជារៀងរាល់ថ្ងៃ ហើយជារៀងរាល់ថ្ងៃដែរ ព្រះមហាមោគ្គល្លាន ក៏និមន្តហោះចេញពីទីនោះដោយឫទ្ធានុភាពរបស់លោក។ អស់រយៈកាលបីខែគត់ ព្រះមហាមោគ្គល្លាន ទ្រង់ឆ្ងល់ជាខ្លាំង ហេតុអ្វីបានជាពួកចោរទាំងនោះចេះតែតាមធ្វើឃាតលោកអ៊ីចឹង? លោកក៏ទ្រង់ពិចារណាទៅឃើញថា អកុសលកម្ម ដ៏មានទម្ងន់ (អកុសលគរុកកម្ម) ដែលលោកបានសាងពីជាតិមុនមក ដោយបានសម្លាប់មាតាបិតា គឺដល់ពេលដែលត្រូវឱ្យផលហើយ។ បើទោះជាមានឫទ្ធានុភាពខ្លាំងយ៉ាងណាក៏ដោយ ក៏លោកមិនអាចបញ្ឈប់ ឬគេចផុតអំពីការឱ្យផលនៃកម្មដែលលោកបានសាងឡើយ។ ហេតុដូចនេះហើយ លោកក៏ឈប់គេចទៀត ហើយពួកចោរទាំងប្រាំរយនោះក៏បានចាប់លោកចង ហើយវាយសំពងដោយដំបងទាល់តែឆ្អឹង





របស់លោកបាក់ជាបំណែកៗ។ ដោយគិតថា ព្រះមហាមោគ្គល្លាន ផុតដង្ហើមហើយនោះ ពួកគេក៏យកទៅបោះចោលក្នុងព្រៃ ហើយចាកចេញទៅ។ ព្រះមហាមោគ្គល្លាន ក៏ទ្រង់ប្រមូលផ្តុំនូវបំណែកឆ្អឹង ដែលបាក់បែកទាំងអស់ ដោយអំណាចនៃឈាន ហើយក៏ហោះទៅកាន់ទីចំពោះមុខនៃព្រះសាស្តា នមស្សការ ហើយ ក៏បានទូលគាល់ព្រះសាស្តាយាងចូលបរិនិព្វាន។ ព្រះសាស្តា ទ្រង់សួរថា តើអ្នកនឹងទៅបរិនិព្វានក្នុងទីណា? ខ្ញុំព្រះអង្គនឹងទៅបរិនិព្វានក្នុងទីឈ្មោះកាឡសីលា។ ម្នាលមោគ្គល្លាន នេះជាលើកចុងក្រោយហើយ ដែលតថាគតឃើញអ្នក ចូរអ្នកសម្តែងនូវធម៌ ហើយចូលទៅកាន់បរិនិព្វានក្នុងកន្លែងដែលអ្នកប្រាថ្នាចុះ។

ព្រះមហាមោគ្គល្លាន ថ្វាយបង្គំចំពោះព្រះដ៏មានព្រះភាគ ហើយក៏ហោះទៅលើអាកាសកំពស់មួយចុងត្នោត។ ហើយក៏ចុះមកវិញ ថ្វាយបង្គំព្រះសាស្តាម្តងទៀត ហើយហោះទៅលើអាកាសកំពស់ពីរចុងត្នោត។ លោកធ្វើដូចនេះ រហូតដល់ហោះកំពស់ប្រាំពីរចុងត្នោត ហើយទ្រង់គង់នៅលើអាកាស សម្តែងអភិនីហារច្រើនបែប ច្រើនសណ្ឋាន រួចហើយសម្តែងព្រះធម៌ថ្វាយបង្គំព្រះសាស្តាជាលើកចុងក្រោយ ហើយហោះទៅកាន់

កាឡសីលា បាត់ទៅ។ នៅទីនោះហើយ ដែលព្រះមហាមោគ្គ-ល្លានទ្រង់រលត់ខន្ធចូលកាន់បរិនិព្វាន។ នេះហើយ គឺជាភ័ស្តុ-តាងបញ្ជាក់ថា គ្មានបុគ្គលណាមួយគេចរួចពីកម្មបានទេ!

## កម្មឱ្យផលជះត្រឡប់មកខ្លួនអ្នកធ្វើវិញ

ហេតុអ្វីបានជាព្រះមហា មោគ្គល្លាន ត្រូវបានចោរទាំងប្រាំរយនាក់ វាយសំពង រហូតដល់បាក់បែកឆ្អឹងជាបំណែកៗ? ហេតុអ្វី ក៏លោកមិនអាចប្រើអភិនីហាររបស់លោកបញ្ឈប់ទៅ?

ដំណឹងដែលថា ព្រះមហាមោគ្គល្លាន ត្រូវបានពួកចោរសម្លាប់ ក៏សាយភាយដូចជាភ្លើងឆេះព្រៃទូទាំងទ្វីបឥណ្ឌា។ ព្រះរាជានៃក្រុង រាជគ្រឹះ ព្រះបាទអជាតសត្តុ ទ្រង់ជ្រាបដំណឹងនេះហើយក៏ទ្រង់ចាត់រាជបុរសដើម្បីតាមចាប់ចោរទាំងប្រាំរយនោះ។ ថ្ងៃមួយខណៈពេល ពួកគេកំពុងផឹកស៊ីក្នុងទៀមស្រាមួយ ស្រាប់តែឈ្លោះទាស់ទែងគ្នា ហើយក៏ផ្លោយចេញរឿង ដែលពួកគេធ្វើឃាតព្រះមហាមោគ្គល្លាននោះ។ រាជបុរសទាំងឡាយ ក៏បានចាប់ពួកគេ ហើយព្រះរាជា ក៏ទ្រង់បង្គាប់ឱ្យគេកប់ចោរទាំងនោះទៅក្នុងដីត្រឹមទ្រូង យកចំបើងដាក់ពីលើ ហើយក៏ដុតទាំងរស់ព្រមទាំងឱ្យគេយករនាស់ដែក រាស់ពួកចោរទាំងនោះ ដាច់ជាកំណាត់ៗ។





គរុកកម្មនេះឱ្យផលគួរឱ្យសង្វេគណាស់ គឺមិនអាចគេចផុតបានទេ។ ប្រៀបដូចជាសំឡេងដែលយើងនិយាយទៅ រមែងមានសំឡេងកងរំពងមកវិញយ៉ាងនោះដែរ។ ទិដ្ឋធម្មវេទនិយកម្មដែលចោរទាំងប្រាំរយនាក់នោះ បានសាងឱ្យផលភ្លាមៗក្នុងបច្ចុ-ប្បន្នជាតិ។ ចុះចំណែកព្រះមហាមោគ្គល្លានវិញ តើលោកបានសាងអ្វីដែរ?

ភិក្ខុសង្ឃប្រជុំគ្នាក្នុងសាលធម្មសភានាំគ្នានិយាយថា ព្រះមហាមោគ្គល្លាន ត្រូវបានគេសម្លាប់ ដូចជាមិនសមទំនងសោះ។

ពេលនោះ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ទៅកាន់ពួកភិក្ខុទាំងឡាយ ដោយពាក្យយ៉ាងនេះ " ម្នាលភិក្ខុទាំងឡាយ ព្រះមហាមោគ្គល្លាន ត្រូវបានគេសម្លាប់យ៉ាងនេះ គឺសមនឹងអ្វីដែលលោកបានសាង " ។ ពេលនោះ ក៏ព្រះសាស្ដាទ្រង់សម្ដែងអំពីបុព្វជាតិព្រះមហាមោគ្គល្លាន។

ក្នុងកាលកន្លងទៅយូរហើយ នៅនគរ ពារាណសី មានបុរសម្នាក់ជាអ្នកចិញ្ចឹមបីបាច់ថែរក្សាមាតាបិតាដែលខ្វាក់ងងឹត។

មាតាបិតាទាំងពីរតែងប្រាប់កូនខ្លួនថា កូនឯងធ្វើការងារនៅព្រៃផង ចិញ្ចឹមពួកយើងផង ការងារផ្ទះផង កូនឯងហត់នឿយណាស់ គួរកូនយកប្រពន្ធទៅ។

កូនបានបដិសេធថា ខ្ញុំមិនយកប្រពន្ធទេ ខ្ញុំចង់នៅថែរក្សាអ្នកទាំងពីរ ដូចនេះរហូតដល់ថ្ងៃស្លាប់។

មាតាបិតា បានបញ្ចុះបញ្ចូលកូននោះឱ្យរៀបការជាច្រើនដងមកហើយ។ ទីបំផុត ពួកគេបានជ្រើសរើសបានកូនប្រសារស្រីម្នាក់ ហើយក៏រៀបការឱ្យពួកគេទៅ។ ពីរបីថ្ងៃក្រោយ ដែលនាងបានបម្រើឪពុកម្ដាយក្មេកមក ស្ត្រីនោះក៏ចាប់ផ្ដើមធុញទ្រាន់ លែងចង់យកចិត្តទុកដាក់។

នាងបានប្រាប់ប្ដីថា នាងមិនអាចរស់នៅជាមួយនឹងឪពុកម្ដាយក្មេកបានទេ នាងចង់រស់នៅដាច់ដោយឡែក ដូចនេះហើយនាងបានលួងលោមប្ដីរបស់នាងគ្រប់មធ្យោបាយ ប៉ុន្តែប្ដីមិនបានយកចិត្តទុកដាក់នឹងការទទូចសូមរបស់នាងឡើយ។ ថ្ងៃមួយពេលប្ដីត្រឡប់មកពីព្រៃវិញ ឃើញបបររាយប៉ាយពេញផ្ទះ ក៏សាកសួរប្រពន្ធថា អ្នកណាធ្វើរឿងនេះ?

នាងក៏បានប្រាប់ថា គ្មាននរណាក្រៅពីឪពុកម្ដាយខ្វាក់បងឯងទេ ហើយក៏ទទូចថា ខ្ញុំលែងចង់នៅក្នុងផ្ទះនេះទៀតហើយ។

ក្រោយពេលដែលប្រពន្ធរបស់ខ្លួន ធ្វើដូចនេះច្រើនលើកច្រើនសាមក ប្ដីដោយអវិជ្ជាគ្រប់ដណ្ដប់ផងនោះក៏ជឿតាមពាក្យប្រពន្ធ ហើយចាប់តាំងពីថ្ងៃនោះមក គាត់ចាប់ផ្ដើមស្វែងរក





កំហុសមាតាបិតារបស់ខ្លួន ដែលជាអ្នកមានគុណធ្ងន់លើសភ្នំព្រះសុមេរុ។

ថ្ងៃមួយ បុរសនោះបានដាក់ឪពុកម្ដាយរបស់ខ្លួនក្នុងរទេះគោ ដោយប្រាប់ថានឹងនាំទៅលេងបងប្អូននៅស្រុក។ ហើយក៏បររទេះសំដៅចូលក្នុងព្រៃ លុះដល់កណ្ដាលព្រៃហើយ ក៏ធ្វើសំឡេងគំរាម ហាក់បីដូចជាពួកចោរកំពុងឡោមព័ទ្ធពួកគេ។

ឮដូច្នោះ មាតាបិតាបានប្រាប់ទៅកូនថា កូនឯងរត់ទៅកុំខ្វល់ពីពួកយើងៗចាស់ហើយ ទោះស្លាប់ក៏មិនអីដែរ។

ទោះបីជា មាតាបិតាបានខ្វល់ខ្វាយពីខ្លួនយ៉ាងណាក្ដី តែកូននោះបានយកដំបងវាយសំពងពួកគាត់រហូតដាច់ខ្យល់ស្លាប់ ហើយយកសាកសពបោះចោលក្នុងព្រៃនោះទៅ។ នេះហើយនៅពេលដែល រាគៈ និងអវិជ្ជា ដឹកមុខ មនុស្សស្លូតត្រង់បែរទៅជាកាចសហាវគ្មានធម៌មេត្តាឡើយ សូម្បីតែឪពុកម្ដាយដែលជាអ្នកមានគុណរបស់ខ្លួនក៏ហ៊ានសម្លាប់ដែរ។

ដោយសារបាបកកម្មដ៏ធ្ងន់ធ្ងរនេះ (គរុកកម្ម) បុរសនោះស្លាប់ទៅក៏បានទៅកើតក្នុង អវិចីនរក ត្រូវគេយកទៅធ្វើទារុណកម្មយ៉ាងឈឺចាប់យ៉ាងក្រៃលែង ស្លាប់កើតៗក្នុងនរកនោះរាប់លានឆ្នាំ។ ពេលរួចផុតពីអវិចីនរកហើយ ឧបបជ្ជវេទនីយកម្ម ឱ្យ

ផលពីមួយជាតិទៅមួយជាតិ ប្រព្រឹត្តទៅជាងរយអត្តភាព បុរសនោះ ត្រូវបានគេវាយសំពង ដោយដំបងដល់ស្លាប់ដោយមានឆ្អឹងបាក់ជាកំណាត់ៗ។បុរសនោះ គឺជាព្រះមហាមោគ្គល្លាននេះឯង។

ហេតុនេះហើយ ការត្រូវបានគេសម្លាប់ ព្រះមហាមោគ្គ-ល្លាន នេះ គឺសាកសមទៅនឹងកម្ម ដែលលោកបានសាងពីជាតិមុនមក។

ក្រោយពីធម្មទេសនានេះ ភិក្ខុច្រើនអង្គបានសម្រេចចាប់ពីសោតាបត្តមគ្គ រហូតដល់អរហត្តផល។

(ធម្មបទជាតក ភាគ៣ ប្រវត្តិព្រះមហាមោគ្គល្លាន)

## កម្មឱ្យផលមិនកំណត់ប្រៀបដូចស្រមោលអន្ទោលតាមប្រាណ

*ធម៌ទាំងឡាយ មានចិត្តជាធំ មានចិត្តប្រសើរបំផុត សម្រេចមកពីចិត្ត បើបុគ្គលមានចិត្ត ត្រូវទោសប្រទូស្តរ៉ាយហើយ ទោះបីនិយាយក្តី ធ្វើក្តី (ក៏អាក្រក់ដែរ) ព្រោះអំពើអាក្រក់នោះឯង ហើយសេចក្តីទុក្ខរមែងជាប់*





*តាមបុគ្គលនោះ ដូចជាកង់រទេះវិលតាមស្នាមជើងគោដែលអូស នឹមរទេះយ៉ាងនោះឯង។*

*ធម៌ទាំងឡាយ មានចិត្តជាធំ មានចិត្តប្រសើរបំផុត សម្រេចមកពីចិត្ត បើបុគ្គលមានចិត្តជ្រះថ្លាហើយ ទោះបីនិយាយក្តី ធ្វើក្តី (ក៏ល្អទាំងអស់)ព្រោះចិត្តជ្រះថ្លានោះឯង សេចក្តីសុខរមែងជាប់តាមបុគ្គលនោះដូចជាស្រមោលដែលអន្ទោលតាមប្រាណយ៉ាងនោះដែរ។*

*(ធម្មបទ ១ និង២)*

**៤)អហោសិកម្ម** - កម្មដែលតាមឱ្យផលមិនទាន់

ទិដ្ឋធម្មវេទនីយកម្ម ឧបបជ្ជវេទនីយកម្ម និងអបរាបរិយ-វេទនីយកម្ម ដែលគ្មានឱកាសឱ្យផលក្នុងរយៈកាលកំណត់របស់វា នឹងក្លាយជាអហោសិកម្ម។

ដើមពោធិ៍មានផ្លែច្រើនរាប់ពាន់ ក្នុងមួយរដូវៗ និងរាប់លានដែលអាចធ្វើជាពូជបាន។ ទោះបីជាពូជនីមួយៗអាចផលិតជារុក្ខជាតិថ្មីទៀតក៏ដោយ មានតែរយ ឬពាន់ពូជប៉ុណ្ណោះ ដែលអាចមានឱកាសកកើតជារុក្ខជាតិថ្មីបាន។ ពូជដទៃក្រៅពីនេះ

នឹងក្លាយជា អហោសិកម្ម។

ដូចគ្នានេះដែរ ខណៈពេលដែលយើងកំពុងធ្វើបុណ្យ កុសលកម្ម រាប់រយកោដិកើតឡើង ហើយពេលកំពុងធ្វើបាប អកុសលកម្ម រាប់រយកោដិ ក៏កើតឡើងដែរ។ ដូច្នេះ យើងឃើញថា ក្នុងមួយជាតិៗកុសលកម្ម និងអកុសលកម្មគឺមានចំនួនច្រើន រាប់មិនអស់។ ប៉ុន្តែ កម្ម មួយចំនួនប៉ុណ្ណោះ ដែលនឹងឱ្យផល ឯកម្មដទៃនឹងក្លាយជា អហោសិកម្ម។

សូមលើកយកឧទាហរណ៍អំពី អង្គុលីមាល៍ ដែលបានសម្លាប់មនុស្សច្រើនអ្នកណាស់ ដើម្បីប្រមូលយកម្រាមដៃមួយពាន់ មកធ្វើជាកម្រង។ នៅពេលដែលព្រះសាស្ដាទ្រង់ប្រោសអង្គុលីមាល៍ហើយ គាត់ក៏បានទម្លាក់ដាវចុះ ហើយចាប់យកព្រះធម៌ គឺបានឧបសម្បទាក្នុងទីចំពោះមុខនៃព្រះសាស្ដា។ លោកក៏បានប្រឹងប្រែងព្យាយាមចម្រើន វិបស្សនាកម្មដ្ឋាន រហូតបានសម្រេចជាព្រះអរហន្ត។ ការបានសម្រេចអរហត្តផលហើយ នឹងមិនកើតទៀតឡើយ ដូច្នេះ កុសលកម្ម និងអកុសលកម្ម ដែលបានសាងទាំងប៉ុន្មាននឹងក្លាយជាអហោសិកម្ម។





## ៥.កម្ម៤យ៉ាងដែលទាក់ទងនឹងទីកន្លែងឱ្យផលកើតឡើង

| | |
|---|---|
| **១)អកុសលកម្ម** | អំពើអាក្រក់ |
| **២)កាមាវចរកុសលកម្ម** | អំពើល្អដែលប្រព្រឹត្តទៅក្នុងកាមភព |
| **៣)រូបាវចរកុសលកម្ម** | អំពើល្អដែលប្រព្រឹត្តទៅក្នុងរូបភព |
| **៤)អរូបាវចរកុសលកម្ម** | អំពើល្អដែលប្រព្រឹត្តទៅក្នុងអរូបភព |

ទីកន្លែងដែលកម្មនីមួយៗត្រូវឱ្យផលយ៉ាងណានោះគឺចែកជា៤យ៉ាងខាងលើ ហើយមានសេចក្ដីពន្យល់ដូចខាងក្រោមនេះ។

***១) អកុសលកម្ម** - កម្មអាក្រក់*

ចេតនាសម្បយុត្តជាមួយអកុសលចិត្ត១២ និងកម្មទាំងឡាយនៅក្នុងវិថីចិត្ត ហៅថា អកុសលកម្ម ។ កម្មនេះនឹងឱ្យផលជាអកុសលវិបាកដែលសម្បយុត្តនឹងចេតសិក និងកម្មជរូប នៅក្នុងអបាយភូមិទាំង ៤ មាន តិរច្ឆាន ប្រេត អសុរកាយ និងនរក។

***២) កាមាវចរកុសលកម្ម** - កុសលកម្មជាកាមាវចរ*

ចេតនាសម្បយុត្តជាមួយកុសលកាមាវចរចិត្ត៨ និងកម្មទាំងឡាយ ក្នុងវិថីចិត្ត ហៅថា កាមាវចរកុសលកម្ម។ នៅពេលដែលបុគ្គលធ្វើអំពើល្អ មានការបរិច្ចាគទាន រក្សាសីល និងចម្រើនកម្មដ្ឋានជាដើម កម្មនេះនឹងឱ្យផលជាកុសលច្រើនកោដិដង។ ពេលកម្មនេះហុចផលឱ្យ នឹងផលិតនូវបញ្ចក្ខន្ធប្រកប

ដោយកាមាវចរវិបាកចិត្ត ដែលសម្បយុត្តជាមួយចេតសិក និង កម្មជរូបនៅក្នុងកាមាវចរភពទាំង៧ណាមួយ មានឋានមនុស្ស១ និង ឋានសួគ៌៦ជាន់។

*៣) រូបាវចរកុសលកម្ម-កុសលកម្មជារូបាវចរ*

ចេតនាសម្បយុត្តជាមួយរូបាវចរកុសលចិត្ត៥ និងកម្មទាំងឡាយ ក្នុងវិថីចិត្ត ហៅថា រូបាវចរកុសលកម្ម។ នៅពេលដែល បឋមជ្ឈាន ទុតិយជ្ឈាន តតិយជ្ឈាន និងចតុត្ថជ្ឈាន ដែលផ្សារភ្ជាប់នឹងរូបភពបានចម្រើនឡើងម្តងមួយៗ អំពើល្អរាប់រយកោដិ នឹងកើតមានប្រព្រឹត្តទៅក្នុងរូបភពនេះឯង។

នៅពេលដែលកម្មនេះហុចផលឱ្យ នឹងផលិតនូវបញ្ចក្ខន្ធ ប្រកបដោយ រូបាវចរវិបាកចិត្ត ជាមួយនឹង ចេតសិក ដែល សម្បយុត្ត និង កម្មជរូប នៅក្នុងរូបភព១៦ជាន់។

*៤) **អរូបាវចរកុសលកម្ម** - កុសលកម្មជាអរូបាវចរ*

ចេតនាសម្បយុត្តជាមួយ អរូបាវចរកុសលចិត្ត៤ ជាមួយនឹងកម្មទាំងឡាយក្នុង វិថីចិត្ត ហៅថា អរូបាវចរកុសលកម្ម។

ដោយការចម្រើននូវ កសិណកម្មដ្ឋាន បុគ្គលអាចចម្រើននូវរូបាវចរកុសលចិត្ត៤ និងអរូបាវចរកុសលចិត្ត៤។នៅពេលដែល





បុគ្គលបានសម្រេច អរូបជ្ឈាន ឈានចិត្ត អាចកើតមានរាប់រយកោដិដង និងគ្រប់វិនាទី ហើយតាក់តែជាកម្មនៅក្នុងអរូបភព។

នៅពេលកម្មនេះហុចផលឱ្យ នឹងផលិតនូវមនោខន្ធ៤ ប្រកបដោយ អរូបាវចរវិបាកចិត្ត ជាមួយនឹង ចេតសិក ដែល សម្បយុត្ត នៅក្នុង អរូបភព៤។

## ឯកសារយោង


1. Dr. Mehm Tin Mon, “Abhidhamma” (Higher Level) Vol-1.pp. 135-164
2. Dr. Mehm Tin Mon, “The Essence of Buddha Abhidhamma”.pp.196-209
3. “ A Comprehensive Manual of Abhidhamma”, Bhikkhu Bodhi, General Editer, Buddhist Publication Society, Sri Lanka, pp.200-210
4. Narada Maha Thera, “The Buddha and His Teachings”, pp.186-221
5. Sayadaw U Silananda, “Volition –An Introduction to the Law of Kamma”, Inward Path Publisher, Penang, Malaysia.
6. “The Manual of Buddhism”, Vol. 1, Religious Affairs Department, in Myanmar Language, pp.650-686

# ៩

# ចិត្តជាអ្នកកសាងពិត

## ១. ចិត្តជាអាទិទេពពិត

អ្វីៗដែលបានកកើតឡើងនៅក្នុងពិភពលោកនេះ គឺសុទ្ធតែចិត្តរបស់មនុស្សជាអ្នកបង្កើតទាំងអស់ ដូចជាសំណង់ផ្សេងៗ អគារខ្ពស់ៗ ផ្លូវថ្នល់ ស្ពាន ឡាន ម៉ូតូ អយស្ម័យយានដែលលឿនបំផុត នាវាចរ កុំព្យូទ័រ ប្រព័ន្ធគមនាគមន៍ ។ល។ សុទ្ធតែជារបស់ដែលហួសពីការគិតស្រមៃរបស់មនុស្ស ដែលអាចបង្កើតបាន។ នៅក្នុងបច្ចុប្បន្ននេះ អ្នកដែលបានសិក្សាមុខវិជ្ជា ឬជំនាញផ្សេងៗ មាន សិល្បៈ វិទ្យាសាស្ត្រជាដើម រឹងរឹតតែធ្វើឱ្យការគិតរបស់គេមានវិសាលភាព និងគំនិតច្នៃប្រឌិតខ្ពស់។

ដូចគ្នានេះដែរ នៅពេលដែលបុគ្គលបានសិក្សា ហើយចម្រើននូវឈានទាំង ៨ ឱ្យកើតឡើង ដោយកសិណកម្មដ្ឋាន អានុភាពនៃចិត្តរបស់បុគ្គលនោះរឹងរឹតតែខ្លាំងក្លា ដែលជាហេតុ





នាំមកនូវសេចក្តីសុខ។ នៅពេលដែលបុគ្គលនោះញ៉ាំងឈានទាំង ៨ ក្នុងកសិណទាំង១០យ៉ាង ឱ្យកើតឡើងហើយ គេអាចប្រតិបត្តិតាមមាគ៌ា១៤យ៉ាង ដូចដែលព្រះសាស្តាទ្រង់សម្តែងទុកមក។ ប្រតិបត្តិយ៉ាងនេះ នឹងនាំឱ្យគេបានសម្រេចនូវឫទ្ធានុភាព៧ប្រការ ដែលប្រសើរឆ្ងាយជាងការសម្រេចបានដោយវិទ្យាសាស្ត្រ។

## លោកិយអភិញ្ញាដ៏អស្ចារ្យ

| | |
|---|---|
| (១) ឥទ្ធិវិធ អភិញ្ញា | អានុភាព ដែលអាចបង្កើតរូប និងសណ្ឋានផ្សេងៗ |
| (២) ទិព្វចក្ខុ អភិញ្ញា | ភ្នែកទិព្វ អាចមើលឃើញចក្រវាឡទាំងមូលដោយជុំវិញ និងភពទាំង៣១ |
| (៣) ទិព្វសោត អភិញ្ញា | ត្រចៀកទិព្វ ដែលអាចស្តាប់ឮសំឡេង គ្រប់បែបយ៉ាងបាន ទាំងសំឡេងខ្សោយបំផុត ឬឆ្ងាយយ៉ាងណាក៏ដោយ |
| (៤) បរចិត្តវិជ្ជានន អភិញ្ញា | អានុភាពដែលអាចដឹងចិត្ត ឬការគិតរបស់អ្នកដទៃ |

(៥)បុព្វេនិវាសានុស្សតិ អភិញ្ញា អានុភាពដែលអាចរលឹកឃើញនូវបុព្វជាតិទាំងឡាយ

(៦)យថាកម្មូបគ អភិញ្ញា អានុភាព ដែលអាចដឹងអំពីកម្មដែលឱ្យផលចំពោះបុគ្គលម្នាក់ៗ

(៧)អនាគតំស អភិញ្ញា អានុភាព ដែលអាចដឹងនូវហេតុ និង កំណើតសត្វក្នុងអនាគតកាល។

## ២.លក្ខណៈសម្បត្តិដែលគួរឱ្យភ្ញាក់ផ្អើលនៃឫទ្ធានុភាព

បុគ្គលដែលបានសម្រេចដោយអំណាចនៃ ឥទ្ធិវិធអភិញ្ញា អាចជ្រែកដី ដើរ ឬអង្គុយលើទឹក ធ្វើដំណើរលើអាកាស ជ្រែកជញ្ជាំង ជ្រែកភ្នំ និងអាចបែងភាគរាប់រយពាន់លានបាន។ បែងភាគច្រើនជាច្រើនចំណែក ហើយអាចប្រែក្លាយឱ្យទៅជារូបតែមួយវិញបាន។ គេអាចធ្វើឱ្យទឹកប្រែក្លាយជាបីរ (ខ្លាញ់ទឹកដោះគោ)បានរបស់ឆ្ងាយឱ្យក្លាយមកជិត របស់ជិតឱ្យឃ្លាតទៅឆ្ងាយ របស់តិចឱ្យក្លាយជាច្រើន របស់ច្រើនឱ្យក្លាយជាតិច អាចបំបាំងខ្លួន ហើយផុសចេញវិញ និងអាចបង្ហាញឱ្យឃើញរបស់ដែលមើលមិនឃើញ របស់ដែលមើលឃើញធ្វើឱ្យមើលមិនឃើញបាន។





ព្រះមហាថេរ ចូឡបន្ថកៈ នៅពេលដែលគេទុកឱ្យលោកនៅចាំវត្ត ជីវិកអម្ពវ័ន តែមួយអង្គឯង បាននិមិត្តខ្លួនលោកជា ១០០០ អង្គ។

ស្ដេចនាគឈ្មោះ នន្ទោបនន្ទ បាននិមិត្តខ្លួនយ៉ាងធំមហាសាល ហើយរុំព័ទ្ធភ្នំព្រះសុមេរុ ៧ជុំ មានក្បាលលាតសន្ធឹងលើឋានតាវតិង្ស ធ្វើឱ្យគេឯងមើលឃើញគ្រប់គ្នា ក្នុងគោលបំណងរារាំងផ្លូវព្រះសម្មាសម្ពុទ្ធ មួយអន្លើដោយព្រះអរហន្តជាសាវ័ក ៥០០អង្គ ដែលកំពុងនិមន្តតាមផ្លូវឆ្ពោះទៅកាន់ឋានតាវតិង្ស។ ព្រះមហា មោគ្គល្លាន បាននិមិត្តខ្លួនរបស់លោកជាស្ដេចនាគរាជយ៉ាងធំមហាសាលដែរ ហើយបានទៅពេនព័ទ្ធ ស្ដេចនាគ នន្ទោ-បនន្ទ ចំនួន១៤ជុំ ហើយមានក្បាលរបស់ខ្លួន គ្រប់សង្កត់លើក្បាល នន្ទោបនន្ទ ហើយក៏គាបផ្ទឹបទៅនឹងភ្នំព្រះសុមេរុ។ ពេលនោះ នន្ទោបនន្ទ ក៏ព្រួសផ្សែងពិសដាក់ព្រះមោគ្គល្លានៗក៏ព្រួសដាក់វិញ ប៉ុន្តែផ្សែងពិសរបស់នន្ទោបនន្ទ មិនបានធ្វើឱ្យប៉ះពាល់ដល់ព្រះមោគ្គល្លានសូម្បីតែបន្តិច ផ្ទុយទៅវិញ មានតែផ្សែងពិសរបស់ព្រះមោគ្គល្លានទេដែលធ្វើឱ្យ នន្ទោបនន្ទ ភិតភ័យជាខ្លាំង។

បន្ទាប់មក នន្ទោបនន្ទ ក៏ព្រួសភ្លើង ហើយព្រះមហាមោគ្គល្លាន ក៏ព្រួសភ្លើងដាក់វិញ ហើយមានតែភ្លើងរបស់ព្រះ

មហាមោគ្គល្លានទេ ដែលធ្វើឱ្យនន្ទោបនន្ទវេទនានោះ។

ស្តេចនាគ នន្ទោបនន្ទក៏បានសួរថា "តើអ្នកជានរណា?"

"ព្រះមហាថេរឆ្លើយថា អាត្មាឈ្មោះ មហាមោគ្គល្លាន"។

នន្ទោបនន្ទ ក៏បានពោលថា "សូមព្រះអង្គប្រែទៅជាភាវៈជាភិក្ខុវិញទៅ"។

ព្រះមហាមោគ្គល្លាន ក៏បាននិមិត្តជាភិក្ខុវិញ។ ព្រះអង្គក៏ហោះចូលក្នុងត្រចៀកខាងស្តាំនៃស្តេចនាគ ហើយហោះចេញវិញតាមត្រចៀកខាងឆ្វេង ហើយចូលតាមឆ្វេង ចេញមកវិញខាងស្តាំ ហើយចូលក្នុងពោះតាមមាត់ និមន្តដើរក្នុងពោះស្តេចនាគទៅវិញទៅមក ពីលើទៅក្រោម ពីក្រោមទៅលើ។

ពេលនោះ ស្តេចនាគដោយមានការឈឺចាប់ពេក ក៏បានសូមអង្វរឱ្យព្រះមហាមោគ្គល្លាននិមន្តចេញមកវិញ។

ព្រះមហាមោគ្គល្លាន ក៏និមន្តចេញតាមសំណើ ហើយទ្រង់ឈរនៅខាងក្រៅ ពេលនោះ នន្ទោបនន្ទ បានបង្ហើរខ្យល់ដែលមានកំដៅខ្លាំងតាមរន្ធច្រមុះ។ ព្រះមហាមោគ្គល្លាន យាងចូលកាន់ឈានទី៤យ៉ាងរហ័ស ដូច្នេះ មិនបានធ្វើឱ្យប៉ះពាល់សូម្បីតែរោមមួយសរសៃនៃព្រះមហាមោគ្គល្លានឡើយ។ បើសិនជាភិក្ខុអង្គដទៃ ដែលមិនអាចយាងចូលកាន់ឈានបានរហ័ស





ដូចព្រះមហាមោគ្គល្លាននោះ ប្រាកដជាត្រូវឆេះខ្លួនខ្លោចស្លាប់មួយរំពេច ដោយសារខ្យល់កំដៅនៃ នន្ទោបនន្ទមិនខាន។

នន្ទោបនន្ទ ក៏ចុះចាញ់ហើយរត់ចេញ ព្រះមហាមោគ្គល្លានបាននិមិត្តជាសុបណ្ណៈ ហើយធ្វើសំឡេងឱ្យឮខ្លាំង ហើយទទះស្លាបដេញចាប់ស្តេចនាគមកវិញ។ នន្ទោបនន្ទ ក៏ចុះចាញ់ឫទ្ធានុភាពរបស់ព្រះមហាមោគ្គល្លាន ហើយនិមិត្តខ្លួនជាបុរសក្មេងម្នាក់ ចុះមកថ្វាយបង្គំចំពោះព្រះមហាមោគ្គល្លាន ហើយពោលថា "បពិត្រព្រះមហាថេរដ៏ចម្រើន ខ្ញុំសូមដល់នូវលោកជាទីពឹងទីរលឹក"។

ព្រះមហាថេរ ក៏បាននាំទៅនមស្សការចំពោះព្រះដ៏មានព្រះភាគ។ បុរសនោះ ក៏បានថ្វាយបង្គំចំពោះព្រះដ៏មានព្រះភាគ ហើយពោលថា "បពិត្រព្រះសមណគោតមដ៏ចម្រើន ខ្ញុំព្រះអង្គសូមដល់នូវព្រះអង្គជាទីពឹងទីរលឹក"។

ព្រះសម្មាសម្ពុទ្ធ ក៏ទ្រង់ប្រទានពរដល់ នន្ទោបនន្ទ "សូមឱ្យអ្នកជាបុគ្គលបាននូវសេចក្តីសុខ សេចក្តីចម្រើនចុះ"។

## ធ្វើរបស់នៅឆ្ងាយឱ្យមកជិត របស់ធំឱ្យក្លាយជាតូច

នៅពេលមួយ មានគ្រោះទុរភិក្ស ក្នុងប្រទេសស្រីលង្កា ព្រះមហា អនុល ឃើញភិក្ខុទាំងឡាយកំពុងអង្គុយនៅមាត់ច្រាំង

នៃទន្លេ ឆាន់ចង្ហាន់បន្តិចបន្តួច ដែលបានមកពីការបិណ្ឌបាត លោកក៏អធិដ្ឋានថា "សូមឱ្យទឹកទន្លេក្លាយជាបឹរ(ទឹកដោះខាប់)"។ បន្ទាប់មកលោក ក៏បង្គាប់ឱ្យសាមណេរទាំងឡាយ ទៅនាំយកមកដាក់បាត្រ ប្រគេនចំពោះភិក្ខុទាំងឡាយ។ ភិក្ខុគ្រប់អង្គឆាន់ឆ្អែតស្កប់ស្កល់។

នៅថ្ងៃបន្ទាប់មក មានភិក្ខុចំនួន៧០០អង្គ និមន្តមកកាន់សំណាក់នៃព្រះមហាថេរៈចូឡសមុទ្ទ ទ្រង់ជ្រាបជាមុន ហើយពិចារណាទៅឃើញថា មានតែនិមន្តទៅទីក្រុង បាដលិបុត្ត ដែលនៅភូមិភាគខាងជើងនៃប្រទេសឥណ្ឌាទេ ទើបអាចទទួលចង្ហាន់បិណ្ឌបាតបាន។ ទើបលោកប្រាប់ដល់ភិក្ខុទាំងឡាយជាសហធម្មិក ឱ្យគ្រងដណ្តប់ចីវរ មួយអន្លើដោយបាត្រ និមន្តទៅបិណ្ឌបាត។ លោកក៏បំព្រួញដី ហើយនិមន្តឆ្ពោះទៅកាន់ក្រុងបាដលិបុត្ត។

ភិក្ខុទាំងឡាយ បានសួរទៅកាន់ព្រះ ចូឡសមុទ្ទត្ថេរ ថា "តើទីក្រុងនេះឈ្មោះអ្វីដែរ?"

"ទីក្រុងនេះឈ្មោះថា បាដលិបុត្ត"។

"ប៉ុន្តែ បាដលិបុត្ត គឺនៅឆ្ងាយជាពន់ពេក"

"ម្នាលអាវុសោទាំងឡាយដ៏ចម្រើន ព្រះមហាថេរ ទាំងឡាយក្នុងកាលមុនក៏អាចធ្វើឱ្យរបស់ឆ្ងាយក្លាយជាជិតបាន"។

" ចុះឯណាទៅមហាសមុទ្រ?"

"ម្នាលអាវុសោទាំងឡាយ តើអ្នកទាំងឡាយចាំទេនៅតាមផ្លូវ យើងបានឆ្លងកាត់ប្រឡាយពណ៌ខៀវមួយ?"

"ករុណាព្រះមហាថេរដ៏មានអាយុ ប៉ុន្តែ មហាសមុទ្រធំធេងណាស់ មិនមែនតូចដូចនេះទេ"

"ម្នាលអាវុសោទាំងឡាយ ព្រះមហាថេរទាំងឡាយ ក្នុងកាលមុនក៏អាចធ្វើឱ្យរបស់ធំក្លាយជាតូចបានដែរ"។

## ធ្វើរបស់ច្រើនឱ្យជាតិច របស់តិចឱ្យជាច្រើន

នៅថ្ងៃបុណ្យនក្ខត្តឫក្សមួយនាក្រុងរាជគ្រឹះមានស្ត្រី៥០០រូបបានទៅចូលរួមក្នុងពិធីបុណ្យនោះដែរ ដោយយកនំសែនព្រះច័ន្ទទៅជាមួយផងដែរ។ ពួកគេបានឃើញព្រះសាស្តា តែពុំបានប្រគេនអ្វីនោះទេ។ ប៉ុន្តែ នៅពេលដែលពួកគេឃើញព្រះមហាកស្សបៈ ក៏នាំគ្នាចូលទៅរកលោក ហើយប្រគេននំមួយដុំម្នាក់ដល់លោកដោយគំនិតថា " នេះគឺជាព្រះមហាថេរនៃយើង"។ ព្រះមហាកស្សបៈ ក៏ទទួលយកបាត្រ ហើយញ៉ាំងបាត្ររបស់លោកឱ្យពោរពេញដោយនំទាំងឡាយ។

ព្រះមហាកស្សបៈ បាននាំយកនំនោះទៅថ្វាយព្រះដ៏មាន

ព្រះភាគ ដែលគង់ចាំនៅក្នុងវត្ត។

ដោយអំណាចនៃឫទ្ធានុភាព របស់តិចអាចធ្វើឱ្យទៅជាច្រើនបាន។ ព្រះមហាកស្សបៈ ទើបតែយាងចេញពីនិរោធសមាបត្តិ ក៏និមន្តបិណ្ឌបាតនៅមុខផ្ទះបុរសដ៏កំសត់ទុគ៌តម្នាក់ឈ្មោះកាកវលិយ។ ប្រពន្ធរបស់បុរសនោះ បានយកបបរស ដែលនាងបានចំអិនសម្រាប់តែហូបពីរនាក់ប្ដីប្រពន្ធទៅដាក់បាត្រព្រះមហាកស្សបៈៗ ក៏យកបបរសនោះទៅថ្វាយព្រះដ៏មានព្រះភាគ។ ព្រះដ៏មានព្រះភាគ បានអធិដ្ឋានឱ្យបបរសនោះ អាចញ៉ាំងឱ្យភិក្ខុសង្ឃ អង្គសាមណេរទាំងអស់ ឆាន់ឆ្អែតគ្រប់គ្រាន់។ ដោយអានិសង្សនៃបបរសនេះ កាកវលិយ ក៏បានក្លាយជាអ្នកមានទ្រព្យធននៅថ្ងៃទីប្រាំពីរ។

### ធ្វើភាពងងឹតឱ្យភ្លឺ និង របស់មើលមិនឃើញឱ្យឃើញបាន

អ្នកដែលមានអភិនីហារអាចនិមិត្តទីងងឹតឱ្យភ្លឺស្វាងបាន អាចបង្ហាញឱ្យឃើញនូវអ្វីដែលបាំងបិទដោយជញ្ជាំងទ្វារ អាចធ្វើឱ្យប្រត្យក្សបាននូវរបស់ដែលឆ្ងាយ ឬល្អិតសុខុម ប្រៀបបាននឹងបុគ្គលយកត្បូងមកដាក់លើបាតដៃយ៉ាងនោះដែរ។

ដោយមានការនិមន្តពីព្រះនាង ចូឡសុភទ្ទា ជាបុត្រីនៃអនាថបិណ្ឌិកសេដ្ឋី ព្រះសម្មាសម្ពុទ្ធទ្រង់និមន្តអស់រយៈចម្ងាយ





ប្រមាណ ៧ យោជន៍ (៥៦ម៉ាយ) ពីនគរ សាវត្ថី ទៅកាន់នគរសាកេត ។ ព្រះសាស្ដា ទ្រង់និមិត្តឱ្យមហាជននៃនគរទាំងពីមើលគ្នាឃើញទៅវិញទៅមក។ បន្ទាប់មកព្រះអង្គទ្រង់គង់លើអាកាសចំកណ្ដាលនៃទីក្រុង ហើយទ្រង់បំភ្លឺដោយរស្មីចិញ្ចែងចិញ្ចាច ទើបទ្រង់ពុះច្រៀកផែនដីជាពីរ បង្ហាញឱ្យមហាជនឃើញដល់អវិចីនរក រួចហើយទ្រង់ពុះច្រៀកអាកាសជាពីរ បង្ហាញឱ្យមហាជនឃើញ ដល់ព្រហ្មលោក។

ម្យ៉ាងវិញទៀត កាលដែលព្រះសម្មាសម្ពុទ្ធ ទ្រង់យាងត្រឡប់ពីសម្ដែងព្រះអភិធម្ម អស់រយៈពេល៣ខែ នៅឋានតាវតិង្សវិញ ព្រះអង្គទ្រង់គង់លើកំពូលភ្នំព្រះសុមេរុ ហើយទ្រង់ធ្វើឱ្យសព្វសត្វទាំងឡាយ ក្នុងចក្រវាឡទាំង១០០០០លោកធាតុមើលគ្នាឃើញ(លោកវិវរណៈ) គឺដោយពុទ្ធានុភាពអភិនីហារបារមីនៃព្រះសាស្ដា ទ្រង់និមិត្តឱ្យចក្រវាឡទាំងមូលមាន ឱកាសលោក សត្តលោក ជាដើមឱ្យមហាជន ក៏ដូចជាពពួកទេវតាទាំងឡាយបានឃើញ។

ពេលនោះ មនុស្សមើលឃើញទេវតា ឯទេវតា ក៏មើលឃើញមនុស្សវិញ ដោយមនុស្សមិនចាំបាច់ងើយមើលទៅលើ

វីឯទេវតាមិនចាំបាច់មើលចុះក្រោម គឺពួកគេអាចមើលគ្នាឃើញក្នុងទីចំពោះមុខ។

នៅពេលដែលព្រះសាស្តាទ្រង់យាងចុះចាកឋានតាវតិង្សពីលើកំពូលភ្នំព្រះសុមេរុ ចុះមកឋានមនុស្សលោកវិញ វិស្សកម្មទេវបុត្តបាននិមិត្តជណ្តើរបីយ៉ាង។ ព្រះសាស្តាទ្រង់យាងចុះតាមជណ្តើរកណ្តាលដែលធ្វើពីត្បូងចរណៃ ទេវតាទាំង៦ជាន់អមខាងឆ្វេងគឺជណ្តើរធ្វើពីមាស និងពពួកព្រហ្មទាំងឡាយដឹកនាំដោយមហាព្រហ្ម អមខាងស្តាំលើជណ្តើរធ្វើពីប្រាក់។

សក្កទេវរាជ ស្តេចនៃទេវតាទ្រង់កាន់បាត្រ និងត្រៃចីវរនៃព្រះសម្ពុទ្ធ មហាព្រហ្មទ្រង់កាន់ក្លស់ ដែលមានទំហំ៣យោជន៍ ស្តេចសុយាមទ្រង់កាន់ផ្លិតកន្ទុយចាមរី បញ្ចសិខា និងគន្ធព្វទេវបុត្ត ចុះមកនមស្សការថ្វាយបង្គំព្រះសម្ពុទ្ធដោយមានពិណរបស់ខ្លួនហៅថា បេលុវបណ្ឌុ ដែលមានប្រវែងមួយភាគ៣នៃយោជន៍។

នៅថ្ងៃនោះ ពេលដែលសព្វសត្វទូទាំងចក្រវាឡ បានឃើញហេតុភេទសព្វគ្រប់យ៉ាងនេះ ហើយគ្មាននរណាម្នាក់ដែលថាមិនចង់ក្លាយជាព្រះពុទ្ធទេ។ នេះគឺជាអព្ភូតហេតុដ៏អស្ចារ្យដែលធ្វើអ្វី ដែលបិទបាំងឱ្យឃើញជាក់ច្បាស់បាន(អាវិភាវបាដិ-ហារ្យ)ដែលព្រះសម្ពុទ្ធទ្រង់សម្តែង។





អ្នកដែលអាចសម្តែងបាដិហារ្យ បង្ហាញឱ្យឃើញរបស់ដែលលាក់ ធ្វើរបស់ដែលមើលមិនឃើញឱ្យមើលឃើញមួយរូបទៀតគឺ ព្រះមហាថេរ ធម្មទិន្ន ដែលលោកគង់នៅក្នុងអារាមឈ្មោះវាលង្ការ ប្រទេសស្រីលង្កា។ លោកគង់នៅលើបរិវេណនៃព្រះចេតិយ ក្នុង តិស្សមហាវិហារ សម្តែងនូវ អបណ្ណិកសូត្រ។ លោកទ្រង់កាន់ផ្លិតចង្អុលចុះក្រោម ពេលនោះអ្វីៗគ្រប់យ៉ាងបង្ហាញឱ្យឃើញទាំងអស់ រហូតទល់ អវិចីនរក ហើយក្លាយជាភ័ស្តុតាងយ៉ាងច្បាស់លាស់បំផុត។ ពេលលោកលើកផ្លិតចង្អុលឡើងលើ អ្វីៗនៅឋានលើបង្ហាញខ្លួនទាំងអស់ រហូតទល់នឹងព្រហ្មលោក ហើយក្លាយជាភ័ស្តុតាងយ៉ាងច្បាស់លាស់បំផុត។

នៅពេលដែលប្រជាបរិស័ទឃើញអបាយភូមិដោយផ្ទាល់ភ្នែកយ៉ាងនេះ ក៏នាំគ្នារឹតតែតក់ស្លុតកើតសង្វេគ ហើយប្រាថ្នាចង់បានសួគ៌ និងព្រះនិព្វាន។ ក្រោយធម្មទេសនា អ្នកខ្លះបានសម្រេចសោតាបត្តិមគ្គ ខ្លះសកទាគាមី ខ្លះទៀត អនាគាមី។

ម្យ៉ាងវិញទៀត បុគ្គល ដែលមានឫទ្ធានុភាពអាចធ្វើឱ្យភ្លឺទៅជាងងឹត របស់បង្ហាញឱ្យទៅជាលាក់ របស់មើលឃើញមិនឱ្យមើលឃើញបាន។ តេជានុភាពនេះហៅថា តិរោភាវបាដិហារ្យ។ កាលព្រះសាស្តាទ្រង់គង់នៅព្រៃឥសិបតន ទ្រង់បាននិមិត្តមិន

ឱ្យឪពុករបស់យសៈ មើលមិនឃើញ យសៈ ដែលស្ថិតនៅក្បែរព្រះអង្គឡើយ។

ដូច្នេះហើយ បន្ទាប់ពីព្រះសាស្តាទ្រង់យាងអស់រយៈចម្ងាយ១២០យោជន៍ ដើម្បីជួបព្រះបាទមហាកបិន ហើយទ្រង់បានប្រោសព្រះរាជាឱ្យតាំងនៅក្នុង អនាគាមិផល មួយអន្លើដោយពលសេនា១០០០នាក់ជាសោតាបត្តិផល។ ហើយព្រះអង្គទ្រង់និមិត្តឱ្យព្រះនាង អនោជា ជាអគ្គមហេសីនៃព្រះបាទមហាកបិន ដែលដេញតាមក្រោយព្រះរាជាមួយអន្លើដោយស្រីស្នំ១០០០នាក់ ដែលកំពុងស្ថិតនៅក្នុងទីជិតនោះ មិនឱ្យមើលឃើញព្រះរាជា និងពលសេនារបស់ព្រះអង្គ។

ពេលនោះ ព្រះនាងបានទូលសួរព្រះសាស្តា ថា "តើព្រះអង្គមានឃើញព្រះរាជាទេ?"

ព្រះសាស្តាទ្រង់ឆ្លើយតបដោយសំណួរថា"តើការស្វែងរកព្រះរាជា និងការស្វែងរកខ្លួនរបស់ព្រះនាង មួយណាប្រសើរជាង?"

ព្រះនាងតបថា "ស្វែងរកខ្លួនឯងប្រសើរជាង"

ក្នុងកាលនោះឯង ព្រះសាស្តា ក៏បានសម្តែងធម្មទេសនាប្រោសព្រះនាង។ នៅអវសាននៃព្រះធម៌ទេសនា ព្រះនាង





អនោជា មួយអន្លើដោយស្រីស្នំ ១០០០នាក់ បានសម្រេចសោតាបត្តិផល ចំណែកឯពលសេនារបស់ព្រះរាជាបានសម្រេចអនាគាមិផល ឯព្រះរាជាបានសម្រេចអរហត្តផល។

*(AA.1, 322; DhA. ii, 124)*

រឿងទាក់ទងនឹងអភិនីហារដ៏អស្ចារ្យនេះ គឺមានច្រើនរាប់មិនអស់ដែលមិនអាចលើកយកមកពិពណ៌នាក្នុងទីនេះ។ បើអ្នកចាប់អារម្មណ៍ចង់អានពីរឿងនេះ សូមអានក្នុងគម្ពីរ វិសុទ្ធិមគ្គ ត្រង់ឥទ្ធិវិធនិទ្ទេស និង អភិញ្ញាណនិទ្ទេស។

## អំណាចកើតឡើងដោយចិត្តតាមរយៈកម្ម

អំណាចកើតឡើងដោយចិត្តតាមរយៈកម្មនេះ គឺវិសេសវិសាលជាងអភិនីហារខាងក្រៅទៀត ព្រោះថា កម្មនាំឱ្យមានកំណើតក្នុងចក្រវាឡនេះ។ បើគេទទួលស្គាល់អភិនីហារ ដែលកើតពីចិត្ត គេក៏អាចទទួលស្គាល់អំណាចផ្លូវចិត្ត ដែលកើតពីកម្មដែរ។ ជាការពិតណាស់ ព្រះធម៌របស់ព្រះសម្មាសម្ពុទ្ធគឺជាសច្ចធម៌ ប្រាកដនិយម សមហេតុផល និងប្រកបដោយវិទ្យាសាស្ត្រ។ បើបុគ្គលបានប្រតិបត្តិដោយខ្លួនឯង បុគ្គលនោះនឹងបានចាក់ធ្លុះក្នុងសច្ចធម៌ដោយឧបាយនៃប្រាជ្ញា។

## ៣. របៀបអកុសលកម្មឱ្យផល

សៀវភៅ អភិធម្មត្ថសង្គហៈ មានពិពណ៌នាយ៉ាងពិស្តារអំពីទ្រឹស្តីកម្មផល។ នៅពេលដែលបុគ្គលសាងអំពើបាប ប្រកបដោយតណ្ហា និងការជាប់ជំពាក់ អកុសលលោភមូលចិត្ត កើតឡើងរាប់រយកោដិ។ ប្រសិនបើ បុគ្គលធ្វើបាបប្រកបដោយទោសៈ ឬព្យាបាទៈ អកុសលទោសមូលចិត្ត កើតមានរាប់រយកោដិដែរ។ នៅពេលដែលអកុសលចិត្តទាំងនោះរលត់អស់ អកុសល រាប់រយកោដិនឹងស្ថិតនៅក្នុងវិថីចិត្តរបស់បុគ្គលនោះ។

ដូច្នេះនៅពេល អកុសលកម្ម ដើរតួជា ជនកកម្ម ដើម្បីបដិសន្ធិក្នុងកំណើតថ្មី អកុសលវិបាកចិត្ត និងចេតសិក ដែលសម្បយុត្ត និងកម្មជរូប នឹងតាក់តែងកំណើតក្នុងអបាយភូមិ។ ដរាបណាកម្មនៅតែឱ្យផល វានឹងតាក់តែងវិបាកចិត្តតៗគ្នាពេញមួយជីវិត។ វិបាកចិត្ត ទី១ ដើរតួជាបដិសន្ធិ(ផ្តល់កំណើត)ឬឱ្យមានគភ៌ ដូចនេះហៅថា បដិសន្ធិចិត្ត។ វិបាកចិត្ត កើតក្រោយតៗមក ដែលបន្តឱ្យជីវិតរបស់យើងរស់រានបានហៅថា ភវង្គ-ចិត្ត។ វិបាកចិត្តចុងក្រោយដែលញ៉ាំងឱ្យមានសេចក្តីស្លាប់ហៅថា ចុតិចិត្ត។

ខណៈពេលវិបាកចិត្តកើតឡើង ចេតសិកដែលសម្បយុត្ត





ក៏កើតឡើងក្នុងពេលទន្ទឹមគ្នានេះដែរ។ កម្មជរូបកើតឡើងគ្រប់ខណៈពេលដែល បដិសន្ធិចិត្ត កើតឡើង រយៈពេលនៃចិត្តហៅថា ចិត្តក្ខណៈ ដែលសំដៅដល់ខណៈ៣យ៉ាងគឺ៖ ខណៈពេលកើត (ឧប្បាទ) ខណៈពេលឋិតនៅ(ឋិតិ) និង ខណៈពេលរលត់(ភង្គៈ)។

វិបាកចិត្ត នីមួយៗជាមួយនឹងចេតសិកដែលសម្បយុត្ត និង កម្មជរូប តាក់តែងបានជាបញ្ចក្ខន្ធ ពោលគឺវាដើរតួនាទីយ៉ាងសំខាន់ក្នុងការផលិត និងរក្សានូវជីវិតថ្មី។

ជាងនេះទៅទៀត នៅពេលដែលអកុសលកម្មឱ្យផល វានឹងតាក់តែងកំណើតក្នុងបេតវិស័យ ប្រសិនបើ **លោភៈ** មានកម្លាំងខ្លាំង បើ **ទោសៈ** ខ្លាំងជាងនឹងកើតក្នុងកំណើតនរក តែបើ **មោហៈ**ខ្លាំងជាង នឹងកើតក្នុងកំណើតតិរច្ឆាន។ អសុរកាយមានកាយធំៗជាងពួកប្រេត ដូច្នេះ ពួកគេ មានទុក្ខវេទនាច្រើនជាងពួកប្រេត ប៉ុន្តែ អាចចាត់ចូលក្នុងប្រភេទតែមួយបាន។

ដោយសារតែកំណើតក្នុងអបាយភូមិទាំងអស់ កើតឡើងដោយ អកុសលវិបាកចិត្ត ហើយរមែងរស់នៅជាមួយអកុសលវិបាកចិត្ត ដែលប្រាសចាកបញ្ញា យើងអាចយល់បានថា បញ្ញារបស់ពួកគេគឺខ្សត់ខ្សោយណាស់ ហើយសម្បូរដោយសេចក្តី

ទុក្ខវេទនាគ្រប់សព្វប្រការ។ ដូច្នេះ យើងគួរតែមានសេចក្ដីអាណិតអាសូរដល់ពពួកប្រេត នរក តិរច្ឆាន និងអសុរកាយទាំងនោះផង។

## ៤. កុសលមូល ២ យ៉ាង និងកុសលមូល ៣យ៉ាង

នៅពេលដែលកុសលកម្ម ដូចជា ការបរិច្ចាគទាន រក្សាសីល និងភាវនាជាដើម ត្រូវបានបុគ្គលបំពេញទុកហើយរាប់រយកោដិ កាមាវចរកុសលចិត្ត កើត និង រលត់ ហើយនៅក្នុងវិថីចិត្តនៃបុគ្គលនោះសន្សំទុកនូវ កាមាវចរកុសលកម្ម រាប់រយកោដិ។

នៅពេលដែលបុគ្គលបំពេញកុសលកម្ម ដោយប្រាសចាកបញ្ញា ពោលគឺមិនយល់ពីកម្ម និងផលរបស់កម្ម កាមាវចរកុសលចិត្ត ជា ញាណវិប្បយុត្ត (អមោហៈ) ដូច្នេះ វាជាទ្វេហេតុក គឺៈ អលោភៈ និង អទោសៈ ។ ហេតុនេះហើយ ចិត្តបែបនេះគេហៅថា *ទ្វេហេតុកចិត្ត* ហើយកម្មដែលបុគ្គលបានបំពេញនោះ ហៅថា *ទ្វេហេតុកកុសលកម្ម*។

នៅពេលដែលបុគ្គលបំពេញកុសលកម្ម ប្រកដោយបញ្ញា យល់ច្បាស់ពីកម្ម និងផលនៃកម្មកាមាវចរកុសលចិត្ត ជា ញាណសម្បយុត្ត ដូចនេះហៅថា *តិហេតុកចិត្ត* ព្រោះមានហេតុ៣គឺៈ





អលោភៈ អទោសៈ និងអមោហៈ(បញ្ញា )ហើយកម្មដែលបុគ្គលបំពេញ នោះហៅថា *តិហេតុកកុសលកម្ម*។

## ៥. ហីនកម្ម និងបណីតកម្ម

ក្នុងការធ្វើបុណ្យ វាចាំបាច់ណាស់ដែលយើងត្រូវតែញ៉ាំងកុសលចេតនា៣យ៉ាងឱ្យកើតឡើង។ មុនពេលធ្វើបុណ្យបុគ្គលត្រូវតែយល់ច្បាស់ពីអានិសង្សនៃបុណ្យនោះ ហើយគួរត្រេកអរជ្រះថ្លា និងមានឆន្ទៈប្រកបដោយសទ្ធាក្នុងការបំពេញបុណ្យ។ ចេតនានេះឈ្មោះថា *បុព្វចេតនា*។

ខណៈពេលកំពុងធ្វើបុណ្យ យើងត្រូវតែសប្បាយចិត្តជ្រះថ្លាចំពោះអំពើល្អ ដែលយើងបាននឹងកំពុងតែធ្វើនេះ ដោយដឹងថា អំពើល្អនឹងនាំមកនូវសេចក្ដីសុខ។ ចេតនានេះ ឈ្មោះថា *មុញ្ចនចេតនា ។*

បន្ទាប់ពីបានបំពេញបុណ្យកុសលហើយ យើងត្រូវតែរីករាយជ្រះថ្លាចំពោះអំពើល្អដែលយើងបានសាងនោះ គឺរាល់ពេលដែលយើងនឹកដល់អំពើល្អនោះ យើងតែងតែរីករាយសប្បាយចិត្ត។ ចេតនានេះឈ្មោះថា *អបរាបរចេតនា ។* នៅពេលដែលយើងបំពេញបុណ្យ ប្រកបដោយចេតនាទាំងបីយ៉ាងនេះហើយ ហៅថា *បណីតទាន* និងទង្វើនេះហៅថា *បណីតកុសលកម្ម ។*

ប្រសិនបើ យើងបំពេញបុណ្យកុសលប្រាសចាកចេតនាទាំងបីយ៉ាងនេះហៅថា *ហីនទាន* និងទង្វើនេះហៅថា *ហីនកុសលកម្ម ។*

បណីតកុសលកម្មឱ្យផលប្រសើរជាង ហីនកុសលកម្ម។ ដូច្នេះ ទោះណាជាបុគ្គលពីររូបបរិច្ចាគទានដូចគ្នាក៏ពិតមែន តែផល ដែលពួកគេទទួលបាន គឺមិនដូចគ្នានោះទេ។ អ្នកដែលបរិច្ចាគដោយសទ្ធាជ្រះថ្លា ប្រកបដោយចេតនាជាកុសលរមែងទទួលបានបណីតកុសលកម្ម គឺបានផលល្អប្រសើរជាងអ្នកឯទៀតៗ។

បុគ្គលមិនគួរធ្វើអំពើល្អ ដោយប្រាថ្នាចង់បានសម្បត្តិជាព្រះរាជា ឬសម្បត្តិសួគ៌នោះទេ ព្រោះការប្រាថ្នានូវសម្បត្តិទាំងឡាយនេះប្រព្រឹត្តទៅក្នុងអំណាចនៃលោភមូលចិត្ត។ ប្រសិនបើអកុសលចិត្ត និងអកុសលចេតនា ប្រព្រឹត្តទៅក្នុង មុញ្ចនចេតនាកកើតបានជាហីនកម្ម។

ដូច្នេះ បុគ្គលគួរបំពេញអំពើល្អប្រកបដោយបញ្ញាយល់ច្បាស់ពីកម្ម និងផលរបស់កម្ម និងប្រកបដោយកុសលចេតនាទាំងបីយ៉ាង ដូចបានរៀបរាប់មកខាងលើនេះចុះ។





## មហាកុសលកម្មបានផលតិច

ក្នុងរជ្ជកាលព្រះបាទ ប៉ ជី ដ (*Ba-gyi-daw*) និងព្រះនាង ណានម៉ ដ ម៉ៃ នុ (*Nanma-daw Mai Nu*) បានកសាងវត្តដ៏ធំស្កឹមស្កៃមួយ ប្រគេនដល់ភិក្ខុជាពហុស្សូតមានព្រះនាមថា ញ៉ោង ហ្គាន សយ៉ាដ ឧបូដ (*Nyaung Gan Sayadaw U Bode*)។ វត្តនោះកសាងអស់តម្លៃប្រមាណជាង បួនសែនក្យាត់ (រូបិយវត្ថុភូមា *four lakh kyats*) ដែលសម័យនោះតម្លៃនេះគឺច្រើនពេកពន់។ ព្រះនាង ក៏បានប្រគេនបច្ច័យបួនដល់ភិក្ខុសង្ឃផងដែរ ដូចជា ចង្ហាន់បិណ្ឌបាត ចីវរ គិលានភេសជ្ជៈ និងគ្រឿងសង្ហារឹមផ្សេងៗជាច្រើនបរិបូណ៌។

ថ្ងៃមួយ ព្រះនាងបានទូលសួរព្រះគ្រូចៅអធិការវត្តអំពីទាន ដែលព្រះនាងបានបរិច្ចាគនោះ តើបានផលយ៉ាងណាដែរ។ ព្រះគ្រូចៅអធិការ ឱ្យព្រះនាងយកភាជន៍ប្រាក់ ដួសទឹកដាក់ឱ្យពេញ ហើយចាក់ទឹកទៅលើដី។

“ចម្រើនពរ ឧបាសិកា លុយដែលឧបាសិកាបានចំណាយកសាងវត្ត និងប្រគេនបច្ច័យបួនដល់ព្រះសង្ឃ គឺប្រៀបដូចទឹកដែលចាក់ទៅលើដី រីឯផលដែលឧបាសិកាទទួលបាន គឺដូចជាទឹកដែលនៅសល់ក្នុងភាជន៍ប្រាក់នេះអ៊ីចឹងដែរ”។

ព្រះនាងមិនសប្បាយចិត្តនឹងចម្លើយនេះឡើយ។ ព្រះនាងក៏បានយាងទៅកាន់ភ្នំសាហ្គាញ (*Sagaing Hills*) ហើយបានទូលថេរដីកាចំពោះព្រះគ្រូចៅអធិការ តោង ពលូ សយ៉ាដ (*Taung Balu Sayadaw)* អំពីសំណួររបស់ព្រះនាង និងចម្លើយរបស់ព្រះគ្រូ ញ៉ោង ហ្គាន សយ៉ាដ ឧបូដ ។ ព្រះគ្រូក៏បានកត់សម្គាល់ " អាត្មាអញគិតថា មានភិក្ខុជាបណ្ឌិត ជាពហុស្សូត នៅភូមិភាគខាងត្បូងដោយនាមថា ឧបូដ ហើយឥឡូវនេះ លោកបានផ្តល់ក្តីអនុគ្រោះដល់ព្រះនាងហើយ ″។

ការកត់សម្គាល់នេះ ពិតជាមានសារៈសំខាន់ណាស់។ ព្រះនាង ណានម៉ ដ ម៉ែ នុ ទ្រង់មានមានៈគិតថា នាងបានថ្វាយវត្តដ៏ស្កឹមស្កៃ ដែលអ្នកដទៃមិនអាចធ្វើបាន។ ព្រះនាងបានញ៉ាំងលោភមូលចិត្តឱ្យចម្រើនឡើង ដោយចំណង់លោកិយចំពោះប្រណីតភាពរបស់ មនុស្ស និង ទេវតា។ ដូច្នេះ មុញ្ចនចេតនា របស់ព្រះនាងក្នុងការថ្វាយវត្ត គឺប្រកបដោយ មានៈ លោភៈ និង មិច្ឆាទិដ្ឋិ។ ព្រោះហេតុនេះទាន ដ៏មហិមាដែលព្រះនាងបានបរិច្ចាគក្លាយជា ហីនទាន ពោលគឺឱ្យផលតិចតួច។

បុគ្គលគួរបំពេញទានដោយសេចក្តីមិនជាប់ជំពាក់ ដោយលោភៈ មច្ឆរិយៈ ឡើយ ហើយគួរតាំងសេចក្តីប្រាថ្នាថា " **ឥទំ**





**មេ បុញ្ញំ និព្វានស្ស បច្ចយោ ហោតុ** ដោយបុណ្យកុសល ដែលខ្ញុំបានបំពេញហើយនេះ សូមឱ្យបានជាបច្ច័យនៃព្រះនិព្វាន ″។

**៦. មនុស្ស៣ពួក**

មិនមែន ព្រះអាទិទេព ឯណា មកបង្កើតមនុស្សលោកឱ្យដូចគ្នានោះទេ។ តាមពិត កម្មទេតើ ដែលបង្កើតសត្វលោកឱ្យមានសភាពខុសៗគ្នានោះ។ ដោយអំណាចនៃកាមាវចរកុសលកម្ម មុនុស្ស ទេវតា ប្រណីតភាពនៃមនុស្ស និងទេវតាកើតមាន។ ពេលដែលបំពេញបុណ្យកុសល បើបុគ្គលប្រាថ្នាសម្បត្តិមនុស្ស គេនឹងទទួលបានសម្បត្តិមនុស្ស ហើយបើគេប្រាថ្នាចង់បានសម្បត្តិទេវតា នោះគេនឹងបានកើតជាទេវតា។ មនុស្សខុសពីគ្នាតាំងពី រូបសម្បត្តិ គុណភាព សុខភាព ទ្រព្យសម្បត្តិ ។ល។ អាស្រ័យទៅតាមកម្ម ដែលខ្លួនបានសាងពីអតីតមក ដូចដែលព្រះសម្មាសម្ពុទ្ធទ្រង់សម្តែងទុកក្នុង ចូឡកម្មវិភង្គសូត្រ។

យោងតាមព្រះអភិធម្ម មនុស្សត្រូវបានចែកជា៣ប្រភេទ គឺ អហេតុកបុគ្គល ទ្វេហេតុកបុគ្គល និងតិហេតុកបុគ្គល។

បើបុគ្គលធ្វើកុសលមិនប្រកបដោយកម្មវិបាកសទ្ធា និង

កុសលចេតនាទាំង៣ទេនោះហៅថា ទ្វេហេតុកហីនកម្ម។ នៅពេលដែលកម្មទាំងនេះឱ្យផល នឹងតាក់តែងបានជា អហេតុកកុសលវិបាកចិត្ត សម្បយុត្តជាមួយចេតសិក និងកម្មជ្ជរូប។ អហេតុកកុសលវិបាកចិត្តនេះមានន័យថា ប្រាសចាកនូវ កុសលមូល។ មនុស្ស និងទេវតា ដែលកើតមកជាមួយអហេតុកកុសលវិបាកចិត្ត នេះហៅថា អហេតុកបុគ្គល ។

អហេតុកបុគ្គល មានប្រាជ្ញាអាប់ឱនជាងគេក្នុងចំណោម មនុស្ស និង ទេវតាទាំងឡាយ។ មនុស្សដែលមានអវយវៈ មិនគ្រប់គ្រាន់ ដូចជា ខ្វាក់ ថ្លង់ គ វិកលចរិត ឬមនុស្សដែលមានទ្រង់ទ្រាយមិនប្រក្រតី និងពពួកទេវតាដែលមានអានុភាពតិចតួច ពួកអសុរ ខ្មោច ម្រេញគង្វាល ។ល។ គឺជា អហេតុកបុគ្គល។

ម្យ៉ាងទៀត បើបុគ្គលធ្វើកុសលមិនប្រកបដោយកម្មវិបាកសទ្ធាក៏ពិតមែន តែប្រកបដោយកុសលចេតនា៣នោះ ហៅថា ទ្វេហេតុកបណីតកម្ម។ មួយវិញទៀត បើបុគ្គលធ្វើកុសលប្រកបដោយ កម្មវិបាកសទ្ធា ប៉ុន្តែប្រាសចាកនូវ កុសលចេតនា ៣ នោះនឹងក្លាយជា តិហេតុកហីនកម្ម។ នៅពេលដែលកម្មទាំងពីរប្រភេទនេះឱ្យផល នឹងបង្កើតបានជា ទ្វេហេតុកកុសលវិបាកចិត្ត សម្បយុត្តជាមួយចេតសិក និងកម្មជ្ជរូប។





មនុស្ស និង ទេវតា ដែលកើតដោយទ្វេហេតុកកុសលវិបាកចិត្តហៅថា ទ្វេហេតុកបុគ្គល ឬទ្វិហេតុកបុគ្គល។ បុគ្គលពួកនេះមិនមានបញ្ញានៅក្នុងបដិសន្ធិចិត្ត និង ភវង្គចិត្តឡើយ។ ទោះបីជាមានអវយវៈគ្រប់គ្រាន់ដូចប្រក្រតីក៏ដោយ តែមានបញ្ញាស្តួចស្តើងមិនអាចបានសម្រេច ឈាន មគ្គផល បើទោះជាគេមានសេចក្តីព្យាយាមក្នុងបច្ចុប្បន្ននេះយ៉ាងណាក៏ដោយ។

ម្យ៉ាងទៀត ប្រសិនបើបុគ្គលធ្វើកុសលប្រកបដោយកម្មវិបាកសទ្ធា និងកុសលចេតនា៣នោះនឹងបង្កើតបានជា តិហេតុកបណីតកម្ម។ នៅពេលដែលកម្មនេះឱ្យផល នឹងតាក់តែងបានជា តិហេតុកកុសលវិបាកចិត្ត សម្បយុត្តជាមួយនឹងចេតសិក និងកម្មជ្ជរូប។

មនុស្ស និង ទេវតាទាំងឡាយ ដែលកើតដោយតិហេតុកកុសលវិបាកចិត្ត ហៅថា តិហេតុកបុគ្គល។ បុគ្គលពួកនេះ មានបញ្ញា មិនមានលោភៈ និងទោសៈឡើយ (អមោហៈ អលោភៈ អទោសៈ)នៅក្នុងបដិសន្ធិចិត្ត និងភវង្គចិត្តរបស់ពួកគេ។ ពួកគេមានបញ្ញាច្រើន អាចសម្រេចឈាន មគ្គ និងផលបាន ប្រសិនបើគេមានសេចក្តីព្យាមក្នុងការប្រតិបត្តិនូវត្រៃសិក្ខា។

ដូច្នេះ ឃើញថា ទោះបីជាមនុស្សមានសណ្ឋានទ្រង់ទ្រាយដូចគ្នាក៏ពិតមែន តែបដិសន្ធិចិត្ត និងភវង្គចិត្ត គឺមិនដូចគ្នាទេ។

**៧. ភាពផ្សេងគ្នារបស់រូបព្រហ្ម**

ដោយសារតែពពួកព្រហ្មមានអំណាចខ្លាំង មនុស្សមួយចំនួនគិតថាព្រហ្មគឺជាអ្នកបង្កើតលោក និងសព្វសត្វទាំងអស់។ តើនរណាជាអ្នកបង្កើតព្រហ្មទាំងនេះ? តើនរណាជាអ្នកបែងចែក រូបព្រហ្មជា១៦ឋានខុសៗគ្នា? តើចិត្តមែនទេ ដែលជាអ្នកបង្កើតព្រហ្ម និងព្រហ្មលោកតាមរយៈកម្ម?

គេអាចអប់រំចិត្ត មួយជំហានម្តងៗរហូតដល់ភាពប្រសើរបំផុតបាន។ ចិត្តដែលប្រសើរជាងកាមាវចរចិត្តមានតែរូបាវចរចិត្ត ឬឈានចិត្ត។ ការចម្រើននូវសមាធិកម្មដ្ឋាន សតិប្បដ្ឋាន អនាបានស្សតិ ឬក៏ការចម្រើននូវ បឋវីកសិណ អបោកសិណ ។ល។ អាចធ្វើឱ្យបុគ្គលបានសម្រេចនូវ រូបាវចរកុសល ឬឈានចិត្ត៤ថ្នាក់បាន។

ឈាន គឺជាសភាពនៃចិត្តដែលតម្កល់នឹងក្នុងនិមិត្តនៃកម្មដ្ឋានក្នុងរយៈពេលមួយដ៏យូរ។ វាជាសភាវៈដែលតម្កល់នឹងមួយកន្លែង មិនមានការកំរើក បរិសុទ្ធ មិនប្រឡូកប្រឡាក់ និង





ស្ងប់ស្ងាត់នៃចិត្ត។ ឈានទី១មានអង្គ៥ មាន៥ចេតសិកដែលសម្បយុត្តជាមួយ កុសលចិត្ត និងអកុសលចិត្ត ពោលគឺៈ

(១)វិតក្ក សភាពដំបូង ដែលញ៉ាំងចិត្តឱ្យចុះកាន់អារម្មណ៍

(២)វិចារ សភាពនៃចិត្ត ដែលរក្សាចិត្តឱ្យចុះកាន់អារម្មណ៍ម្តងហើយម្តងទៀត

(៣) បីតិ សេចក្តីគាប់ចិត្តក្នុងអារម្មណ៍

(៤) សុខ សេចក្តីរីករាយក្នុងអារម្មណ៍

(៥)ឯកគ្គតា សភាពតែមួយនៃចិត្ត ដែលតម្កល់ទុកហើយ ឬសមាធិ

នៅក្នុងសមាធិ ដូចជាការចម្រើននូវ អនាបានស្សតិ កាមាវចរកុសលចិត្ត កើតឡើង ហើយអង្គឈានទាំង៥ ក៏ចម្រើនឡើងជាលំដាប់ដែរ។ នៅពេលដែលអង្គទាំង ៥ ប្រាកដហើយ ចិត្តរមែងបាននូវលំនឹងយ៉ាងរឹងមាំក្នុងអារម្មណ៍នៃសមាធិ។ ដូចនេះ ឯកគ្គតាចិត្ត ដែលជា រូបាវចរបឋមជ្ឈានកើតឡើង។ រូបាវចរមានន័យស្មើនឹង រូបភព។

បន្ទាប់មកចម្រើននូវសមាធិបន្តទៀត ដោយលះបង់នូវ

វិតក្ក និង វិចារ ទុតិយរូបាវចរជ្ឈានក៏កើតឡើង។ ឈានទី២នេះ មានអង្គ៣គឺៈ បីតិ សុខ និងឯកគ្គតា។

បន្ទាប់មក ចម្រើននូវសមាធិបន្តទៀត ដោយលះបង់នូវ បីតិ តតិយរូបាវចរជ្ឈានក៏កើតឡើង។ ឈានទី៣នេះ មានអង្គ ២គឺៈ សុខ និង ឯកគ្គតា។ សុខ នេះ មានកម្លាំងខ្លាំងដែរ យើង អាចនិយាយបានថា ជាសេចក្ដីស្ងប់ចិត្ត ពោរពេញដោយការ រីករាយដ៏ក្រៃលែងក្នុងលោកនេះ។

បន្ទាប់មក ចម្រើននូវសមាធិបន្តទៀត ដោយលះបង់នូវ សុខ ចតុត្ថរូបាវចរជ្ឈាន ក៏កើតឡើង។ ឈានទី៤នេះ ក៏មាន អង្គពីរដែរ ឧបេក្ខា និង ឯកគ្គតា។ ឧបេក្ខា គឺជាអារម្មណ៍ដែល មិនលម្អៀង ឬការតាំងចិត្តជាកណ្ដាល។ ដូចនេះ ឈានទី៤នេះ បរិបូណ៌ដោយសេចក្ដីស្ងប់ស្ងាត់ មានសន្តិភាព ហើយមានចិត្ត តម្កល់មាំដោយល្អ ក្នុងអារម្មណ៍នៃកម្មដ្ឋាន។

ចំពោះ ចិត្ត ស្ថិតនៅក្នុងឈានគឺជ្រះស្រឡះពីកិលេសទាំង ឡាយ។ ដូច្នេះ ចិត្តបរិសុទ្ធ ស្ងប់ មានសន្តិភាពបរិបូណ៌ ដោយ អំណាច។ សេចក្ដីសុខក្នុងឈាន គឺមានលក្ខណៈខ្ពស់ជាង កាម សុខ។

ក្នុង **បចលាយមានុសូត្រ** សម្ដែងថា នៅពេលចុះកាន់





ឈាន ចិត្តមានសភាពល្អបរិសុទ្ធ និងប្រកបដោយភាពនឹងនំ និងមានពន្លឺចែងចាំងសាយភាយ។ ចិត្តកាន់តែស្ងប់ ពន្លឺកាន់តែ ចែងចាំង។ ហើយពន្លឺនេះអាចធ្វើឱ្យមើលឃើញនូវវត្ថុនានាជុំ វិញខ្លួនយើង និងវត្ថុដែលនៅឆ្ងាយពីខ្លួនយើងបានសូម្បីដោយ បិទភ្នែក។ យើងអាចមើលឃើញដោយបិទភ្នែកនេះ គឺតាមរយៈ វិញ្ញាណចក្ខុដែលប្រកបដោយសមាធិចិត្ត។ ហើយគេក៏អាច មើលឃើញក្នុងកាយដូចជា សាច់ ឆ្អឹង សួត បេះដូង ថ្លើម ។ល។ ប្រសិនបើ គេចម្រើនឈានឱ្យកាន់តែមាំមួនឡើង នោះ គេក៏អាចចាក់ធ្លុះយ៉ាងជាក់ច្បាស់នូវបរមត្ថសច្ចៈ ពោលគឺ ចិត្ត ចេតសិក និង រូប។ បន្ទាប់មកគេអាចចម្រើននូវវិបស្សនាកម្មដ្ឋាន តាមសមគួរ។

នៅពេលបុគ្គលចម្រើននូវឈានសមាបត្តិ ពោលគឺតម្កល់ ចិត្តឱ្យនឹងក្នុងអង្គឈានរយៈពេល ១ ម៉ោង ឬ ២ ម៉ោង ។ល។ ឈានចិត្តកើតឡើងជាបន្តបន្ទាប់ច្រើនជាងមួយសែនកោដិ ក្នុង មួយវិនាទី ដូចនេះ រូបាវចរកុសលកម្ម រាប់រយកោដិបានសល់នៅ ក្នុងវិថីចិត្ត។ ឈានកម្មនេះ មានទម្ងន់ធ្ងន់ណាស់ ដែលយើង អាចហៅថា គរុកកម្មបាន។

(១) យោងទៅតាម រូបាវចរកុសលកម្ម ប្រសិនបើ

បុគ្គលចម្រើននូវ *រូបាវចរកុសលបឋមជ្ឈាន* ថ្នាក់បឋម គេនឹងកើតក្នុងឋានឈ្មោះ *ព្រហ្មបារិសជ្ជៈ* បើចម្រើនថ្នាក់មធ្យម កើតក្នុង*ព្រហ្មបុរោហិតា* ហើយបើចម្រើនថ្នាក់ឧត្តម នឹងកើតក្នុងឋាន *មហាព្រហ្ម*។ ដូចនេះ ឃើញថា *រូបាវចរកុសលបឋមជ្ឈាន* ផ្តល់កំណើតក្នុងឋានព្រហ្ម៣ជាន់ដំបូង តាមសមគួរដល់កម្មដែលបុគ្គលបានសាងសន្សំមក។

(២) ដូចគ្នានេះដែរ *រូបាវចរកុសលទុតិយជ្ឈាន* បើចម្រើនថ្នាក់បឋម ផ្តល់កំណើតក្នុងឋាន *បរិត្តាភា* បើចម្រើនថ្នាក់មធ្យមផ្តល់កំណើតក្នុង *អប្បមាណាភា* ហើយបើចម្រើនថ្នាក់ឧត្តម ផ្តល់កំណើតក្នុងឋាន *អាភស្សរា*។ ដូចនេះ *រូបាវចរកុសលទុតិយជ្ឈាន* ផ្តល់កំណើតក្នុងឋានព្រហ្ម ៣ ជាន់ ទី២ តាមសមគួរដល់កម្មដែលបុគ្គលបានសាងសន្សំមក។

(៣)ម្យ៉ាងទៀត *រូបាវចរកុសលតតិយជ្ឈាន* បើចម្រើនថ្នាក់បឋម ផ្តល់កំណើតក្នុងឋាន *បរិត្តសុភា* ថ្នាក់មធ្យមផ្តល់កំណើតក្នុងឋាន *អប្បមាណសុភា* ហើយបើចម្រើនថ្នាក់ឧត្តម ផ្តល់កំណើតក្នុងឋាន *សុភកិណ្ហា* ។ ដូចនេះ *រូបាវចរកុសលតតិយជ្ឈាន* ផ្តល់កំណើតក្នុងឋានព្រហ្ម៣ជាន់ថ្នាក់ទី៣ តាមសមគួរដល់កម្មដែលបុគ្គលបានសាងសន្សំមក។





(៤)*រូបាវចរកុសលចតុត្ថជ្ឈាន* បើចម្រើនថ្នាក់បឋមផ្តល់កំណើតក្នុងឋាន *វេហប្ផលា*។ ក្រោយទទួលបានឈានទី៤នេះហើយ បើបុគ្គលចម្រើននូវ អសុភសញ្ញា នោះនឹងបានកើតក្នុងឋាន *អសញ្ញសត្ត*។ អសញ្ញសត្តព្រហ្មមានតែរូបកាយ មិនមានសញ្ញា និងចិត្ត ចេតសិកទេ។ ជាងនេះទៅទៀត អនាគាមីបុគ្គលដែលមានរូបាវចរចតុត្ថជ្ឈាននឹងចាប់កំណើតក្នុងឋាន សុទ្ធាវាស៥ជាន់ ដោយអំណាចនៃឥន្ទ្រីយ៍៥គឺៈ សទ្ធា វីរិយៈ សតិ សមាធិ និងបញ្ញា។ ដូចនេះ *រូបាវចរកុសលចតុត្ថជ្ឈាន* ផ្តល់កំណើតក្នុងឋានព្រហ្មចតុត្ថជ្ឈាន៧ជាន់ តាមសមគួរដល់កម្ម ដែលបុគ្គលបានសាងសន្សំមក។

ឋានព្រហ្មបឋមជ្ឈាន៣ជាន់ ទុតិយជ្ឈាន៣ជាន់ តតិយ-ជ្ឈាន៣ជាន់ និងចតុត្ថជ្ឈាន៧ជាន់ ត្រូវជា រូបព្រហ្ម១៦ជាន់។ ឋានព្រហ្មព្រមទាំងព្រហ្មគឺបង្កើតឡើងដោយចិត្តទាំងអស់ ដោយអាស្រ័យតាមកម្មដែលបុគ្គលបានសាងសន្សំមក។

ដោយ រូបាវចរកុសលកម្ម មានអានុភាពជាង កាមាវចរកុសលកម្ម រូបបាវចរព្រហ្ម មានអានុភាពជាងមនុស្ស និងទេវតាហើយពពួកព្រហ្មមានអាយុវែងច្រើនលោកធាតុ។

## ៨.អរូបព្រហ្មដែលមានតែចិត្ត

បុគ្គលបានសម្រេច រូបាវចរចតុត្ថជ្ឈាន ហើយ គួរគប្បី ចម្រើននូវអរូបាវចរជ្ឈានតទៅទៀត។ ដំបូងបុគ្គលត្រូវតែកំណត់ដឹងថារូបរាងកាយនេះគឺជាទុក្ខ ពោរពេញដោយការសោកសៅសព្វបែបយ៉ាង ដោយសារ កំដៅ ត្រជាក់ សត្វខាំចឹក សេចក្តីស្រេកឃ្លាន ជំងឺ ការចាស់ជរា សេចក្តីស្លាប់ ។ល។

បន្ទាប់មកចម្រើននូវ រូបាវចរចតុត្ថជ្ឈាន ដោយពិចារណានូវបឋវីកសិណ ចេញចាកឈាន រួចហើយពិចារណាអំពីទោសនៃរូបរាងកាយនេះ។ ឃើញនូវទោសនៃរាងកាយហើយ ចេញចាកនិមិត្តនៃបឋវីកសិណ រួចហើយពិចារណានូវ *អាកាសកសិណ* ថា "អាកាសៈ អាកាសៈ" ឱ្យបានច្រើនដង។

នៅពេលដែលសេចក្តីជាប់ចិត្តក្នុងនិមត្ត និង និមិត្តនោះរលត់ទៅវិញហើយ អាកាសៈ នឹងកើតឡើងក្នុងខណៈនោះ។ ពិចារណាអំពីអាកាសៈនេះ ហើយតម្កល់ទុកក្នុងចិត្តថា"អាកាសៈ អាកាសៈ" រហូតទាល់តែសមាធិចិត្តតាំងនៅស៊ុបក្នុងអាកាសៈនោះ អស់រយៈពេល១ម៉ោង ២ម៉ោង ឬច្រើនជាងនេះ។ ឥឡូវនេះបុគ្គលបានសម្រេច *អរូបបឋមជ្ឈាន* ហើយ ហៅថា *អាកាសានញ្ចាយតនឈាន*។





បន្ទាប់មកអាចចំរើននូវ អរូបទុតិយជ្ឈាន ដោយពិចារណានូវ អាកាសានញ្ចាយតនឈានចិត្តថា " *វិញ្ញាណ វិញ្ញាណ* "។ អរូបទុតិយជ្ឈាននេះឈ្មោះថា *វិញ្ញាណញ្ចាយតនឈាន*។

បន្ទាប់មកទៀតពិចារណានូវ *សុញ្ញត (ភាពសូន្យសោះ)* ដែលកើតចេញពីការរលត់ទៅនៃ អាកាសានញ្ចាយតនឈាន ថា " **នត្ថិ កិញ្ចិ** *(អ្វីៗទាំងអស់គឺសូន្យទទេ)*" ឱ្យបានច្រើនដងទាល់តែឈានកើតឡើង។ ឈាននេះមានឈ្មោះថា*អាកិញ្ចញ្ញាយតនឈាន*។

បន្ទាប់ពីបានពិចារណានូវ អកិញ្ចញ្ញាយតនឈាន ហើយ គប្បីចម្រើននូវ អរូបចតុត្ថជ្ឈាន ដែលមានឈ្មោះថា " *នេវសញ្ញានាសញ្ញាយតនឈាន*"។ " នេវសញ្ញានាសញ្ញា" បានន័យថា " មិនមានសញ្ញា ឬមានសញ្ញាក៏មិនមែន"។ ឈាននេះល្អិតសុខុមណាស់ សូម្បីតែការកើតឡើងនៃឈានចិត្តនេះ ក៏មិនអាចសម្គាល់បាន។

ការសម្រេចបាននូវឈាននីមួយៗ ញ៉ាំងឱ្យបុគ្គលនោះរីករាយជាសុខអស់រយៈពេលជាច្រើនម៉ោង។ ក្នុងកំឡុងពេលនោះ ឈានចិត្ត រាប់រយកោដិកើត និងរលត់ដោយបន្សល់នូវ *អរូបាវចរកុសលកម្ម* ជាច្រើនរយកោដិ។

នៅពេលបុគ្គលស្លាប់ទៅ កម្មនេះនឹងដើរតួរជាផលិតកម្ម ផ្តល់កំណើតជា វិញ្ញាណក្ខន្ធ ប៉ុណ្ណោះ។ ពុំមានរូបក្ខន្ធទេ ព្រោះ បុគ្គលបានចាក់ធ្លុះក្នុងទោសនៃរូបកាយនេះ ហើយបានលះបង់ចោល។

(១) អាកាសានញ្ចាយតនកុសលកម្ម ផ្តល់កំណើតក្នុង អាកាសានញ្ចាយតនព្រហ្ម ដែលមាន អាកាសានញ្ចាយតនវិបាកចិត្ត ដើរតួជា បដិសន្ធិចិត្ត, ភវង្គចិត្ត និង ចុតិចិត្ត ។

(២) វិញ្ញាណញ្ចាយតនកុសលកម្ម ផ្តល់កំណើតក្នុង វិញ្ញាណញ្ចាយតនព្រហ្ម ដែលមាន វិញ្ញាណញ្ចាយតនវិបាកចិត្ត ដើរតួជា បដិសន្ធិចិត្ត, ភវង្គចិត្ត និង ចុតិចិត្ត ។

(៣) អាកិញ្ចញ្ញាយតនកុសលកម្ម ផ្តល់កំណើតក្នុង អាកិញ្ចញ្ញាយតនព្រហ្ម ដែលមាន អាកិញ្ចញ្ញាយតនវិបាកចិត្ត ដើរតួជា បដិសន្ធិចិត្ត, ភវង្គចិត្ត និង ចុតិចិត្ត ។

(៤) នេវសញ្ញានាសញ្ញាយតនកុសលកម្ម ផ្តល់កំណើតក្នុង នេវសញ្ញានាសញ្ញាយតនព្រហ្ម ដែលមាន នេវសញ្ញានាសញ្ញាយតន វិបាកចិត្តដើរតួជា បដិសន្ធិចិត្ត, ភវង្គចិត្ត និង ចុតិចិត្ត ។

ដោយសារតែ អរូបាវចរកុសលកម្ម មានអានុភាពជាង





រូបាវចរកុសលកម្ម ដូចនេះ អរូបព្រហ្ម មានអាយុវែងជាង រូបព្រហ្ម។ អាយុក្ខ័យរបស់ អរូបព្រហ្ម គឺ ២០០០០, ៤០០០០, ៦០០០០ និង ៨៤០០០កប្បតាមឋានានុក្រម ។

តាមការសិក្សាខាងលើនេះឃើញថា ភពទាំង៣១ជាន់ និងពពួកសត្វទាំងឡាយក្នុងភពទាំងអស់ គឺបង្កើតឡើងដោយចិត្តមានកម្មជាមូល។ វាសនារបស់បុគ្គលម្នាក់ៗ ក៏ស្ថិតនៅលើចិត្តរបស់គេជាអ្នកសម្រេចដែរគឺប្រព្រឹត្តទៅតាមកម្ម ឬទង្វើរបស់សត្វរៀងៗខ្លួន ។

"អ្វីដែលយើងកំពុងតែមានក្នុងបច្ចុប្បន្ននេះគឺជាផល ដែលយើងបានសាងពីអតីត ហើយអ្វីដែលយើងនឹងបានក្នុងពេលអនាគតគឺជាផលរបស់កម្មក្នុងបច្ចុប្បន្ននេះឯង"។

**ឯកសារយោង:**


1) Dr. Mehm Tin Mon, "Samatha" (Advanced Level) Vol.II.pp.88-159
2) "Visuddhi Magga" by Bhaddantacariya Buddhaghosa, translated into Myanmar by Ven Nandamala, Vol, II, pp.185-315.
3) "The Path of Purification" (Visuddhi Magga by Bhaddantacariya Buddhaghosa), translated into English By Bhikkhu Nanamoli, pp.409-478.
4) Dr. Mehm Tin Mon, "Abhidhamma" (Higher Level) Vol, I,pp 164-175.

5) Bhikkhu Bodhi, General Editor, “A Comprehensive Manual of Abhidhamma”, pp.210-219
6) Dr. Mehm Tin Mon, “The Essence of Buddha Abhidhamma”, pp. 210-216.



# ១០

## មរណៈ និង បដិសន្ធិ

### ១.តើអ្វីដែលទ្រទ្រង់ជីវិតឱ្យរស់នៅបាន?

“ **សព្វេ សត្តា អាហារ ឋិតិកា** ” "សព្វសត្វទាំងអស់រស់នៅបានដោយសារអាហារ"

" **អាហារ** " ក្នុងភាសាបាលីមានន័យថា ចំណីអាហារ ឬសារធាតុដែលទ្រទ្រង់នូវសព៌ាង្គកាយឱ្យប្រព្រឹត្តទៅបាន។ អាហារនេះ ដើរតួយ៉ាងសំខាន់ដើម្បីទ្រទ្រង់ និងធ្វើឱ្យរូបរាងកាយមានការលូតលាស់។

នៅក្នុងព្រះអភិធម្ម អាហារដែលជាគ្រឿងទ្រទ្រង់នូវសព្វសត្វទាំងអស់ឱ្យមានជីវិតរស់នៅបាន មាន៤យ៉ាងគឺៈ

១) **កបលីការាហារ** - សារធាតុទ្រទ្រង់ដែលមាននៅក្នុងអាហារ( ឱជារស )

អាហារនេះផលិតបានជា អហារជរូបកលាបដែលជាអាហារទ្រទ្រង់សព៌ាង្គកាយឱ្យប្រព្រឹត្តទៅបាន។

**២)ផស្សាហារ** - អាហារគឺការពាល់ត្រូវតាមរយៈវិញ្ញាណ

អាហារនេះគឺជាតួចេតសិក"ផស្សៈ"ដែលសម្បយុត្ត ជាមួយចិត្តគ្រប់ដួង។ វាជាកន្លែងប្រមូលផ្តុំ ដែលចិត្ត និង វិញ្ញាណ ផលិត និងទ្រទ្រង់នូវវេទនា៥។ កត្តាដែលសព្វសត្វទាំងអស់ រំពឹងចង់បានជាងគេគឺ សុខវេទនាផ្លូវកាយ និងចិត្ត។

**៣)មនោសញ្ចេតនាហារ** - អាហារគឺចេតនា ឬកម្ម

អាហារនេះគឺជាតួចេតសិក "ចេតនា" ដែលសម្បយុត្តជាមួយចិត្តគ្រប់ដួង។ ចេតនាគឺជាអ្នកសម្រេចរាល់ទង្វើរបស់មនុស្ស ហើយតាក់តែងឱ្យកើតជាកម្ម។ នៅពេលដែលចេតនារលាយទៅវិញ ឥទ្ធិពលវាសល់នៅក្នុងវិថីចិត្តដែលនោះហៅថា **កម្ម** ។

កុសលកម្ម និង អកុសលកម្មឱ្យផលបន្តបន្ទាប់រហូតក្នុងស្ថានជាវិបាកចិត្ត ចេតសិកដែលសម្បយុត្ត និង កម្មជរូប។ ការប្រព្រឹត្តទៅនៃចេតសិក និងកម្មជរូបនេះ ហើយដែលធ្វើឱ្យជីវិតចេះតែបន្តទៅបាន។ ក្នុងចំណោមចេតសិក ទាំងអស់មាន ចេតសិកមួយឈ្មោះថា "ជីវិតិន្ទ្រីយ៍" ។ ហើយក្នុងកម្មជរូបមាន "ជីវិតរូប"។ ការប្រព្រឹត្ត





ទៅនៃជីវិតន្ទ្រីយ៍ និងជីវិតរូបញ៉ាំងឱ្យជីវិតសព្វសត្វទាំងអស់រស់រាន។ នៅពេលដែល ជីវិតន្ទ្រីយ៍ និងជីវិតរូបកាត់ផ្តាច់ជីវិតសព្វសត្វទាំងអស់បានស្លាប់។

**៤)វិញ្ញាណាហារ** - អាហារគឺចិត្ត ឬវិញ្ញាណ

នៅពេលដែលចិត្តកើតឡើង ចេតសិក ដែលសម្បយុត្ត រួមទាំងជីវិតិន្ទ្រីយ៍ និងចិត្តជរូបកើតឡើងក្នុងពេលទន្ទឹមគ្នានោះដែរ។ ដោយសារតែការកើតឡើងជាលំដាប់នៃចិត្តនេះហើយ ដែលធ្វើឱ្យយើងរស់រានមានជីវិតបាន។ ដូចគ្នានេះដែរ ការកើតឡើងជាលំដាប់នៃចិត្តជរូបនេះហើយ ដែលធ្វើឱ្យយើងអាចធ្វើចលនា ដៃជើង មាត់ ។ល។ បាន និងមានជីវិត។

ក្នុងចំណោមអាហារទាំង៤នេះ មនោសញ្ចេតនាហារ ឬកម្មសំខាន់ជាងគេ។ ដរាបណា ជនកកម្ម ដែលតាក់តែងឱ្យជីវិតបច្ចុប្បន្ននេះប្រព្រឹត្តទៅបាន មានកម្លាំងអន់ថយ ឈប់ផលិតនូវវិបាកចិត្ត សម្បយុត្តចេតសិក និងកម្មជរូប សព្វសត្វទាំងអស់នឹងស្លាប់ភ្លាម។

## ២. ហេតុអ្វីសត្វត្រូវស្លាប់?

អ្វីជាសេចក្តីស្លាប់? សេចក្តីស្លាប់ គឺជាការអស់ទៅនៃ

ជីវិតន្ទ្រីយ៍ ជីវិតរូប វិញ្ញាណ និងកំដៅ (ឧស្មា តេជោ)។

ហេតុអ្វីបានជាសត្វចាំបាច់ស្លាប់? ខាងក្រោមនេះមានមូលហេតុ៤យ៉ាងដែលពន្យល់ពីហេតុអ្វីបានជាសត្វត្រូវស្លាប់៖

(១) អាយុក្ខយមរណៈ ស្លាប់ដោយអស់អាយុ

(២) កម្មក្ខយមរណៈ ស្លាប់ដោយអស់កម្ម(បុណ្យ)

(៣) ឧភយក្ខយមរណៈ ស្លាប់ដោយអស់អាយុ និងកម្ម

(៤) ឧបច្ឆេទកមរណៈ ស្លាប់ដោយកម្មកាត់ផ្តាច់ ស្លាប់ក្នុងមួយរំពេចដូចជា គ្រោះថ្នាក់ចរាចរណ៍ ឬធ្វើអត្តឃាត។

យើងអាចប្រៀបធៀបសេចក្តីស្លាប់ដោយហេតុ ៤ យ៉ាងខាងលើនេះទៅនឹងពន្លឺចង្កៀង។ ពន្លឺចង្កៀងនឹងរលត់នៅពេលដែល ៖

(១) អស់ប្រេងឆេះ

(២) អស់ប្រេង

(៣) អស់ប្រេងឆេះ និងប្រេង

(៤) ខ្យល់បក់មកខ្លាំងមួយរំពេច ឬត្រូវបានគេពន្លត់ដោយចេតនា ភ្លើងចង្កៀងរមែងរលត់ នៅពេលដែលអស់ប្រេងឆេះយ៉ាងណាមិញជីវិតសព្វសត្វ នឹងត្រូវស្លាប់នៅពេលដែលអស់





អាយុ។ អាយុក្ខ័យមនុស្សបច្ចុប្បន្នត្រូវបានគេសន្និដ្ឋានប្រមាណ ៧៥ឆ្នាំ ។ ដូច្នេះ មនុស្សអាចស្លាប់នៅពេលគេមានអាយុ៧៥ឆ្នាំ។

ពេលអស់ប្រេង ភ្លើងចង្កៀងរមែងរលត់ យ៉ាងណាមិញសព្វសត្វនឹងត្រូវស្លាប់ នៅពេលដែលអស់កម្មទ្រទ្រង់ (ជនកកម្ម)។ បុគ្គលខ្លះស្លាប់នៅអាយុក្មេងដោយសារតែមានជនកកម្មតិចតួច រីឯបុគ្គលអ្នកមានអាយុវែង ប្រាកដណាស់ដោយសារតែគេមានកម្មទ្រទ្រង់ច្រើន។

កាលបើអស់ប្រេងឆេះ និងអស់ប្រេងហើយ ភ្លើងចង្កៀងរមែងរលត់ មិនខុសអីពីជីវិតនៃសព្វសត្វទាំងឡាយ ដែលត្រូវស្លាប់ព្រោះការអស់ទៅនៃអាយុ និងកម្ម(បុណ្យ)យ៉ាងនោះដែរ។

ប៉ុន្តែ សត្វខ្លះស្លាប់ដោយសារកម្មណាមួយដែលខ្លួនបានសាងមកពីអតីតចូលមកកាត់ផ្តាច់។ ជួនកាលស្លាប់ដោយធ្វើអត្តឃាតខ្លួនឯង ខ្លះស្លាប់ដោយគេសម្លាប់ ខ្លះស្លាប់ដោយគ្រោះថ្នាក់ និងដោយជំងឺបៀតបៀន។ល។ ប្រៀបបីដូចជាភ្លើងចង្កៀងដែលកំពុងតែឆេះ តែត្រូវរលត់ទៅមួយរំពេចដោយសារតែខ្យល់បក់ត្រូវ ឬត្រូវនរណាមួយពន្លត់ដោយចេតនា។

**៣. តើមាននិមិត្តដូចម្តេចខ្លះមុនពេលស្លាប់?**

នៅពេលដែល ជនកកម្ម ដែលទ្រទ្រង់នូវជីវិតបច្ចុប្បន្ន

ហៀបនឹងអស់ទៅ ឬថានៅពេលដែលយើងជិតស្លាប់ កុសលកម្ម និងអកុសលកម្មរាប់ពាន់លាននៅក្នុងវិថីចិត្តនឹងប្រជែងគ្នាដណ្ដើមយកតួនាទីតាក់តែងកំណើតថ្មី។ ប្រៀបដូចជាគោក្របីច្រើនក្បាល ដែលគេរក្សាក្នុងក្រោលក្នុងពេលរាត្រី លុះព្រឹកឡើងរមែងប្រជែងគ្នាដើម្បីបានចេញពីក្រោលមុនគេ។

ក្នុងចំណោមកម្មទាំងឡាយ កម្មមួយដែលមានឱកាសដើរតួនាទីជាអ្នកតាក់តែងកំណើតថ្មីនឹងស្ថិតនៅ ឯមនោទ្វារនៃបុគ្គលនោះ ហៅថា កម្មវត្ថុ ។ ឬក៏អ្វីដែលធ្លាប់បានឃើញ និងធ្លាប់បានឮពេលកំពុងធ្វើទង្វើផ្សេងៗ ទង្វើទាំងនោះនឹងកើតមានតាមលំដាប់ក្នុងចក្ខុទ្វារ និងសោតទ្វារ។ និមិត្តនេះឱ្យឈ្មោះថា *កម្មនិមិត្ត* ។ ឬក៏ថារូបភាពដែលបានឃើញទាក់ទងទៅនឹងទីកន្លែង ដែលនឹងត្រូវទៅកើតតាមទ្វារណាមួយ ។ និមិត្តនេះឱ្យឈ្មោះថា *គតិនិមិត្ត (និមិត្តនៃដំណើរដែលត្រូវឆ្ពោះទៅ)*។

## និមិត្ត ៣ ប្រភេទពេលជិតស្លាប់

(១) កម្មៈ កុសលកម្ម និងអកុសលកម្ម ដែលបុគ្គលបានសាងពីអតីតមកនឹងតាក់តែងជាបដិសន្ធិក្នុងខណៈនោះ។

ឧទាហរណ៍ថា ចិត្ត និងចេតនាដែលបានកើតក្នុងពេលកំពុងធ្វើកុសល និងអកុសលបានកើតក្នុងមនោទ្វារ។ មនុស្ស





ជិតនឹងស្លាប់ ក៏នឹងមានទំនងដូចគ្នា ដូចដែលគេធ្លាប់មានក្នុងពេលកំពុងធ្វើនូវកម្មនោះៗ។ ឬអាចនិយាយបានថា គេរលឹកនឹកឃើញនូវអ្វីដែលគេបានសាងសន្សំក្នុងអតីត។

(២)កម្មនិមិត្ត សំដៅដល់ រូប សំឡេង ក្លិន កាំភ្លើង កាំបិត ។ល។ ដែលបុគ្គលធ្លាប់បានជួបប្រទះ ឬប្រើប្រាស់ក្នុងពេលធ្វើកម្មផ្សេងៗដែលនឹងត្រូវឱ្យផល។ ឧទាហរណ៍ថា ប្រសិនបើ កម្មនោះគឺជាការថ្វាយផ្កាចំពោះព្រះពុទ្ធ ដូច្នេះ បុគ្គលនោះនឹងឃើញនូវព្រះពុទ្ធបដិមា និងផ្កាក្នុងកម្មនិមិត្តនោះ។

ប្រសិនបើ កម្ម គឺការបង្រៀនសិស្សមួយក្រុម គ្រូបង្រៀននឹងឃើញ សិស្ស សៀវភៅ និងថ្នាក់រៀន ដែលជាកម្មនិមិត្ត។

ប្រសិនបើ កម្មនោះ គឺជាការសម្លាប់ត្រី បុគ្គលនោះនឹងឃើញនូវត្រីដែលគេកាត់ជាពីរ និងកាំបិតដែលប្រឡាក់ដោយឈាមក្នុងកម្មនិមិត្តនោះ។

(៣)គតិនិមិត្ត និមិត្តដែលបានឃើញនូវទីកន្លែងដែលនឹងត្រូវទៅកើត។

ឧទាហរណ៍ថា ប្រសិនបើកុសលកម្មត្រូវតាក់តែងកំណើតជាមនុស្ស បុគ្គលនោះ នឹងឃើញនូវឧទរនៃមាតាអនាគតរបស់ខ្លួន ប្រៀបបីដូចជាកម្រាលនៃសំពត់កម្ពលមានពណ៌ដ៏ក្រហម

ប្រាល ឬក៏ឃើញផ្ទះ និងមនុស្សជាដើម ។ល។

ប្រសិនបើ កុសលកម្ម ត្រូវតាក់តែងកំណើតជាទេវតា បុគ្គលនោះនឹងឃើញនូវទេវវិមាន និងទេវបុត្រ ទេវធីតាជាដើម។

ប្រសិនបើ អកុសលកម្ម ត្រូវតាក់តែងកំណើតក្នុងនរក បុគ្គលនោះនឹងឃើញនូវភ្លើងនរក ខ្ទះភ្លើងដែលពោរពេញដោយលោហធាតុដ៏ក្តៅ ឆ្កែនរក និងស្តេចយមរាជជាដើម ។ល។

## និមិត្តនៅពេលជិតស្លាប់អាចផ្លាស់ប្តូរ

ព្រះសោណត្ថេរ គង់នៅសោណគិរីក្នុងប្រទេសស្រីលង្កា។ ដោយសេចក្តីព្យាយាមដ៏មុតមាំរបស់លោក ក្នុងការកាន់យកនូវត្រៃសិក្ខា លោកបានត្រាស់ដឹងជាព្រះអរហន្ត។ ញោមប្រុសរបស់លោក ជាអ្នកចិញ្ចឹមជីវិតដោយការប្រមាញ់ ក្រោយមកទើបបានបួសជាភិក្ខុ ពេលដែលខ្លួនមានវ័យជរាហើយ។ ដូច្នេះហើយ មិនយូរប៉ុន្មាន ភិក្ខុជាបិតានោះក៏ធ្លាក់ខ្លួនឈឺយ៉ាងខ្លាំងរហូតដល់ដេកស្តូកស្តឹងនៅលើគ្រែ។ លោកឃើញឆ្កែនរកយ៉ាងកាចសាហាវតែងរត់ឡើងមកលើភ្នំដើម្បីខាំស៊ីនូវរូបលោក។ ដូចនេះ លោកក៏ប្រាប់ភិក្ខុជាកូនឱ្យដេញឆ្កែទាំងនោះចេញ។ ព្រះសោណត្ថេរ ទ្រង់ជ្រាប់យ៉ាងច្បាស់ថា ភិក្ខុជាបិតាកំពុងតែឃើញឆ្កែនរកមកខាំ នេះហៅថា គតិនិមិត្ត។





ព្រះសោណត្ថេរ បានប្រើសាមណេរទាំងឡាយនាំយកនូវផ្កាផ្សេងៗ ហើយដាក់ជុំវិញព្រះចេតិយនៅលើភ្នំនោះ រួចហើយឱ្យគេសែងបិតាទៅគង់នៅទីជិតនៃព្រះចេតិយនោះ។

ព្រះសោណត្ថេរ ក៏បានពោលថា "បពិត្របិតា សូមទ្រង់នមស្សការចំពោះព្រះចេតិយ ផ្កាទាំងឡាយត្រូវបានភិក្ខុ និងសាមណេរទាំងឡាយបូជាជំនួសហើយ សូមបិតាញុំាងសេចក្តីជ្រះថ្លាក្នុងការបូជានូវផ្កាទាំងឡាយនេះចំពោះព្រះចេតិយចុះ" ។

ដូចនេះ ភិក្ខុជាបិតាក៏ថ្វាយបង្គំព្រះចេតិយ ហើយញុំាងសេចក្តីជ្រះថ្លាក្នុងការបូជានូវផ្កាទាំងឡាយដល់ព្រះសម្មាសម្ពុទ្ធ។ កុសលកម្មនេះក្លាយជា កម្មដែលឱ្យផលកៀកសេចក្តីស្លាប់ កម្មនេះជាអ្នកតាក់តែងកំណើតថ្មី។

ភិក្ខុជាបិតា ក៏បានឃើញទេវធីតាទាំងឡាយចុះមកពីឋានសួគ៌។ គតិនិមិត្តរបស់លោកបានផ្លាស់ប្តូរ ពោលគឺលោកនឹងមានដំណើរទៅកាន់សុគតិភព។

ពេលនោះលោក ក៏បានប្រាប់ភិក្ខុជាកូនថា " ម្នាលកូនម្តាយចុងកូនឯងស្អាតៗដូចទេវធីតា ហើយពួកគេកំពុងតែហៅបិតាទៅជាមួយហើយ តើបិតាគួរទៅជាមួយពួកគេទេ?" ។

"សូមបិតានិមន្តទៅជាមួយពួកគេចុះ"។ ពេលនោះភិក្ខុជា

បិតា ក៏អនិច្ចធម្មទៅ ហើយក៏បានទៅកើតក្នុងទេវលោកបាត់ទៅ។

## ទេវរថហោះមកមុនពេលស្លាប់

កាលព្រះសម្មាសម្ពុទ្ធទ្រង់គង់ធរមាននៅឡើយ មាន ឧបាសកម្នាក់ឈ្មោះ ធម្មិកៈ ជាប្រធាននៃឧបាសកទាំងឡាយ ៥០០នាក់រស់នៅក្នុងក្រុងសាវត្ថី។ ហើយក្នុងចំណោមឧបាសក ទាំង៥០០នាក់នេះម្នាក់ៗសុទ្ធតែមានឧបាសក៥០០នាក់ ជា បរិវារទៀត ដូច្នេះ ធម្មិកឧបាសក គឺជាប្រធាននៃឧបាសកទាំង ឡាយមានចំនួន ២៥០០០០ នាក់។ ពួកឧបាសកទាំងឡាយ នេះតែងនាំគ្នាបរិច្ចាគទាន រក្សាសីល និងចម្រើននូវកម្មដ្ឋាន។

ថ្ងៃមួយ ធម្មិកឧបាសក ធ្លាក់ខ្លួនឈឺយ៉ាងខ្លាំង ដេកស្តូក ស្តឹងនៅលើគ្រែ ហើយគេបាននិមន្តភិក្ខុសង្ឃ៨អង្គ ដើម្បីចម្រើន នូវ មហាសតិប្បដ្ឋានបាលី។ ខណៈពេលនោះ ស្រាប់តែមានទេវ រថ៦ហោះមកពីឋានទេវលោក ហើយអញ្ជើញឧបាសកឱ្យឡើង កាន់រថនោះ ដោយពោលថានឹងនាំទៅឋានសួគ៌។

ធម្មិកឧបាសកអាចមើលឃើញ និងឮនូវអ្វីដែលពួកទេវតា ទាំងនោះនិយាយ ដូច្នេះគាត់ក៏លើកដៃរាឱ្យពួកគេឈប់អញ្ជើញ គាត់ទៀត ចាំពេលក្រោយទៅ។ ភិក្ខុសង្ឃទាំងឡាយ កាលបើ





បានឮដូច្នោះ គិតថាឧបាសកមិនចង់ឱ្យស្វាធ្យាយទៀត ឡើយ ហើយក៏និមន្តត្រឡប់ទៅវត្តអស់ទៅ។

បុត្រធីតារបស់ ធម្មិកៈ មានការត្អូញត្អែរយ៉ាងខ្លាំងដោយ រៀបរាប់ថា កាលពីដើមឡើយបិតារបស់យើងទាំងអស់គ្នា មិន ដែលធុញទ្រាន់នឹងការស្តាប់ព្រះធម៌នោះទេ ប៉ុន្តែឥឡូវនេះគាត់ បានបញ្ឈប់ភិក្ខុសង្ឃមិនឱ្យសូត្រធម៌ទៀត តើនរណាមួយ ដែល មិនខ្លាចនូវសេចក្តីស្លាប់នោះ? ហើយពួកគេ ក៏យំខ្សឹកខ្សួលតែ រៀងខ្លួន។

ពេលដែល ធម្មិកៈ បានឮដូចនេះ ក៏បានសួរកូនៗថា ហេតុអ្វីបានជាអ្នកទាំងអស់គ្នាយំ? ហើយចុះភិក្ខុសង្ឃនិមន្ត ទៅណាអស់ហើយ?

ពួកយើងខ្ញុំយំ ព្រោះលោកឪពុកបញ្ឈប់មិនឱ្យភិក្ខុសង្ឃ សូត្រធម៌តទៅទៀត ហេតុនេះហើយ លោកក៏និមន្តទៅវត្តវិញ អស់ទៅ។

ពួកយើងគិតថា លើលោកនេះគ្មាននរណាម្នាក់ដែលមិន ខ្លាចសេចក្តីស្លាប់នោះទេ។

តែបិតាមិនបានបញ្ឈប់ភិក្ខុសង្ឃទាំងនោះឯណា ។ មាន ទេវរថ៦ហោះមកពីឋានសួគ៌ ហើយបានហៅបិតាឱ្យទៅជាមួយ

ពួកគេ ដូចនេះ បិតាក៏បញ្ឈប់ពួកគេកុំឱ្យហៅបិតាទៀតអី។

ឮដូចនេះហើយ កូនប្រុសស្រីទាំងនោះគិតថា បិតារបស់ខ្លួនចេះតែនិយាយឥតចុងឥតដើម ហើយពួកគេក៏ចាប់ផ្ដើមយំម្ដងទៀត។

"ហេតុអីបានជាពួកអ្នកទាំងឡាយនាំគ្នាយំទៀតហើយ?"

"បិតាថា មានទេវរថហោះមកដល់ទីនេះ ចុះឥឡូវនេះពួកគេនៅឯណា? ម៉េចក៏ពួកយើងមិនឃើញ?" "តើពួកអ្នកមានកម្រងផ្កាទេ?""បពិត្រលោកឪពុក កម្រងផ្កាមាន"។

"តើឋានទេវលោកមួយណា ដែលពួកអ្នកពេញចិត្តជាងគេ?" "ព្រះពោធិសត្វតែងគង់នៅរីករាយក្នុងឋានតុសិត"។

"បើដូចនេះ ចូរអ្នកទាំងឡាយតាំងចិត្តអធិដ្ឋាន សូមឱ្យកម្រងផ្កានេះ ពាក់ជាប់ទៅនឹងទេវរថ ដែលមកពីឋានតុសិត ហើយចូរបោះកម្រងផ្កានេះទៅលើ"។

កូនៗទាំងឡាយ ក៏បានធ្វើតាមបញ្ជារបស់បិតា ហើយភ្លាមៗនោះកម្រងផ្កានោះ ក៏ស្រាប់តែស្ថិតនៅលើអាកាស (ទើលើទេវរថចុះពីឋានតុសិត) ពុំធ្លាក់ចុះក្រោមឡើយ។ បុត្រធីតាទាំងឡាយ មានសេចក្ដីរីករាយណាស់ ពេលដែលបានឃើញហេតុដ៏អស្ចារ្យយ៉ាងនេះ។





"បិតានឹងទៅកើតនៅឋាន តុសិត ចូរអ្នកទាំងអស់គ្នាកុំបារម្ភពីបិតាអី ឈប់យំទៅ។ ប្រសិនបើ អ្នកទាំងអស់គ្នាចង់ដូចបិតា ចូរខំប្រឹងធ្វើបុណ្យឱ្យបានច្រើនកុំធ្វេសប្រហែសឡើយ"។ ក្រោយពីផ្ដាំផ្ញើហើយ ធម្មិកឧបាសក ក៏បានស្លាប់បាត់ទៅ ហើយក៏បានទៅកើតក្នុងទេវវិមានដ៏ស្កឹមស្កៃ នាឋាន តុសិត មានទេពអប្សរ១០០០នាក់ជាបរិវារ។

### ៤.តើភពថ្មីកើតឡើងបន្ទាប់ពីសេចក្ដីស្លាប់ដូចម្ដេច?

អ្នកខ្លះនិយាយថា នៅពេលមនុស្សស្លាប់ វិញ្ញាណរបស់គេចាកចេញពីសាកសព ហើយត្រាច់ចរ (វិលវល់) អស់រយៈពេល៧ថ្ងៃ បន្ទាប់មកទើបផ្លាស់ទៅនៅក្នុងរាងកាយថ្មី។ តើការយល់ឃើញបែបនេះត្រូវដែរឬទេ? ចម្លើយ គឺមិនត្រឹមត្រូវទាល់តែសោះ។

តើនៅពេលមនុស្សស្លាប់ និង មុនពេលចាប់កំណើតថ្មី មានកំណើតឯណាមកជ្រៀតជ្រែកដែរឬទេ? ច្បាស់ជាមិនមានទេ! ក្នុងករណីនេះ តើកំណើតថ្មីកើតឡើងដូចម្ដេច? តើបុគ្គលដែលស្លាប់ទៅនោះអាចឆ្លងផុតពីជាតិនេះឆ្ពោះទៅកាន់កំណើតថ្មីបានដោយវិធីណា?

ព្រះអភិធម្ម ពន្យល់យ៉ាងច្បាស់ពីបញ្ហានេះ ដោយមិន

សន្និដ្ឋានទៅលើ ដួងវិញ្ញាណ ព្រលឹង ជីវៈ ឬ អត្តៈ អ្វីឡើយ។

ជាធម្មតាក្រោយការឃើញនូវ មរណាសន្នជវន (និមិត្តពេលជិតស្លាប់) ហើយសេចក្ដីស្លាប់នឹងប្រាកដមានដល់បុគ្គលនោះ។ មរណាសន្នជវនកម្ម ឬកម្មនិមិត្តពីអតីតកើតក្នុងវិថីចិត្ត។ កម្មនិមិត្តបច្ចុប្បន្ន ឬគតិនិមិត្តកើតនៅក្នុងទ្វារណាមួយ ក្នុងចំណោមទ្វារទាំង៦។

ឧទាហរណ៍ថា បុគ្គលម្នាក់ស្លាប់ខណៈពេលដែលកំពុងថ្វាយបង្គំចំពោះព្រះពុទ្ធបដិមា។ ប្រសិនបើ កុសលកម្មដែលកើតពីការថ្វាយបង្គំនេះ ដើរតួជាអ្នកតាក់តែងកំណើតថ្មី (ជនកកម្ម) ដូច្នេះ ព្រះពុទ្ធបដិមាគឺជា កម្មនិមិត្ត បច្ចុប្បន្ន។

ប្រសិនបើ បុគ្គលម្នាក់ស្លាប់ ខណៈពេលកំពុងស្ដាប់ព្រះធម៌ទេសនា ដូចនេះ សំឡេងនៃព្រះធម៌គឺជាកម្មនិមិត្តបច្ចុប្បន្ន។ មូលហេតុ ដែលធម្មិកឧបាសកឃើញនូវទេវរថ គឺជាគតិនិមិត្តដែលកើតឡើងចំពោះរូបគាត់។

(១)ប្រសិនបើ បុគ្គលស្លាប់ក្រោយការឃើញនូវកម្មនិមិត្តបច្ចុប្បន្ន ឬក៏ គតិនិមិត្ត ដែលប្រាកដឡើងតាមចក្ខុទ្វារមរណាសន្នវិថី កើតឡើងដូចខាងក្រោមនេះ ៖

តិ-ន-ទ-ប-ច-សំ-សត-វោ-ជ-ជ-ជ-ជ-ជ-តទ-តទ-ភ-ចុ-





"ប-ដិ-ភ-ភ-"

តិ = អតិតភវង្គ - ភវង្គនេះកើតឡើងនៅពេលដែលរូបារម្មណ៍ប៉ះផ្ទប់នឹងចក្ខុទ្វារ និងមុនពេលដែលអារម្មណ៍កើតឡើងនៅចក្ខុទ្វារ។

ន = ភវង្គចលន - ចលនាភវង្គ

ទ= ភវង្គុបច្ឆេទ- ភវង្គវិថី កាត់ផ្ដាច់បន្ទាប់ពីចិត្តនេះ

ប = បញ្ចទ្វារាវជ្ជន ចិត្តនេះតែងកំណត់ដឹងនូវអារម្មណ៍ ហើយញ៉ាំងវិថីចិត្តឱ្យមានដំណើរឆ្ពោះទៅ។

ច = ចក្ខុវិញ្ញាណ ចិត្តនេះអាចមើលឃើញនូវអារម្មណ៍ ហើយបញ្ជូនអារម្មណ៍នោះ ទៅកាន់អារម្មណ៍ ដែលនឹងកើតបន្ទាប់ទៀត។

សំ = សម្បដិច្ឆន្ន ចិត្តនេះចាប់យកនូវរូបារម្មណ៍

សត = សន្តីរណ ចិត្តនេះពិនិត្យមើលនូវអារម្មណ៍ឱ្យឃើញថាល្អ ឬអាក្រក់

វោ = វោដ្ឋបន ចិត្តនេះជាអ្នកសម្រេចថាតើចិត្តនេះល្អ ឬអាក្រក់

ជ = ជវនចិត្ត ចិត្តនេះពេញចិត្តក្នុងរសនៃអារម្មណ៍

តទ= តទាលម្ពន ចិត្តនេះ បន្តនូវការពេញចិត្តក្នុងរសនៃ

អារម្មណ៍

ភ = ភវង្គ ចិត្តនេះសម្គាល់នូវទីបំផុតនៃមរណាសន្នវិថីចិត្ត

ចុ = ចុតិចិត្ត មនុស្សស្លាប់នៅពេលដែលចុតិចិត្តរលត់

បដិ = បដិសន្ធិចិត្ត កំណើតថ្មីចាប់ផ្តើមមានឡើងនៅពេលចិត្តនេះកើតឡើង

ភ = ភវង្គចិត្ត កើតជាលំដាប់

វិថីចិត្តខាងលើនេះគឺជាដំណើរនៃ មរណាសន្នជវនចិត្តដែលកើតឡើងក្នុងចក្ខុទ្វារ។ ប្រសិនបើ មរណាសន្នជវនចិត្តប្រាកដច្បាស់ វិថីចិត្តកើតឡើងដូចបង្ហាញខាងលើ ដោយមានសោតវិញ្ញាណកើតត្រង់កន្លែងនៃចក្ខុវិញ្ញាណនោះ។

ប្រសិនបើ**គតិនិមិត្ត**ប្រាកដឡើងជាមធ្យម តទាលម្ពនចិត្ត ២ដួង មិនអាចកើតបានទេ។ មនុស្សអាចស្លាប់ បន្ទាប់ពីការរលត់ទៅនៃ តទាលម្ពនចិត្តទី២ ប្រសិនបើមិនមានភវង្គចិត្តកើតឡើងទេ។ បន្ទាប់ពីចុតិចិត្តនៃជីវិតបច្ចុប្បន្ននេះ រលត់ទៅ បដិសន្ធិនៃកំណើតថ្មី ក៏ប្រាកដឡើងក្នុងវិថីចិត្តរបស់បុគ្គលនោះ។

(២) នៅពេលកៀកស្លាប់ កម្មនិមិត្ត ឬអតីតកម្មនិមិត្ត ឬគតិនិមិត្តនឹងកើតមានក្នុងមនោទ្វារ។ ប្រសិនបើ អារម្មណ៍នោះ





មានលក្ខណៈប្រាកដ មរណាសន្នវិថីចិត្តកើតឡើងដូចខាងក្រោមនេះ៖

"ន-ទ-ម-ជ-ជ-ជ-ជ-ជ-តទ-តទ-ភ-ចុ-បដិ-ភ"

ន= ភវង្គចលន- ចលនាភវង្គ

ទ=ភវង្គុបច្ឆេទ ភវង្គវិថីកាត់ផ្តាច់បន្ទាប់ពីចិត្តនេះ

ម=មនោទ្វារាវជ្ជន(mind-door directing consciousness) ចិត្តនេះវិភាគមើលនូវអារម្មណ៍ដែលកើតឡើងដើម្បីឱ្យដឹងថាល្អ ឬអាក្រក់។

ជ= ជវនចិត្ត ចិត្តនេះជាអ្នកសោយ(ពេញចិត្ត)នូវរសនៃអារម្មណ៍

តទ= តទាលម្ពន ចិត្តនេះបន្តនូវការសោយនូវរសនៃអារម្មណ៍

ភ= ភវង្គ ចិត្តនេះជាវត្ថុសម្គាល់នូវទីបំផុតនៃមរណាសន្នវិថីចិត្ត

បដិ= បដិសន្ធិ បន្ទាប់ពីចុតិចិត្តនៃជីវិតបច្ចុប្បន្ននេះរលត់ទៅ បដិសន្ធិនៃកំណើតថ្មីក៏ប្រាកដឡើងក្នុងវិថីចិត្តរបស់បុគ្គលនោះ។

ភវ = ភវង្គចិត្ត កើតជាលំដាប់

ដូចគ្នាដែរ ប្រសិនបើ គតិនិមិត្តប្រាកដឡើងជាមធ្យម តទាលម្ពនចិត្ត ២ដួង មិនអាចកើតបានទេ។ មនុស្សអាចស្លាប់ បន្ទាប់ពីការរលត់ទៅនៃតទាលម្ពនចិត្តទី២ ប្រសិនបើ មិនមាន ភវង្គចិត្តកើតឡើងទេ។ បន្ទាប់ពី ចុតិចិត្ត នៃជីវិតបច្ចុប្បន្ននេះ រលត់ទៅ បដិសន្ធិនៃកំណើតថ្មី ក៏ប្រាកដឡើងក្នុងវិថីចិត្តរបស់ បុគ្គលនោះ។ បន្ទាប់មក ភវង្គកើតជាបន្តបន្ទាប់ ដើម្បីញ៉ាំង កំណើតថ្មីឱ្យប្រព្រឹត្តទៅបាន។

**៥.តើបុគ្គលក្នុងភពថ្មី ដូចគ្នានឹងបុគ្គលក្នុងភពបច្ចុប្បន្នដែរឬទេ?**

ក្នុងព្រះពុទ្ធសាសនា នៅពេលដែលមនុស្សចាប់កំណើតថ្មី ចិត្ត និងកាយនៃកំណើតបច្ចុប្បន្នមិនត្រូវបានបញ្ជូនទៅកំណើតថ្មី នោះទេ។ នៅពេលយើងស្លាប់ ចិត្ត និងកាយនៃកំណើតបច្ចុប្បន្ន នេះក៏រលត់ទៅ។ ហើយចិត្ត និងកាយនៃកំណើតថ្មីក៏កើតឡើង ដោយអំណាចនៃជនកកម្ម។ ក្នុងករណីនេះ តើបុគ្គលបច្ចុប្បន្ននេះ និងបុគ្គលក្នុងកំណើតថ្មីជាមនុស្សផ្សេងគ្នា ឬមនុស្សតែមួយ។ បើ តាមគម្ពីរវិសុទ្ធិមគ្គ សម្តែងថាមិនដូចគ្នា ឬផ្សេងគ្នាក៏មិនមែនដែរ។

នៅក្នុងបរមត្ថសច្ចគម្ពីរព្រះអភិធម្ម បុគ្គលមិនមាន មនុស្ស សត្វ ទេវតា ប្រេត នរក តិរច្ឆានមិនមានឡើយ។ អ្វីដែលមាននោះ គឺគ្រាន់តែជាខ្សែច្រវ៉ាក់នៃអង្គធាតុរបស់ចិត្ត និងរូប ដែលបន្តកើត





ប៉ុណ្ណោះ។ ហើយអង្គធាតុទាំងអស់ រមែងរលត់ទៅវិញភ្លាមៗ ក្រោយពេលដែលបានកើតឡើងហើយ។ បន្ទាប់មក ជនកកម្ម បន្តបង្កើតនូវអង្គធាតុចិត្ត និងរូបថ្មីជាលំដាប់មកទៀត។ គ្មានអង្គ ធាតុនៃចិត្ត និងរូបណាមួយ ដែលស្ថិតស្ថេរនោះទេ តែងកើតឡើង ហើយរមែងរលត់ទៅវិញភ្លាមៗមួយរំពេចនោះ។ ដូច្នេះ យើងអាច យល់បានថា តាម បរមត្ថសច្ចៈ គ្មានសត្វ,បុគ្គល,តួ,ខ្លួន,ឡើយ។

ប៉ុន្តែតាម សមុទយសច្ចៈ យើងសន្មតថាជាបុគ្គល បើទោះ ជាដឹងថា នាម និង រូប នេះ តែងប្រែប្រួលយ៉ាងណាក៏ដោយ។ មានអំណះអំណាងមួយ យើងអាចយកមកដើម្បីបញ្ជាក់បាន គឺ នាម និង រូប នៃកំណើតយ៉ាងច្រើនផ្សេងគ្នា នៃព្រះពោធិសត្វ តាំងពីកំណើតជា សុមេធបណ្ឌិត នៅពេលដែលគាត់ទទួលបាន ការព្យាករណ៍ពីសំណាក់ព្រះពុទ្ធ ទីបង្ករ រហូតដល់កំណើតជាក្សត្រ សិទ្ធត្ថ ដែលក្រោយមកបានត្រាស់ជាព្រះសម្មាសម្ពុទ្ធសមណ-គោតម ។ អស់រយៈពេលជាង ៤ អសង្ខេយ្យ កម្រៃ១សែនកប្ប កំណើតរាប់ពាន់លានដែលបានកើត និងរលត់នៅក្នុងដំណើរជា ព្រះពោធិសត្វ ដែលខំព្យាយាមបំពេញបារមី ។ បើបំពេញបារមី ត្រឹមតែមួយជាតិនោះ មិនអាចបានត្រាស់ដឹងជាព្រះពុទ្ធឡើយ។ ៤ អសង្ខេយ្យ កម្រៃ១សែនកប្ប តំណាងគឺជារយៈពេលដ៏ខ្លីបំផុត

សម្រាប់ការបំពេញបារមីធម៌ ដើម្បីបានត្រាស់ដឹងជាព្រះសម្មាសម្ពុទ្ធ។ អស់រយៈពេលដ៏វែងរាប់លានជាតិនៃចិត្ត និងកាយបន្តពីជាតិមួយទៅជាតិមួយ ដែលខ្លួនបានសន្សំនូវកុសលកម្ម រហូតក្លាយជាកម្លាំងដ៏ខ្លាំងជួយទ្រទ្រង់ជំរុញឱ្យត្រាស់ដឹងជាព្រះពុទ្ធ។

**៦. ភស្តុតាងដែលអាចបញ្ជាក់ពីវិថីចិត្តតែមួយ**

ព្រះសម្មាសម្ពុទ្ធទ្រង់សម្តែងព្រះធម៌តាមសភាវៈពិតដោយព្រះបញ្ញាញាណ ចេញពីបទពិសោធន៍ជាក់ស្តែងដែលទ្រង់ធ្លាប់បានយាងឆ្លងកាត់ហើយ។ នៅថ្ងៃពេញបូណ៌មី ខែវិសាខ ឆ្នាំ ៥៨៨ មុនគ.ស រាត្រីនោះព្រះអង្គទៀបនឹងបានត្រាស់ដឹងជាព្រះសម្មាសម្ពុទ្ធ ព្រះពោធិសត្វ ទ្រង់គង់នៅលើអបរាជិតបល្ល័ង្កក្រោមម្លប់ពោធិព្រឹក្ស ទ្រង់ចម្រើននូវ អនាបានស្សតិកម្មដ្ឋាន ហើយទ្រង់បានសម្រេចនូវរូបាវចរចតុត្ថជ្ឈាន។

ព្រះអង្គទ្រង់ចំរើននូវបញ្ញានៅក្នុងវិធី៥ យ៉ាងបានសម្រេចនូវឈាន៨ និងបច្ច័យទាំងឡាយ ដើម្បីបាននូវអភិនីហារផ្សេងៗ។ ចិត្តរបស់ព្រះអង្គស្អាតបរិសុទ្ធ មានកិលេសទៅប្រាសចាកហើយ អាចទូន្មានបាន វាងវៃ នឹងន់ និងមិនញាប់ញ័រឡើយ។ ពោលគឺចិត្តរបស់ព្រះអង្គស្ថិតនៅក្នុងសភាពមួយ ដែល





អភិនីហារអាចនឹងកើតឡើងយ៉ាងងាយស្រួល នៅពេលដែលចិត្តរបស់ព្រះអង្គបង្អោនចុះក្នុងអារម្មណ៍នៃអភិនីហារ។

ព្រះអង្គទ្រង់យាងចេញចាកចតុត្ថជ្ឈានហើយ ទ្រង់ក៏បង្អោនចិត្តទៅរកអតីតកាល ខណៈនោះទ្រង់បានសម្រេចនូវបុព្វេនិវាសានុស្សតិអភិញ្ញា យ៉ាងងាយជាទីបំផុត។ បានសម្រេចនូវ អភិញ្ញានេះ ព្រះអង្គទ្រង់ពិចារណា និងឃើញនូវទង្វើគ្រប់យ៉ាង ព្រឹត្តិការណ៍ និងបទពិសោធន៍ ក្នុងអតីតកាលទាំងអស់តាំងពីជាតិកំណើតយូរលង់ណាស់មកហើយ រហូតដល់ជាតិដែលទ្រង់ជាសុមេធតាបស។ ព្រះអង្គទ្រង់ពិចារណាជាលំដាប់ដល់ជាតិមុនៗជាច្រើនជាតិ និងច្រើនកប្បរហូតដល់ជាតិដែលទ្រង់កើតជា សេតកេតុទេវតា មួយជាតិមុនជាតិបច្ចុប្បន្ននេះ។

ព្រះបរមពោធិសត្វ ទ្រង់ពិចារណានូវកំណើត ក្នុងអតីតកាលជាលំដាប់ដោយអំណាចនៃបុព្វេនិវាសានុស្សតិញាណ ព្រះអង្គក៏ទ្រង់ឃើញនូវសភាវធម៌ ដោយព្រះបញ្ញាញាណថា៖

*"មានតែការកើតឡើងនៃ នាម និង រូប ប៉ុណ្ណោះនៅក្នុងវាលវដ្តសង្សារនេះ ដែលគ្មានបុគ្គលណា អាចដឹងបានពីការចាប់ផ្តើម ក្នុងខណៈទាំង៣ កើត រស់នៅ និងស្លាប់ គឺមានត្រឹមតែការកើតឡើងនៃនាម និងរូប ប៉ុណ្ណោះ។ ពិត*

*ណាស់ នៅក្នុងស្ថានទាំងអស់ និងពេលវេលាទាំងអស់គឺមានតែការកើតឡើងនៃនាម និង រូប ដែលស្ថិតនៅក្នុងសភាពប្រួលប្រែគ្រប់ពេលវេលា ប្រៀបបីដូចជាអណ្តាតភ្លើងចង្កៀងប្រេង ឬក៏ដូចជាខ្សែទឹក និងការកើតឡើងជាប់មិនដាច់ដោយអំណាចនៃហេតុ និងផល។ ការកើតឡើងបន្តគ្នានៃ នាម និង រូប ដែលប្រព្រឹត្តទៅដោយការឃើញរូប ឮសំឡេងជាដើម តាមទ្វារទាំង៦ ភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ និងចិត្ត ទាំងអស់នេះបណ្តាលឱ្យមានវិញ្ញត្តិ កើតឡើងតាមរយៈចលនានៃកាយ និងការបញ្ចេញសំឡេង។ល។*

*"តាមបរមត្ថសច្ចៈ មិនមានបុគ្គលណាមួយ សម្រាប់ឱ្យយើងហៅថា "ខ្ញុំ" "គាត់" "បុរស" "ស្ត្រី" ។ល។ អ្វីឡើយ មិនមាន ទេវតា មារ ឬ ព្រហ្ម ឯណានីមួយអាចបង្កើតសត្វលោកបានឡើយ ។"*

ការរៀបរាប់ខាងលើនេះ គឺត្រូវបាននិពន្ធឡើងដោយព្រះគ្រូ វិចិត្តសារភិវង្ស តិបិដកធរ ធម្មភន្ទាគារិក អគ្គមហាបណ្ឌិត នៅក្នុងគម្ពីរ មហាកាលប្បវត្តរបស់ព្រះសម្ពុទ្ធ (The Great Chronicle of Buddhas)។ តាមការនិពន្ធរបស់ព្រះគ្រូខាងលើ





យើងអាចយល់បានយ៉ាងច្បាស់ អំពីជាតិកំណើត ដែលកើតរលត់ៗជាលំដាប់ពីជាតិមួយទៅជាតិមួយទៀត។ រាប់ពីកំណើតជាសុមេធតាបស រហូតដល់កំណើតជាសិទ្ធត្ថ មានកំណើតរាប់រយកោដិកើតនិងរលត់។ ប៉ុន្តែ នាម និងរូប ពីជាតិមួយទៅជាតិមួយ កើតជាបន្តបន្ទាប់មិនរលត់ឡើយ ប្រៀបដូចជាខ្សែច្រវ៉ាក់ដែលតជាប់ៗគ្នាដូច្នោះដែរ។ ហើយអ្វីដែលបន្តដូចជាខ្សែច្រវ៉ាក់នោះ គឺជាការកើតឡើង និងរលត់ទៅវិញនៃនាម និងរូបប៉ុណ្ណោះ មិនមែនសត្វ មិនមែនបុគ្គលឡើយ ហើយវិញ្ញាណ ឬព្រលឹងអមតៈ ឬជីវៈ នោះក៏មិនមែនដែរ។ ដោយភាពអមតៈនៃជីវៈ មិនមាន អាទិទេព ដែលគេតែងពោលថា ជាអ្នកបង្កើតមនុស្សសត្វទាំងអស់នោះ ក៏ពិតជាមិនមានដែរ។

ដោយសារតែព្រះសម្មាសម្ពុទ្ធទ្រង់ជ្រាបច្បាស់ថា "អត្ត" មិនមានហេតុនេះហើយ ទើបព្រះអង្គទ្រង់ប្រកាស "ទ្រឹស្តី អនត្តា" ។ ប្រសិនបើយើងយល់ច្បាស់ពី "ទ្រឹស្តី អនត្តា" នោះ យើងនឹងងាយស្រួលយល់ពីសភាវពិតនៃនាម និងរូបរបស់យើង ដោយវិបស្សនាញាណផងដែរ ហើយយើងនឹងអាចរួចចាកអំពីសេចក្តីទុក្ខទាំងពួងបាន។

## ការកើតឡើងនូវទិព្វចក្ខុ និងអភិញ្ញាដទៃទៀត

នៅក្នុងមជ្ឈិមយាម ព្រះពោធិសត្វទ្រង់បង្អោនចិត្តទៅក្នុងទិព្វចក្ខុ ឬហៅថា ចុតូបបាតញាណ។ ខណៈពេលនោះ ទិព្វចក្ខុ ក៏បានសម្រេចដល់ព្រះពោធិសត្វយ៉ាងងាយ។ ព្រះអង្គអាចមើលឃើញនូវសព្វសត្វទាំងអស់ដែលហៀបនឹងស្លាប់ និងសព្វសត្វដែលទើបតែចាប់បដិសន្ធិ ហើយព្រះអង្គអាចមើលឃើញនូវសព្វសត្វទាំងអស់ក្នុងភូមិទាំង ៣១។

ក្រោយពីទ្រង់បានឃើញសត្វនរកទាំងឡាយ កំពុងតែរងទុក្ខវេទនាដោយទិព្វចក្ខុហើយ ទ្រង់ពិចារណាអំពីមូលហេតុនៃសេចក្តីទុក្ខទាំងឡាយ ដែលសត្វនរកទាំងនោះកំពុងតែទទួលរងទុក្ខ។ ពេលនោះ យថាកម្មុបគ្គអភិញ្ញា (ឬទ្ធិដែលអាចដឹងនូវកម្មរបស់សត្វទាំងឡាយ) ក៏សម្រេចដល់ព្រះអង្គ ហើយទ្រង់ក៏អាចមើលជ្រាបយ៉ាងជាក់ច្បាស់នូវបាបកម្មទាំងឡាយដែលសត្វនរកទាំងឡាយនោះ បានសាងកាលពីខ្លួននៅរស់។ ដូចគ្នានេះដែរ ព្រះអង្គទ្រង់ជ្រាបនូវកុសលកម្មទាំងឡាយ ដែលមនុស្សទេវតា និងព្រហ្មទាំងឡាយបានសាងហើយដោយល្អ។ ម្យ៉ាងវិញទៀត ព្រះអង្គទ្រង់បានយល់យ៉ាងជាក់ច្បាស់ថា កម្មដែល





បុគ្គលណាបានធ្វើហើយ នឹងតាក់តែងបុគ្គលនោះដោយបការៈយ៉ាងនោះដែរ។

## ការពិចារណាក្នុងបដិច្ចសមុប្បាទធម៌

នៅក្នុងបច្ឆឹមយាមនៃរាត្រីនោះ ព្រះពោធិសត្វ ទ្រង់ពិចារណាអំពី បដិច្ចសមុប្បាទធម៌។ នៅពេលដែលទ្រង់ពិចារណាមើលនូវសព្វសត្វទាំងអស់ក្នុងមួយសែនចក្រវាឡទាំងមូលដោយជុំវិញ ដែលស្ថិតនៅក្នុងវេលាទាំង៣គឺ អតីត បច្ចុប្បន្ន និងអនាគត ព្រះអង្គទ្រង់ឈ្វេងយល់យ៉ាងច្បាស់ថា បើទោះជាសព្វសត្វទាំងអស់មានភាពផ្សេងៗគ្នា ជាមនុស្ស ទេវតា ព្រហ្ម នរក ប្រេត ហើយស្ថិតនៅក្នុងភពផ្សេងគ្នាយ៉ាងណាក៏ដោយ តាមបរមត្ថ សព្វសត្វទាំងអស់ ត្រូវបានរាប់បញ្ចូលក្នុងបដិច្ចសមុប្បាទធម៌ទាំង១២កងដូចគ្នាគឺ អវិជ្ជា សង្ខារ (កម្មអតីតជាមូល) វិញ្ញាណ នាមរូប សឡាយតន ផស្ស វេទនា តណ្ហា ឧបាទាន ភវ (កម្មបច្ចុប្បន្នជាមូល) ជាតិ ជរា និងមរណ (ផលអនាគត)។

ជានិយាមសំរាប់ព្រះពោធិសត្វគ្រប់ព្រះអង្គ នៅថ្ងៃដែលត្រាស់ដឹងជាព្រះសម្មាសម្ពុទ្ធ ទ្រង់តែងពិចារណានូវ បដិច្ចសមុប្បាទធម៌ពីដើមដល់ចុង និងពីចុងដល់ដើមតាមលំដាប់។ បន្ទាប់មកទ្រង់ចម្រើននូវវិបស្សនាកម្មដ្ឋាន ហើយទ្រង់បានឈ្វេងយល់

យ៉ាងជាក់ច្បាស់នូវបដិច្ចសមុប្បាទធម៌ទាំង១២កងមាន វិបស្សនាជាអារម្មណ៍។ តាមពុទ្ធវិស័យ មានចក្រវាឡទាំងអស់ ចំនួនមួយសែន ដូច្នេះ នៅក្នុងបដិច្ចសមុប្បាទទាំង១២កង ក៏មានចក្រវាឡចំនួនមួយសែនដែរ។ សរុបមក អារម្មណ៍ទាំងអស់មានចំនួនមួយលានពីរសែន។

អង្គនីមួយៗនៃ បដិច្ចសមុប្បាទ មានចំនួនមួយលានពីរសែន នោះចាត់ចូលទៅក្នុង វិបស្សនាញាណទាំងបីគឺ អនិច្ចំ ទុក្ខំ អនត្តា ដូច្នេះបើសរុបមក មហាវជីរវិបស្សនាញាណ មានចំនួន បីលានប្រាំមួយសែន។

ការកាន់យកនូវ មហាវជីរវិបស្សនាញាណ អាចធ្វើព្រះពោធិសត្វ ងាយក្នុងការចម្រើននូវ វិបស្សនាញាណទាំង១០ មគ្គ៤ និងផល៤ ។ មគ្គ៤ កំចាត់បង់នូវកិលេសទាំងឡាយ ព្រមទាំងអនុសយកិលេសផងដែរ។ ដូច្នេះ ខណៈពេលដែល អរហត្តផលកើតឡើង សព្វញ្ញុតញ្ញាណក៏កើតឡើងក្នុងពេលជាមួយគ្នានោះ ហើយបានត្រាស់ជាព្រះពុទ្ធក្នុងពេលនោះឯង។

គ្រប់ព្រះពោធិសត្វទាំងអស់ មុននឹងបានត្រាស់ដឹង សុទ្ធតែទ្រង់បានចម្រើននូវ បដិច្ចសមុប្បាទធម៌ ពីដើមរហូតដល់ទីបំផុត ហើយច្រាស់ត្រឡប់មកវិញ ទ្រង់បានចម្រើននូវ វិបស្សនា





កម្មដ្ឋាន ពិចារណានូវ បដិច្ចសមុប្បាទទាំង១២កងមាន សាមញ្ញលក្ខណធម៌ទាំង៣ អនិច្ចំ ទុក្ខំ អនត្តា ជាអារម្មណ៍ ហេតុនេះសាវ័កទាំងឡាយក៏គួរគប្បីចម្រើននូវ បដិច្ចសមុប្បាទធម៌ និងវិបស្សនាកម្មដ្ឋានតាមគន្លងនៃព្រះពោធិសត្វគ្រប់ព្រះអង្គដែរ។

ក្នុងគម្ពីរវិសុទ្ធិមគ្គ(2.22)និងអដ្ឋកថាព្រះអភិធម្ម(2.189) បានសម្តែងថា

" គ្មានបុគ្គលណាម្នាក់ សូម្បីតែក្នុងសុបិន អាចរួចចាកអំពីសេចក្តីទុក្ខបានឡើយ ប្រសិនបើគេពុំអាចកាច់បំបាក់នូវម៉ាស៊ីននៃសង្សារវដ្តពោលគឺ បដិច្ចសមុប្បាទធម៌ ដោយប្រើអាវុធគឺបញ្ញា ហើយសម្រួចដោយថ្មសំលៀងគឺសមាធិនោះទេ" ។

ហេតុនេះ យោគាវចរទាំងឡាយ គប្បីចម្រើននូវបញ្ញាឱ្យចាក់ធ្លុះក្នុង បដិច្ចសមុប្បាទធម៌ ដូចសម្តែងទុកក្នុងព្រះអភិធម្មៈ

(១) នៅក្នុងអតីតជាតិ អាស្រ័យដោយអវិជ្ជា សង្ខារកើតមាន(សង្ខារកើតមានព្រោះអវិជ្ជា)

(២)អាស្រ័យដោយមានសង្ខារ វិញ្ញាណកើតមានក្នុងបច្ចុប្បន្ននេះ

(៣) អាស្រ័យដោយវិបាកចិត្ត នាមរូបកើតមាន

(៤) អាស្រ័យដោយនាមរូប សឡាយតនកើតមាន
(៥) អាស្រ័យដោយសឡាយតន ផស្សកើតមាន
(៦) អាស្រ័យដោយផស្ស វេទនាកើតមាន
(៧) អាស្រ័យដោយវេទនា តណ្ហាកើតមាន
(៨) អាស្រ័យដោយតណ្ហា ឧបាទានកើតមាន
(៩) អាស្រ័យដោយឧបាទាន កម្មភវ និងឧបបត្តិភវ កើតមាន
(១០)អាស្រ័យដោយកម្មភវ(បច្ចុប្បន្ន) ជាតិកើតមាន (ក្នុងអនាគត)
(១១) អាស្រ័យដោយជាតិ ជរា មរណៈ សោក បរិទេវ ទុក្ខ ទោមនស្ស និង ឧបាយាស កើតមាន។

វិធីសាស្ត្រចម្រើននូវបដិច្ចសមុប្បាទធម៌នេះ មានបង្រៀនយ៉ាងពិស្តារនៅ មជ្ឈមណ្ឌលពុទ្ធសាសនាអន្តរជាតិ **ផាអោក** ប្រទេសមីយ៉ានម៉ា (ភូមា) ។ យោគាវចរ ដែលធ្លាប់ចម្រើននូវបដិច្ចសមុប្បាទធម៌នេះ ពីជាតិមួយទៅជាតិមួយ អាចមើលឃើញយ៉ាងច្បាស់នូវការកើតឡើង និង រលត់ទៅវិញនៃនាមរូបនៅក្នុងខ្សែច្រវ៉ាក់ដ៏វែងមួយ ប្រៀបដូចជា ការមើលនូវឈុតឆាកទាំងស្រុងនៃខ្សែភាពយន្តយ៉ាងនោះដែរ។





ព្រះធម៌របស់ព្រះសម្មាសម្ពុទ្ធ ប្រកបដោយគុណសម្បត្តិពិសេស ៦ យ៉ាង បូករួមទាំងសន្ទិដ្ឋិក គឺថាដឹងពិត ឃើញពិតដោយបច្ចវេក្ខណញាណ និងការប្រតិបត្តិដោយខ្លួនឯងផ្ទាល់។ បើអ្នកមានប្រាថ្នាដើម្បីសិក្សា និងប្រតិបត្តិសមាធិ សូមអញ្ជើញមកមណ្ឌលសមាធិអន្តរជាតិផាអោក យើងខ្ញុំរង់ចាំស្វាគមន៍គ្រប់ពេលវេលា។

នៅពេលដែលបុគ្គលពិចារណានូវ បដិច្ចសមុប្បាទធម៌ដោយបច្ចវេក្ខណញាណហើយ គេអាចពិចារណាក្នុងពេលជាមួយគ្នានោះ នូវវិថីចិត្ត ដែលបន្តពីជាតិមួយទៅជាតិមួយទៀតក្នុងខ្សែច្រវ៉ាក់ដ៏វែងមួយ ហើយកម្មឱ្យផលជាបន្តបន្ទាប់ ដើម្បីទ្រទ្រង់នូវជីវិតថ្មីមួយទៀត។

**ភ័ស្តុតាងអំពីការចម្លងរបស់ចិត្ត និងចេតសិកនៅក្នុងវិថីចិត្ត**

ភ័ស្តុតាងមួយបញ្ជាក់ពីការកើតឡើងនៃវិថីចិត្តនៅក្នុងខ្សែជីវិតដ៏វែងមួយគឺថា ចិត្ត និងចេតសិក ត្រូវបានបញ្ជូនពីចិត្តមួយទៅចិត្តមួយទៀតនៅក្នុងវិថីចិត្ត។ សួរថា ហេតុអ្វីបានជាយើងនៅចងចាំនូវអ្វីដែលយើងបានរៀនកាលនៅពីកុមារ ?នោះគឺមកពីចំណេះដឹងដែលយើងបានរៀននោះ ត្រូវបានចម្លង ឬបញ្ជូនពីចិត្តមួយទៅចិត្តមួយទៀត ហើយបានស្តុកទុកក្នុងវិថីចិត្ត។ វា

មិនខុសអីនឹងការចម្លងសំឡេង ឬ វីដេអូ ពី ស៊ីឌីមួយទៅស៊ីឌីមួយទៀតឡើយ។

ញាណ សញ្ញា វេទនា កម្ម ។ល។ ត្រូវបានចម្លងពីចិត្តមួយទៅចិត្តមួយទៀត ហើយស្តុកទុកនៅក្នុងវិថីចិត្ត។ វិថីចិត្តមិនស្លាប់ឡើយ បើទោះជារូបរាងកាយយើងស្លាប់ក៏ដោយ ដូច្នេះវិថីចិត្តនេះ បន្តដំណើរទៅជាតិមួយទៀត ដោយពាំនាំទៅជាមួយនូវ ញាណ សញ្ញា វេទនា និងកម្មទាំងឡាយនោះៗ ដែលយើងបានសាងទុកក្នុងវិថីចិត្តជាច្រើនជាតិមកហើយ។

ហេតុនេះហើយ មានមនុស្សជាច្រើននាក់ទូទាំងសកលលោកដែលអាចចាំជាតិពីអតីតរបស់ពួកគេ ។ សម្រាប់អ្នកដែលមិនចាំ អាចអោយគេសណ្តំ (Hypnotize) ហើយឱ្យគេសាកសួររឿងរ៉ាវដែលទាក់ទងនឹងអតីត គេប្រាកដជាឆ្លើយបានយ៉ាងត្រឹមត្រូវ។ យើងបានអានហើយអំពីស្ត្រីជនជាតិអាមេរិកម្នាក់ឈ្មោះថៃ (Mrs. Tighe) ដែលនាងចងចាំជាតិរបស់នាង ហើយបានប្រាប់ថា ពីជាតិមុននាងឈ្មោះ Bridy Murphy រស់នៅក្នុងប្រទេស Ireland (អាយលែនដ៍) កាលពី១៥០ឆ្នាំមុន។

ម្យ៉ាងទៀត ក៏យើងធ្លាប់បានដឹងមកហើយដែរ អំពីភាពអស្ចារ្យនៃកូនក្មេង ដែលមានទេពកោសល្យពិសេស តាំងពី





កំណើតទូទាំងសកលលោក។ គ្រិសស្ទៀន ហេនិកេន (Christian Heineken) ជាក្មេងប្រុសជនជាតិអង់គ្លេសម្នាក់ ដែលអាចនិយាយបាន បន្ទាប់ពីកើតមកបានរយៈពេលពីរបីម៉ោងប៉ុណ្ណោះ ហើយអាចសូត្រព្រះគម្ពីររបស់សាសនាគ្រិស្ត បានយ៉ាងស្ទាត់នៅអាយុត្រឹមតែ១ឆ្នាំ ជាពិសេសទៀតនោះ កុមារនេះ អាចឆ្លើយសំណួរទាក់ទងទៅនឹងភូមិសាស្ត្របានយ៉ាងត្រឹមត្រូវ នៅអាយុត្រឹមតែ ២ ឆ្នាំប៉ុណ្ណោះ។

បិដក ម៉ោង តុន ក្យិន (Pitaka Maung Tun Kyine) នៅប្រទេសភូមា(មីយ៉ាន់ម៉ា) អាចសូត្រព្រះត្រៃបិដកបាលីបានដោយមិនបានរៀននៅអាយុត្រឹមតែ៦ឆ្នាំប៉ុណ្ណោះ។ រឿងរ៉ាវទាំងនេះ បង្ហាញឱ្យឃើញថា ចំណេះដឹងដែលយើងបានរៀនពីជាតិមុន ត្រូវបានចម្លងមកក្នុងវិថីចិត្តនៃជាតិបច្ចុប្បន្ននេះ។

ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ទ្រង់ឈ្វេងយល់ពីអតីតជាតិរបស់មនុស្សសត្វទាំងអស់បាន ដោយគ្រាន់តែប្រមើលមើលនូវវិថីចិត្តរបស់សព្វសត្វទាំងនោះព្រោះថា កម្មទាំងឡាយដែលសត្វបានប្រព្រឹត្ត ហើយត្រូវបានស្តុកទុកក្នុងវិថីចិត្តទាំងអស់។ មិនត្រឹមតែព្រះពុទ្ធបរមគ្រូប៉ុណ្ណោះទេ សូម្បីតែអ្នកវិទ្យាសាស្ត្រ ជនជាតិអាមេរិកម្នាក់ឈ្មោះ អេដហ្គ័រ ខាយី(Edgar Cayce)ក៏បាន

ប្រើវិធីសណ្តំ(Hypnosis)ទៅលើមនុស្សជាច្រើនរូប ហើយទទួលបានលទ្ធផលវិជ្ជមានគឺថា ពួកគេបានជ្រាបនូវបទពិសោធន៍ទាំងឡាយ ដែលបានធ្វើកាលពីជាតិមុន ហើយបានចម្លងមកដល់បច្ចុប្បន្នជាតិនេះទៀត។ រឿងរ៉ាវពិស្តារទាក់ទងនឹងករណីនេះ មានរៀបរាប់ក្នុងជំពូក៣នៃសៀវភៅនេះ។

ភ័ស្តុតាងទាក់ទងនឹងរឿងអតីតកាល មាននៅក្នុងជំពូកទី៣ ចំណែកឯភ័ស្តុតាងទាក់ទងនឹងរឿងក្នុងអនាគតកាល មាននៅក្នុងជំពូកទី៤ ដែលភ័ស្តុតាងទាំងអស់នេះសុទ្ធតែបានបង្ហាញយ៉ាងច្បាស់អំពីកម្មផល និងដំណើរប្រព្រឹត្តទៅនៃជីវិតសព្វសត្វក្នុងសំសារវដ្ត។

## ឯកសារយោង


1. Dr. Mehm Tin Mon. "Abhidhamma" (Higher Level) Vol I, pp. 175-194.
2. Dr. Mehm Tin Mon. "Abhidhamma" (Higher Level) Vol II, pp. 43-46, 90-122.
3. Bhikkhu Bodhi. General Editor, "A Comprehensive Manual of Abhidhamma", pp. 219-233. 274-278.
4. Bhaddanta Vicittasarabhivamsa (The Creat Chononicle of Buddhas", Vol. II pp. 244 – 265.
5. Pa-auk Tawya Sayadaw and Dr. Mehm Tin Mon, "Breakthrough in Samatha Meditation and Vipassana Meditation", pp. 64-74
6 Narada Maha Thera, "The Buddha and His teachings", pp. 250-272.




# ១១

# សិទ្ធិដើម្បីបង្កើតកម្មផល និង វាសនារបស់ខ្លួនឯងដោយសេរី

### ១.សេរីភាព និងច្បាប់កម្ម

ដោយអានិសង្សនៃការយកព្រះរតនត្រ័យ ជាទីពឹងទីរលឹកព្រះសរណគមនត្តេរ គង់នៅជាសុខជាច្រើនលានជាតិដោយមិនភ្លាត់ធ្លាក់ទៅអបាយភូមិឡើយ។ ជាតិចុងក្រោយ ក្នុងភទ្ទកប្បនៃព្រះសមណគោតមនៃយើង លោកបានត្រាស់ជាព្រះអរហន្តតាំងពីព្រះជន្ម៧ឆ្នាំម្ល៉េះ ដោយគ្រាន់តែសូត្រ " **ពុទ្ធំ សរណំ គច្ឆាមិ, ធម្មំ សរណំ គច្ឆាមិ, សង្ឃំ សរណំ គច្ឆាមិ** " ៗ

ក្នុងជាតិមួយនោះ ព្រះមហាមោគ្គល្លាន កើតជាមាណពម្នាក់ ដោយជឿទៅលើពាក្យមូលបង្កាច់របស់ប្រពន្ធទាំងងងឹតងងុល ក៏បានវាយសំពងមាតាបិតារបស់ខ្លួន ដែលជាមនុស្សខ្វាក់ និងជរាហួតដល់ស្លាប់។ ដោយអំណាចនៃ អកុសលកម្ម

មាណពនេះ បន្ទាប់ពីស្លាប់ទៅបានទៅសោយទុក្ខក្នុងអវិចីនរកអស់រយៈពេលជាច្រើនលានឆ្នាំ។ បន្ទាប់ពីបានរួចពីអវិចីនរកហើយ ក្នុងកំណើតរាប់រយជាតិជាមនុស្ស ត្រូវបានគេវាយសំពងបាក់បែកឆ្អឹងខ្ទិច ជាកំណាត់ៗ ហើយត្រូវស្លាប់យ៉ាងវេទនាជាទីបំផុត។ មកដល់ជាតិចុងក្រោយបំផុត ទោះបីជាបានជាព្រះមហាមោគ្គល្លាន ជាអគ្គសាវ័កឆ្វេងរបស់ព្រះសមណគោតម ឯតទគ្គៈខាងឫទ្ធានុភាពយ៉ាងណាក៏ដោយ ក៏លោកត្រូវបានចោរ ៥០០ នាក់វាយសំពោងដល់បាក់ឆ្អឹងខ្ទិច រហូតដល់ចូលបរិនិព្វាន។

> " អំពើល្អ ដែលបុគ្គលបានធ្វើហើយ នឹងឱ្យផលល្អច្រើនជាងពាន់លាន រីឯអំពើអាក្រក់ដែលបុគ្គលបានធ្វើហើយ នឹងឱ្យផលអាក្រក់ច្រើនជាងពាន់លានដែរ " ។

តាមច្បាប់កម្ម បុគ្គលដែលបានសាងកម្មយ៉ាងណានឹងទទួលយ៉ាងនោះវិញ ពុំមានបុគ្គលណាមួយអាចគេចវេះបានឡើយ ហើយក៏ពុំមានអាទិទេពណាអាចជួយអ្នកបានឡើយ។

ច្បាប់កម្ម គឺជាច្បាប់ធម្មជាតិ ចំណែកឯច្បាប់វិទ្យាសាស្ត្រ ក៏ជាច្បាប់ធម្មជាតិដែរ។ ច្បាប់នេះពុំមានព្រះជាម្ចាស់ ឬអាទិទេពណានីមួយបង្កើតឡើយ។ អ្នកវិទ្យាសាស្ត្រ អាច





ពន្យល់យើងបាន អំពីភពទាំងឡាយ ភពផែនដី ព្រះច័ន្ទ ព្រះអាទិត្យ និងតារាទាំងឡាយ ហើយព្រះអាទិត្យធ្វើដំណើរតាមគន្លងរបស់វា នៅក្នុងលំហរអាកាសដែលគ្មានដែនកំណត់ ទាំងអស់នេះ សុទ្ធតែស្ថិតនៅក្រោមច្បាប់ធម្មជាតិ។

ដោយប្រើប្រាស់នូវច្បាប់ធម្មជាតិ អ្នកវិទ្យាសាស្ត្របានបង្កើតនូវឧបករណ៍ប្រើប្រាស់ និងម៉ាស៊ីនជាច្រើន ដូចជា កាសែតថតចម្លង ទូរទឹកកក ទូរទស្សន៍ និងកុំព្យូទ័រ ជាដើម ។ល។

បណ្តាថាមពលសរីរាង្គទាំងឡាយ ថាមពលបរមាណូមានកម្លាំងខ្លាំងជាងគេបំផុត។ ថាមពលបរមាណូ ត្រូវបានគេបំលែងជាថាមពលអគ្គិសនីដើម្បីយកទៅប្រើប្រាស់ដូចជា សំរាប់បើកទូកកាណូត រទេះភ្លើង និងយន្តហោះជាដើម។ ម្យ៉ាងទៀត គេបំលែងទៅជាគ្រាប់បែក អាតូមិក និងគ្រាប់បែក អ៊ីដ្រូហ្សែនដែលអាចបំផ្លេចបំផ្លាញទីក្រុង និងពិភពលោកបាន។

ដូចគ្នានេះដែរ អំណាចនៃ ចិត្ត និងកម្ម ដែលមានថាមពលខ្លាំងក្លាជាងថាមពលបរមាណូទៀតនោះ ក៏អាចប្រើប្រាស់ ដើម្បីជាប្រយោជន៍ ឬ ជាសេចក្តីវិនាសដល់មនុស្សខ្លួនឯង និងអ្នកដទៃបានដែរ។ ប្រសិនបើគេអប់រំចិត្តឱ្យបានល្អ គេនឹងអាចទទួលបានសេចក្តីសុខចម្រើន ឬអាចសម្រេចបាននូវ

គុណសម្បត្តិខ្ពង់ខ្ពស់ មានការត្រាស់ដឹងជាព្រះពុទ្ធជាដើម។ ចិត្តដែលបានអប់រំល្អហើយ រមែងញ៉ាំងមនុស្ស សត្វ ទេវតា ព្រហ្ម ទាំងឡាយឱ្យរួចចាកសេចក្តីទុក្ខបាន។ ផ្ទុយទៅវិញ ចិត្តដែលមិនបានអប់រំឱ្យបានល្អរមែងនាំបុគ្គលទៅកាន់ អបាយ ភូមិ ឬក៏អាចមានសង្គ្រាមលោកលើកទីបី ដែលនាំឱ្យមានការបំផ្លិចបំផ្លាញដល់មនុស្សជាតិ។

> វាជាពត៌មានដ៏មានតម្លៃបំផុត ដើម្បីឈ្វេងយល់ថា តាមរយៈច្បាប់កម្ម យើងអាចបង្កើតជោគវាសនារបស់យើងដោយសេរីតាមតែយើងចូលចិត្ត និងអាចគ្រប់គ្រងជោគវាសនារបស់យើងបាន។

អ្នកនិពន្ធរឿងល្ខោនដ៏ល្បីមួយរូបឈ្មោះ វីល្លាម ហ្សេក-ស្ពៀរ៍(William Shakespeare) បានសរសេរថា "ខ្ញុំគឺជាមេដឹកនាំ នៃចិត្តរបស់ខ្ញុំ ហើយខ្ញុំក៏ជាអ្នកសម្រេចជោគវាសនារបស់ខ្ញុំដែរ" ។

ឥឡូវយើងអាចនិយាយថា ខ្ញុំគឺជាម្ចាស់លើចិត្ត និងជោគវាសនារបស់ខ្ញុំ។

**២.មិច្ឆាទិដ្ឋិ៣យ៉ាង**

នៅក្នុងអង្គុត្តរមហាវគ្គ តិត្ថាយនសូត្រ ព្រះសម្មាសម្ពុទ្ធទ្រង់សម្តែងអំពី មូលដ្ឋានមិច្ឆាទិដ្ឋិ ៣យ៉ាងៈ





(១). **បុព្វេកតហេតុកទិដ្ឋិ** សេចក្តីយល់ខុសថា សេចក្តីសុខ និងសេចក្តីទុក្ខទាំងឡាយ ដែលសត្វកំពុងតែមានគឺប្រព្រឹត្តទៅតាមកម្មពីអតីតតែម្យ៉ាង។

(២).**ឥស្សរនិមានវាទ** ឬវិសមហេតុកទិដ្ឋិ សេចក្តីយល់ខុសថា សេចក្តីសុខ និងសេចក្តីទុក្ខទាំងឡាយ ដែលសត្វកំពុងតែជួបប្រទះគឺត្រូវបានបង្កើតឡើងដោយ អាទិទេព ដែលជាអ្នកគ្រប់គ្រងចក្រវាឡទាំងមូល វាគឺជាទិដ្ឋិ ដែលប្រាសចាកហេតុផលពិត។

(៣).**អហេតុកទិដ្ឋិ** សេចក្តីយល់ខុសថា សេចក្តីសុខ និងសេចក្តីទុក្ខទាំងឡាយ ដែលសត្វកំពុងតែជួបប្រទះ កើតឡើងដោយគ្មានហេតុ ពោលគឺកើតឡើងដោយចៃដន្យប៉ុណ្ណោះ។

ព្រះពុទ្ធបរមគ្រូបានចូលទៅរកតាបស និងព្រាហ្មណ៍ទាំងឡាយដែលជាអ្នកបង្រៀននូវទិដ្ឋិទាំងនេះ ហើយទ្រង់សួរថា " ម្នាលអ្នកទាំងឡាយ បុគ្គលមួយចំនួន បានប្រព្រឹត្តនូវទង្វើដ៏លាមក មានការសម្លាប់ លួចប្លន់ ប្រព្រឹត្តខុសក្នុងកាម ពោលពាក្យកុហកមួលបង្កាច់ និយាយពាក្យអាក្រក់ រោយរាយឥតប្រយោជន៍ សំលឹងរំពៃទ្រព្យសម្បត្តិអ្នកដទៃ ព្យាបាទ និងប្រកាន់នូវមិច្ឆាទិដ្ឋិ តើបុគ្គលទាំងនោះ ប្រព្រឹត្តនូវអំពើបាបទាំង

នេះ ដោយសារតែកម្មពីអតីត ឬក៏ត្រូវបាន ព្រះអាទិទេព ជាអ្នកដឹកនាំ ឬក៏គេធ្វើដូច្នេះដោយគ្មានហេតុផលអ្វីទេ?” ។

តាបស និងព្រាហ្មណ៍ទាំងឡាយនោះ ពុំអាចផ្តល់ចម្លើយសមរម្យដល់ព្រះអង្គបានឡើយ។ បុគ្គលដែលមានទិដ្ឋិថា សេចក្តីសុខ និងសេចក្តីទុក្ខទាំងឡាយ ដែលសត្វកំពុងតែមានគឺប្រព្រឹត្តទៅដោយកម្មពីអតីតតែម្យ៉ាង មិនមានសេចក្តីប្រាថ្នាដើម្បីបំពេញកុសល និង មិនមានសេចក្តីព្យាយាមក្នុងការបំពេញកុសលឡើយ។ ប្រសិនបើពួកគេមិនយល់ច្បាស់នូវអ្វីល្អ និងអ្វីអាក្រក់ អ្វីដែលគួរធ្វើ និង មិនគួរធ្វើទេ ពួកគេនឹងរស់នៅក្នុងសេចក្តីប្រមាទ ដោយគ្មានកង្វល់ ព្រោះគេយល់ថា ការធ្វើនូវសេចក្តីល្អពុំបានផលឡើយ។ ទិដ្ឋិបែបនេះហៅថា អកិរិយវាទ ។

ដូចគ្នានេះដែរ បុគ្គលដែលមានទិដ្ឋិថា សេចក្តីសុខ និងសេចក្តីទុក្ខទាំងឡាយ ដែលសត្វកំពុងតែជួបប្រទះ គឺព្រះអាទិទេព ជាអ្នកបង្កើត និងកើតឡើងដោយមិនមានហេតុផល បុគ្គលទាំងនេះក៏ជាអ្នកប្រកាន់ក្នុង អកិរិយវាទដែរ ព្រោះគេយល់ថា ការធ្វើនូវសេចក្តីល្អពុំបានផលឡើយ។

**៣.បុគ្គលគប្បីធីពឹងលើខ្លួនឯង**

ប្រសិនបើបុគ្គលម្នាក់ដែលកំពុងមានជីវិតរស់នៅ សេចក្តី





សុខ និងសេចក្តីទុក្ខគ្រប់យ៉ាង ត្រូវបាន ព្រះអាទិទេព បង្កើតឱ្យទៅតាមឆន្ទៈរបស់លោកនោះ ដូច្នេះ បុគ្គលនោះប្រាកដជាគ្មានសិទ្ធិក្នុងការធ្វើនូវការងារផ្សេងៗ ដើម្បីវិបុលភាពអភិវឌ្ឍន៍ខ្លួនឡើយ។ អ្វីដែលគាត់ត្រូវធ្វើ គឺបួងសួងដល់ ព្រះអាទិទេព ពេញមួយថ្ងៃដើម្បីទទួលបាននូវពរជ័យ។

ប៉ុន្តែ តាមសេចក្តីពិត បុគ្គលដែលគ្មានសេចក្តីព្យាយាមបំពេញនូវការងារ ហើយអង្គុយតែបួងសួងចំពោះ អាទិទេព ទាំងយប់ទាំងថ្ងៃនោះ មិនអាចធ្វើឱ្យចម្រើនបានឡើយ។ បុគ្គលត្រូវតែប្រឹងប្រែងបំពេញការងារដោយខ្លួនឯង ទើបប្រយោជន៍កើតមានបាន។ ដូចមានពំនោលមួយ តែងលើកឡើងថា៖

“ព្រះជួយតែនរណា ដែលជួយខ្លួនឯងប៉ុណ្ណោះ” ។

ដូច្នេះព្រះជួយតែបុគ្គលណាដែលប្រឹងប្រែងបំពេញការងារប៉ុណ្ណោះ។ ខ្លឹមសារនៃទស្សនៈខាងលើនេះ គឺថាបុគ្គលត្រូវទីពឹងលើខ្លួនឯង និងពង្រឹងសមត្ថភាពធ្វើការឱ្យរីកចម្រើនឡើង ។

ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ព្រះអង្គទ្រង់ជ្រាបច្បាស់អំពីច្បាប់កម្មផល និង បដិច្ចសមុប្បាទធម៌ ទ្រង់បានប្រកាសទេសនាឱ្យសព្វសត្វទាំងអស់ធ្វើទីពឹងដល់ខ្លួនដោយខ្លួនឯង ព្រោះថាបុគ្គលពុំអាចយកវត្ថុក្រៅខ្លួនឱ្យជាទីពឹងដល់ខ្លួនបានឡើយ ៖

***" អត្តា ហិ អត្តនោ នាថោ កោ ហិ នាថោ បរោ សិយា"***

*បុគ្គល ហ្នឹងឯងជាទីពឹងរបស់ខ្លួន តើបុគ្គលដទៃឯណានឹងទីពឹងដល់ខ្លួនបាន?*

*(ធម្មបទ ១៦០)*

***" អត្តទីបា ភិក្ខវេ វិហរថ អត្ត សរណា អនញ្ញ សរណា "***

*ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរធ្វើខ្លួនឯងជាកោះខ្លួនឯង ហើយរស់នៅលើកោះនោះ ជឿជាក់ ទីពឹងលើខ្លួនឯង និងគោរពចំពោះខ្លួនឯង កុំទីពឹងលើអ្នកដទៃ ។*

***"ធម្មទីបា ភិក្ខវេ វិហរថ ធម្ម សរណា អនញ្ញា សរណា"***

*ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរធ្វើនូវព្រះធម៌ (ធម្មជាតិ) ឱ្យជាកោះ ហើយរស់នៅលើកោះនោះ ធ្វើទីពឹងក្នុងព្រះធម៌ ញ៉ាំងសទ្ធាឱ្យដល់ព្រម ហើយធ្វើនូវសេចក្តីគោរពក្នុងព្រះធម៌នោះ ចូរកុំយកវត្ថុដទៃជាទីពឹងឡើយ។*

ដើម្បីបានត្រាស់ដឹងនូវសព្វញ្ញុតញ្ញាណ ព្រះសម្មាសម្ពុទ្ធផ្ទាល់ព្រះអង្គពុំបានយកបុគ្គលណាមួយ ឬវត្ថុសក្តិសិទ្ធិឯណានីមួយជាទីពឹងឡើយ។ ព្រះអង្គពុំបានទទួលនូវជំនួយពីព្រះអាទិទេព ណានីមួយឡើយ។ ព្រះអង្គទីពឹងលើខ្លួនព្រះអង្គទាំងស្រុងដោយព្យាយាមប្រតិបត្តិនូវធម្មជាតិពិត ហៅថា ព្រះ





ធម៌ បំពេញបារមីអស់រយៈពេល ៤ អសង្ខៃយ្យ កម្រៃ១ សែនកប្ប និងប្រតិបត្តិតាម អរិយអដ្ឋង្គិកមគ្គ ដោយសេចក្តីព្យាយាមដ៏ក្រៃលែង។ ដូច្នេះ ព្រះសម្មាសម្ពុទ្ធបានត្រាស់ដឹងនូវព្រះធម៌ទាំងពួង គឺដោយវីរិយភាពរបស់ព្រះអង្គ ដោយផ្ទាល់។

បន្ទាប់ពីបានត្រាស់ដឹងជាព្រះពុទ្ធ ហើយព្រះអង្គទ្រង់បានបង្រៀននូវសច្ចធម៌ និងចង្អុលបង្ហាញនូវអរិយអដ្ឋង្គិកមគ្គ ឬក៏ត្រៃសិក្ខាគឺ សីល សមាធិ និងបញ្ញា ដើម្បីកំចាត់បង់នូវកិលេស១០ ដែលជាហេតុនៃសេចក្តីទុក្ខទាំងពួង។ បើបុគ្គលប្រតិបត្តិតាមមាគ៌ានេះដោយល្អិតល្អន់ គេនឹងទទួលបាននូវសន្តិភាព និង សុភមង្គល ក្នុងជីវិតយ៉ាងពិតប្រាកដ។

"តថាគត គ្រាន់តែជាអ្នកបង្ហាញផ្លូវប៉ុណ្ណោះ អ្នកទាំងឡាយត្រូវប្រឹងប្រែងដើរដោយខ្លួនឯង ដើម្បីរំដោះអំពីសេចក្តីទុក្ខទាំងពួង ព្រោះនេះជាតួនាទីរបស់អ្នកទាំងឡាយ"។

ដំបូន្មានដ៏បរិសុទ្ធរបស់ព្រះអង្គ គួរត្រូវបានពុទ្ធបរិស័ទគ្រប់រូបចងចាំទុកក្នុងចិត្តជានិច្ច។ ទោះបីព្រះអង្គ ជាបុគ្គលដែលមនុស្ស សត្វ ទេវតា មារ ព្រហ្មទាំងឡាយគោរពក៏ដោយ ទោះបីព្រះអង្គជាកំពូលនៃមនុស្ស និងទេវតាទាំងឡាយ ក្នុងលោកទាំង

អស់ក៏ដោយ ក៏ព្រះអង្គពុំអាចជួយមនុស្សអាក្រក់ ដែលបានធ្វើអំពើបាបឱ្យរួចចាកពីការកើតក្នុងនរក និងសេចក្តីស្លាប់បានឡើយ។ ព្រះអង្គពុំអាចជួយបុគ្គលនោះ ឱ្យទៅកើតក្នុងឋានសួគ៌បានឡើយ លុះណាតែ បុគ្គលនោះវៀរចាកការធ្វើអំពើបាបហើយបំពេញនូវអំពើល្អដោយខ្លួនឯង។ តួយ៉ាងដូចជាព្រះមហាមោគ្គល្លាន ដែលជាកំពូលនៃអ្នកមានឫទ្ធិទាំងឡាយ ក៏មិនអាចគេចផុតអំពីបាបកម្ម ដែលខ្លួនបានសាងឡើយ យ៉ាងណាមិញព្រះសម្មាសម្ពុទ្ធ ក៏ពុំអាចជួយបុគ្គលដែលសាងបាប ឱ្យរួចផុតអំពីបាបកម្មនោះបានដែរ។

*" បុគ្គលណាធ្វើបាបដោយខ្លួនឯង បុគ្គលនោះរមែងសៅហ្មងដោយខ្លួនឯង បុគ្គលណាមិនធ្វើបាបដោយខ្លួនឯង បុគ្គលនោះរមែងបរិសុទ្ធដោយខ្លួនឯង សេចក្តីបរិសុទ្ធ និងមិនបរិសុទ្ធ ស្ថិតនៅលើបុគ្គលរៀងៗខ្លួន បុគ្គលញុំាងបុគ្គលដទៃឱ្យបរិសុទ្ធពុំបានឡើយ " ។*

*(ធម្មបទ ១៦៥)*

*ចិត្ត ដែលបុគ្គលបានធ្វើឱ្យសៅហ្មងដោយខ្លួនឯង ក៏អាចត្រូវធ្វើឱ្យបរិសុទ្ធដោយបុគ្គលនោះខ្លួនឯងដែរ។ គ្រឿងសៅហ្មង ដែលបុគ្គលបានធ្វើហើយ ព្រះពុទ្ធ ឬ ព្រះ*





*អាទិទេព មិនអាចធ្វើឱ្យបុគ្គលនោះបរិសុទ្ធបានឡើយ។ ប្រសិនបើ បុគ្គលប្រាថ្នាដើម្បីបាននូវសេចក្តីសុខចម្រើន បុគ្គលត្រូវតែប្រតិបត្តិតាមអរិយមគ្គ ដែលព្រះបរមគ្រូទ្រង់បង្ហាញហើយ។*

## ៤.មាគ៌ាឆ្ពោះទៅរកជោគជ័យ និងរុងរឿង

កម្ម ដែលនាំឱ្យអ្នកបានមកកើតក្នុងត្រកូលអ្នកមាន អ្នកក្រ ឬក្នុងត្រកូលខ្ពង់ខ្ពស់ ឬទន់ទាប គឺជាមរតកដែលអ្នកបានសាងសន្សំទុកមក។ អ្នកនឹងបានសេចក្តីសុខចម្រើន និងមានអាយុវែង ប្រសិនបើអ្នកមានសេចក្តីព្យាយាម និងយល់ច្បាស់ពីរឿងជីវិតដែលអ្នកកំពុងតែរស់នៅ។

ដូចគ្នានេះដែរ អ្នកវិទ្យាសាស្ត្របញ្ជូនផ្កាយរណបចូលទៅក្នុងតារាវិថី (គន្លងគោចរនៃតារា) ដោយប្រើប្រាស់កាំជ្រួចរ៉ូកែត ហើយគេអាចផ្លាស់ប្តូរដំណើរគោចរនៃផ្កាយរណបបាន ដោយបាញ់បង្ហោះកាំជ្រួចរ៉ូកែតតូចមួយចូលទៅក្នុងផ្កាយរណបនោះ។

រូបមន្តជោគជ័យក្នុងព្រះពុទ្ធសាសនាគឺ៖ **កម្ម បញ្ញា** និង **វីរិយៈ**។ កម្មក្នុងទីនេះ សំដៅដល់កម្មទាំងក្នុងអតីត និងក្នុងបច្ចុប្បន្ន។ កម្មក្នុងបច្ចុប្បន្ន មានសារៈសំខាន់ជាងកម្មក្នុងអតីត ហើយមានថាមពលខ្លាំងក្លាជាង ព្រោះអាចឱ្យផល

លឿនជាងកម្មអតីត។ អំពើល្អក្នុងបច្ចុប្បន្ន នឹងជួយជម្រុញដល់អំពើល្អក្នុងអតីតឱ្យហុចផល។ ដូច្នេះ យើងត្រូវតែបំពេញសេចក្តីល្អឱ្យបានច្រើន ដើម្បីទទួលបាននូវផលល្អទាំងក្នុងបច្ចុប្បន្នជាតិ និងអនាគតជាតិ។

យើងបានកើតមកជាមនុស្ស ក៏ដោយសារកុសលកម្ម ដែលយើងបានសាងទុកមកជាច្រើនជាតិរៀងៗខ្លួន ជាអ្នកតាក់តែង។ វាជាភ័ព្វសំណាងណាស់ ដែលយើងបានកើតជាមនុស្ស ហើយទាន់ព្រះពុទ្ធសាសនា និងរស់នៅក្នុងគន្លងធម៌នៃព្រះដ៏មានព្រះភាគ។ ម្យ៉ាងទៀត យើងបានមកកើតក្នុងត្រកូលជាអ្នកគោរពព្រះពុទ្ធសាសនា ហើយមានឱកាសដើម្បីទទួលយកនូវត្រៃសរណគមន៍គឺ ព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃ ជាទីពឹងទីរលឹក។ ជាងនេះទៅទៀត យើងអាចអានស្តាប់ និងរៀននូវព្រះធម៌របស់ព្រះសម្មាសម្ពុទ្ធ ដែលជាមគ្គុទេសក៍ ក៏ធ្វើជីវិតអោយឧត្តុង្គឧត្តម នេះហើយជាជីវិតដ៏មានតម្លៃ និងមានសេចក្តីសុខបំផុត។

អ្វីៗដែលយើងសម្រេចបានខាងលើនេះ គឺជាផលនៃកុលសកម្ម ដែលមនុស្សបានសាងសន្សំទុកមកពីជាតិមួយទៅជាតិមួយ។ ការបានកើតជាមនុស្ស១ ការបានស្តាប់បានឮនូវព្រះ





សទ្ធម្ម១ ការមានសទ្ធាក្នុងព្រះរតនត្រៃ១ ការបានសិក្សានូវព្រះសទ្ធម្ម១ និងការបានបួសក្នុងព្រះសាសនា១ ទាំង៥យ៉ាងនេះជាការក្រដ៏ក្រៃលែង ដែលភាសាបាលីថា **ទុល្លភ** ។ សំរាប់គ្រហស្ថអ្នកនៅគ្រប់គ្រងផ្ទះ អាចទទួលបាននូវកម្រ៤ ដូច្នេះកំណើតដែលកំពុងតែមាននេះ គឺមានតម្លៃ និងខ្ពង់ខ្ពស់ណាស់ ព្រោះជាការក្រដ៏ក្រៃលែង។ យើងគួរណាតែរីករាយ និងមានមោទនភាពចំពោះការទទួលបាននូវជីវិតដ៏ឧត្តមនេះ។ យើងអាចចាត់ទុកសមិទ្ធិផលទាំងអស់នេះជាប្រាក់ដើមទុនរបស់យើង។

ដើម្បីក្លាយជាអ្នកមាន និងរុងរឿង មានសុខភាពល្អ មានសេចក្តីសុខកាយសប្បាយចិត្តនៅក្នុងបច្ចុប្បន្ននេះ យើងត្រូវតែបំពេញនូវការងារសុចរិត ប្រកបដោយបញ្ញា និងសេចក្តីព្យាយាម។

ដើម្បីរស់រានមានជីវិត មនុស្សគ្រប់រូបត្រូវតែធ្វើការងារ។ មនុស្សដែលមានការងារធ្វើ ចាត់ទុកដូចជាបានចូលរួមចំណែកក្នុងការអភិវឌ្ឍន៍សង្គមគ្រួសារ និងសង្គមជាតិទាំងមូល។ ទោះបីជាការងារអ្វីក៏ដោយ ឱ្យតែយើងធ្វើប្រកបដោយយោនិសោមនសិការ ប្រឹងប្រែងឱ្យអស់ពីសមត្ថភាព និងសេចក្តីព្យាយាមដ៏ខ្ជាប់ខ្ជួន ជាពិសេសក្នុងការពង្រឹងនូវចំណេះដឹង ទាក់ទងទៅ

នឹងការងាររបស់យើង។ ប្រសិនបើ យើងធ្វើពាណិជ្ជកម្ម យើងត្រូវតែដឹងពីអ្វីៗគ្រប់យ៉ាងដែលទាក់ទងនឹងពាណិជ្ជកម្ម ដូច្នេះយើងនឹងទទួលបានជោគជ័យពុំខាន។

បុគ្គលខ្លះពុំមានចំណេះដឹង និងសេចក្តីព្យាយាមគ្រប់គ្រាន់ក្នុងការធ្វើពាណិជ្ជកម្ម ដូច្នេះពេលដែលគេបរាជ័យក្នុងពាណិជ្ជកម្ម គេតែងបន្ទោសថា មកពីកម្មខ្ញុំមិនល្អ ហេតុនេះបានជាខ្ញុំរកស៊ីចេះតែបរាជ័យ ហើយចំណែកអ្នកដទៃគេរកស៊ីបានជោគជ័យ នោះមកពីកម្មគេល្អ។ កម្មក្នុងទីនេះ សំដៅដល់កម្មក្នុងអតីត គេមិនបានគិតថា ការបរាជ័យរបស់គេក្នុងពាណិជ្ជកម្ម អាស្រ័យដោយកម្មក្នុងបច្ចុប្បន្នឡើយ។ ប្រសិនបើគេប្រកាន់ទស្សនៈថា ជាកម្មពីអតីតកាល ដូច្នេះទស្សនៈរបស់គេគឺ **បុព្វេកតហេតុកទិដ្ឋិ** សេចក្តីយល់ខុសថា កម្មអតីតជាអ្នកសម្រេចជោគវាសនាឱ្យគេ ។

បញ្ញា គឺជាគុណសម្បត្តិដ៏សំខាន់របស់មនុស្សដែលត្រូវតែមាន។ ដើម្បីមានបញ្ញា យើងត្រូវទៅរៀននៅសាលារៀនយកទាំងវិជ្ជាផ្លូវលោក ផ្លូវធម៌ និងវិជ្ជាជីវៈផ្សេងៗ ដើម្បីចិញ្ចឹមជីវិត។ ទន្ទឹមគ្នានេះដែរ ការយល់ដឹងពីច្បាប់កម្មផល ក៏មានសារៈ





សំខាន់សំរាប់ជីវិតផងដែរ ព្រោះនៅពេលដែលយើងយល់ពីច្បាប់កម្មផលបានត្រឹមត្រូវនោះទើបឈ្មោះថា យើងមាននូវ សម្មាទិដ្ឋិ។

សម្មាទិដ្ឋិ នាំឱ្យមានសម្មាសង្កប្បៈ សម្មាវាចា សម្មាកម្មន្ត និង សម្មាអាជីវៈ ដែលជាហេតុធ្វើឱ្យយើងមានសតិភ្ញាក់រលឹករៀរចាកនូវអំពើអាក្រក់ ហើយបំពេញនូវសេចក្តីល្អឱ្យបានច្រើន។ ដូច្នេះ ដោយកម្មល្អ យើងនឹងក្លាយជាមនុស្សមានគុណធម៌ និងរីកចម្រើនឡើង។

អំពើល្អដែលយើងធ្វើក្នុងបច្ចុប្បន្ន នឹងចាប់ផ្តើមឱ្យផលពីបច្ចុប្បន្នជាតិនេះតទៅ ហើយនឹងដើរតួជាឧបត្ថម្ភកកម្ម ឱបស្ថបកុសលកម្មពីអតីតឱ្យហុចផល។ បុគ្គលដែលបានសាងកុសលកម្មច្រើន រមែងជាបុគ្គលមានភ័ព្វសំណាង និងធ្វើកិច្ចការអ្វីៗតែងបានសម្រេចដោយងាយ។

ដូច្នេះ នៅពេលដែលយើងធ្វើការងារ ឬជំនួញផ្សេងៗប្រកបដោយ សុចន្ទៈ និង ចេតនាដ៏បរិសុទ្ធនោះ យើងក៏គួរតែធ្វើអំពើល្អ ប្រកបដោយសេចក្តីបរិសុទ្ធ និង សុចន្ទៈផងដែរ។ ដើម្បីទទួលបានជោគជ័យក្នុងការងារ គេត្រូវធ្វើប្រកបដោយបញ្ញា បូករួមទាំងសេចក្តីព្យាយាមដ៏មុតមាំ។ ក្រៅពី បញ្ញា និង

វិរិយៈ គេគួរសេពគប់ឱ្យបានត្រឹមត្រូវ និងស្វែងរកពេលវេលាសាកសមដើម្បីធ្វើការងារឱ្យបានល្អ។

បុគ្គលខ្លះពឹងលើកម្មពីអតីតខ្លាំងពេក ក៏បែរជាធ្វើការងារទាំងប្រញាប់ប្រញាល់ ហើយធ្វេសប្រហែស។ ឧទាហរណ៍ថា ប្រសិនបើគេគិតថា " ខ្ញុំជាមនុស្សមានបុណ្យច្រើនពីអតីត " ហើយទៅលោតចូលភ្លើង នោះគេប្រាកដជារលាកពុំខាន ហើយបើចូលព្រៃខ្លា ប្រាកដជាត្រូវខ្លាខាំពុំខាន ព្រោះថាទង្វើ ឬកម្មក្នុងបច្ចុប្បន្ន ដែលគេធ្វើនេះគឺជាទង្វើល្ងង់ខ្លៅ និងមិនសមហេតុផលទាល់តែសោះ។

មានឧទាហរណ៍ប្រៀបធៀបមួយ និយាយអំពីត្រីបីក្បាល។ មានអ្នកនេសាទម្នាក់ បានចែវទូកនៅតាមដងទន្លេ ហើយបានបង់សំណាញ់ទៅក្នុងទន្លេ ក៏ជាប់បានត្រីបីក្បាល ហើយគាត់ក៏បានយកមកដាក់លើទូក។ និយាយពីត្រីមួយក្បាលសង្ឃឹមលើសំណាងរបស់ខ្លួន ហើយគិតថា ប្រសិនបើសំណាងល្អ អញនឹងរួចខ្លួនវិញ ហើយក៏សម្ងំនៅស្ងៀមក្នុងទូកនោះ។ ទីបំផុត វាក៏ត្រូវបានគេយកទៅផ្ទះ ហើយចំអិនជាម្ហូបបាត់ទៅ។ ចំណែកត្រីមួយក្បាលទៀត ទីពឹងលើសេចក្តីព្យាយាមរបស់ខ្លួន ដោយគិតថា អញនឹងលោតចេញពីទូកនេះ ប្រសិនបើអាច ដូច្នេះវាក៏ចេះ





តែប្រឹងលោតជាញឹកញាប់ ប៉ុន្តែមិនអាចលោតផុតឡើយ។ អ្នកនេសាទបារម្ភក្រែងត្រីនោះលោតរួច ក៏យកចង្វាទូកសំពងត្រីនោះរហូតដល់ស្លាប់បាត់ទៅ។

ចំណែកត្រីទីបីមួយក្បាលទៀតនោះ ជាត្រីមានបញ្ញាច្រើន វាគិតថា បើអញនៅស្ងៀមដោយមិនធ្វើអ្វីសោះនោះ ប្រាកដជាត្រូវស្លាប់មិនខាន ម្យ៉ាងទៀតប្រសិនបើ អញលោតចេញដោយធ្វេសប្រហែសនោះ ប្រាកដជាត្រូវស្លាប់ដូចត្រីមួយក្បាលនោះមិនខាន។ ដូច្នេះ វាក៏សម្ងំនៅស្ងៀមរង់ចាំឱកាសល្អ។ នៅពេលដែលអ្នកនេសាទ លើកសំណាញ់បង់ទៅក្នុងទន្លេម្តងទៀតនោះ ទូកក៏ផ្អៀងម្ខាងឃើញឱកាសល្អ ត្រីនោះក៏លោតចូលទៅក្នុងទន្លេវិញប្រកបដោយសុវត្ថិភាពបាត់ទៅ។

ឆ្លងកាត់តាមបទពិសោធន៍ខាងលើ យើងគួរតែយករូបមន្តនេះមកប្រើ៖ **កម្ម បញ្ញា** និង **វិរិយៈ** ដើម្បីទទួលបានជោគជ័យក្នុងការងាររបស់យើង។

### ៥.គ្រួសារមួយជួបសេចក្តីវិនាសដោយសារខ្វះ បញ្ញា និងវិរិយៈ

ក្នុងសម័យពុទ្ធកាល មានសេដ្ឋីម្នាក់ឈ្មោះថា មហាធនៈ មានទ្រព្យ៨០០លានរូពី។ គាត់មានកូនប្រុសតែម្នាក់គត់ ប៉ុន្តែពុំបានឱ្យកូនសិក្សារៀនសូត្រអ្វីឡើយ ដោយគិតថា ទ្រព្យសម្បត្តិ

ដែលអញមានប៉ុណ្ណេះគឺហួសពីគ្រប់គ្រាន់ដើម្បីឱ្យកូនរបស់អញសោយសុខរហូតមួយជីវិត ដូច្នេះហើយក៏បណ្ដោយឱ្យកូនគិតតែពីលេងសើចសប្បាយ។

នៅពេលដែលកូនប្រុសពេញវ័យកាលណា សេដ្ឋីក៏រៀបចំគូស្រករឱ្យកូនប្រុសជាមួយនឹងកូនស្រីនៃសេដ្ឋីជាមិត្ត ដែលមានទ្រព្យ៨០០លានរូពីដូចគ្នា។ ដូច្នេះ ក្រោយពេលមាតាបិតាពួកគេបានស្លាប់បាត់ទៅ ប្ដីប្រពន្ធវ័យក្មេងទាំងពីរនាក់នេះ មានកេរមត៌កចំនួន១៦០០លានរូពី ហេតុនេះយើងឃើញថា កម្មពីអតីតជាតិរបស់ពួកគេបរិបូណ៌ណាស់ ប៉ុន្តែពួកគេពុំមានចំណេះវិជ្ជាអ្វីបន្តិចសោះនៅបច្ចុប្បន្នជាតិនេះ។

ក្រោយមក មានក្រុមអ្នកប្រមឹកជាច្រើននាក់ ចង់បានទ្រព្យសម្បត្តិរបស់ពួកគេ ដូច្នេះក៏ធ្វើជាសុំរាប់អានជាមិត្ត ហើយល្បួងឱ្យផឹកស្រាជាមួយពួកគេ។ អ្នកប្រមឹកទាំងនោះបានដាក់ស្រានៅក្នុងផ្កាឈូក ហើយក៏នាំគ្នាក្រេបស្រានោះចេញពីផ្កាឈូកដោយប្រើបំពុង ឬទុយោ។ មិនយូរប៉ុន្មាន បុរសនេះក៏ក្លាយជាអ្នកញៀនសុរា។ គាត់ចំណាយលុយទិញចំណីអាហារ និងគ្រឿងស្រវឹង ព្រមទាំងផ្ដល់ជារង្វាន់លើកទឹកចិត្តដល់អ្នករាំច្រៀងកំដរទាំងឡាយ។





មិត្តរបស់បុរសនេះ ចេះតែខ្ចីលុយពីគាត់ម្ដងហើយម្ដងទៀត ហើយមិនដែលសងវិញទាល់តែសោះ។ ដោយសារខ្វះបញ្ញា បុរសនេះខ្ជះខ្ជាយមាសប្រាក់រហូតដល់អស់ ហើយក៏ចាប់ផ្ដើមលក់ទ្រព្យសម្បត្តិ និងផ្ទះរបស់ខ្លួនម្ដងមួយៗ រហូតដល់អស់រលីងពីខ្លួន។ ក្រោយមកក៏ធ្លាក់ខ្លួនលំបាកតោកយ៉ាក គ្មានផ្ទះជ្រោកកោន និងគ្មានចំណីបរិភោគ។ ទីបំផុតក៏ក្លាយជាអ្នកសុំទាន ដើរសុំលុយ និងសុំបាយបរិភោគតាមចិញ្ចើមថ្នល់។

នៅពេលដែលព្រះសម្មាសម្ពុទ្ធ ទ្រង់យាងទៅកាន់ក្រុងដើម្បីបិណ្ឌបាត ក៏បានជួបពួកគេទាំងពីរនាក់ប្ដីប្រពន្ធ ដែលមានវ័យចាស់ជរាទៅហើយ។ ទ្រង់ក៏មានពុទ្ធដីកាទៅកាន់ព្រះអានន្ទថាៈ

" ម្នាលអានន្ទ មើលចុះប្ដីប្រពន្ធទាំងពីរនាក់ដែលកំពុងតែដើរសុំទានគេនោះ គឺជាកូនសេដ្ឋីទាំងពីរ ជាអ្នកមានជាងគេនៅក្រុងសាវត្ថីនេះ"។ ថ្វីបើពួកគេបានទទួលកេរមត៌កយ៉ាងច្រើនពីមាតាបិតាក៏ពិតមែន ប៉ុន្តែពួកគេមិនចេះគ្រប់គ្រងទ្រព្យសម្បត្តិសោះ។ បុរសជាប្ដីរាប់អានអ្នកប្រមឹកធ្វើជាមិត្ត ក៏ត្រូវក្លាយខ្លួនជាអ្នកប្រមឹកដែរ ហើយត្រូវពួកគេបោកបញ្ឆោតឱ្យចេញលុយស៊ីផឹក និងខ្ចីលុយជាញឹកញាប់ ដោយពុំសងវិញរហូតដល់អស់ពី

ខ្លួន ហើយទីបំផុត ក៏ក្លាយជាអ្នកសុំទានតាមចិញ្ចើមថ្នល់យ៉ាងនេះ។

ប្ដីប្រពន្ធទាំងពីរ មានបុណ្យបរិបូណ៌ដោយកម្មពីអតីតជាតិ ប្រសិនបើពួកគេធ្វើជំនួញរកស៊ីសុចរិត ប្រកបដោយ បញ្ញា និងវិរិយៈតាំងពីពួកគេនៅក្មេងៗនោះ ម្ល៉េះពួកគេនឹងក្លាយជាអ្នកមានលំដាប់លេខ១ ហើយប្រសិនបើពួកគេទៅសាងផ្នួសកាន់យកនូវកម្មដ្ឋាន បុរសជាប្ដីនឹងបានសម្រេចអរហត្តផល រីឯស្ត្រីជាប្រពន្ធនឹងបានសម្រេចអនាគាមិផល។ ប៉ុន្តែពួកគេបានបាត់បង់ឱកាសទាំងពីរនេះទៅហើយ។

នៅពេលដែលពួកគេឈានដល់មជ្ឈិមវ័យ ប្រសិនបើ ធ្វើជំនួញរកស៊ីសុចរិត ប្រកបដោយបញ្ញា និងវិរិយៈនោះ ពួកគេនឹងក្លាយជាអ្នកមានលំដាប់លេខ២ ហើយប្រសិនបើសាងផ្នួសកាន់យកនូវកម្មដ្ឋាន បុរសជាប្ដីនឹងបានសម្រេចអនាគាមិផល ឯស្ត្រីជាប្រពន្ធនឹងបានសម្រេចសកទាគាមិផល។ ប៉ុន្តែ ពួកគេក៏បានបាត់បង់ឱកាសទាំងពីរនេះទៅហើយដែរ។

នៅពេលដែលពួកគេឈានដល់បច្ឆឹមវ័យ ប្រសិនបើធ្វើជំនួញរកស៊ីសុចរិត ប្រកបដោយ បញ្ញា និងវិរិយៈនោះ ពួកគេនឹងក្លាយជាអ្នកមានលំដាប់លេខ៣ ហើយប្រសិនបើទៅសាង





ផ្នួសកាន់យកនូវកម្មដ្ឋាន បុរសជាប្ដីនឹងបានសម្រេចសកទាគាមិផល ស្ត្រីជាប្រពន្ធនឹងបានសម្រេចសោតាបត្តិផល។ ប៉ុន្តែគួរឱ្យស្ដាយ ពួកគេក៏បណ្ដោយឱ្យបាត់បង់ឱកាសល្អទាំងពីរនេះទៀត។

ឥឡូវនេះ ពួកគេចាស់ណាស់ទៅហើយ មិនអាចដើម្បីធ្វើជំនួញរកស៊ី ឬក៏ទៅសាងផ្នួសរៀនយកនូវកម្មដ្ឋានអ្វីទៀតឡើយ។ ពួកគេដូចជាសត្វក្រៀល(សត្វស្លាប) ដ៏ចាស់ជរាដែលបាក់ស្លាប មិនអាចហោះហើរ ហើយឈរនៅក្នុងបឹងដ៏ស្ងួតរង់ចាំត្រីចេញមកប៉ុណ្ណោះ ពោលគឺពួកគេកំពុងតែរង់ចាំពេលវេលារបស់មច្ចុរាជប៉ុណ្ណោះ។

**៦. អ្នកមានដល់កំពូល ដោយកម្មល្អបច្ចុប្បន្ន បញ្ញា និង វិរិយៈ**

យើងមិនដឹងថា យើងបានសាងអំពើល្អអ្វីខ្លះទេក្នុងអតីតកាល ប៉ុន្តែយើងអាចបំពេញកម្មល្អឱ្យបានច្រើនតាមដែលយើងពេញចិត្តក្នុងបច្ចុប្បន្ននេះ។ កម្មល្អដែលយើងសាងក្នុងបច្ចុប្បន្ននេះ និងឱ្យផលចាប់ពីបច្ចុប្បន្នជាតិនេះតទៅ ហើយនឹងជួយឧបត្ថម្ភអំពើល្អ ដែលយើងបានសាងពីអតីតៈ ឱ្យហុចផលក្នុងបច្ចុប្បន្ននេះដែរ។

កម្ម គឺជាទង្វើដែលយើងធ្វើប្រកបដោយចេតនា។ យើង

គួរតែធ្វើអំពើល្អ ឬធ្វើការងារអាជីវកម្មផ្សេងៗជាតម្រូវការបឋម។ បន្ទាប់មក យើងគួរធ្វើការងារទាំងនោះ ប្រកបដោយបញ្ញា ដ៏ឈ្លាសវៃ និងវីរិយៈ គឺសេចក្តីព្យាយាមដ៏មុតមាំ។ នេះជារូបមន្តដើម្បីឆ្ពោះទៅរកចំណុចកំពូល។

កាលខ្ញុំនៅជានិស្សិតនៃសាកលវិទ្យាល័យ ខ្ញុំបានអានអំពីខ្សែជីវិតរបស់លោក **អប្រាហាម លីនខុន** (Abraham Lincoln) ដែលជាប្រធានាធិបតីទី១៦ របស់សហរដ្ឋអាមេរិក ហើយខ្ញុំកោតសរសើរគាត់យ៉ាងខ្លាំង។ គាត់កើតនៅក្នុងខ្ទមឈើមួយនៅក្នុងព្រៃ គាត់បានឈប់រៀនតាំងពីនៅក្មេង ដើម្បីជួយឪពុករបស់គាត់កាប់អុសក្នុងព្រៃ។

ទោះបីយ៉ាងណាក៏ដោយ គាត់មិនចង់កាប់អុសអស់មួយជីវិតដូចជាឪពុករបស់គាត់នោះទេ គាត់ចង់ក្លាយជាអ្នកដឹកនាំ ដូច្នេះហើយ គាត់បានព្យាយាមដើម្បីស្វែងរកចំណេះដឹង។ គាត់បានទៅផ្ទះអ្នកជិតខាង ហើយបានខ្ចីសៀវភៅចាស់ៗ ដែលម្ចាស់ផ្ទះបានអានរួច ហើយយកទៅអាន។ គាត់អានសៀវភៅក្នុងពេលគាត់ទំនេរពីការងារ គឺនៅពេលយប់ដោយដុតភ្លើងបំភ្លឺ។ គាត់បានអានចាំនូវចំណុចសំខាន់ៗនៃសៀវភៅមួយហើយ ក៏ទៅប្តូរយកមួយក្បាលផ្សេងទៀត ដូចនេះ គាត់ក៏បានទទួល





ចំណេះដឹងយ៉ាងទូលំទូលាយពីសៀវភៅទាំងឡាយ ដែលគាត់បានអាន។

គាត់បានប្រឡងជាប់ផ្នែកច្បាប់ ហើយក្លាយជាមេធាវីនៅក្នុងឆ្នាំ ១៨៣៧ ។ គាត់បានស្តាប់វាគ្មិន ដែលថ្លែងការណ៍សាធារណៈជាច្រើនរូប ហើយបានហ្វឹកហាត់និយាយខ្លួនឯងនៅលើវាលស្មៅមួយ ដោយចាត់ទុកគោក្របី ដែលកំពុងស៊ីស្មៅជាសវនិកជន។ ដោយសេចក្តីព្យាយាមក្នុងការអនុវត្តន៍ គាត់ក៏បានក្លាយជាវាគ្មិនដ៏ឆ្នើមមួយរូប ដែលប្រកបដោយចំណេះដឹងទូលំទូលាយ។ គាត់គឺជាមនុស្សសុចរិតទៀងត្រង់ណាស់ ដូច្នេះហើយគាត់បានក្លាយជាមេធាវី និងជាអ្នកនយោបាយដ៏ជោគជ័យមួយរូប។ គាត់បានក្លាយជាអ្នកតំណាងរាស្ត្ររបស់អាមេរិកពីឆ្នាំ ១៨៤៧ ដល់ ១៨៤៩។ ឆ្នាំ១៨៥៨ ក្នុងនាមជាបេក្ខជននៃសាធារណរដ្ឋ ក្នុងព្រឹទ្ធសភាអាមេរិក គាត់បានយកឈ្នះពិន្ទុក្នុងការតស៊ូមតិជាមួយលោក ស្ទីហ្វិន អ.ដក្លាស់ (Stephen A. Douglas)។ គាត់បានចាត់ទុកទាសភាពថា ជាភាពអយុត្តិធម៌ និងបាបកម្ម ហើយគាត់ប្រឆាំងដាច់ខាតមិនឱ្យមានទាសភាពទៀតឡើយ។ គាត់បានជាប់ឆ្នោតជាប្រធានាធិបតីនៃ សហរដ្ឋអាមេរិក ក្នុងឆ្នាំ ១៨៦០។

កាលពីថ្ងៃទី៨ ខែ មិនា ឆ្នាំ២០០៤ មានការចុះផ្សាយលើទំព័រទស្សនាវដ្តីថៃម រៀបរាប់សង្ខេបអំពីប្រវត្តិរបស់លោក ប៊ៀល ហ្គេត (Bill Gates) មហាសេដ្ឋីអាមេរិក ដែលជាអ្នកមានបំផុតក្នុងពិភពលោក។ គាត់មានលុយនៅក្នុងកុងធានាគារចំនួន ៤៦ កោដិដុល្លារ។ គាត់បរិច្ចាគលុយ ២៦ កោដិដុល្លារ ដើម្បីទ្រទ្រង់ " មូលនិធិ ប៊ៀលហ្គេត" ដើម្បីធ្វើការស្រាវជ្រាវ និងលើកស្ទួយវិស័យសុខាភិបាល និង វិស័យអប់រំក្នុងពិភពលោក។

ដោយសារមនុស្សធម៌ដ៏អស្ចារ្យរបស់លោក ក្នុងការលើកស្ទួយកិច្ចការសង្គមទូទាំងពិភពលោក ម្ចាស់ក្សត្រីយ៍ អេលីហ្សាប៊ែត នៃប្រទេសអង់គ្លេស បានប្រទានងារជា(Knight Commander) ដែលជាងារង្វាន់ដ៏ខ្ពស់បំផុត នៅក្នុងចក្រភពអង់គ្លេសដល់រូបគាត់។ តើ ប៊ៀល ហ្គេត ក្លាយជាមហាសេដ្ឋីលេខ១ លើពិភពលោកដោយវិធីណា?

ប៊ៀលហ្គេត កើតនៅក្នុងគ្រកូលដែលមានជីវភាពសាមញ្ញមួយក្នុងប្រទេសអាមេរិក។ កាលដែល គាត់កំពុងសិក្សានៅវិទ្យាល័យ ដោយសារសាលារបស់គាត់បំពាក់ទៅដោយកុំព្យូទ័រដូច្នេះ គាត់ក៏ចូលចិត្តប្រើប្រាស់កុំព្យូទ័រ ពេលដែលគាត់ទំនេរម្តងៗ ហើយគាត់មានការចាប់អារម្មណ៍ ចំពោះប្រព័ន្ធកុំព្យូទ័រ





ខ្លាំងណាស់ គាត់តែងតែព្យាយាមស្វែងយល់ពីគន្លឹះសំខាន់ៗនៃកុំព្យូទ័រ។

ដោយសារ សេចក្តីព្យាយាម អនុវត្តជាបន្តបន្ទាប់នោះ ប៊ៀលហ្គេត បានក្លាយជាអ្នកឯកទេសខាងកុំព្យូទ័រមួយរូប។ នៅពេលដែលមន្ត្រីផ្នែកគ្រប់គ្រងចរាចរណ៍នៃមហាវិទ្យាល័យ ស្នើសុំឱ្យជួយបង្កើតប្រព័ន្ធគ្រប់គ្រងចរាចរណ៍ ដោយប្រើកុំព្យូទ័រនោះ គ្រូបន្ទុកថ្នាក់ ក៏ប្រគល់បញ្ហានេះឱ្យ ប៊ៀល ហ្គេត និងមិត្តរបស់គេម្នាក់ជាអ្នកចាត់ចែង។

ប៊ៀល ហ្គេត ក៏បានទទួលបន្ទុកនេះ ដោយក្តីសោមនស្ស ហើយគាត់ធ្វើការរហូតដល់យប់ជ្រៅ ពេលខ្លះអត់បានចូលដំណេកឡើយ។ ចិត្តរបស់មនុស្ស ពិតជាមានឥទ្ធិពលខ្លាំងជាងកុំព្យូទ័រដ៏ទំនើបទៅទៀត។ កាំបិតនឹងកាន់តែមុតស្រួចនៅពេលដែលគេយកទៅសំលៀងជាបន្តបន្ទាប់ យ៉ាងណាមិញចិត្តរបស់មនុស្សនឹងកាន់តែឈ្លាសវៃមុះមុត នៅពេលដែលយើងព្យាយាមពិចារណារឿយៗ ហើយប្រើប្រាស់ដោយឧបាយនៃប្រាជ្ញា។

ដោយសេចក្តីព្យាយាមដ៏មុះមុត ប៊ៀល ហ្គេត បានទទួលជោគជ័យក្នុងការងាររបស់គាត់ ក្នុងរយៈពេលត្រឹមតែមួយខែប៉ុណ្ណោះ។ ក្រោយមក ការងារលំបាកទាំងប៉ុន្មាន ក៏ត្រូវប្រគល់

ឱ្យបៀល ហ្គេត ដោះស្រាយជាបន្តបន្ទាប់ ហើយគាត់ទទួលបានជោគជ័យជាបន្តបន្ទាប់ផងដែរ។ គ្មានអ្វីជោគជ័យជាងការបានទទួលជោគជ័យនោះទេ ហើយក៏គ្មានអ្វីដែលផ្អែមដូចជាជោគជ័យនោះឡើយ។

បន្ទាប់ពីបញ្ចប់ការសិក្សានៅវិទ្យាល័យ បៀល ហ្គេត ក៏បានចូលសិក្សានៅសាកលវិទ្យាល័យ ហាវើត (Harvard University) ដោយសារពេលនេះ បៀល ហ្គេត យល់ឃើញថា សេដ្ឋកិច្ចរបស់ខ្លួនអាចទៅរួច ដូច្នេះក៏ព្យាយាមគិតស្វែងរកតម្រូវការតាមប្រព័ន្ធកុំព្យូទ័រ។ គាត់បានធ្វើការស្រាវជ្រាវពី សូវ៉ែរ (Softwares) កុំព្យូទ័រ ដែលអាចប្រើប្រាស់បានច្រើនយ៉ាង ហើយអាចជួយសម្រាលដល់ការងារមនុស្សបានខ្លះ។ គាត់បានបង្កើត ក្រុមហ៊ុន ម៉ៃក្រូសូហ្វ៍(Microsoft Company)មួយ ហើយបានចាប់ផ្តើមផលិត កម្មវិធីសូវ៉ែរផ្សេងៗ។

ដោយសារគាត់ជាមនុស្សជំនាញមុនគេផ្នែកនេះ កម្មវិធីកុំព្យូទ័ររបស់គាត់ បានក្លាយជាតម្រូវការចាំបាច់នៅលើទីផ្សារ។ គាត់បានបង្កើតក្រុមស្រាវជ្រាវមួយ ដើម្បីផលិតកម្មវិធីកុំព្យូទ័រថ្មីៗ ហើយគាត់ក៏បានក្លាយជាមហាសេដ្ឋី មានប្រាក់រាប់លានកោដិយ៉ាងឆាប់រហ័ស។





ចំណេះដឹងគឺជាអំណាច។ បញ្ញា គឺជាភាជន៍មាស ដែលមានតម្លៃកាត់ថ្លៃមិនបាន ហើយអាចផលិតនូវអ្វីៗដែលមនុស្សចង់បាន។ វាមិនចេះអស់នោះទេ ទោះបីប្រើយ៉ាងណាក៏ដោយ ហើយមិនមានបុគ្គលណាមួយអាចលួចបានឡើយ។

នៅក្នុងសម័យកុំព្យូទ័រនេះ បើបុគ្គលណាមួយអាចបង្កើតកម្មវិធីកុំព្យូទ័រថ្មីៗ ដែលមានប្រយោជន៍ដល់សង្គមនោះ គេអាចលក់ ហើយរកលុយបានដោយងាយ។

នៅក្នុងស្រុកមួយឈ្មោះ ចៃ ថូ (Kyike Hto) ក្នុងរដ្ឋ មន ( Mon State) ប្រទេសភូមា មានបុរសវ័យក្មេងម្នាក់ឈ្មោះ បាទីន (Ba Tiin) រកស៊ីចិញ្ចឹមជីវិតដោយការជីកថ្មបាយក្រៀម ដើម្បីយកទៅធ្វើឥដ្ឋលក់។

ពូរបស់គាត់មកពីក្រុង មណ្ឌលេ បានទៅលេងគាត់ ហើយបានឱ្យយោបល់គាត់ថា ការងាររបស់ក្មួយបានត្រឹមអង្ករច្រកឆ្នាំងប៉ុណ្ណោះ មិនអាចក្លាយជាអ្នកមានបានទេ។ បើក្មួយពិតជាចង់យកមុខរបរជីកថ្មនេះជាអាជីពនោះ ក្មួយគួរតែទៅរកជីកនៅដីដែលមានរតនវត្ថុនៅឯផាកាន ជិត ម្យិត ជីណា រាជធានីនៃរដ្ឋ កឈីន។ ពូមានមិត្តម្នាក់នៅទីនោះ ពូនឹងជួយស្វែង

រកដីឱ្យមួយកន្លែង បើឯងជីកបានត្បូង ឬវត្ថុមានតម្លៃផ្សេងៗ នឹងក្លាយជាអ្នកមានពុំខាន។

បាទីន យល់ព្រម ហើយក៏បានចាកចេញទៅទីក្រុងនោះ គាត់ព្យាយាមជីកដីគាស់កកាយជារៀងរាល់ថ្ងៃ។ ពីរបីខែក្រោយមក គាត់ជីកបានត្បូងដ៏មានតម្លៃជាច្រើន ហើយគាត់ក៏បានក្លាយទៅជាអ្នកមាន។

សភាពនៃការងារ ឬកម្ម ក៏មានសារៈសំខាន់ខ្លាំងណាស់ដែរ។ អ្នកមានប្រាជ្ញា រមែងទទួលបានប្រាក់កម្រៃល្អ ក្នុងការងាររបស់គេ។ ដូច្នេះ យុវជនទាំងឡាយគួរតែខិតខំរៀនសូត្រនូវមុខវិជ្ជាផ្សេងៗ ដូចជា កុំព្យូទ័រ ពាណិជ្ជកម្ម វិស្វកម្ម ពេទ្យ ឬវិជ្ជាជីវៈផ្សេងៗ ដែលអាចឱ្យខ្លួនទទួលបានការងារសមរម្យនាថ្ងៃអនាគត។ មិនថាការងារអ្វីក៏ដោយ ឱ្យតែយើងធ្វើប្រកបដោយបញ្ញា និងសេចក្តីឧស្សាហ៍ព្យាយាម នោះនឹងទទួលបានជោគជ័យជាក់ជាមិនខាន។

មិនត្រឹមតែការងារណា ដែលធ្វើឱ្យយើងក្លាយជាអ្នកមានទើបសំខាន់នោះទេ ការងារណា ដែលធ្វើឱ្យយើងទទួលបានបុណ្យកុសលនោះ រឹងរឹតតែសំខាន់។ តាមពិតការបំពេញបុណ្យកុសល គឺមានសារៈសំខាន់ណាស់ ព្រោះថាជីវិតមិនទៀង





អាចស្លាប់គ្រប់ពេលវេលា និងមិនឱ្យយើងកើតក្នុង អបាយភូមិក្រោយពេលស្លាប់។ ដូច្នេះ គួរតែប្រញាប់ប្រញាល់ធ្វើនូវអំពើល្អឱ្យបានច្រើនទាន់យើងនៅមានឱកាស។ កុសលកម្ម នឹងជួយឧបត្ថម្ភយើងឱ្យបានសុខចម្រើន និង ទទួលបានជោគជ័យក្នុងការងារ។

### ៧. ឱកាសសម្រាប់កម្មល្អ និង កម្មអាក្រក់ឱ្យផល

មានល័ក្ខខ័ណ្ឌ៤យ៉ាង ដែលជំរុញឱ្យកុសលកម្មឱ្យផល ហើយរារាំងអកុសលកម្មពីការឱ្យផលគឺ៖

(១).គតិសម្បត្តិ ដល់ព្រមដោយជីវិតពោរពេញដោយសេចក្តីសុខ

(២).ឧបធិសម្បត្តិ ដល់ព្រមដោយរូបសម្បត្តិល្អសោភា

(៣).កាលសម្បត្តិ ដល់ព្រមដោយវេលាល្អ ឱកាសល្អ

(៤).បយោគសម្បត្តិ ដល់ព្រមដោយព្យាយាម ការតាំងចិត្ត និងប្រាជ្ញា។

មានល័ក្ខខ័ណ្ឌ៤យ៉ាងដូចគ្នា ដែលជំរុញអកុសលកម្មឱ្យហុចផល ហើយរារាំងកុសលកម្មពីការឱ្យផលគឺ៖

(១).គតិវិបត្តិ ជីវិតប្រាសចាកសេចក្តីសុខ

(២).ឧបធិវិបត្តិ មានរូបសម្បត្តិមិនល្អ

(៣).កាលវិបត្តិ ឆ្លងកាត់ពេលវេលា និងឱកាសមិនល្អ

(៤).បយោគវិបត្តិ ប្រាសចាកព្យាយាម ការតាំងចិត្ត និងប្រាជ្ញា។

ឋានមនុស្ស និងទេវលោក ជាឋានដែលពោរពេញដោយជីវិតជាសុខ។ នៅឋានទាំងនេះ កុសលកម្មមានឱកាសឱ្យផល ចំណែក អកុសលកម្ម ពុំសូវមានឱកាសនឹងឱ្យផលឡើយ។

សត្វតិរច្ឆាន សត្វនរក ប្រេត អសុរកាយ គឺជាឋានដែលពោរពេញដោយជីវិតជាទុក្ខ។ នៅឋានទាំងនេះ កុសលកម្ម គ្មានឱកាសឱ្យផលទេ មានតែ អកុសលកម្ម ប៉ុណ្ណោះ ដែលឱ្យផលបាន។

បើប្រៀបធៀបនឹង សត្វតិរច្ឆាន មនុស្សរស់នៅបានសុខច្រើនជាង ចំណែកឯ ប្រេត និងអសុរកាយរស់នៅដោយទុក្ខវេទនា ជាងសត្វតិរច្ឆានទៅទៀត ប៉ុន្តែ សត្វនរករស់នៅដោយសេចក្តីទុក្ខដ៏ក្រៃលែងជាងគេបំផុត។

បើប្រៀបធៀបនឹងមនុស្ស ទេវតាមានសេចក្តីសុខជាងអាចនិយាយបានថា ស្ទើរតែគ្មានទុក្ខ។ ចំណែក ពពួកព្រហ្ម





មានសេចក្តីសុខជាងពពួកទេវតាទៅទៀត ដោយពួកគេទទួលសេចក្តីសុខពីការចម្រើននូវឈានជាបន្តបន្ទាប់។ ទោះបីយ៉ាងណាក៏ដោយ ពពួកទេវតា និងព្រហ្មទាំងឡាយពុំមានសេចក្តីមុះមុត អង់អាច ក្នុងការបំពេញបុណ្យកុសល ដូចពពួកមនុស្សលោកឡើយ។ មនុស្សអាចញុាំងសេចក្តីព្យាយាមឱ្យមុះមុត រហូតដល់បានត្រាស់ដឹងជាព្រះពុទ្ធ ប៉ុន្តែទេវតា និង ព្រហ្ម ពុំអាចត្រាស់ដឹងជាព្រះពុទ្ធឡើយ។

ក្នុងចំណោម ពពួកមនុស្ស អ្នកដែលមានរូបសម្បត្តិល្អច្រើនតែមានឱកាសទទួលបានផលប្រយោជន៍ ជាងអ្នកដែលមានរូបសម្បត្តិមិនល្អ។ មនុស្សយើងជាធម្មតា ចូលចិត្តគោរព និងសរសើរចំពោះមនុស្សដែលមានរូបសម្បត្តិល្អ ហើយចង់រាប់អានពួកគេ។ មនុស្សយើង មិនសូវឱ្យតម្លៃចំពោះមនុស្សដែលមានរូបសម្បត្តិអាក្រក់ ឬពិការអវយវៈណាមួយ ហើយក៏មិនចង់សេពគប់ពួកគេឡើយ។ បើនិយាយអំពីការងារវិញ ទោះបីមានសមត្ថភាពស្មើគ្នា បើគេជ្រើសរើស ប្រាកដជាត្រូវជ្រើសរើសអ្នកដែលមានរូបសម្បត្តិល្អហើយ។ ដូចគ្នាដែរ ក្នុងការថតភាពយន្តបង្ហាញម៉ូត ម៉ូដែលជាដើម អ្នកដែលមានរូបសម្បត្តិល្អ ប្រាកដ

ជាមានឱកាស និងជោគជ័យច្រើនជាងមនុស្សដែលមានរូបសម្បត្តិមិនល្អ។

រូបសម្បត្តិ សំរាប់ស្ត្រី គឺសំខាន់ជាងបុរស។ ស្ត្រីដែលមានសម្រស់ស្អាត រមែងមានមនុស្សស្រឡាញ់រាប់អានច្រើន ជាពិសេសគឺពួកបុរសៗ។ ដូចនេះ ពួកគេអាចជ្រើសរើសមនុស្សស្រី ដែលខ្លួនស្រឡាញ់បំផុតជាគូអនាគត។ ស្ត្រីជាច្រើន ដែលមានសម្រស់ស្អាត ទោះបីជាកើតក្នុងត្រកូលក្រីក្រមិនខ្លង់ខ្លស់យ៉ាងណាក៏ដោយ ក៏ត្រូវបានព្រះរាជា និងព្រះអង្គម្ចាស់ទាំងឡាយជ្រើសរើសជាអគ្គមហេសី។

ការជួបប្រទះនូវឱកាស និងពេលវេលា គឺជារឿងសំខាន់បំផុតផងដែរ។ នៅពេលដែលប្រទេសទាំងមូល ប្រកបដោយសន្តិភាព សេដ្ឋកិច្ចរីកចម្រើន មានឱកាសល្អ ដើម្បីធ្វើពាណិជ្ជកម្មផ្សេងៗ ប្រជាពលរដ្ឋអាចរកការងារធ្វើដោយស្រួល ទទួលបានប្រាក់កម្រៃសមរម្យ នឹងរស់នៅជាសុខ។ នៅពេលនេះហើយ ដែលកុសលកម្មមានឱកាសក្នុងការឱ្យផល។ ម្យ៉ាងវិញទៀត ប្រសិនបើ ប្រទេសគ្មានសន្តិភាព ឬកំពុងមានសង្គ្រាម ឬកំពុងមានវិបត្តិសេដ្ឋកិច្ច ប្រជាពលរដ្ឋគ្មានការងារធ្វើ ការរកស៊ីផ្សេងៗបរាជ័យ ប្រជាជនត្រូវបោះបង់ផ្ទះសម្បែងចោល ហើយ





នឹងរស់នៅជាទុក្ខ។ នៅពេលនេះហើយ ដែលអកុសលកម្មមានឱកាសឱ្យផល។

ល័ក្ខខ័ណ្ឌទីបួន ត្រូវមានសេចក្តីប្រឹងប្រែង ឧស្សាហ៍ព្យាយាម និងប្រកបដោយបញ្ញា ទាំងនេះគឺអាស្រ័យដោយបុគ្គលរៀងៗខ្លួន។ យើងគួរតែខំព្យាយាម ឧស្សាហ៍ប្រឹងប្រែងដើម្បីក្រេបយកនូវចំណេះដឹងផ្សេងៗឱ្យបានព្រោះថា **សេចក្តីព្យាយាម** និង **ចំណេះដឹង** ឬ **បញ្ញា**ទាំងពីរនេះ គឺជាគន្លឹះនៃជោគជ័យ។

បើគ្មាន សេចក្តីព្យាយាម និងចំណេះដឹងទេ គ្មាននរណាម្នាក់អាចជោគជ័យបានឡើយ គេនឹងរស់នៅក្នុងភាពក្រីក្រមិនខាន។ ដូចដែលយើងបានអានពីខាងលើរួចមកហើយ អំពីប្តីប្រពន្ធពីរនាក់ ជាអ្នកមាន បានធ្លាក់ខ្លួនជាអ្នកសុំទាន ព្រោះតែខ្វះសេចក្តីព្យាយាម និងបញ្ញានឹងឯង។ ដូច្នេះចូលយើងគ្រប់គ្នាចងចាំក្នុងចិត្ត នូវរូបមន្តជោគជ័យ៣យ៉ាង៖ **កម្ម បញ្ញា វិរិយៈ** ហើយយកទៅអនុវត្តកុំខាន។

*អ្នកនេះហើយគឺជាប្រធាននៃចិត្តរបស់អ្នក ហើយក៏ជាអ្នកបង្កើតនូវវាសនារបស់អ្នកដែរ។ អ្នកអាចគ្រប់គ្រង*

*ចិត្ត និងកម្ម របស់អ្នក ហើយបង្កើតជីវិតរបស់អ្នក តាមដែលអ្នកចង់បាន។*

**៨.អ្នកនឹងវេទនា ប្រសិនបើអ្នកសេពគប់នឹងមនុស្សពាល**

នៅក្នុងមង្គលសូត្រទាំង ៣៨ ប្រការ ក្នុងគាថាទី១ មានមង្គល ២ ប្រការបានសម្តែងថា៖ (១)បុគ្គលមិនគួរសេពគប់នឹងបុគ្គលពាលឡើយ (២)បុគ្គលគួរសេពគប់នឹងបណ្ឌិត។ ទាំងពីរនេះជាមង្គលដ៏ឧត្តម ហើយមានសារៈសំខាន់ណាស់ សម្រាប់ការជឿនលឿន និងរីកចម្រើនក្នុងជីវិតព្រោះថា មង្គលទាំងពីរនេះផ្តល់ឱកាសសមរម្យ ដើម្បីញ៉ាំងកុសលកម្មឱ្យហុចផល និងបិទឱកាសអកុសលកម្មមិនឱ្យហុចផលបាន។

ប្រសិនបើ បុគ្គលសេពគប់នឹងបុគ្គលពាល នោះគេនឹងក្លាយជាបុគ្គលពាលដែរ ហើយនឹងបាត់បង់នូវគុណធម៌ ដែលជាតម្លៃរបស់មនុស្ស។ ប្រសិនបើបាត់បង់នូវគុណធម៌ហើយ ជីវិតក៏គ្មានន័យដែរ ពេលស្លាប់ទៅនឹងទៅកើតក្នុងអាបាយភូមិម្តងហើយម្តងទៀត។

ដូចមានសុភាសិតរបស់ភូមា ពោលថា “ ត្រីក្នុងទូក បើស្អុយមួយស្អុយទាំងអស់ និងប្រសិនបើ ដើមឈើបែកមែក





សាខាច្រើន ប្រាកដជាមានសត្វបក្សាបក្សីរាប់ម៉ឺនក្បាលជ្រកនៅទីនោះ” ។

នៅក្នុងគ្រួសារមួយ ប្រសិនបើ សមាជិកម្នាក់បានធ្វើបាបកម្មយ៉ាងធ្ងន់ គ្រួសារទាំងមូល ឬសូម្បីសហគមន៍ទាំងមូល នឹងជួបប្រទះនូវបញ្ហាលំបាក។ បើសេពគប់នឹងបុគ្គលបែបនេះ គេនឹងស្ថិតក្នុងស្ថានភាពដ៏លំបាក (កាលវិបត្តិ) គឺជាស្ថានភាព ឬពេលវេលាមួយ ដែល អកុសលកម្ម មានឱកាសល្អក្នុងការឱ្យផល។

ក្នុងកាលដែលព្រះពុទ្ធសមណគោតម ទ្រង់គង់ធរមាននៅ មានភូមិមួយមានមនុស្សរស់នៅ១០០០គ្រួសារ។ ពួកគេរស់នៅដោយពឹងផ្អែកលើការនេសាទត្រី។ ថ្ងៃមួយ ភរិយានៃអ្នកនេសាទម្នាក់មានផ្ទៃពោះ។ ចាប់តាំងពីថ្ងៃនោះមក អ្នកនេសាទទាំងអស់ ក៏នេសាទត្រីលែងបាន។ ក្រោយមកក្នុងភូមិទាំងមូលក៏ត្រូវបានរដ្ឋអំណាចដាក់ទារុណកម្ម៧ដង និងដុតដោយភ្លើង៧ដង។

ព្រឹទ្ធាចារ្យក្នុងភូមិ ក៏ប្រជុំគ្នាពិភាក្សា ពួកគេជឿជាក់ថាក្នុងភូមិនេះ ប្រាកដជាមានបុគ្គលណាមួយ មានបាបកម្មធ្ងន់ធ្ងរមិនខាន។ ដូច្នេះ ពួកគេបានបែងចែកភូមជាពីរផ្នែក មួយផ្នែកមាន៥០០គ្រួសារ។ ផ្នែកនៃភូមិដែលមានស្ត្រីមានផ្ទៃពោះរស់

នៅនោះ បានជួបប្រទះនូវវិបត្តិ ដោយសារតែអ្នកភូមិនេសាទត្រីមិនបាន ជាហេតុធ្វើឱ្យខ្វះខាតអាហារ។ ដូច្នេះ ព្រឹទ្ធាចារ្យក៏បានចែកក្រុមនោះជាពីរផ្នែកទៀត ផ្នែកដែលស្ត្រីមានផ្ទៃពោះរស់នៅក៏ជួបនូវវិបត្តិដដែល។ ហេតុនេះ គេក៏ចែកក្រុមនោះជាផ្នែកតៗ រហូតដល់សល់តែស្ត្រីមានផ្ទៃពោះនោះតែម្នាក់ឯង។

ស្ត្រីនេះបានឆ្លងទន្លេដោយវេទនាបំផុត ហើយចិញ្ចឹមកូនដោយលំបាក។ នៅពេលដែលកូនរបស់ខ្លួនអាចដើរបាន នាងបានឱ្យផ្តិលមួយដល់កូន ដើម្បីដើរសុំទានគេ ហើយក៏រត់ចោលកូនបាត់ទៅ។ នៅពេលដែលកុមារនោះ អាយុបាន៧ឆ្នាំ បានជួបនឹងព្រះសារីបុត្ត ដោយក្តីករុណា លោកក៏បានបំបួសកុមារនោះជាសាមណេរ។ នៅពេលគ្រប់អាយុហើយ ព្រះសារីបុត្ត បានឧបសម្បទាសាមណេរនោះជាភិក្ខុមានព្រះនាមថា លោសកតិស្សត្ថេរ។

លោសកតិស្សត្ថេរ បានញុំាងសេចក្តីព្យាយាមដ៏មុះមុតប្រតិបត្តិ សីល សមាធិ និងបញ្ញា រហូតដល់បានសម្រេចជាព្រះអរហន្ត។ ទោះបីជាបានត្រាស់ជាព្រះអរហន្តក៏ដោយ លោកពុំដែលបានទទួលចង្ហាន់បិណ្ឌបាតឆាន់គ្រប់គ្រាន់ ក្នុងថ្ងៃណាមួយ





ឡើយ។ នៅថ្ងៃដែលលោកនឹងចូលបរិនិព្វាន លោកបាននិមន្តទៅបិណ្ឌបាតជាមួយព្រះសារីបុត្ត។

ព្រះសារីបុត្ត ក៏ពុំបានទទួលចង្ហាន់បិណ្ឌបាត សូម្បីតែបន្តិច។ ព្រះសារីបុត្ត ក៏បានប្រាប់លោកឱ្យនិមន្តទៅចាំនៅវត្តវិញ ហើយក៏និមន្តបិណ្ឌតែមួយអង្គឯង។ ពេលនោះមានគ្រួសារមួយ បាននិមន្តព្រះសារីបុត្តទទួលចង្ហាន់នៅផ្ទះពួកគេ ព្រះសារីបុត្តបានប្រាប់ទៅម្ចាស់ផ្ទះ ដើម្បីយកចង្ហាន់ខ្លះ ទៅប្រគេនព្រះលោសកតិស្សត្ថេរ នៅឯវត្ត។ ពេលយកទៅតាមផ្លូវ បុរសនោះក៏បានបរិភោគអស់ ដោយសារតែខ្លួនហេវពេក ហើយក៏ភ្លេចខ្លួន។

នៅពេល ព្រះសារីបុត្ត និមន្តមកវត្តវិញ ឃើញព្រះលោសកតិស្សត្ថេរ អត់ទាន់មានចង្ហាន់ឆាន់នៅឡើយ លោកក៏ប្រញាប់ និមន្តទៅបិណ្ឌបាតនៅរាជវាំងព្រះបាទកោសល ហើយបិណ្ឌបាតនូវចតុមធុ ដែលធ្វើពីគ្រឿងផ្សំ៤យ៉ាង ប្រេងល្ង ទឹកអំពៅ ទឹកឃ្មុំ និង ប៊ឺរ ឬទឹកដោះខាប់។ ព្រះសារីបុត្ត ក៏និមន្តទៅវត្តវិញ ដោយកាន់យកនូវចតុមធុនោះ ប្រគេនដល់ លោសកតិស្សត្ថេរ។ នេះជាលើកទីមួយក្នុងជីវិតហើយ ដែល លោសក-

តិស្សត្ថេរ បានឆាន់អាហារឆ្អែត បន្ទាប់ពីឆាន់រួចហើយ លោកក៏បានចូលបរិនិព្វាន។

តើលោសកតិស្សត្ថេរ បានសាងបាបកម្មអ្វីដែរកាលពីជាតិមុន? ក្នុងពុទ្ធកាលព្រះពុទ្ធទ្រង់ព្រះនាម កស្សប លោសកតិស្ស-ត្ថេរ គឺជាភិក្ខុមួយអង្គបរិបូណ៌ដោយសីល។ ថ្ងៃមួយមានភិក្ខុមួយអង្គ និមន្តមកកាន់វត្តនេះ ហើយបានស្នើស្នាក់នៅពីរបីថ្ងៃ។ ភិក្ខុជាម្ចាស់វត្ត ឃើញពុទ្ធបរិស័ទមានការទំនុកបំរុងយកចិត្តទុកដាក់ចំពោះភិក្ខុជាអាគន្តុកៈ លោកក៏ស្រាប់តែមានការច្រណែនក្នុងចិត្ត។

ឧបាសកអ្នកមានម្នាក់ បាននិមន្តភិក្ខុទាំងពីរអង្គនោះដើម្បីទទួលចង្ហាន់នៅផ្ទះគាត់នៅព្រឹកស្អែក។ ពេលព្រឹកព្រលឹមស្រាងៗភិក្ខុជាម្ចាស់វត្តបានយកម្រាមដៃទះជួងសើរៗ រួចហើយក៏និមន្តទៅផ្ទះឧបាសកនោះបាត់ទៅ។ ពេលនោះឧបាសកម្ចាស់ផ្ទះបានទូលសួរភិក្ខុនោះថា ហេតុអ្វីភិក្ខុជាអាគន្តុកៈមិននិមន្តមក? លោកឆ្លើយថា ភិក្ខុអង្គនោះសឹងទ្រមក់ណាស់ ទោះបីអាត្មាវាយរគាំងហើយ ក៏នៅតែមិនក្រោកដែរ ដូច្នេះ អាត្មាក៏និមន្តមកតែឯង។

ដូច្នេះ ម្ចាស់ផ្ទះក៏ប្រគេនចង្ហាន់លោកយ៉ាងល្អប្រណីត





រួចហើយគាត់ក៏បានរៀបចំចង្ហាន់ខ្លះដាក់ក្នុងបាត្រ ដើម្បីផ្ញើទៅប្រគេនដល់ភិក្ខុជាអាគន្តុកៈដែលនៅឯវត្ត។ នៅតាមផ្លូវទៅកាន់វត្ត ភិក្ខុនោះគិតថា បើភិក្ខុជាអាគន្តុកៈនោះបានចង្ហាន់ឆ្ងាញ់បែបនេះរាល់ថ្ងៃ ប្រាកដជាមិនចេញពីវត្តនេះទេ។ ដោយសេចក្ដីច្រណែននេះ លោកក៏បានចាក់ចង្ហាន់នោះចោល ក្នុងស្រែអស់ទៅ។

នៅពេលទៅដល់វត្ត ស្រាប់តែរកភិក្ខុជាអាគន្តុកៈមិនឃើញសោះ។ ដោយសារលោកដឹងពីទឹកចិត្តរបស់ភិក្ខុជាម្ចាស់វត្ត លោកក៏បានចាកចេញពីវត្តនោះ ដោយហោះចេញតាមអាកាសបាត់ទៅ។ តាមពិតភិក្ខុអាគន្តុកៈ គឺជាព្រះអរហន្ត។

ភិក្ខុជាម្ចាស់វត្តនោះ ក៏មានសេចក្ដីសោកស្ដាយ ពិបាកចិត្តពេក សឹងមិនលក់ ឆាន់មិនបាន។ មិនយូរប៉ុន្មាន លោកក៏បានសុគតបាត់ទៅ ហើយក៏បានទៅកើតក្នុងនរក។ សេចក្ដីច្រណែន គឺពិតជាគួរឱ្យភ័យខ្លាចណាស់។

បន្ទាប់ពីបានរួចពីនរកហើយ ក៏បានមកកើតជាយក្សចំនួន ៥០០ជាតិ បន្ទាប់មកកើតជាសុនខ៥០០ជាតិ។ ក្នុងកំណើតនីមួយៗ លោកមិនដែលបានអាហារបរិភោគគ្រប់គ្រាន់ឡើយ។

បន្ទាប់ពីកំណើតជាសុនខបានផុតទៅ លោកបានមកកើតក្នុងផ្ទៃនៃប្រពន្ធរបស់អ្នកនេសាទម្នាក់។

ដោយអាស្រ័យកុសលកម្ម ដែលលោកបានសាងទុកមក កាលលោកបួសជាភិក្ខុបានទ្រទ្រង់នូវសីលដ៏បរិសុទ្ធ ក្នុងសម័យព្រះពុទ្ធ កស្សបៈ ក៏បានមកចាប់កំណើត ក្នុងឋានមនុស្សម្តងទៀត ហើយក្រោយមកក៏បានចូលសាងផ្នួស។ ហើយលោកបានប្រតិបត្តិត្រៃសិក្ខា ក៏បានត្រាស់ដឹងជាព្រះអរហន្ត។ ដោយសារតែកម្មដ៏ធ្ងន់ ដែលលោកបានចាក់ចង្ហាន់បិណ្ឌបាតរបស់ព្រះអរហន្តចោលនោះ ក្នុងភូមិទាំងមូល ដែលមានប្រមាណ ១០០០គ្រួសារនោះ ក៏ត្រូវរងទុក្ខអត់អាហារបរិភោគ ខណៈពេលដែលលោកបានទៅចាប់កំណើត ក្នុងផ្ទៃនៃប្រពន្ធអ្នកនេសាទម្នាក់នៅក្នុងភូមិនោះ។

ផលដែលកើតពីកម្មដ៏មានទម្ងន់នេះ អាចធ្វើឱ្យបុគ្គលដែលសេពគប់ជាមួយបុគ្គលដែលមានបាបកម្មនោះ រងទុក្ខទោសដែរ។ ដូច្នេះ យើងគួរតែប្រុងប្រយ័ត្ន ក្នុងការសេពគប់មនុស្ស ការមិនសេពគប់នូវបុគ្គលពាលទាំងឡាយ ជាមង្គលដ៏ឧត្តម។

នៅក្នុងគម្ពីរធម្មបទ ក្នុងរឿង តយោជនៈ យើងបានដឹង





ហើយអំពីសំពៅ ដែលដឹកអ្នកដំណើរ៧០០នាក់ចេញពីត្រើយម្ខាង លុះដល់កណ្តាលសមុទ្រ ក៏ស្រាប់តែគឿងដោយមិនដឹងមកពីមូលហេតុអ្វី។ នៅពេលនោះ ម្ចាស់ទូកដែលមានការវៃឆ្លាត បានយល់ឃើញថា ប្រាកដជាលើសំពៅនេះ មានបុគ្គលណាមួយមានបាបកម្មធ្ងន់មិនខាន ដូច្នេះហើយ ក៏ស្នើអោយអ្នកជិះសំពៅទាំងអស់ចាប់ស្លាក។

នៅពេលនោះ ប្រពន្ធម្ចាស់ទូកដ៏ស្រស់ស្អាត ក៏ចាប់បានស្លាកអាក្រក់ចំនួន៣ដង។ ដូច្នេះគេក៏យកក្អមខ្សាច់ពាក់កនាង ហើយរុញទម្លាក់ទៅក្នុងសមុទ្របាត់ទៅ។ បន្ទាប់មកសំពៅនោះ ក៏ធ្វើដំណើរទៅមុខដូចធម្មតាវិញ អ្នកដំណើរទាំងនោះក៏មានសុវត្ថិភាព។ ដោយសារតែបាបកម្មដ៏ធ្ងន់ធ្ងរនៃបុគ្គលបាប មនុស្សក្នុងសំពៅទាំងមូលក៏អាចស្លាប់ដែរ។

តើនាងបានសាងបាបកម្មអ្វីកាលពីជាតិមុន ?កាលពីជាតិមុន នាងគឺជាស្ត្រីដ៏មានសម្រស់ស្អាតម្នាក់នៅក្នុងភូមិមួយ។ ប្តីរបស់នាងបានស្លាប់ចោលនាង ហើយបានទៅកើតជាឆ្កែ។ កូនឆ្កែនោះ ចេះតែដើរតាមនាងគ្រប់ទីកន្លែង ដែលនាងតែងទៅ។ បុរសៗក្នុងភូមិឃើញដូចនេះ ក៏នាំគ្នាសើចចំអកដោយពាក្យថា " មើលចុះ នាងព្រានព្រៃនោះ កំពុងចេញទៅបរបាញ់ជាមួយឆ្កែ

របស់នាងទៀតហើយ ដូច្នេះថ្ងៃនេះយើងនឹងបានហូបសម្លការី សាច់ក្ងាន់មិនខាន” ។

នាងមានសេចក្តីអៀនខ្មាស់យ៉ាងខ្លាំង ដោយឮពាក្យនេះ។ ដូច្នេះ នាងតែងតែរកវិធីដេញឆ្កែនោះកុំឱ្យចេះតែដើរតាមនាង។ ប៉ុន្តែឆ្កែនោះនៅតែដើរតាមនាងដដែល។ នាងខឹងណាស់ ក៏យកក្អមខ្សាច់តូចមួយចងកវា ហើយរុញទម្លាក់ទឹកប្រឡាយបាត់ទៅ។ ដូច្នេះហើយបានជាក្នុងជាតិបន្ទាប់នោះ នាងត្រូវបានគេចងកដោយក្អមខ្សាច់ ហើយរុញទម្លាក់ទឹក។

**៩.បុគ្គលសេពគប់ជាមួយបុគ្គលមានកម្មល្អ រមែងបានចម្រើនរុងរឿង**

ប្រសិនបើ មានកូនប្រុស ឬកូនស្រីដែលមានកម្មល្អ អស្ចារ្យ កើតក្នុងត្រកូលណា ត្រកូលនោះនឹងបានសេចក្តីសុខចម្រើន។ប្រសិនបើបុគ្គលម្នាក់ក្នុងចំណោមសាច់ញាតិទាំងនោះ បានទទួលបុណ្យសក្តិធំ សាច់ញាតិទាំងនោះនឹងបានទទួលនូវផលប្រយោជន៍ខ្លះជាក់ជាមិនខាន។ មនុស្ស ទេវតា និង ព្រហ្មរាប់លាននាក់ បានរួចផុតពីសេចក្តីទុក្ខដោយសារតែបានជួបនឹងព្រះសម្មាសម្ពុទ្ធ ហើយបានគោរពរាប់អានព្រះពុទ្ធជាកល្យាណបុគ្គលដ៏អស្ចារ្យមួយរូប។

នៅប្រទេសស្រីលង្កាក្នុងរជ្ជកាលព្រះបាទ ភាតិកៈ បុគ្គល





ណា បរិភោគសាច់គោនឹងត្រូវពិន័យជាប្រាក់យ៉ាងច្រើន។ អ្នកដែលគ្មានលុយបង់ត្រូវពិន័យទៅធ្វើការក្នុងរាជវាំង បោសសំរាមសំអាតទីធ្លាជាដើម។

នៅក្នុងត្រកូលមួយ មានកូនស្រីម្នាក់មានរូបឆោមលោមល្អ នៅពេលដែលព្រះរាជាទ្រង់ទតឃើញនាង ក៏មានសេចក្តីប្រតិព័ទ្ធស្នេហាយ៉ាងខ្លាំង ។ ហើយក៏បានតែងតាំងនាងជាព្រះអគ្គមហេសី ដោយមាននាមថា សាមាទេវី។ គ្រួសារ និងសាច់ញាតិនាងទាំងអស់ ក៏បានរួចផុតពីការពិន័យ ថែមទាំងត្រូវបានព្រះរាជាប្រទានទ្រព្យសម្បត្តិ ហើយរស់នៅជាសុខ។

ដោយសារតែកុសលកម្មដ៏ល្អបូករួមទាំងសម្រស់របស់ស្រីក្រមុំនោះផង សាច់ញាតិនាងទាំងអស់ក៏ទទួលបាននូវសេចក្តីសុខចម្រើន និងសប្បាយរីករាយតាំងពីពេលនោះតរៀងមក។

# ១២

# ច្បាប់កម្ម
# ដែលមានសភាពស៊ីជម្រៅ និង ល្អិតសុខុម

## ១. លក្ខណៈរបស់នាម ដែលមានសភាពស៊ីជម្រៅ និងល្អិតសុខុម

រាប់ចាប់តាំងពីសម័យ តាលេស ( Tales, 624-550 BC ) ទស្សនវិទូបុរាណជនជាតិក្រិច ដែលត្រូវបានគេចាត់ទុកជា បិតាទស្សនវិទូលោកខាងលិច អ្នកទស្សនវិទូសម័យនោះ បានធ្វើការស្រាវជ្រាវសភាវៈទាំងឡាយដែលមានក្នុងធម្មជាតិ។ ២៦០០ឆ្នាំបានកន្លងផុតទៅ ពួកគេនៅតែមិនអាចស្វែងយល់ពីសភាវៈ ដែលមាននៅក្នុងធម្មជាតិនៃរូបទាំង២៨ និង នាម៥៣ (ចេតសិក១ និង ចេតសិក៥២ ) ។

នៅក្នុងទេវវិទ្យាមានបរិយាយអំពីចក្រវាឡ ផែនដី មនុស្សជាតិ សត្វតិរិច្ឆាន និងដើមឈើទាំងឡាយ គឺសុទ្ធតែ ព្រះអាទិទេព ជាអ្នកបង្កើត ហើយភពផែនដីត្រូវបានចាត់ទុកជាមជ្ឈ-





មណ្ឌលនៃចក្រវាឡ។ ទោះបីយ៉ាងណាក៏ដោយ នីកូ ឡាស់កូពើនីកុស (Nicholas Copernicus,1473-1543) ជាតារាវិទូ ជនជាតិប៉ូឡូញ និងជាស្ថាបនិកនៃប្រព័ន្ធកូពើនីខែន (Founder of Copernican System)ដែលជាប្រព័ន្ធមួយត្រូវបានអ្នកវិទ្យាសាស្ត្រសម័យទំនើប យកមកប្រើប្រាស់ក្នុងតារាវិទ្យា បានចំណាយពេលក្នុងមួយជីវិតរបស់គាត់សិក្សាពីចលនានៃតារា និងភពទាំងឡាយ។ នៅក្នុងឆ្នាំ ១៥៤៣ គាត់បានប្រកាស់ថា គឺជាព្រះអាទិត្យ មិនមែនផែនដីទេ ដែលជាមជ្ឈមណ្ឌលនៃប្រព័ន្ធព្រះអាទិត្យ ហើយថា ផែនដីគឺជាភពដ៏តូចមួយប៉ុណ្ណោះ ដែលធ្វើដំណើរជុំវិញព្រះអាទិត្យ។

ហ្គាលីលេអូ ហ្គាលីលេ ( Galileo Galilei, 1564-1642 ) តារាវិទូ គណិតវិទូ និងរូបវិទូ ជនជាតិអ៊ីតាលី ដែលការស្រាវជ្រាវរបស់គាត់អំពីច្បាប់ធម្មជាតិ បានបង្កើតជាមូលដ្ឋានវិសោធនកម្មនៃវិទ្យាសាស្ត្រទំនើប ហើយបានបង្កើតកែវយឺត ហើយគាត់គឺជាអ្នកគាំទ្រនូវទ្រឹស្តីកូពើនីកូស។ អាស្រ័យដោយមូលដ្ឋានវិសោធនកម្មវិទ្យាសាស្ត្រនេះហើយ ទើបវិទ្យាសាស្ត្រទំនើបបានលោតផ្លោះរីកចំរើនយ៉ាងខ្លាំង។ តែទោះបីយ៉ាងណា វិទ្យាសាស្ត្រ

ដ៏ទំនើបនេះ នៅតែមិនអាចស្វែងយល់ពីសភាវៈចិត្តរហូតមកទល់បច្ចុប្បន្ននេះ។

ដោយសារតែបុថុជ្ជនមិនអាចយល់អំពីសភាវៈនៃចិត្ត និងចេតសិកបាន ដូច្នេះពិបាកក្នុងការស្វែងយល់ពីច្បាប់កម្មផលឱ្យបានស៊ីជម្រៅណាស់ ព្រោះទ្រឹស្តីកម្មផលមានទំនាក់ទំនងយ៉ាងខ្លាំងជាមួយនឹងចិត្ត និងចេតសិក។ ការមិនជឿនូវកម្ម និងផលរបស់កម្មដែលមានពិត នាំឱ្យគេប្រកាន់មាំក្នុងមិច្ឆាទិដ្ឋិ។

អ្នកដែលមានជំនឿលើទេវនិយមបាននិយាយថា ព្រះអាទិទេព ឬព្រះព្រហ្ម ជាអ្នកបង្កើតចក្រវាឡ ភពផែនដី និងសព្វសត្វទាំងអស់ ហើយថាព្រះជាអ្នកគ្រប់គ្រង និងសម្រេចវាសនារបស់ពួកគេ។ ដូច្នេះ បុគ្គលម្នាក់ៗគ្មានសិទ្ធិសម្រេចជោគវាសនារបស់ខ្លួនទេ អ្វីៗគឺព្រះជាអ្នកតាក់តែងរួចទៅហើយ។ លទ្ធិនេះហៅថា " **ឥស្សរនិមានវាទ** " ឬទិដ្ឋិខុសប្រាស់ចាកហេតុ(**វិសមហេតុកទិដ្ឋិ**)ជឿថាព្រះជាអ្នកបង្កើត និងគ្រប់គ្រងចក្រវាឡ។

បុគ្គលពួកខ្លះជឿថា សេចក្តីសុខ និងទុក្ខ ដែលយើងជួបប្រទះសព្វថ្ងៃនេះ គឺកម្មពីអតីតកាល ជាអ្នកតាក់តែង។ ដូច្នេះ យើងគ្មានសិទ្ធិតវ៉ាទេ ព្រោះកម្មបានតាក់តែងយ៉ាងនេះ





ទៅហើយ។ មិច្ឆាទិដ្ឋិនេះ ហៅថា "**បុព្វេកតហេតុកទិដ្ឋិ**" ជឿថាអ្វីៗកម្មបានតាក់តែងរួចទៅហើយ។

បុគ្គលមួយពួកទៀតជឿថា សេចក្តីសុខ និង ទុក្ខដែលយើងកំពុងជួបប្រទះសព្វថ្ងៃ កើតឡើងដោយគ្មានហេតុផលអ្វីទាំងអស់។ បុគ្គលពួកនេះមិនមានប្រាថ្នា សេចក្តីព្យាយាម និងភាពចាំបាច់ក្នុងការបំពេញការងារអ្វីទេ។ មិច្ឆាទិដ្ឋិ នេះហៅថា " **អហេតុកទិដ្ឋិ** " ជឿថាអ្វីៗគ្មានហេតុគ្មានផលទេ។ លទ្ធិនេះត្រូវបានបង្រៀនដោយអាចារ្យម្នាក់ ក្នុងចំណោមអាចារ្យដ៏ល្បី៦រូបឈ្មោះ មក្ខលិគោសាលៈ។

បុគ្គលមួយពួកទៀតជឿទៅលើ " **អកិរិយវាទ** " ជឿថាកម្មមិនមាន។ ទោះបីបុគ្គលធ្វើ បុណ្យក្តី បាបក្តី គ្មានកម្មទាំងអស់។ បុគ្គលប្រភេទនេះ មិនមានប្រាថ្នា មិនមានសេចក្តីព្យាយាម និងមិនចាំបាច់ក្នុងការធ្វើការងារឡើយ ព្រោះគេជឿថាទោះធ្វើបុណ្យក្តី ធ្វើបាបក្តី ក៏កម្មមិនមាន។ លទ្ធិនេះត្រូវបានបង្រៀនដោយអាចារ្យដ៏ល្បីម្នាក់ឈ្មោះ បូរាណកស្សបៈ។

អាចារ្យម្នាក់ទៀតឈ្មោះ អជិតកេសកម្ពលៈ បានបង្រៀនលទ្ធិឈ្មោះថា "**នត្ថិកទិដ្ឋិ**" ជឿថាបុណ្យ និងបាបពិតជាមាន តែផលនៃបុណ្យ និងបាបមិនមានឡើយ។ គេជឿថា ការដាក់បាត្រ

គ្មានប្រយោជន៍ទេ ចិញ្ចឹមមាតាបិតា ក៏គ្មានផលប្រយោជន៍អ្វីដែរ ហើយការធ្វើខុសចំពោះមាតាបិតា ក៏គ្មានបាបកម្មអ្វីទាំងអស់។ ជាតិមុខមិនមាន អំពើល្អ និងអាក្រក់ ដែលបុគ្គលបានសាង នឹងរលត់អស់ នៅពេលដែលគេស្លាប់គ្មានអ្វីសេសសល់ឡើយ បន្ទាប់ពីស្លាប់បាត់ទៅ។

មិច្ឆាទិដ្ឋិទាំងអស់ខាងលើនេះ គឺគ្មានខ្លឹមសារ និងប្រយោជន៍ឡើយ ព្រោះមិនបានជំរុញឱ្យយើងមានសទ្ធាក្នុងការបំពេញកុសល។ បុគ្គលអ្នកជឿទៅលើលទ្ធិទាំងនេះ នឹងទៅកើតក្នុងនរកក្រោយស្លាប់ទៅ។ មនុស្សភាគច្រើនមិនបានប្រើហេតុផលក្នុងការគិតរបស់ពួកគេ ហើយក៏ជឿលង់ក្នុងលទ្ធិរបស់អាចារ្យទាំង៦រូបនេះ។

នៅពេលព្រះសាសនារបស់ព្រះពុទ្ធអង្គ សាបសូន្យទៅ មិច្ឆាទិដ្ឋិ របស់អាចារ្យទាំងនេះនឹងរីកផ្សព្វផ្សាយក្នុងពិភពលោករហូតដល់ពុទ្ធកាលព្រះពុទ្ធអង្គបន្ទាប់។ រឿងនិទានរបស់ព្រះពោធិសត្វ ក្នុងនារទជាតក នឹងបរិយាយទាក់ទងនឹងប្រវិត្តនេះខាងក្រោម។

**២. នារទជាតក អធិប្បាយពីកម្មចម្លែកឱ្យផល**

នៅក្នុងចន្លោះរវាង ព្រះសាសនា នៃព្រះពុទ្ធ កស្សបៈ និង





ព្រះសមណគោតម ព្រះរាជាទ្រង់ព្រះនាម ឥង្គតិ សោយរាជ្យនគរមិថិលា ក្នុងដែន វិទេហរាជ។ ព្រះអង្គទ្រង់ជាស្តេចគ្រប់គ្រងប្រទេសប្រកបដោយទសពិធរាជធម៌។ ព្រះអង្គទ្រង់ស្រឡាញ់បុត្រីតែមួយគត់របស់ព្រះអង្គយ៉ាងខ្លាំង គឺព្រះអង្គម្ចាស់ក្សត្រីយ៍ រុស្សា ព្រះអង្គទ្រង់ប្រទានបុត្រី៥០០នាក់នៃមន្ត្រីទាំងឡាយជាបរិវារ ហើយទ្រង់ឱ្យព្រះនាងគង់ក្នុងវិមាន៧ជាន់។ ព្រះអង្គទ្រង់ឱ្យគេយកផ្កាស្រស់ៗ សំលៀកបំពាក់ និងចំណីអាហារដ៏ប្រណីតទៅថ្វាយព្រះនាងជារៀងរាល់ថ្ងៃ។

ព្រះនាង រុស្សា ទ្រង់ជាស្ត្រីដ៏ស្រស់ស្អាត មានប្រាជ្ញាវាងវៃ ហើយជាស្ត្រីគួរឱ្យគោរព។ នាងគឺជាស្ត្រីដែលមានបុណ្យបានសន្សំទុកហើយអស់កាលជាង១សែនកប្ប។ ព្រះរាជាតែងប្រទានប្រាក់ដល់ព្រះនាងចំនួន១ពាន់កហបណៈ ក្នុង១ ខែ ២ ដង ហើយ ព្រះនាងយកប្រាក់ទាំងនោះ ប្រគេនដល់សមណព្រាហ្មណ៍ និងបរិច្ចាគដល់ស្មូមយាចក។

នៅថ្ងៃពេញបូណ៌មីនៃខែវិច្ឆិកា ជាថ្ងៃដែលគេប្រារព្ធធ្វើពិធីបុណ្យនក្ខត្តឫក្ស ក្នុងនគរ មិថិលា ដើម្បីទទួលស្វាគមន៍នៃការប្រជុំគ្នានៃតារាទាំង៧ ហៅថា ក្រត្តិកា ហើយទីក្រុងទាំងមូលត្រូវបានលំអរទៅដោយពន្លឺយ៉ាងស្រស់ស្អាត។ នៅថ្ងៃនោះ

ដែរ ព្រះបាទ ឥង្គតិ ទ្រង់សម្អាតព្រះរាជកាយ ហើយ លាបលនដោយប្រេងចាន់ប្រដាប់ដោយគ្រឿងអលង្ការ ហើយទ្រង់សោយក្រយាពេលល្ងាច។ បន្ទាប់មកទ្រង់គង់នៅសាលនៃព្រះរាជវាំងដែលមានសេនាមាត្យនៅជុំវិញ ខណៈពេលនោះ ព្រះច័ន្ទពេញវង់ក៏បានរះឡើងចិញ្ចែងចិញ្ចាច នៅលើអាកាសដ៏ភ្លឺថ្លាផ្នែកខាងកើត ញុំាងភាពអន្ធការនៃរាត្រីអោយភ្លឺស្វាង។

ព្រះរាជាទ្រង់មានបន្ទូលថា "ហៃអាមាត្រទាំងឡាយ ព្រះច័ន្ទរះពេញវង់ល្អណាស់ រីឯផ្ទៃមេឃក៏ស្រឡះគួរជាទីគយគន់ តើយើងគួរកំដរបរិយាកាសបែបនេះដោយវិធីណាទៅ?" លោកមន្ត្រីមហាសង្គ្រាម ឈ្មោះ អលាតៈ ដែលជាមេបញ្ជាការនៅទីនោះបានឆ្លើយមុនថា " បពិត្រព្រះករុណាដ៏ចម្រើន នៅក្នុងបរិយាកាសដ៏ល្អបែបនេះ យើងគួរតែប្រមូលកងទ័ពទៅវាយលុកយករដ្ឋណាដែលយើងពុំទាន់បានយក " ។

កុង្សីម្នាក់ទៀតឈ្មោះ សុនាមៈ " បពិត្រព្រះករុណាដ៏ចម្រើន មិនមានបុគ្គលណាមួយហ៊ានបដិសេធនឹងឆន្ទៈរបស់ព្រះអង្គឡើយ នៅក្នុងថ្ងៃឧបោសថ រាត្រីច័ន្ទពេញវង់បែបនេះ ព្រះអង្គគួរតែទ្រង់សោយក្រយាឆ្ងាញ់ៗ ទ្រង់ទតមើលរបាំ និងចំរៀងដ៏ពិរោះៗ" ។





កុង្សីម្នាក់ទៀតឈ្មោះ វិជយៈ "បពិត្រព្រះករុណាដ៏ចម្រើន សេចក្តីសប្បាយក្នុងបញ្ចកាមគុណមិនជាការពិបាកទេ នៅក្នុងរាត្រីដ៏មនោរម្យបែបនេះ ព្រះអង្គគួរទ្រង់ចូលទៅកាន់សមណព្រាហ្មណ៍ ជាបណ្ឌិតដែលមានប្រាជ្ញាខ្ពង់ខ្ពស់ អាចដោះស្រាយសេចក្តីសង្កាក្នុងព្រះរាជហឫទ័យទ្រង់បាន" ។

ព្រះរាជាទ្រង់ព្រះសណ្តាប់អាមាត្យ វិជយៈ ហើយទ្រង់សព្វព្រះរាជហឫទ័យ ហើយទ្រង់ត្រាស់ថា "ដូច្នេះយើងនឹងចូលទៅរកសមណព្រាហ្មណ៍" ។ លោកមន្ត្រីមហាសង្គ្រាម អលាតៈ ឮដូចនេះក៏ពោលថា "បពិត្រព្រះករុណាដ៏ចម្រើន បើទ្រង់ប្រាថ្នាដើម្បីទៅរកសមណព្រាហ្មណ៍ ខ្ញុំព្រះអង្គស្គាល់អាស្រមនៅជិតក្រុងពារាណសី មានព្រាហ្មណ៍ម្នាក់ឈ្មោះ គុណៈ ។ ព្រាហ្មណ៍នេះ មានចំណេះខ្ពង់ខ្ពស់ណាស់ លោកមានត្រកូលជាកស្សបៈ ហើយមិនស្លៀកពាក់អ្វីទាំងអស់។ លោកអាចនិយាយពីរឿងរ៉ាវចម្លែកៗគួរអោយចង់ស្តាប់ណាស់ ទូលបង្គំជឿជាក់ថា ព្រាហ្មណ៍ម្នាក់នេះ នឹងអាចជួយស្រាយបញ្ហាក្នុងព្រះរាជហឫទ័យ ទ្រង់បានមិនខាន។"

ព្រះរាជាក៏ទ្រង់យល់ស្រប ហើយទ្រង់យាងដោយរទេះសេះធំ មានសេនាជាច្រើនជាបរិវារ ពេលយាងជិតដល់អាស្រម

ហើយ ទ្រង់ចុះពីរទេះសេះ ហើយក៏ទ្រង់យាងទៅកាន់ទីដែលព្រាហ្មណ៍នោះស្នាក់នៅដោយសេចក្តីគោរព។

បន្ទាប់ពីធ្វើគារវកិច្ចទៅវិញទៅមករួចហើយ ព្រះរាជាទ្រង់លើកសំណួរនេះឡើង " បពិត្រ កស្សបៈ ដ៏ចម្រើន តើយើងគួរទំនុកបម្រុងមាតាបិតា ភរិយា បុត្រធីតា ជនចាស់ជរា សមណព្រាហ្មណ៍ និងប្រជារាស្ត្រដោយវិធីណា? " ។

ជំនួសការឆ្លើយសំណួរព្រះរាជា ព្រាហ្មណ៍បានពន្យល់ពីលទ្ធិរបស់ខ្លួន " បពិត្រព្រះរាជាដ៏ចម្រើន បុគ្គលដែលប្រតិបត្តិនូវតបៈធម៌ ឬសមាធិ នឹងមិនមានផលប្រយោជន៍ ឬគុណវិបត្តិអ្វីទាំងអស់ ព្រោះថាជាតិមុខមិនមាន។ មិនមែនមាតាបិតា ឬគ្រូបាធ្យាយ ឯណាមកអប់រំមនុស្សអាក្រក់នោះទេ។ យើងមិនចាំបាច់គោរពចំពោះមនុស្សចាស់ជរាឡើយ មនុស្សគ្រប់រូប គឺស្មើភាពគ្នា អ្នកខ្លះមាន អ្នកខ្លះក្រ ដោយគ្មានហេតុផលអ្វីទេ។ ការបរិច្ចាគទាន មិនមានផលឡើយ អ្នកល្ងង់ជាអ្នកបរិច្ចាគ ឯអ្នកឆ្លាតគេចាំតែទទួល"។

"បពិត្រព្រះរាជាដ៏ចម្រើន នៅក្នុងលោកនេះ មានតែជាតុ៧ប៉ុណ្ណោះគឺ៖ ដី ទឹក ភ្លើង ខ្យល់ សុខ ទុក្ខ និងជីវិត។ មានតែវត្ថុជាតុទាំង ៧ នេះ ប៉ុណ្ណោះ ដែលស្ថិតស្ថេរ។ ការសម្លាប់ និង





បៀតបៀនមិនមានឡើយ។ ប្រសិនបើ មនុស្សម្នាក់កាត់កមនុស្សម្នាក់ទៀត ដោយកាំបិតដ៏មុតស្រួច កាំបិតនោះគឺឆ្លងកាត់តែវត្ថុជាតុទាំង៧ប៉ុណ្ណោះ ដូច្នេះ ការសម្លាប់ គឺមិនមានឡើយ។ បើការសម្លាប់មិនមាន តើនៅពេលធ្វើអំពើបាប យើងទទួលបាបកម្មម្តេចទៅ? "

"សព្វសត្វទាំងអស់នឹងបរិសុទ្ធដោយខ្លួនឯង បន្ទាប់ពី៨៤កប្បក្រោយ។ ដរាបណាកប្បទាំង៨៤មិនទាន់គ្រប់ គ្មានបុគ្គលណាមួយអាចធ្វើខ្លួនអោយបរិសុទ្ធ ដោយការសម្អាតកាយ វាចា និង ចិត្ត និងដោយការធ្វើសេចក្តីល្អបានឡើយ។ ទោះបីបុគ្គលនោះបានធ្វើបុណ្យច្រើនយ៉ាងណាក៏ដោយ ដរាបណាកប្បទាំង៨៤មិនទាន់គ្រប់ គឺមិនអាចបរិសុទ្ធបានឡើយ។ សព្វសត្វទាំងអស់អាចរស់នៅបានត្រឹមតែ៨៤ កប្បផែនដីប៉ុណ្ណោះ។ បន្ទាប់ពីនោះមក គ្មានអ្នកមកចាប់កំណើតទៀតទេ ដូចជា សមុទ្រដែលមិនអាចឆ្លងផុតច្រាំងយ៉ាងណា គ្មានមនុស្សណាឆ្លងផុត កំឡុងពេលនោះឡើយ។"

"ជំនឿថា បុណ្យ និងបាប មិនឱ្យផល ការសម្លាប់មិនមានយ៉ាងនេះគឺពិតជាគ្រោះថ្នាក់ខ្លាំងណាស់។ ជំនឿនេះនឹងធ្វើឱ្យមនុស្សលែងចង់ធ្វើបុណ្យ ហើយគេនឹងប្រព្រឹត្តធ្វើអំពើបាប

ដោយសេរី។ ទីបំផុតពិភពលោកទាំងមូលនឹងក្លាយជាកន្លែងគ្មានសុខសន្តិភាព ហើយ មនុស្សជាតិនឹងត្រូវបំផ្លិចបំផ្លាញ ។

**ការចាំជាតិខ្លួនឯងមួយជាតមិនអាចយល់ពីច្បាប់កម្មផលបានឡើយ**

លោកមន្ត្រីមហាសង្គ្រាម អាលាតៈ យល់ស្រេបនឹងទស្សនៈរបស់កស្សបព្រាហ្មណ៍ដោយនិយាយថា " អ្វីដែលលោកគ្រូកស្សបៈ បានលើកឡើងគឺពិតជាត្រឹមត្រូវណាស់។ ខ្ញុំនៅចាំជាតិរបស់ខ្ញុំ កាលពីជាតិមុនខ្ញុំបានកើតជាអ្នកកាប់សាច់លក់ ឈ្មោះបិង្គលៈ នៅក្នុងក្រុងពារាណសី។ ខ្ញុំបានធ្វើបាបកម្មច្រើនណាស់ដោយសម្លាប់ គោក្របី ជ្រូក ពពែយ៉ាងច្រើន។ ស្លាប់ពីជាតិនោះមក ខ្ញុំក៏បានមកកើតក្នុងត្រកូលនៃមេទ័ពនេះ។ ហើយឥឡូវនេះ ខ្ញុំបានក្លាយជាមន្ត្រីនៅក្នុងក្រុងមិថិលានេះ។ ដូច្នេះបាបកម្មមិនមានផលអ្វីឡើយ។

អលាតៈ មិនបានចងចាំជាតិទី២របស់ខ្លួនទេ ដែលក្នុងជាតិនោះ ខ្លួនបានធ្វើបុណ្យច្រើន ដោយសារបុណ្យកុសលនេះទើបគាត់បានមកកើតក្នុងត្រូកូលមេទ័ពក្នុងជាតិនេះ។ អំពើបាបដែលគាត់បានធ្វើក្នុងជាតិទី១នោះមិនទាន់ដល់ពេលឱ្យផលនៅឡើយ ប៉ុន្តែ វាសម្ងំនៅក្នុងវិថីចិត្តរបស់គាត់រហូត ប្រៀបដូចជារងើកភ្លើង ដែលគ្របដណ្តប់ដោយផេះ ពោលគឺរង់ចាំតែឱកាស





នឹងឱ្យផល។

នៅពេលនោះដែរ មានទាសករដ៏កំសត់ម្នាក់ ឈ្មោះពីជកៈ ជាអ្នករក្សាសីលដែលនៅជិតនោះ បានឮនូវអ្វីដែលកស្សបព្រាហ្មណ៍ បានរៀបរាប់ គាត់ក៏យំយ៉ាងខ្លាំង ព្រះរាជាឃើញដូចនេះ ក៏ទ្រង់សួរពីមូលហេតុ បុរសជាទាសករក៏បានទូលព្រះរាជាថាៈ

"បពិត្រមហារាជដ៏ចម្រើន ខ្ញុំព្រះអង្គក៏ចាំជាតិដែរ។ កាលនោះខ្ញុំព្រះអង្គមានឈ្មោះថា ភាវៈ ជាអ្នកមានស្តុកស្តម្ភមួយរូបនៅនគរ សាកេត និងជាអ្នកបរិច្ចាគទាន រក្សាសីល និងធ្វើតែអំពើល្អប៉ុណ្ណោះ។ ខ្ញុំព្រះអង្គចាំថា ខ្ញុំព្រះអង្គពុំដែលបានធ្វើអំពើបាបអ្វីឡើយ ប៉ុន្តែនៅពេលដែលខ្ញុំព្រះអង្គស្លាប់ទៅ ក៏បានមកកើតក្នុងផ្ទៃនៃស្ត្រីម្នាក់ជាទាសីនៃអ្នកស្នងផ្ទាំងក្នុងនគរ មិថិលាដូច្នេះហើយ ខ្ញុំព្រះអង្គក៏ក្លាយជាមនុស្សកំសត់ទុគ៌តរហូតមក ។

តែទោះបីជាខ្លួនក្រលំបាកយ៉ាងណាក្តី ខ្ញុំព្រះអង្គតែងចែករំលែកអាហារពាក់កណ្តាលដល់អ្នកអត់ឃ្លានរហូត ហើយខ្ញុំព្រះអង្គរក្សាឧបោសថសីលខ្ជាប់ខ្ជួនជានិច្ច។ ខ្ញុំព្រះអង្គមិនដែលបៀតបៀនគេ មិនដែលលួចទ្រព្យសម្បត្តិគេឡើយ ប៉ុន្តែដូចលោកមេទ័ព អលាតៈ បាននិយាយហើយថា អំពើល្អដែលខ្ញុំ

បានធ្វើមិនមានផលឡើយ។ ខ្ញុំព្រះអង្គប្រៀបបាននឹងអ្នកលេងអុកដ៏ល្ងង់ដែលតែងតែចាញ់គេ ចំណែកលោកមេទ័ព អលាតៈ គឺដូចជាអ្នកលេងដ៏ឈ្លាសវៃ ដែលតែងតែឈ្នះគេជាដរាប។ ដោយសារតែខ្ញុំព្រះអង្គ មិនអាចមើលឃើញផ្លូវទៅកាន់ឋានសួគ៌បាន ដូច្នេះហើយ ក្រោយពេលបានស្តាប់នូវពាក្យរបស់ កស្សបព្រាហ្មណ៍ទើបធ្វើឱ្យខ្ញុំព្រះអង្គយំ"។

ពីជកៈធ្លាប់បានកើតជាកសិករម្នាក់ ក្នុងពុទ្ធកាលនៃព្រះពុទ្ធ កស្សបៈ។ ពេលមួយ គាត់បានចូលព្រៃដើម្បីស្វែងរកគោរបស់ខ្លួន នៅពេលនោះមានភិក្ខុមួយអង្គ វង្វេងផ្លូវក្នុងព្រៃនោះដែរ ហើយលោកក៏បានសួរទៅបុរសនោះ ឱ្យជួយបង្ហាញផ្លូវចេញ។ ដោយបារម្ភពីការបាត់គោរបស់ខ្លួន បុរសនោះមិនបានឆ្លើយប្រាប់លោកឡើយ នៅពេលភិក្ខុនោះសួរម្តងទៀត បុរសនោះខឹង ហើយក៏តបថា " តើលោកឯងជាកូនអ្នកទាសករឬ? ម៉េចបាននិយាយពាក្យអសុរោះម្ល៉េះ? អ្នកប្រាកដជាកូនទាសករហើយមែនទេ?" ដូច្នេះ បុរសនោះ ក៏បានប្រព្រឹត្តបាបកម្មយ៉ាងធ្ងន់។

ប៉ុន្តែ នៅពេល បុរសនោះស្លាប់ទៅ បាបកម្មនោះ មិនទាន់មានឱកាសឱ្យផល ដូច្នេះអំពើល្អដែលគាត់បានសាងពីមុន





មក ក៏បានតាក់តែងឱ្យគាត់កើតក្នុងត្រកូលអ្នកមានស្តុកស្តម្ភ ដោយឈ្មោះថា ភាវៈ យ៉ាងនេះ។ ទោះបីក្នុងជាតិនោះ ភាវៈបានធ្វើបុណ្យច្រើនក្តី តែបុណ្យទាំងនោះ មិនទាន់មានឱកាសដើរតួជាផលិតកម្មនៅពេលដែលគាត់ស្លាប់ឡើយ។ បាបកម្មដែលបុរសជាកសិករនោះ បានប្រើពាក្យអសុរសទៅលើភិក្ខុមួយអង្គបានដើរតួជាផលិតកម្ម តាក់តែងកំណើតឱ្យបុរសនោះបានមកកើតក្នុងផ្ទៃនៃស្ត្រីជាទាសី អ្នកស្នូនផ្លាំងនេះឯង។ ប៉ុន្តែ ដោយសារ ពីជកៈ មិនដឹងពីរឿងនេះ ក៏បែរជាយល់ខុសថា អំពើល្អដែលខ្លួន បានសាងពុំមានផលទៅវិញ។

បន្ទាប់ពីបានស្តាប់រឿងរ៉ាវរបស់ អលាតៈ និងពីជកៈ មកព្រះបាទ ឥង្គតិ ក៏ទ្រង់ជឿទៅលើលទ្ធិរបស់ កស្សបព្រាហ្មណ៍ដែលថា អំពើល្អ និងអំពើអាក្រក់មិនមានផលឡើយ។ ទ្រង់បានចាត់ទុក កស្សបៈ ជាគ្រូតាំងពីថ្ងៃនោះមក។ ដោយ កស្សបៈនិយាយថា ការគោរពចំពោះសមណព្រាហ្មណ៍ មិនមានប្រយោជន៍ ព្រះរាជាក៏ទ្រង់មិនគោរព កស្សបៈ ឡើយ ហើយក៏ទ្រង់ចាកចេញទៅ។

## អំពើបាបកាន់តែរីកដុះដាលបើមានមិច្ឆាទិដ្ឋិ

ចាប់តាំងពីព្រះបាទ ឥង្គតិ ទទួលយក លទ្ធិមិច្ឆាទិដ្ឋិ មក ព្រះអង្គឈប់ដាក់បាត្រដល់សមណព្រាហ្មណ៍ ឈប់បរិច្ចាគអាហារដល់ស្មូមយាចកដូចរាល់ថ្ងៃ ហើយសាលាឆទានដាក់ន្លែងបរិច្ចាគដល់អ្នកសូមទាំងឡាយនៅទ្វារក្រុង និងកណ្ដាលទីក្រុង ត្រូវបានរុះរើចោលអស់។ ព្រះរាជាទ្រង់ឱ្យអាមាត្យទាំងបីគឺវិជយៈ សុនាមៈ និងអលាតៈ ជាអ្នកចាត់ចែងកិច្ចការទាំងឡាយក្នុងព្រះបរមរាជវាំង ហើយទ្រង់គង់នៅសោយសុខនឹងកាមគុណ តាមសេចក្ដីប្រាថ្នា។

ទោះបីព្រះអង្គមានអគ្គមហេសី និងស្រីស្នំស្អាតៗជាច្រើនហើយក្ដី ទ្រង់បង្គាប់ឱ្យគេចាប់ស្ត្រីក្រមុំ និងភរិយាអ្នកដទៃដែលទ្រង់ពេញចិត្តយកមកសប្បាយព្រះកាយ។ កាលពីមុនព្រះអង្គទ្រង់គ្រប់គ្រងប្រទេសប្រកបដោយទសពិធរាជធម៌ ប្រទេសជាតិទាំងមូលប្រកបដោយសុខសន្តិភាព តែឥឡូវនេះ ព្រះរាជាទ្រង់ប្រព្រឹត្តអំពើទុច្ចរិត ហើយមន្ត្រីទាំងឡាយ ក៏នាំគ្នាធ្វើអំពើទុច្ចរិតដែរ ដែលជាហេតុធ្វើឱ្យប្រទេសទាំងមូលធ្លាក់ចុះក្នុងភាពវឹកវរពោរពេញ ដោយការភ័យខ្លាច និងទោមនស្ស។

ភីលៀងរបស់ព្រះនាង រុស្សា បានដឹងរឿងនេះ ហើយក៏





ទៅទូលថ្វាយដល់ព្រះនាង។ ព្រះនាងបានសណ្ដាប់រឿងនេះហើយ ទ្រង់មិនសប្បាយព្រះទ័យ និងទ្រង់ព្រះចិន្តាថា "ហេតុអ្វីបានជាព្រះបិតាទ្រង់យាងទៅសាកសួរព្រាហ្មណ៍ដែលគ្មានសីលគ្មានហិរិឪត្តប្បៈ និងគ្មានសំពត់បិទបាំងយ៉ាងនេះ? ហេតុអ្វីបានជាទ្រង់មិនយាងទៅសួរសមណព្រាហ្មណ៍ ដែលជាអ្នកទ្រទ្រង់សីល និងបដិបត្តិសមាធិ? នៅពេលនេះមានតែអញទេ ដែលអាចជួយព្រះបិតា ឱ្យបោះបង់មិច្ឆាទិដ្ឋិនេះបាន។ កាលពីជាតិមុន នៅពេលដែលអញកើតជាទេពធីតា អញអាចដឹងបាន៧ជាតិក្នុងអតីតកាល និង៧ជាតិក្នុងអនាគតកាល។ តែឥឡូវនេះមិនមែនជាពេលវេលាសមរម្យ ដើម្បីចូលគាល់ព្រះបិតានោះទេ តាមធម្មតា អញគួរតែទៅមុនពេលថ្ងៃ១៤បោសថប៉ុណ្ណោះ។ អញនឹងសុំប្រាក់១ពាន់កហបណៈពីព្រះបិតា ហើយព្រះបិតានឹងពោលពាក្យ មិច្ឆាទិដ្ឋិ របស់ទ្រង់ ដូច្នេះជាឱកាសសម្រាប់អញពន្យល់ព្រះអង្គហើយ"។

## ព្រះនាងរុស្សាទ្រង់ពន្យល់ធម៌ដល់ព្រះបិតា

មុនថ្ងៃ១៤បោសថជិតមកដល់ ព្រះនាង រុស្សា តុបតែងព្រះកាយដោយគ្រឿងអលង្ការ និងប្រេងម្សៅរួចហើយ ក៏ទៅកាន់សំណាក់ព្រះរាជបិតាមួយអន្លើដោយភីលៀងជាបំរើ៥០០នាក់។

ពេលទៅដល់ ព្រះរាជាក៏សាកសួរ "តើកូនស្រីសុខព្រះកាយឬទេ តើការរស់នៅក្នុងវិមាន៧ជាន់នោះមានសេចក្ដីសុខទេ? តើកូនបានហូបឆ្ងាញ់ ស្លៀកពាក់ស្អាត មានផ្កាកម្រងដែលគេបម្រើឱ្យទេ?" ។

"ខ្ញុំព្រះអង្គសូមអរព្រះគុណព្រះបិតា អ្វីៗគ្រប់យ៉ាងប្រសើរណាស់ដោយសារគុណបារមី និងព្រះករុណាទិគុណរបស់ព្រះបិតា។ ថ្ងៃស្អែកនេះ គឺជាថ្ងៃឧបោសថ ជាថ្ងៃដែលពពួកទេវតាទាំងឡាយមកប្រជុំគ្នា សូមព្រះបិតាព្រះរាជទានប្រាក់១០០០កហាបណៈដល់ទូលបង្គំ ខ្ញុំព្រះអង្គនឹងថ្វាយទានចំពោះសមណព្រាហ្មណ៍ និងស្មូមយាចកទាំងឡាយ"។

"ម្នាលបុត្រី ការធ្វើទានពុំមានផលឡើយ ចូរកូនកុំចំណាយប្រាក់ឥតប្រយោជន៍ ចូរកូនឈប់រក្សាសីលទៀតទៅ ព្រោះវាមិនមានផលឡើយ កូនក៏មិនចាំបាច់តមអាហារពេលល្ងាចដែរ។ ពេលដែលបិតានៅឯអាស្រមរបស់កស្សបៈ កូនប្រុសរបស់ទាសីម្នាក់ បានយំយ៉ាងជូរចត់ ក្រោយពីបានស្ដាប់ពាក្យទូន្មានរបស់កស្សបៈ។ ម្នាលបុត្រីសម្លាញ់ ចូរសប្បាយក្នុងគំនរមាសប្រាក់សព្វសារពើ ដែលមាននៅក្នុងវិមានអស់មួយជីវិតចុះ"។

"បពិត្រព្រះបិតា បុគ្គលសេពគប់នឹងពាល រមែងក្លាយជា





បុគ្គលពាលដែរ។ អលាតៈ និង ពីជកៈក្លាយជាបុគ្គលពាលដោយសារតែ ពួកគេសេពគប់នឹងកស្សបព្រាហ្មណ៍ ដែលជាបុគ្គលពាល។ ប៉ុន្តែ ព្រះបិតា ជាព្រះរាជាដ៏វាងវៃ អាចបែងចែកអ្វីមានប្រយោជន៍ និងមិនមានប្រយោជន៍ អ្វីដែលសមហេតុផល និងមិនសមហេតុផល។ ហេតុអ្វីបានជាព្រះបិតាជឿទៅលើកស្សបៈ តាម អាលាតៈ និងពីជកៈ ដូច្នេះ? ពួកគេកំពុងតែកាន់យកនូវមិច្ឆាទិដ្ឋិហើយ។

"បពិត្រព្រះបិតា បើកស្សបៈពោលថាបុណ្យ និងបាបមិនមានផលនោះ ហេតុអ្វីបានជាលោកប្រព្រឹត្តខ្លួនឯង ដូចជាអ្នកបួស? មនុស្សល្ងង់ដែលជឿថា សព្វសត្វទាំងអស់នឹងបរិសុទ្ធដោយឯងៗ ហើយរួចចាកពីសង្សារវដ្ដនៅពេលដែលកប្បទាំង៨៤គ្រប់បរិបូណ៌ គឺជាមនុស្សល្ងង់ ដែលដល់នូវសេចក្ដីវិនាស។ បុគ្គលទាំងនោះ នឹងមិនអាចរួចចាកអំពី មិច្ឆាទិដ្ឋិ បានឡើយ ប្រៀបដូចជាត្រីរមែងមិនរួចផុតអំពីផ្លែសន្ទូចយ៉ាងនោះដែរ ។

"បពិត្រព្រះបិតា ខ្ញុំព្រះអង្គសូមថ្វាយជាឧទាហរណ៍មួយៈ អ្នកជំនួញនាំយកទំនិញរបស់ពួកគេបន្តិចម្ដងៗ ក្នុងដំណើរដោយទូក នៅពេលដែលពួកគេប្រមូលបានទំនិញច្រើន ក៏ធ្វើឱ្យទូកមានទម្ងន់ខ្លាំង នឹងអាចធ្វើឱ្យលិចទូកបាន។ យ៉ាងណាមិញ

បុគ្គលពាលដែលសន្សំនូវអំពើបាបបន្តិចម្តងៗ រហូតដល់អំពើបាបនោះមានទម្ងន់ខ្លាំង នឹងអាចទាញបុគ្គលនោះធ្លាក់ក្នុងនរកបាន។ បើសិនអំពើបាបមិនទាន់មានទម្ងន់គ្រប់គ្រាន់នឹងឱ្យផលទេ អលាតៈ នឹងរស់នៅជាសុខក្នុងបច្ចុប្បន្ននេះ ដោយអំណាចនៃកុសលកម្មពីអតីតកាលដែលគាត់បានសាង។ ហើយនៅពេល កុសលកម្មនោះមានកម្លាំងខ្សោយ អលាតៈ នឹងធ្លាក់ទៅរងទុក្ខក្នុងនរកពុំខាន។

"បពិត្រព្រះបិតា ពីជកៈ កំពុងតែសាងសន្សំអំពើល្អបន្តិចម្តងៗ គាត់កំពុងតែស្ថិតនៅលើផ្លូវទៅកាន់ឋានសុគតិហើយ។ ក្នុងពេលបច្ចុប្បន្ននេះ គាត់ជាខ្ញុំបម្រើគេ ដោយសារតែបាបកម្មដែលគាត់បានសាងពីអតីតកាល។ នៅពេល បាបកម្មនោះមានកម្លាំងខ្សោយ ពីជកៈ នឹងទទួលបានសេចក្តីសុខក្នុងករណីថាគាត់លះបង់នូវមិច្ឆាទិដ្ឋិ និងឈប់ជឿតាមលទ្ធិរបស់កស្សបៈ។

"បពិត្រព្រះបិតា ប្រសិនបើ បុគ្គលសេពគប់នឹងបុគ្គលដែលមានមិច្ឆាទិដ្ឋិ និងប្រតិបត្តិតាមផ្លូវខុស បុគ្គលនោះប្រាកដជាដើរផ្លូវខុសដែរ។ ដូច្នេះបុគ្គលអ្នកមានប្រាជ្ញា ដែលជាអ្នកស្អប់ខ្ពើមនូវអំពើបាប រមែងវៀរចាកការសេពគប់នឹងបុគ្គលបាប។ បើបុគ្គលខ្ចប់ត្រីស្អុយដោយស្លឹកឈើណា ស្លឹកឈើនោះនឹងមាន





ក្លិនស្អុយ។ ម្យ៉ាងវិញទៀត បើបុគ្គលយកស្លឹកឈើទៅខ្ចប់ផ្កា ស្លឹកឈើនោះក៏នឹងមានក្លិនក្រអូប។ ហេតុនេះហើយ បុគ្គលអ្នកមានប្រាជ្ញារមែងសេពគប់តែនឹងបុគ្គលជាបណ្ឌិត ហើយរមែងវៀរចាកបុគ្គលពាល។បាបមិត្តរមែងនាំយើងធ្លាក់ទៅនរក ចំណែកកល្យាណមិត្តរមែងនាំយើងទៅឋានសួគ៌។

"បពិត្រព្រះបិតា ក្នុងជាតិមុន ខ្ញុំព្រះអង្គកើតជាទេពធីតាជាបំរើនៃសក្កទេវរាជ។ ក្នុងជាតិនោះ ខ្ញុំព្រះអង្គអាចមើលឃើញបាន៧ជាតិក្នុងអតីតកាល និង៧ជាតិក្នុងអនាគតកាល។ នៅពេលអន្ទោលទៅក្នុងវាលវដ្តសង្សារក្នុងជាតិមួយនោះ ខ្ញុំព្រះអង្គបានទៅកើតជាកូនប្រុសរបស់ជាងមាសម្នាក់ក្នុងក្រុង រាជគ្រឹះ។ នៅក្នុងជាតិនោះ ខ្ញុំព្រះអង្គបានសេពគប់បាបមិត្តម្នាក់ ហើយបានធ្វើអំពើបាបជាច្រើន មានពេលមួយនោះ ខ្ញុំព្រះអង្គបានទៅចាប់ប្រពន្ធគេរំលោភ។ ប៉ុន្តែ ពេលដែលខ្ញុំព្រះអង្គស្លាប់ បាបកម្មនោះមិនទាន់ឱ្យផលនៅឡើយ ប៉ុន្តែ វាសម្ងំនៅក្នុងវិថីចិត្តរហូតបីដូចនឹងរងើកភ្លើងដែលគ្រប់ដណ្តប់ដោយផេះយ៉ាងនោះដែរ។

"ដោយកុសលកម្មឱ្យផល ទើបខ្ញុំព្រះអង្គបានមកកើតជាកូនប្រុសអ្នកមានស្តុកស្តម្ភម្នាក់នៅក្នុងនគរកោសម្ពី។ នៅក្នុងជាតិនោះ ខ្ញុំព្រះអង្គបានសេពគប់នឹងកល្យាណមិត្តម្នាក់ជាអ្នក

មានចំណេះដឹង ហើយក៏បានសាងសន្សំសេចក្តីល្អយ៉ាងច្រើន។ ខ្ញុំព្រះអង្គតែងរក្សាសីលរៀងរាល់ថ្ងៃឧបោសថជាប់មិនដាច់។ នៅពេលដែលខ្ញុំព្រះអង្គស្លាប់ អំពើល្អទាំងនោះពុំទាន់ឱ្យផលទេ គឺនៅសម្ងំប្រៀបដូចជាភាជន៍មាស ដែលនៅត្រាំក្នុងទឹកអណ្តូងយ៉ាងនោះដែរ។

"នៅពេលដែលខ្ញុំព្រះអង្គស្លាប់ទៅ ដោយបាបកម្ម ដែលបានសហាយស្មន់នឹងប្រពន្ធអ្នកដទៃ ខ្ញុំព្រះអង្គបានទៅកើតក្នុងរោរុវៈនរក ហើយត្រូវបានគេយកទៅដាក់ក្នុងខ្ទះភ្លើង ដែលមានទឹកពុះអស់រយៈពេលយ៉ាងយូរ សោយទុក្ខនៅក្នុងនរកនោះគ្មានថ្ងៃស្រាកស្រាន្ត។

នៅពេលដែលខ្ញុំព្រះអង្គរួចផុតអំពីនរកនោះហើយ បានទៅកើតជាពពែឈ្មោលនៅក្នុងនគរ ពិណ្ណាគតៈ។ ដោយបាបកម្មដែលបានសហាយស្មន់នឹងប្រពន្ធអ្នកដទៃនោះ អង្គជាតិ ឬពងស្វាសរបស់ពពែត្រូវបានគេក្រៀវ ហើយដោយវាមានកម្លាំងខ្លាំងក្លា ពពែនោះត្រូវបានគេប្រើឱ្យអូសរទេះធ្ងន់ៗជារឿយៗ។

បន្ទាប់ពីស្លាប់ពីជាតិជាពពែមក ខ្ញុំព្រះអង្គបានទៅកើតជាស្វាឈ្មោលនៅក្នុងព្រៃដ៏ជ្រៅមួយ។ កើតហើយភ្លាម ម្តាយរបស់ខ្ញុំបានយកទៅប្រគល់ឱ្យស្តេចស្វា ពេលនោះស្រាប់តែស្តេច





ស្វានោះវាយកំទេចអង្គជាតិខ្ញុំ។ នេះក៏ដោយសារតែបាបកម្មដែលខ្ញុំព្រះអង្គបានក្បត់នឹងប្រពន្ធខ្លួនឯង ហើយទៅសហាយស្មន់ជាមួយប្រពន្ធអ្នកដទៃ។

បន្ទាប់ពីស្លាប់ពីជាតិជាស្វាឈ្មោលមក ខ្ញុំព្រះអង្គបានទៅកើតជាគោឈ្មោលនៅក្នុងរដ្ឋមួយឈ្មោះទស្សនៈ គោនោះក៏ត្រូវបានគេក្រៀវទៀត នេះក៏ដោយសារតែបាបកម្មដែលបានសហាយស្មន់នឹងប្រពន្ធអ្នកដទៃដែរ។

បន្ទាប់ពីស្លាប់ពីជាតិជាគោឈ្មោលមក ខ្ញុំព្រះអង្គបានទៅកើតជា មនុស្សស្រីមិនស្រី ប្រុសមិនប្រុស (ខ្ទើយ) នៅក្នុងគ្រួសារមួយជាមេភូមិនៅក្នុងរដ្ឋវជ្ជី។ នេះក៏ដោយសារតែបាបកម្មដែលបានសហាយស្មន់នឹងប្រពន្ធអ្នកដទៃដែរ។

បពិត្រព្រះបិតាដ៏ចម្រើន បន្ទាប់ពីខ្ញុំព្រះអង្គបានស្លាប់ពីជាតិជាមនុស្សខ្ទើយនោះមក ក៏បានទៅកើតជាទេពធីតានៅក្នុងឧទ្យាន នន្ទវនៈ នៃឋានតាវតិង្ស។ ខ្ញុំព្រះអង្គគឺជាស្នំនៃ សក្កទេវរាជ ជាអ្នកដែលពូកែខាងរាំ និងច្រៀង។ នៅក្នុងជាតិនោះ ខ្ញុំព្រះអង្គដឹងបាន៧ជាតិក្នុងអតីតៈ និង៧ជាតិក្នុងអនាគត ។ នៅក្នុងជាតិជាទេពធីតនោះ និងជាតិទាំង៧ក្នុងអនាគត ខ្ញុំព្រះអង្គ

បរិបូណ៌ដោយសេចក្តីសុខ។ ជាតិទាំង៧ក្នុងអនាគតនោះ គឺមាន៦ជាតិជាស្ត្រី និង១ជាតិជាទេវបុត្រដ៏មានឫទ្ធិ។

បពិត្រព្រះបិតាដ៏ចម្រើន អាយុរបស់ខ្ញុំព្រះអង្គ១៦ឆ្នាំគឺខ្លីណាស់នៅក្នុងឋានសួគ៌។ ១០០ឆ្នាំ នៅឋានមនុស្សស្មើនឹង១ថ្ងៃនៅឋានតាវតិង្ស។ ព្រះបិតាគួរតែកំណត់ទុកក្នុងព្រះរាជហឫទ័យថា អំពើល្អ និង អំពើបាប ដែលយើងបានធ្វើមិនបាត់បង់ឡើយ វានឹងអន្ទោលតាមយើងប្រៀបដូចជាស្រមោលអន្ទោលតាមប្រាណយ៉ាងនោះដែរ។

បពិត្រព្រះបិតាដ៏ចម្រើន ប្រសិនបើ បុគ្គលណាមួយចង់កើតជាប្រុសគ្រប់ៗជាតិ គេត្រូវតែវៀរចាកឱ្យបាននូវកាមេសុមិច្ឆាចារៈ នោះប្រៀបដូចជាបុគ្គលបានលាងជម្រះហើយនូវជើងដែលប្រឡាក់ដោយភក់។ ប្រសិនបើស្ត្រីណាចង់កើតជាប្រុសគ្រប់ៗជាតិ នាងត្រូវតែបំរើស្វាមីរបស់ខ្លួនដោយភាពស្មោះត្រង់មិនផិតក្បត់។

បពិត្រព្រះបិតាដ៏ចម្រើន ប្រសិនបើបុគ្គលចង់បានសេចក្តីសុខជារបស់មនុស្ស និងរបស់ទេវតាដែលបរិបូណ៌ដោយបរិវារហែរហមអមដំណើរ គេត្រូវតែវៀរចាកនូវអំពើអាក្រក់ទាំងពួងហើយបំពេញតែសេចក្តីល្អឱ្យបានច្រើនដែលអាចធ្វើបាន ហើយ





ព្យាយាមហាត់ពត់ កាយ វាចា និងចិត្ត។ បុគ្គលដែលមានទ្រព្យសម្បត្តិច្រើន មានបរិវារច្រើន គឺជាមិត្ត ឬជាអ្នកដែលបានធ្វើបុណ្យច្រើនក្នុងអតីតជាតិ។ បពិត្រព្រះបិតាដ៏ចម្រើន ព្រះអង្គមានអគ្គមហេសីស្អាតៗជាច្រើន និងស្រីស្នំជាច្រើនជាបរិវារសុទ្ធតែបរិបូណ៌ដោយសម្រស់ប្រៀបបាននឹងស្រីសួគ៌។ តើព្រះអង្គទ្រង់ជ្រាបទេថា ទាំងនេះតើមកពីមូលហេតុអ្វីដែរ?

ព្រះនាង រុស្សា បានពន្យល់ព្រះបិតារបស់នាងពេញមួយថ្ងៃមួយយប់ ដើម្បីឱ្យទ្រង់លះបង់នូវមិច្ឆាទិដ្ឋិ ហើយចាប់យកនូវសម្មាទិដ្ឋិវិញ។ ទោះបីជាព្រះនាងបានខំពន្យល់លើកយកហេតុផលសមរម្យ និងរឿងរ៉ាវពីអតីតជាតិជាច្រើន ទាក់ទងនឹងការឱ្យផលរបស់កម្មយ៉ាងណាក្តី ក៏ព្រះរាជា ពុំបានលះបង់នូវមិច្ឆាទិដ្ឋិឡើយ។ ប្រៀបដូចជាមាតាបិតា ដែលរីករាយពេលបានឮកូនរបស់ពួកគេនិយាយលេងយ៉ាងសប្បាយ យ៉ាងណាមិញព្រះរាជាក៏ទ្រង់រីករាយក្នុងព្រះរាជហឫទ័យ ពេលដែលបានទ្រង់សណ្តាប់នូវពាក្យពេជន៍ ដ៏សមហេតុផលរបស់ធីតាជាទីស្រឡាញ់នៃព្រះអង្គ។

មហាជនសប្បាយចិត្តណាស់ក្នុងថ្ងៃនោះ ដោយបានឮដំណឹងថាព្រះនាង រុស្សា អាចពន្យល់ព្រះបិតារបស់ខ្លួនឱ្យទ្រង់

លះបង់នូវមិច្ឆាទិដ្ឋិ ហើយដឹកនាំប្រទេសប្រកបដោយទសពិធរាជធម៌ ដើម្បីសេចក្ដីសុខចំរើន និងសន្តិភាពដល់ប្រជារាស្ត្រទាំងឡាយ។ ពួកគេបានរង់ចាំប្រកបដោយការរំពឹងទុកយ៉ាងខ្ពស់។

## នារទព្រហ្មសម្ដែងធម្មទេសនា

ទោះបីជា មិនអាចធ្វើឱ្យព្រះរាជាលះបង់នូវមិច្ឆាទិដ្ឋិ បានក៏ដោយ ក៏ព្រះនាង រុស្សា ទ្រង់មិនលះបង់នូវសេចក្ដីព្យាយាមឡើយ។ ព្រះនាងទ្រង់លើកម្រាមដៃដាក់លើសិរសា ហើយថ្វាយបង្គំទៅទិសទាំងអស់ ហើយបញ្ចេញនូវវាចាខាងក្រោមនេះ ៖

" នៅក្នុងលោកនេះ មានសមណព្រាហ្មណ៍ទាំងឡាយជាអ្នកបរិបូណ៌ដោយ សីល និងសមាធិ ជាបុគ្គលដែលមនុស្សទាំងឡាយយកជាទីពឹង និង គោរពបូជា។ ដោយអំណាចនៃសីល និងការអធិដ្ឋានរបស់នាងខ្ញុំ សូមឱ្យសមណព្រាហ្មណ៍ទាំងឡាយនោះនិមន្តមកក្នុងទីនេះ។ ដោយអំណាចនៃតេជានុភាព សូមទ្រង់ជួយប្រោសដល់ព្រះបិតារបស់នាងខ្ញុំ ព្រះបាទ ឥង្គតិ ឱ្យរួចចាកអំពីមិច្ឆាទិដ្ឋិ ហើយទ្រង់ដឹកនាំប្រទេសប្រកបដោយធម៌ ដើម្បីសេចក្ដីសុខចម្រើនដល់ប្រជារាស្ត្រទាំងឡាយ។

ក្នុងកាលនោះឯង ព្រះគោតមពោធិសត្វ ទ្រង់ជាព្រហ្មមានព្រះនាមថា នារទៈ។ ជានិយាមសំរាប់ព្រះពោធិសត្វគ្រប់ព្រះ





អង្គទ្រង់ផ្សាយនូវមេត្តាធម៌ចំពោះសព្វសត្វទាំងឡាយ និងទ្រង់ក្រឡេកមើលនូវពិភពលោក ដើម្បីទ្រង់ជ្រាបនូវឧបនិស្ស័យសត្វ។ ខណៈពេលដែល នារទព្រហ្ម កំពុងក្រឡេកមើលឧបនិស្ស័យសត្វទ្រង់បានឮនូវសេចក្ដីប្រាថ្នារបស់ព្រះនាងរុស្សា។ ហើយក៏ទ្រង់ជ្រាបដែរថា ក្រៅពីព្រះអង្គមិនមានបុគ្គលណាអាចដើម្បីកំចាត់បង់នូវមិច្ឆាទិដ្ឋិរបស់ព្រះបាទ ឥង្គតិ បានឡើយ។ ដូច្នេះទ្រង់ក៏សម្រេចព្រះទ័យយាងចុះមកឋានមនុស្ស ដើម្បីជាប្រយោជន៍ និងសេចក្ដីសុខចម្រើនដល់ព្រះរាជា និងប្រជារាស្ត្រទាំងឡាយ។

ខណៈដែលមហាជនកំពុងថ្វាយបង្គំ ចំពោះសមណព្រាហ្មណ៍ នៅពេលនោះ នារទព្រហ្ម ក្លែងជាព្រះឥសីមួយអង្គ ដ៏វិសេសបំផុត ទ្រង់យាងតាមអាកាស កាយព្រះអង្គបញ្ចេញពន្លឺយ៉ាងចិញ្ចែញចិញ្ចាចប្រៀបបាននឹងពន្លឺខែពេញវង់ ហើយទ្រង់ចូលទៅកាន់ព្រះរាជវាំង ដែលវិចិត្រហើយដោយខ្លឹមច័ន្ទន៍ ហើយទ្រង់ស្ថិតនៅលើអាកាសក្នុងទីចំពោះមុខនៃព្រះបាទ ឥង្គតិ ។

ព្រះនាង រុស្សា ក៏ក្រាបថ្វាយបង្គំចំពោះព្រះមុនីឥសី។ ដោយអានុភាពនៃព្រះមុនីឥសី ព្រះរាជាមិនអាចទ្រង់គង់នៅសុខក៏ទ្រង់យាងចេញមក ហើយទ្រង់សួរទៅកាន់ព្រះមុនីឥសីថាៈ

"បពិត្រព្រះមុនីឥសី ទ្រង់មានរូបសម្បត្តិស្រស់ស្អាតដូច

ជាទេវតា ហើយទ្រង់មានរស្មីផ្សាយចេញពីព្រះកាយ ដូចជារស្មីនៃព្រះច័ន្ទញ៉ាំងរាជវាំងទាំងមូលឱ្យភ្លឺប្រាល តើទ្រង់យាងមកពីទីណា? ហើយមានព្រះនាមអ្វីដែរ?" ។

"បពិត្រមហារាជ អាត្មាមកពីឋានសួគ៌ កាយរបស់អាត្មាមានរស្មីចែងចាំងផ្សាយទៅគ្រប់ទិសដូចជារស្មីនៃព្រះច័ន្ទ អាត្មាមាននាមថា នារទៈ ឬ កស្សបៈ" ។

"អាចយាងទៅមកតាមអាកាស ហើយទ្រង់គង់លើអាកាសបាន នេះពិតជាអស្ចារ្យក្រៃលែង បពិត្រព្រះមុនីឥសី តើអានុភាពទាំងនេះបានមកពីណា?" ។

"បពិត្រមហារាជ ក្នុងអតីតៈ អាត្មាបានចម្រើននូវធម៌៤ប្រការគឺ និយាយពាក្យពិត ស្វែងយល់ពីសច្ចធម៌ សង្រួមឥន្ទ្រីយ៍ទាំង៦ និងបរិច្ចាគទាន។ ដោយសារកុសលផលបុណ្យទាំងនេះទើបអាត្មាមានតេជានុភាពនេះ ហើយអាត្មាអាចញ៉ាំងសេចក្តីប្រាថ្នាដែលមានក្នុងចិត្តរបស់អាត្មាឱ្យសម្រេចបាន។

"បពិត្រព្រះមុនីឥសី លោកពោលអំពីផលបុណ្យ ដែលលោកបានសាងមកដូចជាមានទំនុកចិត្តណាស់ បើសិនជាអំពើល្អពិតជាឱ្យផលមែន ចូរលោកបញ្ជាក់ឱ្យច្បាស់ទៅមើល"។

"បពិត្រមហារាជ ព្រះអង្គទ្រង់ដូចជាមានសង្កាច្រើនណាស់





សូមព្រះអង្គប្រាប់អាត្មាមក អាត្មានឹងជម្រះនូវសេចក្តីសង្ស័យដោយហេតុផល តាមច្បាប់កម្មផលដ៏សម្បូរបែប" ។

"បពិត្រព្រះមុនីឥសី ខ្ញុំព្រះករុណានឹងលើកជាសំណួរ ខ្ញុំព្រះករុណា ឮគេនិយាយថា ទេវតាពិតជាមាន មាតាបិតាពិតជាមាន បច្ចុប្បន្នលោក និងលោកខាងមុខពិតជាមាន តើនេះជាការពិតឬ?" ។

"បពិត្រមហារាជ នេះជាការពិតទាំងអស់ ដែលថា ទេវតាពិតជាមាន មាតាបិតាពិតជាមាន លោកនេះ និងលោកខាងមុខពិតជាមាន។ដោយសារមនុស្សលោកមាន រាគៈ តណ្ហា និងអវិជ្ជា គ្របដណ្តប់ ដូច្នេះពួកគេមើលមិនឃើញ និងមិនដឹងថាជាតិខាងមុខពិតជាមានក្រោយពេលស្លាប់" ។

"ព្រះរាជាទ្រង់សើចដាក់ព្រះមុនីឥសី ហើយទ្រង់ព្រះតម្រាស់ថា បពិត្រព្រះមុនីឥសី បើលោកជឿថា ជាតិខាងមុខមានអ៊ីចឹងសូមលោកឱ្យខ្ញុំព្រះករុណាខ្ចីប្រាក់ ៥០០ កហាបណៈ សិនចាំជាតិក្រោយខ្ញុំព្រះករុណាសងវិញ១០០០កហាបណៈចុះ" ។

"បពិត្រមហារាជ ប្រសិនបើ ព្រះអង្គជាបុគ្គលសម្មាទិដ្ឋិជាកតញ្ញូជន និងជាអ្នកបរិបូណ៌ដោយសីល អាត្មានឹងឱ្យព្រះអង្គខ្ចីប្រាក់៥០០កហាបណៈនោះ ប៉ុន្តែ ព្រះអង្គជាបុគ្គលពាល

ជាបុគ្គលមិច្ឆាទិដ្ឋិ ព្រះអង្គនឹងទៅកើតក្នុងនរកបន្ទាប់ពីសោយទីវង្គតទៅ ដោយគ្មានប្រាក់យកទៅតាម អ៊ីចឹងតើនរណានឹងទៅតាមយកប្រាក់ពីព្រះអង្គចំនួន ១០០០ កហបណៈនៅឋាននរកនោះ?៉ ។

៉បពិត្រមហារាជ នៅឋានមនុស្ស បុគ្គលជាបណ្ឌិតអនុញ្ញាតឱ្យខ្ចីប្រាក់សម្រាប់តែបុគ្គលជាសម្មាទិដ្ឋិ ជាអ្នកមានសីលជាអ្នកមានវិរិយភាព និងជាកតញ្ញូជន ព្រោះពួកគេច្បាស់ជាសងប្រាក់វិញដោយថែមទាំងការប្រាក់ទៀត៉ ។

នៅពេលដែល នារទព្រហ្ម ញ៉ាំងព្រះបាទ ឥង្គតិ ឱ្យជ្រះចាកមិច្ឆាទិដ្ឋិហើយ ព្រះរាជាទ្រង់គង់នៅជាតុណ្ហីភាព។ ព្រះព្រហ្ម ជាពោធិសត្វ ដោយតេជានុភាពរបស់លោក ទ្រង់ញ៉ាំងមហាជនទាំងមូលក្នុងនគរមិថិលា ដែលមានប្រមាណ៧យោជន៍ (៥៦ម៉ែល៍)ដោយជុំវិញបានឮនូវអ្វីដែលលោកបានដេញដោលជាមួយនឹងព្រះរាជា។ មហាជនមានសេចក្តីត្រេកអរជាពន់ពេកដែលដឹងថា ព្រះបាទ ឥង្គតិ ទ្រង់លះបង់នូវមិច្ឆាទិដ្ឋិ ក្រោយពីបានស្តាប់ព្រះធម៌ទេសនារបស់នារទព្រហ្ម។

## ការបង្ហាញឋាននរក និងឋានសួគ៌

នារទព្រហ្ម បានញ៉ាំងព្រះបាទ ឥង្គតិ ឱ្យប្រាសចាក





មិច្ឆាទិដ្ឋិ ដោយរៀបរាប់ពីរឿងរ៉ាវនៅក្នុងឋាននរក ហើយទ្រង់ជម្រុញទឹកព្រះទ័យព្រះរាជាដោយលើកពីរឿងរ៉ាវនៅឋានសួគ៌។

៉បពិត្រមហារាជ នៅពេលព្រះអង្គលាចាកលោកនេះទៅព្រះអង្គនឹងបានឃើញនូវសត្វនរកដែលត្រូវបាន សត្វក្អែក សត្វត្មាត សត្វស្វាំង និងសត្វឆ្កែខាំចឹកហែកស៊ី។ រាងកាយរបស់ព្រះអង្គនឹងពោរពេញទៅដោយឈាម ព្រោះត្រូវបានសត្វទាំងនោះចឹកខាំ និងហែកជាកំណាត់ៗ។ ដូចនេះ តើនរណាទៅហ៊ានឹងទៅទារប្រាក់១០០០កហបណៈពីព្រះអង្គ?៉។

៉បពិត្រមហារាជ ប្រសិនបើ ព្រះអង្គមិនទៅកើតក្នុងនរកនោះទេ ព្រះអង្គនឹងទៅកើតក្នុងនរកមួយទៀតឈ្មោះថា លោកន្តរនរក។ នរកនេះតែងងងឹតជាដរាប ពុំមានពន្លឺព្រះអាទិត្យ ព្រះច័ន្ទឡើយ គឺងងឹតសូន្យឈឹង និងមានសម្លេងគួរឱ្យភ័យខ្លាច។ បើព្រះអង្គ រងទុក្ខវេទនានៅក្នុងនរកនេះម្លឹងៗ តើនរណាទៅហ៊ានឹងទៅទារប្រាក់១០០០កហបណៈពីព្រះអង្គ?៉ ។

៉បពិត្រមហារាជ បើព្រះអង្គមិនទៅកើត ក្នុងលោកន្តរនរកទេ ព្រះអង្គនឹងទៅកើតក្នុងនរកមួយទៀត ទីនោះមានឆ្កែដ៏កំណាចធំៗពីរក្បាល មានធ្មេញដែក នឹងខាំស៊ីសាច់របស់ព្រះអង្គ រាងកាយទ្រង់នឹងពោរពេញដោយឈាម និង ដាច់រហែក

ខ្ទេចខ្ទី ជាច្រើនបំណែក។ ដូចនេះ តើនរណាទៅហ៊ុំនឹងទៅទារប្រាក់១០០០កហបណៈពីព្រះអង្គ?”។

“បពិត្រមហារាជ បើព្រះអង្គមិនទៅកើតក្នុងនរកនោះទេ ព្រះអង្គនឹងទៅកើតក្នុងនរកមួយទៀត។ ទីនោះមានអ្នកយាមទ្វារនរកពីរនាក់នឹងចាប់ព្រះអង្គចង ហើយយកលំពែង និងព្រួញចាក់ទម្លុះរាងកាយរបស់ព្រះអង្គ ពុះច្រៀកជាពីរបំណែក ព្រលាត់ពោះ បកស្បែកព្រះអង្គ។ ដូចនេះ តើនរណាទៅហ៊ុំនឹងទៅទារប្រាក់១០០០កហបណៈពីព្រះអង្គ?”។

“បពិត្រមហារាជ បើព្រះអង្គមិនកើតក្នុងនរកនោះទេ ព្រះអង្គនឹងទៅកើតក្នុងនរកមួយទៀត។ នៅទីនោះ មានលំពែង ព្រួញ ផ្លែសន្ទូច និងផ្លែសម នឹងធ្លាក់ជាភ្លៀងចំលើសីសៈរបស់ព្រះអង្គ។ ថ្មដែលដុតដោយភ្លើងក្តៅក្រហមឆ្អៅ ដុំលោហធាតុដ៏ក្តៅក៏នឹងធ្លាក់លើព្រះអង្គដែរ។ ហើយខ្យល់អគ្គីនឹងបក់បោកមកលើព្រះអង្គទៀត ព្រះអង្គនឹងរងទុក្ខវេទនាគ្មានពេលសម្រាក។ នៅពេលព្រះអង្គរងទុក្ខវេទនាម្លឹងៗ តើនរណាទៅហ៊ុំនឹងទៅទារប្រាក់១០០០កហបណៈពីព្រះអង្គ?”។

“បពិត្រមហារាជ បុរសដែលប្រព្រឹត្តខុសក្នុងប្រពន្ធអ្នកដទៃ និង ភរិយាដែលផិតប្តី នឹងឡើងដើមឈើដែលពោរពេញដោយបន្លាដែកយ៉ាងស្រួច ហើយត្រូវបន្លាទាំងនោះមុតរយះស្បែក និងសាច់ដោយជាបំណែកៗ ម្យ៉ាងទៀត នឹងត្រូវគេយកលំពែងដ៏មុតស្រួចចាក់ទម្លុះរាងកាយ រហូតដល់រាងកាយទាំងមូលប្រេទ្បាក់ប្រេទ្បូសដោយឈាម ហើយត្រូវគេបង្ខំឱ្យឡើងរកាដែកទៀត។ ការធ្វើទារុណកម្មទាំងនេះ នឹងធ្វើឱ្យព្រះអង្គរងទុក្ខវេទនាយ៉ាងក្រៃលែងស្ទើររកពេលដកដង្ហើមគ្មាន។ នៅពេលព្រះអង្គរងទុក្ខវេទនាម្លឹងៗ តើនរណាទៅហ៊ុំនឹងទៅទារប្រាក់១០០០កហបណៈពីព្រះអង្គ?” ។

“បពិត្រមហារាជ ដើមឈើទាំងនោះសុទ្ធតែមានកាំបិតដាវ និងបន្លាដែកស្រួចៗ ហើយខ្ពស់ទល់នឹងពពក។ ព្រះអង្គត្រូវតែឡើងលើដើមឈើទាំងនោះ ហើយព្រះអង្គនឹងធ្លាក់ចុះទៅក្នុងជ្រោះមួយឈ្មោះថា វេតរនី។ ទឹកជ្រោះនោះក្តៅណាស់អាចរំលាយលោហធាតុបាន ហើយមានស្លឹកផ្កាឈូកដ៏មុតស្រួចប្រៀបបាននឹងកំបិត។ ព្រះអង្គនឹងត្រូវហែលក្នុងទឹកជ្រោះនោះយ៉ាងវេទនាជាទីបំផុត។ នៅពេលព្រះអង្គរងទុក្ខវេទនាម្លឹងៗ តើនរណាទៅហ៊ុំនឹងទៅទារប្រាក់១០០០ កហបណៈពីព្រះអង្គ?”។

“ក្រោយពីបានឮនូវសភាពដ៏គួរឱ្យភ័យខ្លាចនៃឋាននរក

នីមួយៗហើយ ព្រះបាទ ឥង្គតិ មានការភ័យខ្លាច និងតក់ស្លុតយ៉ាងខ្លាំង ហើយក៏បានពោលពាក្យសូមទោសដូចខាងក្រោម ៖

"បពិត្រព្រះមុនីឥសី បន្ទាប់ពីបានសណ្តាប់នូវការរៀបរាប់របស់លោកអំពីឋាននរកទាំងឡាយមក ខ្ញុំពិតជាមានការតក់ស្លុតណាស់ ខ្ញុំមានអារម្មណ៍ដូចជាដើមឈើ ដែលត្រូវបានគេផ្តាច់ឫសដូច្នោះឯង ខ្ញុំហាក់ភាន់ភាំងស្មារតី មិនដឹងជាត្រូវទៅខាងណាមកណាទេ ខ្ញុំមានការសោកស្តាយណាស់ចំពោះទង្វើមិនគប្បីដែលខ្ញុំបានធ្វើ។ បពិត្រព្រះមុនីឥសី ខ្ញុំសូមដល់នូវលោកជាទីពឹងជាទីសក្ការៈ សូមមេត្តាបង្ហាញផ្លូវសួគ៌ដល់ខ្ញុំផង។"

"បពិត្រមហារាជ នៅក្នុងអតីតកាល ព្រះបាទ ធតរដ្ឋ ព្រះបាទ វេស្សមិត្ត ព្រះបាទ អដ្ឋក ព្រះបាទយមទគ្គិ ព្រះបាទ ឧសិន្នរ និងព្រះបាទ សិវិរាជ ធ្លាប់ជាពុទ្ធសាសនូបត្ថម្ភ ក៏បានទំនុកបំរុងបច្ច័យបួនដល់សមណព្រាហ្មណ៍ទាំងឡាយ ក្រោយពីស្លាប់ទៅបានទៅកើតក្នុងសុគតិភព ។ បពិត្រមហារាជ ចូរព្រះអង្គវៀរចាកនូវអំពើបាបទាំងពួង ហើយបំពេញតែអំពើល្អគ្រប់យ៉ាងមានដូចជា៖ ផ្តល់ទឹក និងអាហារដល់ជនទុគ៌តអត់ឃ្លាន ឱ្យផ្កា ទឹកអប់ សំលៀកបំពាក់ ទ្រនាប់ជើង ឆ័ត្រ ។ល។





ដល់ជនដែលត្រូវការរៀងរាល់ថ្ងៃ។ ចូរផ្តល់នូវទ្រព្យសម្បត្តិដល់ជនចូលនិវត្តន៍ទាំងឡាយ ដែលធ្លាប់បម្រើព្រះអង្គ ដូចកាលដែលគេនៅធ្វើការបម្រើព្រះអង្គបាន។ ចូរព្រះអង្គថែរក្សានូវវិញ្ញាណកទ្រព្យ និងអវិញ្ញាណកទ្រព្យចាស់ៗទាំងឡាយរបស់ប្រជារាស្ត្រកុំបីឱ្យវិនាសឡើយ"។

## សេចក្តីប្រៀបធៀបនូវយានដែលបំពេញនូវបំណងប្រាថ្នាគ្រប់យ៉ាង

ព្រះពោធិសត្វ នារទព្រហ្ម ក្រោយពីបានរៀបរាប់ពីការឱ្យទានរក្សាសីលដល់ព្រះបាទ ឥង្គតិ រួចហើយក៏ទ្រង់ពិពណ៌នាសេចក្តីប្រៀបធៀបអំពីរថ ដើម្បីឱ្យព្រះរាជាទ្រង់ជ្រាបកាន់តែច្បាស់ ។

"បពិត្រមហារាជ ព្រះកាយរបស់ព្រះអង្គទុកដូចជាតួនៃរថ ចិត្តរបស់ព្រះអង្គជា នាយសារថី សេចក្តីមេត្តារបស់ព្រះអង្គជាភ្លៅ (ស្នូល សំរាប់បង្វិល)នៃរថ ការរិះគន់ និងការបែងចែកខុសត្រូវជាទម្រនៃរថ ព្រះបាទារបស់ព្រះអង្គជាកង់នៃរថ ព្រះហស្តរបស់ព្រះអង្គជា បង្កាន់ដៃនៃរថ ពោះរបស់ព្រះអង្គជាដុំនៃរថ រីឯព្រះសូរសៀងរបស់ព្រះអង្គគឺជា សម្លេងនៃរថ ។

"បពិត្រមហារាជ វាចាប្រកបដោយសច្ចៈរបស់ព្រះអង្គ គឺ

ជាឯកសណ្ឋាននៃរថ វាចាដែលនាំឱ្យបានសុខ ឬវៀរចាកការញុះញង់គឺជាទង់ជ័យ ដែលដាក់នៅខាងមុខនៃរថ វាចាដ៏ស្រទន់ប្រកបដោយមេត្តារបស់ព្រះអង្គ គឺជាបំណែកនៃរថ ដែលផ្គុំចូលគ្នាយ៉ាងល្អ វាចាដ៏ខ្ពង់ខ្ពស់ថ្លៃថ្នូររបស់ព្រះអង្គ គឺជាការរចនានៃរថ ជំនឿ និងភាពម៉ឺងម៉ាត់របស់ព្រះអង្គ គឺជារថ ដែលគេបានធ្វើហើយដោយល្អ ភាពសុភាពរាបសារ និងការចេះបង្អោនខ្លួនរបស់ព្រះអង្គគឺជាកន្លាស់ ឬម្ហូល ដែលគេដាក់ភ្ជាប់ទៅនឹងភ្លៅនៃរថ ភាពចាស់ទុំនៃឥន្ទ្រីយ៍ និងការបន្ទាបខ្លួនរបស់ព្រះអង្គ គឺជាទូកនៃរថ និងការរក្សានូវសីលរបស់ព្រះអង្គ គឺជាខ្សែចងនឹមទៅនឹងទូកនៃរថយ៉ាងនោះឯង" ។

"បពិត្រមហារាជ ការមិនខឹងក្រោធ ការមិនសម្លាប់ ការមិនបៀតបៀន និងការចេះអប់រំខ្លួន ទុកដូចជាស្វេតឆ័ត្រដែលគេដាក់នៅខាងមុខនៃរថយ៉ាងនោះដែរ។ ហើយបញ្ញា ដ៏វិសាលប្រៀបដូចជាបង្អែកខ្នង សេចក្ដីស្ងប់ចិត្ត ប្រៀបដូចជាគ្រឿងកម្រាល ការចេះស្គាល់កាលៈទេសៈប្រៀបដូចជាគ្រឿងអលង្ការដ៏វិសេសនៃរថ ភាពក្លាហានប្រៀបដូចជាចន្ទល់ចំពាមដែលដាក់នៅក្រោមនឹម សតិប្រៀបដូចជាលំពែងនៃរថ និង សមាធិប្រៀបដូចជាខ្សែរថដែលទាញដោយនាយសារថីយ៉ាងនោះដែរ" ។





"បពិត្រមហារាជ វាគ្រាន់តែប្រៀបដូចជា ព្រះអង្គកាលយាងធ្វើទស្សនកិច្ច បន្ទាប់ពីបានរៀបចំសេះ និងរថយ៉ាងល្អហើយ យ៉ាងណាមិញ ដំណើរទៅកាន់ព្រះនិព្វានអាចប្រព្រឹត្តទៅបានលុះត្រាតែ យើងបានអប់រំទូន្មាន និងសម្អាតចិត្តឱ្យបានស្អាតផូរផង់។ តណ្ហាក្នុងបញ្ចកាមគុណជាផ្លូវនាំទៅកាន់អបាយភូមិ។ អប់រំកាយវាចា និងចិត្ត គឺជាផ្លូវដ៏ត្រឹមត្រូវឆ្ពោះទៅកាន់សុគតិភព។ នៅពេលដែលរថគឺកាយកំពុងតែធ្វើដំណើរនៅលើផ្លូវដែលប្រកបដោយ រូប សំឡេង ក្លិន រស និងផោដ្ឋព្វ ពេលនោះបញ្ញាដើរតួនាទីសំខាន់ណាស់ ក្នុងការតម្រង់ទិសដៅឱ្យបានត្រឹមត្រូវ។ រីឯចិត្តរបស់ព្រះអង្គគឺជានាយសារថីនៃរថ គឺកាយនេះឯង។

"បពិត្រមហារាជ ពេលដែលព្រះអង្គបានហ្វឹកហាត់អប់រំចិត្ត ឬមានសតិសម្បជញ្ញៈល្អហើយ ព្រះអង្គនឹងមិនធ្លាក់ទៅក្នុងអបាយភូមិឡើយ រថរបស់ព្រះអង្គនឹងនាំទៅកាន់សុគតិភព" ។

នារទព្រហ្ម បានទូន្មានព្រះបាទ ឥង្គតិ ដូចបានរៀបរាប់មកខាងលើនេះហើយ ក៏បានញ៉ាំងព្រះរាជាឱ្យមាននូវសម្មាទិដ្ឋិ វៀរចាកនូវបាបមិត្ត សេពគប់សប្បុរស រក្សាសីល និងញ៉ាំងសេចក្ដីព្យាយាមក្នុងកុសលធម៌ឱ្យកើតឡើង។ នារទព្រហ្ម ក៏បាន

ពោលសរសើរចំពោះព្រះនាង រុស្សា ហើយផ្តល់នូវឱវាទចំពោះអគ្គមហេសីនៃព្រះរាជាព្រមទាំងស្រីស្នំទាំងឡាយ។ បន្ទាប់មកក៏យាងទៅកាន់ព្រហ្មលោកវិញ ដោយសម្តែងនូវបាដិហារ្យឱ្យមហាជនទាំងឡាយបានឃើញ។

សរុបជាតកនេះ ព្រះបាទ ឥង្គតិ ក្នុងកាលនោះបានមកជាឧរុវេលកស្សបៈ អលាតៈ បានមកជាទេវទត្ត សុនាម បានមកជា ភទ្ទសី វិជយៈ បានមកជា ព្រះសារីបុត្ត បុរសទុគ៌តពីជកៈបានមកជាព្រះមហាមោគ្គល្លាន កស្សបៈតាបស បានមកជាសុនក្ខត្តរាជកុមារ នៃនគរលិច្ឆវី រុស្សាទេវី បានមកជាព្រះអានន្ទរីឯនារទព្រហ្មក្នុងកាលនោះ គឺជាតថាគតហ្នឹងឯង។

### ៣.ហេតុអ្វីអ្នកធ្វើបាបកាន់តែមាន ឯអ្នកធ្វើល្អបែរជាក្រីក្រទៅវិញ?

សម័យបច្ចុប្បន្ន មានមនុស្សជាច្រើននាក់ ដែលធ្វើអំពើអាក្រក់តែគេកាន់តែមាន ហើយក៏មានមនុស្សមួយចំនួនដែរដែលធ្វើតែអំពើល្អ ហើយចេះតែក្រទៅៗ។

នៅក្នុងភូមិមួយនៃប្រទេសភូមាមានបុរសម្នាក់ឈ្មោះ **បាខេត** ធ្វើតែជំនួញខុសច្បាប់ ប៉ុន្តែគាត់កាន់តែមានទៅៗ មានផ្ទះវីឡា និងឡាន ទំនើបៗ ។ ចំណែកបុរសម្នាក់ឈ្មោះថា **ហ្លាក់អោង** វិញគឺជាគ្រូបង្រៀននៅវិទ្យាល័យ គាត់ព្យាយាមបង្រៀន



កម្ម អ្នកសាងលោកពិត

សិស្ស ដោយការយកចិត្តទុកដាក់ល្អ មិនតែប៉ុណ្ណោះគាត់ជាមនុស្សរក្សាសីលទៀត ប៉ុន្តែគាត់មានជីវភាពខ្សត់ខ្សោយណាស់រកព្រឹកខ្វះល្ងាច។ តើយើងគួរពន្យល់សេចក្តីនេះយ៉ាងដូចម្តេចទៅ?

យើងអាចវិភាគសេចក្តីនេះបានយ៉ាងងាយ ដោយមើលទៅលើគោលការណ៍សេដ្ឋកិច្ច។ ប្រសិនបើ **បាខេត** ធ្វើជំនួញធំដុំ ទោះបីជា កុសលក្តី អកុសលក្តី នោះគេនឹងទទួលបានផលច្រើន ឬគេនឹងក្លាយជាអ្នកមាន។ ចំណែកឯ **ហ្លាក់អោង** វិញប្រាក់ខែគ្រូបង្រៀនគឺតិចតួច ហើយម្យ៉ាង គាត់មិនមានការងារក្រៅបន្ថែមទៀត ដូច្នេះ គាត់នៅតែក្រីក្រ។ ប្រសិនបើគាត់ប្រឹងប្រែងបន្ថែមទៀត គាត់អាចក្លាយជាគ្រូម្នាក់ដ៏ល្បីល្បាញ បើកបង្រៀនគួក្រៅម៉ោង ឬបង្រៀនសិស្សតាមផ្ទះជាដើម គាត់ប្រាកដជាមានជីវភាពធូរធាមិនខាន។

ប៉ុន្តែ បើយើងនិយាយពីច្បាប់កម្មវិញ **បាខេត** គឺកំពុងតែសន្សំនូវអកុសលកម្មយ៉ាងច្រើន ដែលនឹងនាំគាត់ទៅកាន់អបាយភូមិក្រោយពីស្លាប់ទៅ ។ ជីវិតមនុស្សមិនវែងប៉ុន្មានឡើយបន្ទាប់ពីសោយសុខក្នុងគំនរមាសប្រាក់បានប៉ុន្មានឆ្នាំមក បើយើងត្រូវធ្លាក់ទៅសោយទុក្ខ ក្នុងអបាយភូមិអស់រយៈពេលជា

ច្រើនកប្ប អ៊ីចឹងតើមានន័យអ្វី ដូច្នេះយើងគួរជៀសវាងឱ្យបាន។ ចំណែក **ហ្លាក់អោង** វិញគឺកំពុងតែសាងសន្សំនូវអំពើល្អដែលជាហេតុនាំទៅកាន់សុគតិភព។ យើងគួរសម្លឹងមើលឱ្យបានវែងឆ្ងាយ មិនត្រឹមតែរៀបចំជីវិតរបស់យើងឱ្យបានល្អក្នុងបច្ចុប្បន្នប៉ុណ្ណោះទេ តែត្រូវរៀបចំដំណើរបរលោករបស់យើងឱ្យបានល្អផង។ ដូចយើងធ្លាប់បានសិក្សានៅក្នុង នារទជាតក ដែលនិយាយពីការឱ្យផលរបស់កម្មប្លែកៗគ្នា។ នៅក្នុងជាតិមួយនោះ បុរសទុគ៌តឈ្មោះពីជកៈ បានបាត់គោរបស់គាត់ ខណៈពេលកំពុងដើររកក្នុងព្រៃ បានជួបនឹងភិក្ខុមួយអង្គដែលវង្វេងផ្លូវ ហើយបានសួរទៅគាត់ម្តងហើយម្តងទៀត ពីជកៈតបទៅវិញទាំងកំហឹងថា អ្នកឯងជាកូនរបស់ទាសកទេដឹង បានជានិយាយពាក្យមិនពិរោះសោះ? គ្រាន់តែពោលពាក្យអសុរោះប៉ុណ្ណឹងសោះ ពីជកៈបានញ៉ាំងអកុសលកម្មតាមវចីទ្វារឱ្យកើតឡើង។

ប៉ុន្តែ អកុសលកម្មនេះមិនទាន់ឱ្យផលភ្លាមៗទេ តែវាស្ថិតនៅក្នុងវិថីចិត្តរបស់គាត់ ដូចជារងើកភ្លើងរុំព័ទ្ធដោយផេះ ។ រហូតដល់កុសលកម្មរបស់គាត់អន់ថយ ផលនៃអកុសលកម្មនោះ ក៏ចាប់ផ្តើមឱ្យផលម្តង ហើយក៏បានមកកើតក្នុងត្រកូលនៃនាងទាសី មានឈ្មោះថា ពីជកៈ នេះឯង។ បើទោះជា ពីជកៈ





ធ្វើតែបុណ្យយ៉ាងណាក៏ដោយ អកុសលវិបាក មិនទាន់អស់ គាត់នៅតែក្រដដែល។

\+ + +

នៅក្នុងក្រុងរាជគ្រឹះ ចុន្ទ អ្នកសម្លាប់ជ្រូក រស់នៅជិតវត្តវេឡុវ័ន។ រដូវប្រមូលផលស្រូវមកដល់ គាត់តែងតែជិះរទេះពីភូមិមួយទៅភូមិមួយ ដើម្បីដូរស្រូវយកកូនជ្រូកទៅចិញ្ចឹមនៅ ទីធ្លាក្រោយផ្ទះរបស់គាត់។ ពេលជ្រូកធំធាត់ហើយ ជារៀងរាល់ថ្ងៃ គាត់តែងតែសម្លាប់ជ្រូកមួយក្បាលយ៉ាងព្រៃផ្សៃជាទីបំផុត។ គាត់ចងជើងជ្រូកទៅនឹងបង្គោលទាំងបួន ហើយផ្តេកទៅនឹងដីរួចហើយចំហមាត់វាដោយដោតឈើ ហើយគាត់វាយខ្លួនជ្រូកដោយដំបងដើម្បីឱ្យសាច់វាទន់។

បន្ទាប់មក គាត់ចាក់ទឹកក្តៅទៅក្នុងមាត់ជ្រូក ទាល់តែទឹកដែលចេញតាមគូថវាថ្លាល្អ។ ហើយទើបចាក់ទឹកក្តៅលើខ្លួនវាដើម្បីកោសស្បែកខាងក្រៅ។ រួចមកគាត់កាត់កជ្រូក ហើយយកឈាមដាក់ក្នុងធុង គាត់យកសាច់ដែលល្អបំផុតជ្រលក់ក្នុងឈាម។ គាត់យកសាច់ទាំងនោះឱ្យប្រពន្ធគាត់ធ្វើម្ហូបរៀងរាល់ថ្ងៃ ហើយសាច់ដែលនៅសល់គាត់យកទៅលក់នៅឯផ្សារ។

នាយ ចុន្ទ រស់នៅដោយជីវភាពយ៉ាងនេះអស់រយៈពេលជាង៥០ឆ្នាំ។ ដោយអកុសលកម្មដែលគាត់បានសាងមកច្រើនពេក ថ្ងៃមួយគាត់ធ្លាក់ខ្លួនឈឺ ភ្លើងក្នុងអវិចីនរក បណ្ដាលឱ្យឆេះរលាកពោះវៀនរបស់គាត់។ ភ្លើងនេះដុតរោលពោះវៀនរបស់គាត់ខ្លាំងជាងពេលគាត់យកទឹកក្ដៅចាក់ចូលក្នុងពោះវៀនជ្រូកទៅទៀត។ ដោយសារតែក្ដៅខ្លាំងពេក គាត់ក៏យំស្រែកយ៉ាងខ្លាំងដូចជាសំឡេងនៃជ្រូក ហើយគាត់លូនក្រាបទៅលើកម្រាលឥដ្ឋប្រៀបដូច ពេលដែលគាត់ចាប់ចងដៃជើងជ្រូកភ្ជាប់នឹងបង្គោលយ៉ាងនោះឯង។ ប្រពន្ធ និង កូនរបស់គាត់ឮសំឡេងដូចនោះ មានការអាម៉ាសមុខយ៉ាងខ្លាំង ហើយបានអង្វរឱ្យនាយ ចុន្ទ ឈប់យំស្រែកទៀតខ្មាស់គេណាស់ ប៉ុន្តែ គាត់មិនបានឈប់យំស្រែកឡើយ ហើយចេះតែលូនទៅលូនមកផងយំផងរហូតអស់៧ថ្ងៃ។

ថ្ងៃមួយពេល ភិក្ខុសង្ឃកំពុងនិមន្តបិណ្ឌបាតកាត់ទីនោះ លោកបានឮសំឡេងយំស្រែក ហើយក៏បានទូលព្រះដ៏មានព្រះ-ភាគថា "បពិត្រព្រះអង្គដ៏ចម្រើន នាយ ចុន្ទ នេះ បានបិទទ្វារសម្លាប់ជ្រូកក្នុងផ្ទះរបស់ខ្លួនអស់រយៈពេល៧ថ្ងៃហើយ ប្រហែលជាគាត់រៀបចំធ្វើពិធីអ្វីមួយទេដឹង ?ប៉ុន្តែវាពិតជាសាហាវព្រៃផ្សៃ





ណាស់ សម្លាប់ជ្រូកទាំងយប់ថ្ងៃដូចនេះ" ។ ព្រះបរមគ្រូទ្រង់តបទៅភិក្ខុទាំងឡាយថា "ម្នាលភិក្ខុទាំងឡាយ មិនមែននាយចុន្ទកំពុងតែសម្លាប់ជ្រូកទេ គឺគាត់កំពុងតែស្រែកយំរងទុក្ខវេទនាដោយអាស្រ័យអកុសលកម្ម ដែលគាត់បានសាងនោះឯង ភ្លើងអវិចីនរក បានដុតរោលពោះវៀនគាត់អស់រយៈពេល៧ថ្ងៃមកហើយ។ ព្រោះតែទ្រាំមិនបាន គាត់បានស្រែកយំដូចជាជ្រូកដូច្នេះ ហើយថ្ងៃនេះគាត់បានស្លាប់បាត់ទៅហើយ ឥឡូវនេះកំពុងតែសោយទុក្ខក្នុងនរកអវិចី" ។

## អំពើអាក្រក់នឹងមិនឱ្យផលល្អ

នៅពេលខ្ញុំផ្ដល់បាឋកថាមួយស្ដីពីកម្ម ខ្ញុំតែងតែនិទានរឿងមួយ។ នៅក្នុងភូមិមួយ មានមិត្តភក្តិពីរនាក់ មួយឈ្មោះ បា (Mr. Ba) និង ហ្លា (Mr. Hla) បានលេងល្បែងបញ្ជល់មាន់ និងល្បែងបញ្ជល់គោ បានផឹកស្រា និងលេងបៀរ។ គាត់បានធ្វើអំពើអាក្រក់ច្រើនណាស់។ លោក ហ្លា គឺជាអ្នកកាន់សាសនា។ គាត់បានទៅវត្ត និងចេតិយ រក្សាឧបោសថ ហើយបានបម្រើព្រះភិក្ខុសង្ឃ ។

នៅថ្ងៃអាទិត្យមួយ ពួកគាត់បានឡើងទៅលើភ្នំជាមួយគ្នាដើម្បីដកផ្សិត។ នៅត្រង់ទីកន្លែងចោត ទាំងពីរនាក់ក្នុងចំណោមពួកគាត់បានរអិលដួល។ លោក ហ្លា មានអារម្មណ៍ភ័យ ហើយ

ថ្វាសរបស់គាត់ប៉ះចេញឈាម។ លោក បា បានរមៀលពីរបីត្រឡប់ ហើយទៅទើលើគុម្ពឫស្សី។ នៅពេលនោះ គាត់បានបើកភ្នែក គាត់បានឃើញមាសបីដុំ ហើយបានរើសយក។ លោក ហ្លា មិន សប្បាយចិត្តទេ ។ ពេលនោះ គាត់បានឃើញភិក្ខុសង្ឃមួយអង្គ ស្រគត់ស្រគំ ហើយបានថ្វាយបង្គំ ហើយពោលថា បពិត្រព្រះ តេជគុណដ៏ចម្រើន ខ្ញុំព្រះករុណាបានធ្វើនូវអំពើល្អជាច្រើន ដូច ជាគោរពវត្តអារាម រក្សាសីល និង បម្រើព្រះភិក្ខុសង្ឃ ។ ប៉ុន្តែ នៅពេលដែលខ្ញុំព្រះករុណាដួល នៅឯចំណោតឯជើងភ្នំ ខ្ញុំព្រះ ករុណាបានបែកថ្វាស។ មិត្តភក្តិខ្ញុំព្រះករុណា គឺលោក បា បាន ប្រព្រឹត្តអំពើអកុសលជាច្រើន លេងល្បែងបញ្ជល់មាន់ និងល្បែង បញ្ជល់គោ លេងបៀរ និង ផឹកស្រា។ ប៉ុន្តែ នៅពេលដែលគាត់ ដួល។ គាត់រើសបានមាសបីដុំ ។ ខ្ញុំព្រះករុណាមិនសប្បាយចិត្ត ទេលោកម្ចាស់។

ព្រះភិក្ខុសង្ឃ បានសម្លឹងមើលដោយទិព្វចក្ខុ ហើយបាន ពោលថា ម្នាលឧបាសក នៅក្នុងអតីតកាល អ្នកបានឈ្លោះជា មួយបុរសម្នាក់នោះ និងបានសម្លាប់គាត់។ អកុសលកម្មនោះឱ្យ ផលនៅពេលដែលអ្នកដួល។ អ្នកបំរុងតែនឹងស្លាប់ ប៉ុន្តែអំពើល្អ របស់អ្នកបានការពារអ្នក។ ដូច្នេះ បានត្រឹមតែបែកថ្វាសប៉ុណ្ណោះ។





ម្យ៉ាងវិញទៀត លោក បា សង់កុដិឫស្សី ហើយបានប្រគេន វាទៅព្រះសង្ឃ ។ នៅពេលគាត់រអិលធ្លាក់នោះ គាត់បំរុងទទួល បានមាសបីផ្ទាំង ជាផលរបស់កុសលកម្ម ពីអតីតរបស់គាត់។ ដោយសារតែអកុសលកម្ម នាពេលបច្ចុប្បន្នរបស់គាត់ បានទទួល ត្រឹមតែមាសបីដុំប៉ុណ្ណោះ។

លោក ហ្លា មានចិត្តសប្បាយរីករាយឡើងវិញ។ ដោយ គ្មានការឃើញកម្មពីអតីតនោះ យើងមិនគួរបែងចែកទៅលើឫស គល់ត្រឹមតែភស្តុតាងបច្ចុប្បន្នប៉ុណ្ណោះទេ។

*អកុសលកម្ម មិនដែលឱ្យផលល្អទេ វាបានតែ ផលអាក្រក់។ កុសលកម្ម មិនឱ្យផលអាក្រក់ ទេ វារមែងឱ្យផលល្អ។*

*មិនប្រព្រឹត្តអំពើបាបដោយធ្វេសប្រហែស ដោយ និយាយ " វានឹងមិនមករកខ្ញុំ " ឧបមាដូចជាតំណក់ ទឹក សូម្បីមួយតក់ៗគង់ពេញក្នុងពាងបាន ដូច្នេះ សេចក្តីល្ងង់ដោយការប្រមូលផ្តុំបន្តិចៗ គង់ពេញបាន ដោយអំពើបាបខ្លួនឯង។*

*(ធម្មបទ.១២១)*

*មិនប្រព្រឹត្តកុសល ដោយធ្វេសប្រហែស ដោយនិយាយ "វានឹងខិតជិតមករកខ្ញុំ" ឧបមាដូចជាតំណក់ទឹកសូម្បីមួយតំណក់ៗគង់ពេញពាងបាន ដូច្នេះ បណ្ឌិតរមែងសន្សំបន្តិចៗ គង់ពេញដោយអំពើល្អសម្រាប់ខ្លួនឯង។*

*(ធម្មបទ.១២២)*

*ទោះបី អ្នកប្រព្រឹត្តអំពើអាក្រក់ឃើញថា ជាអំពើល្អ ដរាបណាអំពើអាក្រក់មិនទាន់ឱ្យផល ប៉ុន្តែកាលណាវាឱ្យផលពេលនោះ ឃើញថាជាលទ្ធផលអាក្រក់។*

*(ធម្មបទ.១១៩)*

*ដរាបណា បុគ្គលល្អ មើលឃើញអំពើអាក្រក់ដរាបនោះអំពើល្អមិនទាន់ឱ្យផល ប៉ុន្តែកាលណាវាឱ្យផលពេលនោះគេឃើញថាជាលទ្ធផលល្អ។*

*(ធម្មបទ.១២០)*

*ទឹកឃ្មុំផ្អែមឆ្ងាញ់ ដូចជាអំពើអាក្រក់។ គិតដូច្នេះ ល្ងង់មែនទែន វាមិនទាន់ឱ្យផល ប៉ុន្តែកាលណាវាឱ្យផល ពេលនោះវាក្លាយជាសេចក្តីទុក្ខ។*

*(ធម្មបទ.៦៩)*





## ៤. ធ្វើជាអ្នកមាន និងរុងរឿងគ្រប់ៗជាតិ

មនុស្សយើងចង់មានបាន មិនត្រឹមតែក្នុងបច្ចុប្បន្នជាតិប៉ុណ្ណោះទេ គឺចង់មានគ្រប់ៗអនាគតជាតិទៀតផង។ ដូចនេះត្រូវតែស្វែងយល់ឱ្យបានច្បាស់ពីច្បាប់កម្មផល ដើម្បីរៀបចំជោគវាសនាជីវិតរបស់ខ្លួនឱ្យបានល្អ គឺថាត្រូវយករូបមន្តជោគជ័យ ដូចបានរៀបរាប់ពីមុនមកអនុវត្ត " ***កម្ម បញ្ញា វីរិយៈ*** " ប្រតិបត្តិឱ្យបានល្អនូវចំណុចទាំង៣នេះ នោះអ្នកនឹងមិនធ្លាក់ខ្លួនក្រឡើយ។

***កម្ម*** សំដៅដល់ចេតនា ព្រះសម្មាសម្ពុទ្ធបានសម្តែងយ៉ាងច្បាស់ពីកុសលកម្ម និង អកុសលកម្ម។ អំពើទាំងឡាយណាដែលធ្វើទៅនាំឱ្យខាតបង់ប្រយោជន៍អ្នកដទៃផង ប្រយោជន៍របស់ខ្លួនផង និងប្រយោជន៍ទាំងពីរ អំពើនោះមានទោស ជាអកុសលកម្ម ហើយនឹងឱ្យផលជាបាប។ អំពើទាំងឡាយណាដែលធ្វើទៅមិនប៉ះពាល់ ដល់អ្នកដទៃផង ដល់ខ្លួនឯងផង និងដល់អ្នកទាំងពីរផង អំពើនោះមិនមានទោស ជាកុសលកម្មហើយនឹងឱ្យផលជាបុណ្យ។

ជាមូលដ្ឋាន អំពើបាបសំដៅដល់ អកុសលកម្មបថ១០ អាចលាងជម្រះបានដោយ កុសលកម្មបថ ១០ ដូចគ្នា។ ព្រះ

ពុទ្ធោវាទ បានសម្តែងទុក " វៀរចាកការធ្វើបាបទាំងពួង បំពេញបុណ្យឱ្យបានច្រើន និងជម្រះចិត្តឱ្យបានស្អាតបរិសុទ្ធ"ឃ្លាទី១ ឱ្យយើងវៀរចាកនូវ អកុសលកម្មបថ១០ ឃ្លាទី២ ឱ្យយើងប្រតិបត្តិនូវកុសលកម្មបថ១០ ពោលគឺយើងត្រូវរក្សាសីល៥ ឬបញ្ចសីលឱ្យបានខ្ជាប់ខ្ជួនល្អ។ ម្យ៉ាងទៀត ដើម្បីឱ្យបានអានិសង្សច្រើនយើងគួរថ្វាយខ្លួនចំពោះព្រះរតនត្រ័យ រក្សាសីល៥ យកព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃជាទីពឹងទីរលឹក។ បុគ្គលអ្នកបានដល់នូវរតនៈទាំង៣ជាទីពឹងទីរលឹកហើយ រមែងបានអានិសង្សច្រើនមានតេជៈ បានសុខចម្រើន និងមិនទៅកាន់អបាយឡើយ។

អានិសង្ស ដែលកើតពីការគោរពបូជា ចំពោះព្រះរតនត្រ័យ និងរក្សាសីល ៥ អាចញ៉ាំងអកុសលកម្ម ដែលស្លូចស្តើងមិនឱ្យកើតឡើងបាន។ តួយ៉ាងដូចជាឆ្មាំទ្វារម្នាក់ឈ្មោះ ធម្មិលៈ តែងតែស្ទូចត្រីរៀងរាល់ថ្ងៃ ហើយប្រពន្ធរបស់គាត់យកត្រីទាំងនោះទៅដូរយកអង្ករ និងម្ហូប។ នាងដាំបាយ និងយកត្រីដែលសេសសល់ធ្វើម្ហូប រស់នៅដោយជីវភាពយ៉ាងនេះអស់រយៈពេលជាង៥០ឆ្នាំ។

ក្រោយមកពេលវ័យកាន់តែជរា ធម្មិលៈ ក៏បានធ្លាក់ខ្លួនឈឺ។ នៅពេលភិក្ខុសង្ឃនិមន្តមកបិណ្ឌបាតនៅផ្ទះរបស់ពួកគេ





ប្រពន្ធរបស់គាត់ តែងសូមខមាទោសរាល់ពេលព្រោះខ្លួនគ្មានចង្ហាន់ប្រគេន។ ភិក្ខុមួយអង្គបានសូមនាងដើម្បីចូលទៅសួរសុខទុក្ខ ធម្មិលៈ ហើយបានញ៉ាំងឱ្យគាត់រក្សានូវបញ្ចសីល។ ក្រោយពីបានទទួលនូវត្រ័យសរណគមន៍ហើយ ធម្មិលៈ មិនអាចហាមាត់កើតទៀតឡើយ។ ពេលនោះភិក្ខុអង្គនោះ ក៏និមន្តចេញទៅគោចរបិណ្ឌបាតនៅផ្ទះទីទៃទៀត។ នៅពេលដែលលោកនិមន្តទៅដល់វត្តវិញ ស្រាប់តែលេចចេញឧបាសកម្នាក់ មានរូបចែងចាំង ស្ថិតនៅក្នុងទីចំពោះមុខ ហើយក្រាបសំពះលោក។

ពេលនោះលោក ក៏សួរទៅកាន់ឧបាសកនោះថាៈ " តើអ្នកជានរណា?"

"ខ្ញុំព្រះអង្គគឺជា ធម្មិលៈ" ។

"ចុះតើឧបាសកនៅទីណា"?

"ឥឡូវនេះខ្ញុំព្រះអង្គនៅឋានមហារាជិកា។ ខ្ញុំព្រះអង្គសូមអរព្រះគុណលោកម្ចាស់ជាអនេក ដែលបានប្រទាននូវ ត្រ័យសរណគមន៍ ដល់ខ្ញុំព្រះអង្គ ប្រសិនបើ បានទទួលនូវនិច្ចសីលទៀត នោះខ្ញុំព្រះអង្គនឹងបានទៅកើតក្នុងឋានសួគ៌ជាន់លើជាងនេះ" ។

ដូច្នេះ យើងឃើញថា អានិសង្សដែលកើតពីការយកព្រះ

រតនត្រ័យជាទីពឹងមានគុណានុភាពថ្លៃថ្លាណាស់គឺអាចបញ្ចៀស នូវអកុសលកម្ម ដែលគាត់បានសន្សំអស់រយៈពេល៥០ឆ្នាំ ដោយការនេសាទត្រី ហើយនាំឱ្យបានទៅកើតក្នុងសុគតិភព។

## កម្មល្អតែងតែមានអំណាចខ្លាំងជាងកម្មអាក្រក់

ស្តេច មិលិន្ទ បានសាកសួរព្រះនាគសេនថា "បពិត្រព្រះមហាថេរ ដ៏ចម្រើន លោកបានពោលថា អកុសលកម្មដែលកើតពីការសម្លាប់ត្រីនឹងនាំទៅកើតក្នុងអបាយ ប៉ុន្តែឥឡូវនេះធម្មិលៈបានសម្លាប់ត្រីច្រើនណាស់ ហើយមុនគាត់ស្លាប់គ្រាន់តែបានទទួលយកត្រ័យសរណគមន៍ជាទីពឹងប៉ុណ្ណឹងសោះ គាត់បានទៅកាន់សុគតិភព ខ្ញុំព្រះករុណា មិនជឿរឿងនេះទេ។

ចម្លើយរបស់ព្រះអរហន្តនាគសេនត្រង់ចំណុចនេះ គួរឱ្យចាប់អារម្មណ៍ខ្លាំងណាស់។

"បពិត្រមហារាជ ប្រសិនបើ ព្រះអង្គចោលដុំថ្មតូចមួយទៅក្នុងទឹក តើមានអ្វីកើតឡើង?"

"ដុំថ្មនោះនឹងលិចក្នុងទឹក"

"ចុះប្រសិនបើ ព្រះអង្គចោលដុំថ្មមួយដុំធំទៅក្នុងទឹកវិញ តើនឹងមានអ្វីកើតឡើង?"

"ដុំថ្មមួយដុំធំនោះ ក៏នឹងលិចក្នុងទឹកដូចគ្នា"។





"ជាការពិតណាស់ ដោយសារតែថ្មធ្ងន់ជាងទឹក ដូចនេះវាត្រូវតែលិចក្នុងទឹក ទោះបីថ្មនោះធំក៏ដោយ តូចក៏ដោយ។ ដូចគ្នានេះដែរ បាបដែលកើតពីការសម្លាប់សត្វមិនថា តិចក្តីច្រើនក្តីនឹងនាំទៅកើតក្នុងអបាយ ប្រសិនបើ វាមានឱកាសឱ្យផលខណៈពេលរៀបស្លាប់។ ឧទាហរណ៍ថាព្រះអង្គមានសំពៅយ៉ាងធំមួយ ហើយព្រះអង្គដាក់ថ្ម៥រទេះនៅក្នុងសំពៅនោះ តើសំពៅនោះនឹងលិចទេ?"

"វានឹងមិនលិចទេ"។

"បើវាមិនលិចទេ តើវាអាចទៅដល់គោលដៅឬទេ?"

"ប្រាកដជានឹងទៅដល់"។

"ដូចគ្នានេះដែរ កុសលកម្មដែលកើតពីការគោរព ចំពោះគុណព្រះរតនត្រ័យ គឺមានអានុភាពណាស់ ប្រៀបដូចជាសំពៅដ៏រឹងមាំយ៉ាងនោះដែរ។ ឯ អកុសលកម្មនៃការសម្លាប់ត្រី ទុកដូចជាដុំថ្មមួយដុំតូច ។ ប្រៀបដូចសំពៅដែលអាចផ្ទុកនូវទម្ងន់នៃថ្មយ៉ាងច្រើន ហើយធ្វើដំណើរទៅដល់គោលដៅ យ៉ាងណាមិញ កុសលកម្ម កើតពីការគោរពចំពោះគុណនៃព្រះរតនត្រ័យ ក៏អាចដឹកនាំសត្វទៅដល់គោលដៅ ពោលគឺសុគតិភពយ៉ាងនោះដែរ"។

ព្រះរាជា ក៏បានពោលសរសើរថា នេះពិតជាសមហេតុផលណាស់ ។

## ចូរញ៉ាំង កម្ម បញ្ញា វិរិយៈ ឱ្យមានតុល្យភាព

ដើម្បីញ៉ាំង **កម្ម បញ្ញា វិរិយៈ** ឱ្យមានតុល្យភាព យើងត្រូវតែស្គាល់ឱ្យបានច្បាស់នូវ(តេជានុភាពព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃតែម្យ៉ាង)តាំងពីមានព្រះរតនត្រ័យ មានការគោរពដ៏បរិសុទ្ធវិសេសនោះ កុសលកម្ម បានរីកចម្រើនដោយការគោរពថ្វាយបង្គំ ហើយយកតេជានុភាពនៃត្រៃសរណគមន៍ ជាទីពឹងជាទីរលឹក។ យើងគួរតែនិទានរឿងប្រាប់ក្មេងៗ ដោយពិពណ៌នាអំពីផលប្រយោជន៍នៃត្រៃសរណគមន៍ ព្រមទាំងអានិសង្ស ដ៏វិសេសបំផុត របស់ព្រះត្រៃរតន៍ ដូច្នេះពួកគេអាចគោរពប្រតិបត្តិ ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ប្រកបដោយបញ្ញា។ ម្តងទៀត ដើម្បីអាចឱ្យក្មេងធ្វើការគោរពប្រតិបត្តិព្រះត្រៃរតន៍ ប្រកបដោយសេចក្តីព្យាយាមបំផុត ពួកគេគួរត្រូវបានបង្រៀនឱ្យនឹករលឹក គុណព្រះពុទ្ធ ដូចជា អរហំ ម្តងហើយម្តងទៀត នេះហៅថា ពុទ្ធានុស្សតិ ឬការរលឹកគុណព្រះពុទ្ធ។ ពួកគេគួរតែរៀនប្រតិបត្តិឱ្យបានសមរម្យ វាផ្តល់ប្រយោជន៍កុសលកម្មដ៏ធំ។ ក្នុងពុទ្ធសម័យ ក្មេងប្រុសម្នាក់អាចការពារខ្លួនឯងពីយក្សស៊ី ដោយគ្រាន់តែសូត្រថា នមោ ពុទ្ធស្ស (ខ្ញុំសូមដល់





ព្រះពុទ្ធជាទីពឹង)។

នៅពេលពួកគេ មានវ័យល្មមចូលសាលាមត្តេយ្យ ពួកគេគួរបង្រៀនឱ្យស្រឡាញ់សត្វ ហើយដើម្បីឱ្យចម្រើននូវមេត្តាចំពោះសត្វទាំងអស់។ បន្ទាប់មក ពួកគេគួរបង្រៀនឱ្យកាន់សីលប្រាំ។ វាអាចបញ្ចៀស ការសម្លាប់ ការលួច ពោលពាក្យកុហក ប្រព្រឹត្តខុសក្នុងកាម ផឹកទឹកស្រវឹង នៅខណៈ អកុសលកម្ម ទាំងនេះបានប្រឆាំងមេត្តា និងសន្តិសុខសង្គម។ ពួកគេគួរត្រូវបាននិទានរឿងល្អៗ ដោយពិពណ៌នាអំពីប្រយោជន៍នៃសីល ដែលមានគុណប្រយោជន៍សម្រាប់មនុស្ស។ ដូច្នេះ បើមនុស្សអាចរក្សាត្រៃសរណគមន៍ និងនិច្ចសីលយ៉ាងខ្ជាប់ខ្ជួនបំផុតនៅក្នុងជីវិត គេមិនអាចក្លាយជាអ្នកក្រ។ គេនឹងក្លាយជាអ្នកមាន និងបានសម្រេចជីវិតជោគជ័យប្រកបដោយសុភមង្គលនៅក្នុងជាតិជាអនាគត។

ក្នុងចំណោម " **កម្ម បញ្ញា វិរិយៈ** " បញ្ញា គឺជាមេដឹកនាំ។ បញ្ញាមានមូលដ្ឋានដ៏សំខាន់គឺពុទ្ធិកម្ម និងផលរបស់កម្ម។ ដូច្នេះ យើងត្រូវយល់ឱ្យបានច្បាស់នូវពុទ្ធិកម្ម ដើម្បីធ្វើឱ្យមាន សម្មាទិដ្ឋិ (ការយល់ត្រូវ) ។ ពុទ្ធិ នេះ នឹងបង្កើនកុសលកម្ម ហើយបញ្ជូនសព្វសត្វទៅឋានសួគ៌ក្រោយពេលស្លាប់។

នៅពេលក្មេងមានវ័យវ័ឈ្លនាការល្មម ដើម្បីចូលសាលា

យើងត្រូវតែព្យាយាមទទួលបាននូវការអប់រំទំនើប។ ការអនុលោមតាមការប្រៀនប្រដៅរបស់ព្រះពុទ្ធ។

*ពាហុសច្ចញ្ច ច* -ជាពាហុសូត្របានស្តាប់ បាន រៀន ចេះច្រើន

*សិប្បញ្ច* -ការប៉ិនប្រសប់ក្នុងបច្ចេកវិទ្យា និងសិប្បកម្ម

*វិនយោ ច សុសិក្ខិតោ* -វិន័យដែលបុគ្គលសិក្សាដោយប្រពៃ

*សុភាសិតា ច យា វាចា* -វាចាដែលបុគ្គលពោលដោយប្រពៃប្រកបដោយប្រយោជន៍។

ទាំងនេះជាមង្គលដ៏ឧត្តម។ ដូច្នេះ បុគ្គលណាមួយ មានវិជ្ជាជីវៈ និងបំណិនប្រសប់ ដូចលោក បៀល ហ្គេត(Bill Gate)។ បុគ្គលនោះ អាចជាអ្នកមានភ្លាមៗ និងចម្រើនរុងរឿង។

ក្រោយពីការទទួលបានពុទ្ធិល្អៗ និងការងារល្អៗ បុគ្គលនោះគួរតែព្យាយាមសម្រេចឱ្យបាននូវមង្គលដ៏ឧត្តម។

*មាតាបិតុ ឧបដ្ឋានំ* - កិរិយាបម្រើដោយយកចិត្តទុកដាក់ចំពោះមាតាបិតា





*បុត្តទារស្ស សង្គហោ* - ការសង្គ្រោះចំពោះបុត្រ និង ភរិយា

*អនាកុលា ច កម្មន្តា* - ការងារមិនច្របូកច្របល់

*ទានញ្ច* - ការឱ្យទាន

*ធម្មចរិយា ច* - ការប្រព្រឹត្តនូវធម៌ ដែលវៀរចាកនូវអកុសលកម្មបថ១០

*ញាតកានញ្ច សង្គហោ* - ការសង្គ្រោះញាតិទាំងឡាយ

*អនវជ្ជានិ កម្មានិ* -ការរក្សានូវសិក្ខាបទ ឧបោសថ និង ការធ្វើកិច្ចការងារសង្គមទាំងអស់

ទាំងនេះជាមង្គលដ៏ឧត្តម។ ដើម្បីទទួលបាននូវមង្គលដ៏ឧត្តម គឺប្រសើរថ្លៃថ្លាដ៏ឧត្តុង្គឧត្តម។ មង្គលទាំងអស់នេះ នឹងនាំទៅរកជីវិតដ៏មានសុភមង្គលជោគជ័យ។

*កាលេន ធម្មស្សវនំ* -បុគ្គលបានស្តាប់ បានរៀននូវធម៌ ឧទាហរណ៍ការប្រៀនប្រដៅរបស់ព្រះពុទ្ធតាមកាល

*កាលេន ធម្មសាកច្ឆា* - កិរិយាសន្ទនា សាកសួរធម៌តាមកាល

*តបោ ច* -សេចក្តីព្យាយាមដុតនូវបាបធម៌ គឺញ៉ាំងកិលេស ដែលនៅក្នុងខន្ធសន្តាន ឱ្យក្តៅរីងស្ងួតអស់

*ព្រហ្ម ចរិយញ្ច* -កិរិយាប្រព្រឹត្តនូវធម៌ដ៏ឧត្តម ដើម្បីចម្រើននូវ សីល សមាធិ បញ្ញា

*អរិយ សច្ចាន ទស្សនំ* -កិរិយាឃើញនូវអរិយសច្ចៈ

*និព្វាន សច្ឆិកិរិយា ច* -កិរិយាធ្វើនូវព្រះនិព្វានឱ្យជាក់ច្បាស់បានដោយបញ្ញា។

ទាំងនេះជាមង្គលដ៏ឧត្តម អាចសម្រេចក្នុងជីវិតបច្ចុប្បន្ន។ ព្រះពុទ្ធសាសនា នៅតែកំពុងតែរីកចម្រើនរុងរឿង ក្នុងប្រទេសព្រះពុទ្ធសាសនាថេរវាទ ហើយមានគ្រូអាចារ្យ មានសមត្ថភាពដែលអាចបង្រៀនយោគី ដើម្បីឱ្យចម្រើនឡើងនូវបញ្ញា ដ៏ឧត្តមនោះហៅថា "**មគ្គបញ្ញា**" ។

ដូច្នេះ បុគ្គលណាមួយសម្រេចបាននូវបញ្ញានេះ បុគ្គលនោះនឹងជាអរិយបុគ្គល ហើយអាចសប្បាយរីកខិតជិតចូលទៅក្នុងនិព្វានសុខជានិរន្តរ៍។ មនុស្សទាំងអស់ អាចរស់នៅយ៉ាងសប្បាយពេញលេញជាមួយគ្រួសារ ដោយជឿជាក់ថា នឹងមិនកើតក្នុងអបាយភូមិ។ មនុស្សទាំងអស់ ត្រូវបានខិតជិតចូលទៅ





កាន់ព្រះនិព្វាន និងមិនយូរមិនឆាប់ សត្វលោក នឹងចូលទៅដល់ទីនោះ។

**៥. ចូរយើងនាំគ្នាហែលឆ្លងសង្សារវដ្តរួមគ្នារហូតដល់ត្រើយសុវត្ថិភាព**

រឿងនេះ យើងអាចចាត់ចែងដោគវាសនារបស់យើង ដើម្បីឱ្យសម្រេចនូវជាតិថ្មីផ្សេងទៀត យើងទំនងជាបង្កើតឱ្យប្រើថាមពលកម្ម ដែលវាមានថាមពលខ្លាំងជាងកម្លាំងអាតូមិច គឺជាពត៌មានដ៏រីករាយបំផុត។ ប្រសិនបើ គូស្នេហ៍ប្រកបដោយការសម្រេចចិត្តពិតប្រាកដ និងមានបំណងប្រាថ្នាដូចគ្នា ប្រព្រឹត្តយ៉ាងសប្បាយចិត្តនូវកុសលកម្មរួមគ្នា ហើយមានបំណងប្រាថ្នារួមគ្នាជារឿយៗ ដោយឆ្លងកាត់សង្សារវដ្ត ពួកគេអាចមានជីវិតរួមគ្នាពីជីវិតមួយទៅជីវិតមួយ នៅខណៈពេល ពួកគេអាចកំពុងតស៊ូ ដើម្បីទទួលបាននូវការរួចចាកពីសេចក្តីទុក្ខទាំងអស់។

សុមេធ តាបស និងនាងសុមិត្តា ជាស្ត្រីក្រមុំក្នុងត្រកូលព្រាហ្មណ៍ ជាឧទាហរណ៍ ដោយគ្រាន់តែប្រព្រឹត្តនូវកុសលកម្ម ដែលបានថ្វាយផ្កាឈូក និង ថ្វាយបង្គំព្រះពុទ្ធ **ទីបង្ករ** រួមគ្នា និងប្រាថ្នារួមគ្នា ដោយឆ្លងកាត់រយៈពេលយ៉ាងយូរអស់បួនអសង្ខេយ្យ និងកម្រៃមួយសែនកប្ប ក្នុងវាលវដ្តសង្សារ ដែលជាពេលដ៏ខ្លីបំផុត សម្រាប់ព្រះពោធិសត្វ ដើម្បីបំពេញបារមី ហើយព្យាយាម

បន្តជាប់រហូត ដើម្បីបានត្រាស់ជាព្រះពុទ្ធ។ ពួកគេជាប្ដីប្រពន្ធក្នុងជាតិជាច្រើន រហូតចុងបញ្ចប់នៃជាតិ នៅពេលដែលពួកគេគឺជាព្រះអង្គម្ចាស់ សិទ្ធត្ថ និងព្រះនាងយសោធរា ដែលបានអភិសេក ប្រសូតបុត្រមួយព្រះអង្គ គឺ រាហុលកុមារ។ ពួកគេទាំងអស់គ្នាបានសោយនូវសេចក្ដីសុខក្នុងព្រះនិព្វាន។

ដោយមានជំនួយអំពីការតាក់តែងកម្ម យើងអាចក្លាយជាអ្នកមានដូច សេដ្ឋីជោតិកៈ ឬយើងអាចសប្បាយរីករាយបរិបូរណ៍ដោយលាភសក្ការៈ ដូចជាព្រះថេរៈ សីវលី ឬយើងអាចក្លាយជាមនុស្សមានគំនិត ប្រាជ្ញាខ្លាំងក្លា ដូចជាស្ដេច មិលិន្ទ និងព្រះថេរ នាគសេន ឬក៏បុគ្គលណាក្លាយជាមនុស្ស មានសម្រស់ស្រស់ស្អាតជាច់គេដូចជានាងឱមាទន្តី ឬ បុគ្គលណាមួយបានជាស្ត្រី ក្រមុំប្រកបដោយសម្ផស្សដ៏ស្រស់ត្រកាលដាច់គេ ដូចនាង បញ្ចបាបា។

យើងគួរតែស្វាធ្យាយ និងពិចារណានូវ អភិណ្ហសូត្រ ឱ្យបានជារឿយៗរៀងរាល់ថ្ងៃ ដើម្បីដាស់តឿនសតិបញ្ញារបស់យើង កុំឱ្យភ្លើតភ្លើនៈ

អហំ = រីខ្ញុំ
កម្មស្សកា =មានកម្មជារបស់ខ្លួន
កម្មទាយាទោ =មានកម្មជាទាយាទ





កម្មយោនិ =មានកម្មជាកំណើត
កម្មពន្ធូ = មានកម្មជាញាតិ
កម្មប្បដិស្សរណោ = មានកម្មជាទីពឹង
កល្យាណំ វា = បុណ្យក្ដី
បាបកំ វា =បាបក្ដី
យំ កម្មំ ករិស្សាមិ =កម្មណាមួយខ្ញុំដែលធ្វើ
តស្ស កម្មស្ស ករិស្សាមិ= ខ្ញុំនឹងទទួលនូវ ផលនៃកម្មនោះ ពុំខានឡើយ។

ការសិក្សាស្វែងយល់ពីទ្រឹស្ដីកម្មផល ទុកដូចជាការបំភ្លឺផ្លូវ ដើម្បីដើរតាមមាគ៌ាឆ្ពោះទៅរកសេចក្ដីសុខសុភមង្គលក្នុងជីវិត។ កាលណាគេយល់ច្បាស់ពីច្បាប់កម្មផលហើយ រមែងប្រព្រឹត្តតែកម្មណា ដែលមានប្រយោជន៍ជាហេតុបានសម្រេចនូវសម្បត្តិទាំងពួងដោយវៀរចាកនូវអំពើអាក្រក់គ្រប់យ៉ាង ព្យាយាមសាងតែអំពើល្អ និងដុះខាត់សម្អាតចិត្តរបស់ខ្លួនឱ្យបរិសុទ្ធផូរផង់ ទីបំផុតនឹងបានសម្រេចមគ្គផលជាពុំខាន។

28-9-2006 Dr.Mehm Tin Mon

## ជីវប្រវត្តិសង្ខេបរបស់អ្នកនិពន្ធ

បណ្ឌិត ម៉ែម ទីនមន ( Dr. Mehm Tin Mon )

បរិញ្ញាបត្រ វិទ្យាសាស្ត្រអប់រំ សាកលវិទ្យាល័យ យ៉ាំងហ្គុន

អនុបណ្ឌិត វិទ្យាសាស្ត្រអប់រំ និងបញ្ចប់ថ្នាក់បណ្ឌិត នៅសហរដ្ឋអាមេរិក

មានងារជា៖ មហាសទ្ធម្មជោតិកធជៈ

ទីប្រឹក្សា ក្រសួងធម្មការ និងសាសនា,

សាស្ត្រាចារ្យ សាកលវិទ្យាល័យ ពុទ្ធសាសនទូតថេរវាទ អន្តរជាតិ ទីក្រុងយ៉ាំងហ្គុន ប្រទេសមីយ៉ាន់ម៉ា ។

បណ្ឌិត **ម៉ែម ទីន មន** គឺជាគីមីវិទូផង និងជាទស្សនវិទូផ្នែកព្រះពុទ្ធសាសនាផង។ លោកបានយកទ្រឹស្តីវិទ្យាសាស្ត្របូកបញ្ចូលជាមួយទ្រឹស្តីព្រះពុទ្ធសាសនាបង្ហាត់បង្រៀននៅសាកល-វិទ្យាល័យរបស់លោកអស់ រយៈពេលជាង៣៧ឆ្នាំកន្លងមកនេះ។ ក្រោយពីចូលនិវត្តន៍ពីសាស្ត្រាចារ្យ គីមីវិទ្យា ហើយលោកបានក្លាយជាទីប្រឹក្សានៃក្រសួងធម្មការ និងសាសនា និងជាសាស្ត្រា-ចារ្យ នៅសាកលវិទ្យាល័យ ពុទ្ធសាសនទូតថេរវាទអន្តរជាតិ ក្នុង





ទីក្រុងយ៉ាំងហ្គុន។ លោកបានបម្រើការងារទាំងពីរនេះ នៅក្នុងប្រទេស របស់លោកចាប់តាំងពីឆ្នាំ ១៩៩៣មកម្ល៉េះ។

គាត់ខិតខំបង្ហាត់បង្រៀនព្រះអភិធម្ម សមាធិកម្មដ្ឋាន និងបង្រៀនព្រះធម៌ តាមកន្លែងសាធារណៈជាច្រើនកន្លែង ទាំងក្នុងប្រទេស និងក្រៅប្រទេសអស់រយៈពេលជាច្រើនឆ្នាំ។ គាត់ត្រូវបានរដ្ឋាភិបាលនៃប្រទេស មីយ៉ាន់ម៉ា ប្រគល់ងារជា **មហាសទ្ធម្មជោតិកធជៈ** ក្នុងឆ្នាំ២០០៣ ចំពោះស្នាដៃ និងការផ្សព្វ-ផ្សាយព្រះពុទ្ធសាសនានៅក្នុងប្រទេស និងក្រៅ ប្រទេស ។

គាត់បានសរសេរសៀវភៅចំនួន២០ក្បាល ទាក់ទងនឹងការអប់រំ ៥០ក្បាលទាក់ទងនឹងព្រះពុទ្ធសាសនា និងជាង២០០ អត្ថបទចុះផ្សាយ តាមទស្សនាវដ្តី និងកាសែត។ ការបង្រៀនរបស់គាត់ច្បាស់លាស់ សាមញ្ញ និងគួរជាទីពេញចិត្តដែលមនុស្សជាច្រើន តែងតែពោលសរសើរជាប់មិនដាច់។

បណ្ឌិត **ម៉ែម ទីនមន** ក៏ជាប្រធាននៃ **មជ្ឈមណ្ឌលផាអោក** ដែលជាកន្លែងបង្រៀន និងប្រតិបត្តិសមថៈ និងវិបស្សនាដ៏ល្បីល្បាញមួយនៅក្នុងរដ្ឋមន ប្រទេសមីយ៉ាន់ម៉ាផងដែរ ៕